### សៀវភៅផែនទី ស្តីអំពី

# ការទូតសភា

## ភាគទី ១៖ ការទូតសភាសភាបែបបុរេសកម្ម
## ភាគទី ២៖ ការទូតសភាក្នុងបរិបទអាស៊ាន



ប.ស.ក P.I.C Parliamentary Institute of Cambodia

វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

PCAsia
PARLIAMENTARY CENTRE OF ASIA
Strengthening Parliamentary Capacity

# សៀវភៅផែនទី ស្តីអំពី

# ការទូតសភា

**ភាគទី ១៖** ការទូតសភាសភាបែបបុរេសកម្ម

**ភាគទី ២៖** ការទូតសភាក្នុងបរិបទអាស៊ាន

# សេចក្តីផ្តើមអំពីសៀវភៅផែនទីស្តីអំពីការទូតសភា

បន្ទាប់ពីការបោះពុម្ពផ្សាយសៀវភៅផែនទីភូមិសាស្ត្រនយោបាយរបស់កម្ពុជានៅក្នុងអាស៊ី និងពិភពលោកក្នុងឆ្នាំ២០១៧ សៀវភៅផែនទីស្តីពី ការទូតសភា (ជាសៀវភៅផែនទីចុងក្រោយបំផុតនៅក្នុងភាគនៃសៀវភៅផែនទីរបស់វិទ្យាស្ថានសភាកម្ពុជា) ត្រូវធ្វើការផ្តល់ជូនជាភាសាអង់គ្លេស ឯការបកប្រែជាភាសាខ្មែរក្រៅផ្លូវការមានជាទម្រង់ឯកសារអេឡិចត្រូនិច ដែលអាចចូលអានបានតាមរយៈគេហទំព័ររបស់វិទ្យាស្ថានសភាកម្ពុជា។ ការរៀបចំសៀវភៅផែនទីថ្មីចុងក្រោយបំផុតនេះ គឺព្យាយាមបង្ហាញពីការកើនឡើងនូវតួនាទីដ៏មានសារៈសំខាន់របស់សភានៅក្នុងការទូតអន្តរជាតិ ដោយចែករំលែកនូវទស្សនៈនានា លើបញ្ហាដែលប៉ះពាល់ដល់ប្រជាពលរដ្ឋនៅក្នុងតំបន់អាស៊ី និងអឺរ៉ុប។ សៀវភៅផែនទីចុងក្រោយនេះផ្តោតជាក់លាក់ទៅលើយន្តការ និងឧបករណ៍ដែលការទូតសភាប្រើ ដើម្បីដោះស្រាយបញ្ហាប្រឈមរួម ជាពិសេសនៅក្នុងបរិបទអាស៊ាន។

ការទូតសភាមិនមែនព្យាយាមប្រើដើម្បីជំនួសការទូតនៃអង្គនីតិប្រតិបត្តិទេ។ ផ្ទុយមកវិញ ការទូតសភាជួយបំពេញបន្ថែមនូវអធិបតេយ្យភាពការទូតដល់អង្គនីតិប្រតិបត្តិ។ ការទូតសភាមានប្រយោជន៍ក្នុងការបន្ថែមនូវសំឡេងរបស់អង្គនីតិបញ្ញត្តិ (ជាស្ថាប័នតំណាងរបស់ប្រជាពលរដ្ឋ) ដែលអាចមានឥទ្ធិពលដល់ការធ្វើសេចក្តីសម្រេចចិត្តដែលធ្វើឡើងដោយស្ថាប័នថ្នាក់តំបន់ និងស្ថាប័នពហុភាគី ក៏ដូចជាអាចមានឥទ្ធិពលដល់ដំណើរការអនុវត្តនូវសេចក្តីសម្រេចចិត្តទាំងនោះដែរ។

សៀវភៅផែនទីនេះមានគោលដៅចម្បងចំនួនបី។ គោលដៅទីមួយ គឺផ្តល់នូវឧបករណ៍គរុកោសល្យសម្រាប់ប្រើប្រាស់ក្នុងកម្មវិធីបណ្តុះបណ្តាលថ្នាក់តំបន់ស្តីពី ការទូតសភារបស់វិទ្យាស្ថានសភាកម្ពុជា ដែលបានចាប់ផ្តើមនៅក្នុងឆ្នាំ២០១៩ ដោយត្រូវបានផ្តល់តាមរយៈអនឡាញនៅក្នុងឆ្នាំ២០២០ និងសម្រាប់មជ្ឈមណ្ឌលសភាអាស៊ី (Parliamentary Center of Asia) ដែលនឹងបង្កើតឡើង ចាប់ពីឆ្នាំ២០២១នេះទៅ។ គោលដៅបន្ទាប់ គឺសម្រាប់ប្រើប្រាស់ជាឯកសារយោងដែលផ្តល់នូវព័ត៌មានអំពីបញ្ហាឆ្លងប្រទេសដល់សមាជិក សមាជិកាសភា និងមន្ត្រីសភា ជាពិសេសសភាក្នុងតំបន់អាស៊ាន ដោយផ្តល់នូវទស្សនៈនានាដែលអាចយកមកពិចារណានៅក្នុងដំណើរការធ្វើច្បាប់ និងពីរបៀបដែលការទូតសភាអាចមានឥទ្ធិពលដល់រដ្ឋាភិបាលនៃប្រទេសរៀងៗខ្លួនប្រកបដោយប្រសិទ្ធិភាព។ សៀវភៅផែនទីនេះក៏ជួយដល់អ្នកអានក្នុងការស្វែងយល់ពីអភិក្រមនានាសម្រាប់ពហុភាគីនិយម ដែលកំពុងត្រូវការចាំបាច់សម្រាប់ពេលបច្ចុប្បន្ននេះ នៅក្នុងបរិបទនៃវិបត្តិជំងឺ COVID-19។ ចុងក្រោយ សៀវភៅផែនទីនេះក៏ផ្តល់នូវទស្សនៈនានាស្តីពី ក្របខ័ណ្ឌនិងសកម្មភាពនៃសភាថ្នាក់ជាតិ និងថ្នាក់តំបន់ក្នុងការដោះស្រាយបញ្ហាឆ្លងប្រទេស និងការធ្វើអន្តរទំនាក់ទំនងជាមួយប្រទេសដទៃទៀត ក្នុងស្មារតីកិច្ចសហប្រតិបត្តិការ ពីព្រោះសភាទាំងនោះព្យាយាមធ្វើការរួមគ្នាដើម្បីឈានដល់ការទទួលបាននូវដំណោះស្រាយរួម។

ដើម្បីសម្រេចបាននូវគោលដៅទាំងនេះ សៀវភៅផែនទីនេះ ត្រូវបានរៀបចំដោយបែងចែកជាពីរផ្នែក។ ផ្នែកទីមួយ នៃសៀវភៅផែនទីនេះផ្តល់នូវគំនិត និងទស្សនៈជាច្រើនពីអ្នកជំនាញ និងប្រជាពលរដ្ឋពីតំបន់អាស៊ី និងអឺរ៉ុប ទៅលើបញ្ហាប្រឈមរួមរបស់ពិភពលោក៖ ការប្រែប្រួលអាកាសធាតុនិងបរិស្ថាន គ្រោះមហន្តរាយធម្មជាតិនិងសន្តិសុខស្បៀង-ថាមពល-ទឹក យេនឌ័រ សន្តិភាពនិងសន្តិសុខ សេដ្ឋកិច្ចនិងពាណិជ្ជកម្ម ដោយផ្អែកលើច្បាប់ ការរីកចម្រើននិងការអភិវឌ្ឍប្រកបដោយចីរភាពរួម។ ផ្នែកទីពីរ គឺផ្តោតលើបរិបទអាស៊ាន និងតួនាទីរបស់សភា និងសមាគមថ្នាក់តំបន់ (ដូចជា AIPA) ក្នុងការដោះស្រាយបញ្ហាឆ្លងប្រទេសនៅកម្រិតថ្នាក់ជាតិ និងថ្នាក់តំបន់។

សៀវភៅផែនទីនេះបង្ហាញពីបញ្ហានានា ដោយឈរលើមូលដ្ឋានទស្សនៈរបស់តំបន់អឺរ៉ុប អាស៊ី និងអាស៊ាន ដែលអាចឲ្យយើងធ្វើការប្រៀបធៀបរវាងអភិក្រមរបស់អឺរ៉ុប (ស្ថាប័នប្រកបដោយបរិយាបន្ន ដែលចងដោយការប្តេជ្ញាចិត្ត) និងអភិក្រមរបស់អាស៊ាន (មានលក្ខណៈមិនផ្លូវការ និងផ្អែកលើវេទិកា និងការបង្កើតក្រុមការងារចំពោះកិច្ចដើម្បីការស្វែងរកការមូលមតិគ្នាទាំងស្រុង)។ ភាពខុសគ្នាទាំងនេះត្រូវតែគិតគូរពិចារណាព្រោះអាស៊ាន និងអឺរ៉ុបកំពុងតែស្វះស្វែងបង្កើននូវកិច្ចសហប្រតិបត្តិការ តាមរយៈការផ្សារភ្ជាប់វប្បធម៌ និងសេដ្ឋកិច្ច ដែលកំពុងមានស្រាប់។

លើសពីភាពខុសគ្នានៃអភិក្រមខាងលើគឺថា វិបត្តិបច្ចុប្បន្ននៃពហុភាគីនិយមជាការដាស់តឿនដល់តំបន់ទាំងពីរ។ នៅទីនេះការទូតសភាអាចដើរតួនាទីសំខាន់ដោយផ្តល់នូវមធ្យោបាយបន្ថែម ដើម្បីប្រើប្រាស់យន្តការពហុភាគីនានា សម្រាប់ដោះស្រាយបញ្ហាឆ្លងប្រទេសក្នុងករណីដែលអ្នកដឹកនាំជ្រើសរើសយកមធ្យោបាយនេះមកប្រើ។

វិធានការរួមគឺជាតម្រូវការចាំបាច់ ដោយសារកិច្ចខិតខំប្រឹងប្រែងពិតជាសំខាន់ ដើម្បីលើកកម្ពស់ បន្សាំ និងអនុម័តនូវវិធានការថ្មីៗនៅពេលចាំបាច់។ សំឡេងរបស់ពលរដ្ឋដែលត្រូវបានបង្ហាញតាមរយៈសភារបស់ពួកគេ គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការឈានដល់ការធ្វើសេចក្តីសម្រេចចិត្តដែលត្រឹមត្រូវ។




ប្រទេសដែលចូលរួមក្នុងកិច្ចប្រជុំអាស៊ី-អឺរ៉ុបលើកទី ១២ (ASEM-12) និងកិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុបលើកទី ១០ (ASEP-10) នៅខែតុលា ឆ្នាំ២០១៨

# ភាគទី ១

## ការទូតសភាសភាបែបបុរេសកម្ម

ជំពូកទី
០១
ទំ. ១៧ - ទំ. ៤៧

### តួនាទីសភាក្នុងការតទល់នឹងបញ្ហាប្រឈមឆ្លងដែន៖ ទស្សនទានមួយបែបអឺរ៉ុប


ទំ. ១៨ | ១.១ ការកសាងពហុភាគីនិយមថ្មីនៅអឺរ៉ុប និងអាស៊ី
ទំ. ២១ | ១.២ ការពង្រឹងភាពជាដៃគូសភាសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព
ទំ. ២៤ | ១.៣ តួនាទីសភាក្នុងការតទល់នឹងបញ្ហាប្រឈមឆ្លងដែន៖ ទស្សនទានមួយបែបអឺរ៉ុប
ទំ. ២៨ | ១.៤ ផលប៉ះពាល់នៃកូវីដ-១៩ និងការឆ្លើយតប
ទំ. ២៨ | ១.៤.១ ការឆ្លើយតបរបស់ឥណ្ឌូណេស៊ីទៅនឹងវិបត្តិកូវីដ-១៩
ទំ. ៣១ | ១.៤.២ ផលប៉ះពាល់នៃកូវីដ-១៩ លើភាពក្រីក្រនៅកម្ពុជា
ទំ. ៣៥ | ១.៤.៣ សភានៅអឺរ៉ុបប្រឈមនឹងវិបត្តិកូវីដ-១៩
ទំ. ៣៩ | ១.៥ តើសភាអាចមានភាពនិម្មិតបានក្នុងកម្រិតណា?


ជំពូកទី
០២
ទំ. ៤៩ - ទំ. ៦៧

### បុរេសកម្មសភា ដើម្បីសន្តិភាព សន្តិសុខ និងវិបុលភាពរួម៖ ទស្សនាទាននៃអាស៊ី


ទំ. ៥០ | ២.១ វិធីបែបអាស៊ានឆ្ពោះទៅរកពហុភាគីនិយម ដើម្បីសន្តិភាព សន្តិសុខ និងវិបុលភាព
ទំ. ៥៤ | ២.២ បុរេសកម្មសភា ដើម្បីសន្តិភាព សន្តិសុខ និងវិបុលភាពរួម៖ ទស្សនាទាននៃអាស៊ី
ទំ. ៥៨ | ២.៣ បញ្ហាប្រឈមសន្តិសុខនៅអាស៊ី៖ ទស្សនាទាននៃអឺរ៉ុប
ទំ. ៦២ | ២.៤ ការត្រួតពិនិត្យរបស់សភាទៅលើការប្រើប្រាស់កម្លាំង និងកម្លាំងប្រដាប់អាវុធ

# តារាងមាតិកា


សេចក្តីផ្តើម ទំ. ១០
សេចក្តីសង្ខេបនៃបទវិភាគ ទំ. ១២


ជំពូកទី ០៣ ទំ. ៦៩ - ទំ. ៨៣

## ការលើកកម្ពស់ប្រព័ន្ធពាណិជ្ជកម្មពហុភាគី អន្តរជាតិអាស្រ័យច្បាប់ដើម្បីការអភិវឌ្ឍដោយបរិយាបន្ន និងចីរភាព


ទំ. ៧០ | ៣.១ កិច្ចព្រមព្រៀងពាណិជ្ជកម្មពហុភាគីជួបប្រទះបញ្ហាប្រឈម
ទំ. ៧៣ | ៣.២ ប្រព័ន្ធពាណិជ្ជកម្មពហុភាគី៖ ទស្សនៈទានមួយបែបអាស៊ី
ទំ. ៧៧ | ៣.៣ ប្រព័ន្ធពាណិជ្ជកម្មពហុភាគី៖ ទស្សវិស័យមួយបែបអឺរ៉ុប


### បញ្ជីផែនទី


ទំ. ៧៦ | ផែនទី ១៖ ពាណិជ្ជកម្មអឺរ៉ុប-អាស៊ី


ជំពូកទី ០៤ ទំ. ៨៥ - ទំ. ១១៩

## ការដោះស្រាយទំនាក់ទំនង រវាងសន្តិសុខទឹក ស្បៀង និងថាមពល ក្រោមលក្ខណ្ឌនៃការប្រែប្រួលអាកាសធាតុ


ទំ. ៨៦ | ៤.១ សន្តិសុខស្បៀង និងការប្រែប្រួលអាកាសធាតុ៖ ទស្សនៈមួយពីប្រទេសសិង្ហបុរី
ទំ. ៩០ | ៤.២ បណ្តាទីក្រុងនៅអាស៊ានប្រឈមនឹងហានិភ័យបរិស្ថាននិងការប្រែប្រួលអាកាសធាតុ
ទំ. ៩៦ | ៤.៣ ការប្រែប្រួលអាកាសធាតុ និងការការពារតំបន់ព្រៃធម្មជាតិ៖ ទស្សនៈពីខាងតំបន់អាស៊ីអាគ្នេយ៍
ទំ. ១០០ | ៤.៤ ប្រសិទ្ធភាពនៃច្បាប់ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមដែលបណ្តាលមកពីបម្រែបម្រួលអាកាសធាតុ
ទំ. ១០៧ | ៤.៥ សន្តិសុខថាមពលអឺរ៉ុប៖ បញ្ហាប្រឈមក្នុងការធ្វើពិពិធកម្ម និងការបំបែកកាបូនឌីអុកស៊ីតចេញពីរបាយឥន្ធនៈ
ទំ. ១១២ | ៤.៦ សហភាពអឺរ៉ុប និងបញ្ហាប្រឈមទៅនឹងការប្រែប្រួលអាកាសធាតុ៖ អំណាចកំពូលក្នុងការចេញបទបញ្ញត្តិ


### បញ្ជីផែនទី


ទំ. ៩១ | ផែនទី ២៖ ទីក្រុង និងទីក្រុងធំៗនៅអាស៊ីអាគ្នេយ៍
ទំ. ១០៣ | ផែនទី ៣៖ ផូស៊ីលឥន្ធនៈ និងការបញ្ចេញឧស្ម័ន $CO_2$ តាមប្រទេស
ទំ. ១០៥ | ផែនទី ៤៖ កម្រិតហានិភ័យនៃការប្រែប្រួលអាកាសធាតុ

# ភាគទី ២

# ការទូតសភាក្នុងបរិបទអាស៊ាន

ជំពូកទី ០៥ ទំ. ១២៧ - ទំ. ១៤១

## បរិបទអាស៊ាន


ទំ. ១២៨ ៥.១ ទិដ្ឋភាពទូទៅនៃតំបន់អាស៊ាន៖ ភូមិសាស្ត្រ និងភូមិសាស្ត្រនយោបាយ

ទំ. ១៣២ ៥.២ ការចូលជាសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន)

ទំ. ១៣៣ ៥.៣ ទំនាក់ទំនងការបរទេសនៃបណ្តារដ្ឋសមាជិកអាស៊ាន

ទំ. ១៣៩ ៥.៤ អាស៊ាននៅក្នុងបរិបទអន្តរជាតិ


### បញ្ជីផែនទី


ទំ. ១២៩ ផែនទី ៥៖ ឯករាជ្យ ប្រវត្តិសាស្ត្រ និងប្រជាជន

ទំ. ១៣១ ផែនទី ៦៖ ការធ្វើសមាហរណកម្មតំបន់អាស៊ាន (១៩៦៧-២០១៨)


ជំពូកទី ០៦ ទំ. ១៤៣ - ទំ. ១៦១

## សភានៃរដ្ឋជាសមាជិកអាស៊ាន


ទំ. ១៤៤ ៦.១ បរិបទនយោបាយ៖ ពីការរីកលូតលាស់ផ្នែកសេដ្ឋកិច្ចទៅកាន់អន្តរកាលផ្នែកនយោបាយ

ទំ. ១៤៥ ៦.២ សភាជាសមាជិកសភាអាយប៉ា (AIPA)៖ ក្របខ័ណ្ឌ សមាសភាព និងនីតិវិធី


### បញ្ជីផែនទី


ទំ. ១៤៥ ផែនទី ៧៖ ព្រុយណេ ដារូសាឡឹម

ទំ. ១៤៧ ផែនទី ៨៖ ព្រះរាជាណាចក្រកម្ពុជា

ទំ. ១៤៨ ផែនទី ៩៖ សាធារណរដ្ឋឥណ្ឌូណេស៊ី

ទំ. ១៤៩ ផែនទី ១០៖ សាធារណរដ្ឋប្រជាមានិតឡាវ

ទំ. ១៥១ ផែនទី ១១៖ ម៉ាឡេស៊ី

ទំ. ១៥៣ ផែនទី ១២៖ សាធារណរដ្ឋសហព័ន្ធមីយ៉ាន់ម៉ា

ទំ. ១៥៥ ផែនទី ១៣៖ សាធារណៈរដ្ឋហ្វីលីពីន

ទំ. ១៥៧ ផែនទី ១៤៖ សាធារណៈរដ្ឋសិង្ហបុរី

ទំ. ១៥៩ ផែនទី ១៥៖ ព្រះរាជាណាចក្រថៃ

ទំ. ១៦០ ផែនទី ១៦៖ សាធារណៈរដ្ឋសង្គមនិយមវៀតណាម

# តារាងមាតិកា

សេចក្តីផ្តើម ទំ. ១២៦

ជំពូកទី ០៧ ទំ. ១៦៣ - ទំ. ១៧១

## សមាគមសភា និងអាស៊ាន

ទំ. ១៦៤ ៧.១ ការទូតសភា៖ ការអភិវឌ្ឍ និងនិន្នាការថ្មីៗ
ទំ. ១៦៦ ៧.២ សភាជាសមាជិកអាយប៉ាដែលចូលរួមក្នុងសមាគមការទូតសភា
ទំ. ១៦៨ ៧.៣ កិច្ចប្រជុំ
ទំ. ១៦៨ ៧.៣.១ កិច្ចប្រជុំនៅក្នុងឆ្នាំ២០១៩
ទំ. ១៧០ ៧.៣.២ កិច្ចប្រជុំនៅក្នុងឆ្នាំ២០២០

ជំពូកទី ០៨ ទំ. ១៧៣ - ទំ. ២២៩

## ទិដ្ឋភាពទូទៅនៃបញ្ហាឆ្លងដែននានានៅក្នុងតំបន់

ទំ. ១៧៤ ៨.១ ភាពជាតំណាងរបស់ស្ត្រីនៅក្នុងសភាអាស៊ាន
ទំ. ១៧៩ ៨.២ ការវិវត្តក្របខ័ណ្ឌគតិយុត្តិស្តីអំពីអាកាសធាតុនៅអាស៊ាន
ទំ. ១៨៤ ៨.៣ ទេសន្តរប្រវេសន៍
ទំ. ១៨៦ ៨.៤ ការអប់រំនៅអាស៊ានក្នុងដំណាក់កាលដំបូងនៃបដិវត្តន៍ឧស្សាហកម្មលើកទី ៤
ទំ. ១៩០ ៨.៥ សេដ្ឋកិច្ចនិងពាណិជ្ជកម្ម
ទំ. ១៩២ ៨.៦ ហេដ្ឋារចនាសម្ព័ន្ធ
ទំ. ១៩៥ ៨.៧ សន្តិភាព និងសន្តិសុខ
ទំ. ១៩៩ ៨.៨ បញ្ហាផ្សេងៗ
ទំ. ១៩៩ ៨.៨.១ អាស៊ានវិវឌ្ឍឆ្ពោះទៅកាន់សេដ្ឋកិច្ចបៃតង និងឌីជីថល
ទំ. ២០៨ ៨.៨.២ សហគ្រាសធុនតូច និងមធ្យមនៅអាស៊ាន
ទំ. ២១០ ៨.៨.៣ ទម្រង់ថ្មីក្នុងការធ្វើធុរកិច្ច និងកម្លាំងចលករសម្រាប់ប្រទេសក្នុងតំបន់អាស៊ាន
ទំ. ២១៣ ៨.៨.៤ ការបណ្តុះបណ្តាលជំនាញ ការចាប់ផ្តើមអាជីវកម្ម និងនវានុវត្តន៍
ទំ. ២១៧ ៨.៨.៥ ហេដ្ឋារចនាសម្ព័ន្ធនិងទីក្រុងឆ្លាតវៃនៅអាស៊ីអាគ្នេយ៍

### បញ្ជីផែនទី

ទំ. ១៧៨ ផែនទី ១៧៖ តំណាងស្ត្រីនៅក្នុងសភានៅអាស៊ាន
ទំ. ១៨១ ផែនទី ១៨៖ ភូមិសាស្ត្ររូបវន្ត និងគ្រោះមហន្តរាយធម្មជាតិ
ទំ. ១៨៣ ផែនទី ១៩៖ ច្បាប់អាកាសធាតុ
ទំ. ១៨៥ ផែនទី ២០៖ ទេសន្តរប្រវេសន៍ក្នុងអាស៊ាន
ទំ. ១៨៩ ផែនទី ២១៖ ការអប់រំក្នុងអាស៊ាន
ទំ. ១៩១ ផែនទី ២២៖ ផលិតផលក្នុងស្រុកសរុប និងផលិតផលជាតិសរុបតាមប្រទេស
ទំ. ១៩៤ ផែនទី ២៣៖ ហេដ្ឋារចនាសម្ព័ន្ធ៖ ការតភ្ជាប់តំបន់
ទំ. ១៩៦ ផែនទី ២៤៖ បញ្ហាព្រំប្រទល់ដែនដីនៅអាស៊ាន
ទំ. ១៩៧ ផែនទី ២៥៖ បញ្ហាសមុទ្រចិនខាងត្បូង
ទំ. ១៩៨ ផែនទី ២៦៖ បញ្ហាឈូងសមុទ្រថៃ
ទំ. ២០៧ ផែនទី ២៧៖ កំណើន បច្ចេកវិទ្យាឌីជីថល និងសេដ្ឋកិច្ចពណ៌បៃតង
ទំ. ២០៩ ផែនទី ២៨៖ សហគ្រាសធុនតូច និងមធ្យម
ទំ. ២១២ ផែនទី ២៩៖ ទម្រង់ធុរកិច្ច និងកាតាលីករថ្មី
ទំ. ២១៦ ផែនទី ៣០៖ ការបណ្តុះបណ្តាល ធុរកិច្ចថ្មី និងនវានុវត្តន៍
ទំ. ២២០ ផែនទី ៣១៖ ទីក្រុងឆ្លាត

ផ្លូវចូលទៅអាគារ Louise Weiss នៃអសនៈសភាអឺរ៉ុប
នៅទីក្រុង ស្ត្រាសបួរ ប្រទេសបារាំង



# ភាគទី ១

# ការទូតសភា
# សភាបែបបុរេសកម្ម



# សេចក្តីផ្តើម

យើងមានសេចក្តីសោមនស្សរីករាយក្រៃលែងដែលវិទ្យាស្ថានសភាកម្ពុជា (PIC) និងលេខាធិការដ្ឋានអាយប៉ា (AIPA) បាននាំមកជូននូវសៀវភៅ «ការទូតសភាបែបបុរេសកម្ម» ដែលជាសៀវភៅទី ៣ នៅក្នុងភាគនៃសៀវភៅផែនទីរបស់យើង។ សៀវភៅផែនទីដំបូងផ្តោតលើប្រទេសកម្ពុជា និងទីតាំងរបស់ប្រទេសនេះនៅក្នុងអាស៊ីអាគ្នេយ៍ និងពិភពលោក បន្ទាប់មកនៅក្នុងភាគនេះយើងបានពង្រីកវិសាលភាពនៃសៀវភៅផែនទីរបស់យើងដែលជំហានដំបូងគឺ ផ្តោតលើតំបន់អាស៊ានទាំងមូល នឹងនៅក្នុងការបោះពុម្ពផ្សាយលើកនេះ គឺយើងភ្ជាប់ទៅនឹងតំបន់អាស៊ីនិងអឺរ៉ុបទៀត។

ការផ្លាស់ប្តូរនេះឆ្លុះបញ្ចាំងពីការអភិវឌ្ឍធំៗចំនួនពីរសម្រាប់ទាំងវិទ្យាស្ថានសភាកម្ពុជានិងលេខាធិការដ្ឋានអាយប៉ា។សម្រាប់វិទ្យាស្ថានសភាកម្ពុជា សៀវភៅផែនទីភាគនេះ គឺជាផលិតផលដែលឆ្លុះបញ្ចាំងពីសកម្មភាពដែលកាន់តែរីកធំឡើង និងជាការវិវត្តរបស់ស្ថាប័នខ្លួនឆ្ពោះទៅកាន់មជ្ឈមណ្ឌលសភាអាស៊ី (PCAsia) ដែលរួមមានតួនាទីកាន់តែធំជាងមុនក្នុងការអភិវឌ្ឍសមត្ថភាព និងការចែករំលែកបទពិសោធន៍ក្នុងតំបន់អាស៊ានទាំងមូល។ សម្រាប់លេខាធិការដ្ឋានអាយប៉ា ការបោះពុម្ពផ្សាយថ្មីចុងក្រោយបំផុតនេះបានបង្ហាញពីអាទិភាពរបស់អាយប៉ាក្នុង «ការលើកកម្ពស់សមត្ថភាពមន្ត្រីរបស់ខ្លួន និងមន្ត្រីរបស់សភានៅក្នុងអាស៊ាន» ដែលតាមរយៈអាទិភាពនេះអាយប៉ា អាច «បន្តបំពេញតម្រូវការដែលស្នើឡើងដោយសមាជិករបស់ខ្លួនពោលគឺការកសាងសមត្ថភាពរបស់ពួកគេឲ្យសមជាស្ថាប័នដែលមានសមត្ថភាពប្រកបដោយប្រសិទ្ធភាព មានភាពទទួលខុសត្រូវកម្រិតខ្ពស់ និងអាចជឿទុកចិត្តបាន»។ សៀវភៅភាគនេះ គឺជាការស្តែងឡើងនូវការរួមបញ្ចូលគ្នានៃគោលដៅរបស់ស្ថាប័នទាំងពីរ ដែលបង្កើតឡើងស្របពេលនឹងការព្យាយាមសម្រេចនូវគោលដៅដែលមាននៅក្នុងសេចក្តីសម្រេចស្តីពី កិច្ចសហប្រតិបត្តិការរវាងអាយប៉ា និងវិទ្យាស្ថានសភាកម្ពុជា ដែលបានអនុម័តដោយមហាសន្និបាតអន្តរសភាអាស៊ានលើកទី៣៧ និងបានបន្ត ហើយទទួលបានការអនុម័តនៅក្នុងមហាសន្និបាតលើកទី៤០ នាថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩ នៅទីក្រុងបាងកក។

ពិសេសជាងនេះទៅទៀតសៀវភៅ «ការទូតសភាបែបបុរេសកម្ម» ត្រូវបានសរសេរឡើងដើម្បីជួយគាំទ្រសមាជិកសមាជិកាសភា និងមន្ត្រីសភាសម្រាប់ចូលរួមក្នុងសកម្មភាពការទូតសភានៅក្នុងតំបន់អាស៊ាន និងជាមួយសមភាគីរបស់ខ្លួននៅអឺរ៉ុប និងកន្លែងផ្សេងទៀត។

សៀវភៅនេះក៏ជាឧបករណ៍សម្រាប់ប្រើប្រាស់ក្នុងកម្មវិធីបណ្តុះបណ្តាលថ្នាក់តំបន់ស្តីពី ការទូតសភា របស់វិទ្យាស្ថានសភាកម្ពុជា ដែលជួយណែនាំមន្ត្រីសភាដែលចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលនេះឲ្យបានដឹងពីទស្សនៈផ្សេងៗ គោលនយោបាយ និងផែនការនានា ដែលបានសរសេរដោយអ្នកនិពន្ធដែលបានចូលរួមចំណែកផលិតអត្ថបទនៅក្នុងសៀវភៅនេះ រួមមានទាំងអ្នកអនុវត្តផ្ទាល់ និងបញ្ញវន្តជាច្រើនមកពីបណ្តាប្រទេសនៅអាស៊ី និងអឺរ៉ុប។ ក្នុងឱកាសនេះដែរ យើងសូមសម្តែងនូវការដឹងគុណដ៏ស្មោះស្ម័គ្រចំពោះអ្នកដែលចូលរួមចំណែកសរសេរអត្ថបទទាំងអស់នៅក្នុងសៀវភៅនេះ។

ជាការពិតសម្រាប់ទាំងលេខាធិការដ្ឋានអាយប៉ា និងវិទ្យាស្ថានសភាកម្ពុជា គឺមានគោលបំណងរួមក្នុងការចូលរួមចំណែកពង្រឹងសមត្ថភាពសភា និងជម្រុញឲ្យមានការចែករំលែកព័ត៌មាន ព្រមទាំងបទពិសោធន៍រវាងសភាទាំងឡាយ។ យើងជឿជាក់ថា សៀវភៅថ្មីចុងក្រោយបំផុតនេះនៅក្នុងភាគនៃសៀវភៅផែនទីរបស់យើងនឹងរួមចំណែកធ្វើឲ្យសម្រេចនូវគោលបំណងទាំងនេះ។ ដូចនៅក្នុងសៀវភៅផែនទីមុនដែរ សៀវភៅថ្មីនេះត្រូវបានរៀបចំបែបជាឯកសាររស់រវើក ដោយយើងបន្តធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់ទៅលើទម្រង់បោះពុម្ពជាអេឡិចត្រូនិច ដែលមានបង្ហោះនៅលើគេហទំព័ររបស់វិទ្យាស្ថាន ហើយតាមដំណាក់កាលយើងនឹងមានការបោះពុម្ពជាសៀវភៅ ដែលធ្វើឲ្យសៀវភៅនេះក្លាយជាឯកសារយោងដ៏មានតម្លៃ និងជាយានមួយសម្រាប់កិច្ចសហការបន្ត។ ដោយសារការទទួលបានព័ត៌មានទាន់ហេតុការណ៍មិនមែនជារឿងងាយស្រួល ការធ្វើការរួមគ្នាគឺជាវិធីសាស្ត្រដែលល្អបំផុត។ ដោយហេតុនេះហើយ យើងបានស្នើសុំជំនួយពីថ្នាក់ដឹកនាំ អ្នកជំនាញ និងអ្នកដែលបានយល់ដឹងពីព័ត៌មានតាមរយៈការអានដទៃទៀតឲ្យជួយចែករំលែកចំណេះដឹងដែលពាក់ព័ន្ធ ដើម្បីយកមកបញ្ចូលសម្រាប់ធ្វើបច្ចុប្បន្នភាពសៀវភៅនេះជាបន្តបន្ទាប់នាពេលអនាគត។ យើងសូមថ្លែងអំណរគុណដ៏ស្មោះអស់ពីចិត្ត ចំពោះអ្នកគ្រប់គ្នាដែលបានចំណាយពេលវេលា និងប្រើប្រាស់ជំនាញរបស់ខ្លួនក្នុងការចូលរួមផលិតឯកសាររស់រវើកដែលត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំមួយនេះ។ រួមគ្នាយើងសង្ឃឹមថា ឯកសារនេះនឹងក្លាយជាធនធានដ៏មានអត្ថប្រយោជន៍សម្រាប់មន្ត្រីសភាដែលចូលរួមការបណ្តុះបណ្តាលក្នុងកម្មវិធីនានារបស់វិទ្យាស្ថានសភាកម្ពុជា មន្ត្រីដទៃទៀតនៃសភាជាសមាជិកអាយប៉ា និងអ្នកគ្រប់គ្នាដែលចាប់អារម្មណ៍លើតួនាទីការទូតសភានៅអាស៊ី និងអឺរ៉ុប។

ដើម្បីជួយវិទ្យាស្ថានសភាកម្ពុជា និងលេខាធិការដ្ឋានអាយប៉ាអាចផ្តល់ព័ត៌មានពាក់ព័ន្ធ និងទាន់សភាពការណ៍ សូមផ្ញើយោបល់ និងការចែករំលែកនានាតាមរយៈអ៊ីមែល digital.atlas@pic.org.kh ។

**គឹមឃាត ដារ៉ារិទ្ធ**
**នាយកប្រតិបត្តិ វិទ្យាស្ថានសភាជាតិកម្ពុជា**

**NGUYEN Tuong Van**
**អគ្គលេខាធិការ អន្តរសភាអាស៊ាន (AIPA)**







អគ្គលេខាធិការអន្តរសភាអាស៊ាន (២០១៣-២០១៦) លោក Otharam PERIOWSAMY និងនាយកប្រតិបត្តិនៃវិទ្យាស្ថានសភាកម្ពុជា លោក គីមយាត ដារ៉ារិទ្ធ បានចុះកិច្ចព្រមព្រៀងលើអនុស្សរណៈនៃការយោគយល់គ្នារវាងអង្គការទាំងពីរកាលពីថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ហើយបានបន្តកិច្ចព្រមព្រៀងនេះជាថ្មីក្នុងសម័យប្រជុំពេញអង្គលើកទី ២ មហាសន្និបាត AIPA នៅទីក្រុងបាងកកប្រទេសថៃ នាថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩ ។ ភាពជាដៃគូរវាង វិទ្យាស្ថានសភាកម្ពុជា និងលេខាធិការដ្ឋានអន្តរសភាអាស៊ាន បន្តរីកចំរើនក្រោមការដឹកនាំរបស់អគ្គលេខាធិការ អន្តរសភាអាស៊ាន នាពេលបច្ចុប្បន្ន គឺលោកស្រី NGUYEN Tuong Van ។

អែម សូ៉ានី និង ឡឹង វណ្ណា

# សេចក្តីសង្ខេបនៃបទវិភាគ

## សេចក្តីផ្តើម

សៀវភៅនេះដែលផ្នែកទី១ ផ្តោតលើការទូតសភា ជាបណ្តុំនៃមតិយោបល់និងការយល់ឃើញពីអ្នកជំនាញនិងពលរដ្ឋពីអឺរ៉ុប និងអាស៊ី។ គោលបំណងនៃសៀវភៅនេះគឺដើម្បីចែករំលែកទស្សនៈជាលក្ខណៈបុគ្គលជាមួយសមាជិក សមាជិកាសភា សម្រាប់ជាមូលដ្ឋានក្នុងការពិនិត្យ និងពិភាក្សាច្បាប់ និងក្នុងការជះឥទ្ធិពលដល់ការយល់ឃើញរបស់រដ្ឋាភិបាលរៀងៗខ្លួន អំពីវិធីសាស្ត្រល្អបំផុតក្នុងការដោះស្រាយបញ្ហាបន្ទាន់ៗសព្វថ្ងៃនេះ។ ក្នុងកម្មវិធីទាំងឡាយណាដែលសមាជិក សមាជិកាសភាជួបប្រជុំគ្នា ដូចជាកិច្ចប្រជុំភាពជាដៃគូសភាអាស៊ីអឺរ៉ុប (ASEP) ទស្សនៈរបស់ពលរដ្ឋប្រកបដោយពិពិធភាពទាំងនេះអាចជួយសម្រួលកិច្ចសន្ទនារវាងប្រជាជាតិនិងប្រជាជាតិនៅទ្វីបផ្សេងៗគ្នា។ ក្នុងនាមជាអ្នកតំណាងពលរដ្ឋ សមាជិក សមាជិកាសភាមានទំនួលខុសត្រូវក្នុងការពិចារណាមតិយោបល់របស់ពលរដ្ឋ។ កិច្ចការទាំងនេះអាចជួយរដ្ឋាភិបាលក្នុងការទទួលស្គាល់មតិយោបល់ផ្សេងៗដែលស្តែងចេញតាមរយៈសភា ជាពិសេសនៅពេលដែលសភាទាំងនោះចូលរួមជាមួយគ្នា បង្កើតជាកិច្ចព្រមព្រៀងបែបកុងសង់ស៊ុស និងបង្ហាញជំហររួមមួយ។ ជាសេចក្តីផ្តើម អត្ថបទនៃបទវិភាគនេះនឹងចែករំលែកការយល់ឃើញចេញពីការសម្រាំងយកអត្ថបទមួយចំនួនដើម្បីផ្តល់ជាសេចក្តីសង្ខេបជាមុនពីទស្សនៈផ្សេងៗដែលមាននៅក្នុងសៀវភៅនេះ។

## តួនាទីសភាក្នុងការដោះស្រាយបញ្ហាប្រឈមឆ្លងដែន

ក្នុងសតវត្សរ៍ទី២១ ឱកាសនិងបញ្ហាប្រឈមជាច្រើនឆ្លងហួសពីព្រំដែននៃរដ្ឋនីមួយៗ ហើយទាមទារនូវកិច្ចសហប្រតិបត្តិការអន្តរជាតិ។ បច្ចុប្បន្ន លើសពេលណាៗទាំងអស់ តថភាពនេះកំពុងត្រូវបានស្តែងឲ្យឃើញកាន់តែច្បាស់តាមរយៈការរាតត្បាតជាសកលនៃជំងឺកូវីដ១៩ និងតម្រូវការរបស់យើងក្នុងការធ្វើការរួមគ្នាក្នុងនាមជាប្រជាជាតិផ្សេងៗដើម្បីដោះស្រាយបញ្ហាប្រឈមមួយនេះដែលមិនធ្លាប់ជួបប្រទះពីមុនមក។ អង្គការពហុភាគីជាច្រើនបានលេចរូបរាងតាំងពីការបិទបញ្ចប់សង្គ្រាមលោកលើកទី២ ដើម្បីជំរុញស្ថិរភាពតំបន់ គ្រប់គ្រងជម្លោះនិងវិបត្តិសុខភាព សម្រេចគោលដៅរួម និងដោះស្រាយបញ្ហាប្រឈមសកលផ្សេងៗទៀតដោយផ្អែកទៅតាមក្បួនច្បាប់នានា។ បញ្ហានៅត្រង់ថាសេចក្តីសម្រេចពហុភាគីភាគច្រើនត្រូវបានធ្វើឡើងនៅក្រៅដែនសមត្ថកិច្ចរបស់ស្ថាប័ននានាដែលតំណាងពលរដ្ឋ។ នេះជាភាពទន់ខ្សោយមួយដែលអាចនាំមកនូវកង្វះការគាំទ្រពីសំណាក់ពលរដ្ឋទូទៅ។ ការទូតសភា ជាពិសេសការទូតសភាពហុភាគី នាំយកមតិយោបល់របស់ពលរដ្ឋទៅកាន់វេទិកាតស៊ូមតិ និងការចចារកិច្ចការសកល និងផ្តល់ជាយានក្នុងការចែករំលែកទស្សនៈរបស់ពួកគេក្នុងអំឡុងពេលវិបត្តិតាមរយៈសភារបស់ពួកគេផ្ទាល់។ វាជាការផ្តល់ធម្មានុរូបភាព ទម្ងន់នយោបាយ និងភាពធន់ ទៅដល់ការសម្រេចចិត្តទាំងនេះ ក៏ដូចជាជួយឲ្យអង្គការអន្តររដ្ឋាភិបាលកាន់តែមានគណនេយ្យភាព និងតម្លាភាព ស្របពេលជំរុញឲ្យមានការយល់ពីគ្នារវាងពលរដ្ឋនិងប្រទេស។

## កូវីដ១៩៖ ផលប៉ះពាល់ និងការឆ្លើយតប

ការរីករាលដាលជាសកលនៃវីរុសកូវីដ១៩ ជាបញ្ហាប្រឈមមិនធ្លាប់មានពីមុនចំពោះរដ្ឋាភិបាល ពលរដ្ឋ និងសភានានានៅក្នុងពិភពលោក។ ក្នុងទ្វីបអាស៊ី អឺរ៉ុប និងទ្វីបដទៃ ប្រជាពលរដ្ឋមិនត្រឹមតែទទួលរងការគំរាមកំហែងផ្នែកសុខភាពប៉ុណ្ណោះទេ តែជីវភាពនិងសេរីភាពប្រចាំថ្ងៃក៏រងផលប៉ះពាល់ដែរ។ នៅក្នុងអត្ថបទនេះបង្ហាញថា សភាជាច្រើនដែលកំពុងប្រើប្រាស់ឧបករណ៍និងនីតិវិធីថ្មីៗចុងក្រោយ បានបំពេញតួនាទីដ៏សំខាន់ក្នុងការសហការជាមួយរដ្ឋាភិបាលដើម្បីជួយទប់ស្កាត់ផលប៉ះពាល់ដល់សុខភាពនិងសន្តិសុខសេដ្ឋកិច្ច។ នៅប្រទេសបារាំង សំណុំនៃច្បាប់ជាច្រើន រួមមាន "សេចក្តីថ្លែងការណ៍ស្តីពីស្ថានភាពអាសន្ននៃសុខភាព" ត្រូវបានអនុម័តដោយសភាទាំងពីរថ្នាក់ ដោយផ្តល់អាទិភាពទៅលើកិច្ចព្រមព្រៀងនយោបាយជាតិបែបកុងសង់ស៊ុស ដោយទទួលស្គាល់ថា កិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការកម្រិតសិទ្ធិពលរដ្ឋដើម្បីផលប្រយោជន៍រួម ពេលខ្លះគួរត្រូវរឹតត្បិតដែរក្រោយមានការពិចារណាសមរម្យមួយ។ នៅប្រទេសឥណ្ឌូនេស៊ី នៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០២០ សភាជាន់ទាបបានដឹកនាំកិច្ចប្រជុំមួយតាមរយៈសន្និសីទវីដេអូ ដោយពិនិត្យលើ "តួនាទី

សភាសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងការកម្ចាត់ជំងឺកូវីដ១៩” ដែលផ្តល់ឱកាសឲ្យអ្នកចូលរួមប្រៀបធៀបកិច្ចការដែលបានធ្វើនៅប្រទេសជាច្រើនផ្សេងៗគ្នា និងពិភាក្សាពីវិធីបង្កើនកិច្ចសហប្រតិបត្តិការក្នុងការឆ្លើយតបនឹងជំងឺរាតត្បាតសកលប្រកបដោយប្រសិទ្ធភាពខ្ពស់។

ផ្ទុយពីកិច្ចការដ៏សំខាន់ដែលបំពេញដោយសភាមួយចំនួន ឱកាសជាច្រើនសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិរួមមានការផ្លាស់ប្តូរព័ត៌មាន និងការសហការលើការព្យាបាលនិងជម្រើសនៃការស្រាវជ្រាវនានាបានមើលរំលងទាំងស្រុងដោយសារតែកង្វះឆន្ទៈនយោបាយ។ នៅក្នុងអត្ថបទនេះបង្ហាញថា ការបំពេញការងាររបស់សភា ដោយសភារៀងៗខ្លួនក្តី និងជាសមូហភាពក្តីបានឆ្លុះបញ្ចាំងពីផលប្រយោជន៍ដែលប្រទេសនីមួយៗមានសភាដែលមានអំណាចមិនថាក្នុងកំរិតជាតិតំបន់ឬអន្តរជាតិ។

## បុរេសកម្មសភាដើម្បីសន្តិភាព សន្តិសុខ និងវិបុលភាពរួម

ខុសពីអតិក្រមអឺរ៉ុបចំពោះពហុភាគីនិយកម្ម ដែលផ្តោតសំខាន់លើស្ថាប័នប្រកបដោយបរិយាបន្ននិងគ្រប់ជ្រុងជ្រោយជាមួយនឹងការប្តេជ្ញារបស់រដ្ឋសមាជិកដែលចងដោយច្បាប់ “វិធីរបស់អាស៊ាន” បានជ្រើសយកនីតិវិធីដែលមានលក្ខណៈក្រៅផ្លូវការ ពោលគឺតំបន់និយកម្មដែលចូលរួមដោយពហុក្រុម និងរួមមានវេទិកានានាជាច្រើន ជាមួយនឹងសេចក្តីសម្រេចចិត្តដែលមិនត្រូវចងដោយច្បាប់ និងផ្អែកលើកិច្ចព្រមព្រៀងជាលក្ខណៈកុងសង់ស៊ីស។ បញ្ហាប្រឈមធំបំផុតសម្រាប់តំបន់អាស៊ាន និងប្រហែលសម្រាប់ពិភពលោកទាំងមូល គឺជម្លោះរវាងមហាអំណាចធំៗ និងកង្វះសមត្ថភាពក្នុងការរឹតត្បិតសកម្មភាពរបស់ពួកគេ។ ជម្រើសទ្វេភាគីនិយមពីសំណាក់សហរដ្ឋអាម៉េរិកនិងចិន កំពុងក្លាយជាឧបសគ្គរាំងស្ទះដល់ពហុភាគីនិយមនិយាយជារួម និងប៉ះពាល់ដល់ភាពមជ្ឈភាពអាស៊ាន ភាពស្អិតរមួត និងសារៈសំខាន់របស់អង្គការនេះបើនិយាយដោយឡែក។

បញ្ហាប្រឈមចំពោះពហុភាគីនិយមនេះទាមទារឲ្យសភាមានភាពបុរេសកម្មកាន់តែខ្លាំង និងពង្រឹងតួនាទីដែលមានស្រាប់និងតួនាទីថ្មីៗរបស់ខ្លួន រួមមានតួនាទីនៃការទូតសភាជាដើម។ សមាជិកសភាអាចបញ្ជូនសារនិងលើកកម្ពស់ផលប្រយោជន៍ជាតិរបស់ខ្លួន ហើយក្នុងពេលជាមួយគ្នានោះក៏អាចលើកទឹកចិត្តស្ថាប័ននីតិប្រតិបត្តិរបស់ខ្លួនឲ្យលះបង់ក្តីបារម្ភបន្ទាន់របស់ប្រទេសខ្លួននៅពេលខ្លះ ដើម្បីឈោងចាប់អតិក្រមបែបសហប្រតិបត្តិការដែលជាយានឆ្ពោះទៅដោះស្រាយបញ្ហាប្រឈមសកលរយៈពេលយូរប្រកបដោយចីរភាព។ កិច្ចការនេះអាចរាប់បញ្ចូលការគាំទ្រកិច្ចប្រឹងប្រែងបែបពហុភាគីក្នុងការប្រយុទ្ធប្រឆាំងការប្រែប្រួលអាកាសធាតុ វិធានការណ៍សេដ្ឋកិច្ចនិងរូបិយវត្ថុក្នុងការដោះស្រាយផលប៉ះពាល់សកលនៃវិបត្តិផ្សេងៗដូចជា កូវីដ១៩ និងគំនិតផ្តួចផ្តើមសង្គមនិងសុខភាព ដើម្បីឲ្យពិភពលោកត្រៀមខ្លួនប្រសើរជាងមុនក្នុងការទប់ទល់ទៅនឹងគ្រោះអាសន្ននានានៅពេលអនាគត។ ជាផ្នែកមួយនៃកិច្ចប្រឹងប្រែងនេះ អាស៊ីនិងអាស៊ានគួរតែព្យាយាមកសាងភាពជាដៃគូកាន់តែរឹងមាំជាមួយនឹងសហភាពអឺរ៉ុប ដែលអាចសហការជាមួយគ្នាក្នុងការបង្កើតសណ្តាប់ធ្នាប់ថ្មីមួយនៃពហុភាគីនិយមដែលមានគោលដៅដោះស្រាយបញ្ហាប្រឈមរួម និងបញ្ចៀសគ្រោះថ្នាក់នៃជម្លោះនិងការប៉ះទង្គិចរវាងមហាអំណាចនានា។

## ការលើកកម្ពស់ប្រព័ន្ធពាណិជ្ជកម្មពហុភាគីដោយផ្អែកលើបទបញ្ញត្តិដើម្បីការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាបន្ន

ក្នុងនាមជាស្ថាប័នស្នូលមួយនៃពហុភាគីនិយម អង្គការពាណិជ្ជកម្មពិភពលោកមានការវិវត្តគួរឲ្យកត់សម្គាល់ ដោយធ្វើឲ្យមានប្រព័ន្ធពាណិជ្ជកម្មពិភពលោកសេរីស្ទើរតែទាំងស្រុង ជាពិសេសការកាត់បន្ថយពន្ធនាំចូលរវាងប្រទេសនានា ស្របពេលជាមួយគ្នានេះ ក៏សង្កត់ធ្ងន់ទៅលើគោលការណ៍ដូចជា សមភាព កិច្ចសហប្រតិបត្តិការ និងការចរចា ដែលរួមចំណែកជួយឲ្យមានសន្តិភាព។ ប្រព័ន្ធពាណិជ្ជកម្មពហុភាគីដែលផ្អែកលើបទបញ្ញត្តិនេះបានផ្តល់ប្រយោជន៍យ៉ាងធំធេងដល់ទាំងប្រទេសអភិវឌ្ឍន៍ និងកំពុងអភិវឌ្ឍន៍។ ប្រព័ន្ធនេះបានជួយឲ្យអាស៊ីធ្វើសមាហរណកម្មចូលទៅក្នុងទីផ្សារពិភពលោកយ៉ាងទូលំទូលាយដែលនាំឲ្យមានកំណើននៃការនាំចេញយ៉ាងគំហុក បង្កើតបានកំណើនការងាររាប់លានកន្លែង និងធ្វើកម្រិតនៃការអភិវឌ្ឍមានកំណើនថេរ។ អ្នកប្រើប្រាស់នៅអឺរ៉ុបបានទទួលប្រយោជន៍ពីទំនិញនិងសេវាកម្មពីអាស៊ីក្នុងតម្លៃថោកជាង

មុន។ ក៏ប៉ុន្តែបញ្ហាធំៗបានកើតឡើង។ សហរដ្ឋអាម៉េរិក ដែលជាស្ថាបនិកចម្បងមួយនៃសណ្តាប់ធ្នាប់អន្តរជាតិក្រោយឆ្នាំ១៩៤៥ កំពុងតែងាកទៅរកការចរចាទ្វេភាគី ហើយថែមទាំងមានសង្គ្រាមពន្ធនាំចូលជាមួយនឹងដៃគូពាណិជ្ជកម្មរបស់ខ្លួនទៀត។ ប្រព័ន្ធដោះស្រាយជម្លោះរបស់អង្គការពាណិជ្ជកម្មពិភពលោក កំពុងត្រូវបានគំរាមកំហែងខ្លាំង ពេលដែលសហរដ្ឋអាម៉េរិកបានរារាំងការតែងតាំងបេក្ខជនទៅកាន់សាលាឧទ្ធរណ៍ ដោយសារក្តីព្រួយបារម្ភអំពី អភិក្រមបែបសកម្មនិយម និងពីការគំរាមកំហែងដល់អធិបតេយ្យភាពរដ្ឋ។

ជាការឆ្លើយតប អាស៊ីកំពុងដំណើរការនូវផែនការទាក់ទងនឹងគំនិតផ្តួចផ្តើមអន្តរតំបន់ដូចជា CPTPP និង RCEP-16 ហើយ RCEP-16 នេះអាចនឹងក្លាយជាកិច្ចព្រមព្រៀងពាណិជ្ជកម្មធំបំផុតរបស់ពិភពលោកបើគិតលើចំនួនប្រជាជន និងចំណូលសរុប។ សហភាពអឺរ៉ុបកំពុងស្វះស្វែងឲ្យមានកំណែទម្រង់អង្គការពាណិជ្ជកម្មពិភពលោកតាមរយៈការពង្រឹងការអនុវត្តច្បាប់ ការផ្តល់អំណាចទៅឲ្យគណៈកម្មាធិការក្នុងការកែប្រែច្បាប់ជាបន្តបន្ទាប់ និងការព្យាយាមកាត់បន្ថយក្តីព្រួយបារម្ភរបស់សហរដ្ឋអាម៉េរិកអំពី សាលាឧទ្ធរណ៍។

ក៏ប៉ុន្តែ កិច្ចការជាច្រើនទៀតចាំបាច់ត្រូវធ្វើដើម្បីដោះស្រាយភាពតានតឹងដ៏ធំមួយក្នុងសកលភាវូបនីយកម្ម។ ភាពតានតឹងនោះក៏ដោយសារតែ រដ្ឋនីមួយៗចង់បានអធិបតេយ្យភាពពេញលេញ ហើយពលរដ្ឋទាមទារនូវសិទ្ធិបញ្ចេញមតិលើសេចក្តីសម្រេចចិត្តដែលប៉ះពាល់ដល់ជីវភាពរបស់ពួកគេ ខណៈដែលពាណិជ្ជកម្មពិភពលោកទាមទារនូវប្រព័ន្ធពហុភាគីដែលផ្អែកទៅលើច្បាប់។ ការដែលប្រព័ន្ធនេះជារឿយៗមានលក្ខណៈការិយាធិបតេយ្យ មានគម្លាតនិងកាត់ផ្តាច់ពីប្រជាពលរដ្ឋអាចមើលឃើញយ៉ាងច្បាស់តាមរយៈភាពបរាជ័យនៃការចរចា TTIP រវាងសហរដ្ឋអាម៉េរិក និងសហភាពអឺរ៉ុប។ ហេតុនេះ ដើម្បីកសាងប្រព័ន្ធពហុភាគីដែលកាន់តែរឹងមាំនិងមានប្រសិទ្ធភាពក្នុងការគ្រប់គ្រងពាណិជ្ជកម្មពិភពលោកនិងបទបញ្ញត្តិនានា ការបញ្ចេញមតិយោបល់របស់ប្រជាពលរដ្ឋនិងស្ថាប័នតំណាងរបស់ពួកគេគួរតែមានតួនាទីកាន់តែធំ។

## ការដោះស្រាយបញ្ហាអន្តរកម្មនៃសន្តិសុខទឹក ថាមពល និងស្បៀងក្រោមឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ

ដើម្បីទទួលបានការយល់ដឹងអំពីអន្តរកម្មរវាងសន្តិសុខធនធាន និងការប្រែប្រួលអាកាសធាតុ សៀវភៅផែនទីនេះផ្តល់ការយល់ឃើញអំពី សន្តិសុខថាមពលពីអឺរ៉ុប និងការយល់ឃើញអំពីសន្តិសុខស្បៀងពីអាស៊ី ជាមួយនឹងពិពិធភាពនៃការយល់ឃើញអំពីមូលហេតុផ្សេងៗ និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

ខណៈដែលការផ្គត់ផ្គង់ស្បៀង និងថាមពលទៀងទាត់ មានសារៈសំខាន់ចំពោះប្រជាជនក្នុងសម័យទំនើប ផលប៉ះពាល់ដល់បរិស្ថានក៏ចាំបាច់ត្រូវបានពិចារណាផងដែរ។ ជាផ្នែកមួយនៃការធ្វើឲ្យមានតុល្យភាពនេះ សហភាពអឺរ៉ុបបានជម្រុញឲ្យមានការលូតលាស់នៃប្រភពថាមពលជំនួសផ្សេងៗនៅអឺរ៉ុប។ ស្របពេលដែលមានភាពវិជ្ជមានក្នុងវិស័យអាកាសធាតុ ផលវិបាកមួយទៀត គឺការថយចុះនៃផលិតកម្មថាមពលសរុប ដោយសារកម្រិតនៃផលិតកម្មសម្រាប់ប្រភពថាមពលមិនកកើតឡើងវិញបានធ្លាក់ចុះ។ សព្វថ្ងៃនេះ លើសពីពាក់កណ្តាលនៃតម្រូវការថាមពលរបស់សហភាពអឺរ៉ុបត្រូវបានផ្គត់ផ្គង់ដោយបណ្តាប្រទេសនៅក្រៅសហភាពអឺរ៉ុប ដែលបង្កឲ្យមានស្ថានភាពភូមិសាស្ត្រនយោបាយមួយដែលស្មុគស្មាញ និងមិននឹងនរ។

បញ្ហាធនធានដ៏ធំមួយសម្រាប់អាស៊ី គឺការផ្គត់ផ្គង់ស្បៀង ស្របពេលដែលតំបន់នេះកំពុងមានតម្រូវការស្បៀងខ្ពស់បំផុត ហើយខណៈប្រជាជនក៏កំពុងកើនឡើងយ៉ាងឆាប់រហ័ស។ គួរឲ្យព្រួយបារម្ភ ការសិក្សាបានបង្ហាញថា សីតុណ្ហភាពកើនឡើងអាចនឹងបណ្តាលឲ្យមានការធ្លាក់ចុះនូវទិន្នផលដំណាំយ៉ាងគំហុកក្នុងប៉ុន្មានទសវត្សរ៍ខាងមុខនេះ។ សភាសិង្ហបុរីបានបោះជំហានដ៏សំខាន់ក្នុងការដោះស្រាយបញ្ហានេះនៅពេលដែលខ្លួនបានបង្កើត “ភ្នាក់ងារស្បៀងសិង្ហបុរី”។ ភ្នាក់ងារនេះកំពុងបំពេញភារកិច្ចស្វែងរកវិធីនានាសម្រាប់ឲ្យទីក្រុងទាំងឡាយដែលជាទីលំនៅនៃប្រជាជនពាក់កណ្តាលនៃប្រជាជនសរុបរបស់ពិភពលោក រួមចំណែកដល់ផលិតកម្មស្បៀងសកលជាមួយនឹងវិធីសាស្ត្រកសិដ្ឋានទីក្រុងប្រកបដោយចីរភាព និងការបង្រួញខ្សែចង្វាក់ការផ្គត់ផ្គង់ស្បៀង ដែលអាចជួយបង្ការការខ្វះខាតចំណីអាហារ និងកាត់បន្ថយដានកាបូនរបស់ស្បៀង។

ប៉ុន្តែសន្តិសុខស្បៀងមិនមែនជាក្តីព្រួយបារម្ភធំតែមួយគត់របស់អាស៊ីទេ។ ក្នុងនាមជាប្រភពនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពាក់កណ្តាលនៃការបញ្ចេញសរុបរបស់ពិភពលោក អាស៊ីក៏ជាតំបន់ដែលងាយប្រឈមនឹងការប្រែប្រួលអាកាសធាតុ។ កាន់តែធ្ងន់ធ្ងរជាងនេះទៀតនោះ ទីក្រុងធំៗនៃអាស៊ីអាគ្នេយ៍មានទីតាំងឋិតនៅលើដីទន់ក្នុងតំបន់ដីល្បាប់ និងតំបន់ដីសណ្តរ ទីដែលមានការវិវត្តនគរូបនីយកម្មដ៏ឆាប់រហ័ស និងការប្រើប្រាស់ទឹកក្រោមដីច្រើន កំពុងបណ្តាលឲ្យមានការស្រុតលិចផ្ទៃដីខាងលើ ដែលនាំឲ្យមានការកើនឡើងនៃទឹកជំនន់។ បញ្ហាប្រឈមមួយទៀតសម្រាប់អាស៊ីនោះគឺការកាប់បំផ្លាញព្រៃឈើដែលភាគច្រើនបណ្តាលមកពីការទន្ទ្រានយកដីដើម្បីធ្វើកសិកម្ម និងការកាប់ឈើ។ ហេតុការណ៍នេះត្រូវបានជំរុញដោយតម្រូវការសកលដ៏ច្រើនសម្បើមលើកសិផល និងការកើនឡើងនៃវិនិយោគទុនពីប្រទេសចិន ជាមួយនឹងភាពលំបាកក្នុងការអនុម័តច្បាប់ប្រកបដោយប្រសិទ្ធភាព ហើយពេលខ្លះការអនុវត្តច្បាប់ដែលមានស្រាប់ក៏នៅមានលក្ខណៈទន់ខ្សោយនៅឡើយ។ នេះជាមូលហេតុដែលរួមចំណែកបង្កើនបរិមាណឧស្ម័នកាបូនិកនៅក្នុងបរិយាកាស ដែលនាំឲ្យឡើងកម្តៅផែនដីនិងកើនកម្ពស់ទឹកសមុទ្រ។

ទន្ទឹមនឹងនេះ សហភាពអឺរ៉ុបក៏កំពុងប្រឈមមុខនឹងបញ្ហាផ្សេងៗរបស់ខ្លួនផងដែរ ស្របពេលដែលខ្លួនព្យាយាមក្លាយជាអ្នកដឹកនាំសកលក្នុងការប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ។ ក្រោយជោគជ័យជាច្រើនរួមមាន កិច្ចព្រមព្រៀងទីក្រុងប៉ារីស និងសន្និសីទការប្រែប្រួលអាកាសធាតុសហប្រជាជាតិ ក្នុងឆ្នាំ២០១៧ សហភាពអឺរ៉ុបបានសម្រេចខ្លះៗនូវការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ស្របពេលដែលខ្លួនអាចរក្សាអត្រាកំណើនសេដ្ឋកិច្ចដ៏ល្អមួយ ក៏ប៉ុន្តែគោលដៅអាកាសធាតុជាតិបច្ចុប្បន្ននៅតែមិនទាន់សម្រេចបានដូចការប្តេជ្ញាក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីស។ កិច្ចព្រមព្រៀងបៃតងអឺរ៉ុបដែលត្រូវបានស្នើឡើងថ្មីៗនេះជាជំហានបន្ទាប់ដ៏សំខាន់មួយ។ គោលបំណងធំរបស់កិច្ចព្រមព្រៀងថ្មីនេះគឺដើម្បីសម្រេចឲ្យបាននូវការលែងមានការបញ្ចេញឧស្ម័នកាបូនិកក្នុងរយៈពេល៣ទសវត្សរ៍ ដែលតម្រូវឲ្យមានការពិចារណាឡើងវិញនូវគោលនយោបាយនានាទាក់ទងនឹងធនធាននិងបរិស្ថាន។ បន្ទុកនៃការកាត់បន្ថយការបញ្ចេញឧស្ម័នទាំងនេះក៏ប្រហែលនឹងធ្លាក់ទៅលើដៃគូពាណិជ្ជកម្មរបស់សហភាពអឺរ៉ុប ហេតុនេះច្បាស់ណាស់នឹងមានឧបសគ្គផ្នែកនយោបាយផ្សេងៗ។

ឆ្លើយតបចំពោះបញ្ហាទាំងនេះនៅថ្នាក់ជាតិ សភាអាចរួមចំណែកតាមរយៈការបង្កើតច្បាប់ប្រកបដោយការគិតគូរពិចារណាគ្រប់ជ្រុងជ្រោយ លើកកម្ពស់ការយល់ដឹងសាធារណៈ និងជួយពាំនាំមតិយោបល់ពីអង្គការសង្គមស៊ីវិលក៏ដូចជាតាមដាននិងត្រួតពិនិត្យ ការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធភាពពីសំណាក់រដ្ឋាភិបាល ភ្នាក់ងារនិងស្ថាប័នជំនាញពហុភាគីនានា។ ការរួមចំណែកនេះក៏អាចជួយដល់សកម្មភាពពហុភាគីនានាតាមរយៈការនាំមកនូវធម្មានុរូបភាព និងគណនេយ្យភាពប្រជាធិបតេយ្យទៅកាន់កិច្ចប្រឹងប្រែងនានាក្នុងការបន្សាំខ្លួន និងកាត់បន្ថយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។ កិច្ចប្រជុំអន្តរសភា (ដូចជា ASEP, IPU, AIPA -ល-) ក៏ជាព្រឹត្តិការណ៍សំខាន់ផងដែរសម្រាប់ការផ្លាស់ប្តូរទៅវិញទៅមកដែលអាចប្រើប្រាស់សម្រាប់ជម្រុញកិច្ចព្រមព្រៀងអន្តរតំបន់ និងការប្តេជ្ញាចិត្តរួម។

## សេចក្តីបញ្ចប់

រួមជាមួយនឹងតំណាងសភាពីអាស៊ីនិងអឺរ៉ុប វិទ្យាស្ថានសភាកម្ពុជា (PIC) និង មជ្ឈមណ្ឌលសភាអាស៊ី (PCAsia) ដែលនឹងបង្កើតឡើងនាពេលខាងមុខនេះ មានការប្តេជ្ញាចិត្តរួមគ្នាមួយក្នុងការកសាងការយល់ដឹងលើបញ្ហាដែលប៉ះពាល់ដល់យើងទាំងអស់គ្នា ដែលរួមមានបញ្ហាសន្តិសុខផ្នែកសុខាភិបាលនិងការគ្រប់គ្រងវិបត្តិ បញ្ហាសេដ្ឋកិច្ចនិងពាណិជ្ជកម្ម និងបញ្ហាប្រែប្រួលអាកាសធាតុនិងសន្តិសុខផ្នែកធនធាន។ ស្របពេលដែលសភាកំពុងមានភាពបុរេសកម្មក្នុងការបង្កើនតួនាទីរបស់ខ្លួន ដើម្បីពង្រឹងការកសាងសន្តិភាព ការប្រឹងប្រែងចងក្រងសៀវភៅនេះ គឺសំដៅជួយផ្តល់មតិយោបល់ទៅកាន់អ្នកពាក់ព័ន្ធជាច្រើនផ្សេងៗគ្នាដែលមានចំណែកសំខាន់ក្នុងដំណើរការនៃកិច្ចសន្ទនា និងជួយដោះស្រាយជម្លោះដែលចាំបាច់ក្នុងការកសាងពិភពលោកមួយដែលប្រកបដោយសន្តិភាព និងស្ថិរភាពប្រសើរជាងមុន។ PIC/PCAsia សង្ឃឹមថា ការរួមចំណែកពីសំណាក់អ្នកជំនាញនិងពលរដ្ឋក្នុងសៀវភៅនេះអាចផ្តល់ជាទស្សនៈថ្មីៗសម្រាប់សមាជិក សមាជិកាសភានៅក្នុងដំណើរការបំពេញមុខងាររបស់ខ្លួនដើម្បីសម្រេចគោលដៅទាំងនេះដែលរួមចំណែកជួយកសាងអនាគតមួយប្រកបដោយបរិស្ថានស្អាត មានសន្តិភាព សុវត្ថិភាព វិបុលភាព សម្រាប់យើងទាំងអស់គ្នា។



ស្ពានឆ្លងទន្លេកាម៉ានៅជិតទីក្រុង Perm ប្រទេសរុស្ស៊ី ឥឡូវនេះជាផ្នែកមួយនៃផ្លូវសូត្រថ្មី ដែលភ្ជាប់កំពង់ផែសមុទ្រនៅមហាសមុទ្រប៉ាស៊ីហ្វិកជាមួយប្រទេសនៅអឺរ៉ុប។
Sergei Prokudin-Gorskii

ជំពូកទី

# ០១

# តួនាទីសភាក្នុងការតទល់នឹងបញ្ហាប្រឈមឆ្លងដែន៖ ទស្សនទានមួយបែបអឺរ៉ុប


ទំ.១៨ | ១.១ ការកសាងពហុភាគីនិយមថ្មីនៅអឺរ៉ុប និងអាស៊ី
*ដោយ មីហៃ្យល ហ្វូសហៃ្យ*

ទំ.២១ | ១.២ ការពង្រឹងភាពជាដៃគូសភាសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព
*ដោយ បណ្ឌិត ឈាង វណ្ណរិទ្ធិ*

ទំ.២៤ | ១.៣ តួនាទីសភាក្នុងការតទល់នឹងបញ្ហាប្រឈមឆ្លងដែន៖ ទស្សនទានមួយបែបអឺរ៉ុប
*ដោយ ហ៊្សាវីយេ៉ នូទីន*

ទំ.២៨ | ១.៤ ផលប៉ះពាល់នៃកូវីដ-១៩ និងការឆ្លើយតប

ទំ.២៨ | ១.៤.១ ការឆ្លើយតបរបស់តណ្ឌាលោសីទៅនឹងវិបត្តិកូវីដ-១៩
*ដោយ ដេវី អាមីលៀ ត្រេស្នា វីចាយ៉ានទី &*
*លោក ហឺរីយូណូ អាឌី អាំងគូរ*

ទំ.៣១ | ១.៤.២ ផលប៉ះពាល់នៃកូវីដ-១៩ លើភាពក្រីក្រនៅកម្ពុជា
*ដោយ បណ្ឌិត លន់ ពេជ្រតារា*

ទំ.៣៥ | ១.៤.៣ សភានៅអឺរ៉ុបប្រឈម នឹងវិបត្តិកូវីដ-១៩
*ដោយ បណ្ឌិត ឈាង វណ្ណរិទ្ធិ*

ទំ.៣៩ | ១.៥ តើសភាអាចមានភាពនិម្មិតបានក្នុងកម្រិតណា ?
*ដោយ បណ្ឌិត ម៉ូរីហ្ស៍ វុន វីស្ស៍*

# ១.១ ការកសាងពហុភាគីនិយមថ្មីនៅអឺរ៉ុប និងអាស៊ី

## អំពីពហុភាគីនិយម

> “ពហុភាគីនិយមជាទម្រង់ស្ថាប័នមួយដែលសម្របសម្រួលទំនាក់ទំនងរវាងរដ្ឋបី ឬច្រើន ដោយផ្អែកលើមូលដ្ឋាននៃគោលការណ៍ប្រតិបត្តិរួម ។ គោលការណ៍នេះ បញ្ជាក់ច្បាស់ពីការអនុវត្តសមស្របតាមប្រភេទសកម្មភាព ដោយមិនគិតពីផលប្រយោជន៍ពិសេស (particularistic interests) ឬ យុទ្ធសាស្ត្របន្ទាន់របស់ភាគី ដែលអាចកើតមានឡើងក្នុងកាលៈទេសៈជាក់លាក់ណាមួយ [១, ទំ. ៥៧១]។”

ពហុភាគីនិយមបង្កប់នូវអត្ថន័យពីសមត្ថភាពក្នុងការលះបង់ផលប្រយោជន៍រយៈពេលខ្លីដើម្បីផលប្រយោជន៍រយៈពេលវែងក្នុងបុព្វហេតុនៃគុណតម្លៃរួម។ ក្នុងន័យនេះ សហភាពអឺរ៉ុបបានទទួលយកនូវឥទ្ធិពលនៃទម្រង់នេះចាប់តាំងពីការកកើតសហភាពអឺរ៉ុបដំបូង ក្នុងប្រភេទជាអង្គការពហុភាគី ដែលឲ្យតម្លៃលើគោលដៅរួមនៃកិច្ចសហប្រតិបត្តិការ និងសមាហរណកម្មតំបន់ស្មើនឹងផលប្រយោជន៍ជាតិ។ ក្នុងកម្រិតសកល រដ្ឋជាសមាជិកនៃសហភាពអឺរ៉ុបតែងតែគាំទ្រការប្រើប្រាស់ប្រព័ន្ធដ៏រឹងមាំសម្រាប់ដោះស្រាយជម្លោះ និងរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ និងគាំទ្រស្ថាប័នអន្តរជាតិនានា រាប់បញ្ចូលទាំងអង្គការអាកាសចរណ៍អន្តរជាតិ (ឆ្នាំ១៩៩៤) រហូតដល់អង្គការពាណិជ្ជកម្មពិភពលោក (១៩៩៥) អង្គការយូណេស្កូ តុលាការយុត្តិធម៌អន្តរជាតិ កម្មវិធីស្បៀងអាហារពិភពលោក អង្គការសុខភាពពិភពលោក UNDP ឬ UNEP និងក្រុមធនាគារពិភពលោក។ ដើម្បីគាំទ្របុព្វហេតុទាំងនេះ ប្រទេសជាសមាជិកនៃសហភាពអឺរ៉ុបចូលរួមចំណែកនូវថវិកា ៤០% នៃថវិកាបច្ចុប្បន្នរបស់អង្គការសហប្រជាជាតិ។

## វិបត្តិបច្ចុប្បន្ននៃពហុភាគីនិយម

ឥរិយាបថសហការគ្នានេះកំពុងតែទទួលការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ ហើយអ្វីដែលជាចំណុចល្អរួមកាន់តែពិបាកកំណត់។ រដ្ឋបាលសហរដ្ឋអាម៉េរិកបច្ចុប្បន្នកំពុងតែបំផ្លាញមួយចំណែកធំនូវអ្វីដែលជាមូលដ្ឋានគ្រឹះស្ថាប័ននៃសកលភាវូបនីយកម្ម និងបានបំផ្លាញទំនុកចិត្តដែលធុរកិច្ចអន្តរជាតិតែងតែមានពីប្រតិបត្តិការនានាដែលអាចស្មានទុកជាមុនបានដោយផ្អែកលើប្រព័ន្ធមួយដែលឈរលើមូលដ្ឋានច្បាប់។

យន្តការនៃមជ្ឈត្តកម្មពាណិជ្ជកម្មរបស់អង្គការពាណិជ្ជកម្មពិភពលោកត្រូវបានរាំងស្ទះតាំងពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៩ ដោយការបដិសេធរបស់ប្រតិភូអាម៉េរិកក្នុងការចាត់តាំងចៅក្រមថ្មីនៅក្នុងស្ថាប័នឧទ្ធរណ៍របស់អង្គការពាណិជ្ជកម្មពិភពលោក។ នៅក្នុងឆ្នាំ២០២០ ក្នុងអាកប្បកិរិយាស្រដៀងគ្នានេះ សហរដ្ឋអាម៉េរិកនៅតែស្ថិតនៅក្រៅកិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្តីពីការប្រែប្រួលអាកាសធាតុដដែល។ សេតវិមាន (White House) បច្ចុប្បន្នបានគាំទ្រការដកខ្លួនរបស់អង់គ្លេសចេញពី សហភាពអឺរ៉ុប (Brexit) និងគាំទ្រកិច្ចខិតខំប្រឹងប្រែងនានាដែលធ្វើឲ្យភាពរួបរួមគ្នាក្នុងសហភាពអឺរ៉ុបចុះខ្សោយ។ នេះជាលើកដំបូងហើយចាប់តាំងពីឆ្នាំ១៩៥០មកដែលរដ្ឋបាលអាម៉េរិកមិនចូលរួមពេញលេញក្នុងប្រតិបត្តិការសមាហរណកម្មរបស់សម្ព័ន្ធមិត្តអឺរ៉ុបរបស់ខ្លួន។

ជម្លោះពាណិជ្ជកម្មនិងពន្ធគយរវាងសហរដ្ឋអាម៉េរិកជាមួយចិន កាណាដា ម៉ិកស៊ិក ប្រេស៊ីល បារាំង អាល្លឺម៉ង់ ជប៉ុន និងកូរ៉េខាងត្បូង កំពុងរំខានជាពិសេសដល់ពួកក្រុមសម្ព័ន្ធមិត្តយុទ្ធសាស្ត្រ។ ការរុះរើជាប្រព័ន្ធនៃសណ្តាប់ធ្នាប់អន្តរជាតិក្រោយឆ្នាំ១៩៤៥ កំពុងត្រូវបានធ្វើឡើងដោយស្ថាបនិកដំបូងដ៏សំខាន់មួយរបស់ប្រព័ន្ធនេះ។ ជាលទ្ធផល “ឆ្មានៃពាណិជ្ជវិស័យនិយម (mercantilist cat) មួយត្រូវបានព្រលែងឲ្យចេញពីបាវ”។ អ្វីដែលជាហានិភ័យនោះគឺពិភពលោកត្រូវបែកបាក់ជាប្លុកពាណិជ្ជកម្មតំបន់ ជាក់ស្តែងគឺ ប្លុកសហរដ្ឋអាម៉េរិក សហភាពអឺរ៉ុប និងចិន[២]។

កត្តាផ្សេងៗទៀតកំពុងតែលេចឡើង ធ្វើឲ្យមានការធ្លាក់ចុះនូវកិច្ចសហប្រតិបត្តិការ និងនាំទៅរកការបង្កើតឲ្យមានគោលនយោបាយមួយដែលត្រូវធ្វើឲ្យមានតុល្យភាពអំណាចជាងមុន ជាពិសេសនៅអាស៊ី ជាកន្លែងដែលមានស្ថានភាពផ្ទុយគ្នាពីអឺរ៉ុប ដែលមិនមានផែនការសន្តិសុខ (security matrix) នោះទេ [១, ទំ. ៥៦២] [B]។

ដូចនេះហើយ បើសិនជាពហុភាគីនិយមមិនទាន់មានសភាព «ធ្លាក់ចុះទន់ខ្សោយបំផុត» នៅឡើយ នោះទាមទារឲ្យមានការបង្កើតជាបន្ទាន់នូវទម្រង់ វិសាលភាព និងព្រំដែនថ្មីសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ ដែលអ្នកជំនាញហៅថា «ពហុជាតិ» [៣]។ ការគំរាមកំហែងនិងបញ្ហាប្រឈមនានាកំពុងតែមានសភាពកាន់តែធ្ងន់ធ្ងរ ហើយបញ្ហាអន្តរជាតិមួយចំនួនមិនអាចដោះស្រាយបានតាមវិធីសាស្ត្រទ្វេភាគីដ៏សាមញ្ញបាននោះទេ ឧទាហរណ៍ដូចជា បញ្ហាបរិស្ថាន កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីថ្មីដែលពឹងផ្អែកលើច្បាប់ ដំណើរការនៃប្រព័ន្ធហិរញ្ញវត្ថុអន្តរជាតិ សន្តិសុខទូរគមនាគមន៍ និងភេរវកម្ម។

ចំពោះគ្រប់បញ្ហានីមួយៗ កិច្ចពិភាក្សា «ពហុជាតិ» បង្ហាញនូវផ្លូវឆ្ពោះទៅមុខដែលអាចធ្វើទៅបាន។ ឧទាហរណ៍ សហភាពអឺរ៉ុបនិងចិនអាចធ្វើការដោះស្រាយបញ្ហាពាក់ព័ន្ធនឹង WTO ព្រោះចិនត្រូវការស្ថិរភាពពាណិជ្ជកម្មដែលផ្អែកលើច្បាប់ ដរាបណារាល់កិច្ចព្រមព្រៀងស្តីពី ការការពារវិនិយោគផ្ទាល់ពីបរទេសត្រូវរៀបចំដោយប្រទេសចិន។ សហភាពអឺរ៉ុបក៏អាចចូលរួមក្នុងកិច្ចពិភាក្សាជាមួយចិនទាក់ទងនឹងការអភិវឌ្ឍប្រកបដោយចីរភាព និងការលើកស្ទួយសេដ្ឋកិច្ចដែលអំណោយផលដល់បរិស្ថានជាងមុន ហើយសមស្របជាមួយពាណិជ្ជកម្ម។ ការដឹងពីហានិភ័យដែលបន្សល់ទុកពីការបរាជ័យនៃសេដ្ឋកិច្ចសន្តិសហត្ថិភាព (peaceful economic coexistence) ដែលមានស្រាប់ បាននាំឲ្យបារាំងនិងអាល្លឺម៉ង់បង្កើតបាននូវសម្ព័ន្ធភាពដើម្បីពហុភាគីនិយមថ្មីមួយនៅអង្គការសហប្រជាជាតិ នាទីក្រុងញូវយ៉ក កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៩ ដែលពេលនេះមានប្រទេសជាង៦០ នៅទូទាំងពិភពលោកបានចូលជាសមាជិក ក្នុងនោះរួមមាន កាណាដា ម៉ិកស៊ិក ស៊ីលី សិង្ហបុរី និងហ្គាណាផងដែរ។

## សម្ព័ន្ធភាពដើម្បីពហុភាគីនិយម

«សម្ព័ន្ធភាពដើម្បីពហុភាគីនិយម» បង្កើតឡើងដោយរដ្ឋមន្ត្រីការបរទេសបារាំងនិងអាល្លឺម៉ង់ គឺជាបណ្តាញក្រៅផ្លូវការមួយ នៃបណ្តាប្រទេសដែលមានជំនឿរួមគ្នាថា សណ្តាប់ធ្នាប់ពហុភាគីដែលផ្អែកលើច្បាប់ គឺជាវិធីតែមួយគត់ដែលអាចធានាបាននូវសន្តិភាពនិងស្ថិរភាពអន្តរជាតិ ហើយមានតែតាមរយៈកិច្ចសហប្រតិបត្តិការប៉ុណ្ណោះ ដែលអាចឲ្យយើងដោះស្រាយបញ្ហារួមនានាបាន។

ក្នុងកាលៈទេសៈមួយដែលគោលការណ៍គន្លឹះ នៃសណ្តាប់ធ្នាប់អន្តរជាតិផ្អែកលើច្បាប់ និងលិខិតូបករណ៍សំខាន់ៗនៃកិច្ចសហប្រតិបត្តិការអន្តរជាតិកំពុងតែជួបនឹងបញ្ហាប្រឈម សម្ព័ន្ធភាពដើម្បីពហុភាគីនិយមមានបំណងបង្រួបបង្រួមប្រទេសទាំងឡាយដែលជឿជាក់លើភាពខ្លាំង និងប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការពហុភាគី។ រាល់ប្រទេសដែលបានរួមដៃក្នុងការធ្វើសកម្មភាពសម្រាប់បុព្វហេតុនេះជឿជាក់ ថាគោលបំណងនិងគោលការណ៍នៃច្បាប់អន្តរជាតិ យុត្តិធម៌ និងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ គឺជាគ្រឹះដែលមិនអាចខ្វះបានសម្រាប់ការធានាឲ្យបាននូវសន្តិភាព ស្ថិរភាព និងវិបុលភាព។

សម្ព័ន្ធភាពនេះមានបំណងស្តារឡើងវិញនូវការប្តេជ្ញាចិត្តជាសកលចំពោះសណ្តាប់ធ្នាប់អន្តរជាតិមួយដែលផ្អែកលើច្បាប់ លើកស្ទួយគោលការណ៍នេះ និងធ្វើការកែសម្រួលត្រង់ចំណុចណាដែលចាំបាច់។ គោលដៅរបស់សម្ព័ន្ធភាពនេះគឺ៖

- ការពារ និងរក្សាទំនៀមទំលាប់អន្តរជាតិ កិច្ចព្រមព្រៀង និងស្ថាប័ននានា ដែលកំពុងទទួលរងសម្ពាធ ឬការបំផ្លិចបំផ្លាញ
- ប្រកាន់យករបៀបវារៈដែលមានភាពបុរេសកម្មជាងមុន នៅក្នុងផ្នែកណាមួយនៃគោលនយោបាយដែលខ្វះអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាព និងទប់ទល់ឲ្យបានទៅនឹងបញ្ហាប្រឈមថ្មីនានាដែលទាមទារការអនុវត្តសកម្មភាពរួមគ្នា និង
- ជំរុញកំណែទម្រង់ផ្សេងៗដោយមិនបោះបង់នូវគោលការណ៍និងគុណតម្លៃគន្លឹះនានា ដើម្បីធ្វើឲ្យស្ថាប័នពហុភាគី និងសណ្តាប់ធ្នាប់នយោបាយនិងសេដ្ឋកិច្ចសកលមានបរិយាបន្ន និងប្រសិទ្ធភាពជាងមុនក្នុងការសម្រេចឲ្យបាននូវលទ្ធផលជាក់ស្តែងសម្រាប់ប្រជាជនទូទាំងពិភពលោក។

សម្ព័ន្ធភាពនេះនឹងជំរុញរបៀបវារៈពហុភាគីមួយដែលគោរពយ៉ាងពេញលេញនូវតួនាទីដ៏សំខាន់របស់អង្គការសហប្រជាជាតិ ក៏ដូចជាអនុលោមតាមគោលបំណងនិងគោលការណ៍នៃធម្មនុញ្ញរបស់អង្គការសហប្រជាជាតិនិងច្បាប់អន្តរជាតិ។ ដៃគូទាំងឡាយនៃសម្ព័ន្ធភាពនេះមានការប្តេជ្ញាចិត្តក្នុងការដើរតួជាកម្លាំងចលករក្នុងការការពារ អភិវឌ្ឍន៍ និងកែសម្រួលសណ្តាប់ធ្នាប់អន្តរជាតិមួយដែលផ្អែកលើនីតិរដ្ឋ។

ក្នុងវិស័យគោលនយោបាយការបរទេស ពហុភាគីនិយមមានន័យថា រដ្ឋទាំងឡាយសហការគ្នា ដើម្បីជំរុញការសម្រេចគោលដៅរួម ធ្វើឲ្យមានតុល្យភាព និងធ្វើនិយតកម្មផលប្រយោជន៍ដែលមានភាពប្រកួតប្រជែង។ ភាគីទាំងនោះធ្វើបែបនេះព្រោះគេដឹងថា នៅចុងបញ្ចប់ រដ្ឋទាំងអស់ជាអ្នកទទួលបានផលច្រើនបំផុត ប្រសិនបើគេធ្វើការរួមគ្នានិងព្រមព្រៀងគ្នាអនុវត្តតាមច្បាប់។ កិច្ចសហប្រតិបត្តិការបែបនេះពឹងផ្អែកលើគោលការណ៍ និងគុណតម្លៃជាក់លាក់នានាដែលប្រកាន់យកដោយគ្រប់តួអង្គទាំងអស់។ ក្នុងសម័យសកលភាវូបនីយកម្ម ស្ទើរតែគ្រប់ប្រទេសនៅលើសកលលោកមានការទាក់ទងគ្នាទៅវិញទៅមក។ ជម្លោះដែលកើតមានឡើងក្នុងតំបន់មួយអាចនឹងជះឥទ្ធិពលដោយផ្ទាល់លើជីវិតរបស់ប្រជាជនដែលរស់នៅតំបន់ឆ្ងាយពីគ្នារាប់ពាន់ម៉ាល (mile)។ បាតុភូតមួយចំនួនដូចជា ការប្រែប្រួលអាកាសធាតុបង្កឡើងនូវបញ្ហាជាច្រើន ដែលមិនឈប់នៅត្រឹមព្រំដែននៃប្រទេសមួយទេ ដូចនេះហើយទើបនាពេលបច្ចុប្បន្នកិច្ចសហប្រតិបត្តិការពហុភាគីកាន់តែមានសារៈសំខាន់ជាងពេលណាៗទាំងអស់។

ក្នុងចំណោមកិច្ចផ្តួចផ្តើមនានាដែលត្រូវបានព្រមព្រៀងដោយសម្ព័ន្ធភាពដើម្បីពហុភាគីនិយម ក៏មានការទទូចឲ្យមានសកម្មភាពដើម្បីពង្រឹងការគោរពច្បាប់មនុស្សធម៌អន្តរជាតិ និងសកម្មភាពមនុស្សធម៌ដែលផ្អែកលើគោលការណ៍ពាក់ព័ន្ធនឹង៖ ទំនុកចិត្តនិងសន្តិសុខក្នុងលំហរទូរគមនាគមន៍ ភាពជាដៃគូអន្តរជាតិសម្រាប់ព័ត៌មាននិងប្រជាធិបតេយ្យ ជំហររួមមួយលើបញ្ហាបំរែបម្រួលអាកាសធាតុនិងសន្តិសុខ បច្ចេកវិទ្យានាពេលអនាគត ការរំសាយនិងគ្រប់គ្រងសព្វាវុធ ទំនិញនិងសេវាសាធារណៈសកលការពង្រឹងស្ថាប័នអន្តរជាតិ និងសមភាពយេនឌ័រ។

> “**សម្តីរបស់លោក Sovann Ke ក្នុងកិច្ចប្រជុំពេញអង្គស្តីពី ពហុភាគីនិយម[៤].**
>
> សម្រាប់លោក **Sovann Ke** (តំណាងអចិន្ត្រៃយ៍កម្ពុជាប្រចាំនៅអង្គការសហប្រជាជាតិ) អង្គការសហប្រជាជាតិជាស្ថាប័នតំណាង ដែលមានសមត្ថភាពបំផុតក្នុងការការពារគុណធម៌នៃពហុភាគីនិយម និងជាមធ្យោបាយមួយក្នុងចំណោមមធ្យោបាយដទៃទៀត ដែលសក្តិសមបំផុតក្នុងការទប់ទល់ជាមួយនឹងបញ្ហាប្រឈមនៅសតវត្សរ៍ទី២១នេះ។ តាមរយៈការធ្វើការរួមគ្នានេះហើយ ទើបសហគមន៍អន្តរជាតិអាចសម្រេចសមិទ្ធផលជោគជ័យសំខាន់ៗបាន។ លោកក៏បានលើកឡើងពីសន្ធិសញ្ញាទីក្រុងប៉ារីស និងរបៀបវារៈ២០៣០ ជាភស្តុតាងដែលឆ្លុះបង្ហាញពីឥទ្ធិពលដ៏ «លើសលុប» នៃការងារការទូត។ ក្នុងពេលជាមួយគ្នានោះផងដែរ លោកក៏បានធ្វើការរិះគន់លើឯកត្តោភាគីនិយមដែលធ្វើឲ្យប៉ះពាល់ជាអវិជ្ជមានដល់វិបុលភាពនៃសហគមន៍ទាំងមូល។ លោកបានលើកយកកម្ពុជាជាឧទាហរណ៍៖ កម្ពុជាបានទទួលសុខសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍឆាប់រហ័សក្នុងរយៈពេល២០ឆ្នាំ កន្លងមកនេះ ជាមួយនឹងកំណើនសេដ្ឋកិច្ចខ្ពស់៧%ក្នុងមួយឆ្នាំ។ ការណ៍នេះអាចសម្រេចបានទៅរួច ក៏ដោយសារតែពាណិជ្ជកម្ម ការទូត និងកិច្ចសហប្រតិបត្តិការ។ ជាការពិតណាស់ បើគ្មានពហុភាគីនិយម ឬកិច្ចសហប្រតិបត្តិការទេ សេដ្ឋកិច្ចនឹងកាន់តែធ្លាក់ចុះ មនុស្សកាន់តែក្រីក្រ ហើយរបៀបវារៈ២០៣០ នឹងនៅតែជាអ្វីដែលយើងមិនអាចឈោងទៅសម្រេចបាន។ លោកបានព្រមានថា ស្ថានការណ៍បែបនេះនឹងច្បាស់ជាបំផុសឲ្យកើតមានឡើងនូវមនោគមន៍វិជ្ជា និងជម្លោះដ៏គ្រោះថ្នាក់។”

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការ ដែលបកដោយវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិនៃកម្ពុជា (NIDIR)។ អ្នកអានអាចទាញយកអត្ថបទដើមជាភាសាអង់គ្លេសពីគេហទំព័រ៖ https://www.pic.org.kh ។

# ១.២ ការពង្រឹងភាពជាដៃគូសភាសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព

## សេចក្តីផ្តើម

ប្រព័ន្ធអន្តរជាតិកំពុងមានសភាពកាន់តែស្មុគស្មាញឡើង និងវិវឌ្ឍយ៉ាងរហ័សក្នុងទិសដៅឆ្ពោះទៅពិភពពហុភាពពិភពលោកមួយដែលមានភាពប្រទាក់ក្រឡាគ្នាដ៏ស្មុគស្មាញមានការពឹងផ្អែកគ្នាទៅវិញទៅមក និងមានលទ្ធភាពធ្វើអន្តរសកម្មភាពជាមួយគ្នា។ ប្រទេសជាតិទាំងឡាយកំពុងតែមានការពឹងផ្អែកគ្នាទៅវិញទៅមកកាន់តែខ្លាំង។ បញ្ហាសកលកាន់តែមានភាពប្រទាក់ក្រឡាគ្នាកាន់តែខ្លាំង។ ច្បាស់ណាស់ថា បច្ចុប្បន្ននេះគ្មានប្រទេសណាមួយអាចដោះស្រាយបញ្ហាសកលបានតែឯកឯងទេ ដូចជាបញ្ហាការប្រែប្រួលអាកាសធាតុ ភេរវកម្ម អំពើហិង្សាជ្រុលនិយម គ្រោះធម្មជាតិ និងជំងឺរាតត្បាតសកលជាដើម។ កិច្ចសហប្រតិបត្តិការពីគ្រប់ពហុភាគីដែលពាក់ព័ន្ធត្រូវបានទទួលស្គាល់ថា ជាវិធីសាស្ត្រចាំបាច់ចម្បងក្នុងការផ្តល់នូវដំណោះស្រាយគ្រប់ជ្រុងជ្រោយ និងមានប្រសិទ្ធភាពសម្រាប់បញ្ហាប្រឈមរួមទាំងនេះ ។ អត្ថបទនេះមានគោលបំណងបង្ហាញពីតួនាទីរបស់សភាក្នុងការដោះស្រាយបញ្ហាសកល ដោយសង្កត់ធ្ងន់លើការធ្វើឲ្យសម្រេចនូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព(SDGs) និងថា តើគេអាចប្រើភាពជាដៃគូសភាអាស៊ី-អឺរ៉ុបបែបណាដើម្បីជាយន្តការក្នុងការសម្រេចគោលដៅទាំងនេះ។

## តួនាទីរបស់សភាក្នុងការដោះស្រាយបញ្ហាសកល

បញ្ហាប្រឈមសកលនានាដូចជា ការប្រែប្រួលអាកាសធាតុ និងអំពើហិង្សាជ្រុលនិយមកាន់តែមានសភាពស្មុគស្មាញ និងមានឥទ្ធិពលឆ្លងហួសព្រំដែនជាតិ។ សភាបានចាប់ផ្តើមកែសម្រួលបែបបទប្រតិបត្តិការរបស់ខ្លួន ដើម្បីកំណត់ទីតាំងខ្លួនឯងក្នុងការដោះស្រាយបញ្ហាសកលនានាឲ្យមានប្រសិទ្ធភាព។ សភាបានទទួលស្គាល់ថាវិធីតែមួយគត់ដែលមានប្រសិទ្ធភាពក្នុងការដោះស្រាយបញ្ហាទាំងនេះ គឺមានតែតាមរយៈកិច្ចសហប្រតិបត្តិការអន្តរជាតិ និងភាពជាដៃគូប៉ុណ្ណោះ។

តួនាទីអន្តរជាតិមួយចំនួនរបស់សភា គឺរួមចំណែកក្នុងដំណើរការនៃការចរចាអន្តររដ្ឋាភិបាល និងក្នុងដំណើរការនៃការកសាងស្ថាប័ន អនុវត្តការត្រួតពិនិត្យរបស់សភាលើដំណើរការចរចាជាអន្តរជាតិ ផ្តល់សច្ចាប័ន និងពង្រឹងការអនុវត្តកិច្ចព្រមព្រៀងអន្តរជាតិនានា លើកកម្ពស់កិច្ចសន្ទនាពហុភាគីដែលពាក់ព័ន្ធពីបញ្ហាអន្តរជាតិ និងការឆ្លើយតបទៅនឹងបញ្ហាទាំងនេះ ព្រមទាំងផ្សព្វផ្សាយព័ត៌មានពីបញ្ហា និងអង្គការអន្តរជាតិនានាទៅកាន់ប្រជាពលរដ្ឋ។

បញ្ហាសកល និងការចូលរួមពីខាងក្រៅកាន់តែពាក់ព័ន្ធខ្លាំងសម្រាប់សភា និងប្រជាពលរដ្ឋ។ សមាជិក សមាជិកាសភាត្រូវធ្វើការប្រាស្រ័យឆ្លើយឆ្លង និងប្រមូលធាតុចូលសម្រាប់ម្ចាស់ឆ្នោត និងពីម្ចាស់ឆ្នោតរបស់ខ្លួន ជាពិសេសលើបញ្ហាអន្តរជាតិទាំងឡាយណា ដែលប៉ះពាល់ដល់សន្តិសុខសុខមាលភាពសេដ្ឋកិច្ចសង្គមរបស់ម្ចាស់ឆ្នោត។ ស្របពេលដែលការផ្តល់គំនិតយោបល់តាមបែបប្រជាធិបតេយ្យមានការកើនឡើង ដោយសារតែវត្តមានរបស់បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ (ICT) សមាជិក សមាជិកាសភាកាន់តែត្រូវធ្វើការប្រាស្រ័យឆ្លើយឆ្លងជាមួយម្ចាស់ឆ្នោតរបស់ខ្លួនឲ្យកាន់តែមានប្រសិទ្ធភាព ដើម្បីឆ្លើយតបទៅនឹងការរំពឹងទុកកាន់តែខ្ពស់របស់ពួកគេ។ ស្របពេលជាមួយគ្នានេះ សមាជិក សមាជិកាសភាដែលធ្វើការជាពិសេសលើបញ្ហាការបរទេស អាចអញ្ជើញថ្នាក់ដឹកនាំក្រសួង ស្ថាប័នរបស់រដ្ឋាភិបាល និងភ្នាក់ងាររដ្ឋ ដើម្បីរាយការណ៍ និងឆ្លើយតបទៅនឹងសំណួរដេញដោលលើបញ្ហាអន្តរជាតិ ការបរទេស និងគោលនយោបាយពាណិជ្ជកម្ម ដែលប៉ះពាល់ដល់ប្រជាពលរដ្ឋរបស់ខ្លួន។

## តួនាទីរបស់សភាក្នុងការសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព

ការកសាងភាពជាដៃគូសកលដើម្បីការអភិវឌ្ឍប្រកបដោយចីរភាពត្រូវបានបង្ហាញក្នុងគោលដៅទី១៧នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព(SDGs) របស់អង្គការសហប្រជាជាតិ។ ដូចដែលគោលដៅនេះចង់បង្ហាញ ភាពជាដៃគូអន្តរជាតិ និងកិច្ចសហប្រតិបត្តិការរវាងពហុភាគីដែលពាក់ព័ន្ធមានសារៈសំខាន់ណាស់ក្នុងការសម្រេចឲ្យបានSDGs។ SDGs ក៏បានសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃបរិយាបន្នពោលគឺការចូលរួមពីគ្រប់ផ្នែកនៃសង្គម ដើម្បីកៀរគរ និងចែករំលែកចំណេះដឹងនិងជំនាញ ក៏ដូចជាដើម្បីផ្តល់នូវ

ធនធានបច្ចេកទេស និងហិរញ្ញវត្ថុដែលចាំបាច់។ ស្ថាប័នសភាដែលដើរតួជាស្ពានយ៉ាងសំខាន់ក្នុងការតភ្ជាប់រដ្ឋ និងសង្គម គឺជាតួអង្គចូលរួមដ៏គន្លឹះមួយនៅក្នុងការកៀរគរធនធាន និងតម្រង់ទិសរបៀបវារៈជាតិឆ្ពោះទៅរកការសម្រេចឲ្យបាននូវគោលដៅតំបន់ និងអន្តរជាតិ។ ហេតុដូចនេះហើយ ភាពជាដៃគូរវាងរដ្ឋ-ឯកជន និងសង្គមស៊ីវិលមានសារៈសំខាន់ណាស់ក្នុងការធ្វើឲ្យកិច្ចសហការក្នុងការអនុវត្ត SDGs មានភាពរឹងមាំ។ គោលដៅទី១៦ នៃ SDG បង្ហាញយ៉ាងច្បាស់នូវសារៈសំខាន់នៃការលើកកម្ពស់សង្គមប្រកបដោយសន្តិភាព និងបរិយាបន្នសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។ សេចក្តីប្រកាសរបៀបវារៈ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិបានចែងថា «យើងទទួលស្គាល់នូវតួនាទីដ៏សំខាន់របស់សភាជាតិនីមួយៗតាមរយៈការអនុម័តច្បាប់ និងការអនុម័តថវិកា និងតួនាទីរបស់សភាក្នុងការធានាឲ្យបាននូវគណនេយ្យភាព ដើម្បីប្រសិទ្ធភាពនៃការអនុវត្តការប្តេជ្ញាចិត្ត»។

ដូចមានចែងនៅក្នុងសេចក្តីប្រកាសនេះ សភាមានតួនាទីសំខាន់បួនក្នុងការសម្រេចឲ្យបាននូវ SDGs ក្នុងនោះមានដូចជា មុខងារត្រួតពិនិត្យ មុខងារនីតិកម្ម មុខងារតំណាង និងការត្រួតពិនិត្យថវិកា។ ដើម្បីសម្រេចបាននូវបេសកកម្មនេះ សភាអាចបង្កើនការចូលរួមថ្នាក់ជាតិ ផ្តល់នូវវេទិកាសម្រាប់កិច្ចពិភាក្សា និងកិច្ចសន្ទនាជាតិ និងអន្តរជាតិ លើកទឹកចិត្តឲ្យមានការជជែកដេញដោល និងរកការឯកភាពរួមគ្នារវាងភាគីពាក់ព័ន្ធជាតិ ការបង្កើតក្របខ័ណ្ឌច្បាប់ដែលរឹងមាំដែលអាចលើកទឹកចិត្តភាគីពាក់ព័ន្ធទាំងអស់ឲ្យចូលរួមអនុវត្ត SDGs ប្រមូលធាតុចូលពីប្រជាពលរដ្ឋ និងក្រុមសង្គមស៊ីវិល បែងចែកមូលនិធិក្នុងកម្រិតសមស្រប និងធ្វើការត្រួតពិនិត្យ ដោយប្រើប្រាស់ការត្រួតពិនិត្យប្រចាំឆ្នាំលើរបាយការណ៍ សំណួមពរ និងការវាយតម្លៃពីវឌ្ឍនភាពនៃការអនុវត្ត SDGs ដែលធ្វើឡើងដោយគណៈកម្មការដែលពាក់ព័ន្ធ។

ការចូលរួមចំណែករបស់សភាក្នុងការធ្វើរបាយការណ៍វាយតម្លៃដោយស្ម័គ្រចិត្តថ្នាក់ជាតិ (VNRs) បានជួយដល់ការវាយតម្លៃ និងតាមដានពីវឌ្ឍនភាពនៃការអនុវត្ត SDGs។ តួនាទីគន្លឹះនៃ VNRs គឺការរៀបចំផែនការ ការធ្វើស្ថាបនីយកម្ម ការប្រមូលធាតុចូលនិងទិន្នន័យ ការសរសេរនិងត្រួតពិនិត្យឡើងវិញ ការធ្វើបទបង្ហាញនិងការបន្តតាមដាន។ លទ្ធផលរំពឹងទុករបស់ VNRs គឺការធ្វើឲ្យប្រសើរឡើងនូវភាពជាដៃគូនៃពហុភាគីដែលពាក់ព័ន្ធ និងការលើកកម្ពស់ការចូលរួមឲ្យបានសកម្ម ដោយមានការគោរពភាពជាម្ចាស់នៃគ្រប់ភាគីដែលពាក់ព័ន្ធ។ ជាងនេះទៅទៀត ការផ្តល់អាទិភាពទៅលើ SDGs ដោយធ្វើការរៀបចំផែនការអភិវឌ្ឍន៍ជាតិ លើកកម្ពស់ការយល់ដឹងសាធារណៈ និងការតស៊ូមតិលើគោលនយោបាយ ព្រមទាំងការអភិវឌ្ឍយន្តការវាយតម្លៃប្រកបដោយប្រសិទ្ធភាពនិងបរិយាបន្នទាក់ទងនឹងការអនុវត្ត SDGs ត្រូវបានចាត់ទុកថាជាបញ្ហាសំខាន់។

បញ្ហាប្រឈមចម្បងសម្រាប់សភា ជាពិសេសសភាក្នុងបណ្តាប្រទេសនៅអាស៊ី គឺការធ្វើយ៉ាងណាដើម្បីបង្កើនការចូលរួមនិងឥទ្ធិពលរបស់សភាលើរបៀបវារៈនៃ SDGs ដោយហេតុថា កម្មវិធីទាំងឡាយទាក់ទងនឹង SDGs ភាគច្រើនត្រូវបានរៀបចំនិងគ្រប់គ្រងដោយស្ថាប័ននីតិប្រតិបត្តិ។ វេទិកាសភាអន្តរជាតិដូចជា សហភាពអន្តរសភា (IPU) វេទិកាសភាអាស៊ី-ប៉ាស៊ីហ្វិក (APPF) វេទិកាសភាពិភពលោកស្តីពី ការអភិវឌ្ឍប្រកបដោយចីរភាព (WPFSD) និងកិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុប (ASEP) ត្រូវតែចំណាយកម្លាំង និងធនធានបន្ថែមទៀត ដើម្បីប្រមូលផ្តុំនូវការមូលមតិជាអន្តរជាតិ និងរៀបចំយុទ្ធសាស្ត្រចូលរួមទាក់ទងនឹង SDGs។

## តួនាទីនៃកិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុប (ASEP)

កិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុប (ASEP) គឺជាកិច្ចប្រជុំនៃសមាជិក សមាជិកាសភាមកពីអាស៊ី និងអឺរ៉ុប ដែលរៀបចំឡើងដើម្បីស្វែងរកធាតុចូលជាគោលនយោបាយ និងអនុសាសន៍ ដើម្បីផ្តល់ទៅកាន់កិច្ចប្រជុំអាស៊ី-អឺរ៉ុប (ASEM)។ ASEP គឺជាដៃនៃសភារបស់ ASEM ហើយកិច្ចប្រជុំដំបូងរបស់ ASEP ត្រូវបានធ្វើឡើងក្នុងឆ្នាំ១៩៩៦។ ដោយ ASEP ជាវេទិកាក្រៅផ្លូវការ ហេតុនេះសេចក្តីប្រកាសរបស់ ASEP មិនមានចំណងគតិយុត្តិទេ។

ASEP មានគោលដៅចម្បងពីរ។ ទី១ គឺជាវេទិកាសម្រាប់ទំនាក់ទំនងអន្តរសភា សម្រាប់ការផ្លាស់ប្តូរគំនិតយោបល់ និងការទូតរវាងសភានានា និងជាយានក្នុងការលើកកម្ពស់ការយោគយល់គ្នារវាងប្រជាជន និងរវាងប្រទេសនៅអាស៊ី និងអឺរ៉ុប។ ទីពីរ ASEP ផ្តល់នូវតំណភ្ជាប់រវាងសភានៅអាស៊ី និងអឺរ៉ុប ជាមួយនឹង ASEM ដែលធ្វើឲ្យសភាចូលរួមបានសកម្មក្នុងដំណើរការរបស់ ASEM ជាពិសេសក្នុងកិច្ចប្រជុំរៀងរាល់ពីរឆ្នាំម្តង។

ការសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) ជាផ្នែកគន្លឹះមួយនៃកិច្ចសហប្រតិបត្តិការដែលសម្របសម្រួលដោយកិច្ចប្រជុំអាស៊ី-អឺរ៉ុប (ASEM)។ ក្នុងសេចក្តីថ្លែងការណ៍រួមកាលពីឆ្នាំ២០១៨ ថ្នាក់ដឹកនាំ ASEM បានសង្កត់ធ្ងន់លើសារៈសំខាន់នៃភាពជាដៃគូពហុ

ភាគីដែលពាក់ព័ន្ធក្នុងការសម្រេចឲ្យបាននូវបរិយាបន្នសង្គម និងសេដ្ឋកិច្ច សង្គមប្រកបដោយចីរភាព និងការអភិវឌ្ឍ ដែលផ្ដោតសំខាន់លើប្រជាពលរដ្ឋ។ ជាងនេះទៅទៀត ថ្នាក់ដឹកនាំ ASEM ក៏បានស្នើឲ្យមានការផ្សារភ្ជាប់បញ្ហានៃទំនាក់ទំនង ASEM ជាមួយនឹងការអភិវឌ្ឍប្រកបដោយចីរភាពដើម្បីជួយដោះស្រាយរបៀបវារៈ២០៣០។ ទន្ទឹមនឹងនេះ នៅក្នុងសេចក្តីថ្លែងការណ៍នៃកិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុបលើកទី១០(ASEP10)បានផ្តោតសំខាន់លើសារៈសំខាន់នៃពហុភាគីនិយម និងភាពជាដៃគូអន្តរជាតិ ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍប្រកបដោយចីរភាព។

## សេចក្តីបញ្ចប់

សព្វថ្ងៃនេះ ស្ថាប័នសភាកំពុងតែដើរតួរកាន់តែសំខាន់ក្នុងការដោះស្រាយបញ្ហាសកលជាច្រើនដែលស្មុគស្មាញ និងប្រទាក់ក្រឡាគ្នា។ ទាក់ទងនឹង SDGs សភាមានតួនាទីសំខាន់ជាច្រើនដូចជា ការត្រួតពិនិត្យ ការតាក់តែងច្បាប់ និងការត្រួតពិនិត្យថវិកា។ ទោះជាយ៉ាងណាក៏ដោយ ដើម្បីបង្កើនឥទ្ធិពលរបស់ខ្លួនក្នុងការតម្រង់ និងចូលរួមអនុវត្ត SDGs សភាត្រូវតែពង្រឹងភាពជាអ្នកដឹកនាំ និងសមត្ថភាពស្ថាប័នរបស់ខ្លួន និងអភិវឌ្ឍយុទ្ធសាស្ត្រចូលរួមប្រកបដោយប្រសិទ្ធភាព។

ASEPជាវេទិកាមួយក្នុងចំណោមវេទិកាសភាអន្តរជាតិគន្លឹះផ្សេងទៀត ដែលអាចជួយលើកកម្ពស់កិច្ចសន្ទនា និងកិច្ចពិគ្រោះយោបល់ថ្នាក់សភាលើរបៀបវារៈ SDG ជាពិសេសក្នុងការកសាងភាពជាដៃគូអន្តរជាតិ និងកិច្ចសហការនៃពហុភាគីដែលពាក់ព័ន្ធចាំបាច់។ ក្នុងកិច្ចខិតខំប្រឹងប្រែងនេះ ការកសាងសមត្ថភាព ការចែករំលែកចំណេះដឹង និងកិច្ចខិតខំប្រឹងប្រែងរួមលើ SDGs ត្រូវតែមានការលើកកម្ពស់បន្តទៀត។

អនុសាសន៍ជាក់លាក់សម្រាប់ ASEP រួមមាន (១) លើកទឹកចិត្តសមាជិក ASEP ទាំងអស់ឲ្យចូលរួមក្នុងការវាយតម្លៃដោយស្ម័គ្រចិត្តថ្នាក់ជាតិ(VNR)សម្រាប់ប្រទេសរបស់គេនីមួយៗ និងបង្កើតយន្តការសម្រាប់ចែករំលែកចំណេះដឹងជុំវិញលទ្ធផលនៃការវាយតម្លៃដោយស្ម័គ្រចិត្តថ្នាក់ជាតិ (២) បង្កើតកម្មវិធីកសាងសមត្ថភាពដល់ប្រទេសកំពុងអភិវឌ្ឍដែលជាសមាជិក ASEP ស្តីពី SDGs សម្រាប់សមាជិក សមាជិកា និងមន្ត្រីសភា(៣) បង្កើតបេសកជនពិសេស ASEP ទទួលបន្ទុក SDGs ដើម្បីចូលរួមដោយប្រសិទ្ធភាពជាមួយនឹងសមាជិក សមាជិកាសភានៃ ASEP និងអង្គការអន្តរជាតិនានា ដូចជាអង្គការសហប្រជាជាតិជាដើម។

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការ ដែលបកដោយវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិនៃកម្ពុជា (NIDIR)។ អ្នកអានអាចទាញយកអត្ថបទដើមជាភាសាអង់គ្លេសពីគេហទំព័រ៖ https://www.pic.org.kh ។

## ១.៣ តួនាទីរបស់សភាក្នុងការទប់ទល់នឹងបញ្ហាប្រឈមឆ្លងដែន៖ ទស្សនៈមួយបែបអឺរ៉ុប

យើងរស់នៅក្នុងពិភពសកលភាវូបនីយកម្មដែលមានទាំងឱកាស និងបញ្ហាប្រឈម រួមមានទាក់ទងទៅនឹងបញ្ហាដូចជា ការកើនឡើងកម្ដៅផែនដី ពាណិជ្ជកម្ម ទេសន្តប្រវេសន៍ ការរក្សាជីវៈចម្រុះ ឧក្រិដ្ឋកម្មឆ្លងដែន អភិបាលកិច្ចសមុទ្រ និងការពង្រីកហួសព្រំដែនជាតិ ដែលបញ្ហាទាំងនេះទាមទារឲ្យមានការដោះស្រាយតាមរយៈកិច្ចសហប្រតិបត្តិការអន្តរជាតិ។ ដោយសារតែសកលភាវូបនីយកម្ម ធ្វើឲ្យមានភាពស្រពិចស្រពិលអំពី ព្រំដែនដែលត្រូវបានចាត់ទុកក្នុងគោលនយោបាយជាតិ និងនៅក្នុងគោលនយោបាយទំនាក់ទំនងអន្តរជាតិ។ ជាការពិតណាស់ អ្វីដែលត្រូវសម្រេចនៅទីក្រុងប៉េកាំង ឬវ៉ាស៊ីនតោន ដោយរដ្ឋាភិបាល ឬដោយទីផ្សារសកល ច្បាស់ជានឹងអាចជះឥទ្ធិពលដល់បច្ចុប្បន្ន និងអនាគតនៃប្រជាពលរដ្ឋនៅប្រទេសប្រេស៊ីល អេស្ប៉ាញ កម្ពុជា ឬនៅអូស្ត្រាលី។

បន្ទាប់ពីឆ្លងកាត់ប្រវត្តិសាស្ត្រដ៏យូរអង្វែងនៃជម្លោះបំផ្លិចបំផ្លាញ ជាបទពិសោធន៍ពេលនេះបណ្ដាប្រទេសនៅអឺរ៉ុបមានជាស្រេចនូវវិធីសាស្ត្រកិច្ចសហប្រតិបត្តិការអន្តរជាតិដ៏រឹងមាំ ដែលរៀបចំតាមរយៈស្ថាប័ន និងច្បាប់របស់សហភាពអឺរ៉ុប (EU) ក្នុងនោះរួមមានគោលការណ៍ចម្បងៗស្ដីពី ការផ្ទេរផ្នែកខ្លះនៃអធិបតេយ្យភាពជាតិទៅរដ្ឋាភិបាលសហភាព (supra-national level)។ មិនប្លែកទេ សហភាពអឺរ៉ុបគឺជាជើងឯកនៃពហុភាគីនិយម ដែលជឿជាក់យ៉ាងម៉ុតមាំលើប្រព័ន្ធពហុភាគីនិយមអាស្រ័យច្បាប់ ថាជាវិធីសាស្ត្រដ៏មានប្រសិទ្ធភាពបំផុតក្នុងការដោះស្រាយបញ្ហាប្រឈមរួមនាពេលបច្ចុប្បន្នដោយយុត្តិធម៌ និងមានការចូលរួម។

ទោះបីជាមានការប្រឆាំងទៅនឹងវិធីសាស្ត្រនេះ ពីសំណាក់មហាអំណាចក្នុងសហគមន៍អន្តរជាតិមួយចំនួនក៏ដោយ តែបណ្ដាប្រទេសនៅអាស៊ីបានទទួលស្គាល់វិធីសាស្ត្រនេះជារួមដូចដែលត្រូវបានបញ្ជាក់ក្នុងកិច្ចប្រជុំ ASEP ១០ នៅទីក្រុងព្រុចសែល កាលពីឆ្នាំ២០១៨។ ពហុភាគីនិយមជាប្រធានបទមួយក្នុងចំណោមប្រធានបទសំខាន់ពីរ នៃកិច្ចប្រជុំនោះ។ ពេលថ្មីៗនេះ ការប្ដេជ្ញាចិត្តរួមមួយត្រូវបានធ្វើឡើងក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេស ASEM ធ្វើឡើងនៅទីក្រុងម៉ាឌ្រីដ ប្រទេសអេស្ប៉ាញ ក្នុងខែធ្នូ ឆ្នាំ២០១៩ ក្រោមមូលបទ «អាស៊ី និង អឺរ៉ុប៖ រួមគ្នាដើម្បីពហុភាគីនិយមប្រកបដោយប្រសិទ្ធភាព» ។

ជាការពិតណាស់ វិធីតាមបែបអឺរ៉ុប និងអាស៊ីមានលក្ខណៈខុសគ្នា ទាំងលើវិធីសាស្ត្រ និងខ្លឹមសារ។ តាមបែបអឺរ៉ុប កិច្ចព្រមព្រៀងត្រូវចងដោយច្បាប់ ឯបែបអាស៊ី គឺនិយមការឯកភាពគ្នាបែបកុងសង់ស៊ុស និងការទុកចិត្តគ្នាផ្អែកលើទំនាក់ទំនងល្អ និងអធិបតេយ្យភាពជាតិ។ ទំនាក់ទំនងសេដ្ឋកិច្ចគឺជាអាទិភាពរបស់រដ្ឋាភិបាលនៃបណ្ដាប្រទេសនៅអាស៊ី ផ្ទុយទៅវិញការប្ដេជ្ញាចិត្តគោរពសិទ្ធិមនុស្ស ឬការទប់ស្កាត់ទៅនឹងការប្រែប្រួលអាកាសធាតុ ជាអាទិភាពដូចគ្នាចំពោះអឺរ៉ុប។ ទោះជាយ៉ាងនេះក៏ដោយ ទ្វីបទាំងពីរមានចំណាប់អារម្មណ៍ចម្បងដូចគ្នាប្រឆាំងទៅនឹងរបបគាំពារនិយម និងរបបឯកោនិយម ហើយទ្វីបទាំងពីរក៏យល់ស្របដូចគ្នាចំពោះតម្រូវការរក្សាប្រព័ន្ធពហុភាគីមួយបើកចំហរ។

ក្នុងខណៈពេលដែលសកលភាវូបនីយកម្មបាននាំមកនូវផលប្រយោជន៍ជាច្រើន ដូចជាការធ្វើឲ្យមនុស្សរាប់លាននាក់ក្នុងពិភពលោកចាកចេញពីភាពក្រីក្រ តែវាក៏បានធ្វើឲ្យមូលដ្ឋានគ្រឹះវប្បធម៌ សង្គម និងសេដ្ឋកិច្ចរបស់យើងមានអស្ថិរភាព បង្កភាពភ័យខ្លាច និងអសន្តិសុខក្នុងបណ្ដាប្រទេសជាច្រើនក្នុងទ្វីបអឺរ៉ុបផងដែរ។ មនុស្សភ័យខ្លាចថាពួកគេកំពុងតែបាត់បង់ភាពម្ចាស់ការលើអនាគតរបស់ខ្លួន ហើយមានអារម្មណ៍អសុវត្ថិភាពជាមួយស្ថានភាពបច្ចុប្បន្នរបស់ពួកគេ។ ការណ៍នេះបាននាំឲ្យមានការប្រឆាំងទៅ «ក្រុមវរជន និងក្រុមការិយាធិបតេយ្យដែលមានគម្លាតឆ្ងាយពីពួកគេ» ហើយជាអ្នកធ្វើ សេចក្ដីសម្រេចចិត្តនានា ស្របពេលជាមួយនឹងការកើនឡើងនៃការប្រឆាំងទៅនឹងពហុវប្បធម៌និយម ដែលនាំឲ្យលេចចេញនូវការពង្រឹងគោលនយោបាយប្រជានិយមនៅស្ទើរពាសពេញទ្វីបអឺរ៉ុប។ សព្វថ្ងៃនេះ មេដឹកនាំនយោបាយជាច្រើនកំពុងប្រឈមនឹងការខ្វះសេចក្ដីទុកចិត្តពីប្រជាពលរដ្ឋ ដោយបានចាត់ទុកអ្នកនយោបាយទាំងនោះថា ជាផ្នែកមួយនៃពិភពលោកដ៏សែនឆ្ងាយដាច់ពីស្ថានភាពពិតរបស់ពួកគេ។ គម្លាតរវាងអ្នកធ្វើសម្រេចចិត្ត និងអ្នកបោះឆ្នោតកាន់តែរីកធំ ដូចមានស្ដែងចេញនៅក្នុងការជជែកដេញដោលទាក់ទងនឹងវិបត្តិនៃប្រជាធិបតេយ្យក្នុងប្រព័ន្ធអភិបាលកិច្ច។

សកលភាវូបនីយកម្មក៏បានគាំទ្រដល់ការកសាងស្ថាប័នអន្តរជាតិ៖ អង្គការពហុភាគីនានាបានរីកសាយភាយតាំងពីទសវត្សរ៍ ១៩៩០ ដើម្បីគ្រប់គ្រងដំណើរការ និងឥទ្ធិពល

នៃសកលភាវូបនីយកម្ម។ អង្គការទាំងនេះត្រូវបានបង្កើតឡើងដើម្បីជំរុញស្ថិរភាពតំបន់គ្រប់គ្រងជម្លោះ គាំទ្រការរីកលូតលាស់នៃសេដ្ឋកិច្ច កាត់បន្ថយគម្លាតអភិវឌ្ឍន៍ កសាងវិបុលភាព និងដោះស្រាយបញ្ហាប្រឈមសកល ដោយផ្អែកលើទិដ្ឋភាពច្បាប់។ អង្គការទាំងនេះមានទម្រង់ខុសៗគ្នា រាប់ចាប់ពីអង្គការដែលបានធ្វើសមាហរណកម្មយ៉ាងស៊ីជម្រៅ ដូចជាសហភាពអឺរ៉ុប រហូតដល់អង្គការដែលទន់ខ្សោយដូចជាសមាគមសម្រាប់កិច្ចសហប្រតិបត្តិការតំបន់អាស៊ីខាងត្បូង (SAARC) ជាដើម។

កាន់តែញឹកញាប់ ការធ្វើសេចក្តីសម្រេចចិត្តលើបញ្ហាគោលនយោបាយគន្លឹះដែលប៉ះពាល់ដល់ប្រជាពលរដ្ឋច្រើនតែងត្រូវបានយកមកពិភាក្សា និងសម្រេចក្នុងក្របខ័ណ្ឌតំបន់ និងពហុភាគី៖ ពី WTO រហូតដល់ APEC អំពីបញ្ហាពាណិជ្ជកម្ម និងការអភិវឌ្ឍសេដ្ឋកិច្ច ពី EAS និង ARF ដល់ NATO អំពីបញ្ហាសន្តិសុខ ពី UNFCC ដល់ AOSIS អំពីបញ្ហាបម្រែបម្រួលអាកាសធាតុ។ ក្រុមប្រទេស G20 ក៏ពិភាក្សាលើបញ្ហាទាំងអស់នេះដែរ។ នេះគឺដោយសារតែបញ្ហាដែលមានលក្ខណៈសកលមានចំនួនកាន់តែច្រើនឡើង ហើយកាន់តែមានភាពស្មុគស្មាញផ្នែកបច្ចេកទេស។ ការធ្វើសេចក្តីសម្រេចចិត្តទាំងនេះភាគច្រើនត្រូវបានធ្វើឡើងដោយគ្មានការត្រួតពិនិត្យពីស្ថាប័នតំណាងជាតិ ដូចជាសភា ដែលនាំឲ្យសភាពិបាកក្នុងការអនុវត្តមុខងារត្រួតពិនិត្យ និងវិនិច្ឆ័យទៅលើស្ថាប័នលើជាតិទាំងនោះ។ នេះគឺជាចំណុចខ្សោយដ៏ធំមួយ ដែលនាំឲ្យមានកង្វះការគាំទ្រពីប្រជាពលរដ្ឋកម្រិតមធ្យម លើសេចក្តីសម្រេចចិត្តដែលធ្វើឡើងដោយស្ថាប័នទាំងនោះ។ និយាយជាទូទៅ ដំណើរការសមាហរណកម្មតំបន់ពិតជាទទួលរងការលំបាកពីឱនភាពប្រជាធិបតេយ្យ៖ វិធីសាស្ត្រសម្រេចពីថ្នាក់លើមកក្រោមតែងត្រូវប្រើជាញឹកញាប់ ហើយការចូលរួមពីភាគីពាក់ព័ន្ធផ្សេងៗនៅមានកម្រិត រួមមានកង្វះការចូលរួមទាំងពីសមាជិក សមាជិកាសភាដែលជាប់ឆ្នោត និងតំណាងសង្គមស៊ីវិល។

នៅពេលដែលការធ្វើសេចក្តីសម្រេចចិត្តធំៗ កំពុងត្រូវបានធ្វើឡើងដាច់កាន់តែឆ្ងាយពីប្រជាពលរដ្ឋ ការអភិវឌ្ឍចម្បងនិងដោយឡែកមួយផ្សេងទៀតក៏កំពុងកើតមានឡើង៖ គោលនយោបាយ និងការសម្រេចចិត្តរបស់រដ្ឋាភិបាលស្ថិតនៅក្រោមការពិនិត្យវិនិច្ឆ័យកាន់តែខ្លាំងពីក្រុមសង្គមស៊ីវិល បណ្តាញព័ត៌មាន និងប្រជាជនសាមញ្ញ។ អ្នកបោះឆ្នោតទទួលបានការអប់រំប្រសើរជាងមុន ដោយចេះប្រើជាប្រយោជន៍ដ៏ពេញលេញពីប្រព័ន្ធព័ត៌មានសង្គម ដែលនាំឲ្យមានការផ្លាស់ប្តូរដំណើរការប្រជាធិបតេយ្យ៖ ប្រជាពលរដ្ឋងាយស្រួលទទួលបានព័ត៌មានសំបូរបែបងាយស្រួលបញ្ចេញមតិយោបល់ និងងាយស្រួលសាកល្បងជះឥទ្ធិពលដោយផ្ទាល់ដល់ការធ្វើសេចក្តីសម្រេចចិត្ត។

នេះគឺជារឿងល្អមួយ៖ ជាធម្មតាត្រូវតែមានការចូលរួមពីប្រជាពលរដ្ឋ ដើម្បីឲ្យមានការទទួលស្គាល់ពីសាធារណជនលើគោលនយោបាយ និងកិច្ចព្រមព្រៀងអន្តរជាតិដែលប៉ះពាល់ផ្ទាល់ដល់ជីវភាពរបស់ពួកគេ។ សាធារណជនពេលនេះរំពឹងថា មេដឹកនាំនឹងធ្វើសកម្មភាពប្រកបដោយតម្លាភាព និងតាមរបៀបរបបប្រជាធិបតេយ្យ។ ព័ត៌មានកិច្ចសន្ទនា និងការចូលរួម គឺជាពាក្យគន្លឹះក្នុងការអះអាងពីភាពស្របច្បាប់។ តម្រូវការឲ្យភាពស្របច្បាប់ និងគណនេយ្យភាពកំពុងតែកើនឡើងគ្រប់ទីកន្លែង។

ក្នុងបរិបទនៃការប្រឈមជាសកល និងការរំពឹងទុកបែបប្រជាធិបតេយ្យថ្មី តួនាទីរបស់សមាជិក សមាជិកាសភាគឺពិតជាសំខាន់។ ក្នុងនាមជាអ្នកតំណាងឲ្យប្រជាពលរដ្ឋសមាជិក សមាជិកាសភាត្រូវតែបញ្ចេញសម្លេងនៅក្នុងការជជែកដេញដោល និងការចរចាពីកិច្ចការសកល ត្រូវព្យាយាមតម្រង់ និងជះឥទ្ធិពលលើគោលនយោបាយ និងធ្វើសកម្មភាពការទូតឲ្យស្របទៅនឹងការទូតនៃអង្គនីតិប្រតិបត្តិដែរ។ ការទូតសភាបំពេញបន្ថែមនូវភាពស្របច្បាប់ ភាពស្និតស្នាញ និងទម្ងន់ផ្នែកនយោបាយលើការធ្វើសេចក្តីសម្រេចចិត្តនានា។ ការណ៍នេះអាចសម្រេចបានដោយសភាជាតិ ដោយការរួមចំណែក និងការពិនិត្យតាមដានការអនុវត្តគោលនយោបាយរបស់ប្រទេសខ្លួន ដើម្បីដោះស្រាយបញ្ហាសកលនានា (ដូចដែលបានឃើញថ្មីៗនេះ ក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអឺរ៉ុប-កាណាដា ឬ CETA)។

នេះពិតជាសំខាន់ និងមានប្រយោជន៍ ប៉ុន្តែកិច្ចសហប្រតិបត្តិការអន្តរជាតិដើម្បីដោះស្រាយបញ្ហាប្រឈមឆ្លងដែនជាញឹកញាប់ត្រូវបានដោះស្រាយរួមគ្នាដោយអង្គការពិភពលោក អង្គការតំបន់ និងអនុតំបន់។ ហេតុដូចនេះហើយកិច្ចប្រតិបត្តិការរួមពហុភាគីបានក្លាយជាព្រំដែនថ្មីសម្រាប់សមាជិក សមាជិកាសភា ដែលតែងរំពឹងចង់ឃើញអង្គការអន្តររដ្ឋាភិបាលកាន់តែមានគណនេយ្យភាព និងតម្លាភាព។

នេះប្រហែលជាមិនមែនជារឿងងាយស្រួលទេ ព្រោះរដ្ឋអធិបតេយ្យមានការស្ទាក់ស្ទើរក្នុងការប្រគល់អំណាចទៅឲ្យអង្គនីតិប្បញ្ញត្តិជាតិរបស់គេ។ ការមិនចង់ផ្តល់អំណាចដល់សភាថ្នាក់លើជាតិ កាន់តែខ្លាំងជាងនេះទៅទៀត (សភាអឺរ៉ុបត្រូវប្រឈមនឹងបញ្ហានេះជារៀងរាល់ថ្ងៃ)។ ដើម្បីសម្រេចបានភាពស្របច្បាប់កម្រិតខ្ពស់ថែមទៀត និងដើម្បីឲ្យអង្គការតំបន់មានគណនេយ្យភាព និងដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមរួម សភាតំណាងតំបន់ត្រូវតែបង្កើតឡើង និងទទួល

បានការពង្រឹង ដើម្បីចូលរួមចំណែក និងត្រួតពិនិត្យលើការធ្វើសេចក្តីសម្រេចចិត្តដែលធ្វើឡើងដោយអង្គការទាំងនោះ។

អង្គការថ្នាក់តំបន់ និងអន្តរជាតិជាច្រើនជុំវិញពិភពលោក បានបង្កើតសភាតំណាងសម្រាប់ខ្លួនគេ (IPU, WTO, AIPA, APF, APA) ឬសភាតំបន់ (EP, PAP)។ ជាការពិតណាស់ អង្គការសភាទាំងនោះមានលក្ខណៈខុសៗគ្នាទៅលើរបៀបនៃការបង្កើត អំណាច និងនីតិវិធីអនុវត្តការងារ ប៉ុន្តែជាក់ស្តែង គឺស្ថាប័នសភាអន្តរជាតិទាំងនេះច្រើននៅមានភាពទន់ខ្សោយ ហើយតួនាទី ឥទ្ធិពល អំណាច និងជាតុចូលផ្នែកគោលនយោបាយនៅមានកម្រិត។

នេះមិនមានន័យថា ការទូតសភាគួរតែជំនួសការទូតបែបប្រពៃណីនោះទេ។ គោលការណ៍ទូទៅនៅតែរក្សាដដែល ពោលគឺ៖ អង្គនីតិប្រតិបត្តិរបស់រដ្ឋាភិបាលជាអ្នកតំណាងឲ្យរដ្ឋក្នុងការចរចាកិច្ចព្រមព្រៀងអន្តរជាតិ ហើយសភាជាអ្នកត្រួតពិនិត្យលើសកម្មភាពរបស់រដ្ឋាភិបាល និងជះឥទ្ធិពលលើគោលនយោបាយដែលធ្វើឡើងដោយរដ្ឋាភិបាលក្នុងការយកទៅចរចាលើកិច្ចព្រមព្រៀង ជាអ្នកផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងទាំងនោះ ជាអ្នកការអនុម័តច្បាប់ និងធ្វើវិភាជន៍ថវិកាសមស្រប ដើម្បីឲ្យរដ្ឋាភិបាលយកប្រការនៃកិច្ចព្រមព្រៀងទៅប្រើ និងជាអ្នកត្រួតពិនិត្យលើដំណើរការអនុវត្តទាំងមូលតែម្តង។

ប៉ុន្តែការចូលរួមរបស់សភាក្នុងវិស័យការទូតពិតជាមានប្រយោជន៍៖ សភាមិនចាំបាច់ប្តេជ្ញាធ្វើតាមដូចដែលអ្វីរដ្ឋាភិបាល បានរៀបចំទេ ហេតុដូចនេះហើយសភាអាចមានភាពងាយស្រួលក្នុងការបត់បែន ជាពិសេសក្នុងស្ថានភាពរសើប ឬពេលដែលមានការមិនឯកភាពគ្នាខ្លាំង។ សភាអាចស្នើ និងធ្វើការពិភាក្សារកដំណោះស្រាយប្រកបដោយនវានុវត្តន៍។ ការចូលរួមរបស់សភាធ្វើឲ្យមានមធ្យោបាយសន្ទនាចម្រុះ ដែលផ្តល់ឱកាសបន្ថែមដើម្បីទាញយកផលប្រយោជន៍ ព្រោះសភាមិនមានតួនាទីជាផ្លូវការនៅក្នុងការចរចានោះទេ។ ឧទាហរណ៍៖ សភាអឺរ៉ុបមានទំនោរក្នុងការបង្ហាញសារត្រង់ៗពីបញ្ហាអភិបាលកិច្ច និងសិទ្ធិមនុស្ស ឬពីការចូលទៅកាន់ទីផ្សារដែលទាក់ទងនឹងចិន។ សារទាំងនេះជួយសម្រួលដល់ការងាររបស់រដ្ឋជាសមាជិករបស់សហភាពអឺរ៉ុប និងដាក់សម្ពាធលើគណៈកម្មការអឺរ៉ុបឲ្យរក្សាតុល្យភាពត្រឹមត្រូវរវាងគុណតម្លៃ និងផលប្រយោជន៍។

បន្ថែមពីលើនេះសភានៃបណ្តារដ្ឋជាសមាជិកសហភាពអឺរ៉ុប ដែលពិតជាមានឥទ្ធិពលផ្ទាល់លើគោលនយោបាយក្នុងស្រុក និងសកលតាមរយៈកិច្ចដេញដោលនៅក្នុងសភារបស់ខ្លួន ការវិភាជន៍ថវិកា សវនការ និងការធ្វើសេចក្តីសម្រេច សភាអឺរ៉ុប (EP) នៅតែត្រូវបានទទួលស្គាល់ជាផ្លូវការថា ជាស្ថាប័នតំណាងដែលកើតឡើងពីការបោះឆ្នោតរបស់ EU ហើយសមាជិករបស់សភានេះ មានការចូលរួមដោយផ្ទាល់ក្នុងការធ្វើសេចក្តីសម្រេចចិត្ត៖ EP ជាអ្នកធ្វើច្បាប់រួមគ្នាជាមួយក្រុមប្រឹក្សាអឺរ៉ុបក្នុងបញ្ហាជាច្រើន លើកលែងតែបញ្ហាការបរទេស និងពន្ធ។ EP អនុម័ត ឬច្រានចោលច្បាប់និងកិច្ចព្រមព្រៀងអន្តរជាតិ (ឧទាហរណ៍៖ការបដិសេធកិច្ចព្រមព្រៀងអឺរ៉ុប-អាមេរិក ស្តីពីការចែករំលែកទិន្នន័យហិរញ្ញវត្ថុក្នុងឆ្នាំ២០១០ ឬការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយសិង្ហបុរីនៅ ខែកុម្ភៈ ២០១៩) និងបោះឆ្នោតលើសេចក្តីសម្រេច ដើម្បីជះឥទ្ធិពលដល់គោលនយោបាយរបស់សហភាពអឺរ៉ុបលើបញ្ហានានាដែលត្រូវបានលើកយកមកដោះស្រាយនៅក្នុងវេទិកាអន្តរជាតិ ដូចជាការប្រែប្រួលអាកាសធាតុ ឬសន្តិសុខទូរគមនាគមន៍ជាដើម។ ស្ថាប័ននេះក៏ជាអ្នកអនុម័តថវិកាប្រចាំឆ្នាំ និងត្រួតពិនិត្យការងាររបស់រដ្ឋាភិបាលពហុជាតិ តែក្នុងស្ថានភាពផ្សេងមួយចំនួន ជារឿយៗស្ថាប័ននេះដំណើរការដោយមិនមានការត្រួតពិនិត្យ (free of any check and balance)។

នៅក្នុងសហភាពអឺរ៉ុប ច្បាប់ច្រើនជាង ៦០% លែងត្រូវបានសម្រេចនៅថ្នាក់ជាតិទៀតហើយ ប៉ុន្តែគឺនៅថ្នាក់សហភាពអឺរ៉ុប។ ក្នុងករណីមានភាពផ្ទុយគ្នា ឬមានជម្លោះច្បាប់របស់សហភាពអឺរ៉ុបមានអាទិភាពលើច្បាប់ជាតិ៖ EP ដែលជាស្ថាប័នដែលកើតពីការបោះឆ្នោតដោយផ្ទាល់ បន្តិចម្តងៗយកមុខងារនីតិកម្ម និងត្រួតពិនិត្យទៅគ្រប់គ្រង។

សមាជិក សមាជិកាសភាដែលចូលរួមចំណែកក្នុងការងាររបស់សភាថ្នាក់តំបន់ក៏ប្រឈមនឹងបញ្ហាផ្ទាល់របស់ពួកគេផងដែរ៖ ដោយពួកគេត្រូវគ្រប់គ្រងផ្សេង ហើយពេលខ្លះអាចមានទំនាស់ទៅនឹងផលប្រយោជន៍ ដែលអាចជាទំនាស់ទាក់ទងនឹងប្រយោជន៍របស់ថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ ឬក៏បញ្ហាជាក់លាក់ទាក់ទងនឹងគណបក្សនយោបាយរបស់គេ[A]។ សំខាន់បំផុតពួកគេត្រូវកំណត់នូវអ្វីដែលជាផលប្រយោជន៍ក្នុងតំបន់ និង/ឬ សកល(រយៈពេលវែង)។ ការណ៍នេះតម្រូវឲ្យមានការប្រកាន់ខ្ជាប់នូវវប្បធម៌នយោបាយដោយផ្អែកលើការកសាងការឯកភាពបែបកុងសង់ស៊ីស ដែលផ្តល់អាទិភាពដល់តម្រូវការសកលលើសតម្រូវការមូលដ្ឋាន ឬជាតិ។ នៅក្នុងបរិបទតំបន់ (ប៉ុន្តែជាញឹកញាប់ផងដែរនៅក្នុងបរិបទជាតិ និងអាស្រ័យលើប្រព័ន្ធនយោបាយ) គេត្រូវផ្សារភ្ជាប់និងជំរុញឲ្យមានការព្រមព្រៀងដើម្បីស្វែងរកការឯកភាពបែបកុងសង់ស៊ីស។ នៅពេលពិភាក្សាអំពីសេដ្ឋកិច្ច នៅពេលដោះស្រាយវិបត្តិ នៅពេលប្រយុទ្ធ

ប្រឆាំងនឹងអំពើភេរវកម្ម នៅពេលដោះស្រាយបញ្ហាសង្គម ការការពារទិន្នន័យ ការប្រែប្រួលអាកាសធាតុ ឬសន្តិសុខថាមពល គេត្រូវតែគិតដល់សហគមន៍ទាំងមូល។

នេះគឺជាហេតុផលដែលគេត្រូវការសភាថ្នាក់តំបន់ដែលរឹងមាំ ដើម្បីត្រួតពិនិត្យលើការងាររបស់ស្ថាប័នថ្នាក់លើជាតិ ដើម្បីពិនិត្យមើលលើការធ្វើសេចក្តីសម្រេចចិត្តរបស់ស្ថាប័នទាំងនោះ តាមដានការអនុវត្ត បង្ហាញការគាំទ្រលើគោលនយោបាយមួយចំនួន និងធ្វើវិសោធនកម្ម ឬជំទាស់ទៅនឹងអ្វីមួយ។ ទោះបីជាស្ថាប័នសភាទាំងនេះមិនមានអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តដោយផ្ទាល់ក៏ដោយ ក៏ការផ្តួចផ្តើម សេចក្តីថ្លែងការណ៍ និងសេចក្តីសម្រេចដែលធ្វើឡើងដោយស្ថាប័ននេះអាចមានឥទ្ធិពលខ្លាំងដល់ «ការទូតផ្លូវការ» ដែលធ្វើឡើងដោយអង្គនីតិប្រតិបត្តិ។ គេអាចចូលរួមចំណែក និងជះឥទ្ធិពលលើការអភិវឌ្ឍអន្តរជាតិ ដោយការបញ្ចេញនូវទស្សនៈផ្សេងៗដែលពេលខ្លះខុសពីទស្សនៈរបស់អង្គការតំបន់ ដោយសារតែលទ្ធភាពនៃការបត់បែនរបស់គេ។

នៅក្នុងពិភពសកលភាវូបនីយកម្មដែលមានតួអង្គមិនមែនរដ្ឋកំពុងមានឥទ្ធិពលកាន់តែខ្លាំងឡើង ពិភពលោកមួយ ដែលការធ្វើសេចក្តីសម្រេចចិត្តសំខាន់ៗស្តីពី កិច្ចការសាធារណៈឆ្លងហួសពីព្រំដែនជាតិ ភាគច្រើនការធ្វើសេចក្តីសម្រេចចិត្តទាំងនោះត្រូវបានគេធ្វើឡើងនៅក្នុងវេទិកាសកល និងតំបន់ សន្និបាតសភាថ្នាក់តំបន់ និងសកល ដូចជា ASEP ដែលត្រូវតែមានការផ្តល់អំណាច ដើម្បីធ្វើឲ្យវេទិកាទាំងនោះមានគណនេយ្យភាព និងបន្ថែមភាពស្របច្បាប់លើការធ្វើសេចក្តីសម្រេចចិត្តរបស់ស្ថាប័នទាំងនោះ។ សមាជិក សមាជិកាសភាដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តថ្នាក់ជាតិ។ ដូចគ្នានេះដែរ សមាជិកសមាជិកាសភាក៏ត្រូវតែក្លាយខ្លួនជាតួអង្គសំខាន់នៅក្នុងរចនាសម្ព័ន្ធតំបន់ដែលការធ្វើសេចក្តីសម្រេចចិត្តសំខាន់ៗកាន់តែច្រើនកំពុងតែត្រូវបានធ្វើឡើងនៅក្នុងវេទិកាទាំងនោះ ។



**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការ ដែលបកដោយវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិនៃកម្ពុជា (NIDIR)។ អ្នកអានអាចទាញយកអត្ថបទដើមជាភាសាអង់គ្លេសពីគេហទំព័រ៖ https://www.pic.org.kh ។

# ១.៤ ផលប៉ះពាល់នៃកូវីដ-១៩ និងការឆ្លើយតប

## ១.៤.១ ការឆ្លើយតបរបស់ឥណ្ឌូណេស៊ីទៅនឹងវិបត្តិកូវីដ-១៩

### តួនាទីនៃការទូតសភា

«សភាពធម្មតាតាមបែបគន្លងថ្មី» ( "A new normal" ) ជាពាក្យដែលត្រូវបានប្រើប្រាស់ជាញឹកញាប់នៅក្នុងឆ្នាំ ២០២០ ដើម្បីរៀបរាប់ពីស្ថានការណ៍រួមរបស់យើងទាំងអស់គ្នា។ ការផ្ទុះឡើងនៃជំងឺដែលបង្កដោយវីរុសកូរ៉ូណាក្នុងឆ្នាំ ២០១៩ ( កូវីដ-១៩ ) ដែលពេលនេះជាជំងឺរាតត្បាតសកល បានផ្លាស់ប្តូរវិធីរស់នៅរបស់យើង។

ពេលវេលាកន្លងផុតពីមួយថ្ងៃទៅមួយថ្ងៃក្នុងអំឡុងពេលវិបត្តិនេះ គឺកំពុងតែកំណត់សកម្មភាពរបស់យើង។ "ការសម្រេចចិត្តរបស់រដ្ឋាភិបាល និងប្រជាពលរដ្ឋក្នុងរយៈពេលពីរ-បីសប្តាហ៍ខាងមុខនេះ អាចនឹងមានឥទ្ធិពលដល់ពិភពលោកនៅរយៈពេលច្រើនឆ្នាំខាងមុខទៀត ការសម្រេចចិត្តដែលក្នុងពេលធម្មតាអាចត្រូវការរយៈពេលច្រើនឆ្នាំក្នុងការគិតពិចារណាត្រូវបានធ្វើក្នុងរយៈពេលត្រឹមតែប៉ុន្មានម៉ោងប៉ុណ្ណោះ។ បច្ចេកវិទ្យាថ្មីមួយចំនួនដែលមិនមានការអភិវឌ្ឍពេញលេញ និងពេលខ្លះមានគ្រោះថ្នាក់ថែមទៀត ត្រូវបានយកមកប្រើប្រាស់ទាំងប្រញាប់ប្រញាល់ ព្រោះតែហានិភ័យនៃការមិនធ្វើសកម្មភាពអ្វីនោះវាមានទំហំធំជាង។ ប្រទេសទាំងអស់ដើរតួជាកណ្តុរពិសោធន៍សម្រាប់សង្គមក្នុងទ្រង់ទ្រាយធំមួយ។"[៥]

លទ្ធភាពរបស់ប្រទេសនីមួយៗក្នុងការឆ្លើយតបនឹងការកាត់បន្ថយផលប៉ះពាល់នៃជំងឺរាតត្បាតសកលនេះ គឺពិតជាកត្តាកំណត់ជោគវាសនារបស់ប្រជាជាតិទាំងនោះសម្រាប់ឆ្នាំបន្តបន្ទាប់ខាងមុខ។ ទោះជាយ៉ាងនេះក្តី ជំងឺរាតត្បាតនេះ គឺជាបញ្ហាប្រឈមដ៏ធំដែលមិនមានប្រទេសណាមួយអាចប្រយុទ្ធប្រឆាំងតែឯងបាននោះទេ។ មនុស្សខ្លះបានប្រៀបធៀបសង្គ្រាមប្រឆាំងនឹងកូវីដ-១៩ ទៅនឹងសង្គ្រាមលោកលើកទី២ ដោយគ្រាន់តែខុសគ្នាត្រង់ថា ម្តងនេះជំនួសឲ្យការប្រយុទ្ធប្រឆាំងរវាងគ្នានឹងគ្នា ប្រជាជាតិទាំងអស់គឺជាបក្សពួកតែមួយ។ ជាការពិតណាស់ ប្រទេសទាំងអស់ត្រូវតែការពារពលរដ្ឋរបស់ខ្លួនប្រឆាំងនឹងវីរុសដែលឆ្លងដោយមិនប្រកាន់ពូជសាសន៍ ជំនឿ ឬទស្សនៈនយោបាយនោះទេ។ តែការឆ្លើយតបនៅត្រឹមកម្រិតជាតិមួយបានបង្ហាញថាមិនមានប្រសិទ្ធភាពសម្រាប់ដោះស្រាយភាពស្មុគស្មាញនៃបញ្ហាប្រឈមដែលបណ្តាលមកពីជំងឺរាតត្បាតសកលនេះឡើយ។ វីរុសនេះបាននាំមកនូវផលវិបាកជាបន្តបន្ទាប់ដែលលាតសន្ធឹងហួសពីសុខភាពរបស់ពលរដ្ឋម្នាក់ៗហើយឆ្លងហួសព្រំដែនជាតិនីមួយៗថែមទៀតផង។ ដូចនេះ ជំងឺរាតត្បាតសកលនេះ គឺជាចំណុចរបត់មួយដែលកំហិតឲ្យយើងស្តារឡើងវិញនូវជំនឿរបស់យើងទៅលើគុណតម្លៃនៃកិច្ចសហប្រតិបត្តិការ និងកិច្ចសហការជាសកល។

កូវីដ-១៩ ក៏ជាការដាស់តឿន និងជាការក្រើនរំលឹកដ៏ខ្លាំងក្លាមួយពីតម្រូវការនៃកិច្ចសហប្រតិបត្តិការ និងសាមគ្គីភាពជាសកល ព្រោះជំងឺនេះវាបានវាយលុកពិភពលោកចំពេលដែលប្រព័ន្ធពហុភាគីកំពុងទទួលរងសម្ពាធពីការប្រកួតប្រជែងគ្នារវាងមហាអំណាចធំៗ។ នៅក្នុងសិក្ខាសាលាតាមប្រព័ន្ធវីដេអូដែលធ្វើឡើងដោយសហភាពអន្តរសភា ( IPU ) និងការិយាល័យអង្គការសហប្រជាជាតិសម្រាប់ការកាត់បន្ថយហានិភ័យបណ្តាលមកពីគ្រោះមហន្តរាយ ( UNDRR ) នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០ អគ្គនាយកអង្គការសុខភាពពិភពលោក ( WHO ) បានសង្កត់ធ្ងន់ថា សាមគ្គីភាពជាសកល គឺចាំបាច់សម្រាប់ប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាតនេះ [៦] ដែលសារនេះមានស្មារតីដូចគ្នាទៅនឹងសាររបស់ប្រធានសភាឥណ្ឌូនេស៊ី លោកស្រី Puan Maharani ។ នៅក្នុងសុន្ទរកថាបើករបស់លោកស្រីថ្លែងទៅកាន់ក្រុមពិភាក្សាតាមប្រព័ន្ធវីដេអូ ដែលរៀបចំឡើងដោយគណៈកម្មាធិការសម្រាប់កិច្ចសហប្រតិបត្តិការអន្តរសភានៃរដ្ឋសភាឥណ្ឌូនេស៊ីលោកស្រីបានអំពាវនាវស្រដៀងគ្នា ដោយសូមឲ្យមានសាមគ្គីភាពជាអន្តរជាតិ ហើយត្រូវពិនិត្យមើលជាថ្មីម្តងទៀតលើគោលគំនិតនៃការធ្វើការរួមគ្នាជាក្រុមគ្រួសារនៃប្រជាជាតិ ដែលជាគោលគំនិតគាំទ្រយ៉ាងប្តូរផ្តាច់ដោយអតីតប្រធានាធិបតីឥណ្ឌូនេស៊ី Soekarno កាលពី៧៥ឆ្នាំមុន [៧]។

សភាដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្វិលកង់នៃកិច្ចសហប្រតិបត្តិការសកល។ សភាក៏ដូចជាសមាជិក សមាជិកាសភាម្នាក់ៗដែរមានតួនាទីពិសេសមួយក្នុងការជំរុញទំនាក់ទំនងឆ្លងដែន ដើម្បីប្រមូលផ្តុំសាមគ្គីភាពក្នុងចំណោមសមាជិកសមាជិកាសភាទាំងអស់។ទោះជាយ៉ាងណាក៏ដោយការកើនឡើងនៃតួនាទីអន្តរជាតិរបស់សភាទាមទារការគាំទ្រជារួមពីអង្គការអន្តរសភានានា។ នវានុវត្តន៍ ( Innovation ) គឺជាពាក្យគន្លឹះ ជាពិសេសចាប់តាំងពីពេលមានកូវីដ-១៩

របៀបដែលមនុស្សទាក់ទងគ្នាទៅវិញទៅមកបានផ្លាស់ប្តូរ។ ពេលនេះបានកន្លងផុតទៅហើយ ដែលថា តួនាទីរបស់អង្គការអន្តរសភាពីមុន គឺមានត្រឹមតែធ្វើការសម្របសម្រួលការទំនាក់ទំនង និងការប្រាស្រ័យឆ្លើយឆ្លងរវាងសមាជិកសមាជិកាសភាតាមរយៈសន្និបាតប្រចាំឆ្នាំប៉ុណ្ណោះ។ នវានុវត្តន៍ថ្មីៗរួមមានការប្រមូលព័ត៌មាន និងចងក្រងថ្មីៗរបស់ IPU ពីរបៀបដែលសភាកំពុងទប់ទល់នឹងជំងឺរាតត្បាតសកល និងសិក្ខាសាលាតាមប្រព័ន្ធវីដេអូជាច្រើនជាមួយអង្គការអន្តរជាតិជាដៃគូ ដែលផ្តោតលើបញ្ហាផ្សេងៗទាក់ទងនឹងវិបត្តិនេះ។

## ការឆ្លើយតបជាក់លាក់របស់សភាឥណ្ឌូនេស៊ីចំពោះវិបត្តិកូវីដ-១៩

រដ្ឋាភិបាលឥណ្ឌូនេស៊ីបានដើរតួនាទីនាំមុខក្នុងការអះអាងឡើងវិញពីការគាំទ្រនូវកិច្ចសហប្រតិបត្តិការ និងកិច្ចសហការអន្តរជាតិ។ រួមគ្នាជាមួយប្រទេសហ្គាណា លិចតិនស្តាញ ន័រវែស សិង្ហបុរី និងស្វីស ឥណ្ឌូណេស៊ីបានដាក់ចេញនូវសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិស្តីពីសាមគ្គីភាពសកលដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺដែលបណ្តាលមកពីវីរុសកូរ៉ូណា២០១៩។ សេចក្តីសម្រេចដែលត្រូវបានគាំទ្ររួមគ្នាដោយប្រទេស១៨៨ ផ្តោតសំខាន់លើកិច្ចសហប្រតិបត្តិការអន្តរជាតិដែលជាឧបករណ៍ស្នូលក្នុងការដោះស្រាយជំងឺរាតត្បាតសកលនេះបានជំរុញឲ្យមានការផ្លាស់ប្តូរព័ត៌មានរបកគំហើញវិទ្យាសាស្រ្ត និងឧត្តមានុវត្តន៍ ក្រោមការដឹកនាំរបស់អង្គការសុខភាពពិភពលោក។ លើសពីនេះទៀតប្រទេសឥណ្ឌូនេស៊ីគឺជាអ្នកចូលរួមក្នុងគម្រោងពិសោធន៍ប្រៀបធៀប និងវាយតម្លៃពីប្រសិទ្ធភាពនៃការព្យាបាលជំងឺកូវីដ-១៩ ដោយឈរលើស្មារតីសាមគ្គីភាពរបស់អង្គការសុខភាពពិភពលោក ( WHO Solidarity Trial ) ផងដែរ។ ការពិសោធន៍ និងវាយតម្លៃនេះមានគោលបំណងពន្លឿនការរកឲ្យឃើញផ្នែកវេជ្ជសាស្រ្ត ឱសថ និងវិធីសាស្រ្តព្យាបាលសម្រាប់កូវីដ-១៩ ដែលមានប្រសិទ្ធភាព[៩]។ ក្រៅពីអង្គការសហប្រជាជាតិ ឥណ្ឌូណេស៊ីក៏បានលើកទឹកចិត្តយ៉ាងសកម្មដល់កិច្ចសហប្រតិបត្តិការ និងកិច្ចសហការនៅក្នុងអង្គការផ្សេងៗដូចជា G20, អាស៊ាន, G77, D8, OIC, MIKTA, WTO, WIPO, ICAO, និងIMO ជាដើម។

កូវីដ-១៩ ក៏បានផ្លាស់ប្តូររបៀបដែលសភាធ្វើការផងដែរ។ ការចងក្រងរបស់ IPU ពីការឆ្លើយតបរបស់សភាទៅនឹងរោគរាតត្បាតសកលដែលបានរៀបរាប់ខាងលើ ជួយឲ្យយើងអាចចែករំលែក និងប្រៀបធៀបការអនុវត្តរបស់សភា[១០]។ វាបង្ហាញថា ការធ្វើការពីចម្ងាយ ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងប្រាស្រ័យឆ្លើយឆ្លង ក៏ដូចជាការអនុវត្តការរក្សាគម្លាតបុគ្គលបានក្លាយជាវិធានការបង្ការរួមក្នុងចំណោមសភានានា។ សភាតំណាងរាស្ត្រនៃសាធារណរដ្ឋឥណ្ឌូនេស៊ីបានប្រកាន់យកសភាពធម្មតាតាមបែបគន្លងថ្មីនេះ ដោយអនុវត្តតាមនីតិវិធីទាំងអស់ខាងលើនេះ។ នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ សភាតំណាងរាស្ត្រឥណ្ឌូនេស៊ីបានបើកសម័យប្រជុំរបស់ខ្លួនក្រោមវិធានការការពារជាច្រើន ដោយមានសមាជិក សមាជិកាសភាខ្លះចូលរួមដោយផ្ទាល់ និងច្រើននាក់ទៀតចូលរួមតាមរយៈប្រព័ន្ធវីដេអូ។ បន្ទាប់ពីការបើកសម័យប្រជុំនោះមក ការរៀបចំស្រដៀងគ្នានេះត្រូវបានអនុវត្តសម្រាប់សភា និងលេខាធិការដ្ឋានសភា រាល់ការពិភាក្សារវាងលេខាធិការដ្ឋាន និងសមភាគីនីតិប្បញ្ញត្តិរបស់ខ្លួន នាពេលបច្ចុប្បន្ននេះត្រូវបានធ្វើឡើងតាមរយៈប្រព័ន្ធវីដេអូ។

ជាញឹកញាប់វិបត្តិតែងតែនាំមកនូវការខូចខាតផ្នែកប្រជាធិបតេយ្យ។ ដូចនៅក្នុងប្រទេសភាគច្រើនដែរ នៅក្នុងប្រទេសឥណ្ឌូនេស៊ី អំណាចចម្បងក្នុងការសម្រេចចិត្តលើគោលនយោបាយដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺរាតត្បាតសកល គឺជាសិទ្ធិអំណាចរបស់ស្ថាប័ននីតិប្រតិបត្តិ។ ដើម្បីធានាថា កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការកែសម្រួលវិធានការសុខភាពសាធារណៈនិងសង្គម ដែលមិនធ្វើឲ្យខូចដល់ប្រជាធិបតេយ្យ តម្លាភាពនិងគណនេយ្យភាពនោះ ក្នុងខណៈពេលដែលកំពុងគ្រប់គ្រងហានិភ័យនៃការកើតឡើងជាថ្មីនៃករណីឆ្លង ការបិទសភាមិនមែនជាជម្រើសសម្រាប់ប្រទេសឥណ្ឌូនេស៊ីទេ។

ទោះបីសភាឥណ្ឌូនេស៊ីបានចាប់ផ្តើមបើកសម័យប្រជុំរបស់ខ្លួននៅចុងខែមីនា ពោលគឺ ប៉ុន្មានសប្តាហ៍បន្ទាប់ពីការរកឃើញពីករណីដំបូងនៃកូវីដ-១៩ ដែលបានប្រកាសដោយប្រធានាធិបតី Jokowi ក៏ដោយ ការងាររបស់សភាមិនដែលឈប់ឡើយ។ មួយថ្ងៃបន្ទាប់ពីមានករណីដំបូងត្រូវបានប្រកាស សភាឥណ្ឌូនេស៊ីតាមរយៈប្រធានសភាលោកស្រី Puan Maharani បានរំលឹករដ្ឋាភិបាលឲ្យផ្តល់អាទិភាពលើសុខភាព និងសុវត្ថិភាពសាធារណៈច្រើនជាងបញ្ហាដទៃទៀត រួមទាំងផលប៉ះពាល់សេដ្ឋកិច្ចផងដែរ។ លោកស្រីបានជំរុញឲ្យរដ្ឋាភិបាលមានតម្លាភាពក្នុងការគ្រប់គ្រងករណីឆ្លង ពង្រឹងការត្រួតពិនិត្យតាមព្រំដែន និងពិនិត្យរកមេរោគឲ្យបានលឿន ហើយត្រូវគិតពីវិធានការទប់ទល់បុរេសកម្មផ្សេងៗទៀត។ លោកស្រីថែមទាំងស្នើឲ្យមានការបង្កើតក្រុមការងារសម្របសម្រួលរួម ដើម្បីប្រយុទ្ធប្រឆាំងនឹងជម្ងឺរាតត្បាតសកលនេះ[១១]។ ការអំពាវនាវទាំងនេះត្រូវបានធ្វើឡើងស្របពេលមានការព្រួយបារម្ភជាសាធារណៈថា ស្ថាប័ននីតិប្រតិបត្តិកំពុងផ្តោតលើការកាត់បន្ថយផល

ប៉ះពាល់សេដ្ឋកិច្ចមកពីជំងឺរាតត្បាតសកលជាជាងការត្រៀមរៀបចំនិងកាត់បន្ថយផលវិបាកដែលកើតឡើងភ្លាមៗបន្ទាប់ពីការឆ្លងលើកដំបូង។

មិនមានប្រទេសណាមួយស្មានដល់ថា នឹងមានការរីករាតត្បាតជាសកលនៃជម្ងឺកូវីដ-១៩ បែបនោះទេ។ ដូចនេះហើយ វាសមហេតុផលដែលរដ្ឋាភិបាលទាំងអស់នៅលើពិភពលោកបានប្រើអំណាចក្នុងគ្រាអាសន្នរបស់ពួកគេដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺនេះ។ ប៉ុន្តែភាពចាំបាច់ក្នុងការធ្វើសកម្មភាពឲ្យបានរហ័សនិងអង់អាចមិនមែនជាលេសដើម្បីប្រមូលផ្តុំអំណាច និងសមត្ថកិច្ចទាំងអស់នៅស្ថាប័ននីតិប្រតិបត្តិនោះទេ។ ការប្រមូលផ្តុំអំណាចអាចនាំឲ្យមានការរំលោភអំណាច។ ត្រង់នេះហើយដែលធ្វើឲ្យអំណាចតាមរដ្ឋធម្មនុញ្ញរបស់សភាមានសារៈសំខាន់ជាងពេលណាៗទាំងអស់។

ក្នុងបរិបទនេះហើយ ទើបសភាឥណ្ឌូនេស៊ីបានបង្កើតក្រុមការងារសភាមួយ ដើម្បីត្រួតពិនិត្យ និងតាមដានការគ្រប់គ្រងវិបត្តិកូវីដ-១៩។ ក្រុមនេះត្រូវបានប្រគល់ភារកិច្ចទាក់ទងនឹងការតាមដានពីរបៀបដែលស្ថាប័ននីតិប្រតិបត្តិឆ្លើយតបចំពោះបញ្ហាទាក់ទងនឹងសុខភាព បន្ទាប់ពីរដ្ឋាភិបាលបានប្រកាសដាក់ជំងឺកូវីដ-១៩ ជាភាពអាសន្ននៃសុខភាពសាធារណៈ តាមរយៈបទបញ្ជារបស់ប្រធានាធិបតីដែលប្រកាសនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០។ ក្រុមការងារនេះបានចាប់ផ្តើមពីការលុបចោលនូវការវិធានការរបស់អន្តរស្ថាប័ននានាដែលមានលក្ខណៈមិនរួមគ្នា (interinstitutional ego-sectoral) [C] ក្នុងការគ្រប់គ្រងវិបត្តិនេះ។ ក្រុមនេះត្រូវបានចាត់តាំងឲ្យតាមដានការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្នុងស្រុកដែលចាំបាច់ត្រូវប្រើដើម្បីដោះស្រាយវិបត្តិសុខភាព រួមមានដូចជា កញ្ចប់ឧបករណ៍ធ្វើតេស្តរកមេរោគឆ្លង (PCR) ការស្រាវជ្រាវរកវ៉ាក់សាំង និងវិធានការផ្សេងៗទៀត។

សភាក៏បានធ្វើការជជែកដេញដោលគ្នាទៅលើបទបញ្ញត្តិរបស់រដ្ឋាភិបាលដែលបានចេញជំនួសច្បាប់ស្តីពី គោលនយោបាយហិរញ្ញវត្ថុ និងស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុរបស់រដ្ឋ ដោយសារបទបញ្ញត្តិទាំងនេះបានផ្តល់សិទ្ធិអំណាច និងភាពបត់បែនដល់រដ្ឋាភិបាលក្នុងការរំលោភលើដែនសមត្ថកិច្ចច្បាប់ដែលមានស្រាប់ និងនីតិវិធីនានាក្នុងការចេញនូវគោលនយោបាយហិរញ្ញវត្ថុក្នុងពេលមានជំងឺរាតត្បាតសកល។ បទបញ្ញត្តិថ្មីត្រូវបានគេមើលឃើញថា ផ្តល់ក្របខ័ណ្ឌច្បាប់ធំធេង ដែលអាចឲ្យរដ្ឋាភិបាលចេញគោលនយោបាយថវិកាហិរញ្ញវត្ថុ និងរូបិយវត្ថុ ដើម្បីដោះស្រាយផលប៉ះពាល់ដោយសារកូវីដ-១៩។

បទបញ្ញត្តិនេះបានអនុញ្ញាតឲ្យរដ្ឋាភិបាលបង្កើនឱនភាពថវិកាដល់ជាង៣% នៃផលិតផលក្នុងស្រុកសរុប ដែលពីមុនត្រូវបានហាមឃាត់យ៉ាងតឹងតែង ដោយច្បាប់ហិរញ្ញវត្ថុរបស់រដ្ឋ។ ការធ្វើបែបនេះក៏បានកាត់ចេញនូវនីតិវិធីចាំបាច់នានាលើការកែប្រែរចនាសម្ព័ន្ធថវិការបស់រដ្ឋ ដោយគ្មានការពិគ្រោះយោបល់ជាមុនជាមួយសភា។ ចំណុចចម្រូងចម្រាសនៃបទបញ្ញត្តិនេះត្រូវបានរិះគន់ដោយសាធារណៈជនមួយចំនួនថា បទបញ្ញត្តិនេះបានផ្តល់អភ័យឯកសិទ្ធិដល់អាជ្ញាធរព្រោះពួកគេមិនអាចទទួលរងការចោទប្រកាន់ក្រោមច្បាប់ព្រហ្មទណ្ឌ និងរដ្ឋប្បវេណី នៅពេលអនុវត្តគោលនយោបាយក្នុងពេលមានជំងឺរាតត្បាតសកលនោះទេ។

ការជជែកដេញដោលបានបញ្ចប់នៅថ្ងៃទី១២ ខែឧសភា ដែលត្រូវបានកត់សម្គាល់ ដោយមានការអនុម័តបទបញ្ញត្តិនេះទៅជាច្បាប់ដោយសភាឥណ្ឌូនេស៊ី។ ការអនុម័តនេះត្រូវបានធ្វើឡើងបន្ទាប់ពីមានការពិភាក្សាគ្នាយ៉ាងក្តៅគគុកលើខ្លឹមសាររបស់បទបញ្ញត្តិនេះដែលនៅក្នុងការពិភាក្សានោះ សភាបានទទួលស្គាល់ថា វិបត្តិដ៏ធំដែលកំពុងតែកើតឡើងនេះ ទាមទារឲ្យមានការឆ្លើយតបជាពិសេសមួយ។ គេបានទទួលស្គាល់ថា ការផ្លាស់ប្តូររចនាសម្ព័ន្ធថវិការបស់រដ្ឋដោយគ្មានការពិគ្រោះយោបល់ជាមុនជាមួយសភា គឺធ្វើឡើងក្នុងករណីចាំបាច់ ដើម្បីអាចឲ្យរដ្ឋាភិបាលអនុវត្តសកម្មភាពដែលចាំបាច់បានឆាប់រហ័ស ដើម្បីទប់ស្កាត់កុំឲ្យមានគ្រោះមហន្តរាយហិរញ្ញវត្ថុបន្ថែមទៀត។

ទោះជាយ៉ាងណា ការពង្រីកអំណាច និងសមត្ថកិច្ចពិសេសដែលត្រូវបានផ្តល់ឲ្យរដ្ឋាភិបាលក្នុងពេលមានវិបត្តិមិនមែនគ្មានដែនកំណត់នោះទេ។ ចំណុចលេចធ្លោមួយនៃការជជែកដេញដោលរបស់សភា ដែលមិនគួរមើលរំលងនោះគឺការបន្ថែមកថាខណ្ឌបញ្ចប់ ដោយបានចែងថា ភាពបត់បែននៃឱនភាពថវិកាត្រូវផុតកំណត់ត្រឹមឆ្នាំ២០២៣។ រដ្ឋាភិបាលក៏បានប្តេជ្ញាចិត្តវិលត្រឡប់ទៅរកដំណើរការធម្មតាឡើងវិញ សម្រាប់ការជជែកពិភាក្សាពីថវិកាក្នុងឆ្នាំ២០២១។ លើសពីនេះទៅទៀតស្ថាប័ននីតិប្រតិបត្តិក៏បាននិយាយថា ខ្លួននឹងស្នើសុំឲ្យមានការជជែកដេញដោលពីសភាលើកញ្ចប់ថវិកានៃឆ្នាំក្រោយនៅពាក់កណ្តាលខែមិថុនា ឆ្នាំ២០២០។ ការជជែកដេញដោលនេះក៏រួមបញ្ចូលការជជែកដេញដោលលើបំណុលសាធារណៈផងដែរ។

យោងតាមច្បាប់ដែលបានអនុម័ត ឥណ្ឌូណេស៊ីបានវិភាជថវិកាបន្ថែមសរុបប្រមាណជា ៤០៥,១ ទ្រីលានរូពា (Rp) (២៧,៦ ប៊ីលានដុល្លារអាមេរិក) សម្រាប់វិស័យរួមមាន សុខាភិបាល (៥,១ ប៊ីលានដុល្លារអាមេរិក) ប្រព័ន្ធគាំពារសង្គម (៧,៥ប៊ីលានដុល្លារអាមេរិក) ការជួយសម្រួល

ដល់វិស័យពន្ធ និងឥណទានអាជីវកម្មរបស់ប្រជាពលរដ្ឋ (៤,៨ ប៊ីលានដុល្លារអាម៉េរិក) និងកម្មវិធីស្តារឡើងវិញ (១០,២ ប៊ីលានដុល្លារអាម៉េរិក) [១២]។ ច្បាប់នេះក៏បានកំណត់កំរិតឱនភាពនៃថវិកាត្រឹមប្រហែល ៥,០៧% នៃផលិតផលក្នុងស្រុកសរុប ឬប្រហែល ៨៥២,៩ ទ្រីលានរូភា (៥៧,៩ ប៊ីលានដុល្លារអាម៉េរិក)។ ដើម្បីផ្តល់ហិរញ្ញប្បទានទ្រទ្រង់ឱនភាពថវិកា រដ្ឋាភិបាលបានស្នើឲ្យផ្តល់មូលប័ត្របំណុលរដ្ឋដែលមានតម្លៃស្មើនឹង ៥៧,១១ ប៊ីលានដុល្លារអាម៉េរិក[១៣]។ ក្នុងកិច្ចប្រជុំសភាមួយ ការជជែកដេញដោលមួយបានកើតឡើង ស្តីពីការធ្វើបែបណាដើម្បីរក្សាអត្រាការប្រាក់ទាបសម្រាប់មូលប័ត្របំណុលទាំងនេះ។ ក្តីបារម្ភចម្បងរបស់សភាគឺតើត្រូវកាត់បន្ថយផលវិបាកហិរញ្ញវត្ថុក្នុងប៉ុន្មានទសវត្សរ៍ខាងមុខដោយរបៀបណា[១៤]។ ដើម្បីដោះស្រាយបញ្ហានេះ សភាចាំបាច់ត្រូវពិនិត្យវិនិច្ឆ័យឲ្យបានច្បាស់លាស់ពីផែនការបំណុល ការស្នើសុំ និងលទ្ធភាពនៃការទូទាត់ជាពិសេសដើម្បីធានាថា ថវិកាដែលបានបង្កើនតាមរយៈបំណុលនឹងត្រូវយកទៅប្រើប្រាស់ដើម្បីគាំទ្រដល់អ្នកដែលរងផលប៉ះពាល់ខ្លាំង។ សរុបសេចក្តីមក ការគ្រប់គ្រងបំណុល គឺជាផ្នែកមួយក្នុងចំណោមផ្នែកជាច្រើនដែលសភាចាំបាច់ត្រូវចូលរួម ជាពិសេសនៅពេលមានវិបត្តិ។

## ១.៤.២ ផលប៉ះពាល់នៃកូវីដ-១៩ លើវិស័យសេដ្ឋកិច្ចនាំមុខរបស់កម្ពុជា

### សេចក្តីផ្តើម

ពិភពលោកមានការរន្ធត់ដោយសារវិបត្តិកូវីដ-១៩ ដែលមិនបានដឹងពីមុន។ វីរុសថ្មីនេះបានជះឥទ្ធិពលអវិជ្ជមានដល់ប្រទេសចំនួន២១៣ និងដែនដីចំនួនពីរ នៅជុំវិញពិភពលោក។ មនុស្សឆ្លងមានចំនួនជាង ៧ លាននាក់ គិតត្រឹមកាលបរិច្ឆេទនៃការសរសេរអត្ថបទនេះក្នុងនោះបានបណ្តាលឲ្យមានមនុស្សស្លាប់ចំនួន៤០០,០០០នាក់ និងមានអ្នកជាសះស្បើយចំនួន៣,៤លាននាក់។ ផលវិបាកសេដ្ឋកិច្ចក៏មានសភាពធ្ងន់ធ្ងរផងដែរ។ សេដ្ឋកិច្ចពិភពលោកខាតបង់ចន្លោះពី ៥,៨ ទ្រីលានដុល្លារអាម៉េរិកទៅ ៨,៨ ទ្រីលានដុល្លារអាម៉េរិក ដោយសារការរាំងស្ទះផ្នែកសេដ្ឋកិច្ចសង្គមនិកម្មភាព ការបិទទីក្រុង និងភាពធ្ងន់ធ្ងរផ្នែកសុខភាពសាធារណៈក្នុងការឆ្លើយតបនឹងវិបត្តិនេះ[១៥,១៦]។

នៅកម្ពុជា ករណីដំបូងបំផុតនៃវីរុសកូរ៉ូណាត្រូវបានរកឃើញនៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០។ រាជរដ្ឋាភិបាលបានចាត់វិធានការយ៉ាងសកម្ម និងទាន់ពេលវេលាតាមរយៈការបញ្ជាឲ្យផ្អាកជាបណ្តោះអាសន្ននូវការបណ្តុះបណ្តាលដោយផ្ទាល់នៅតាមសាលារៀន ហាមឃាត់ការជួបជុំទ្រង់ទ្រាយធំ ពន្យារពេលនៃការឈប់សម្រាកពិធីបុណ្យចូលឆ្នាំខ្មែរឆ្នាំ២០២០ រួមទាំងការហាមឃាត់មិនឲ្យប្រជាពលរដ្ឋធ្វើដំណើរទៅកាន់ស្រុកកំណើត និងការផ្តួចផ្តើមយុទ្ធនាការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ ដែលរួមបញ្ចូលការផ្សព្វផ្សាយតាមបណ្តាញសង្គម តាមក្រុមហ៊ុនផ្តល់សេវាទូរស័ព្ទ តុកតុក(ម៉ូតូកង់បី) ម៉ូតូឌុប និងរថយន្ត។ វិធានការផ្សេងៗរួមមាន ការហាមឃាត់ជើងហោះហើរមកពីបណ្តាប្រទេសដែលមានឆ្លងមេរោគមកកាន់កម្ពុជា និងការតម្រូវឲ្យធ្វើចត្តាឡីស័កសម្រាប់អ្នកធ្វើដំណើរអន្តរជាតិ និងអ្នកដែលមានពាក់ព័ន្ធជាមួយអ្នកជំងឺដែលបានឆ្លងមេរោគ។ ជាលទ្ធផល គិតត្រឹមខែឧសភា ឆ្នាំ២០២០ កម្ពុជាមិនមានករណីស្លាប់ដោយសារជំងឺកូវីដ-១៩ នោះទេ ហើយអ្នកជម្ងឺចំនួន១២៣ រូប បានជាសះស្បើយ និង០៣ រូប កំពុងស្ថិតនៅក្រោមការព្យាបាល។ ទោះបីជាយ៉ាងណាក៏ដោយ ការផ្ទុះឡើងនេះនៅតែមានភាពមិនច្បាស់លាស់ និងមិនអាចទស្សន៍ទាយទុកមុនបាន។ ការព្រួយបារម្ភពីរលកទីពីរ ឬទីបី នៃមេរោគនេះនៅតែកើនឡើង ដោយសារតែមិនទាន់មានវ៉ាក់សាំងណាមួយត្រូវបានរកឃើញនៅឡើយទេ។

ការកើតឡើងនៃជំងឺកូវីដ-១៩ បានធ្វើឲ្យធនាគារពិភពលោកទស្សន៍ទាយថា សេដ្ឋកិច្ចរបស់កម្ពុជានឹងមានសន្ទុះយឺតបំផុតដែលមិនធ្លាប់ជួបប្រទះតាំងពីឆ្នាំ១៩៩៤ ដោយថយចុះរហូតដល់រវាង -១%(ក្នុងសេណារីយ៉ូទិន្នន័យគោល) ឬ -២,៩ % (ក្នុងសេណារីយ៉ូធ្លាក់ចុះទាប) ដែលធ្វើឲ្យការងាររបស់ប្រជាពលរដ្ឋយ៉ាងហោចណាស់ ១,៧៦ លានកន្លែង ស្ថិតក្នុងហានិភ័យនៅឆ្នាំ២០២០ និងនៅឆ្នាំបន្តបន្ទាប់ទៀត [១៩]។ ក្នុងសេណារីយ៉ូធ្ងន់ធ្ងរបំផុត ធនាគារអភិវឌ្ឍន៍អាស៊ី ADB បានប៉ាន់ស្មានថា កម្ពុជាអាចនឹងខាតបង់រហូតដល់ ៣,៤៩% នៃផលិតផលក្នុងស្រុកសរុប ដែលស្មើនឹង ៨៥៦.៥ លានដុល្លារអាម៉េរិក [១៧]។

វិស័យដែលរងផលប៉ះពាល់បំផុតនៅកម្ពុជារួមមាន វិស័យទេសចរណ៍ វិស័យកម្មន្តសាលសម្រាប់ការនាំចេញ និងវិស័យសំណង់ ដែលសរុបជារួមស្មើនឹង៧០%នៃកំណើន និង៣៩% នៃការងារសរុបក្នុងឆ្នាំ២០១៩ [១៩]។ ក្នុងឆ្នាំដដែលនេះ ប្រហែល ១០% (ឬ ១,៥០០,០០០ នាក់) នៃចំនួនប្រជាជនសរុប (១៥,៣ លាននាក់) រស់នៅក្រោមបន្ទាត់ភាពក្រីក្រ [២០.២១]។ ផលប៉ះពាល់នៃកូវីដ-១៩ ត្រូវបានរំពឹងទុកថានឹងធ្វើឲ្យមានកំណើនអត្រានេះចន្លោះពី ៣% ទៅ ១១% ដែលបណ្តាលមកពីការបាត់បង់ប្រាក់ចំណូលរយៈពេលជាងប្រាំមួយខែរបស់ក្រុមគ្រួសារដែលធ្វើការក្នុងវិស័យទេសចរណ៍ អាជីវកម្មលក់ដុំនិងរាយ កាត់ដេរ សំណង់ ឬកម្មន្តសាល [១៩]។

**តារាង ១**. កត្តាជំរុញកំណើនសំខាន់ៗ និងការងារ នៃប្រទេសកម្ពុជា

| កត្តាជំរុញកំណើន | ទេសចរណ៍ | សំលៀកបំពាក់ និងស្បែកជើង | សំណង់ | សរុប |
|---|---|---|---|---|
| ការរួមចំណែកក្នុងកំណើនផ.ស.ស (២០១៩, គិតជាភាគរយ) | ១៨,៧ | ១៧ | ៣៥,៧ | ៧១,៤ |
| ការបង្កើតការងារផ្ទាល់ (000) | ៦២០ | ៩៤១ | ២០០ | ១,៧៦១ |
| ភាគរយនៃការងារដែលមានប្រាក់ឈ្នួល[១] | ១៣,៩ | ២១ | ៤,៥ | ៣៩,៤ |
| ភាគរយនៃការងារមិនមែនកសិកម្ម | ១១,២ | ១៧ | ៣,៦ | ៣១,៨ |
| ភាគរយនៃការងារសរុប | ៧,១ | ១០,៧ | ២,៣ | ២០,១ |

***ប្រភព៖** ដកស្រង់ចេញពីធនាគារពិភពលោក ២០២០*

***ចំណាំ៖** ១ ការងារដែលទទួលបានប្រាក់កម្រៃ*

## វិស័យទេសចរណ៍

វិស័យទេសចរណ៍ (រួមទាំងបដិសណ្ឋារកិច្ច) តំណាងឲ្យ១៨,៧%នៃកំណើនផលិតផលក្នុងស្រុកសរុប(ផ.ស.ស) របស់កម្ពុជាក្នុងឆ្នាំ២០១៩ (តារាង ១) [១៩]។ ប្រទេសទាំងប្រាំដែលរួមចំណែកក្នុងវិស័យទេសចរណ៍អន្តរជាតិកម្ពុជារួមមាន ចិនដែលមាន២២,៥% តាមដោយ វៀតណាម ថៃ កូរ៉េ និងសហរដ្ឋអាម៉េរិក (រូបភាពទី ១) [២២]។វិស័យនេះបានបង្កើតការងារដោយផ្ទាល់ចំនួនប្រមាណ ៦២០,០០០ ការងារ និងដោយប្រយោលប្រមាណ ១ លានការងារ។វិស័យនេះបានទទួលភ្ញៀវអន្តរជាតិចំនួន ៦ លាននាក់ ដែលរកចំណូលបានចំនួន ៥ លានដុល្លារអាម៉េរិក ក្នុងឆ្នាំ២០១៩ បើប្រៀបនឹង ២,៥ លានដុល្លារអាម៉េរិក នៅឆ្នាំ២០១៣ (តារាង ១) [២២]។

ជាមួយនឹងការរីករាលដាលជាអន្តរជាតិនៃកូវីដ-១៩ វិស័យនេះបានទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ និងថយចុះរវាង ៥០% និង ៩០% [២៣]។ នេះគឺបណ្តាលមកពីការផ្ទុះឡើងនៃជំងឺនេះដំបូងនៅប្រទេសចិន ដោយអ្នកទេសចរណ៍ចិនជាចំណែកធំមួយនៃទេសចរនៅកម្ពុជា វិស័យទេសចរណ៍ដួលរលំទាំងស្រុង ដោយជើងហោះហើរអន្តរជាតិធ្លាក់ចុះមកនៅត្រឹម១ %នៃកម្រិតពីមុន។ ការរីករាលដាលនៃជំងឺនេះក៏បណ្តាលឲ្យមានការហាមឃាត់ការធ្វើដំណើរជាអន្តរជាតិ និងការបិទប្រទេស ដែលនាំឲ្យមានការថយចុះ ២៥,១% នៃការមកដល់របស់អ្នកទេសចរណ៍ (ពីមួយឆ្នាំទៅមួយឆ្នាំ) ក្នុងអំលុងនៃពីរខែដំបូងនៃឆ្នាំ២០២០ដែលជាការធ្លាក់ចុះដំបូងបំផុតបន្ទាប់ពីវិបត្តិហិរញ្ញវត្ថុសកលឆ្នាំ ២០០៨-២០០៩ [១៩]។ ខេត្តសៀមរាបដែលជាទិសដៅទេសចរណ៍ពេញនិយមបំផុតរបស់ប្រទេសកម្ពុជាបានធ្លាក់ចុះ៤៥,៦%នៃការមកដល់នៃភ្ញៀវទេសចរណ៍ក្នុងត្រីមាសទី ១ និង ៩៩,៦% ក្នុងខែមេសា ឆ្នាំ២០២០ (WB ២០២០)។ ប្រហែល ១៦៩ ក្រុមហ៊ុននៅក្នុងវិស័យទេសចរណ៍បានបិទទ្វារជាបណ្តោះអាសន្ន ដែលធ្វើឲ្យប្រជាពលរដ្ឋប្រហែល ១៦,៨៩១នាក់ គ្មានការងារធ្វើ [២៥]។ បុគ្គលិកសណ្ឋាគារដែលមានជំនាញទាបទទួលបានប្រាក់ខែតែពាក់កណ្តាលនៃប្រាក់ខែរបស់ពួកគេ ដោយសារតែការធ្លាក់ចុះដ៏គំហុកនៃការស្នាក់នៅក្នុងសណ្ឋាគារ។ ធនាគារអភិវឌ្ឍន៍អាស៊ីប៉ាន់ស្មានថា វិស័យទេសចរណ៍អាចនឹងខាតបង់ប្រាក់ ៨៥៦,៥ លានដុល្លារអាម៉េរិក (៣,៥% នៃផ.ស.ស) ក្នុងករណីនៃសេនារីយ៉ូអាក្រក់បំផុត (តារាងទី២) [១៧]។

ការអន្តរាគម និងការរឹតបន្តឹងការធ្វើដំណើររបស់រដ្ឋាភិបាលដែលប៉ះពាល់ដល់ទេសចរណ៍អន្តរជាតិ រួមមានការព្យួរការលើកលែងទិដ្ឋាការ ទិដ្ឋាការទេសចរណ៍ ទិដ្ឋាការអេឡិចត្រូនិច និងទិដ្ឋាការនៅពេលមកដល់រយៈពេលមួយខែ។ យោងតាមរដ្ឋាភិបាល ជនបរទេសដែលមានបំណងធ្វើដំណើរមកប្រទេសកម្ពុជាត្រូវបានតម្រូវឲ្យស្នើសុំទិដ្ឋាការនៅឯស្ថានបេសកកម្មការទូតកម្ពុជានៅឯបរទេស និងត្រូវមានវិញ្ញាបនបត្រសុខភាពបញ្ជាក់ថា គ្មានជំងឺកូវីដ-១៩ ដែលមិនលើសពី ៧២ ម៉ោងមុនពេលចេញដំណើរ។

**តារាង ២.** ការធ្លាក់ចុះចំណូលពីវិស័យទេសចរណ៍ធៀបនឹងកំណើននៃផលិតផលក្នុងស្រុក

| | ករណីល្អបំផុត | | ករណីមធ្យម | | ករណីធ្ងន់ធ្ងរបំផុត | |
|---|---|---|---|---|---|---|
| ប្រទេស | គិតជា % នៃ ផ.ស.ស | គិតជា លានដុល្លារ | គិតជា % នៃ ផ.ស.ស | គិតជា លានដុល្លារ | គិតជា % នៃ ផ.ស.ស | គិតជា លានដុល្លារ |
| កម្ពុជា | -១,៤០៩ | -៣៤៥,៧ | -១,៩២៩ | -៤៧៣,៤ | -៣,៤៩ | -៨៥៦,៥ |

***ប្រភព៖*** *ADB ២០២០*

ដើម្បីជួយកាត់បន្ថយបន្ទុកលើវិស័យសណ្ឋាគារ រាល់សណ្ឋាគារ និងផ្ទះសំណាក់ដែលបានចុះឈ្មោះក្នុងខេត្តសៀមរាប ព្រះសីហនុ កែប និងកំពត ត្រូវបានលើកលែងពន្ធរហូតដល់ខែឧសភា ឆ្នាំ២០២០[១៨]។ កម្ពុជាក៏បានអនុវត្តគោលនយោបាយម៉ាក្រូហិរញ្ញវត្ថុផ្សេងៗដូចជា កាត់បន្ថយអត្រាការប្រាក់ បន្តអនុវត្តវដ្តនៃគោលនយោបាយជួយបន្ធូរបន្ថយដែលបានចាប់ផ្តើមនៅឆ្នាំ២០១៩ ក៏ដូចជាអនុវត្តវិធានការសារពើពន្ធផ្សេងទៀត ដើម្បីជួយទ្រទ្រង់សេដ្ឋកិច្ចជាទូទៅ [១៧]។

រដ្ឋាភិបាលក៏បានព្យាយាមគ្រប់គ្រងការឆ្លងនៃវីរុសនេះដើម្បីការពារសេដ្ឋកិច្ច ដោយនៅពេលដែលចាំបាច់អនុវត្តការតាមដានស្វែងរកអ្នកដែលមានទំនាក់ទំនងជាមួយអ្នកជំងឺ ធានានូវការផ្គត់ផ្គង់ឧបករណ៍ការពារផ្ទាល់ខ្លួនឲ្យបានគ្រប់គ្រាន់ ពង្រឹងសមត្ថភាពមន្ទីរពិសោធន៍ និងធានាឲ្យមានការផ្សព្វផ្សាយឲ្យបានគ្រប់គ្រាន់ទៅកាន់សាធារណជនអំពីហានិភ័យ និងការការពារពីជំងឺនេះ។

ទោះបីមានការលំបាកក្នុងវិស័យបដិសណ្ឋារកិច្ចនាពេលបច្ចុប្បន្នក៏ដោយ មិនមានរបាយការណ៍ណាមួយរាយការណ៍ថា គម្រោងសាងសង់សណ្ឋាគារណាមួយត្រូវបានបញ្ឈប់ ឬអ្នកអភិវឌ្ឍន៍បានលុបចោលផែនការរបស់ពួកគេនោះទេ ហើយសណ្ឋាគារថ្មីជាច្រើនបានបើកដំណើរការនៅប៉ុន្មានសប្តាហ៍ចុងក្រោយនៃខែកុម្ភៈឆ្នាំ២០២០ និងនៅមានច្រើនទៀតនៅពេលឆាប់ៗខាងមុខ [២៤]។

## ការនាំចេញវិស័យកម្មន្តសាល

ឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់និងស្បែកជើងជាវិស័យចម្បង ដែលបានជួយជំរុញសេដ្ឋកិច្ចកម្ពុជា ដោយរួមចំណែក ១៧ ភាគរយ ដល់កំណើនផលិតផលក្នុងស្រុកសរុប និងផ្តល់ការងារផ្ទាល់ចំនួន ៩៤០,០០០ នាក់ ឬ ១០% នៃការងារសរុបនៅក្នុងឆ្នាំ២០១៩ (តារាងទី ១)។ ទោះយ៉ាងណាក៏ដោយ បន្ទាប់ពីការរីករាលដាលជាសកលនៃកូវីដ-១៩ ចាប់តាំងពីខែមីនា ឆ្នាំ២០២០ តម្រូវការពីអ្នកប្រើប្រាស់និងអ្នកលក់រាយនៅបរទេសមានតិចតួចតែប៉ុណ្ណោះ។ ការផ្គត់ផ្គង់វត្ថុធាតុដើមដែលត្រូវបានប្រើដើម្បីផលិតទំនិញក៏ត្រូវបានពន្យារពេលដូចគ្នា។ ជាលទ្ធផល គិតត្រឹមថ្ងៃទី១ ខែឧសភា ឆ្នាំ២០២០ មានរោងចក្រកាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរចំនួនប្រមាណ២៥៦ បានផ្អាកប្រតិបត្តិការដោយសារការផ្ទុះឡើងនៃជំងឺកូវីដ-១៩ ដែលបណ្តាលឲ្យប៉ះពាល់ដល់កម្មករជាង ១៣០,០០០ នាក់ [២៥] ។

រដ្ឋាភិបាលបានធ្វើអន្តរាគមន៍ដោយប្រកាសផ្តល់ប្រាក់ប្រចាំខែចំនួន ៧០ដុល្លារអាមេរិក សម្រាប់កម្មករម្នាក់ (៤០ដុល្លារអាមេរិកបានពីរដ្ឋាភិបាល និង ៣០ដុល្លារអាមេរិកទៀតបានពីម្ចាស់រោងចក្រ) សម្រាប់អ្នកដែលត្រូវបានបញ្ឈប់ពីការងារជាបណ្តោះអាសន្ន ក្នុងអំឡុងពេលមានវិបត្តិជំងឺកូវីដ-១៩[២៦]។ នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានប្រកាសវិធានការឧបត្ថម្ភហិរញ្ញវត្ថុនេះដល់កម្មករ ដែលត្រូវបានបញ្ឈប់ជាបណ្តោះអាសន្ននៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ស្បែកជើងនិងទេសចរណ៍[២៧]។ការចំណាយរបស់រដ្ឋាភិបាលត្រូវបានបែងចែកជា ៣ ប្រភេទដោយផ្តល់ប្រាក់ ១៥ ដុល្លារអាមេរិក សម្រាប់កម្មករ ដែលត្រូវបានបញ្ឈប់ពី ៧ ទៅ ១០ថ្ងៃ ៣០ ដុល្លារអាមេរិក សម្រាប់ចន្លោះពី ១១ ទៅ ២០ថ្ងៃ និង ៤០ ដុល្លារអាមេរិក សម្រាប់រយៈពេល ២១ ថ្ងៃទៅ ១ខែ។ គម្រោងប្រាក់ឧបត្ថម្ភនេះត្រូវបានគេសរសើរថា ជាគំរូដ៏ល្អមួយរបស់រដ្ឋាភិបាលក្នុងការដោះស្រាយវិបត្តិនៃជំងឺរាតត្បាតនៅកម្ពុជា ទោះបីការផ្តល់ជំនួយនេះមិនអាចគ្របដណ្តប់លើគ្រប់វិស័យដែលរងផលប៉ះពាល់ក៏ដោយ។ ទោះជាយ៉ាងណាក៏ដោយ ប្រាក់អតីតភាពការងារ ដែលត្រូវផ្តល់ពីរដងក្នុងមួយឆ្នាំសម្រាប់កម្មករកាត់ដេរសម្លៀកបំពាក់ និងស្បែកជើងត្រូវបានពន្យារពេលរហូតដល់ឆ្នាំ ២០២១ ពីព្រោះរដ្ឋាភិបាលក៏កំពុងផ្តល់ជំនួយសង្គ្រោះដល់ម្ចាស់រោងចក្រដើម្បីបន្ធូរបន្ថយបន្ទុករបស់ពួកគេដោយសារគ្មានការបញ្ជាទិញ និងគ្មានប្រាក់ចំណូលក្នុងអំឡុងពេលមានជំងឺរាតត្បាតនេះផងដែរ [២៨,២៩]។

**រូបភាពទី ១៖** ការមកដល់របស់ភ្ញៀវទេសចរអន្តរជាតិច្រើនបំផុតទាំង ១០ប្រទេស នៅខែមករា ឆ្នាំ២០២០




| | ចិន | វៀតណាម | ថៃ | កូរ៉េខាងត្បូង | អាមេរិក | អង់គ្លេស | បារាំង | ជប៉ុន | ឡាវ | អូស្ត្រាលី |
|---|---|---|---|---|---|---|---|---|---|---|
| ២០២០ | ១២៣,៥៥០ | ៧៥,៩២៩ | ៥៣,៨៧៤ | ៣៧,២០៦ | ៣០.៣១៥ | ២០,០៤២ | ១៩,៣៤៤ | ១៨,៧៦៧ | ១៧,៨៥០ | ១៤,០៨៧ |
| ២០១៩ | ១៨២,៤៤៩ | ៦៣,៤៩៣ | ៤៤,០៨៧ | ៤១,៣៦៤ | ៣០,២៥៤ | ១៩,៦៥៤ | ២២,១៨៩ | ១៩,៤៣៥ | ៦២,១៣៤ | ១៥,៤៧០ |
| ចំណែក (%) | ២២,៥ | ១៣,៩ | ៩,៨ | ៦,៨ | ៥,៥ | ៣,៧ | ៣,៥ | ៣,៤ | ៣,៣ | ២,៦ |
| ប្រែប្រួល (%) | -៣២,៣ | ១៩,៦ | ២២,២ | -១០,១ | ០,២ | ២ | -១២,៨ | -៣,៤ | -៧១,៣ | -១០,៥ |

*__ប្រភព៖__ ក្រសួងទេសចរណ៍កម្ពុជា ២០២០*

## សំណង់ និងអចលនទ្រព្យ

បច្ចុប្បន្នវិស័យសំណង់ គឺជាវិស័យធំបំផុតរបស់ប្រទេសកម្ពុជាដែលតំណាងឲ្យចំនួន ៣៥,៧% នៃផ.ស.ស សរុប ហើយបន្ទាប់មក គឺវិស័យទេសចរណ៍ និងវិស័យកាត់ដេរសម្លៀកបំពាក់-ស្បែកជើង (តារាងទី ១)។ សកម្មភាពពាក់ព័ន្ធនឹងវិស័យសំណង់បានផ្តល់ការងារចំនួន ២០០,០០០ កន្លែង ក្នុងឆ្នាំ២០១៩។ ការវិនិយោគពីដៃគូក្នុងតំបន់ ជាពិសេសពីប្រទេសចិន ហុងកុង និងតៃវ៉ាន់ បានចូលរួមចំណែក ៥០% នៃលំហូរចូលនៃវិនិយោគផ្ទាល់ពីបរទេសសរុបទៅក្នុងវិស័យនេះ ក្នុងប៉ុន្មានឆ្នាំថ្មីៗចុងក្រោយ[១៩]។

បន្ទាប់ពីការកើតឡើងនៃជំងឺកូវីដ-១៩ លំហូរចូលមូលធនសម្រាប់វិស័យនេះត្រូវបានកាត់ផ្តាច់មនុស្សជាច្រើនបានព្យាករណ៍ថានឹងមានការបញ្ចប់នៃការរីកដុះដាលនៃវិស័យសំណង់។ បរិមាណដែកថែបដែលបាននាំចូលសម្រាប់ឧស្សាហកម្មសំណង់ត្រូវបានកាត់បន្ថយ ៤៧ % បាត់ទៅហើយ ក្នុងរយៈពេលពីរខែដំបូងនៃឆ្នាំ២០២០ ហើយការវិនិយោគផ្ទាល់ពីបរទេសសម្រាប់វិស័យនេះបានធ្លាក់ចុះ ៤០% ក្នុងរយៈពេលដូចគ្នានេះ [១៩]។ កង្វល់បន្ថែមមួយទៀតនោះគឺ ចំនួនដ៏ច្រើននៃឥណទានមិនទាន់ទូទាត់ ដែលជះឥទ្ធិពលដល់វិស័យសំណង់ អចលនទ្រព្យ និងហ៊ីប៉ូតែក និងការកើនឡើងនូវប្រាក់កម្ចីដែលមិនដំណើរការ [១៩]។ ការធ្លាក់ចុះនៅក្នុងវិស័យសំណង់នឹងទៅទាញកំណើនសេដ្ឋកិច្ចទាំងមូល ទោះបីជាផលប៉ះពាល់របស់វាលើការងារអាចនឹងមានតិចតួចក៏ដោយ ពីព្រោះការរីកចម្រើនចុងក្រោយនៃវិស័យនេះត្រូវបានជំរុញដោយការអភិវឌ្ឍអគារប្រណិតខ្ពស់ៗ ដែលប្រើដើមទុនធំ [១៩]។

## សេចក្តីសន្និដ្ឋាន

រដ្ឋាភិបាលកម្ពុជាបានអនុវត្តតាមការណែនាំរបស់អ្នកជំនាញសុខភាពសាធារណៈជាតិ ជាពិសេសអ្នកដែលនៅក្រសួងសុខាភិបាល ដោយបានចាត់វិធានការយ៉ាងឆាប់រហ័ស និងប្រកបដោយប្រសិទ្ធភាពជាមួយនឹងយុទ្ធសាស្ត្រ ឆ្លើយតបជាបឋម ដើម្បីដោះស្រាយវិបត្តិកូវីដ-១៩។ ជាលទ្ធផលរហូតមកដល់ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២០ ពុំមានអ្នកស្លាប់ក្នុងចំណោមអ្នកកើតជំងឺកូវីដ-១៩ ទេ ហើយអ្នកជំងឺ ១២៧នាក់ (ស្រី ៣៩ ប្រុស ៨៨) បានជាសះស្បើយ និងមានអ្នកជំងឺប្រុសកម្ពុជា ២នាក់ កំពុងស្ថិតក្នុងការព្យាបាល [៣០,១៦]។

ទោះបីជាការចំណាយក្នុងជំនួយហិរញ្ញវត្ថុអាចជួយកាត់បន្ថយការខាតបង់ជាបណ្តោះអាសន្ននូវប្រាក់ចំណូល ឬប្រាក់ខែក៏ដោយ តែផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចធ្ងន់ធ្ងរនៃកូវីដ-១៩ នឹងធ្វើឲ្យប្រជាពលរដ្ឋប្រមាណ ១,៧៦ លាននាក់ប្រឈមមុខនឹងហានិភ័យនៃនិកម្មភាពនៅក្នុងវិស័យដែលរងគ្រោះខ្លាំងបំផុត រួមមានវិស័យទេសចរណ៍ កាត់ដេរសម្លៀកបំពាក់-ស្បែកជើង និងសំណង់ [១៩]។ បើគ្មានវិធានការកាត់បន្ថយហានិភ័យបន្ថែមទេ ចំនួនប្រជាពលរដ្ឋដែលនឹងធ្លាក់ចូលក្នុងភាពក្រីក្រទំនងជានឹងកើនឡើង រាប់បញ្ចូលទាំងពលករចំណាកស្រុកមួយចំនួនដែលវិលត្រឡប់មកពីប្រទេសថៃ និងគ្រួសារដែលនៅក្នុងបន្ទុករបស់ពួកគេផងដែរ។

# ១.៤.៣ សភាអឺរ៉ុបប្រឈមនឹងវិបត្តិកូវីដ-១៩

សភាអឺរ៉ុប និងសភាជាតិនៃរដ្ឋជាសមាជិកនៃសហភាពអឺរ៉ុបបានកំពុងធ្វើការយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងដ៏ស្រួចស្រាវទៅនឹងជំងឺរាតត្បាតសកលកូវីដ-១៩ ដើម្បីព្យាយាមកាត់បន្ថយផលប៉ះពាល់ ការពារប្រជាពលរដ្ឋ និងសេដ្ឋកិច្ចរបស់ខ្លួន និងលើកកម្ពស់សាមគ្គីភាព។

សភាអឺរ៉ុបបានគាំទ្រសកម្មភាពទាំង ១០ ដែលបានធ្វើឡើងដោយគណៈកម្មការអឺរ៉ុបក្នុងការប្រយុទ្ធប្រឆាំងវីរុសកូរ៉ូណា ទោះបីជា យើងអាចចាំថា បើយោងតាមសន្ធិសញ្ញានានា បញ្ហាសុខភាពមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់សហភាពអឺរ៉ុបទេ តែគឺជាការទទួលខុសត្រូវរបស់រដ្ឋាភិបាលនៃប្រទេសជាសមាជិក។ ទោះបីជាបែបនេះក្តី សហភាពអឺរ៉ុបបានរៀបចំនីតិវិធីជាបន្តបន្ទាប់ រួមទាំងការផ្ទេរអ្នកជំងឺឆ្លងព្រំដែន ដោយមានការសម្របសម្រួលរវាងមន្ទីរពេទ្យ (បារាំង អាល្លឺម៉ង់ និងលុចសំបួ)។ ជាការពិតជំងឺរាតត្បាតសកលនេះបានផ្តល់ផលវិបាកដែលប៉ះពាល់ហួសពីវិស័យសុខាភិបាល តែប៉ះពាល់ដល់វិស័យជាច្រើនទៀត ដែលស្ថិតនៅក្នុងដែនអំណាចដែលមាននៅក្នុងសហភាពអឺរ៉ុប (ការគាំទ្រផ្នែកហិរញ្ញវត្ថុពីធនាគារកណ្តាលអឺរ៉ុប ការបន្ធូរបន្ថយវិធានការរូបិយវត្ថុ និងការសម្របសម្រួលការគ្រប់គ្រងព្រំដែនខាងក្រៅ)។

អត្ថបទនេះបង្ហាញជាដំបូងពីវិធានការដែលចាត់ចែងដោយគណៈកម្មការសហភាពអឺរ៉ុប បន្ទាប់មកអនុសាសន៍របស់សភាសហភាពអឺរ៉ុប និងចុងក្រោយពីគំនិតផ្តួចផ្តើមដែលធ្វើឡើងរួមគ្នារវាងបារាំង និងអាល្លឺម៉ង់។

## សកម្មភាពទាំង ១០ ដែលចាត់វិធានការដោយសហភាពអឺរ៉ុប[៣១]

### ព្រំដែន

ដើម្បីជួយទប់ស្កាត់ការចម្លងវីរុសនៅអឺរ៉ុបនិងនៅកន្លែងដទៃទៀត សហភាពអឺរ៉ុបបានបិទព្រំដែនខាងក្រៅរបស់ខ្លួនសម្រាប់ការធ្វើដំណើរដែលមិនចាំបាច់ តែធានាឲ្យមានការបន្តចរាចរណ៍ទំនិញសំខាន់ៗនៅក្នុងសហភាពអឺរ៉ុប តាមរយៈការដាក់ចេញនូវច្រកសុវត្ថិភាព (Green Lanes)។ ធនធានបន្ថែមត្រូវបានរៀបចំរួចរាល់សម្រាប់មជ្ឈមណ្ឌលអឺរ៉ុបគ្រប់គ្រង និងការពារជំងឺ ជាភ្នាក់ងារដែលមានភារកិច្ចផ្តល់ការវាយតម្លៃឆាប់រហ័សលើហានិភ័យ និងផ្តល់ព័ត៌មានបច្ចុប្បន្នភាពពីការផ្ទុះឡើងនៃពេគរាតត្បាតនេះ។

### ការផ្តល់ឧបករណ៍វេជ្ជសាស្ត្រ

បណ្តាប្រទេសក្នុងសហភាពអឺរ៉ុបមានស្តុកសម្ភារៈវេជ្ជសាស្ត្រដំបូងគេ RescEU ដែលអាចយកមកប្រើប្រាស់បានលឿន មានដូចជាឧបករណ៍ជួយការដកដង្ហើម និងម៉ាស់ការពារ ក្រោមយន្តការការពារជនស៊ីវិល។ លើសពីនេះទៀតសហភាពអឺរ៉ុបបានបង្កើតមូលនិធិអន្តរជាតិដ៏ធំមួយដែលអនុញ្ញាតឲ្យរដ្ឋជាសមាជិកធ្វើការទិញឧបករណ៍ និងថ្នាំរួមគ្នា ហើយកំពុងកៀរគរថវិកាចំនួន ៣,០៨ ពាន់លានអឺរ៉ូ ក្រោមជំនួយរបស់សហភាពអឺរ៉ុប ដើម្បីទិញឧបករណ៍ធ្វើតេស្តបន្ថែម និងជួយបុគ្គលិកពេទ្យដែលថែទាំអ្នកជំងឺ។ សហភាពអឺរ៉ុបក៏បានរៀបចំកម្មវិធីរៃអង្គាសប្រាក់តាមអ៊ីនធឺណែត ដើម្បីរៃអង្គាសថវិកាឲ្យបានចំនួនដំបូង ៧,៥ ពាន់លានអឺរ៉ូ សម្រាប់ការស្រាវជ្រាវវ៉ាក់សាំង ថ្នាំ និងការធ្វើពេគវិនិច្ឆ័យ ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺនេះទូទាំងសកលលោក។

### ការលើកកម្ពស់ការស្រាវជ្រាវ

កម្មវិធីស្រាវជ្រាវ Horizon ២០២០ របស់សហភាពអឺរ៉ុបផ្តល់ថវិកាដល់គម្រោងស្រាវជ្រាវចំនួន ១៨ និង១៥១ក្រុម នៅទូទាំងទ្វីបអឺរ៉ុប ដើម្បីជួយស្រាវជ្រាវរកវ៉ាក់សាំង COVID-១៩ ឲ្យបានឆាប់រហ័ស។ គោលបំណងជាក់លាក់គឺធ្វើឲ្យប្រសើរឡើងនូវការធ្វើពេគវិនិច្ឆ័យ ការត្រៀមខ្លួនជាស្រេច ការគ្រប់គ្រងវេជ្ជសាស្ត្រ និងការព្យាបាល។

### ការជំរុញសាមគ្គីភាពអឺរ៉ុប

សភាអឺរ៉ុបបានគាំទ្រនូវវិធានថ្មី ដែលអនុញ្ញាតឲ្យរដ្ឋជាសមាជិកស្នើសុំជំនួយហិរញ្ញវត្ថុពីមូលនិធិសាមគ្គីភាពអឺរ៉ុបដើម្បីគ្រប់គ្រងលើភាពអាសន្នផ្នែកសុខភាព។ ជាមួយនឹងវិសាលភាពថ្មីដែលត្រូវបានពង្រីកបន្ថែមនៃមូលនិធិនេះ ទឹកប្រាក់ រហូតដល់ចំនួន ៨០០លានអឺរ៉ូ នឹងត្រូវត្រៀមសម្រាប់រដ្ឋជាសមាជិកក្នុងឆ្នាំ២០២០ ដើម្បីប្រយុទ្ធប្រឆាំងនឹងការរាតត្បាតជាសកលនៃវីរុសកូរ៉ូណានេះ។

### ការធានានូវការងើបឡើងវិញរបស់សហភាពអឺរ៉ុប

ដើម្បីជួយសហភាពអឺរ៉ុបឲ្យងើបឡើងវិញពីផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចនិងសង្គម ដែលបណ្តាលមកពីកូវីដ-១៩ គណៈកម្មការអឺរ៉ុបត្រូវបានស្នើសុំឲ្យធ្វើបច្ចុប្បន្នភាពទៅលើផែនការថវិការយៈពេលវែងរបស់សហភាពអឺរ៉ុបសម្រាប់ឆ្នាំ ២០២១-២០២៧ ដែលក្នុងនោះរួមមានកញ្ចប់ដើម្បីជំរុញសន្ទុះសេដ្ឋកិច្ចផងដែរ។ សមាជិក សមាជិកានៃសភាអឺរ៉ុប (MEPs) បានអំពាវនាវឲ្យមានកញ្ចប់សម្រាប់ការស្តារ និងការស្ថាបនាឡើងវិញដ៏ធំមួយដែលត្រូវបានផ្តល់ហិរញ្ញប្បទាន

ពីកំណើនកញ្ចប់ថវិការយៈពេលវែងសម្រាប់សហភាពអឺរ៉ុប មូលនិធិសហភាពអឺរ៉ុបដែលមានស្រាប់ និងមធ្យោបាយហិរញ្ញវត្ថុ ក៏ដូចជាពីអ្វីដែលគេហៅថា ប័ណ្ណបំណុលសម្រាប់ការស្តារឡើងវិញ។ លើសពីនេះទៀតគណៈកម្មការបានបង្ហាញពីផែនទីបង្ហាញផ្លូវក្រោយការបិទប្រទេសរបស់ខ្លួនសម្រាប់ជាយុទ្ធសាស្ត្រត្រៀមឲ្យមានប្រសិទ្ធភាព និងមានការសម្របសម្រួល ដែលរួមបញ្ចូលទាំងការធ្វើតេស្តទ្រង់ទ្រាយធំ និងសម្ភារៈការពារសម្រាប់ប្រជាពលរដ្ឋ។

## ការគាំទ្រសេដ្ឋកិច្ច

សហភាពអឺរ៉ុបបានដាក់ចេញនូវកញ្ចប់ថវិកាគាំទ្រ ៥៤០ ពាន់លានអឺរ៉ូ ដើម្បីដោះស្រាយវិបត្តិ ជួយដល់កម្មករ ធុរកិច្ច និងរដ្ឋជាសមាជិក។ លើសពីនេះទៀត ធនាគារកណ្តាលអឺរ៉ុបកំពុងផ្តល់ប្រាក់ចំនួន ៧៥០ពាន់លានអឺរ៉ូ ដើម្បីសម្រាលបំណុលរដ្ឋាភិបាលក្នុងពេលមានវិបត្តិ ក៏ដូចជាការបញ្ចេញកញ្ចប់ថវិកាចំនួន ១២០ពាន់លានអឺរ៉ូសម្រាប់ទិញមូលប័ត្រ និងចំនួន ២០ពាន់លានអឺរ៉ូ សម្រាប់ការទិញបំណុល។ សមាជិក សមាជិកានៃសភាអឺរ៉ុបក៏បានបោះឆ្នោតគាំទ្រការអនុញ្ញាតឲ្យប្រទេសនៅសហភាពអឺរ៉ុបប្រើប្រាស់ទឹកប្រាក់ចំនួន ៣៧ពាន់លានអឺរ៉ូ នៃមូលនិធិអឺរ៉ុបសម្រាប់ការគាំទ្រសេដ្ឋកិច្ច និងកាត់បន្ថយវិសមភាពរវាងតំបន់នីមួយៗក្នុងអឺរ៉ុប (EU Strutural Fund) ដែលមានស្រាប់ ដើម្បីដោះស្រាយវិបត្តិវីរុសកូរ៉ូណា និងគាំទ្រសេវាកម្មថែទាំសុខភាព ធុរកិច្ច និងកម្មករ។

## ការការពារមុខរបរ

ដើម្បីធានាថា និយោជិកអាចរក្សាការងាររបស់ពួកគេបាន គណៈកម្មការបានស្នើឲ្យមានការគាំទ្រដល់ការងាររយៈពេលខ្លី (Sure) ដោយផ្តល់មូលនិធិសម្រាប់ក្រុមហ៊ុនដែលប្រឈមនឹងការថយចុះនៃតម្រូវការដោយសារតែវិបត្តិវីរុសកូរ៉ូណា។ គណៈកម្មការអឺរ៉ុបក៏បានដកប្រាក់ចំនួន ១ ពាន់លានអឺរ៉ូ ពីមូលនិធិអឺរ៉ុបសម្រាប់ការវិនិយោគយុទ្ធសាស្ត្រសម្រាប់ធានាដល់ការលើកទឹកចិត្តធនាគារ និងអ្នកផ្តល់ប្រាក់កម្ចីផ្សេងៗ ដោយផ្តល់ថវិកាដល់ទៅ ៨ពាន់លានអឺរ៉ូជាសាច់ប្រាក់ ដើម្បីគាំទ្រដល់ធុរកិច្ចចំនួន ១០០,០០០ នៅអឺរ៉ុប ។

## ការធ្វើមាតុភូមិនិវត្តន៍របស់ពលរដ្ឋអឺរ៉ុប

ប្រជាពលរដ្ឋអឺរ៉ុបរាប់ម៉ឺននាក់ដែលជាប់នៅក្រៅប្រទេសនៅជុំវិញពិភពលោកដោយសារការផ្ទុះឡើងនៃជំងឺនេះ ត្រូវបានបញ្ជូនត្រឡប់ទៅផ្ទះវិញដោយសារយន្តការការពារជនស៊ីវិលអឺរ៉ុប។

## ការជួយប្រទេសកំពុងអភិវឌ្ឍន៍ដែលប្រឈមនឹងការរាតត្បាតសកល

គណៈកម្មាធិការអឺរ៉ុបបានបញ្ចេញទឹកប្រាក់ចំនួន ២០ ពាន់លានអឺរ៉ូ ដើម្បីជួយប្រទេសមិនមែនជាសមាជិកសហភាពអឺរ៉ុប ក្នុងការប្រយុទ្ធប្រឆាំងនឹងវិបត្តិនេះ ដែលជាផ្នែកមួយនៃកញ្ចប់ថវិកាសហភាពអឺរ៉ុបសម្រាប់ជួយសម្របសម្រួលការឆ្លើយតបជាសកលដើម្បីដោះស្រាយការរីករាលដាលនៃកូវីដ-១៩ ។

## ការធានានូវព័ត៌មានត្រឹមត្រូវ

ការផ្សព្វផ្សាយព័ត៌មានមិនត្រឹមត្រូវអំពីវីរុសកូរ៉ូណាធ្វើឲ្យកាន់តែមានគ្រោះថ្នាក់ចំពោះសុខភាពប្រជាពលរដ្ឋ។ សមាជិក សមាជិកាសភាអឺរ៉ុបបានអំពាវនាវឲ្យប្រគពព័ត៌មានអឺរ៉ុបទាំងអស់ធានាថា មនុស្សគ្រប់គ្នាអាចទទួលបានព័ត៌មានត្រឹមត្រូវ និងមានការផ្ទៀងផ្ទាត់តាមភាសារបស់ពួកគេ ហើយក៏បានស្នើសុំឲ្យក្រុមហ៊ុនបណ្តាញសង្គមដោះស្រាយចំពោះការផ្សព្វផ្សាយព័ត៌មានមិនពិត និងការប្រើពាក្យសម្តីនាំឲ្យមានការស្អប់ខ្ពើមគ្នា។

## សកម្មភាពរបស់សភាអឺរ៉ុប [៣២]

នៅក្នុងសេចក្តីសម្រេចមួយដែលត្រូវបានអនុម័តនៅថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២០ សភាអឺរ៉ុបបានស្វាគមន៍ចំពោះវិធានការសារពើពន្ធ និងការគាំទ្រជាសាច់ប្រាក់របស់សហភាពអឺរ៉ុប ដើម្បីដោះស្រាយជំងឺរាតត្បាតសកលនេះ។ សមាជិក សមាជិកាសភាក៏បានបញ្ជាក់ផងដែរថា ក្រៅពីអ្វីដែលបាននិងកំពុងធ្វើ អឺរ៉ុបក៏ត្រូវការកញ្ចប់ថវិកាសម្រាប់ការស្តារនិងកសាងឡើងវិញដ៏ធំមួយ ដែលផ្តល់ហិរញ្ញប្បទានដោយកំណើនកញ្ចប់ថវិការយៈពេលវែង (MFF) មូលនិធិសហភាពអឺរ៉ុបដែលមានស្រាប់ និងមធ្យោបាយហិរញ្ញវត្ថុ ក៏ដូចជា "ប័ណ្ណបំណុលសម្រាប់ការស្តារឡើងវិញ" ដែលធានាដោយកញ្ចប់ថវិការបស់សហភាពអឺរ៉ុប។ សមាជិក សមាជិកាសភាបានបញ្ជាក់ថា ទោះបីជាយ៉ាងណាក៏ដោយ ការឆ្លើយតបខាងសេដ្ឋកិច្ចទៅនឹងវីរុសនេះមិនគួរពាក់ព័ន្ធនឹងការចែករំលែកស្មើគ្នានូវបន្ទុកបំណុល ដែលមានស្រាប់នោះទេ ប៉ុន្តែគួរផ្តោតលើការវិនិយោគនាពេលអនាគត។ សមាជិក សមាជិកាសភាបានសង្កត់ធ្ងន់ថា កិច្ចព្រមព្រៀងបៃតងនៃសហភាពអឺរ៉ុប និងការផ្លាស់ប្តូរផ្នែកឌីជីថល គួរតែជាចំណុចស្នូលរបស់ខ្លួនដើម្បីជំរុញការចាប់ផ្តើមសេដ្ឋកិច្ច។

## ព្រំដែន

សមាជិក សមាជិកាសភាបានទទូចថា ព្រំដែននៅក្នុងសហភាពអឺរ៉ុបត្រូវតែរក្សាឲ្យបើកចំហ ដើម្បីធានាថា ឱសថ

ឧបករណ៍ការពារ បរិក្ខារវេជ្ជសាស្ត្រ ម្ហូបអាហារ និងទំនិញចាំបាច់នានាអាចចរាចរបាន។ ពួកគេបានទទួលស្គាល់ថា ទីផ្សាររួមតែមួយរបស់សហភាពអឺរ៉ុប គឺជាប្រភពនៃ «វិបុលភាពសម្ញហាភាពរបស់យើង» និងជាគន្លឹះក្នុងការឆ្លើយតបបន្ទាន់ និងជាបន្តបន្ទាប់ទៅនឹងកូវីដ-១៩។

## ការការពារ

សភាអឺរ៉ុបបានអំពាវនាវឲ្យបង្កើតយន្តការឆ្លើយតបផ្នែកសុខភាពរបស់អឺរ៉ុប ដើម្បីធានាឲ្យមានការឆ្លើយតបប្រសើរជាងមុនចំពោះវិបត្តិសុខភាព ឬអនាម័យនាពេលអនាគត។ គេសង្ឃឹមថាឧបករណ៍ចាំបាច់ សម្ភារៈ និងស្តុកថ្នាំអាចប្រមូលបានឆាប់រហ័ស ដើម្បីជួយសង្គ្រោះជីវិតមនុស្ស។ ក្នុងករណីបន្ទាន់ សមាជិក សមាជិកាសភាក៏ចង់ឃើញមានថវិកាបន្ថែមរបស់សហភាពអឺរ៉ុបសម្រាប់គាំទ្រផ្នែកហិរញ្ញវត្ថុលើការស្រាវជ្រាវស្វែងរកវ៉ាក់សាំងផងដែរ។

## មូលនិធិសាមគ្គីភាពសហភាពអឺរ៉ុបសម្រាប់ប្រយុទ្ធប្រឆាំងនឹងវីរុសកូរ៉ូណា

សមាជិក សមាជិកានៃសភាអឺរ៉ុបក៏បានអំពាវនាវឲ្យមានជាអចិន្ត្រៃយ៍គម្រោងធានាភាពគ្មានការងារធ្វើរបស់អឺរ៉ុប ហើយសង្ឃឹមថា នឹងមានការបង្កើតមូលនិធិសាមគ្គីភាពសហភាពអឺរ៉ុបសម្រាប់ប្រយុទ្ធប្រឆាំងនឹងវីរុសកូរ៉ូណា ដែលមានទឹកប្រាក់យ៉ាងហោចណាស់ចំនួន ៥០ ពាន់លានអឺរ៉ូ។ មូលនិធិដែលបានស្នើឡើងនេះមានគោលបំណងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងផ្នែកហិរញ្ញវត្ថុ សម្រាប់យកមកអនុវត្តក្នុងវិស័យថែទាំសុខភាពនៅក្នុងរដ្ឋជាសមាជិកទាំងអស់ក្នុងពេលមានវិបត្តិ ក៏ដូចជាផ្តល់នូវការវិនិយោគនាពេលអនាគត ដើម្បីធ្វើឲ្យប្រព័ន្ធថែទាំសុខភាពទាំងនោះមានភាពធន់ និងផ្តោតការយកចិត្តទុកដាក់បន្ថែមទៅលើអ្នកដែលមានតម្រូវការបំផុត។

## ការផ្តល់អំណាចធំជាងមុនសម្រាប់សហភាពអឺរ៉ុបក្នុងការដោះស្រាយការគំរាមកំហែងសុខភាពឆ្លងព្រំដែន

សេចក្តីសម្រេចថ្ងៃសុក្រ ទី១៤ បានថែងថា ដំណោះស្រាយរួមរបស់អឺរ៉ុបដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាតសកលកូវីដ-១៩ គឺពិតជាមិនអាចខ្វះបាន។ សហភាពអឺរ៉ុបមិនត្រឹមតែត្រូវធ្វើខ្លួនឲ្យបានខ្លាំងជាងមុនដើម្បីងើបចេញពីវិបត្តិនេះនោះទេ តែស្ថាប័នអឺរ៉ុបនានាក៏គួរតែត្រូវបានផ្តល់អំណាចដើម្បីធ្វើសកម្មភាពនៅពេលដែលមានការគំរាមកំហែងសុខភាពឆ្លងព្រំដែនកើតឡើង។ ការណ៍នេះអាចឲ្យស្ថាប័នទាំងនោះសម្របសម្រួលការឆ្លើយតបនៅកម្រិតអឺរ៉ុបដោយមិនបង្អង់យូរនិងអាចនាំយកធនធានចាំបាច់ទៅកន្លែងដែលត្រូវការបំផុត មិនថាជាសម្ភារៈ ដូចជាម៉ាស់មុខ ឧបករណ៍ជួយដកដង្ហើម និងថ្នាំ ឬជំនួយហិរញ្ញវត្ថុនោះទេ។ សមាជិក សមាជិកានៃសភាអឺរ៉ុបក៏បានសម្តែងការគាំទ្ររបស់ពួកគេចំពោះការបង្កើនការផលិតសំខាន់ៗក្នុងសហភាពអឺរ៉ុប ដូចជា គ្រឿងផ្សំឱសថ បរិក្ខារ ឧបករណ៍ និងគ្រឿងប្រើប្រាស់វេជ្ជសាស្ត្រ ដើម្បីធានាថា អឺរ៉ុបបានរៀបចំខ្លួនដ៏ប្រសើរដើម្បីទប់ទល់នឹងវិបត្តិសកលនាពេលអនាគត។

## វិធីសាស្ត្រសម្របសម្រួលក្រោយការបិទប្រទេសដែលត្រូវការ

សមាជិក សមាជិកានៃសភាអឺរ៉ុបបានគូសបញ្ជាក់បន្ថែមនូវតម្រូវការឲ្យមានវិធីសាស្ត្រសម្របសម្រួលមួយ ក្រោយការបិទប្រទេសនៅសហភាពអឺរ៉ុប ដើម្បីចៀសវាងការរីករាលដាលឡើងវិញនៃវីរុស។ ពួកគេបានជំរុញឲ្យបណ្តាប្រទេសនៅសហភាពអឺរ៉ុបរួមគ្នាបង្កើតលក្ខណៈវិនិច្ឆ័យសម្រាប់ការបញ្ឈប់ការធ្វើចត្តាឡីស័ក និងវិធានការណ៍បន្ទាន់នានាផ្សេងទៀត ហើយបានស្នើសុំឲ្យគណៈកម្មការអឺរ៉ុបដាក់ចេញនូវយុទ្ធសាស្ត្រត្រៀមដើម្បីងើបចេញពីវិបត្តិឲ្យមានប្រសិទ្ធភាព ដែលរួមមានទាំងការធ្វើតេស្តទ្រង់ទ្រាយធំ និងឧបករណ៍ការពារផ្ទាល់ខ្លួន សម្រាប់ចំនួនប្រជាពលរដ្ឋច្រើនបំផុតតាមដែលអាចធ្វើទៅបាន។

## ប្រភពព័ត៌មានអឺរ៉ុបសម្រាប់ទប់ស្កាត់នឹងការផ្សព្វផ្សាយព័ត៌មានមិនពិត

ជាចុងក្រោយ សេចក្តីសម្រេចបានសង្កត់ធ្ងន់ថា ការផ្សព្វផ្សាយព័ត៌មានមិនពិតអំពីជំងឺកូវីដ-១៩ គឺជាកង្វល់សុខភាព សាធារណៈដ៏ធំមួយ។ ដូចនេះហើយ សមាជិក សមាជិកានៃសភាអឺរ៉ុបបានស្នើថា អឺរ៉ុបគួរតែបង្កើតប្រភពព័ត៌មានអឺរ៉ុប ដើម្បីធានាថា ប្រជាពលរដ្ឋទាំងអស់អាចទទួលបានព័ត៌មានត្រឹមត្រូវ និងព័ត៌មានដែលមានការផ្ទៀងផ្ទាត់ច្បាស់លាស់។ សមាជិក សមាជិកាសភាក៏បានអំពាវនាវដល់ក្រុមហ៊ុនបណ្តាញសង្គមនានាចាត់វិធានការប្រកបដោយបុរេសកម្ម ដើម្បីបញ្ឈប់ការរីករាលដាលនៃការផ្សព្វផ្សាយព័ត៌មានមិនពិត និងពាក្យសម្តីស្អប់ខ្ពើមដែលទាក់ទងទៅនឹងមេរោគនេះ។

## តួនាទីរបស់សភាជាតិ

ស្ថាប័ននីតិប្បញ្ញត្តិនៃរដ្ឋជាសមាជិកមួយចំនួនបានដោះស្រាយបញ្ហាមួយចំនួននៅថ្នាក់ជាតិ ទាក់ទងនឹងការរឹតត្បិតសេរីភាពបណ្តោះអាសន្ន ការតាមដានស្វែងរក និងការត្រួតពិនិត្យអ្នកដែលឆ្លងជំងឺ និងការត្រួតពិនិត្យរកព័ត៌មានពិត។

បារាំងជាប្រទេសនៃសហភាពអឺរ៉ុបតែមួយគត់ដែលតម្រូវឲ្យមានការបោះឆ្នោតដោយរដ្ឋសភានិងព្រឹទ្ធសភា មុនពេលរដ្ឋាភិបាលអាចប្រកាសនិងធ្វើសកម្មភាពលើស្ថានភាពអាសន្នផ្នែកសុខភាព [៣៣]។ បញ្ហាសំខាន់ៗមួយចំនួនដែលត្រូវបានពិភាក្សាក្នុងសភា គឺការទទួលខុសត្រូវរបស់អភិបាលក្រុងក្នុងការវិនិច្ឆ័យលើការបើកសាលារៀនឡើងវិញ និងដែនកំណត់នៃសេរីភាពក្នុងការធ្វើដំណើរ ដែលគិតត្រឹមពេលសរសេរអត្ថបទនេះ នៅតែត្រូវបានរឹតត្បិតត្រឹមនៅក្នុងកាំរង្វង់ចម្ងាយ១០០គីឡូម៉ែត្រជុំវិញ។

នៅប្រទេសអាល្លឺម៉ង់ បញ្ហាសំខាន់មួយគឺការចេញ «ប័ណ្ណបំណុលកូរ៉ូណា» ដើម្បីបង្កើតយន្តការមួយសម្រាប់ចែករំលែកបំណុលសាធារណៈរវាងរដ្ឋជាសមាជិកអឺរ៉ុប។ អធិការបតី Angela Markel បានសង្កត់ធ្ងន់លើចំណុចនេះទៅកាន់សភា Bundestag របស់ខ្លួនថា ជំហានបែបនេះ គឺជាមធ្យោបាយតែមួយគត់ដែលអាចជៀសវាងការដួលរលំនៃប្រព័ន្ធសេដ្ឋកិច្ច របស់សហភាពអឺរ៉ុប ("Systemabsturz")។

នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០ លោកស្រី Angela Merkel និងប្រធានាធិបតីបារាំង Emmanuel Macron បានប្រកាសកិច្ចព្រមព្រៀងទ្វេភាគី ដើម្បីគាំទ្រដល់ការស្តារសេដ្ឋកិច្ចឡើងវិញតាមរយៈការជួយតំបន់និងវិស័យដែលខ្សោយបំផុតនៅក្នុងប្រទេសនៃសហភាពអឺរ៉ុបទាំង ២៧ (EU 27)។ កិច្ចព្រមព្រៀងនេះនឹងអនុញ្ញាតឲ្យគណៈកម្មការសហភាពអឺរ៉ុបខ្ចីប្រាក់រហូតដល់ ៥០០ពាន់លានអឺរ៉ូ ពីទីផ្សារហិរញ្ញវត្ថុ។ ជាការពិត ភាពខុសគ្នានៅតែមានក្នុងចំណោមប្រទេសនៃសហភាពអឺរ៉ុបទាំង ២៧ ទាក់ទងនឹងវិសាលភាព និងមធ្យោបាយនៃសាមគ្គីភាពអឺរ៉ុប ដូចជាការចែករំលែកបំណុល ប្រាក់កម្ចី ឬជំនួយឥតសំណងដើម្បីជួយប្រទេសដែលរងផលប៉ះពាល់ធ្ងន់ធ្ងរបំផុតពីកូវីដ-១៩ ដែលក្នុងនោះមានអ៊ីតាលី និងអេស្ប៉ាញជាប្រទេសអាទិភាព។

សរុបសេចក្តីមក សហភាពអឺរ៉ុបនៅតែប្តេជ្ញាចិត្តយ៉ាងមុតមាំប្រកាន់យកពហុភាគីនិយមថា ជាមធ្យោបាយដ៏សក្តិសមតែមួយគត់ដើម្បីដោះស្រាយបញ្ហាប្រឈមរួមគ្នានេះ ដែលការក្រើនរំលឹកនេះដូចជាធ្ងន់ធ្ងរបន្តិចតែជាការល្អដែលរំលឹកយើងពីភាពកាន់តែកើនឡើងក្នុងការទាក់ទងគ្នាទៅវិញទៅមក។ ប្រជាពលរដ្ឋនៅអឺរ៉ុបបានឃើញវីរុសនេះជាលើកដំបូងនៅក្នុងតំបន់ឧស្សាហកម្ម ដែលមានទីតាំងនៅភាគខាងជើងនៃប្រទេសអ៊ីតាលី(Lombardy) និងនៅទីក្រុងបាវ៉ារៀ (Bavaria) ដែលមានទំនាក់ទំនងសេដ្ឋកិច្ច និងពេញនិយមជាមួយទីក្រុងវូហាននៃប្រទេសចិន។ វាទំនងជាឆ្លងចូលប្រទេសអេស្ប៉ាញតាមរយៈអ្នកគាំទ្រនៃក្លឹបបាល់ទាត់ Valencia ចំនួន ៣០០០ នាក់ ដែលបានទៅទីក្រុង Milan មើលការប្រកួតរវាងក្រុមរបស់ពួកគេនិងក្រុម Atalanta មកពី Lombardy។ ករណីដំបូងៗផ្សេងទៀតត្រូវបានគេតាមរកឃើញនៅរមណីយដ្ឋានជិះស្គីនៅតំបន់ភ្នំអាល់បារាំង (French Alps) ដែលទំនងជាឆ្លងពីជនជាតិអង់គ្លេសដែលត្រឡប់មកពីសន្និសីទនៅឯប្រទេសសិង្ហបុរី ដែលពួកគេបានបរិភោគអាហារពេលល្ងាចជាមួយអ្នកចូលរួមសន្និសីទមកពីវូហាន។ ការរីករាលដាលនៃ COVID-១៩ បានឆ្លុះបញ្ចាំងពីវិធីជាច្រើនដែលប្រជាពលរដ្ឋមកពីជុំវិញពិភពលោកនាពេលបច្ចុប្បន្នធ្វើការទាក់ទងគ្នាដូចជា ធុរកិច្ចពិភពលោក សិក្ខាសាលាអន្តរជាតិ ទេសចរណ៍ និងការជួបជុំខាងសាសនា កីឡា និងការធ្វើចំណាកស្រុកដើម្បីស្វែងរកការងារជាដើម។ នៅឆ្នាំ២០១៨ អ្នកដំណើរចំនួន ៤,៥ពាន់លាននាក់ បានធ្វើដំណើរតាមផ្លូវអាកាស។ មិនមានអ្វីគួរឲ្យភ្ញាក់ផ្អើលនោះទេ ការចម្លងកូវីដ-១៩ ក៏កើតឡើងតាមរយៈចរាចរណ៍ផ្លូវអាកាសសំខាន់ៗផងដែរ។ ទោះបីជាមានវិបត្តិនាពេលបច្ចុប្បន្នក៏ដោយ និន្នាការនៃការកើនឡើងអន្តរកម្មរវាងពលរដ្ឋនៃពិភពលោកហាក់ដូចជានៅតែបន្តទៅអនាគត។ ការសម្របសម្រួល និងការគ្រប់គ្រងតាមបទបញ្ញត្តិនូវពិភពលោកដែលមានភាពស្មុគស្មាញ និងមានការកើនឡើងនៃអន្តរទំនាក់ទំនង គឺជាការទទួលខុសត្រូវស្នូលរបស់សភា។

ក្នុងចំណោមរដ្ឋាភិបាល សភា និងពលរដ្ឋនៃទ្វីបអឺរ៉ុប ការឆ្លងកាត់បទពិសោធន៍រួមគ្នាក្នុងការប្រឈមទៅនឹងកូវីដ-១៩ បានកសាងជាថ្មីនូវជំនឿដ៏មុតមាំលើគុណតម្លៃនៃពហុភាគីនិយម ដែលជាឧបករណ៍មិនអាចខ្វះបានសម្រាប់ជួយក្នុងការដោះដូរទិន្នន័យវិទ្យាសាស្ត្រ ការសម្របសម្រួលការឆ្លើយតបចំពោះភាពអាសន្ននិងការបង្កើតវិធានរួមគ្នា។មានការសោកស្តាយយ៉ាងខ្លាំងផងដែរចំពោះជំហរឯកតោភាគីដ៏អកុសល ដែលត្រូវបានប្រកាន់យកដោយមហាអំណាចមួយចំនួន ជាពិសេសនៅចំពេលដែលមានការបញ្ជាក់ថាការធ្វើសកម្មភាពរួមគ្នា ពិតជាមានសារៈសំខាន់។ ជាការពិត ការប្រឈមទៅនឹងវិបត្តិកូវីដ-១៩ រួមគ្នា និងការឆ្លើយតបស្របគ្នា បានបង្ហាញថា ពហុភាគីនិយមគឺជា ចម្លើយទាំងផ្នែកស្ថាប័ន និងនយោបាយតែមួយគត់ ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈម និងឱកាសរួមនៃពិភពលោករបស់យើង ដែលមានទំនាក់ទំនងគ្នាទៅវិញទៅមកទាំងខាងសង្គម សេដ្ឋកិច្ច និងបច្ចេកវិទ្យា។

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការ ដែលបកដោយវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិនៃកម្ពុជា (NIDIR)។ អ្នកអានអាចទាញយកអត្ថបទដើមជាភាសាអង់គ្លេសពីគេហទំព័រ៖ https://www.pic.org.kh ។

# ១.៥ តើសភាអាចមានភាពនិម្មិតបានក្នុងកម្រិតណា?

ជំងឺរាតត្បាតសកលកូវីដ-១៩ បានជម្រុញឲ្យយើងផ្តោតការយកចិត្តទុកដាក់ទៅលើដំណើរការនៃប្រព័ន្ធនយោបាយរបស់យើង។ ក្នុងប្រទេសស្វីស បើនិយាយដោយឡែកយើងបានឃើញច្បាស់ថាទំនាក់ទំនងរវាងសភានិងរដ្ឋាភិបាលក្នុងអំឡុងពេលប្រឈមនឹងវិបត្តិនៅមិនទាន់ត្រូវបានកំណត់ពេញលេញនៅឡើយទេ ហើយម្យ៉ាងទៀតតួនាទីរបស់សភាក្នុងអំឡុងស្ថានភាពបច្ចុប្បន្ននៃវិបត្តិក៏នៅមិនច្បាស់លាស់សម្រាប់សមាជិកសមាជិកាសភាក៏ដូចជាសម្រាប់រដ្ឋាភិបាលដែរ។ ក្នុងប្រព័ន្ធប្រជាធិបតេយ្យ នយោបាយមិនអាចជាបញ្ហាផ្តាច់មុខរបស់រដ្ឋាភិបាលទេ ប៉ុន្តែគេនៅតែអាចចោទជាសំណួរឡើងថា៖ តើសភាពិតជាចាំបាច់ត្រូវជួបប្រជុំ បើទោះបីក្នុងអំឡុងពេលមានវិបត្តិដែរឬទេ? ដើម្បីជាជំនួយស្មារតីក្នុងការឈ្វេងយល់អំពីសំណួរនេះ អត្ថបទនេះនឹងផ្តល់សេចក្តីសង្ខេបគោលៗអំពី វិធីសាស្ត្រដែលប្រទេសស្វីសអនុវត្តក្នុងការទប់ទល់ទៅនឹងវិបត្តិកូវីដ ហើយជាពិសេសថាតើសំនួរអំពីសភានិយមលេចឡើងយ៉ាងដូចម្តេចនៅតំបន់ហ្ស៊ូរិច។

## និដ្ឋភាពទូទៅ [៣៤]

ដោយសារតែជំងឺរាតត្បាតសកលកូវីដ-១៩ ប្រទេសស្វីសបានដាក់ប្រទេសក្នុងភាពអាសន្នផ្នែកនយោបាយចាប់ពីខែមីនា ដល់ខែឧសភា ឆ្នាំ២០២០។ ផ្អែកតាមបទបញ្ញត្តិស្តីពីភាពអាសន្ន (មាត្រា ១៨៥(៣) នៃរដ្ឋធម្មនុញ្ញសហព័ន្ធ)រដ្ឋាភិបាលស្វីស(ក្រុមប្រឹក្សាសហព័ន្ធ)បានធ្វើសេចក្តីសម្រេចចិត្តជាច្រើនលើរឿងរ៉ាវនានាពីពាក់កណ្តាលខែមីនា ឆ្នាំ២០២០ រួមមាន ការបិទសាលានិងហាងពីថ្ងៃទី១៧ ខែមីនា ការហាមប្រាមការជួបជុំមនុស្សចាប់ពី៥នាក់ឡើងទៅ ការប្រកាន់យកវិធានការណ៍ពិសេសដើម្បីផ្តល់ប្រយោជន៍ដល់និយោជិត និយោជក និងក្រុមហ៊ុន ដូចជាការកាត់បន្ថយម៉ោងការងារ ការផ្តល់សំណងចំពោះការបាត់បង់ប្រាក់ចំណូល ច្បាប់ស្តីពីការរឹតបន្តឹងបំណុល និងការក្ស័យធន។ ក៏មានផងដែរនូវការដាក់ចេញក្រឹត្យអាសន្នលើវិស័យអបរំ និងវប្បធម៌។ បទបញ្ញត្តិអាសន្នទាំងនេះមានលក្ខណៈបណ្តោះអាសន្នតែប៉ុណ្ណោះដោយក្នុងនោះភាគច្រើនមានសុពលភាពត្រឹមដំណាច់ខែសីហា ឆ្នាំ២០២០។

សេចក្តីសម្រេចចិត្តទាំងនេះធ្វើឡើងដោយអត្តនោម័តិពីសំណាក់រដ្ឋាភិបាលស្វីស។ យ៉ាងហោចណាស់ ក្នុងអំឡុង៤សប្តាហ៍ដំបូង សេចក្តីសម្រេចចិត្តទាំងនេះទទួលបានការគាំទ្រខ្លាំងក្លាពីបណ្តាគណបក្សនយោបាយ អ្នកនយោបាយ និងប្រជាពលរដ្ឋដោយពុំមានការរិះគន់ឬបាតុកម្មឡើយ។ ផ្អែកលើកិច្ចប្រឹងប្រែងរបស់ខ្លួនរដ្ឋាភិបាលអាចកសាងបាននូវទំនុកចិត្តយ៉ាងច្រើន។សង្គមស្វីសបានបង្ហាញនូវភាពធន់នឹងបញ្ហាហើយបានដោះស្រាយវិបត្តិយ៉ាងល្អ។ប្រជាពលរដ្ឋគ្រប់ជំនាន់(ក្មេងនិងចាស់)បានជួយយកអាសារគ្នាទៅវិញទៅមក ហើយប្រជាពលរដ្ឋបានប្រកាន់ខ្ជាប់នូវវិន័យ បើទោះបីជាពុំមានការដាក់បម្រាមលើការដើរហើរជាសាធារណៈក៏ដោយ។ ប្រព័ន្ធផ្សព្វផ្សាយ និងបណ្តាគណបក្សនយោបាយក៏បានសាមគ្គីគ្នាក្នុងការគាំទ្រវិធានការណ៍ទាំងនេះ។ ជារួមក្រុមប្រឹក្សាសហព័ន្ធត្រូវបានផ្តល់ឲ្យនូវបណ្ណរបាយការណ៍ល្អ (good report card) ក្នុងការគ្រប់គ្រងវិបត្តិ។ ក្នុងពេលជាមួយគ្នានេះ ស្ថិតក្រោមសម្ពាធនៃជំងឺរាតត្បាតសកលកូវីដ-១៩ សភាសហព័ន្ធបានបិទបញ្ចប់សម័យប្រជុំ រដូវផ្ការីករបស់ខ្លួននៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០។ កិច្ចការសភាក្នុងសម័យប្រជុំពេញអង្គត្រូវបានផ្អាករហូតដល់សម័យប្រជុំវិសាមញ្ញពីថ្ងៃទី៤ ដល់ទី៧ ខែឧសភា ឆ្នាំ២០២០។

សភាពការណ៍មានភាពប្រហែលគ្នានៅកម្រិតរដ្ឋនីមួយៗ។ រដ្ឋាភិបាលនៃតំបន់នីមួយៗបានកោះប្រជុំក្រុមជំនាញទាក់ទងនឹងវិបត្តិរៀងៗខ្លួនដោយបន្ទាន់ ស្របពេលដែលសភានៃរដ្ឋចំនួន១៦ ក្នុងចំណោម២៦ បានលុបចោលកិច្ចប្រជុំនានាដែលបានកំណត់។ ក្នុងតំបន់ហ្ស៊ូរិច មានការខ្វែងយោបល់គ្នាទាក់ទងនឹងកម្រិតនៃអំណាចដែលរដ្ឋាភិបាលមាន និងថាតើរដ្ឋាភិបាលអាចរារាំងសភាមិនឲ្យជួបប្រជុំដោយផ្អែកលើហេតុផលគោលនយោបាយសុខភាពបានដែរឬទេ។ ដូចដែលយើងបានដឹង សភាហ្ស៊ូរិចមានសមាជិក១៨០រូប ដែលលើសពីចំនួនកំណត់១០០រូបសម្រាប់សភា ដែលកំណត់ដោយក្រុមប្រឹក្សាសហព័ន្ធ។ ក៏ប៉ុន្តែគណៈកម្មាធិការប្រតិបត្តិនៃសភាហ្ស៊ូរិចបានបញ្ឈប់កិច្ចពិភាក្សាទាំងនេះនៅពេលដែលគណៈកម្មាធិការនេះបានសម្រេចភ្លាមៗឲ្យមានការប្រជុំសភា។ បើមើលលើជ្រុងម្ខាងការសម្រេចនេះបានរក្សានូវតថភាពដែលបង្ហាញថា សភាជាអង្គដែលបង្កើតដោយរដ្ឋធម្មនុញ្ញ ហេតុដូច្នេះដោយផ្អែកតាមរដ្ឋធម្មនុញ្ញ សភាចាំបាច់ត្រូវអនុម័តបទបញ្ញត្តិអាសន្នរបស់រដ្ឋាភិបាល ក្នុងអំឡុងពេលនៃវិបត្តិ។ តែបើមើលលើជ្រុងម្ខាងទៀត សភាក៏ចាំបាច់ត្រូវមានភាពជាគំរូដល់ប្រជាពលរដ្ឋផងដែរ។ បើទោះបីស្ថិតក្នុងអំឡុងពេលនៃវិបត្តិ សភាចាំបាច់ត្រូវប្រកាន់ខ្ជាប់ដោយសុទ្ធចិត្តនូវតួនាទីរបស់ខ្លួន

និងធានាឲ្យបាននូវធម្មានុរូបភាពបែបប្រជាធិបតេយ្យនៃការសម្រេចចិត្តរបស់រដ្ឋនីមួយៗ។ លើសពីនេះគ្មានរដ្ឋាភិបាលណាមួយនៅប្រទេសស្វីសមានសិទ្ធិតាមរដ្ឋធម្មនុញ្ញក្នុងការបញ្ជាទៅសភាថា ត្រូវជួបប្រជុំនៅពេលណា ក្នុងហេតុផលណា ឬនៅទីកន្លែងណាឡើយ។ ដូច្នេះ សភារបស់តំបន់ហ្សូរិចបានដើរតួនាទីត្រួសត្រាយផ្លូវក្នុងប្រទេស ដោយបានផ្លាស់ប្តូរទីតាំងពីអគារសភាដែលមានតម្លៃជាប្រវត្តិសាស្ត្រដែលមានទំហំតូចចង្អៀតសង់តាំងពីឆ្នាំ១៦៩៨ ទៅកាន់សាលពិព័រណ៍ដ៏ទំនើបនៅជាយក្រុងហ្សូរិច ដើម្បីរៀបចំសម័យប្រជុំសភាស្របទៅតាមបទបញ្ញត្តិអនាម័យរបស់ការិយាល័យសហព័ន្ធផ្នែកសុខភាពសាធារណៈ និងស្របតាមអនុសាសន៍ស្តីពីគម្លាតសុវត្ថិភាពសង្គម។ ជាសរុបសភាហ្សូរិចបានជួបប្រជុំបីដង រហូតដល់ការបន្តនូវប្រតិបត្តិការប្រចាំសប្តាហ៍ជាទៀងទាត់ឡើងវិញ នៅថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២០។ ស្របតាមរដ្ឋធម្មនុញ្ញរបស់តំបន់ សភាហ្សូរិចបានអនុម័តបទបញ្ញត្តិអាសន្នបីដែលស្នើដោយអង្គនីតិប្រតិបត្តិ បំពេញបន្ថែមបទបញ្ញត្តិមួយជាមួយនឹងបទបញ្ជាទៅកាន់រដ្ឋាភិបាល និងព្យួរបទបញ្ញត្តិមួយ។ បន្ថែមលើនេះ សភាបានបោះឆ្នោតលើគ្រប់បញ្ហាទាំងឡាយដែលត្រូវការអនុម័ត ជាពិសេសសេចក្តីសម្រេចចិត្តទាក់ទងនឹងហិរញ្ញវត្ថុ។ គណៈកម្មាធិការសភាក៏បានជួបប្រជុំម្តងទៀត ហើយផែនការទូទៅមួយត្រូវបានដាក់ចេញដើម្បីចរចានិងដោះស្រាយកិច្ចការរដ្ឋាភិបាលដែលមានច្រើនក្នុងវេលាសមស្រប។សភាហ្សូរិចបានសម្រេចថា ខ្លួននឹងបន្តជួបប្រជុំនៅក្នុងសាលពិព័រណ៍ក្នុងប៉ុន្មានខែដែលនៅសេសសល់ក្នុងឆ្នាំ២០២០។

ក្នុងអំឡុងពេលច្របូកច្របល់នេះនៅពេលដែលទំនួលខុសត្រូវនានាចាំបាច់ត្រូវបញ្ជាក់ឲ្យបានច្បាស់ សំណួរសំខាន់ខ្លះៗបានលេចឡើងភ្លាមៗអំពីសភា៖ ហេតុអ្វីបានជាសម័យប្រជុំសភាមិនអាចរៀបចំបានតាមរយៈវីដេអូ? ហើយតើសមាជិក សមាជិកាសភាទាំងឡាយដែលជាអ្នកតំណាងឲ្យក្រុមប្រជាពលរដ្ឋងាយរងគ្រោះគួរត្រូវបានទទួលការជួយសម្រួលដោយរបៀបណាខ្លះ? រដ្ឋធម្មនុញ្ញនៅប្រទេសស្វីសផ្តល់ចម្លើយច្បាស់ៗទៅកាន់សំណួរទាំងនេះ។ សភាអាចធ្វើការពិភាក្សានិងធ្វើសេចក្តីសម្រេចចិត្តដែលមានសុពលភាពដរាបណាមានវត្តមានសមាជិក សមាជិកាសភាភាគច្រើន។ រដ្ឋធម្មនុញ្ញបានចែងផងដែរពី ការជួបប្រជុំដោយផ្ទាល់។ ក៏ប៉ុន្តែនេះមិនទាន់ឆ្លើយទៅនឹងសំណួរពិតប្រាកដឬក៏បញ្ជាក់ថាតើសំណួរត្រូវបានចោទសួរត្រឹមត្រូវឬនៅ៖ ផ្អែកលើទស្សនៈសេរីប្រជាធិបតេយ្យ គេគួរសួរជំនួសវិញថា តើសភាគួរ ឬមិនគួរជួបប្រជុំក្នុងអំឡុងពេលមានវិបត្តិ? តើសភាមិនមានមតិផ្នែកនយោបាយក្នុងអំឡុងពេលមានវិបត្តិទេឬ? តើកិច្ចពិភាក្សាប្រជាធិបតេយ្យមិនសំខាន់ទេឬក្នុងអំឡុងពេលមានវិបត្តិ?

វាហាក់ដូចជាមិនទំនងបើសិនជានរណាម្នាក់ហ៊ានសន្មត់ថា ខ្លួនមានចម្លើយទៅកាន់គ្រប់សំណួរទាំងនេះ។ អ្វីដែលយើងដឹងនៅពេលនេះគឺថា មិនទាន់មានដំណោះស្រាយជាក់ស្តែងចំពោះបញ្ហាដែលគេលើកឡើងទាំងអស់នោះទេខណៈដែលគ្រោះអាសន្ននៅខាងមុខនេះ គឺច្បាស់ណាស់អាចនៅក្បែរៗនេះ។ វាអាចនឹងមិនមែនជាជំងឺរាតត្បាតទេ តែអាចជាបញ្ហាកង្វះថាមពល ឬកង្វះទឹក វិបត្តិសេដ្ឋកិច្ច គ្រោះទឹកជំនន់ ឬខ្យល់ព្យុះជាដើម ហើយសង្ឃឹមថា វាមិនមែនជាឧប្បត្តិហេតុនុយក្លេអ៊ែរទៅចុះ។ ប្រសិនបើមានឧប្បត្តិហេតុនុយក្លេអ៊ែរ ទោះបីជាមានសម័យប្រជុំសភាតាមរយៈសន្និសីទតាមវីដេអូក៏ដោយ ក៏នឹងមិនមានផលប្រយោជន៍អ្វីដែរ។ ដើម្បីឆ្លើយសំណួរទាំងនេះ ច្បាស់ណាស់ថា ចាំបាច់ត្រូវមានការផ្លាស់ប្តូរវប្បធម៌ ស្របពេលយើងនឹងពិនិត្យមើលពីគំនិតជាក់ស្តែងរបស់សភាក្នុងប្រព័ន្ធប្រជាធិបតេយ្យ។

## គំនិតរបស់ "សភា"

"រដ្ឋាភិបាលដោយផ្អែកលើការពិភាក្សា" គឺជាពាក្យស្លោកដែល "កត់សម្គាល់ពីសមិទ្ធផលពិតប្រាកដនៃប្រព័ន្ធសភានិយម ហើយក៏ជាចរិតលក្ខណៈនៃប្រជាធិបតេយ្យរបស់ប្រព័ន្ធនេះដែរ" [៣៥]។ សភាជាស្ថាប័នដែលជួយឲ្យមានវិធាននយោបាយស្របច្បាប់ក្នុងក្របខ័ណ្ឌនៃសមត្ថភាព និងឆន្ទៈ ការចរចា និងការជជែកដេញដោល [៣៦]។ វាជានីតិវិធីតាមលំដាប់លំដោយ អនុលោមតាមវិធានរបស់គូភាគី ដែលចូលទៅគ្រប់គ្រងកិច្ចពិភាក្សាដោះស្រាយទំនាស់ដើម្បីដាក់ចេញនូវសេចក្តីសម្រេចចិត្តរបស់រដ្ឋ ដើម្បីធ្វើឲ្យគូភាគីក្នុងជម្លោះស្រុះស្រួលគ្នា [៣៧]។ សភាក្នុងនាមជាវេទិកាសម្រាប់សង្គម គឺជាជាឆាកនយោបាយដែលតំណាងពិពិធភាពនៃមតិនៅក្នុងសហជីព និងជានិមិត្តរូបដែលប្រជាពលរដ្ឋស្វីសនិយមហៅថា "ឆន្ទៈនៃប្រជាជាតិ"។

គន្លឹះមួយនៃមុខងារតំណាងក្នុងដំណើរការនយោបាយគឺទំនុកចិត្ត។ សភាអនុវត្តតាមអ្វីដែលមាត្រា២នៃក្រមរដ្ឋប្បវេណីស្វីសតម្រូវឲ្យពលរដ្ឋគ្រប់រូបត្រូវធ្វើក្នុងជីវិតប្រចាំថ្ងៃ គឺ "ការធ្វើអំពើដោយសុចរិត" [E] មិនត្រឹមតែក្នុងជីវិតជាសាធារណៈ តែក្នុងរាល់ទំនាក់ទំនងរវាងមនុស្ស ឧទាហរណ៍ រវាងក្រុមទទួលប្រយោជន៍ ក្រុមនយោបាយ និងសមាជិក សមាជិកាសភា [F][៣៨]។ មូលដ្ឋានគ្រឹះប្រជាធិបតេយ្យនៃភាពជាតំណាង គឺទំនុកចិត្តពីប្រជាពលរដ្ឋទៅលើការ

សម្រេចចិត្តរបស់សភា ជាពិសេសទៅភាពច្បាស់លាស់អាចយល់បាន។ មូលដ្ឋានគ្រឹះនេះអាចរក្សាឲ្យឋិតថេរបានលុះត្រាតែតួអង្គពាក់ព័ន្ធក៏ត្រូវមានការទុកចិត្តគ្នាទៅវិញទៅមកដែរ។ ឧទាហរណ៍ជាច្រើនពីអតីតកាលនៃនយោបាយរបស់ប្រទេសស្វីសបានគូសបញ្ជាក់ពីសារៈសំខាន់នៃការផ្តល់សេចក្តីទុកចិត្តពីអ្នកដែលត្រូវបានគេតំណាងដល់ស្ថាប័ននយោបាយ៖ សាធារណជនមានការមិនពេញចិត្ត និងមានកំហឹងនៅពេលដែលសភាស្វីសអាចអនុវត្តបានតែចំណុចខ្លះៗនៃការផ្តួចផ្តើមធ្វើច្បាប់ពីរដែលបានអនុម័តដោយប្រជាពលរដ្ឋ [៣៩ , ៤០] ទីមួយទាក់ទងនឹងការដាក់កម្រិតលើការពង្រីកទីក្រុងទៅតំបន់ដែលមានដង់ស៊ីតេប្រជាជនទាប និងទំហំនៃលំនៅឋានទីពីរ (ជាពិសេសសំដៅលើលំនៅឋានសម្រាកវិសមកាល) ក្នុងប្រទេសស្វីស និងទីពីរត្រូវបានគេហៅថា "ការប្រឆាំងនឹងអន្តោប្រវេសន៍ទ្រង់ទ្រាយធំ" ដែលធ្វើឡើងដើម្បីតម្រង់គោលនយោបាយមូលដ្ឋានអន្តោប្រវេសន៍ស្វីស ដែលអាចប៉ះពាល់ដល់ទំនាក់ទំនងគ្រឹះជាមួយសហភាពអឺរ៉ុប។ ទោះជាបែបនេះក្តី ប្រជាពលរដ្ឋបានទទួលយកសំណើនានារបស់សភាសម្រាប់ការអនុវត្ត ហើយបានសម្រេចចិត្តមិនធ្វើប្រជាមតិទាក់ទងនឹងបញ្ហាទាំងនោះទៀតឡើយ [G][៤១]។ ការទទួលយកនេះអាចមានឫសគល់ចេញពីទំនុកចិត្តរបស់អ្នកបោះឆ្នោតដែលមានទៅលើអ្នកនយោបាយ។ សមាជិក សមាជិកានៃសភាសហព័ន្ធទទួលបានទំនុកចិត្តនេះ ដោយសារមានការបង្ហាញជា សាធារណៈពីដំណើរការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយតម្លាភាព និងមានភាពងាយយល់។ ពួកគេបានពន្យល់ទៅកាន់ប្រជាពលរដ្ឋថា សំណើសម្រាប់ការអនុវត្តទាំងនោះគឺជាការសម្របសម្រួលដែលចាំបាច់ដោយសារតែជំហរគោលនយោបាយការបរទេសរបស់ស្វីសដែលមានយូរលង់មកហើយ។ ផ្ទុយមកវិញ ការរៀបចំដោយសម្ងាត់នៃក្រុមសភាបី ដែលសម្រេចមិនបោះឆ្នោតជ្រើសរើសសមាជិកពីររូបនៃរដ្ឋាភិបាលសហព័ន្ធម្តងទៀតបានបង្កឲ្យមានផលប៉ះពាល់ជាអវិជ្ជមាន និងយូរអង្វែងចំពោះកិត្តិនាមនៃសភាសហព័ន្ធ។ ការបោះឆ្នោតមួយចំនួនទៀតត្រូវបានរៀបចំឡើងប្រកបដោយតម្លាភាព ដើម្បីទទួលបានទំនុកចិត្តជាសាធារណៈឡើងវិញចំពោះដំណើរការជ្រើសរើស និងដំណើរការបោះឆ្នោត។

ឧទាហរណ៍ទាំងពីរនេះបង្ហាញថា ស្ថាប័នរបស់សភាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការបង្កើត ឬស្តារឡើងវិញនូវអត្តសញ្ញាណ ការធ្វើសមាហរណកម្ម និងការកសាងទំនុកចិត្ត ជាពិសេសដោយមានការរួមផ្សំនឹងប្រជាធិបតេយ្យដោយផ្ទាល់។ ក្រោយពីមានការតស៊ូយ៉ាងជូរចត់ដើម្បីទទួលបានការបោះឆ្នោតពីប្រជាពលរដ្ឋលើច្បាប់ប្រជាមតិ និងសំណើរអនុវត្តរបស់រដ្ឋាភិបាលតុល្យភាពរវាងក្រុមនយោបាយនៅតែមិនអាចបង្កើតបាន។ ក៏ប៉ុន្តែក្នុងសភា ការសម្រុះសម្រួលគ្នាអាចចរចាបាន។ ដូច្នេះគំនិតដែលថា សភាជាស្ថាប័នប្រជាធិបតេយ្យ គឺសំដៅលើមុខងារបង្កើតសន្តិភាពនេះឯង។ គូបដិបក្ខនយោបាយមានកាតព្វកិច្ចក្នុងការចូលរួមក្នុងដំណើរការបង្កើតសេចក្តីសម្រេចចិត្តប្រកបដោយតម្លាភាព និងសណ្តាប់ធ្នាប់។ នៅជ្រុងមួយ សភាបង្កើតជាចំណុចប្រសព្វដែលនៅទីនោះនយោបាយត្រូវបានប្រែក្លាយទៅជាសកម្មភាពរបស់រដ្ឋ ហើយនៅជ្រុងមួយទៀត សភាជាចំណុចភ្ជាប់រវាងសកម្មភាពរដ្ឋ និងនយោបាយ[៤២]។ និយាយដោយខ្លី ស្ថាប័នសភាជាទីកន្លែងដែលជួយឲ្យអ្នកនយោបាយមានការស្រុះស្រួលលើភាពខុសគ្នារបស់ពួកគេដោយចំហ តម្លាភាព ងាយយល់ និងដោយសន្តិវិធី។

សភា និងប្រជាធិបតេយ្យដោយផ្ទាល់កើតមានព្រមគ្នានៅប្រទេសស្វីស [៤៣]។ ប្រជាធិបតេយ្យដោយផ្ទាល់នឹងមិនអាចធ្វើទៅបានទេ បើសិនជាគ្មានការសម្រុះសម្រួលដែលសម្របសម្រួលដោយសភា មិនថាពេលមុនឬពេលក្រោយទេ។ ក្នុងករណីប្រទេសស្វីស សភានិងប្រជាធិបតេយ្យដោយផ្ទាល់ជួយពង្រឹងគ្នាទៅវិញទៅមក[៤៤]។ បើសិនជាសភាមិនទទួលបានបរិយាបន្ន នោះក្តីស្រមៃបែបប្រជាភិថុតនឹងក្លាយជាការពិត ហើយពេលនោះរដ្ឋាភិបាលនឹងអាចធ្វើសកម្មភាពនានាដោយផ្ទាល់ជាមួយនឹងប្រជាពលរដ្ឋដោយប្រើអំណាចគ្មានការបែងចែកនិងគ្មានដែនកំណត់។ ការប្រមូលផ្តុំអំណាចបែបនេះជារឿងមិនត្រូវបានគេស្វាគមន៍ឡើយនៅប្រទេសស្វីស ដោយសារម៉ូទាំងបីគឺ "ប្រជាពលរដ្ឋ សភា និងរដ្ឋាភិបាល" បានបង្កើតឲ្យមាននូវតុល្យភាពប្រជាធិបតេយ្យចម្រុះ ប៉ុន្តែរឹងមាំ ដែលនាំឲ្យមានសមាហរណកម្មទំនុកចិត្ត និងសន្តិភាព។

ទំនាក់ទំនងរវាងបុគ្គល និងរដ្ឋមានសារៈសំខាន់ខ្លាំងណាស់។ មុខងារទាំងឡាយនៃអំណាចរដ្ឋទាំងបួន (ប្រជាពលរដ្ឋ សភា រដ្ឋាភិបាល និងតុលាការ) ចូលរួមចំណែករួមគ្នាជានា និងអភិវឌ្ឍប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស៖ តុលាការវិនិច្ឆ័យបញ្ហាទាំងឡាយណាដែលមិនអនុលោមទៅតាមបទបញ្ញត្តិច្បាប់ ចំណែកប្រជាពលរដ្ឋធានាថា សិទ្ធិមនុស្សត្រូវបានអង្កេតតាមដាន[៤៥] រីឯសភាមានតួនាទីជាអន្តរការីរវាងប្រជាពលរដ្ឋនិងរដ្ឋាភិបាលឬរដ្ឋបាល[៤៥]។ រដ្ឋាភិបាលតំណាងរដ្ឋក្នុងវិស័យការបរទេស ចំណែកសភាតំណាងប្រជាពលរដ្ឋនៅក្នុងប្រទេស[៤១] ដែលតទល់ទៅនឹងរដ្ឋាភិបាលដោយការផ្តួចផ្តើមធ្វើច្បាប់ និងប្រជាមតិ[៤៦]។ តុល្យភាពនេះបណ្តាលធ្វើឲ្យសភាក្លាយជាប្រភពនៃការឆ្លើយ

តបរហ័ស និងប្រកបដោយប្រសិទ្ធិភាពខ្ពស់ ក្នុងការជម្រុញទឹកចិត្ត និងធ្វើឲ្យមានការផ្តួចផ្តើមផ្នែកនយោបាយ[៤៧]។

ដោយសារហេតុផលនេះ ក្រុមជនភាគតិចនៅប្រទេសស្វ៊ីសតែងតែប្រើប្រាស់នីតិវិធីសភាដើម្បីបញ្ចេញមតិយោបល់របស់ពួកគេជាសាធារណៈ។ តាមរយៈយន្តការនានារួមមាន ដូចជា ការដាក់ញត្តិជាដើម បញ្ហានានាអាចត្រូវបានលើកទៅដល់វេទិកានយោបាយតាមរយៈសមាជិក សមាជិកាសភា ហើយដែលបញ្ហាទាំងនោះអាចនឹងបាត់ក្នុងដំណើរនីតិវិធីនយោបាយធំៗ ដូចជាសិទ្ធិផ្តួចផ្តើមធ្វើច្បាប់និងប្រជាមតិ នីតិវិធីពិគ្រោះយោបល់ ឬការតវ៉ាជាសមូហភាពជាដើម។ កិច្ចការអាចធ្វើទៅរួចក៏ដោយសារតែវិន័យគណបក្សនៅប្រទេសស្វ៊ីសមិនត្រូវបានអង្កេតតាមដានតឹងតែងដូចក្នុងបណ្តាប្រទេសប្រជាធិបតេយ្យសភានិយមជាច្រើនផ្សេងទៀតទេ។ ដោយការយល់ពីភាពជាតំណាងជាលក្ខណៈបុគ្គល និងដោយសមាជិក សមាជិកាសភានាំយកផលប្រយោជន៍តំបន់ និងសហគមន៍ ឬផលប្រយោជន៍របស់សមាគមមកបន្ថែមលើផលប្រយោជន៍របស់គណបក្សនយោបាយ សភាបានផ្តល់ជាការរួមចំណែកដ៏សំខាន់ដោយធ្វើឲ្យមានសមាហរណកម្មនៃជនភាគតិច និងភាពស្អិតរមួតក្នុងសង្គម។

ដូច្នេះ សភាបង្កើតបាននូវអត្តសញ្ញាណ និងទំនុកចិត្ត ហើយធានាបាននូវពិពិធភាពនិងការចូលរួម។ អំណាចនយោបាយស្ថិតនៅត្រង់សភានិងសមត្ថភាពរបស់សភាក្នុងការដោះស្រាយបញ្ហាជម្លោះនានា ដោយពឹងផ្អែកលើភាពច្បាស់លាស់ក្នុងការធ្វើសេចក្តីសម្រេចចិត្តពីរបៀបគ្រប់គ្រងដំណើរការ និងតើនរណាដែលពាក់ព័ន្ធក្នុងការចរចា។ រាល់ការសម្រុះសម្រួលដែលធ្វើឡើងនៅក្នុងសភាត្រូវបានសម្រេចឡើងតាមនីតិវិធីបែបប្រជាធិបតេយ្យ។ វាជានីតិវិធីដែលមានសមាជិក សមាជិកាសភាចូលរួម និងមានទំនាក់ទំនងដោយផ្ទាល់ជាមួយមនុស្ស ដែលអាចឲ្យមានតុល្យភាពរវាងអំណះអំណាង ការពិត ទ្រឹស្តី និងវោហារស័ព្ទ។ តាមវិធីនេះសភាធានាបាននូវការចាប់ផ្តើម ការពិភាក្សា និងការជជែកវែកញែកអំពីរាល់បញ្ហានយោបាយ[៤៨]។

តថភាពនៃសភានេះបញ្ជាក់នូវការភ្ជាប់ទំនាក់ទំនងគ្នាដោយបន្ទាន់នៃពេលវេលានិងទីកន្លែង "នៅទីនេះ និងនៅពេលនេះ" ដែលជាតថភាពសភាក្នុងនយោបាយ។ គោលការណ៍នៃការភ្ជាប់ទំនាក់ទំនងគ្នាដោយបន្ទាន់នេះទាមទារនូវសមាសភាគសំខាន់ដែលលើសពីនិយមន័យទូទៅរបស់គោលការណ៍នេះ។ វាមិនមែនគ្រាន់តែជាគោលការណ៍បែបនីតិវិធីធម្មតាប៉ុណ្ណោះទេ តែជាគោលការណ៍ដែលរួមបញ្ចូលនូវមុខងារនយោបាយរបស់សភាដែលបានរៀបរាប់ខាងលើ។ គោលការណ៍នេះត្រូវបានផ្តល់និយមន័យទៅតាមរបៀបសភានិងនីតិវិធីរបស់សភា ដែលមានឥទ្ធិពលរួមគ្នា ដែលធានានូវអត្តសញ្ញាណនៃពិពិធភាពនយោបាយ និងដែលធ្វើឲ្យនយោបាយស្ថិតនៅក្រោមឥទ្ធិពលដោយផ្ទាល់របស់សភា និងអាចចរចាបាននៅនឹងកន្លែងផ្ទាល់។

បើប្រជាពលរដ្ឋចង់លើកឡើងថា សភាគ្មានអ្វីពិសេសលើសពីប្រជាពលរដ្ឋធម្មតានោះ វាជារឿងត្រឹមត្រូវណាស់។ សភាមិនអាច និងមិនគួរជាអ្វីលើសពីប្រជាពលរដ្ឋនោះទេ។ សភាគួរតែជាតំណាង ជារូបភាពឆ្លុះបញ្ចាំងពីសង្គមនូវរាល់ទិដ្ឋភាព។ នីតិវិធីនេះបង្ហាញពីគំនិតរបស់សភា ហើយធ្វើឡើងក្នុងទម្រង់នៃសកម្មភាពដោយផ្ទាល់នៃតួអង្គរបស់ខ្លួន។

## ទំនុកចិត្តតាមការផ្តល់ឲ្យ

ពេលនេះ គេអាចនឹងមានទំនោរនិយាយថា ការភ្ជាប់ទំនាក់ទំនងគ្នាដោយបន្ទាន់នៃការចរចាសភាអាចនឹងត្រូវបានបង្កើតឡើងនៅក្នុងសន្និសីទតាមវីដេអូ ដោយសារប្រធានបទត្រូវពិភាក្សា និងសម្រេចត្រូវយកទៅចរចាជាមួយភាគីពាក់ព័ន្ធទាំងឡាយក្នុងពេលតែមួយ។ មានតែការភ្ជាប់ទំនាក់ទំនងគ្នាដោយបន្ទាន់ក្នុងប្រទេសទេដែលអាចជំនួសបានដោយទីកន្លែងនិម្មិត។ វាជាការវែកផ្លូវទៅកាន់ ការភ្ជាប់ទំនាក់ទំនងគ្នាដោយបន្ទាន់បែបនិម្មិត។ ការភ្ជាប់ទំនាក់ទំនងគ្នាដោយបន្ទាន់បែបនិម្មិតមិនមានភាពស៊ីសង្វាក់គ្នានឹងនីតិវិធីសភាដែលមានពីយូរលង់ដែលកំពុងប្រើសព្វថ្ងៃនេះទេ ព្រោះសភាមានទំនោរយ៉ាងច្បាស់ទៅរកការជួបប្រជុំដោយផ្ទាល់នៅនឹងកន្លែង[៤១, ៤៩]។

សន្មត់ថា មានឧបករណ៍ប្រាស្រ័យទាក់ទងមួយអាចបំពេញរាល់តម្រូវការនៃការជជែកដេញដោលរបស់សភា ដូចជា អាចធ្វើការបង្ហាញជាបន្តបន្ទាប់ពីអត្តសញ្ញាណរបស់សមាជិក សមាជិកាសភាក្នុងអំឡុងពេលប្រជុំ ធានាបាននូវបណ្តាញតភ្ជាប់ដោយមិនអាក់អួល ប្រព័ន្ធសំឡេងបោះឆ្នោតនិងការបោះឆ្នោតដែលអាចផ្តល់ជូនទៅបេក្ខជនបាន អាចបង្កើតនិងប្រគល់ជូនសំណើនានា ក៏ដូចជាឱកាសសម្រាប់ការចូលរួមពីសាធារណជនជាដើម។ បើទោះបីជាចំណុចទាំងអស់នេះអាចធ្វើបានក៏ដោយហើយបើទោះបីជាអាចធ្វើទៅរួច ឧទាហរណ៍ មានមនុស្ស៦០០នាក់ នៅក្នុងក្រុមប្រឹក្សាពីរក្នុងពេលតែមួយក៏ដោយ ក៏នៅតែមានសំណួរចោទសួរថា តើមុខងារអត្តសញ្ញាណស្ថាប័នរបស់សភាអាចបង្កើតឡើងយ៉ាងដូចម្តេច បើសិនវាមិនអាចកាត់ផ្តាច់ពីទីកន្លែងរូបវន្តបានផងនោះ។

គ្មានមន្ទិលសង្ស័យអ្វីទេថាក្នុងរយៈពេល៥ឬ ១០ឆ្នាំខាងមុខទៀតសភាដែលផ្អែកលើប្រព័ន្ធសន្និសីទតាមវីដេអូនឹងអាចបំពេញមុខងាររបស់ខ្លួនបានប្រកបដោយប្រសិទ្ធភាពយ៉ាងល្អ។ បច្ចេកវិទ្យា ជាពិសេសមធ្យោបាយទំនាក់ទំនងរវាងអ្នកប្រើប្រាស់ និងប្រព័ន្ធកុំព្យូទ័រនឹងបន្តរីកចម្រើន ដែលអាចនាំឲ្យមានការបង្កើតនូវទីតាំងនិម្មិត។ ហើយប្រហែលជាយើងអាចចូលរួមបានដោយមិនចាំបាច់ប្រើឧបករណ៍អ្វីផងក៏ថាមិនត្រូវ។ ហេតុនេះវាពិតជាមានសារៈសំខាន់ ដែលក្នុងពេលបច្ចុប្បន្នពេលបង្កើតគម្រោងទាំងឡាយ ត្រូវគិតដោយយកចិត្តទុកដាក់ពីការអនុវត្តរបស់សភាបែបឌីជីថល [៥០]។ក៏ប៉ុន្តែ ក្នុងពេលបច្ចុប្បន្ននេះមិនទាន់មានឧបករណ៍បែបនេះនៅឡើយទេ ហើយការដាក់មុខងារសភាដែលបានពិពណ៌នាខាងលើទៅក្នុងលំហនិម្មិតមួយនឹងទាមទារកិច្ចប្រឹងប្រែងខ្លាំង ក៏ដូចជាការព្រាងគោលការណ៍សណ្ដាប់ធ្នាប់សភាថ្មី ក្នុងចំណោមកិច្ចការជាច្រើនទៀត។

ក៏ប៉ុន្តែគួរកត់សម្គាល់ផងដែរថា មុខងារអត្តសញ្ញាណ និងពិពិធភាពពេញលេញរបស់សភាអាចនឹងពិបាកយកមកតំណាងក្នុងសន្និសីទតាមវីដេអូ។ ជំនួសមកវិញ អ្នកដែលសម្របសម្រួលសន្និសីទ និងដែលលេចមុខឥតដាច់នៅផ្ទៃខាងមុខអេក្រង់នឹងដើរតួជាជនបង្គោលមួយនិងជាអ្នកបង្កើតអត្តសញ្ញាណ។ ប្រធានសភានឹងក្លាយជាតួអង្គដែលគេអាចមើលឃើញជាអត្តសញ្ញាណបន្តបន្ទាប់ ឯសភាទាំងមូលនឹងត្រូវរុញទៅជាផ្ទៃខាងក្រោយនៃអេក្រង់។ ប្រព័ន្ធនេះពិតជាមិនស៊ីសង្វាក់គ្នាទាល់តែសោះជាមួយនឹងក្បួនទម្លាប់របស់សភា។ តាមក្បួនទម្លាប់ប្រធានក្រុមប្រឹក្សាជាអ្នកផ្ដល់នូវអព្យាក្រិតភាពប្រកបដោយសុភវិនិច្ឆ័យ និងមិនចេញមុខលេចធ្លោខ្លាំងទេ។ ភាពនិម្មិតនេះធ្វើឲ្យប៉ះពាល់ដល់តុល្យភាពនៃប្លង់អង្គប្រជុំរូបវន្ត ជាពិសេសនៅពេលដែលគេមិនអាចមើលឃើញសភាទាំងមូលក្នុងពេលតែមួយបាន។ នៅប្រទេសស្វីសមានបញ្ហាមួយទៀតត្រង់ថា ប្រធានសភាត្រូវបោះឆ្នោតជ្រើសតាំងឲ្យកាន់មុខតំណែងតែរយៈពេលមួយឆ្នាំប៉ុណ្ណោះ ដែលជាបញ្ហាប្រឈមបន្ថែមទៀតទាក់ទងនឹងមុខងារអត្តសញ្ញាណ។

ដោយសារសភាចាំបាច់ត្រូវរក្សាលទ្ធភាពរបស់ខ្លួនក្នុងការបំពេញការងារអំឡុងពេលមានជំងឺរាតត្បាតសកលដើម្បីធ្វើសេចក្ដីសម្រេចចិត្តចាំបាច់នានា ឬក៏រៀបចំការបោះឆ្នោតក្នុងករណីបន្ទាន់ខ្លាំង សន្និសីទតាមវីដេអូអាច យកមកជំនួសកិច្ចប្រជុំផ្ទាល់បាន តែជាបណ្ដោះអាសន្នប៉ុណ្ណោះ។ នេះក៏ដោយសារចំណុចស្នូលនៃមុខងារសភាគឺ ពឹងផ្អែកលើទំនាក់ទំនងដោយផ្ទាល់រវាងមនុស្សនិងមនុស្ស ដែលជួយបង្កើតតុល្យភាពរវាងកម្លាំង និងអំណះអំណាងផ្នែកនយោបាយ ក្នុងស្មារតីប្រកបដោយការទុកចិត្ត។ ប្រហែលជាកត្តានេះមិនអាចកើតឡើងបានទេក្នុងលំហនិម្មិតមួយ ដោយសារការភ្ជាប់ទំនាក់ទំនងបន្ទាន់ដែលជួយបង្កើនទំនុកចិត្តតាមរយៈការប្រាស្រ័យទាក់ទងរវាងមនុស្ស ដែលជាផ្នែកដ៏សំខាន់នៃប្រជាធិបតេយ្យត្រូវបាត់បង់។ អត្តសញ្ញាណរួមរបស់សភាអាចត្រូវផ្អែកទៅលើបុគ្គលដោយឡែករៀងៗខ្លួននៃសមាជិកសមាជិកាក្រុមប្រឹក្សា។ នេះអាចជាទម្រង់ថ្មីមួយនៃប្រព័ន្ធសភានិយម តែវានឹងមិនងាយមានភាពទាក់ទាញនិងមានគុណភាពដូចគ្នាទេ។



**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការ ដែលបកដោយវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិនៃកម្ពុជា (NIDIR)។ អ្នកអានអាចទាញយកអត្ថបទដើមជាភាសាអង់គ្លេសពីគេហទំព័រ៖ https://www.pic.org.kh ។

# លេខយោង

A. ទំនាក់ទំនងសន្តិសុខនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកមានចំណុចអវិជ្ជមានដូចគ្នា។ នៅក្នុងរយៈពេលក្រោយសង្គ្រាមភ្លាមៗ ការកសាងក្របខ័ណ្ឌស្ថាប័នពហុភាគីនៅក្នុងតំបន់នេះគឺមិនអាចទៅរួចនោះ។ សព្វថ្ងៃនេះ អវត្តមាននៃការរៀបចំបែបនេះរារាំងការបន្សាំទៅនឹងការផ្លាស់ប្តូរជាមូលដ្ឋាននៃសកល។ ឧទាហរណ៍៖សហរដ្ឋអាម៉េរិក និងជប៉ុនមិនចូលចិត្តការលើកឡើងនូវសំណួរធ្ងន់ៗអំពីសន្ធិសញ្ញាការពារគ្នាទៅវិញទៅមក ដោយការភ័យខ្លាចការបង្ហាញឲ្យឃើញស្ថិរភាពមួយដែលផុយស្រួយ និងនាំឲ្យមានការប្រណាំងប្រជែងអាវុធនៅទូទាំងតំបន់។ ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកគ្មានសហភាពអឺរ៉ុប និងគ្មានណាតូសម្រាប់ផ្លាស់ប្តូរភាពលំបាកសម្រេចចិត្តជាច្រើននៃសន្តិសុខក្នុងតំបន់ ដូចដែលបានធ្វើនៅអឺរ៉ុបនោះទេ ដូចមានទំនាក់ទំនងបារាំង-អាល្លឺម៉ង់ជាឧទាហរណ៍ស្រាប់។ ជាការពិតតំបន់នេះក៏មិនមានដំណើរការដូច Helsinki ដែលត្រូវប្រើប្រាស់ ដើម្បីចាប់ផ្តើមការងារតូចតាចនៃការកសាងទំនុកចិត្តគ្នាទៅវិញទៅមកនៅក្នុងតំបន់នោះដែរ។ ដូច្នេះសព្វថ្ងៃនេះ ទោះបីជាទ្វីបអឺរ៉ុបមានសក្តានុពលក្នុងការផ្លាស់ប្តូរហួសពីនយោបាយ នៃតុល្យភាពអំណាចនៅក្នុងទម្រង់បែបប្រពៃណីក៏ដោយ តុល្យភាពមានស្ថិរភាព និងសមហេតុផលមួយគឺជាការល្អបំផុតហើយដែលគេអាចសង្ឃឹមថានឹងសម្រេចបាននៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក" ។

B. ក្រុមគ្រួសារនយោបាយ ប្រមូលផ្តុំគណបក្សមកពីប្រទេសផ្សេងៗដែលមានរបៀបវារៈនយោបាយដូចគ្នា។ ឧទាហរណ៍ដូចជា ALDE (គណបក្សសេរីនៅអឺរ៉ុប) ឬអង្គការសង្គមនិយមអន្តរជាតិ (អង្គការគណបក្សសង្គមនិយមទូទាំងពិភពលោក) ។

C. Sectoral Ego សម្តៅដល់និន្នាការដែលវិស័យ ឬអង្គភាពផ្សេងៗគ្នាធ្វើការអនុវត្តកម្មវិធី ឬសកម្មភាពយោងទៅតាមអំណាចជាក់លាក់របស់ខ្លួនជាជាងសហការគ្នាជាមួយនឹងវិស័យ ដែលពាក់ព័ន្ធ ដើម្បីធានាឲ្យបានលទ្ធផលប្រកប ដោយប្រសិទ្ធភាពជាងមុន។

D. មាត្រា ១៦៨ នៃ TFUE, កថាខណ្ឌ ៤ (វិធាននៃសមភាព និងសន្តិសុខលើឈាមនិងសរីរាង្គ សម្រាប់ថ្នាំ និងឧបករណ៍វេជ្ជសាស្ត្រ) មន្ទីរពេទ្យដែលសហការរវាងប្រជាជាតិពីរដែលមានផ្លាក EU កំពុងតែដំណើរការនៅព្រំដែនបារាំង និងអេស្ប៉ាញ។

## REFERENCES


១. Ruggie, J. (1992). Multilateralism: the anatomy of an institution. International Organization, 46(3), pp.561- 598.

២. Plender, J. (2018). US needs multilateralism as much as its partners [Online]. UK: Financial Times (FT). Available at: https://www.ft.com/content/39026868-0135-11e9-99df-6183d3002ee1 [Accessed 06 Mar. 2020].

៣. Fabry, E. (2019). Crise de l'OMC : peut-on se passer du multilatéralisme à l'ère numérique? . [Blog] Institut Jacques Delors. Available at.: https://institutdelors.eu/publications/la-crise-de-lomc-peut-on-se-passer-du-multilateralisme-a-lere-numerique/ [Accessed 06 Mar. 2020].

៤. United Nation (UN). (2019). High-level plenary meeting to celebrate and promote the International Day of Multilateralism and Diplomacy for Peace. In: Plenary Meeting of the General Assembly, General Assembly Hall, New York: UN.

៥. Yuval Noah Harari: the World after Coronavirus accessed from https://www.ft.com/content/19d90308-6858-11ea-a3c9-1fe6fedcca75

៦. Ghebreyesus, Tedros Adhanom, Lessons from the COVID-19 pandemic: Parliamentary action to reduce risks, strengthen emergency preparedness and increase resilience, (webinar), Inter Parliamentary Union, United Nations Office for Disaster Risk Reduction and World Health Organization, 28 April 2020

៧. Maharani, Puan, Opening Speech, the Role of Parliament for International Cooperation to Defeat Covid-19, (webinar), the Committee for Inter-parliamentary Cooperation, 21 April 2020

៨. Zon, Fadli, the Role of Parliament for International Cooperation to Defeat Covid-19, (webinar), the Committee for Inter-parliamentary Cooperation, 21 April 2020

៩. Ruddyard, Febrian A., International Cooperation in Countering the COVID-19 Pandemic, (webinar), the Committee for Inter-parliamentary Cooperation, 21 April 2020

១០. Country compilation of the parliamentary responses to the pandemic https://www.ipu.org/country-compilation-parliamentary-responses-pandemic#I

១១. Speaker of the Indonesian House Public Statement and Calls, https://twitter.com/DPR_RI/status/1234852158664773632 retrieved on 12 May 2020.

១២. Financial Minister Statement, https://kemenkeu.go.id/covid19 retrieved by 13 May 2020.

១៣. Government to offer bonds worth $ 57.1b until year-end, https://www.thejakartapost.com/news/2020/04/30/government-to-offer-bonds-worth-57-1b-until-year-end.html

១៤. Komisi X dan Menkeu Sri Mulyani terlibat perdebatan/Commission X and Finance Ministry Sri Mulyani involved on a debate, https://www.beritasatu.com/nasional/629573-komisi-xi-dan-menkeu-sri-mulyani-terlibat-perdebatan

១៥. ADB. 2020a. An Updated Assessment of the Economic Impact of COVID-19.

១៦. Worldometer. 2020. "Coronavirus Cases." Worldometer 1–22.

១៧. Abiad, A., RM Arao, and S. Dagli. 2020. "The Economic Impact of the COVID-19 Outbreak on Developing Asia."

១៨. Marie, Lamy; Va, Sonyka. 2020. "Tourism Hit in Coronavirus Fight." Khmer Times. Retrieved June 1, 2020 (https://www.khmertimeskh.com/707708/tourism-hit-in-coronavirus-fight/).

១៩. WB. 2020. Cambodia Economic Update, Cambodia in the Time of COVID 19, Special Focus Teacher Accountability and Student Learning Outcomes.

២០. NIS. 2019. General Population Census 2019 Cambodia.

២១. Shi, Yinglun. 2020. "Cambodia Sees Rapid Decline in Poverty Rate in Last 15 Years: Cambodian PM." Xinhua | English.News.Cn. Retrieved June 15, 2020 (http://www.xinhuanet.com/english/2019-09/21/c_138410532.htm).

២២. MoT. 2020. Tourism Statisitc Report January 2020.

២៣. ADB. 2020b. "The Economic Impact of the COVID-19 Outbreak on Developing Asia." 9(128):1–14.

២៤. Jose Rodriguez T., Senase. 2020. "Hotel Openings Continue Unabated in Cambodia despite COVID-19 - Khmer Times." Khmer Times. Retrieved June 1, 2020 (https://www.khmertimeskh.com/694396/hotel-openings-continue-unabated-despite-covid-19/).

២៥. Huaxia. 2020. "Cambodian PM Says 256 Factories Suspended Due to COVID-19, Affecting over 130,000 Workers - Xinhua | English.News.Cn." Xinhua News. Retrieved June 11, 2020 (http://www.xinhuanet.com/english/2020-06/01/c_139105722.htm).

២៦. Sen David. 2020. "Each Laid-off Worker to Get $70 a Month - Khmer Times." Khmer Times. Retrieved June 12, 2020 (https://www.khmertimeskh.com/710752/each-laid-off-worker-to-get-70-a-month/).

២៧. MoLVT. 2020a. Announcement on Paying for Laid-off Workers in Garment and Tourism Sector for the 6th Time. Phnom Penh.

២៨. MoLVT. 2020b. "Notification on Postponement of Payment of Back Pay Seniority Indemnity Before 2019 and New Seniority Indemnity in 2020 According."

២៩. VOA. 2020. "Workers Decry Labor Ministry's Move to Postpone Indemnity Payments." Retrieved June 13, 2020 (https://www.voacambodia.com/a/workers-decry-labor-ministry-s-move-to-postpone-indemnity-payments-/5447157.html).

៣០. MoH. 2020. Press Release from the Ministry of Health of Cambodia on Successful Treatment on One More Covid 19 Patient and No New Positive Case of Covid 19 by June 20th, 2020.

៣១. News European Parliament. (2020). 10 things the EU is doing to fight the coronavirus [online]. Brussels: European Parliament. Available at: https://www.europarl.europa.eu/news/en/headlines/society/20200327STO76004/10-things-the-eu-is-doing-to-fight-the-coronavirus [Accessed 27 May. 2020].

៣២. European Parliament. (2020). European Parliament resolution of 17 April 2020 on EU coordinated action to combat the COVID-19 pandemic and its consequences [online]. Brussels: European Parliament. Available at: https://www.europarl.europa.eu/doceo/document/TA-9-2020-0054_EN.html [Accessed 27 May. 2020].

៣៣. Foundation Robert Schuman. (2020). Parliamentary oversight in the health crisis [online]. Brussels: Robert Schuman Foundation. Available at: https://www.robert-schuman.eu/en/european-issues/0558-parliamentary-oversight-in-the-health-crisis [Accessed 27 May. 2020].

៣៤. Dieter, K. (2020). Die Bewältigung der Corona-Krise durch den Zürcher Kantonsrat – eine Chronik. SGP-SSP-Mitteilungsblatt. Germany: SGP-SSP. p.35. Available at: http://sgp-ssp.net/ [Accessed 11 Sep. 2020].

៣៥. Stefan, M. (2016). Parlamentarismus: Eine Einführung, 2nd ed. Baden-Baden: Germany, p.29.

៣៦. Kurt, K. (1983). Geschichte und Problematik des Parlamentarismus, Frankfurt am Main, Suhrkamp, p. 12.

៣៧. Müller, J. P. (1993). Demokratische Gerechtigkeit, Munich, Deutscher Taschenbuch Verlag, p. 157.

៣៨. Swiss Civil Code (2020, art. 2) The Federal Assembly of the Swiss Confederation. Available at: https://www.admin.ch/opc/en/classified-compilation/19070042/index.html [Accessed 10 Sep. 2020].

៣៩. Second Residence Act (2014, act 14.023) Federal Council. Available at: https://www.parlament.ch/en/ratsbetrieb/suche-curia-vista/geschaeft?AffairId=20140023 [Accessed 11 Sep. 2020].

៤០. Foreigners Act, Managing immigration and improving the implementation of the agreements on the free movement of persons (2016, act 16-027). Available at: https://www.parlament.ch/en/ratsbetrieb/suche-curia-vista/geschaeft?AffairId=20160027 [Accessed 11 Sep. 2020].

៤១. Swiss Federal Constitution (2020, art. 143-184) Federal Council. Available at: https://www.admin.ch/opc/en/classified-compilation/19995395/index.html [Accessed 11 Sep. 2020].

៤២. Tschannen, P. (1995). Stimmrecht und politische Verständigung. Beiträge zu einem erneuten Verständnis von direkter Demokratie, Basel, p. 180.

៤៣. Graf, M.,Theler, C. and von Wyss, M. (2014). Die Stellung der der Bundesversammlung im politischen System der Schweiz. Parlamentsrecht und Parlamentspraxis der Schweizerischen Bundesversammlung: Kommentar zum Parlamentsgesetz,. Basel: Helbing Lichtenhahn. pp.17-18.

៤៤. Rhinow, R.,Schefer, M. and Uebersax, P. (2016). Schweizerisches Verfassungsrecht, 3rd ed. Basel, Switzerland: Helbing & Lichtenhahn (Verlag) p. 389.

៤៥. Giacometti, Z. (2018). Die Demokratie als Hüterin der Menschenrechte / Festrede des Rektors Prof. Dr. Zaccaria Giacometti, gehalten an der 121. Stiftungsfeier der Universität Zürich am 29. April 1954, Bern: Schweizerische Nationalbibliothek, p. 7.

៤៦. Biaggini, G. (2017). BV Kommentar, 2nd ed. Zürich.

៤៧. Diggelmann, O.,Randall, M. H.,Schindler, B., et al. (2020, vol.3). Verfassungsrecht der Schweiz/ Droit constitutionnel suisse Zurich, Schulthess Juristische Medien, p. 1700.

៤៨. Blackburn, R.,Kennon, A.,Wheeler-Booth, M., et al. (2003). Griffith and Ryle on Parliament : Functions, Practice and Procedures 2nd ed. London: Sweet & Maxwell, London, p. 7.

៤៩. Federal Act on the Federal Assembly (2019, art. 32) The Federal Assembly of the Swiss Confederation. Available at: https://www.admin.ch/opc/en/classified-compilation/20010664/index.html [Accessed 11 Sep. 2020].

៥០. Dermont, C.,Hoesch, F.,Gassert, H., et al. (2020). A tool bringing the politicians back to work by providing a secure online space to do their parliamentary business [Blog] pandemia-parliament. Available at.: https://www.versusvirus.ch/blog/pandemia-parliament [Accessed 10 Sep. 2020].




ឆ្លើយតបទៅនឹងការរីករាលដាលនៃជំងឺរាតត្បាត មហាសន្និបាតអន្តរសភាអាស៊ានលើកទី ៤១ ត្រូវបានប្រារព្ធធ្វើឡើងតាមអនឡាញចាប់ពីថ្ងៃទី ៨-១០ ខែកញ្ញាឆ្នាំ២០២០ ។




"ការទូតសភាប្រកបដោយភាពស្អិតរមួត និងការឆ្លើយតប នៃសហគមន៍អាស៊ាន" ត្រូវបានពិភាក្សាបន្ថែមទៀតនៅក្នុងសម័យប្រជុំពេញអង្គលើកទី២ នៃមហាសន្និបាតអន្តរសភាលើកទី ៤១ ដែលបានប្រព្រឹត្តតាមអនឡាន នៅថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ២០២០ ។




បទបង្ហាញស្តីពី ប្រកតភ្ជាប់គ្នាប្រកបដោយនិរន្តរភាព នៃ ASEM ក្នុងកំលុងពេល កិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុប លើកទី១០ (ASEP 10) ក្នុងខែកញ្ញា ឆ្នាំ២០១៨ នៅទីក្រុងព្រុចសែល ប្រទេសបែលហ្សិក។
Dominique Hommel / រក្សាសិទ្ធិ©សហភាពអឺរ៉ុបឆ្នាំ២០១៨

ជំពូកទី

# ០២

# ប្រុសេកម្មសភា ដើម្បីសន្តិភាព សន្តិសុខ និងវិបុលភាពរួមៈ ទស្សនាទាននៃអាស៊ី


ទំ.៥០ ២.១ វិធីបែបអាស៊ានឆ្ពោះទៅរកពហុភាគីនិយម ដើម្បីសន្តិភាព សន្តិសុខ និងវិបុលភាព
*ដោយ ឯកអគ្គរាជទូត ពូ សុធីរៈ*

ទំ.៥៤ ២.២ ប្រុសេកម្មសភា ដើម្បីសន្តិភាព សន្តិសុខ និងវិបុលភាពរួមៈ ទស្សនាទាននៃអាស៊ី
*ដោយ លោក ហេង សន្យា*

ទំ.៥៨ ២.៣ បញ្ហាប្រឈមសន្តិសុខនៅអាស៊ីៈ ទស្សនាទាននៃអឺរ៉ុប
*ដោយ ហ្វ្រេដេរីក ហ្គ្រារេ*

ទំ.៦២ ២.៤ ការត្រួតពិនិត្យរបស់សភាទៅលើការប្រើប្រាស់កម្លាំង និងកម្លាំងប្រដាប់អាវុធ
*ដោយ បណ្ឌិត ម៉ាតឺស មូហ៍លីន*

# ២.១ វិធីបែបអាស៊ានឆ្ពោះទៅរកពហុភាគីនិយម ដើម្បីសន្តិភាព សន្តិសុខ និងវិបុលភាព

## វិធីបែបអាស៊ានឆ្ពោះទៅរកពហុភាគីនិយម

នៅក្នុងពេលជំណាលគ្នាដែលពហុភាគីនិយមទូទាំងសាកលលោកកំពុងស្ថិតក្រោមភាពតានតឹងយ៉ាងខ្លាំង ពហុភាគីនិយមនៅអាស៊ីអាគ្នេយ៍បែរជាកំពុងមានកម្លាំង និងឥទ្ធិពល។ វឌ្ឍនភាពនេះកើតមានឡើង ដោយសារមានការអភិវឌ្ឍបទដ្ឋាន និងគំនិតផ្តួចផ្តើមមួយចំនួនដែលជំរុញឲ្យមានការចូលរួម និងមានកិច្ចសហប្រតិបត្តិការរវាងរដ្ឋនិងរដ្ឋ។ ការរីកចម្រើននេះភាគច្រើន គឺដោយសារសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ទទួលបានភាពល្បីល្បាញពីអន្តរជាតិ តាមរយៈកិច្ចប្រឹងប្រែងការទូតរបស់ខ្លួនដើម្បីស្វែងរកដំណោះស្រាយនយោបាយគ្រប់ជ្រុងជ្រោយមួយចំពោះជម្លោះអូសបន្លាយ ដែលប្រទេសកម្ពុជាបានប្រឈមក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៨០។ ចាប់តាំងពីពេលនោះមក អាស៊ានត្រូវបានគេស្គាល់ថា ជាប្រភពដែលនាំឲ្យមានស្ថិរភាពក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលជាលទ្ធផលនៃកិច្ចសហប្រតិបត្តិការនិម្មាបនកម្មសន្តិសុខ (cooperative security Architectures) និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការទូលំទូលាយជាងមុនជាមួយនឹងមហាអំណាចធំៗ ជាមួយនឹងតំបន់អាស៊ីខាងកើត និងជាមួយប្រទេសផ្សេងៗក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។

យោងទៅតាម «វិធីបែបអាស៊ាន» មេដឹកនាំអាស៊ានចូលចិត្តប្រើនីតិវិធីក្រៅផ្លូវការ ព្រោះអាស៊ានជឿជាក់ទៅលើបរិយាកាសដែលគ្មានការគំរាមគំហែងក្នុងការការស្វែងរកវិធីដោះស្រាយបញ្ហា។ ដូច្នេះ នៅក្នុងការចូលរួមរបស់អាស៊ានក្នុងការពិគ្រោះយោបល់ស្តីពី សន្តិសុខពហុភាគី គឺអាស៊ានតែងតែសង្កត់ធ្ងន់ជានិច្ចពីសារៈសំខាន់នៃ"កម្រិតផាសុខភាព" របស់អ្នកចូលរួម ដោយបានអះអាងថា បញ្ហាណាដែលចម្រូងចម្រាសគួរតែដកចេញពីរបៀបវារៈ ជាជាងទុកនៅដែលអាចនាំឲ្យមានហានិភ័យដែលបង្កឲ្យមានភាពតានតឹង។ ជាឧទាហរណ៍ជាក់ស្តែងនៃអភិក្រមនេះ គឺវេទិកាតំបន់អាស៊ាន(ARF) ដែលមើលឃើញពហុភាគីនិយម ថាជាយន្តការសម្រាប់ដោះស្រាយបញ្ហាដើម្បីការពារ និងទប់ស្កាត់កុំឲ្យមានហានិភ័យនៃភាពគ្មានសណ្តាប់ធ្នាប់ក្នុងតំបន់។

អាស៊ានឈានទៅចាប់យកពហុភាគីនិយមតាមបែបបទដោយឡែកនៃតំបន់និយមរបស់ខ្លួន។ អភិក្រមនេះបាននាំឲ្យមានការវិវត្តនៃក្រុមនិងវេទិកាចម្រុះតែមិនមានលក្ខណៈដូចសហភាពអឺរ៉ុប ដែលធ្វើឲ្យមានបរិយាប័នស្ថាប័ននានាជាទ្រង់ទ្រាយធំ ដូចស្ថាប័នផ្សេងៗដែលបានបង្កើតនៅអឺរ៉ុបនោះទេ។ ពហុភាគីនិយមបែបអាស៊ានជាទូទៅពឹងផ្អែកលើការឯកភាពបែបកុងសង់ស៊ីស និងមិនចងកាតព្វកិច្ចទេ។ លក្ខណៈនេះ គឺផ្ទុយទៅនឹងអភិក្រមរបស់លោកខាងលិចចំពោះពហុភាគីនិយម ដែលច្រើនតែនិយមស្ថាប័និយកម្ម និងការចងកាតព្វកិច្ចចំពោះអង្គការក្នុងតំបន់របស់ខ្លួន។ "វិធីបែបអាស៊ាន" ចំពោះពហុភាគីនិយមច្រើនជំរុញដោយដំណើរការ ជាជាងដោយតួអង្គណាមួយ ដោយបញ្ហាប្រឈម ឬដោយព្រឹត្តិការណ៍ជាក់លាក់ណាមួយ។ ក្នុងន័យនេះ អាស៊ានប្រាថ្នាចង់អភិវឌ្ឍនីតិវិធីទាំងឡាយឲ្យស្របទៅនឹងបទដ្ឋាន និងការអនុវត្តដែលមានស្រាប់ក្នុងតំបន់របស់ខ្លួន។ វិធីនេះធ្វើឲ្យអ្នកដែលចូលរួមអាចធ្វើអន្តរកម្មជាមួយគ្នាប្រកបដោយផាសុកភាព ដែលនេះជាហេតុជួយជំរុញឲ្យមានអន្តរកម្មនៃពហុភាគី ពង្រឹងតម្លាភាព ភាពទុកចិត្តគ្នាទៅវិញទៅមក និងជួយឲ្យអាចដោះស្រាយបញ្ហាចម្រូងចម្រាសបានដោយសន្តិវិធី និងប្រកបដោយការស្តាបនា។

ចាប់ពីដែលបានបង្កើតឡើងនៅ ឆ្នាំ១៩៦៧ មក ដំណើរការតាមបែបតំបន់និយមរបស់អាស៊ានត្រូវបានប្រើដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការរឹងមាំក្នុងតំបន់ ឈានដល់ការពង្រីកកិច្ចសហប្រតិបត្តិការជាមួយតំបន់អាស៊ីខាងកើត ក្នុងពេលជាមួយគ្នាឈានទៅពង្រឹងទំនាក់ទំនងពហុភាគីជាមួយបណ្តាមហាអំណាចទាំងជិតនិងឆ្ងាយ។ អាស៊ានធ្វើបែបនេះ ដោយបានបន្តពង្រឹងវេទិកាតំបន់អាស៊ាន(ARF) (ចាប់ផ្តើមឡើងក្នុងឆ្នាំ១៩៩៤ ដោយមានសមាជិក២៧ប្រទេស) អាស៊ានបូកបី (ក្នុងឆ្នាំ១៩៩៧ បានរួមបញ្ចូលអាស៊ានទាំងដប់ បូកនឹងចិន ជប៉ុន និងកូរ៉េខាងត្បូង) កិច្ចប្រជុំកំពូលអាស៊ីបូព៌ា (សមាជិក១៨ប្រទេស រួមមាន ១៣ប្រទេសនៃអាស៊ានបូកបី ជាមួយនឹងឥណ្ឌា អូស្ត្រាលី នូវែលសេឡង់ រុស្ស៊ី និងសហរដ្ឋអាមេរិក ដែលបានជួបគ្នាលើកដំបូងនៅខែធ្នូ ឆ្នាំ២០០៥) និងកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិបូក (ADMM-Plus) (បានបង្កើតឡើងនៅខែតុលា ឆ្នាំ២០១០ មានសមាជិកអាស៊ាន រួមនឹងប្រទេសដែលមានអំណាចប្រាំបីទៀតគឺ៖ អូស្ត្រាលី ចិន ឥណ្ឌា ជប៉ុន នូវែលសេឡង់ សាធារណរដ្ឋកូរ៉េ រុស្ស៊ី និងសហរដ្ឋអាមេរិក)។

ការប្រកាន់ខ្ជាប់នូវពហុភាគីនិយមជួយការពារវិធាន និងបទដ្ឋាននានាដែលមានស្រាប់របស់សមាគម ក៏ដូចជាជួយការពារតំបន់ទប់ទល់នឹងការមើលស្រាលពីមហាអំណាចធំៗ។ “វិធីបែបអាស៊ាន” ឆ្ពោះទៅរកកិច្ចសហប្រតិបត្តិការសន្តិសុខពហុភាគី គឺជាការដាក់រាល់ការបារម្ភស្តីពីសន្តិសុខនៅលើតុដើម្បីពិភាក្សា ដោយអនុវត្តវិធីរបស់អាស៊ានក្នុងការកិច្ចសន្ទនា កិច្ចពិគ្រោះយោបល់ និងក្នុងស្ថាប័ន ដើម្បីបញ្ចៀសការសង្ស័យ ហើយបង្កើតឲ្យមានការយោគយល់គ្នាកាន់តែប្រសើរកសាងបាននូវទំនុកចិត្តរវាងគ្នា និងសម្របសម្រួលឲ្យមានការដោះស្រាយតាមអភិក្រមសន្តិវិធី ដើម្បីជៀសវាងនូវជម្លោះតំបន់ ការគំរាមគំហែង និងការប្រើប្រាស់កម្លាំង។ នេះហើយជាវិធីដែលអាស៊ានទាំងមូលអាចធ្វើឲ្យចិនចូលរួមជាលក្ខណៈពហុភាគីបាន ខណៈពេលដែលរដ្ឋជាសមាជិកនៅបន្តទទួលបានផលប្រយោជន៍ដោយឡែកៗពីវត្តមានដ៏រឹងមាំរបស់សហរដ្ឋអាម៉េរិកនៅក្នុងផ្នែកមួយនេះនៃពិភពលោក។

## បញ្ហាប្រឈមចំពោះតំបន់និយមរបស់អាស៊ាន

ទោះបីជាអាស៊ានទទួលបានជោគជ័យក្នុងការរក្សាទំនាក់ទំនងវិជ្ជមានជាមួយចិន និងសហរដ្ឋអាម៉េរិកក៏ដោយ ក៏បញ្ហាប្រឈមធំបំផុតចំពោះកិច្ចសហប្រតិបត្តិការពហុភាគីគឺនៅតែជាការព្រួយបារម្ភជុំវិញជម្លោះដែលអាចនឹងកើតមានក្នុងចំណោមមហាអំណាចធំៗ និងការខ្វះនូវយន្តការដើម្បីរារាំងឬជួយគ្រប់គ្រងឥរិយាបថរបស់មហាអំណាចទាំងនោះ។ ទោះបីសហរដ្ឋអាម៉េរិកជាប្រធានស្ថាបនិកនៃសណ្តាប់ធ្នាប់អន្តរជាតិដែលកើតក្រោយពីសង្គ្រាមលោកលើកទី២ក៏ដោយ ក៏អ្វីដែលបាននឹងកំពុងរីកដុះដាលនៅក្នុងសង្គមអាម៉េរិកចាប់តាំងពីប្រធានាធិបតីត្រាំឡើងកាន់តំណែងពីខែមករា ឆ្នាំ២០១៧មក គឺជាការឆ្លុះបង្ហាញឲ្យឃើញច្បាស់នូវការកើនឡើងនៃការផ្តាច់ខ្លួនរបស់ប្រជាជាតិនេះពីពិភពលោក។ ដោយផ្តោតលើ “America First” អាម៉េរិកហាក់ដូចជាបានបោះបង់ចោលនូវសណ្តាប់ធ្នាប់អន្តរជាតិ ដែលបានដឹកនាំដោយសហរដ្ឋអាម៉េរិកផ្ទាល់។ ក្នុងការព្យាយាម “ធ្វើឲ្យអាម៉េរិកក្លាយជាអស្ចារ្យម្តងទៀត” សហរដ្ឋអាម៉េរិកឥឡូវនេះកំពុងតែបដិសេធថាសាកលភាវូបនីយកម្មមិនមែនជាកម្លាំងវិជ្ជមានមួយ។ ជាមួយនឹងទស្សនៈជាតិនិយមដ៏ខ្លាំងក្លា និងការឆ្ពោះទៅរកគាំពារនិយម សព្វថ្ងៃនេះ សហរដ្ឋអាម៉េរិកគឺ កំពុងតែបោះបង់នូវតួនាទីដឹកនាំរបស់ខ្លួនលើសណ្តាប់ធ្នាប់អាស្រ័យច្បាប់បែបពហុភាគី ដែលធ្លាប់ជាចំណុចស្នូលមួយនៃគោលនយោបាយការបរទេសរបស់អាម៉េរិក និងប្រភពនៃអនុត្តរភាពរបស់អាម៉េរិក។

ការងើបឡើងដ៏អស្ចារ្យនិងភ្ញាក់ផ្អើលរបស់ចិន គឺមិនមែនផ្តល់ភាពតានតឹងតិចតួចដល់អាស៊ាននោះទេ។ ប្រកបដោយទំនុកចិត្ត និងកម្លាំងកាន់តែខ្លាំងក្លា ចិនបានតាមទាន់ជាមួយលោកខាងលិចទាក់ទងនឹងផ្នែកសេដ្ឋកិច្ច ការអភិវឌ្ឍបច្ចេកវិទ្យា និងសមត្ថភាពការពារមួយចំនួន និងបានធ្វើសមាហរណកម្មខ្លួនទៅក្នុងសេដ្ឋកិច្ចសាកលលោក។ ប៉ុន្តែចិនមិនបានយកតាមនូវទ្រឹស្តីសណ្តាប់ធ្នាប់អាស្រ័យច្បាប់របស់លោកខាងលិច ឬគុណតម្លៃណាមួយរបស់លោកខាងលិចដូចជា ប្រជាធិបតេយ្យតំណាង និងសិទ្ធិមនុស្សជាសកលនោះទេ។នៅពេលដែលចិនត្រូវការពារអត្ថប្រយោជន៍ស្នូលរបស់ខ្លួន ដូចជាបញ្ហាទាក់ទងនឹងសមុទ្រចិនខាងត្បូង ចិនមានភាពស៊ីសង្វាក់និងភាពច្បាស់លាស់ពីជំហរដែលខ្លួនចង់បាន ពោលគឺប្រើការរចរចាទ្វេភាគីជាមួយនឹងភាគីពាក់ព័ន្ធផ្ទាល់ ជាជាងពឹងផ្អែកលើការរៀបចំបែបពហុភាគី ដូចជាតាមរយៈតុលាការអន្តរជាតិជាដើម។ ទ្វេភាគីនិយមផ្តល់នូវក្របខ័ណ្ឌមួយដែលអាចបត់បែនបានច្រើនសម្រាប់កិច្ចសហប្រតិបត្តិការ ហើយផ្តល់ឲ្យចិននូវឥទ្ធិពលកាន់តែខ្លាំងលើសម្ព័ន្ធមិត្តរបស់ខ្លួន។

បញ្ហាប្រឈមមួយផ្សេងទៀត គឺជាឌីអិនអេ (DNA) ផ្ទាល់របស់អាស៊ាន។ បទដ្ឋានដែលបានចាក់ឫសយ៉ាងជ្រៅគឺការមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុង និងការធ្វើសេចក្តីសម្រេចចិត្តផ្អែកលើការឯកភាពបែបកុងសង់ស៊ីសអាចកម្រិតការចូលរួមរបស់សមាគមនេះលើការទទួលបន្ទុកដោះស្រាយបញ្ហាបន្ទាន់ផ្នែកសន្តិសុខ និងភូមិសាស្ត្រនយោបាយក្នុងតំបន់។ ការប្រកាន់ខ្ជាប់យ៉ាងរឹងមាំទៅនឹងគោលការណ៍ទាំងនេះ ក្នុងពេលនេះធ្វើឲ្យអាស៊ានបាត់ឱកាសក្នុងការបោះជំហានឲ្យបានវែង និងទទួលបានការគោរពបន្ថែមទៀតពីប្រទេសជាសមាជិក និងដៃគូខាងក្រៅ ជាពិសេសដើម្បីពង្រឹងតួនាទីរបស់ខ្លួនឲ្យបានត្រឹមត្រូវ ក្នុងនាមជាអ្នកដែលជំរុញឲ្យមានសន្តិភាព ស្ថិរភាព និងវិបុលភាពក្នុងតំបន់អាស៊ីអាគ្នេយ៍នេះ។ ឧទាហរណ៍មួយនៃយន្តការកិច្ចសហប្រតិបត្តិការពហុភាគីដ៏សំខាន់របស់អាស៊ាន ដែលរួមមានដូចជា វេទិកាតំបន់អាស៊ាន (ARF) នៅតែខ្វះសមត្ថភាពពង្រឹងក្របខ័ណ្ឌសម្រាប់ “ច្បាប់នៃអាកប្បកិរិយាដែលអាចទទួលយកបាន”។

បញ្ហាប្រឈមផ្ទៃក្នុងអាស៊ាន រួមមានល្បឿនយឺតនៃដំណើរការសមាហរណកម្មរបស់ខ្លួនដើម្បីកាត់បន្ថយគម្លាតខុសគ្នានៃសេដ្ឋកិច្ច និងវិសមភាពរវាងរដ្ឋសមាជិក។ ចំពោះការគ្រប់គ្រងសន្តិសុខតាមព្រំដែន អាស៊ានត្រូវតែស្វែងរកវិធីសាស្ត្រច្បាស់លាស់បន្ថែមទៀត ដើម្បីជួយសម្របសម្រួល និងដោះស្រាយជម្លោះរវាងសមាជិកនៃសមាគម។ អាស៊ានក៏អាចជំរុញស្មារតីយកចិត្តទុកដាក់ និងឆន្ទៈរបស់ខ្លួនក្នុង

> “អាស៊ានត្រូវតែរកវិធីច្បាស់លាស់ ដើម្បីជួយផ្សះផ្សារ និងដោះស្រាយទំនាស់រវាងសមាជិករបស់សមាគម”

ការជួយរដ្ឋជាសមាជិកដែលមានការលំបាកដោយសារបញ្ហាផ្ទៃក្នុងប្រទេស។ ដូច្នេះការគិតគូរសមរម្យឡើងវិញអំពី គោលការណ៍មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុង និងដំណើរនៃការធ្វើសេចក្តីសម្រេចចិត្តដែលមានលក្ខណៈឆ្លើយតបទាន់ពេលវេលា ក៏ដូចជាអភិក្រមដែលសកម្មជាងមុនលើបញ្ហាដូចជាអភិបាលកិច្ចល្អ សិទ្ធិមនុស្ស ប្រជាធិបតេយ្យ គណនេយ្យភាព និងតម្លាភាព គួរសិក្សាបន្ថែមទៀត។

ចំណែកឯបញ្ហាប្រឈមខាងក្រៅសម្រាប់អាស៊ាន គឺមានដូចជាភាពលំបាករបស់អាស៊ានក្នុងការពិភាក្សាគ្នាដោយស្រុះស្រួល ពីបញ្ហាសន្តិសុខដែលមិនមានការគំរាមកំហែងផ្នែកយោធាដែលធ្វើឲ្យបាត់នូវ“មជ្ឈភាពអាស៊ាន”។ការណ៍នេះបានជះផលប៉ះពាល់ដល់មុខមាត់ និងកេរ្តិ៍ឈ្មោះរបស់សមាគម ដែលជានិច្ចជាកាលមានការរិះគន់មួយចំនួនដែលថា អាស៊ានជាវេទិកាមួយដែល “សម្រាប់តែនិយាយ និងមិនមានសកម្មភាពគ្រប់គ្រាន់”។ អាស៊ានត្រូវតែចាត់វិធានការណ៍ឲ្យបានស៊ីជម្រៅជាជាងធ្វើសកម្មភាពសើរៗ ទៅលើបញ្ហាទាំងឡាយនាពេលសព្វថ្ងៃ ដូចជាការរំសាយអាវុធនុយក្លេអ៊ែរនៅឧបទ្វីបកូរ៉េ ជម្លោះសមុទ្រចិនខាងត្បូង វិបត្តិមនុស្សធម៌នៅរដ្ឋរ៉ាឃីនដែលពោរពេញដោយបញ្ហា ផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ និងការវាយប្រហារតាមប្រព័ន្ធទូរគមនាគមន៍ និងបញ្ហាសន្តិសុខមិនមែនប្រពៃណីផ្សេងទៀត។ នៅក្នុងន័យនេះ ARF ត្រូវតែឈានទៅមុខលើសពីតួនាទីរបស់ខ្លួន ដែលគ្រាន់តែជាវេទិកានិយាយដើម្បីដោះស្រាយស្ថានការណ៍សន្តិសុខដ៏ស្មុគស្មាញនាពេលបច្ចុប្បន្ន។ ចក្ខុវិស័យបីដំណាក់កាលឆ្ពោះទៅមុខរបស់ARF រួមមាន៖ ទីមួយ ត្រូវដើរទៅឲ្យហួសពីការកសាងភាពជឿជាក់និងទំនុកចិត្ត, ទីពីរ ទប់ស្កាត់ជម្លោះតាមរយៈការទូតបែបទប់ស្កាត់ជម្លោះ (Preventive Diplomacy) និងទីបី បញ្ចប់ជម្លោះតាមរយៈការដោះស្រាយជម្លោះ។

## ដំណើរឆ្ពោះទៅមុខសម្រាប់អាស៊ាន ដើម្បីលើកកម្ពស់ពហុភាគីនិយម សម្រាប់ផលប្រយោជន៍សន្តិភាព សន្តិសុខ និងវិបុលភាព

ពហុភាគីនិយមតាមបែបអាស៊ាន មានប្រវត្តិដ៏យូរលង់នៅក្នុងតំបន់ ដោយផ្សារភ្ជាប់ទៅនឹងវិធីពិសេសរបស់អាស៊ានក្នុងកិច្ចពិគ្រោះយោបល់និងការរៀបចំជាសមូហភាពក្នុងវិស័យសេដ្ឋកិច្ច នយោបាយ និងសន្តិសុខ។ ទោះបីជាវិធីបែបអាស៊ាន គឺយកការឯកភាពបែបកុងសង់ស៊ីសជាជាងយកមតិភាគច្រើន ប៉ុន្តែការប្តេជ្ញាចិត្តអនុវត្តតាមគោលការណ៍មិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់ប្រទេសដទៃ និងការធ្វើសេចក្តីសម្រេចចិត្តតាមរយៈរចនាសម្ព័ន្ធក្រៅផ្លូវការ និងភាពជាគំរូ បានដំណើរការយ៉ាងល្អនៅក្នុងអាស៊ានក្នុងអំឡុងពេល ៥០ឆ្នាំកន្លងមកក៏ដោយ ក៏មានមតិខ្លះអះអាងថា “អាស៊ាននៅតែជាស្ថាប័ននយោបាយមួយដែលមានកម្រិតដែលនៅមានភាពស្ទាក់ស្ទើរក្នុងការដោះស្រាយកង្វល់ទាក់ទងនឹងបញ្ហាសន្តិសុខក្រោយសង្គ្រាមត្រជាក់” [១]។

ដើម្បីឲ្យពហុភាគីនិយមបែបអាស៊ានធ្វើបានជោគជ័យ និងអាចដោះស្រាយបញ្ហាសន្តិសុខធំៗបាន រដ្ឋជាសមាជិកអាស៊ានទាំងអស់ត្រូវស្រមៃថា កិច្ចសហប្រតិបត្តិការពហុភាគីមិនមែនគ្រាន់តែជាការដោះស្រាយលំហាត់ធម្មតានៃការគ្រប់គ្រងបញ្ហាភាពគ្មានសណ្តាប់ធ្នាប់នៅក្នុងតំបន់នោះទេ។ ដើម្បីមានភាពបុរេសកម្មក្នុងការរក្សាសន្តិភាព និងធ្វើសកម្មភាពឆ្ពោះទៅមុខសំដៅលើកកម្ពស់វិបុលភាព អាស៊ានត្រូវពិចារណាលើចំណុចដូចខាងក្រោម៖

- ត្រូវមានកិច្ចប្រឹងប្រែងបន្ថែមជាចាំបាច់ដើម្បីទាក់ទាញចិនក្នុងន័យស្ថាបនា។ ប្រទេសចិនមិនត្រឹមតែស្ថិតនៅចំកណ្តាលនៃបញ្ហាថាតើរបៀបវារៈសន្តិសុខក្នុងតំបន់ត្រូវវិវត្តបែបណាទេ ប៉ុន្តែក៏ជាចំណុចស្នូលនៃលទ្ធភាពឈានទៅរកភាពជោគជ័យនៃការបង្កើតក្របខ័ណ្ឌសន្តិសុខណាមួយផងដែរ។ អាស៊ានគប្បីទទួលស្គាល់ការពិតនេះ។
- អាស៊ានត្រូវខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីអាចទទួលបានចំណាប់អារម្មណ៍ និងការចូលរួមយូរអង្វែងពីសហរដ្ឋអាម៉េរិក ព្រោះថា ស្ថានភាពសន្តិសុខក្នុងតំបន់កាន់តែមានភាពប្រែប្រួលជាងពេលណាៗទាំងអស់។ សហរដ្ឋអាម៉េរិក នៅតែមានផលប្រយោជន៍ច្រើននៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ហើយវត្តមានបន្តរបស់សហរដ្ឋអាម៉េរិកនៅក្នុងតំបន់អាចជួយទប់ស្កាត់ជម្លោះក្នុងតំបន់ និងការប៉ុនប៉ងត្រួតត្រាពីមហាអំណាចខាងក្រៅ។
- អាស៊ានមិនត្រូវលំអៀងទេ ប៉ុន្តែត្រូវរក្សាឲ្យបាននូវគោលការណ៍អព្យាក្រឹតរបស់ខ្លួនដើម្បីកុំឲ្យមានឧបសគ្គក្នុងការសម្រេចឲ្យបាននូវការរៀបចំសន្តិសុខ ដែល

អាចជួយកាត់បន្ថយភាពតានតឹងដែលបណ្តាលមកពីការប្រកួតប្រជែងក្នុងចំណោមមហាអំណាច។ អាស៊ានត្រូវតែបញ្ជាក់ឲ្យច្បាស់ថា អាស៊ីអាគ្នេយ៍គ្មាននរណានៅពីក្រោយទេ ហើយគ្មានអំណាចមកពីក្រៅណាមួយដែលត្រូវបានអនុញ្ញាតឲ្យយកមកប្រើលើកិច្ចការណាមួយ ដែលអាចបង្កគ្រោះថ្នាក់ដល់ប្រយោជន៍រួមនៅក្នុងតំបន់ឡើយ។ ជម្រើសរបស់អាស៊ាននឹងមានតិច ប្រសិនបើសមាគមនេះពឹងផ្អែកលើមហាអំណាចតែមួយ។ ហេតុដូច្នេះ អាស៊ានត្រូវបន្តទាក់ទាញគ្រប់មហាអំណាចខាងក្រៅឲ្យចូលរួមដោយភាពស្មោះត្រង់ និងប្រកបដោយស្មារតីស្ថាបនា។

- អាស៊ានគប្បីបន្តនូវការព្យាយាមរបស់ខ្លួនក្នុងការធ្វើឲ្យសហរដ្ឋអាម៉េរិក និងចិនបន្តចូលរួម តាមរយៈក្របខ័ណ្ឌដែលមានស្រាប់ដូចជា ARF បើទោះជាអ្វីដែលអាចសម្រេចបាននៅមានកំរិតក៏ដោយ។ ទីក្រុងវ៉ាស៊ីនតោន និងប៉េកាំងមានចំណាប់អារម្មណ៍ក្នុងការបំពេញចិត្តអាស៊ាន និងផ្តល់ការយកចិត្តទុកដាក់បំពេញតាមបំណងប្រាថ្នារបស់អាស៊ាននៅពេលរៀបចំគោលនយោបាយរបស់គេរៀងៗខ្លួន។ អាស៊ានមានឥទ្ធិពលយ៉ាងណាចំពោះបញ្ហានេះ គឺអាស្រ័យលើសមត្ថភាពអាស៊ានខ្លួនឯង ក្នុងការធ្វើឲ្យមានការរួបរួម និងមានមជ្ឈភាព ដូច្នេះការជំរុញដំណើរការរបស់ ARF កិច្ចប្រជុំកំពូលអាស៊ីបូព៌ា (EAS) និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការពារជាតិបូកឲ្យឈានទៅមុខ គឺជាការចាំបាច់ដែលអាស៊ានត្រូវធ្វើដោយយកចិត្តទុកដាក់។
- ដើម្បីឲ្យអាស៊ានអាចក្លាយជា "ជើងឯក" នៃពហុភាគីនិយម អាស៊ានត្រូវតែពង្រឹងខ្លួនឡើងវិញ ហើយសម្របសម្រួលស្ថាប័នដែលមានស្រាប់ទៅនឹងនិន្នាការថ្មីៗ ដើម្បីធានាឲ្យបានថា កិច្ចសហប្រតិបត្តិការតំបន់ និងពហុភាគីអាចដំណើរការបានដោយត្រឹមត្រូវក្នុងការដោះស្រាយបញ្ហាតំបន់។ ជាពិសេសទៀតអាស៊ានត្រូវព្យាយាមធ្វើឲ្យមានតុល្យភាពរវាងកិច្ចសហប្រតិបត្តិការពហុភាគីដែលមានរចនាសម្ព័ន្ធទន់ខ្សោយ ដែលសង្កត់ធ្ងន់តែលើការពង្រឹងឯកភាពបែបកុងសង់ស៊ុស ទៅនឹងការអនុវត្តតាមបែបផ្សេងទៀតនៃពហុភាគីនិយមដែលធ្វើឡើងតាមរបៀបរបស់អឺរ៉ុប គឺការប្តេជ្ញាចិត្តដែលចងកាតព្វកិច្ចដោយច្បាប់ នៅក្នុងរចនាសម្ព័ន្ធស្ថាប័នទូលំទូលាយ។
- ដោយតថភាពជាក់ស្តែងនៃអំណាចនយោបាយអាចមានឥទ្ធិពលអវិជ្ជមានដល់ពហុភាគីនិយមបែបអាស៊ាន តែវាប្រហែលជាអាចនឹងមានផលប្រយោជន៍បើអាស៊ានអាចធ្វើតាមគំរូរបស់សហភាពអឺរ៉ុបនៃ "ពហុភាគីនិយមប្រកបដោយប្រសិទ្ធភាព" (ជាសណ្តាប់ធ្នាប់អាស្រ័យលើច្បាប់មួយ ដែលសង្កត់ធ្ងន់លើការចែករំលែកនូវអធិបតេយ្យភាព ការដោះស្រាយបញ្ហារួម និងមានសកម្មភាពដូចគ្នា ដើម្បីសម្រេចបានសន្តិភាព សន្តិសុខ និងវិបុលភាព)។ អាស្រ័យហេតុនេះ អាស៊ានគប្បីប្រឹងប្រែងកសាងភាពជាដៃគូជាមួយសហភាពអឺរ៉ុបឲ្យកាន់តែខ្លាំងក្លាឡើង។ ក្នុងនាមជាដៃគូ អាស៊ាននិងសហភាពអឺរ៉ុបអាចប្រមូលឆន្ទៈនយោបាយ ដែលចាំបាច់ដើម្បីកែសម្រួល និងបង្កើតនូវសណ្តាប់ធ្នាប់ថ្មីមួយនៃពហុភាគីនិយមដើម្បីបញ្ចៀសនូវគ្រោះថ្នាក់នៃជម្លោះ និងការប៉ះទង្គិចដោយកម្លាំងរវាងរដ្ឋដែលមានអំណាច។ សម្រាប់ផ្នែករបស់ខ្លួន សហភាពអឺរ៉ុបគប្បីទទួលស្គាល់នូវការចូលរួមចំណែកដ៏មានអត្ថន័យរបស់អាស៊ានឆ្ពោះទៅរកពហុភាគីនិយមដែលកំពុងវិវត្តទៅមុខនេះ។

ទោះបីជាមានចំណុចខ្វះចន្លោះក៏ដោយ ក៏អាស៊ានបានទទួលជោគជ័យគួរឲ្យកត់សម្គាល់ ក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការតំបន់តាមរយៈកិច្ចសន្ទនាបែបកុងសង់ស៊ុស។ អភិក្រមនេះបានជួយបង្កើតនូវសណ្តាប់ធ្នាប់តំបន់ក្រោយពីសង្គ្រាមត្រជាក់ ដែលមានលក្ខណៈខុសប្លែកទាក់ទងទៅនឹងវិធីដែលស្ថាប័នពហុភាគីបានរៀបចំដើម្បីអាចមានអត្ថិភាពរួមគ្នា តែមិនមែនជំនួសគ្នាទេ ក្នុងការរៀបចំសន្តិសុខតាមបែបប្រពៃណី ដូចជាការបង្កើតសម្ព័ន្ធមិត្ត រចនាសម្ព័ន្ធពិភពលោកធំទូលាយ ឬរចនាសម្ព័ន្ធទ្វេភាគីតូចចង្អៀតសម្រាប់អភិបាលកិច្ច សេដ្ឋកិច្ច ឬការរៀបចំសន្តិសុខបែបប្រពៃណីទូលំទូលាយផ្សេងទៀតជាដើម។ ដូច្នេះ វិធីបែបអាស៊ានគួរតែទទួលបាននូវការស្វាគមន៍មួយបន្ថែមទៅលើការកសាងអនាគតនៃពហុភាគីថ្មីមួយ។

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដែលបកដោយវិទ្យាស្ថានជាតិការទូតនិងទំនាក់ទំនងអន្តរជាតិនៃកម្ពុជា (NIDIR)។ អ្នកអានអាចទាញយកអត្ថបទដើមជាភាសាអង់គ្លេសពីគេហទំព័រ៖ https://www.pic.org.kh ។

# ២.២ ប្រសេកម្មសភា ដើម្បីសន្តិភាព សន្តិសុខ និង វិបុលភាពរួម៖ ទស្សនៈបែបអាស៊ី

លាតសន្ធឹងលើផ្ទៃដី ៣០ ភាគរយនៃផ្ទៃដីពិភពលោកទាំងមូល និងជាទីស្នាក់អាស្រ័យនៃប្រជាពលរដ្ឋជាង ៤ ពាន់លាននាក់ [២] អាស៊ីជាទ្វីបប្រកបដោយពិពិធភាពផ្នែកនយោបាយ សេដ្ឋកិច្ច និងវប្បធម៌។ នេះក៏ដោយសារតែទំហំដ៏ធំល្វឹងល្វើយ ភាពស្មុគស្មាញនៃប្រជាសាស្ត្រ និងកេរដំណែលប្រវត្តិសាស្ត្រដែលបង្កឲ្យមានបរិយាកាសភូមិសាស្ត្រនយោបាយមួយប្រកបដោយថាមវន្ត និងបញ្ហាច្រើនក្នុងពេលជាមួយគ្នា។ អ្វីដែលគួរឲ្យកត់សម្គាល់នោះគឺ ទ្វីបអាស៊ីមានអនុតំបន់ធំៗជាច្រើនដូចជា អាស៊ីបូព៌ា អាស៊ីអាគ្នេយ៍ អាស៊ីខាងត្បូង អាស៊ីកណ្ដាល និងមជ្ឈឹមបូព៌ា ដែលជាទីប្រជុំប្រទេសមានអំណាចធំៗដែលទន្ទឹមនឹងសហការគ្នាក៏ប្រកួតប្រជែងគ្នាយ៉ាងស្រួចស្រាវលើវិស័យសេដ្ឋកិច្ច និងយោធា។ ការណ៍ទាំងនេះជម្រុញឲ្យមានការកើនឡើងនូវបញ្ហាសន្តិសុខសហសម័យ ទាំងសន្តិសុខបែបប្រពៃណី និងមិនមែនប្រពៃណី ដែលអាចគំរាមកំហែងយ៉ាងធ្ងន់ធ្ងរលើសន្តិភាព សន្តិសុខ និងវិបុលភាពរួមមិនត្រឹមតែរបស់អាស៊ីខ្លួនឯង តែក៏ពាក់ព័ន្ធដល់ដៃគូខាងក្រៅរបស់អាស៊ីដូចជាសហរដ្ឋអាមេរិក អឺរ៉ុប និងបណ្ដាប្រទេសសម្ព័ន្ធមិត្តរបស់ពួកគេ។

## ស្ថានភាពសន្តិសុខសហសម័យនៅអាស៊ី

បញ្ហាសន្តិសុខបែបប្រពៃណីដែលកំពុងកើតមាននៅទ្វីបអាស៊ីមានចាប់តាំងពី ជម្លោះក្នុងដែនសមុទ្រចិនខាងត្បូងរវាងចិន និងរដ្ឋដើមបណ្ដឹងជាសមាជិកអាស៊ានមួយចំនួនដែលបង្កការរំខានដល់សេរីភាពនាវាចរណ៍ ប៉ះពាល់ដល់សណ្ដាប់ធ្នាប់ បទដ្ឋាន និងច្បាប់អន្តរជាតិ ហើយជាវិញ្ញាសារសាកល្បងសាមគ្គីភាពរបស់អាស៊ានទាំងមូល រហូតដល់បញ្ហាទំនាក់ទំនងនយោបាយការទូតរវាងចិន និងតៃវ៉ាន់ដែលរឹងរឹតតែស្មុគស្មាញឡើងដោយសារតែ "ភាពស្រពេចស្រពិលជាយុទ្ធសាស្ត្រ" របស់សហរដ្ឋអាមេរិក [៣]។ បន្ថែមលើនេះ បញ្ហាលុបបំបាត់កម្មវិធីអាវុធនុយក្លេអ៊ែរនៅឧបទ្វីបកូរ៉េបានបង្កការគំរាម កំហែងជាពិសេសដល់សន្តិសុខរបស់សម្ព័ន្ធមិត្តសហរដ្ឋអាមេរិកតួយ៉ាង កូរ៉េខាងត្បូង និងជប៉ុន ខណៈដែលជម្លោះក្នុងដែនសមុទ្រចិនខាងកើតបាន និងកំពុងរុញមហាអំណាចសេដ្ឋកិច្ចពិភពលោកទី២ (ចិន) ឲ្យប្រឈមនឹងមហាអំណាចសេដ្ឋកិច្ចពិភពលោកទី៣ (ជប៉ុន)។ មិនតែប៉ុណ្ណោះ វិបត្តិសង្គ្រាមស៊ីវិលនៅស៊ីរីបន្តបញ្ឆេះភាពតានតឹងរវាងសហរដ្ឋអាមេរិក និងរុស្ស៊ី នេះមិនទាន់គិតពីបញ្ហាលំហូរនៃជនភៀសខ្លួនទៅកាន់អឺរ៉ុបផង។ ក្នុងពេលជាមួយគ្នានេះ ការខកខានមិនអាចធ្វើបានតាមកិច្ចព្រមព្រៀងនុយក្លេអ៊ែរអ៊ីរ៉ង់កាន់តែធ្វើឲ្យរាំងស្ទះដល់ដំណើរការរក្សាស្ថិរភាព និងសន្តិភាពតំបន់ ក៏ដូចជារាំងស្ទះដល់ការផ្គត់ផ្គង់ប្រេងជាសកលផងដែរ។

ម្យ៉ាងទៀត អាស៊ីក៏នៅតែបន្តប្រឈមនឹងជម្លោះព្រំដែនអន្តរជាតិដែលមិនទាន់ដោះស្រាយទាក់ទងនឹងរដ្ឋនៅអាស៊ីអាគ្នេយ៍ ជម្លោះព្រំដែនរវាងឥណ្ឌា និងប៉ាគីស្ថាន ហើយនៅមានជម្លោះរវាងអ៊ីស្រាអែល និងប៉ាឡេស្ទីន ក៏ដូចជាចលនាបំបែករដ្ឋប្រដាប់អាវុធនៅភាគនិរតីមីយ៉ាន់ម៉ា និងភាគខាងត្បូងថៃ។ បើគ្មានការតាមដានត្រួតពិនិត្យហ្មត់ចត់ និងវិធានការណ៍ត្រឹមត្រូវ និងទាន់ពេលវេលាទេ បញ្ហាទាំងនេះអាចបង្កគ្រោះធ្ងន់ធ្ងរដល់ទំនុកចិត្តក្នុងតំបន់ក្នុងចំណោមរដ្ឋអាស៊ីដែលពាក់ព័ន្ធ និងដៃគូខាងក្រៅរបស់ខ្លួន ក៏ដូចជាផលប៉ះពាល់ដោយផ្ទាល់លើសន្តិសុខតំបន់ជារួមដែរ។

ទន្ទឹមនឹងនេះ បញ្ហាសន្តិសុខមិនមែនប្រពៃណីមួយចំនួនដែលកំពុងរាលដាលសព្វថ្ងៃនេះប្រៀបបានដូចជាដាវមុខពីរ ដោយម្យ៉ាងបាន និងកំពុងបំផ្លាញកាន់តែច្រើនឡើងនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសន្តិសុខមនុស្សជាតិក្នុងទ្វីបអាស៊ី ហើយម្យ៉ាងទៀតក៏ជម្រុញរដ្ឋដែលពាក់ព័ន្ធទាំងឡាយឲ្យស្វះស្វែងរកវិធានការណ៍ឆ្លើយតបរួមគ្នា។ ឧទាហរណ៍ដូចជា អំពើភេរវកម្ម ជាពិសេសការផ្ទុះឡើងនៃចលនាក្រុមរដ្ឋអ៊ីស្លាមជ្រុលនិយម អាយស៊ីស (ISIS) នៅមជ្ឈឹមបូព៌ា និងផ្នែកខ្លះនៅអាស៊ីអាគ្នេយ៍ បានបង្កវិនាសកម្មរូបវន្ត និងគ្រោះមហន្តរាយផ្នែកមនុស្សធម៌យ៉ាងធ្ងន់ធ្ងររួមមានលំហូរជនភៀសខ្លួនទ្រង់ទ្រាយធំទាំងក្នុងតំបន់ និងអន្តរតំបន់។ ការដួលរលំនៃពួក ISIS ក្នុងឆ្នាំ២០១៩ បានបង្វែរឥទ្ធិពលមកកាន់ក្រុមអាល់កៃដា (Al-Qaeda) និងបង្កើតភាពភ័យខ្លាចអំពីការវិលត្រឡប់នៃក្រុមភេរវកម្មបរទេសរបស់ ISIS មកកាន់ស្រុកកំណើតវិញដែលរួមបញ្ចូលទាំងនៅអាស៊ីអាគ្នេយ៍ផងដែរ [៤]។

លើសពីនេះ ជំងឺឆ្លង ឬជំងឺរាតត្បាតសកល ជាពិសេស ការផ្ទុះរីករាលដាលនៃជំងឺកូវីដ-១៩ (Covid-19) នៅប្រទេសចិននៅដើមឆ្នាំ២០២០ បាននាំឲ្យមានចត្តាឡីស័កទ្រង់ទ្រាយធំក្នុងប្រទេស និងក្នុងទ្វីបជាច្រើន ការកើនឡើងនៃការរើសអើងពូជសាសន៍ និងភាពអាក់រអួលផ្នែកសេដ្ឋកិច្ចគួរឲ្យកត់សម្គាល់។ បញ្ហានេះបានបន្ថែមភាពធ្ងន់ធ្ងរទាក់ទងនឹងការគំរាមកំហែងក្នុងតំបន់មកលើសន្តិសុខមនុស្សជាតិ និងបន្ថែមបន្ទុកថ្មីមួយទៀតពីលើបន្ទុកដែលមានស្រាប់ក្នុងបញ្ជីបញ្ហាសន្តិសុខមិនមែនប្រពៃណីដូចជា បម្រែបម្រួលអាកាសធាតុ ការបំផ្លាញបរិស្ថាន ការជួញដូរថ្នាំញៀន និងមនុស្ស ការទន្ទ្រានធនធានធម្មជាតិ សន្តិសុខស្បៀង និងថាមពល គ្រោះមហន្តរាយធម្មជាតិ និងសង្គ្រាមតាមប្រព័ន្ធទូរគមនាគមន៍ រួមទាំងការផ្សព្វផ្សាយព័ត៌មានមិនពិត។

## និម្មាបនកម្មសន្តិសុខបច្ចុប្បន្នរបស់អាស៊ី

ក្នុងបរិបទបច្ចុប្បន្ននេះ ច្បាស់ណាស់ដែលថាគ្មានរដ្ឋណាមួយអាចទប់ទល់នឹងភាពចាក់ស្រេះនៃបញ្ហាសន្តិសុខទាំងបែបប្រពៃណី និងមិនមែនប្រពៃណីបានតែឯកឯងទេ ដូច្នេះយន្តការនៃកិច្ចសហប្រតិបត្តិការរួមគ្នាជារឿងមិនអាចខ្វះបានឡើយ។ ហេតុនេះ បញ្ហាប្រឈមរួមទាំងនេះអាចដើរតួរជាបុរេលក្ខខណ្ឌជម្រុញឲ្យមានការបង្កើតឡើងនូវនិម្មាបនកម្មសន្តិសុខអាស៊ីប្រកបដោយបរិយាបន្ន[៥] ដែលរួមមានដូចជា វេទិកាតំបន់អាស៊ាន (ARF) កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការពារជាតិអាស៊ាន (ADMM) កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការពារជាតិអាស៊ានបូក (ADMM+) កិច្ចប្រជុំកំពូលអាស៊ីបូព៌ា (EAS) និងគំនិតផ្តួចផ្តើមពាក់ព័ន្ធដទៃទៀតដែលបង្កើតឡើងដើម្បីដោះស្រាយបញ្ហាសន្តិសុខតំបន់ទាំងបែបប្រពៃណី និងមិនមែនប្រពៃណី។ ស្ថាប័នទាំងនេះធ្វើប្រតិបត្តិការមិនត្រឹមតែក្នុងកម្រិតរដ្ឋាភិបាល (Track I) ប៉ុណ្ណោះទេ តែក៏តាមរយៈក្រុមមន្ត្រីជំនាញ (Track II) ផងដែរ ហើយដែលប្រតិបត្តិការទាំងនេះអាចត្រូវបានជួយលើកកម្ពស់បន្ថែមដោយការគាំទ្រពីសំណាក់សភាដែលត្រូវបានពិភាក្សានៅចំណុចខាងក្រោម។ គួរឲ្យកត់សម្គាល់និម្មាបនកម្មដែលមានស្រាប់ក្នុងពេលបច្ចុប្បន្នស្ទើរទាំងអស់មានជាប់ពាក់ព័ន្ធជាមួយនឹងរដ្ឋដែលនៅអមសងខាងមហាសមុទ្រប៉ាស៊ីហ្វិច ដោយហេតុថា អនុតំបន់ដទៃទៀតក្នុងទ្វីបអាស៊ីពុំទាន់ឈានទៅបង្កើត ឬសម្រេចបាន គំនិតផ្តួចផ្តើមតំបន់ដែលមានលក្ខណៈជាក់ស្តែងនៅឡើយ។

## ទស្សនវិស័យរបស់អាស៊ីលើបញ្ហាសន្តិសុខ៖ វិធីបែបអាស៊ីចំពោះពហុភាគីនិយកម្ម

ខណៈដែលពហុភាគីនិយមមានសារៈសំខាន់ចំពោះសន្តិសុខតំបន់ គេមិនគួរបណ្តោយឲ្យវាប៉ះពាល់ដល់មជ្ឈភាពអាស៊ីឡើយ។ តួនាទីក្នុងការកំណត់ជោគវាសនារបស់ខ្លួន និងអធិបតេយ្យភាពនៅតែមានភាពសំខាន់ខ្លាំងបំផុត ដែលជាតម្លៃដក់ជាប់ជ្រៅក្នុងសរសៃឈាមនយោបាយរដ្ឋអាស៊ីទាំងអស់។ ឧទាហរណ៍ចម្បងមួយគឺ មជ្ឈភាពអាស៊ាន [៦] ដែលក្នុងនោះវិធីបែបអាស៊ាន (សង្កត់ធ្ងន់លើការមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុង កិច្ចពិគ្រោះយោបល់ និងការសម្រេចចិត្តដោយការឯកភាពបែបកុងសង់ស៊ុស) ជាគោលការណ៍គ្រឹះសម្រាប់ស្ថាប័នពហុភាគីជាច្រើនក្នុងតំបន់ដូចជា អាស៊ានបូកបី (APT) កិច្ចប្រជុំអាស៊ីអឺរ៉ុប (ASEM) វេទិកាសន្តិសុខអាស៊ាន (ARF) និង កិច្ចប្រជុំកំពូលអាស៊ីបូព៌ា (EAS) ជាដើម។ មជ្ឈភាពអាស៊ីអាចសម្រេចទៅបានលុះត្រាតែមានការប្រកាន់ខ្ជាប់នូវគោលការណ៍គម្រោងតំបន់ដែលមានលក្ខណៈ "ក្រៅផ្លូវការ" ឬ "ទន់" ដែលបង្កប់នូវលក្ខណៈជាក់លាក់មួយចំនួនដូចជា ការប្រកាន់យកអធិបតេយ្យភាពរដ្ឋធំជាងអំណាចស្ថាប័នតំបន់ ការយល់ពីគ្នាទៅវិញទៅមក និងភាពបត់បែន រួមទាំងភាពមានកម្រិតនៃកាតព្វកិច្ចផ្លូវច្បាប់ ដែលទាំងនេះផ្ទុយពីគម្រោងដែលមានលក្ខណៈ "ផ្លូវការ" ឬ "រឹង" របស់លោកខាងលិច [៧]។ ក្នុងន័យនេះ ការតាក់តែងគោលការណ៍ស្ថាប័នតំបន់គួរតែផ្សារភ្ជាប់ទៅនឹង "លក្ខខណ្ឌដែលត្រូវនឹងតំបន់" ឬអ្វីទៅដែលត្រូវនឹងតថភាពរបស់អាស៊ី ជាជាង "ការប្រៀបធៀបតំបន់ និងតំបន់" ដែលព្យាយាមប្រៀបធៀបវិធីបែបអាស៊ីទៅនឹងវិធីបែបលោកខាងលិច។ ប្រតិបត្តិការដ៏ប៉ិនប្រសព្វនៃប្រព័ន្ធពហុភាគីនិយមដែលសក្តិសមសម្រាប់អាស៊ីនេះ ជារឿងដ៏សំខាន់ដើម្បីឲ្យអាស៊ីអាចបត់បែនយ៉ាងប្រុងប្រយ័ត្នក្នុងចន្លោះមហាអំណាច ជាពិសេសសហរដ្ឋអាមេរិក និងចិនដើម្បីទាញយកប្រយោជន៍ជាតិ និងតំបន់ជាអតិបរិមា និងកាត់បន្ថយហានិភ័យក្នុងការក្លាយជារដ្ឋរណបជាអប្បបរមា ហើយស្របពេលជាមួយគ្នា ចាំបាច់ត្រូវសង្កត់ធ្ងន់លើច្បាប់ និងបទដ្ឋាននានាដែលជាគន្លឹះក្នុងការរក្សាសណ្តាប់ធ្នាប់អន្តរជាតិ។

## តួនាទីបុរេសកម្មរបស់សភាក្នុងបរិបទសន្តិភាព សន្តិសុខ និងវិបុលភាពរួម

ក្នុងនាមជាស្ថាប័នឯករាជ្យមួយដែលមានទំនួលខុសត្រូវលើផ្នែកនីតិកម្ម ការត្រួតពិនិត្យការអនុវត្តច្បាប់និងគោលនយោបាយ និងក្នុងភាពជាតំណាង សភាមានតួនាទីដ៏សំខាន់ក្នុងការលើកកម្ពស់សន្តិភាព សន្តិសុខ និងវិបុលភាពរួម។ ក្នុងបរិបទនៃការគំរាមកំហែងសន្តិសុខបែបប្រពៃណីនិងមិនមែនប្រពៃណីបច្ចុប្បន្នដែលប្រកបដោយថាមវន្តនិងភាពស្មុគស្មាញ វាជាពេលដ៏សំខាន់ដែលសភានៅអាស៊ីត្រូវមានភាពបុរេសកម្ម ដែលសំដៅដល់ការគ្រប់គ្រងស្ថានការណ៍ជាជាងប្រតិកម្មទៅនឹងស្ថានការណ៍ តាមរយៈការពង្រឹងតួនាទីដែលមានស្រាប់របស់ខ្លួន និងក្រសោបយកតួនាទីថ្មីៗបន្ថែម។

ទីមួយ សភានៅអាស៊ីមានភារកិច្ចចម្បងៗជាច្រើនដែលអាចរួមចំណែកក្នុងការកសាងគំរូនិម្មាបនកម្មសន្តិសុខនិងសមាហរណកម្មសេដ្ឋកិច្ចតំបន់។ ឧទាហរណ៍ សភាមានតួនាទីផ្ដល់សច្ចាប័ន និងត្រួតពិនិត្យការអនុវត្តកិច្ចព្រមព្រៀងអន្តរជាតិ (ដែលឆ្លុះបញ្ចាំងពីផលប្រយោជន៍ជាតិរៀងៗខ្លួន) ត្រួតពិនិត្យការអនុវត្តគោលនយោបាយការបរទេសនិងអនុម័តកញ្ចប់ថវិកាជាតិជាដើម។សភាក៏ទទួលខុសត្រូវក្នុងការធ្វើសេចក្ដីស្នើច្បាប់ ពិនិត្យ និងអនុម័ត ច្បាប់ (ក្នុងនោះកម្រិតនៃសមត្ថកិច្ចមានភាពខុសៗគ្នាទៅតាមរដ្ឋ) ដើម្បីធានាសន្តិភាព និងស្ថិរភាពជាតិក្នុងប្រទេស ដែលអាចមានផលទាក់ទងខ្លាំងទៅដល់សន្តិសុខតំបន់។ ហេតុនេះ ដើម្បីមានភាពបុរេសកម្ម សភានៅអាស៊ីចាំបាច់ត្រូវពង្រឹងតួនាទីដែលមានស្រាប់ទាំងនេះតាមរយៈការកសាងសមត្ថភាពដើម្បីឈានទៅគ្រប់គ្រង និងកំណត់បរិយាកាសសន្តិសុខតំបន់ក្នុងកម្រិតខ្ពស់បំផុតតាមដែលអាចទៅរួច ជាជាងគ្រាន់តែឆ្លើយតបនឹងការគំរាមកំហែងដែលកើតឡើងរួចហើយ។

ទីពីរ ដើម្បីមានភាពបុរេសកម្ម សភានៅអាស៊ីក៏ត្រូវបន្សាំខ្លួនទៅនឹងតួនាទីថ្មីៗរួមមានការចូលរួមកាន់តែផុសផុលក្នុងការទូតសភា [៨] ដែលជាសកម្មភាពការទូតនានានៃសភាដើម្បីបំពេញបន្ថែមលើការទូតរបស់ស្ថាប័ននីតិប្រតិបត្តិ។ តាមរយៈវិធីនេះ សភាដែលមានភាពបុរេសកម្មអាចជ្រោមជ្រែងបណ្ដាញការទូតបែបប្រពៃណីបានច្រើនដោយការប្រើប្រាស់បណ្ដាញវេទិកាអន្តរសភាដែលកំពុងលូតលាស់ខ្លាំងដូចជា របស់សហភាពអន្តរសភា (IPU) អន្តរសភា អាស៊ាន (AIPA) និង សភាក្នុងតំបន់អាស៊ី (APA) ជាដើម។

## ពិពិធភាពនៃសភានៅអាស៊ី៖ សមត្ថភាព សមាសភាព និងក្របខ័ណ្ឌរដ្ឋធម្មនុញ្ញ

ពុំមានរដ្ឋណាមួយមានសភាពដូចគ្នាទៅនឹងរដ្ឋដទៃទេ ហើយសភានៅអាស៊ីក៏ដូច្នោះដែរ។ ពិពិធភាព ជាពាក្យដែលគេអាចប្រើដើម្បីពិពណ៌នាស្ថានភាពបច្ចុប្បន្នរបស់សភាក្នុងតំបន់នេះដោយផ្អែកលើកត្តាចំនួនបីគឺ សមត្ថភាព សមាសភាព និងក្របខ័ណ្ឌរដ្ឋធម្មនុញ្ញ។ ទីមួយ សភានៅអាស៊ីមានភាពខុសគ្នាបើផ្អែកលើកត្តាសេដ្ឋកិច្ចរបស់រដ្ឋរៀងៗខ្លួន ហើយគម្លាតសេដ្ឋកិច្ចទាំងនេះមានផលទាក់ទងទៅនឹងគម្លាតសមត្ថភាពរវាងសភានីមួយៗ ដោយហេតុថា សមត្ថភាពក្នុងការអនុម័តកញ្ចប់ថវិកាដោយសភាក្នុងគោលនយោបាយណាមួយពឹងផ្អែកដោយផ្ទាល់លើសមត្ថភាពសេដ្ឋកិច្ចរបស់រដ្ឋខ្លួន។ ទីពីរ សមាសភាពនៃគណបក្សនយោបាយក្នុងសភានីមួយៗក៏ខុសគ្នាអាស្រ័យទៅលើប្រព័ន្ធនយោបាយផ្សេងៗគ្នានៃរដ្ឋនីមួយៗ។ រដ្ឋខ្លះមានការបោះឆ្នោតសកលដែលបង្ហាញពីភាពចម្រុះនៃគណបក្សប្រកួតប្រជែងគ្នាច្រើន ឯរដ្ឋខ្លះមានការបោះឆ្នោតសកលដែលគ្របដណ្ដប់ដោយបក្សតែមួយខណៈដែលរដ្ឋខ្លះទៀតពុំមានការបោះឆ្នោតសកលទេដោយមានបក្សតែមួយប៉ុណ្ណោះ។ ចុងក្រោយ សភានៅអាស៊ីក៏អាចបែងចែកទៅតាមក្របខ័ណ្ឌនៃរដ្ឋធម្មនុញ្ញដែលរួមមានប្រព័ន្ធប្រធានាធិបតីនិយម និងប្រព័ន្ធសភានិយម [៩]។ប្រព័ន្ធប្រធានាធិបតីនិយមមានការបោះឆ្នោតពីរផ្សេងគ្នា ក្នុងនោះមួយសម្រាប់ជ្រើសរើសប្រមុខរដ្ឋាភិបាល និងមួយទៀតសម្រាប់សភា ដែលប្រព័ន្ធបែបនេះអាចបំបែកអំណាចរវាងស្ថាប័ននីតិប្រតិបត្តិ និងស្ថាប័ននីតិបញ្ញត្តិ។ ចំណែកប្រព័ន្ធសភានិយមវិញមានការបោះឆ្នោតតែមួយសម្រាប់សភា ហើយសភានោះនឹងធ្វើការបោះឆ្នោតជ្រើសតាំងប្រមុខរដ្ឋាភិបាលដែលមានទំនួលខុសត្រូវផ្ទាល់ចំពោះមុខសភា។

តាមអ្វីដែលគេអាចសន្និដ្ឋានបាន ភាពខុសគ្នាខាងលើដែលទាក់ទងនឹងសមត្ថភាព សមាសភាព និងក្របខ័ណ្ឌរដ្ឋធម្មនុញ្ញ អាចបង្កឲ្យមានភាពខុសគ្នាចំពោះកម្រិតអំណាចឬសមត្ថកិច្ចសភាក្នុងការព្រាងពិនិត្យ និងអនុម័តច្បាប់។ ថាតើសភាអាចមានភាពបុរេសកម្មកម្រិតណា វាពឹងផ្អែកទៅលើកម្រិតនៃភាពខុសគ្នាទាំងនេះ។ សភាទាំងឡាយណាដែលស្ថិតក្នុងរដ្ឋដែលមានសេដ្ឋកិច្ចអភិវឌ្ឍខ្លាំងនឹងទទួលបានលក្ខខណ្ឌអំណោយផលច្រើនក្នុងអំណាចអនុម័តថវិកាជាតិរបស់ខ្លួន ខណៈសភាទាំងឡាយណាដែលស្ថិតក្នុងរដ្ឋប្រកាន់របបប្រធានាធិបតីនិយម និងប្រព័ន្ធបោះឆ្នោតពហុ

បក្សអាចមានតួនាទីកាន់តែសំខាន់ក្នុងនីតិកម្ម។ ភាពខុសគ្នាទាំងនេះ ដែលជាលទ្ធផលនៃកេរដំណែលនយោបាយ និងប្រវត្តិសាស្ត្ររបស់រដ្ឋនីមួយៗ ចាំបាច់ត្រូវលើកយកមកពិចារណានៅក្នុងកិច្ចពិភាក្សាអំពីពិពិធភាពនៃអភិក្រមដែលសភាអាចប្រើប្រាស់ក្នុងការលើកកម្ពស់សន្តិភាព សន្តិសុខ និងវិបុលភាពរួម។



ស្ពានមិត្តភាពឡាវ ថៃទី៣ ខេត្តណាខនប៉ាថុម សហគមន៍សេដ្ឋកិច្ចអាស៊ាន
Peemakon Rattanon

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដែលបកដោយវិទ្យាស្ថានសភាកម្ពុជា (PIC)។ អត្ថបទដើមជាភាសាអង់គ្លេសអាចទាញយកពីគេហទំព័រ៖ https://www.pic.org.kh ។

# ២.៣ បញ្ហាប្រឈមសន្តិសុខនៅអាស៊ី៖ ទស្សនៈបែបអឺរ៉ុប

នៅក្នុងបទវិចារណកថាផ្ទាល់ខ្លួនមួយចេញផ្សាយកាលពីខែឧសភា ឆ្នាំ២០១៨ ដោយ Federica Mogherini ដែលកាលនោះជាតំណាងជាន់ខ្ពស់នៃសហភាពអឺរ៉ុបទទួលបន្ទុកកិច្ចការបរទេស និងគោលនយោបាយសន្តិសុខ បានសរសេរថា "អឺរ៉ុប និងអាស៊ីមិនដែលជិតស្និទ្ធនឹងគ្នាដូចពេលនេះទេ [...] សន្តិសុខរបស់យើង គឺមានអន្តរទំនាក់ទំនងនឹងគ្នាទៅវិញទៅមក៖ ពួកយើងជួបប្រទះនឹងបញ្ហាប្រឈមដូចគ្នា ពួកយើងប្រឈមនឹងការគំរាមកំហែងស្រដៀងគ្នា ហើយពួកយើងក៏មានចំណាប់អារម្មណ៍រួមគ្នាក្នុងការថែរក្សាសន្តិភាពក្នុងតំបន់របស់យើង និងក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិជាសកលផងដែរ"[១០]។ លោកស្រីបានសំដៅលើការរីកចម្រើននៃកិច្ចសហប្រតិបត្តិការផ្នែកសន្តិសុខរវាងសហភាពអឺរ៉ុប និងអាស៊ី ជាពិសេសការកើនឡើងនៃភាពកាន់តែស្រដៀងគ្នា ក៏ដូចជាការរីកចម្រើននូវអន្តរទំនាក់ទំនងនៅក្នុងវិស័យសន្តិសុខ។

ជាយូរអង្វែងមកហើយ បញ្ហាសន្តិសុខដ៏រ៉ាំរ៉ៃនៅតំបន់អាស៊ីបូព៌ា និងជាពិសេសនៅតំបន់អាស៊ីអាគ្នេយ៍ មិនត្រូវបានគេផ្តល់សារៈសំខាន់ខ្លាំងទេនៅក្នុងយុទ្ធសាស្ត្រពិភពលោក។ ទោះបីជាពេលនេះ បញ្ហានេះត្រូវបានឯកភាពគ្នាយ៉ាងសុខដុមក្នុងការយកមកដាក់ជាបញ្ហាស្នូលនៅក្នុងកិច្ចពិភាក្សាស្តីពី សន្តិសុខរបស់អាស៊ី អឺរ៉ុបក៏ដោយ ក៏បញ្ហានេះនៅតែជាបញ្ហាតូចតាចតែប៉ុណ្ណោះសម្រាប់ការពឹងផ្អែកគ្នាទៅវិញទៅមករវាងអឺរ៉ុប និងអាស៊ី។ ជាមួយនឹងការងើបឡើងរបស់ចិន ដែលចិនកាន់តែមានអំណាចជាងមុន បញ្ហាទាក់ទងនឹងផលប្រយោជន៍ក៏មានកាន់តែខ្ពស់។ ការប្រែប្រួលនៃស្ថានការណ៍សង្គម និងសេដ្ឋកិច្ចបច្ចុប្បន្ននៅអាស៊ីអាចនឹងមានផលប៉ះពាល់មិនត្រឹមតែនៅតំបន់អាស៊ីប៉ុណ្ណោះទេ តែក៏ប៉ះពាល់ដល់សណ្តាប់ធ្នាប់ពិភពលោកដែលជាហេតុធ្វើឲ្យមានការជះឥទ្ធិពលដល់ក្របខ័ណ្ឌដែលកំពុងដំណើរការនៅអឺរ៉ុប នៅអាស៊ី និងនៅទីកន្លែងផ្សេងទៀត។ ដូច្នេះ ដូចដែលត្រូវបានបង្ហាញនៅក្នុងបញ្ហាដ៏ពិបាកនិងស្មុគស្មាញនៃជម្លោះដែនសមុទ្រចិនខាងត្បូង "បញ្ហាសន្តិសុខនៅអាស៊ីលែងជាបញ្ហារបស់អាស៊ីតែម្នាក់ឯងទៀតហើយ"។ ការគ្រប់គ្រងបញ្ហានៅតែស្ថិតក្រោមទំនួលខុសត្រូវរបស់អាស៊ី ប៉ុន្តែអឺរ៉ុបត្រូវតែចាំមើល ហើយនៅពេលណាដែលអាចធ្វើទៅបាន នោះសហភាពអឺរ៉ុបនឹងចូលរួមចំណែកដើម្បីកាត់បន្ថយបញ្ហាសន្តិសុខទាំងនេះនៅអាស៊ី។

## ស្វ័យភាពរបស់អាស៊ីក្រោមជម្រកយុទ្ធសាស្ត្ររបស់អាមេរិក

បញ្ហាសន្តិសុខចម្បងៗនៅអាស៊ី ស្ទើរតែមិនបានផ្លាស់ប្តូរចាប់តាំងពីចប់សង្គ្រាមត្រជាក់មក។ ភាពងាយរងគ្រោះនៃសេដ្ឋកិច្ច ភាពផុយស្រួយផ្នែកនយោបាយ និងភាពមិននឹងនរនៃអភិបាលកិច្ច រួមជាមួយនឹងបញ្ហាជនជាតិភាគតិចជាដើម តែងតែប៉ះពាល់ដល់ផ្នែកធំៗនៃអាស៊ី ហើយនិងស្ថិរភាពក្នុងតំបន់ ជាក់ស្តែងដូចឃើញច្បាស់ពីបញ្ហាភេរវកម្ម ការបំបែកខ្លួននិងការបះបោរប្រដាប់អាវុធ ចោរសមុទ្រនិងការបំផ្លាញធនធានធម្មជាតិ និងសូម្បីតែការជួញដូរគ្រឿងញៀន។ ស្រដៀងគ្នានេះ បញ្ហាជម្លោះព្រំដែនក៏មិនមែនជាបញ្ហាថ្មីសម្រាប់តំបន់ដែរ [១១]។ ទាំងអស់នេះនៅតែចាត់ទុកជាជាបញ្ហាតូចតាច ដរាបណាបញ្ហាទាំងនេះត្រូវបានទុកដោះស្រាយតែត្រឹមកម្រិតក្នុងប្រទេសនៅអាស៊ីអាគ្នេយ៍។ បញ្ហាទាំងនេះមិនបានធ្វើឲ្យរាំងស្ទះទេ តែពេលខ្លះបានជួយជម្រុញដល់ដំណើរការធ្វើសមាហរណកម្មតំបន់។ បញ្ញវន្តអាម៉េរិក Marvin C. Ott បានសង្កេតឃើញថា "រដ្ឋនៅអាស៊ីអាគ្នេយ៍បាននឹងកំពុងអភិវឌ្ឍស្ថាប័នតំបន់ និងគំរូអន្តរកម្មដែលបានធ្វើឲ្យតំបន់នេះកាន់តែមានភាពស៊ីសង្វាក់គ្នា ហាក់ដូចជាស្ថាប័ននយោបាយ សេដ្ឋកិច្ច និងសន្តិសុខតែមួយ ដែលលើសឆ្ងាយពីកម្រិតដែលមាននៅកន្លែងដទៃ ក្នុងពិភពអាហ្វ្រិក-អាស៊ី" [១២]។ នៅអាស៊ីអាគ្នេយ៍ដែលជាតំបន់មិនធ្លាប់ជួបប្រទះនឹងការគំរាមកំហែងពីបញ្ហាសន្តិសុខធំៗទាំងពីខាងក្នុងឬពីខាងក្រៅតំបន់តាំងពីពេលចប់សង្គ្រាមត្រជាក់ រាល់ជម្លោះដែលកើតឡើងត្រូវបានដោះស្រាយតាមរយៈយន្តការគ្រប់គ្រងដោយសន្តិវិធី។ វេទិកាតំបន់អាស៊ាន (ARF) បានបង្កើតឡើងនៅឆ្នាំ១៩៩៤ ហើយអស់រយៈកាលដ៏យូរមកហើយ ដែលស្ថាប័នសន្តិសុខរបស់អាស៊ានមួយនេះមានគោលដៅចម្បងគឺ "ការជំរុញកិច្ចសន្ទនានិងកិច្ចពិគ្រោះយោបល់ប្រកបដោយការស្ថាបនាលើបញ្ហានយោបាយ និងសន្តិសុខ ដែលជាប្រយោជន៍និងជាកង្វល់" និងដើរតួក្នុងការរួមចំណែកកសាងទំនុកចិត្ត និងការទូតបែបការពារក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក [១៣]។ សហរដ្ឋអាម៉េរិកបានធានាឲ្យមានសណ្តាប់ធ្នាប់តំបន់ដែលនឹងផ្តល់ឲ្យអាស៊ីនូវបរិយាកាសនយោបាយ និងស្វ័យភាពក្នុងការធ្វើសកម្មភាពដោះស្រាយបញ្ហាសន្តិសុខមិនមែនយុទ្ធសាស្ត្រដោយខ្លួនឯង។

## ចាប់ពីតំបន់ដល់សកលលោក៖ ការងើបឡើងរបស់ចិន និងអន្តរជាតូនីកម្មបញ្ហាសន្តិសុខរបស់អាស៊ី

ការកើនឡើងនៃអំណាចរបស់ចិនមិនបាននាំឲ្យមានការកែសម្រួលស្ថាប័នតំបន់ទេ ប៉ុន្តែបាននាំឲ្យមានការផ្លាស់ប្តូរទាំងស្រុង (ទោះបីជាបន្តិចម្តងៗ) នូវបរិបទនៃដំណើរការប្រតិបត្តិ។ ទសវត្សរ៍ដំបូងនៃសតវត្សរ៍ទី២១ គេឃើញមានការធ្វើអន្តរជាតូនីយកម្មបន្តិចម្តងៗនូវបញ្ហាសន្តិសុខដែលជាការបារម្ភរបស់តំបន់។ ភាពកាន់តែមានទំនុកចិត្ត និងក្លាហានរបស់ចិន បាននាំឲ្យចិនឈានទៅទាមទារអធិបតេយ្យភាពរបស់ខ្លួននៅលើដែនសមុទ្រចិនខាងត្បូងស្ទើរតែទាំងមូល ដែលធ្វើឲ្យដើមបណ្តឹងដែលជាគូប្រកួតប្រជែង (ប្រ៊ុយណេ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន កោះតៃវ៉ាន់និងវៀតណាម) មានការខឹងសម្បារ។ ការកើតមានជម្លោះដែនទឹកទ្វេភាគីនៅក្នុងអាស៊ានមិនបានបញ្ចប់នោះទេប៉ុន្តែត្រូវបានគេបញ្ចូលទៅជាបញ្ហាធំមួយដែលប្រឆាំងនឹងចិន និងបណ្តារដ្ឋជាសមាជិកអាស៊ានមួយចំនួន។

ម៉្យាងទៀត ការដាក់មូលដ្ឋានទ័ពនៅកោះ Paracel និងSpratly ដែលចិនបានបោះទីតាំងចំនួន២០ និង ៧ រៀងគ្នានៅទីនោះ [១៤] បានធ្វើឲ្យកាន់តែរីកសាយភាយនូវសក្តានុពលនៃជម្លោះនេះ និងបានធ្វើឲ្យមានការជំរុញបញ្ហានេះទៅក្នុងការដោះស្រាយកំរិតអន្តរជាតិក្នុងពេលតែមួយ។ ចិនមិនត្រឹមតែជំទាស់នឹងការបកស្រាយនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ (UNCLOS) លើបញ្ហានានាដូចជាការគ្រប់គ្រងកម្លាំងយោធានៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ (EEZ) ឧទាហរណ៍នៅពេលដែលគេផ្តល់និយមន័យចង្អៀតនៃ "សេរីភាពក្នុងការធ្វើនាវាចរណ៍" ប៉ុណ្ណោះទេ ប៉ុន្តែចិនក៏ប្រឆាំងផងដែរទៅនឹង គោលការណ៍គ្រឹះនៃច្បាប់អន្តរជាតិ ឧទាហរណ៍ដូចជាការលើកឡើងនូវ "សិទ្ធិជាប្រវត្តិសាស្ត្រ"។ នៅក្នុងដំណើរការនេះ ចិនបានបង្កើតនូវភាពមិនប្រាកដប្រជា ចំពោះអ្វីដែលធ្លាប់តែអាចដឹងមុនបានតាមរយៈនីតិរដ្ឋ។ ភាពមិនប្រាកដប្រជានេះបានកើតមានឡើងនៅគ្រប់ទីកន្លែង រួមទាំងនៅអឺរ៉ុបផងដែរ។

> "អន្តរជាតូនីយកម្មនៃបញ្ហាសន្តិសុខដែលជាការព្រួយបារម្ភរបស់តំបន់បានកើតមានឡើងសន្សឹមៗនៅក្នុងទសវត្សរ៍ដំបូងនៃសតវត្សរ៍ទី២១ ។"

បញ្ហាសន្តិសុខនៅអាស៊ីលែងត្រូវបានកម្រិតនៅត្រឹមតែបញ្ហានៅក្នុងអាស៊ីទៀតហើយ។

## បញ្ហាប្រឈមចំពោះពហុភាគីនិយម និងការបែកចែកប៉ូលម្ខាងម្ខាក់រវាងចិន និងអាម៉េរិក (SINO-US POLARIZATION)៖ អាស៊ីបាត់បង់ភាពម្ចាស់ការអនាគតយុទ្ធសាស្ត្ររបស់ខ្លួន

កត្តាបន្ថែមលើសពីនេះទៀតគឺ ជាពិសេសទាក់ទងនឹងភាពផ្ទុយគ្នារវាងចិន និង អាម៉េរិក (SINO-US) និងបញ្ហាប្រឈមរួមនៃពហុភាគីនិយមដែលឥឡូវកំពុងរួមចំណែកក្នុងការធ្វើអន្តរជាតូបនីយកម្មនៃបញ្ហាសន្តិសុខរបស់អាស៊ី និងធ្វើឲ្យអាស៊ីបាត់បង់នូវសិទ្ធិគ្រប់គ្រងយុទ្ធសាស្ត្រអនាគតរបស់ខ្លួន។ ការប្រជែងគ្នារវាងស៊ីណូ-អាម៉េរិកកំពុងកើនឡើង ហើយភាពផ្ទុយពីគ្នាក្នុងតំបន់បន្តិចម្តងៗកំពុងតែបង្វែរគ្រប់បញ្ហាទាំងអស់ទៅជាល្បែងដែលមានតែឈ្នះ និងចាញ់ (zero-sum game) ដែលគ្រប់តួអង្គនីមួយៗត្រូវបានបង្ខំចិត្តធ្វើការសម្រេចចិត្តជ្រើសរើសគាំទ្រភាគីមួយណា ដែលស្ថានភាពនេះធ្វើភាពស្អិតរមួតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ចុះខ្សោយ និងបង្កើតឲ្យមានភាពតានតឹងប្រឈមទៅនឹងអាទិភាពរៀងៗខ្លួនរបស់ប្រទេសនីមួយៗ។

ភាពផ្ទុយគ្នាក្នុងតំបន់នៅចន្លោះរវាងផលប្រយោជន៍ចិន និងសហរដ្ឋអាម៉េរិក គឺបានធ្វើឲ្យកាន់តែមានបញ្ហាប្រឈមចំពោះពហុភាគីនិយម៖ តាមរបៀបផ្សេងៗគ្នា មហាអំណាចយក្សទាំងពីរនៃតួអង្គក្នុងទំនាក់ទំនងអន្តរជាតិកំពុងធ្វើឲ្យស្ថាប័នពហុភាគីនិយមចុះខ្សោយយ៉ាងឆាប់រហ័ស។ សហរដ្ឋអាម៉េរិកបានព្រងើយកន្តើយទៅនឹងអាស៊ាន និងស្ថាប័នអាស៊ាន[១៥] ហើយព្យាយាមប្រើទំនាក់ទំនងទ្វេភាគី ដែលអាម៉េរិកអាចទទួលបានផលប្រយោជន៍ដោយសារអតុល្យភាពនៃអំណាច។ ដោយឃើញដូច្នេះ ចិនកាន់តែមានភាពសកម្មចំពោះទំនាក់ទំនងជាមួយអាស៊ាន។ ក្រុងប៉េកាំងបានវិនិយោគក្នុងទំនាក់ទំនងជាមួយស្ថាប័នអាស៊ាន និងកំពុងទាញយកផលចំណេញសេដ្ឋកិច្ចពីការវិនិយោគរបស់ខ្លួននៅក្នុងរដ្ឋសមាជិកអាស៊ានមួយចំនួន ធ្វើឲ្យសមាគមនេះលែងមានភាពសំខាន់ ដើម្បីបែងចែកតំបន់នេះតាមន័យនយោបាយ និងដើម្បីកម្រិតសមត្ថភាពអាស៊ានក្នុងការប្រឆាំងនឹងគោលនយោបាយចិន និងខិតខំប្រឹងប្រែងធ្វើឲ្យតំបន់នេះក្លាយជាតំបន់ថាមវន្តគំរូទៅតាមបំណងប្រាថ្នារបស់ខ្លួន។

លើសពីនេះទៀត ចំណុចទំនាញកណ្ដាលរបស់អាស៊ីអាគ្នេយ៍កំពុងតែរំកិលបន្តិចម្ដងៗចេញក្រៅតំបន់។ ជាលទ្ធផល ការណ៍នេះនាំឲ្យមានការប៉ះពាល់ជាអវិជ្ជមានធ្ងន់ធ្ងរដល់មជ្ឈភាពអាស៊ានដែលត្រូវបានគេយល់ឃើញថាជាយន្តការសម្រេចចិត្តមួយដែលពឹងផ្អែកលើការឯកភាពតាមបែបកុងសង់ស៊ីសរបស់អាស៊ាន ដែលយន្តការនេះបាននាំឲ្យមានការបញ្ឈប់យ៉ាងមានប្រសិទ្ធិភាពនូវគំនិតប៉ុនប៉ងធ្វើអនុត្តរភាពទាំងអស់ក្នុងតំបន់។ អាទិភាពផ្នែកសន្តិសុខរបស់អាស៊ី និងនម្មាបនកម្មសន្តិសុខត្រូវបានធ្វើស្ថាបនីយកម្មបន្ថែមក្នុងអំឡុងពេលតែមួយជាមួយនឹងការបង្កើតកិច្ចប្រជុំកំពូលអាស៊ីបូព៌ា (EAS) [១៦] ក្នុងឆ្នាំ២០០៥ និងបន្ទាប់មកការបង្កើតកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការពារជាតិបូក (ADMM Plus)[១៧] នៅឆ្នាំ២០១០។ ប៉ុន្តែស្ថាប័នថ្មីទាំងនេះកំពុងក្លាយជាចំណាប់ខ្មាំងរបស់ការប្រកួតប្រជែងឥទ្ធិពលពិភពលោករវាងសហរដ្ឋអាម៉េរិក និងចិន។

ការជជែកដេញដោលជុំវិញទស្សនាទានអំពី ឥណ្ឌូ-ប៉ាស៊ីហ្វិក បានបង្ហាញពីភាពលំបាកដែលប្រទេសនៅអាស៊ីបូព៌ាកំពុងប្រឈមនាពេលបច្ចុប្បន្ន និងភាពមានកម្រិតនៃមធ្យោបាយដែលអាចអោយពួកគេគេចចេញពីភាពលំបាកនេះបាន។ ដោយត្រូវរងសម្ពាធក្នុងការជ្រើសរើសរវាងចិន និងសហរដ្ឋអាម៉េរិក ប្រទេសនៅអាស៊ីបូព៌ាបានគាំទ្រទស្សនាទានអំពីឥណ្ឌូ-ប៉ាស៊ីហ្វិក ដើម្បីរក្សានូវទំនាក់ទំនងជាមួយអាម៉េរិក ប៉ុន្តែត្រូវបកស្រាយទៅតាមវិធីបរិយាបន្នផ្ទាល់របស់ពួកគេ ដើម្បីជៀសវាងការប្រឆាំងនឹងចិន និងការពារខ្លួនទប់ទល់នឹងផលប៉ះពាល់ជាអវិជ្ជមាននានាពីការប្រកួតប្រជែងរវាងស៊ីណូ-អាម៉េរិក។ ទោះជាយ៉ាងណា យុទ្ធសាស្ត្រឥណ្ឌូ-ប៉ាស៊ីហ្វិកទាំងអស់ស្ថិតនៅដំណាក់កាលដំបូងនៅឡើយ ហើយផលប៉ះពាល់មកលើថាមវន្តតំបន់ក៏មិនទាន់ច្បាស់លាស់ដែរ។

## តើបញ្ហាសន្តិសុខបរិស្ថាន គឺជាកត្តានាំឲ្យមានការផ្លាស់ប្ដូរចម្បង និងធំធំទូលំទូលាយទាំងស្រុងឬ?

នៅក្នុងបរិបទនេះ លក្ខណៈថ្មី និងសំខាន់របស់សន្តិសុខមានដូចជាសន្តិសុខបរិស្ថានអាចផ្ដល់ឲ្យអាស៊ីវិញនូវភាពប្រកបដោយបរិយាបន្នដែលខ្លួនកំពុងតែបាត់បង់។ បម្រែបម្រួលអាកាសធាតុជាឧទាហរណ៍នៃមេគុណនៃការគំរាមកំហែងមន្ថែម។ បញ្ហានេះបាននាំឲ្យមានការរៀបចំផែនទីឡើងវិញ ធ្វើឲ្យមានបម្លាស់ទីលំនៅប្រជាពលរដ្ឋ បង្កើតប្រភពថ្មីនៃភាពតានតឹង និងធ្វើឲ្យផលប៉ះពាល់យ៉ាងខ្លាំងដល់ហេដ្ឋារចនាសម្ព័ន្ធ។ ការគំរាមកំហែងដល់ ជីវចម្រុះបរិស្ថានសមុទ្រ ឬការបង្កដោយផ្ទាល់ និងដោយប្រយោលសុទ្ធតែផ្ដល់នូវផលវិបាកស្រដៀងគ្នា។ ពិតណាស់ ការគំរាមកំហែងដល់សន្តិសុខបរិស្ថានប៉ះពាល់ដល់គ្រប់ផ្នែកទាំងអស់នៃសន្តិសុខ។ ជាឧទាហរណ៍អ្នកជំនាញទទួលស្គាល់ថា ទ្វីបអាស៊ីនឹងស្ថិតក្នុងចំណោមតំបន់ដែលរងផលប៉ះពាល់ខ្លាំងបំផុតពីបម្រែបម្រួលអាកាសធាតុ។ ទីក្រុងនៅតាមបណ្ដាយឆ្នេរសមុទ្រទាបៗនៅប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ជាច្រើន និងប្រជាជនរាប់លាននាក់ដែលរស់នៅទីនោះ គឺងាយរងគ្រោះជាពិសេស។

ទោះបីជាយ៉ាងណាក៏ដោយ ក៏បញ្ហាសន្តិសុខបរិស្ថានតែងតែជាបញ្ហាឆ្លងដែន ហើយដំណោះស្រាយ គឺជាកិច្ចខិតខំប្រឹងប្រែងរួម។ ការការពារបរិស្ថានសមុទ្រ(MEP) គឺជាឧទាហរណ៍មួយ។ មានការប៉ាន់ស្មានថា ស្ថានភាពនៃអត្រាសឹករិចរិលនៃថ្មប៉ប្រះទឹកក្នុងសមុទ្រចិនខាងត្បូងដែលជាប្រព័ន្ធអេកូឡូស៊ីដែលមានលក្ខណៈចម្រុះជាងគេនៅលើពិភពលោក និងផ្ដល់ជម្រកដល់ទៅ៧៦% នៃប្រភេទសត្វសមុទ្រលើពិភពលោក និង៣៧% នៃប្រភេទត្រីប៉ប្រះទឹកនឹងនាំឲ្យរដ្ឋដែលនៅជាប់សមុទ្រអាចនឹងខាតបង់សក្ដានុពលសេដ្ឋកិច្ចប្រហែល ៥,៧ពាន់លានដុល្លារអាម៉េរិកក្នុងមួយឆ្នាំ[១៨]។ ផែនការគោលឆ្នាំ២០២៥ នៃសហគមន៍សង្គម-វប្បធម៌អាស៊ាន បានលើកទឹកចិត្តរដ្ឋសមាជិក "លើកកម្ពស់កិច្ចសហប្រតិបត្តិការដើម្បីការពារ ស្ដារឡើងវិញ និងប្រើប្រាស់តំបន់ឆ្នេរសមុទ្រ និងបរិស្ថានសមុទ្រប្រកបដោយចីរភាព..." [១៩] ប៉ុន្តែនៅតែគ្មានការយកគោលការណ៍នេះទៅបញ្ចូលក្នុងស្ថាប័ន ដែលនិយាយពីរបៀបទាក់ទងរបស់អាស៊ានជាមួយដៃគូពាក់ព័ន្ធសំខាន់ៗ ដូចជាចិន ដើម្បីអនុវត្តផែនការនេះទេ។ ទោះបីការការពារបរិស្ថានសមុទ្រគឺជាទិដ្ឋភាពសំខាន់សម្រាប់ការបន្សាំទៅនឹងបម្រែបម្រួលអាកាសធាតុក៏ដោយក៏នៅមិនទាន់មានអនុសញ្ញា ឬស្ថាប័នកំរិតតំបន់ត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រងបរិស្ថានសមុទ្ររួមគ្នានៅឡើយទេ ទោះបីមានយន្តការកិច្ចសហប្រតិបត្តិការពហុភាគីក្នុងតំបន់ជាច្រើនហើយក៏ដោយ។ ទោះជាយ៉ាងណាក៏ដោយ ការការពារសន្តិសុខបរិស្ថានបានផ្ដល់ឲ្យមាននូវឱកាសក្នុងការអនុវត្តអភិក្រមនៃកិច្ចសហប្រតិបត្តិការដែលមិនមានលក្ខណៈនយោបាយដើម្បីដោះស្រាយបញ្ហាសមុទ្រចិនខាងត្បូង ដោយពឹងផ្អែកលើមូលដ្ឋានបច្ចេកទេស និងនៅតែជាអ្វីដែលមានតម្លៃសម្រាប់ការធ្វើបន្តទៅមុខទៀត។

## តួនាទីរបស់សភា

សភាមានទំនួលខុសត្រូវរបស់ខ្លួនក្នុងការគិតគូរពីនម្មាបនកម្មសន្តិសុខនៅអាស៊ី។ តួនាទីដំបូងបង្អស់របស់សភាគឺត្រូវធានាថា កិច្ចព្រមព្រៀងដែលបានចុះហត្ថលេខាដោយរដ្ឋាភិបាលនឹងអនុលោមទៅតាមផលប្រយោជន៍ជាតិ និងកាតព្វកិច្ចអន្តរជាតិ។ សភាក៏មានតួនាទីគ្រប់គ្រង និងត្រួតពិនិត្យលើការអនុវត្តគោលនយោបាយការបរទេស និងគោលនយោបាយសន្តិសុខដែលអនុវត្តដោយរដ្ឋាភិបាលតាមរយៈគណៈកម្មការកិច្ចការការបរទេស និងការពារជាតិរបស់សភាដែរ។សម្រាប់គោលដៅនេះ សភាមានឧបករណ៍ក្នុងដៃដ៏មានអំណាចមួយគឺការអនុម័តកញ្ចប់ថវិកាសម្រាប់ក្រសួងពាក់ព័ន្ធ។

សភាក៏មានតួនាទីក្នុងការអប់រំដល់គណបក្សនយោបាយធំអំពី កិច្ចការការបរទេស និងបញ្ហាសន្តិសុខ។ ការជជែកដេញដោលអំពី នយោបាយជាសាធារណៈបានជួយឲ្យគេអាចយល់កាន់តែច្បាស់ពីចំណុចគន្លឹះនៅក្នុងគោលនយោបាយការបរទេសជាតិ និងបានចូលរួមផ្តល់ព័ត៌មានបន្ថែមដល់សង្គមអំពី បញ្ហាដែលប៉ះពាល់ដល់សន្តិសុខជាតិ និងតំបន់ក៏ដូចស្ថានភាពពាក់ព័ន្ធនឹងការឆ្លើយតបរបស់រដ្ឋាភិបាលទៅលើបញ្ហាទាក់ទងនឹងគោលនយោបាយការបរទេស និងសន្តិសុខ។ ធ្វើដូចនេះ សភាក៏នឹងមានសមត្ថភាពក្នុងការសម្របសម្រួលការអនុវត្តកិច្ចព្រមព្រៀងអន្តរជាតិនៅថ្នាក់ជាតិផងដែរ។ អាស្រ័យហេតុនេះ ក្នុងករណីអាស៊ី និងអាស៊ានជាពិសេស សភាក៏អាចមានសមត្ថភាពសម្របសម្រួលការធ្វើសមាហរណកម្មតំបន់តាមរយៈការអនុវត្តសេចក្តីថ្លែងការណ៍ និងកិច្ចព្រមព្រៀងនានាផងដែរ។តំណាងសភាមានភាពជាកាន់តែចម្រុះ នោះសភាកាន់តែខិតជិតប្រជាពលរដ្ឋ និងមានលទ្ធភាពអភិវឌ្ឍអភិក្រមនានាដែលពាក់ព័ន្ធគោលនយោបាយការបរទេសបានកាន់តែមានប្រសិទ្ធភាព។

ជាចុងក្រោយ សភាក៏អាចធ្វើការទូតដោយខ្លួនឯងផ្ទាល់ផងដែរ។ ការទូតសភាគឺ “ជាឧបករណ៍បំពេញបន្ថែមដែលផ្តល់សក្តានុពលសម្រាប់សម្រេចលទ្ធផលដែលមើលទៅទំនងពិបាកសម្រេចបានតាមរយៈការទូតបែបប្រពៃណី ឬតាមបណ្តាញការទូតធម្មតា” [២០] ដូចដែលបានគូសបញ្ជាក់នៅមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤០ (AIPA)។ ការទូតសភាអាចបង្កើតដៃគូរឹងមាំដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងតំបន់ ជាពិសេសការពារការបែកបាក់នៃនម្មាបនកម្មសន្តិសុខអាស៊ាន។និយាយឲ្យចំការទូតសភា គឺជាការទូតនៃឥទ្ធិពល។ តាមរយៈបណ្តាញជាច្រើនផ្សេងៗ សមាជិក សមាជិកាសភាអាចប្រាស្រ័យទាក់ទងគ្នាពីសារ និងលើកកម្ពស់ផលប្រយោជន៍ជាតិនៃរដ្ឋនីមួយៗរៀងៗខ្លួន។ អាស្រ័យហេតុផលនេះ ការទូតសភាគួរតែជាឧបករណ៍ដែលគួរជ្រើសរើសមកប្រើដើម្បីដោះស្រាយជាមួយបញ្ហាសន្តិសុខបរិស្ថាន។

ដូច្នេះសភាអាចដើរតួយ៉ាងសំខាន់ក្នុងការថែរក្សាការឯកភាព និងភាពចូលរួម ក៏ដូចជាពហុភាគីនិយម ដែលអាស៊ីនៅមិនទាន់យកមកអនុវត្តបានស៊ីជម្រៅនៅឡើយ។ ដូច្នេះសភា គឺជាដៃគូសម្របសម្រួលដែលអឺរ៉ុបមិនអាចព្រងើយកន្តើយបានតែត្រូវបន្តពូនជ្រុំបន្ថែម។ ទោះបីជាភាពជាតំណាងសភាដ៏ស្មោះត្រង់របស់ប្រជាពលរដ្ឋខុសគ្នាពីប្រទេសមួយទៅប្រទេសមួយកម្រិតណាក៏ដោយ ក៏សភានៅតែជាឧបករណ៍ដ៏មានអំណាចមួយសម្រាប់រដ្ឋាភិបាលដើម្បីទប់ទល់នឹងសម្ពាធនៅចំកណ្តាលនៃមហាអំណាចដូចដែលអាស៊ីកំពុងជួបប្រទះដែរ។ ដូច្នេះហើយសភាអាចចូលរួមយ៉ាងសំខាន់ដើម្បីសន្តិសុខតំបន់ និងពិភពលោក។

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដែលបកដោយវិទ្យាស្ថានជាតិការទូតនិងទំនាក់ទំនងអន្តរជាតិនៃកម្ពុជា (NIDIR)។ អ្នកអានអាចទាញយកអត្ថបទដើមជាភាសាអង់គ្លេសពីគេហទំព័រ៖ https://www.pic.org.kh ។

# ២.៤ ការត្រួតពិនិត្យរបស់សភាទៅលើការប្រើប្រាស់កម្លាំង និងកងកម្លាំងប្រដាប់អាវុធ

> “ គោលបំណងនៃសង្គ្រាម (ដែលជាសកម្មភាពនៃការប្រយុទ្ធប្រឆាំងគ្នាដោយប្រើសព្វាវុធ) គឺតែងតែមានពាក់ព័ន្ធនឹងរឿងនយោបាយ។ ដោយសារតែអត្ថន័យនៃពាក្យសង្គ្រាមមិនអាចត្រូវកំណត់បានជាក់លាក់ អត្ថន័យរបស់វាត្រូវបានទាញយកចេញពីតក្កវិជ្ជានៃគោលនយោបាយ ឬកំលាំងចលករពីខាងក្រៅ [២១]។ ”

## សេចក្តីផ្តើម

គ្រប់សង្គ្រាមទាំងអស់គឺមានពាក់ព័ន្ធនឹងរឿងនយោបាយ។ សង្គ្រាមរវាងរដ្ឋនិងរដ្ឋ និងសង្គ្រាមផ្ទៃក្នុងតែងតែធ្វើឡើងដោយហេតុផល គោលដៅ និងគោលបំណងនយោបាយ។ គោលការណ៍ចម្បងមួយនេះនៃសង្គ្រាម ត្រូវបានកត់ត្រាទុកតាំងពីប្រវត្តិសាស្ត្រដំបូង និងនៅបន្តមានសុពលភាពហូតដល់សព្វថ្ងៃនេះ [២២]។ ដោយសារសង្គ្រាមមានពាក់ព័ន្ធនឹងរឿងនយោបាយ ដូច្នេះវាអាចប៉ះពាល់ដល់ប្រជាពលរដ្ឋ និងប្រជាជាតិទាំងមូល។ ប្រហែលជាធ្លាប់មានពេលវេលាពិសេសណាមួយដែលស្តេច និងអ្នកកាន់អំណាចអាចធ្វើសង្គ្រាម ដោយគ្មានការគាំទ្រពីប្រជាពលរដ្ឋរបស់ខ្លួន ហើយក៏ប្រហែលជាធ្លាប់មានពេលណាមួយដែលសង្គ្រាមមិនបានបំផ្លាញដល់ប្រទេសជាតិទាំងមូលឡើយ។ សង្គ្រាមក្នុងសម័យឧស្សាហកម្មទំនើប និងផលប៉ះពាល់នៃសាកលភាវូបនីយកម្ម បានផ្លាស់ប្តូរផលប៉ះពាល់ទាំងនោះ ហើយប្រជាជាតិទាំងមូលកំពុងរងគ្រោះច្រើនជាងពីមុនដោយសារសង្គ្រាម និងជម្លោះអន្តរជាតិ។ ដូច្នេះការដេះឥទ្ធិពលតាមបែបប្រជាធិបតេយ្យទៅលើការសម្រេចចិត្តប្រកបដោយយុទ្ធសាស្ត្រ និងការគ្រប់គ្រងលើកងកម្លាំងប្រដាប់អាវុធជាតិជារឿងមួយដ៏ចាំបាច់។

## ករណីនៃការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ

តាមការគិតបែបរំពឹងខ្ពស់បំផុត តួនាទីរបស់សភាគួរតែពង្រីក «ទៅគ្រប់វិស័យទាំងអស់នៃសកម្មភាពរបស់រដ្ឋាភិបាល ជាពិសេសពាក់ព័ន្ធនឹងការវិភាជថវិកា» រួមទាំងការផ្តល់អំណាចសំខាន់ៗក្នុងនាមជាសភា ដែលកើតឡើងពីការបោះឆ្នោត ដែលត្រូវមានអំណាចក្នុងការបោះឆ្នោតនិងអនុម័តច្បាប់ដែលស្នើដោយរដ្ឋាភិបាល។ នៅក្នុងន័យនេះ រដ្ឋាភិបាលមួយ «ដំណើរការក្រោមការត្រួតពិនិត្យពីសភា» [២៣]។ ស្ថាប័នជាប់ឆ្នោតជាតំណាងរបស់ប្រជាពលរដ្ឋ ដូច្នេះហើយត្រូវដើរតួជំនួសប្រជាពលរដ្ឋ និងត្រូវបំពេញតួនាទីឲ្យមានតុល្យភាពអំណាចជាមួយដៃគូនីតិប្រតិបត្តិ។ អាស្រ័យហេតុនេះ ស្ថាប័ននីតិប្រតិបត្តិត្រូវរក្សាគណនេយ្យភាពចំពោះមុខសភានិងត្រូវបានត្រួតពិនិត្យដោយសភា។

ការធ្វើឲ្យមានតុល្យភាពនេះ គឺជាចំណុចស្នូលមួយនៃលទ្ធិប្រជាធិបតេយ្យ និងអាចចាត់ទុកជារឿងសំខាន់នៅពេលដែលត្រូវការប្រើប្រាស់កម្លាំងយោធា។ ប្រសិនបើគ្មានការត្រួតពិនិត្យបែបប្រជាធិបតេយ្យនេះទេ ស្ថាប័ននីតិប្រតិបត្តិអាចនឹងមានអំណាចលើគ្រប់រឿង និងអាចងាយធ្វេសប្រហែសមិនបានពិនិត្យទស្សនៈនិងយោបល់របស់ប្រជាពលរដ្ឋ រួមទាំងរបស់គណបក្សប្រឆាំងផងដែរ។ ដូច្នេះ បើគ្មានការត្រួតពិនិត្យពីសភា នោះប្រជាធិបតេយ្យសេរីពហុនិយមនឹងប្រឈមការគំរាមកំហែងនានាដែលកំពុងកើតមានឡើង។

ទោះបីជាបញ្ហាពាក់ព័ន្ធនឹងសន្តិសុខជាតិ «អាចមានលក្ខណៈពិសេស» [២៤] ក៏ដោយ ក៏បញ្ហានេះនៅតែបង្ហាញច្បាស់ថា សភាគួរតែមានឥទ្ធិពលទៅលើទំនាក់ទំនងការបរទេសរបស់រដ្ឋ និងលើបញ្ហាទាក់ទងនឹងសន្តិសុខ និងការការពារជាតិ។

កាលពីអតីតកាល ស្តេច និងមេដឹកនាំផ្តាច់ការ គឺជាមេបញ្ជាការកំពូលរបស់កងកម្លាំងយោធា [២៥]។ ហេតុនេះកងកម្លាំងទាំងនោះមានភាពស្មោះស្ម័គ្រចំពោះស្តេច មិនមែនចំពោះប្រជាពលរដ្ឋទេ។ ហេតុដូចនេះ កងកម្លាំងយោធាក៏ជាអ្នកដែលផ្តល់គ្រោះថ្នាក់ដល់ប្រជាពលរដ្ឋក្នុង

ស្រុកដែរ។ នេះជាហេតុផលដែល Machiavelli ដែលជាអ្នកវិភាគកិច្ចការនយោបាយនៃសម័យចន្លោះមជ្ឈឹមសម័យ និងសម័យទំនើប (Renaissance) បានលើកឡើងថា ជាតិមួយគប្បីលុបបំបាត់កងទ័ពឯកជន និងកងទ័ពស៊ីឈ្នួល ហើយជំនួសមកវិញដោយការបង្កើតកងទ័ពរបស់ប្រជាពលរដ្ឋ [២៦]។ នៅសម័យទំនើបដែលមានការរីករាលដាលនៃរបបប្រជាធិបតេយ្យ និងការកើនឡើងនៃជំនឿចូលរួមក្នុងកិច្ចការនយោបាយ គេមិនគួរពឹងផ្អែកលើព្រះរាជានុវង្ស ក្រុមផ្តាច់ការ និងឥស្សរជន ជាអ្នកសម្រេចថាតើគួរប្រើប្រាស់កងកម្លាំងយោធា និងកងកម្លាំងប្រដាប់អាវុធរបៀបណា ឬថាតើគួរប្រើប្រាស់ ឬមិនប្រើប្រាស់នោះទេ។ ផ្ទុយទៅវិញ ការសំខាន់ គឺត្រូវឲ្យតំណាងរាស្ត្រដែលកើតឡើងពីការបោះឆ្នោតចូលរួមក្នុងសេចក្តីសម្រេចចិត្តពាក់ព័ន្ធនឹងការប្រើប្រាស់កម្លាំង និងកងទ័ព។

## ឧត្តមភាពនៃនយោបាយ

យោងទៅតាមអ្នកយុទ្ធសាស្ត្រដ៏ល្បីឈ្មោះ Colin S. Gray «គ្មាននរណាអាចជំទាស់អំពីឧត្តមភាពនៃនយោបាយលើបញ្ហាយោធានោះទេ»[២៧]។ នេះមានន័យថា ប្រតិបត្តិការយោធា គឺធ្វើឡើងក្រោមគោលដៅ និងទិសដៅធំរបស់នយោបាយ។ ដូច្នេះកងកម្លាំងយោធាត្រូវរៀបចំទៅតាមរបៀបដែលឆ្លុះបញ្ចាំងពីគោលដៅ និងគោលបំណងនយោបាយដូចគ្នា។ មានសម័យកាលមួយនៅក្នុងប្រវត្តិសាស្ត្រ ដែលអ្នកនយោបាយត្រូវបានរំពឹងថា នឹងប្រគល់ការគ្រប់គ្រងកិច្ចការសង្គ្រាម និងការធ្វើសង្គ្រាមទៅឲ្យអ្នកជំនាញយោធា ដើម្បីឲ្យអ្នកជំនាញយោធាទាំងនោះអាចបំពេញប្រតិបត្តិការរបស់ពួកគេក្នុងបែបផែន «មិនពាក់ព័ន្ធនយោបាយ»។ ដោយសារគំនិតបែបនេះហើយទើបសង្គ្រាមក្នុងដើមសតវត្សរ៍ទី២០បានក្លាយជាការកាប់សម្លាប់ដោយគ្មានគោលបំណងច្បាស់លាស់ពោលគឺ«គ្មានគោលបំណងនយោបាយ» [២៨]។

វាអាចជារឿងសមហេតុផលក្នុងការអះអាងថា សង្គ្រាមគឺជាបញ្ហាស្មុគស្មាញ និងតម្រូវឲ្យមានអ្នកជំនាញធ្វើការសម្រេចចិត្តទាក់ទងនឹងការរៀបចំ និងការប្រើប្រាស់កងកម្លាំងសន្តិសុខ និងយោធា។ វាក៏ប្រហែលជារឿងធម្មតា ដែលមនុស្សភាគច្រើនដែលចូលរួមបញ្ចេញគំនិតក្នុងការរៀបចំយុទ្ធសាស្ត្រយោធា គឺជាអ្នកជំនាញយោធា មិនមែនជាប្រជាពលរដ្ឋស៊ីវិល។ ទន្ទឹមនឹងនេះ អ្នកបញ្ញវន្តផ្នែកយុទ្ធសាស្ត្រ (បើសិនយើងអាចហៅដូច្នោះបាន) ដែលទទួលខុសត្រូវក្នុងការបង្កើតយុទ្ធសាស្ត្រគោលសម្រាប់ប្រទេសជាតិ ភាគច្រើនជាប្រជាពលរដ្ឋស៊ីវិល [២៩]។

តាមរយៈការជានាឲ្យបានថា កងកម្លាំងប្រដាប់អាវុធ និងសង្គ្រាមស្ថិតក្រោមការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ នោះគោលបំណងនយោបាយនៃសង្គ្រាមអាចត្រូវគ្រប់គ្រងបានយកមកប្រើដើម្បីប្រយោជន៍ផ្សេងៗ ដូច្នេះសន្តិសុខនៃប្រជាជាតិនឹងមិនចាំបាច់ប្រុងប្រយ័ត្នពីការគំរាមកំហែងទេ។ វាពិតជាមានសារៈសំខាន់ក្នុងការគ្រប់គ្រង (និងដាក់កម្រិត) លទ្ធភាពដែលអាចបង្កើតសង្គ្រាមបាន ដើម្បីរក្សាប្រជាជាតិមួយមិនឲ្យធ្លាក់ចូលក្នុងជម្លោះដោយសារតែអារម្មណ៍របស់បុគ្គលដែលជាអ្នកដឹកនាំ។

## ស្ថាប័ននីតិប្រតិបត្តិគួរដំណើរការក្រោមក្របខ័ណ្ឌនីតិយុត្តិ

នៅឆ្នាំ១៩៨៣ ក្រោយពីការទម្លាក់គ្រាប់បែកនៅស្ថានទូតអាម៉េរិកប្រចាំទីក្រុង Beirut នៃប្រទេសលីបង់ ជាកន្លែងដែលកងកម្លាំងយោធាអាម៉េរិកច្រើនជាង២២០នាក់ត្រូវបានសម្លាប់ លោកប្រធានាធិបតី Ronald Reagan និងក្រុមសន្តិសុខជាតិរបស់គាត់បានពិភាក្សាពីការបន្តវត្តមាននៃកងកម្លាំងរបស់អាម៉េរិកនៅប្រទេសនោះ។ ទោះបីជាប្រធានាធិបតីរូបនេះមានការខឹងសម្បារលើការទម្លាក់គ្រាប់បែកនោះ រហូតដល់គាត់បានកត់ត្រាក្នុងកំណត់ហេតុប្រចាំថ្ងៃអំពីអារម្មណ៍របស់គាត់នៅពេលនោះថា «ស្អប់មនុស្សដែលអាចប្រព្រឹត្តអំពើដ៏ឃោរឃៅ ប៉ុន្តែកំសាកបែបនេះ» [៣០] គាត់មិនបានជ្រើសរើសធ្វើការសងសឹកដោយឯកតោភាគីទេ ប៉ុន្តែបានយកករណីនេះទៅសភាដើម្បីសុំការសម្រេច។ នៅក្នុងសៀវភៅកត់ត្រាប្រចាំថ្ងៃរបស់គាត់ លោកប្រធានាធិបតី Reagan បានសំដៅជាពិសេសដល់ច្បាប់ស្តីពីអំណាចសង្គ្រាម[៣១] និងរបៀបដែលគាត់ស្វែងរក «ការសម្រេចពីសភា ដើម្បីដាក់ពង្រាយទ័ពជើងទឹកនៅលីបង់»[៣២]។ ទោះបី ជាប្រធានាធិបតីអាម៉េរិក ជាមេបញ្ជាការកំពូលនៃកងទ័ពយោធាអាម៉េរិកក៏ដោយ ក៏គាត់មិនមានអំណាចដូចស្តេចនិងមេដឹកនាំផ្តាច់ការកាលពីអតីតកាល ដើម្បីធ្វើសង្គ្រាមដោយមិនឆ្លងកាត់ការត្រួតពិនិត្យ និងតាមចិត្តនោះទេ[៣៣]។

ផ្ទុយទៅវិញ រដ្ឋធម្មនុញ្ញរបស់សហរដ្ឋអាម៉េរិក បានចាត់ទុកការសម្រេចពីសភា មិនត្រឹមតែជាការទាមទារទេ តែជាកិច្ចការចាំបាច់បំផុតមុននឹងប្រធានាធិបតីអាម៉េរិកអាចដាក់ពង្រាយកងទ័ព និងប្រើកម្លាំងប្រដាប់អាវុធនៅបរទេសបាន [៣៤]។ នៅសហរដ្ឋអាម៉េរិក ការអនុវត្តបែបនេះ គឺត្រូវបានគេចាត់ទុកថាជាការត្រួតពិនិត្យរបស់សភា និងជាយន្តការផ្លូវការមួយក្រោមការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ។ប្រទេសប្រជាធិបតេយ្យទំនើបភាគច្រើនមានយន្តការស្រដៀងគ្នាក្នុងការអនុវត្តផងដែរ។

## ដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត និងការធ្វើផែនការយុទ្ធសាស្ត្រល្អបំផុត

ដើម្បីការពារការត្រួតពិនិត្យតាមបែបប្រជាធិបតេយ្យលើកម្លាំងយោធា និងការប្រើប្រាស់កងកម្លាំងយោធា សមាជិក សមាជិកាសភា ត្រូវតែជាផ្នែកមួយនៃដំណើរការក្នុងការធ្វើផែនការយុទ្ធសាស្ត្រ។ សមាជិក សមាជិកាសភាមិនត្រឹមតែគួរត្រូវបានអញ្ជើញចូលរួមក្នុងការធ្វើផែនការទេ តែថែមទាំងគួរធ្វើជាដៃគូចាំបាច់ និងជាអ្នកពាក់ព័ន្ធក្នុងដំណើរការនេះ។

អំណះអំណាងខ្លះបានលើកឡើងប្រឆាំងថាដំណើរការគ្រប់គ្រងកម្លាំងយោធាត្រូវធ្វើជាសម្ងាត់ ហើយយុទ្ធសាស្ត្រនេះជាបញ្ហាស្មុគស្មាញដែលអ្នកមិនមានជំនាញយោធាមិនអាចយល់បានឡើយ កុំថាឡើយដល់គ្រប់គ្រងលើបញ្ហានេះ។ ប៉ុន្តែទីមួយ បើទោះជាមានតម្រូវការច្បាស់លាស់ថា ផ្នែកណាមួយនៃយុទ្ធសាស្ត្រត្រូវការរក្សាការសម្ងាត់ក៏ដោយ តែមិនត្រូវយកចំណុចនេះជាលេសមិនឲ្យតំណាងរាស្ត្រដែលត្រូវបានបោះឆ្នោតជ្រើសរើសដោយប្រជាពលរដ្ឋដឹងឮនោះទេ។ ផ្ទុយទៅវិញ ការរក្សាការសម្ងាត់នេះហើយដែលធ្វើឲ្យការត្រួតពិនិត្យបែបប្រជាធិបតេយ្យកាន់តែចាំបាច់។ ដើម្បីធានាបានថា ការធ្វើផែនការយុទ្ធសាស្ត្រនេះត្រូវបានរក្សាការពារបានល្អ អ្នកដែលចូលរួមក្នុងដំណើរការនេះត្រូវតែទទួលបានការត្រួតពិនិត្យ ដោយហេតុផលសន្តិសុខ។ ទីពីរ និងប្រហែលជាអំណះអំណាងធំបំផុតសម្រាប់ភាពជាតំណាងតាមបែបប្រជាធិបតេយ្យ នៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តនោះ គឺ «យុទ្ធសាស្ត្រមិនអាចត្រូវបានគូសវាសដោយពឹងផ្អែកតែទៅលើកត្តាយោធាទាំងស្រុងទេ» [៣៥]។ ជាការពិត ប្រជាពលរដ្ឋស៊ីវិលចាំបាច់ត្រូវចាត់ទុកជាអ្នកគ្រប់គ្រងលើយោធាដោយឥតលក្ខខណ្ឌ [៣៦]។ នេះពាក់ព័ន្ធទៅនឹងទំនាក់ទំនងដែលយើងលើកឡើងខាងលើថា សង្គ្រាមមានពាក់ព័ន្ធនឹងរឿងនយោបាយ។ មុខងារនយោបាយនៃសង្គ្រាមត្រូវតែនៅពីមុខជានិច្ច។

ភាពជាតំណាងតាមបែបប្រជាធិបតេយ្យនៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តអាចប្រព្រឹត្តទៅបានក្នុងរបៀប ខុសប្លែកគ្នា ប៉ុន្តែមិនត្រូវទទួលបានការមើលស្រាលទេ។ ឧទាហរណ៍៖ គួរតែមានគណៈកម្មាធិការ ឬគណៈរដ្ឋមន្ត្រីពិសេសមួយដែលមានសមាសភាពពីបុគ្គលដែលជាប់ឆ្នោតដើម្បីតំណាងឲ្យសភាតំណាងរាស្ត្រ ឬសភាជាតិ។ នៅក្នុងគណៈកម្មាធិការនោះ គ្រប់បញ្ហាទាំងអស់ដែលពាក់ព័ន្ធនឹងគោលនយោបាយការពារជាតិ និងយុទ្ធសាស្ត្រជាតិត្រូវតែយកមកជជែកដេញដោល។ ទោះបីជាពេលនោះមានទម្រង់ទីពីរ ឬទីបី នៃការធ្វើសេចក្តីសម្រេចចិត្តពាក់ព័ន្ធនឹងការប្រើប្រាស់កងកម្លាំងទ័ពជាក់ស្តែង ឬទោះបីជាគណៈកម្មាធិការអាចជាផ្នែកមួយដែរនោះឬមិនអាច ការជជែកដេញដោលត្រូវតែធ្វើឡើងដូចគ្នា។ អ្វីដែលសំខាន់គឺ ការបង្កើតគោលនយោបាយក៏ដូចជាការសម្រេចចិត្តពាក់ព័ន្ធនឹងការប្រើប្រាស់កងកម្លាំង ត្រូវធ្វើឡើងដោយមានការចូលរួមពីបុគ្គលជាប់ឆ្នោតតាមបែបប្រជាធិបតេយ្យ។

## សេចក្តីបញ្ចប់

សង្គ្រាមប្រហែលជារឿងដ៏អាក្រក់បំផុតដែលអាចកើតឡើងលើប្រជាជាតិណាមួយ ហើយសង្គ្រាមស៊ីវិលអាចនឹងអាក្រក់ជាងសង្គ្រាមអន្តរជាតិទៅទៀត។ ដូច្នេះរាល់ការសម្រេចចិត្តពាក់ព័ន្ធនឹងការធ្វើសង្គ្រាម ឬប្រើប្រាស់កម្លាំងទ័ពចាំបាច់ត្រូវត្រួតពិនិត្យឲ្យបានច្បាស់លាស់ និងឆ្លងកាត់ការពិភាក្សាជាច្រើនដំណាក់កាល។ ទីមួយ ការប្រើប្រាស់កម្លាំងត្រូវតែធ្វើស្របទៅនឹងច្បាប់ដែលបានចែងទាំងច្បាប់អន្តរជាតិ និងច្បាប់ជាតិ។ ទីពីរ នៅពេលណាដែលប្រជាជាតិមួយគ្មានជម្រើសអ្វីក្រៅពីការប្រើប្រាស់កម្លាំងទ័ព ដំណើរការនោះត្រូវធ្វើឡើងតាមបែបប្រជាធិបតេយ្យ ដោយអនុញ្ញាតឲ្យមានការជជែកវែកញែកនយោបាយលើសារៈសំខាន់នៃការធ្វើសង្គ្រាម ក៏ដូចជាការពិភាក្សាអំពីគ្រប់ជម្រើសយុទ្ធសាស្ត្រទាំងអស់ដែលមានក្នុងដៃ។ ការសម្រេចចិត្តដែលនាំឲ្យប្រជាជាតិ និងប្រជាពលរដ្ឋធ្លាក់ចូលក្នុងជម្លោះប្រដាប់អាវុធ ដោយឯកតោភាគីពីសំណាក់ស្ថាប័ននីតិប្រតិបត្តិ គឺមិនអាចទទួលយកបានឡើយ។

ការត្រួតពិនិត្យត្រូវធ្វើឡើងដោយសភា ដែលកើតឡើងពីការបោះឆ្នោតតាមបែបប្រជាធិបតេយ្យ និងសមាជិក សមាជិកាសភា។ សមាជិក សមាជិកាសភាទាំងនេះត្រូវតែចូលរួមក្នុងគ្រប់ទិដ្ឋភាពទាំងអស់នៃការរៀបចំផែនការយុទ្ធសាស្ត្រនិងយោធា គោលនយោបាយ ក៏ដូចជាគ្រប់ដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត។ ការធ្វើសង្គ្រាម និងជម្លោះអន្តរជាតិគឺជាបញ្ហាដែលពាក់ព័ន្ធនឹងនយោបាយ ដូច្នេះហើយអ្នកគ្រប់គ្រងបញ្ហាទាំងនេះត្រូវតែជាប្រជាពលរដ្ឋស៊ីវិល។

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដែលបកដោយវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិនៃកម្ពុជា (NIDIR)។ អ្នកអានអាចទាញយកអត្ថបទដើមជាភាសាអង់គ្លេសពីគេហទំព័រ៖ https://www.pic.org.kh ។

## REFERENCES


១. Ball, D. (1996). The Transformation of Security in the Asia/Pacific Region. Oxford. FRANK CASS & CO LTD.

២. Geographic, N. (2020). Asia: Physical Geography. Retrieved 18 February 2020, from https://www.nationalgeographic.org/encyclopedia/asia/

៣. Zhongqi, P. (2003). US Taiwan Policy of Strategic Ambiguity: A dilemma of deterrence. Journal Of Contemporary China, 12(35), 387-407. doi: 10.1080/1067056022000054678

៤. Clarke, C., & Abuza, Z. (2019). The Islamic State Meets Southeast Asia. Retrieved 18 February 2020, from https://www.foreignaffairs.com/articles/southeast-asia/2019-09-16/islamic-state-meets-southeast-asia

៥. More discussion on 'Inclusive Regionalism' is available at: Rozman, G. (2012). East Asian Regionalism. In M. Beeson & R. Stubbs, Routledge Handbook of Asian Regionalism (1st ed., pp. 22-32).

៦. Caballero-Anthony, M. (2014). Understanding ASEAN's centrality: bases and prospects in an evolving regional architecture. The Pacific Review, 27(4), 563-584. doi: 10.1080/09512748.2014.924227

៧. For comparative study between 'Formal' and 'Informal' Regionalism, see: Acharya, A., & Johnston, A. (2007). Crafting cooperation: Regional International Institutions in Comparative Perspective. Cambridge: Cambridge University Press.

៨. See also:

- Noulas, G. (2011). The Role of Parliamentary Diplomacy in Foreign Policy. Foreign Policy Journal.
- Sayfullaev, D. (2016). Parliamentary Diplomacy in Making of Foreign Policy. The Advanced Science Journal, 2016(1), 52-54. doi: 10.15550/asj.2016.01.052
- Weisglas, F., & de Boer, G. (2007). Parliamentary Diplomacy. The Hague Journal Of Diplomacy, (2), 93-99.

៩. Moe, T., & Caldwell, M. (1994). The Institutional Foundations of Democratic Government: A Comparison of Presidential and Parliamentary Systems. Journal of Institutional and Theoretical Economics, 150(1), 171-195.

១០. Federica Mogherini, « Europe and Asia – together for a more secure world », The Strategist, ASPI, 31May 2018, https://www.spistrategist.org.au

១១. Territorial disputes in Southeast Asia included for example : The claim of the Philippines to the Malaysian state of Sabah; Claims to the Spratly Islands by Malaysia, Brunei and the Philippines; Disputed ownership by Malaysia and Singapore over Pedra Blanca Island; Disputed ownership by Malaysia and Indonesia of the islands of Sipadan, Sbetik and Ligitan; Clashes along the Thai-Myanmar border; A dispute between Thailand and Malaysia over the land border and offshore demarcation line; Boundary disputes between Malaysia and Vietnam and between Indonesia and Vietnam over their offshore demarcation lines; A boundary dispute between Cambodia and Vietnam and; A dispute between Malaysia and Brunei over Limbang and offshore boundaries.

១២. Marvin C. Ott, Southeast Asia Security : A Regional Perspective , National Defense University, Institute for National Strategic Studies, 2001, https://www.hsdl.org/?view&did=2194

១៣. ASEAN Regional Forum, http://aseanregionalforum.asean.org/about-arf/#objectives

១៤. Global Conflict Tracker, Council on Foreign Relations, December 2019, https://www.cfr.org/interactive/global-conflict-tracker/conflict/territorial-disputes-south-china-sea

១៥. The US delegation to the November 5th East Asia Summit, led by US National Security Advisor, Robert O'Brien, was the lowest ranking delegation ever sent to the East Asia Summit.

១៦. The East Asia Summit (EAS) is a forum held annually by leaders of the ASEAN plus six mechanism as well as Russia and the United States.

១៧. The ASEAN Defense Ministers Meeting Plus is a platform for ASEAN and its eight Dialogue Partners to strengthen security and defense cooperation in the region. It focuses on five areas of practical cooperation: maritime security, counter-terrorism, humanitarian assistance and disaster relief, peacekeeping operations and military medicine.

១៨. Julius Cesar Trajano, Marine Environmental Protection and Cooperation: An ASEAN-China Framework?, RSIS Commentary, No 113 – 6 June 2017, https://think-asia.org/bitstream/handle/11540/11047/CO17113.pdf?sequence=1

១៩. ASEAN Socio-Cultural Community Blueprint 2025, Jakarta, 2016, https://asean.org/storage/2016/01/ASCC-Blueprint-2025.pdf

២០. Draft Resolution on Promoting Parliamentary Diplomacy to Move Forward the ASEAN Community, (Res.40GA/2019/Pol/xx), 40th General Assembly of the Inter-Parliamentary Assembly, 25-30 August 2019, Bangkok, Thailand. https://www.parliament.go.th/ewtadmin/ewt/aipa2019/download/article/AIPAGA/Political/5POL.pdf

២១. Colin S. Gray, Fighting Talk. Forty maxims on war, peace and strategy. Potomac Books Inc.: Washington D.C., 2009, p. 7

២២. Thomas G. Mahnken and Jospeh A. Maiolo, Strategic Studies. A Reader. Routledge: London and New York, 2008, p. 2

២៣. Wim F. van Eekelen, Democratic control of armed forces: the national and international parliamentary dimension. Geneva Centre for the Democratic Control of Armed Forces (DCAF): Geneva, 2002, p. 5

២៤. Wim F. van Eekelen, Democratic control of armed forces: the national and international parliamentary dimension. Geneva Centre for the Democratic Control of Armed Forces (DCAF): Geneva, 2002, p. 5

២៥. See for instance Max Boot, War made new. Weapons, warriors, and the making of the modern world. Gotham Books: New York, p. 130-131

២៦. Niccoló Machiavelli, The Prince. Pocket Books: New York, 2004, p. 56-62

២៧. Colin S. Gray, The Strategy Bridge. Theory for practice. Oxford University Press: Oxford, 2010, p. 204

២៨. Colin S. Gray, The Strategy Bridge. Theory for practice. Oxford University Press: Oxford, 2010, p.31

២៩. Colin S. Gray, The Strategy Bridge. Theory for practice. Oxford University Press: Oxford, 2010, p. 202-203

៣០. Ronald Reagan, The Reagan Diaries, as edited by Douglas Brinkley. Harper Perennial: New York, 2007, p. 146

៣១. The War Powers Resolution of 1973 limits presidential power in reacting to international crises. See for example Andrew L. Johns, “Declining the ´’Invitation to Struggle’, Congressional Complicity in the Rise of the Imperial Presidency”, Pacific Historical Review, Vol. 89 No. 1, Winter 2020, pp. 97-130.

៣២. Ronald Reagan, The Reagan Diaries, as edited by Douglas Brinkley. Harper Perennial: New York, 2007, p. 180-181

៣៣. Jules Lobel, ”Cover war and the Constitution”, Journal of National Security, Law and Policy, Vol 5, 2012p. 393

៣៤. Jules Lobel, ”Cover war and the Constitution”, Journal of National Security, Law and Policy, Vol 5, 2012p. 393

៣៥. Colin S. Gray, p. 130

៣៦. Colin S. Gray, p. 150




កងនាវាចរសិង្ហបុរីធ្វើសមយុទ្ធនៅឆកសមុទ្រម៉ារីណា
Piyavachara Nacchanandana




រូបសំណាក ៤ ជាតិសាសន៍ តំណាងឲ្យអ្នកធ្វើការក្នុងផ្នែកពាណិជ្ជកម្មផ្សេងៗគ្នា និងទ្វីបនានា នៅមុខអាគារអង្គការពាណិជ្ជកម្មពិភពលោក (WTO) ក្នុងទីក្រុងហ្សឺណែវ ប្រទេសស្វីស

ជំពូកទី

# ០៣

# ការលើកកម្ពស់ប្រព័ន្ធពាណិជ្ជកម្មពហុភាគីអន្តរជាតិអាស្រ័យច្បាប់ដើម្បីការអភិវឌ្ឍដោយបរិយាបន្ន និងចីរភាព


ទំ.៧០ ៣.១ កិច្ចព្រមព្រៀងពាណិជ្ជកម្មពហុភាគី ជួបប្រទះបញ្ហាប្រឈម

*ដោយ លោក ស្កុត ខេមីរូន*
*កញ្ញា ជា សិរីរតន៍,*
*លោក វត្តាវង្ស វឌ្ឍនៈ*
*លោក ឈន ហាំ*

ទំ.៧៣ ៣.២ ប្រព័ន្ធពាណិជ្ជកម្មពហុភាគី៖ ទស្សនៈទានមួយបែបអាស៊ី

*ដោយ បណ្ឌិត ស្រ៊ីនីវ៉ាសា ម៉ាឌូ*

ទំ.៧៧ ៣.៣ ប្រព័ន្ធពាណិជ្ជកម្មពហុភាគី៖ ទស្សវិស័យមួយបែបអឺរ៉ុប

*ដោយ ហ្វ្រូរិន ហ្សីយើស្ស៍*

# ៣.១ កិច្ចព្រមព្រៀងពាណិជ្ជកម្មពហុភាគីជួបប្រទះបញ្ហាប្រឈម

កិច្ចសហប្រតិបត្តិការពាណិជ្ជកម្មពហុភាគីបានចាប់ផ្តើមរីកលូតលាស់ ចាប់តាំងពីការបង្កើតឡើងនូវ "កិច្ចព្រមព្រៀងទូទៅស្តីអំពីពន្ធគយ និងពាណិជ្ជកម្ម" (General Agreement on Tariffs and Trade) ក្នុងឆ្នាំ១៩៤៧ និងបន្ទាប់មកទៀត គឺការបង្កើតនូវ "អង្គការពាណិជ្ជកម្មពិភពលោក" (World Trade Organization) ក្នុងឆ្នាំ១៩៩៥។ ក្របខ័ណ្ឌនៃសហប្រតិបត្តិការទាំងនេះបានកំណត់នូវច្បាប់ជាមូលដ្ឋាន សម្រាប់ការធ្វើពាណិជ្ជកម្មអន្តរជាតិរវាងសមាជិករបស់ខ្លួន (ដែលបច្ចុប្បន្ននេះអង្គការពាណិជ្ជកម្មពិភពលោកមានសមាជិកចំនួន១៦៤ប្រទេស) [១]។

ដោយប្រើប្រាស់ក្របខ័ណ្ឌរបស់អង្គការពាណិជ្ជកម្មពិភពលោកជាគោល កិច្ចព្រមព្រៀងពាណិជ្ជកម្មជាច្រើន (ដែលជាការរៀបចំឲ្យមានលំហូរទំនិញ និងសេវាកម្មដោយមានរបាំងពន្ធគយតិចតួច ឬមិនមានទាល់តែសោះរវាងប្រទេសចំនួនពីរ ឬច្រើន) ត្រូវបានចរចាជុំវិញពិភពលោក រួមមាន៖"តំបន់ពាណិជ្ជកម្មសេរីអាស៊ាន(AFTA)"សម្រាប់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) និងថ្មីៗនេះ "តំបន់ពាណិជ្ជកម្មសេរីទ្វីបអាហ្វ្រិក" សម្រាប់តំបន់អាហ្វ្រិក។

ទោះបីជាយ៉ាងណាក៏ដោយ រដ្ឋបាលប្រធានាធិបតីសហរដ្ឋអាម៉េរិកដែលជាប្រទេសមានសេដ្ឋកិច្ចធំជាងគេបំផុតក្នុងពិភពលោកមានការប្រែប្រួលចាកឆ្ងាយចេញពីប្រព័ន្ធពហុភាគីនិយម ដោយជំនួសមកវិញនូវការងាកទៅរកការចរចាទ្វេភាគីដែលកាន់តែប្រឆាំងនឹងមតិភាគច្រើន។ សហរដ្ឋអាម៉េរិកបានចាប់ផ្តើមវិធានការបែបគាំពារនិយមដែលមានចំណាយខ្ពស់ នាំឲ្យមានការកើនឡើងនូវភាពតានតឹង ភាពមិនច្បាស់លាស់ និងជាងនេះទៅទៀតគឺ សង្គ្រាមពន្ធគយពេញទំហឹងជាមួយនឹងដៃគូពាណិជ្ជកម្មរបស់ខ្លួន។

ដោយមើលឃើញនូវការអនុវត្តរបស់រដ្ឋបាលសហរដ្ឋអាម៉េរិក ប្រទេសផ្សេងទៀតហាក់ដូចជាបានចាប់ផ្តើមអនុវត្តសកម្មភាពប្រហាក់ប្រហែលគ្នា ដែលគួរឲ្យកត់សម្គាល់នោះគឺ ប្រទេសដែលជាអ្នកផ្គត់ផ្គង់គ្រឿងអេឡិចត្រូនិចធំជាងគេពីរនៅអាស៊ី គឺប្រទេសជប៉ុន និងកូរ៉េខាងត្បូង។

ជាមួយនឹងការគំរាមកំហែងទាំងនេះទៅលើការអនុវត្តពាណិជ្ជកម្មសកល ការពិនិត្យឡើងវិញនូវទ្រឹស្តីពាណិជ្ជកម្ម

> "សហរដ្ឋអាម៉េរិកបានចាប់ផ្តើមវិធានការបែបគាំពារនិយមដែលចំណាយខ្ពស់ នាំឲ្យមានការបង្កើនភាពតឹងតែង ភាពមិនប្រាកដប្រជា និងជាងនេះទៅទៀតនាំឲ្យមានសង្គ្រាមពន្ធគយពេញទំហឹងជាមួយដៃគូពាណិជ្ជកម្ម។"

និងសារៈសំខាន់នៃកិច្ចព្រមព្រៀងពហុភាគី គឺជាការចាំបាច់សម្រាប់ពេលបច្ចុប្បន្ន និងអនាគត ជាពិសេសសម្រាប់ប្រទេសជាសមាជិកអាស៊ាន។

## ហេតុអ្វីបានជាប្រទេសជាច្រើនធ្វើពាណិជ្ជកម្ម?

ពាណិជ្ជកម្មក្នុងទ្រឹស្តីសេដ្ឋកិច្ចបែបបុរាណ (Classical Economics) បានលើកឡើងថា ប្រទេសមួយអាចបង្កើនសុខមាលភាពរបស់ខ្លួនបាន ដោយផ្តោតជំនាញទៅលើការផលិតតែផលិតផលមួយណាដែលផ្តល់អត្ថប្រយោជន៍ខ្ពស់ជាងគេធៀបនឹងផលិតផលផ្សេងៗទៀត (ផលិតផល ឬសេវាកម្មណាមួយដែលខ្លួនអាចផលិតបាន ដោយប្រើថ្លៃដើមទាបជាងគេ ធៀបនឹងផលិតផលដទៃទៀតដែលខ្លួនមិនបានផលិត) ខណៈដែលប្រទេសនោះអាចធ្វើពាណិជ្ជកម្មជាមួយប្រទេសដទៃដើម្បីបំពេញតម្រូវការប្រើប្រាស់របស់ខ្លួន។ អត្ថប្រយោជន៍ដែលខ្ពស់ជាងគេនេះអាចកើតមានដោយពឹងលើកត្តាមួយចំនួន ដូចជា៖ អាកាសធាតុ បច្ចេកវិទ្យា កម្រិតជំនាញ ឬគោលនយោបាយរបស់រដ្ឋាភិបាល [២]។

ពាណិជ្ជកម្មក៏អាចចូលរួមចំណែកក្នុងសន្តិភាពផងដែរ។ ជាក់ស្តែង ប្រព័ន្ធនៃអង្គការពាណិជ្ជកម្មពិភពលោកត្រូវបានបង្កើតឡើងតាមរយៈបំណងរបស់ប្រទេសមានអំណាចមួយចំនួន ដើម្បីជៀសវាងការកើតឡើងម្តងទៀតនូវសង្គ្រាមលោកលើកទីពីរ។ ហេតុដូចនេះ បេសកកម្មរបស់អង្គការពាណិជ្ជកម្មពិភពលោកផ្តោតទៅលើគោលការណ៍ច្បាស់លាស់ដូចជា៖ សមភាព សហប្រតិបត្តិការ និងសន្តិភាពតាមរយៈការចរចា[១]។

## សារៈសំខាន់នៃពាណិជ្ជកម្មចំពោះអាស៊ាន

ចំនួនប្រជាជនអាស៊ានប្រមាណជាង ៦០០លាននាក់ ធ្វើឲ្យតំបន់នេះក្លាយជាទីផ្សារពាណិជ្ជកម្មធំទីបី និងជាសេដ្ឋកិច្ចធំទីប្រាំពីររបស់ពិភពលោក[៣]។ ទោះបីជាការនាំចេញផលិតផលជារួមមានការកើនឡើងពី ៩៩០ប៊ីលានដុល្លារសហរដ្ឋអាម៉េរិកក្នុងឆ្នាំ២០០៨ ទៅប្រមាណ ១ ៤៤៧ ប៊ីលានដុល្លារសហរដ្ឋអាម៉េរិក ក្នុងឆ្នាំ២០១៧ សមាសភាពនៃដៃគូនាំចេញរបស់រដ្ឋជាសមាជិកអាស៊ានហាក់ដូចជាមិនមានការផ្លាស់ប្តូរគួរឲ្យកត់សម្គាល់ឡើយក្នុងរយៈពេល១០ ឆ្នាំចុងក្រោយនេះ ពោលគឺ៖ ២៤% នៃការនាំចេញ គឺទៅកាន់ដៃគូតំបន់ពាណិជ្ជកម្មសេរីអាស៊ាន (AFTA) ៤៣% ទៅកាន់ដៃគូក្នុងតំបន់ដែលមិនមែនជាផ្នែកនៃពាណិជ្ជកម្មសេរីអាស៊ាន និង ៣៣% ទៀតទៅកាន់ដៃគូពាណិជ្ជកម្មនៅក្រៅតំបន់[៤]។

រូបភាពខាងក្រោមបង្ហាញថា អាស៊ានមានសក្តានុពលដែលមិនទាន់បានប្រើប្រាស់ជាច្រើនក្នុងការពង្រីកគម្រោងអនុគ្រោះពន្ធ ដើម្បីរួមបញ្ចូលដៃគូក្នុងតំបន់បន្ថែមទៀត ប៉ុន្តែសកម្មភាពនេះហាក់មានការរីកចម្រើនតិចតួចក្នុងអំឡុងមួយទសវត្សរ៍ចុងក្រោយនេះ។

## ការនាំចេញក្នុងចំណោមដៃគូកិច្ចព្រមព្រៀងពាណិជ្ជកម្ម ដៃគូក្នុងតំបន់ និងទូទាំងពិភពលោក

### តួលេខទី១. ដៃគូពាណិជ្ជកម្មអាស៊ាន

## តួនាទីរបស់ស្ថាប័នសភាក្នុងការលើកកម្ពស់ឡើងវិញនូវកិច្ចព្រមព្រៀងពហុភាគី

ក្នុងដំណាក់កាលនៃភាពតានតឹងផ្នែកពាណិជ្ជកម្ម អង្គការពាណិជ្ជកម្មពិភពលោករំពឹងថាការនាំចេញផលិតផលប្រចាំឆ្នាំនឹងមានកំណើនធ្លាក់ចុះនៅត្រឹមប្រមាណ ១,២% ក្នុងឆ្នាំ២០១៩ ដែលធ្លាក់ពី ៣,០% ពីឆ្នាំ២០១៨[៥]។ តើអ្វីដែលគេអាចធ្វើបានដើម្បីត្រឡប់ទំនោរនៃភាពមិនច្បាស់លាស់នេះ ដែលអាចឲ្យពាណិជ្ជកម្មវិលត្រឡប់ទៅរកសក្តានុពលពេញលេញឡើងវិញ ក្នុងការជំរុញកំណើនសកល?

សភា និងអង្គការអន្តរសភាអាចដើរតួនាទីក្នុងការរំលឹកដល់រដ្ឋាភិបាលទូទាំងពិភពលោកអំពីអត្ថប្រយោជន៍នៃពាណិជ្ជកម្ម។ ស្ថាប័ននីតិប្បញ្ញត្តិអាចជួយទទួលយក និងពង្រីកប្រព័ន្ធពាណិជ្ជកម្មពហុភាគីដោយម៉្យាងតាមរយៈការផ្តល់ជម្រើសផ្សេងៗដល់អង្គនីតិប្រតិបត្តិទាំងឡាយណាដែលបច្ចុប្បន្នកំពុងមិនពេញចិត្តនឹងពហុភាគីនិយម និងម៉្យាងតាមរយៈការផ្តល់នូវជំនួយចាំបាច់នានាដល់រដ្ឋាភិបាលទាំងឡាយ ដែលមានបំណងបង្កើនកិច្ចសហប្រតិបត្តិការ។ សម្រាប់កិច្ចការនេះ សភាដែលជាសមាជិកនៃអន្តរសភាអាស៊ាន (AIPA) អាចធ្វើការពន្លឿន និងពង្រីកពាណិជ្ជកម្មក្នុងតំបន់ AFTA ឲ្យកាន់តែទូលំទូលាយ ដែលអាចបង្កើនវិបុលភាពក្នុងតំបន់ ក៏ដូចជាបង្ហាញដៃគូផ្សេងទៀត និងពិភពលោកថា ពហុភាគីនិយមគឺនៅតែមានវត្តមានជានិច្ច។ ជម្រើសកិច្ចព្រមព្រៀងពាណិជ្ជកម្មផ្សេងៗ អាចត្រូវបានស្វែងរកផងដែរ ដូចជាករណី "កិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយ និងវឌ្ឍនភាពសម្រាប់ភាពជាដៃគូអន្តរប៉ាស៊ីហ្វិក"




***ប្រភព៖**WTO ស្ថិតិពាណិជ្ជកម្មពិភពលោក ២០១៩*

> **"ស្ថាប័ននីតិប្បញ្ញត្តិអាចជួយទទួលយក និងពង្រីកប្រព័ន្ធពាណិជ្ជកម្មពហុភាគី ដោយម៉្យាងតាមរយៈការផ្ដល់ជម្រើសផ្សេងៗដល់អង្គនីតិប្រតិបត្តិទាំងឡាយណាដែលបច្ចុប្បន្នកំពុងមិនពេញចិត្តនឹងពហុភាគីនិយម និងម៉្យាងតាមរយៈការផ្ដល់នូវជំនួយចាំបាច់នានាដល់រដ្ឋាភិបាលទាំងឡាយ ដែលមានបំណងបង្កើនកិច្ចសហប្រតិបត្តិការ។"**

(Comprehensive and Progressive Agreement for Transpacific Partnership)[១] និង "ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់" (Regional Comprehensive Economic Partnership)[២] ដែលសមាជិកអាស៊ានបានធ្វើសមាហរណកម្មទៅក្នុងការរៀបចំពាណិជ្ជកម្មទាំងក្នុង និងក្រៅតំបន់។

ពហុភាគីនិយមក៏អាចត្រូវបានពង្រឹងផងដែរ តាមរយៈហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងបច្ចេកវិទ្យា ដែលសកម្មភាពនេះត្រូវបានគាំទ្រដោយសភាអឺរ៉ុបក្នុងការដោះស្រាយបញ្ហាប្រឈមនៃប្រព័ន្ធពាណិជ្ជកម្មពហុភាគី[៦, ៧]។ ជាឧទាហរណ៍ ក្នុងការបំពេញផ្នែកមួយនៃមុខងាររបស់ស្ថាប័ននីតិប្បញ្ញត្តិ គណៈកម្មាធិការពាណិជ្ជកម្មអន្តរជាតិនៃសភាអឺរ៉ុបបានទទួលយករបាយការណ៍ស្ដីអំពីបច្ចេកវិទ្យាផ្ទុក និងចែករំលែកបណ្ដុំឯកសារ (blockchain technology) ដើម្បីពង្រឹងពាណិជ្ជកម្មសកល និងបង្កើនតម្លាភាព ដោយហេតុថា បច្ចេកវិទ្យា blockchain ជំរុញនូវកិច្ចសហប្រតិបត្តិការ និងកាត់បន្ថយហានិភ័យនៃការគេចវេសការបង់ប្រាក់ និងកាត់បន្ថយថ្លៃដើមក្នុងដំណើរការឯកសារនានា[៧]។ ប្រព័ន្ធនេះអាចសម្របសម្រួលពាណិជ្ជកម្មឆ្លងកាត់ព្រំដែនគយ ដែលអ្នកនាំចេញអាចដាក់បញ្ចូលនូវឯកសារទៅជាមួយពាក្យស្នើសុំរបស់អង្គការពាណិជ្ជកម្មពិភពលោក និងបង្ហាញថាបានអនុលោមតាមវិធាននៃកិច្ចព្រមព្រៀងពាណិជ្ជកម្មរៀងៗខ្លួន។

ស្ថាប័នសភាក៏មានតួនាទីសំខាន់ផងដែរក្នុងការតម្រង់ត្រួតពិនិត្យ និងទំនាក់ទំនងសកម្មភាពរបស់រដ្ឋាភិបាល ដើម្បីធានានូវការធ្វើពាណិជ្ជកម្មដោយយុត្តិធម៌ និងប្រកបដោយបរិយាបន្ន ជំរុញការអភិវឌ្ឍ អនិកម្មភាព និងការកាត់បន្ថយភាពក្រីក្រ[៨]។ កិច្ចខិតខំប្រឹងប្រែងអាចធ្វើឡើងតាមរយៈកិច្ចសហប្រតិបត្តិការជាមួយរដ្ឋាភិបាល និងវិស័យឯកជន ដែលស្ថាប័នសភាប្រើប្រាស់ការស្រាវជ្រាវ និងសេវាអប់រំដើម្បីផ្ដល់នូវរបាយការណ៍ អំពីបញ្ហានានាដែលពាក់ព័ន្ធនឹងពាណិជ្ជកម្ម។ ស្ថាប័នសភាក៏អាចរៀបចំផងដែរនូវសិក្ខាសាលាផ្សព្វផ្សាយព័ត៌មាននៅថ្នាក់មូលដ្ឋាន ដើម្បីពន្យល់ដល់សាធារណជន អំពីសារៈសំខាន់នៃប្រព័ន្ធពាណិជ្ជកម្មដែលអាស្រ័យច្បាប់[៧]។

> **"ស្ថាប័នសភាក៏មានតួនាទីសំខាន់ផងដែរក្នុងការតម្រង់ ត្រួតពិនិត្យ និងទំនាក់ទំនងសកម្មភាពរបស់រដ្ឋាភិបាល ដើម្បីធានានូវការធ្វើពាណិជ្ជកម្មដោយយុត្តិធម៌ និងប្រកបដោយបរិយាបន្ន ជំរុញការអភិវឌ្ឍ អនិកម្មភាព និងការកាត់បន្ថយភាពក្រីក្រ"**

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដែលបកដោយវិទ្យាស្ថានសភាកម្ពុជា (PIC)។
អត្ថបទដើមជាភាសាអង់គ្លេសអាចទាញយកពីគេហទំព័រ៖ https://www.pic.org.kh ។

# ៣.២ ប្រព័ន្ធពាណិជ្ជកម្មពហុភាគី៖ ទស្សនៈមួយបែបអាស៊ី

## ស្ថាប័នដែលបង្កើតឡើងក្រោយសង្គ្រាម

ប្រព័ន្ធពាណិជ្ជកម្មពហុភាគីដែលត្រូវបានបង្កើតឡើងបន្ទាប់ពីសង្គ្រាមលោកលើកទី២ ហើយដែលទទួលបានជោគជ័យក្នុងការជំរុញសេដ្ឋកិច្ចពិភពលោកឆ្ពោះទៅរកបបពាណិជ្ជកម្មសេរីអស់រយៈពេលជាច្រើនទសវត្សរ៍មកហើយនោះ បច្ចុប្បន្ននេះកំពុងស្ថិតនៅក្នុងសភាពមិនច្បាស់លាស់។ របបពាណិជ្ជកម្មពហុភាគីដែលគ្រប់គ្រងដោយអង្គការពាណិជ្ជកម្មពិភពលោក (WTO) ដែលមុនឆ្នាំ១៩៩៥ គឺជាការរៀបចំអន្តររដ្ឋាភិបាលមួយដែលត្រូវបានស្គាល់ថា ជាកិច្ចព្រមព្រៀងទូទៅស្តីពី ពន្ធគយនិងពាណិជ្ជកម្ម (GATT) គឺជាជោគជ័យដ៏គួរឲ្យកត់សម្គាល់មួយនៃអភិបាលកិច្ចពិភពលោក (Basedow, ២០១៧) [៨] ។

ប្រព័ន្ធនេះមានវឌ្ឍនភាពគួរឲ្យកត់សម្គាល់ក្នុងការសម្រេចបាននូវរបបពាណិជ្ជកម្មសេរីស្ទើរតែទាំងស្រុងអស់រយៈពេលជាច្រើនទសវត្សរ៍។ ទីមួយ ពន្ធគយជាមធ្យមក្នុងចំណោមប្រទេសដែលជាសមាជិកអង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍ (OECD) ដែលមានចន្លោះពី ២០% ទៅ ៣០% នៅក្នុងទសវត្សរ៍ឆ្នាំ១៩៥០ បច្ចុប្បន្នមានចំនួនតិចជាង ៤%ប៉ុណ្ណោះ។ ទីពីរ ការរឹតត្បិតផ្នែកបរិមាណលើពាណិជ្ជកម្មពិភពលោក ក្នុងទម្រង់កូតាពាណិជ្ជកម្មជាច្រើនត្រូវបានដកចេញ។ ទីបី វិធានពហុភាគីនិងយន្តការអនុវត្តច្បាប់ថ្មីដែលគ្របដណ្តប់លើពាណិជ្ជកម្មផ្នែកសេវាកម្ម កម្មសិទ្ធិបញ្ញា និងការវិនិយោគធ្វើឲ្យទំនាក់ទំនងពាណិជ្ជកម្មរវាងប្រទេសមានភាពច្បាស់លាស់ជាងមុន។ ទីបួន យន្តការដោះស្រាយវិវាទនៃអង្គការពាណិជ្ជកម្មពិភពលោកដែលគ្រប់គ្រងពាណិជ្ជកម្មពហុភាគីត្រូវបានពង្រឹង។ ចុងក្រោយ របប GATT ឬWTO បានវិវត្តពីក្រុមតូចមួយនៃប្រទេសដែលមានសេដ្ឋកិច្ចអភិវឌ្ឍន៍នៅលោកខាងលិចចំនួន ២៣ នៅយុគសម័យក្រោយសង្គ្រាម ទៅជាស្ថាប័នពិភពលោកមួយដែលមានសមាជិក ១៦៤ ប្រទេស និងមានប្រទេសជាច្រើនទៀតប្រាថ្នាចង់ចូលរួម។

ទោះបីជាទទួលបានជោគជ័យជារួមក៏ដោយ ប្រព័ន្ធពាណិជ្ជកម្មពហុភាគី ក្រោមរបប GATT ឬWTO ប្រឈមនឹងឧបសគ្គជាច្រើននាពេលកន្លងមក រួមទាំងបរាជ័យគួរឲ្យកត់សម្គាល់មួយ គឺការចរចាពាណិជ្ជកម្មនៅទីក្រុងដូហាផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយ ការដំឡើងពន្ធគយជាឯកតោភាគីដោយសហរដ្ឋអាម៉េរិកលើផលិតផលរបស់ចិននៅឆ្នាំ២០១៨ ដែលនាំឲ្យមានសកម្មភាពសងសឹកវិញពីចិនប្រឆាំងនឹងសហរដ្ឋអាម៉េរិក គឺជាហេតុនាំមកនូវការប្រេះឆាកាន់តែធំ និងស៊ីជម្រៅនៅក្នុងប្រព័ន្ធពាណិជ្ជកម្មពហុភាគី។ ខណៈដែលឧបសគ្គពីមុនបានរារាំងការរីកចម្រើនទៅមុខដល់ការចរចាពហុភាគី ការបែកបាក់នាពេលបច្ចុប្បន្នបង្កការគំរាមកំហែងដល់អត្ថិភាពនៃប្រព័ន្ធពាណិជ្ជកម្មពហុភាគី (Panagariya, ២០១៨) [៩]។

## ជម្លោះពាណិជ្ជកម្មអាម៉េរិក-ចិន

នៅថ្ងៃទី៨ ខែមីនា ឆ្នាំ២០១៨ អាម៉េរិកបានដាក់ពន្ធគយដោយឯកតោភាគីចំនួន២៥%លើការនាំចូលដែកថែប និង១០%លើការនាំចូលអាលុយមីញ៉ូមពីចិន។បន្ទាប់ពីនោះ ចិនបានចាត់វិធានការសងសឹកមួយកាលពីថ្ងៃទី២ ខែមេសា ឆ្នាំ២០១៨ ដោយដាក់ពន្ធគយ ២៥% លើការនាំចូលទំនិញចំណីអាហារពីអាម៉េរិក។ នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៨ អាម៉េរិកបានសម្រេចចាត់វិធានការឯកតោភាគីបន្ថែមទៀតដោយដាក់ពន្ធគយ ២៥% លើការនាំចូលពីចិនដែលមានតម្លៃ ៣៤ ប៊ីលានដុល្លារអាម៉េរិក។ ចិនបានឆ្លើយតបនៅថ្ងៃដដែលដោយបានដាក់ពន្ធគយក្នុងអត្រាដូចគ្នាលើការនាំចូលដែលមានតម្លៃស្មើគ្នាពីអាម៉េរិក។ នៅថ្ងៃទី២ ខែសីហា ឆ្នាំ២០១៨ អាម៉េរិកបានគំរាមដាក់ពន្ធគយ ២៥% លើការនាំចូលរបស់ចិនដែលមានតម្លៃ ២០០ប៊ីលានដុល្លារអាម៉េរិក ហើយចិនក៏បានឆ្លើយតបប្រឆាំងទៅនឹងការគំរាមកំហែងនេះដោយបានដាក់ពន្ធគយលើការនាំចូលដែលមានតម្លៃ ៦ប៊ីលានដុល្លារអាម៉េរិក។ បន្ទាប់មក អាម៉េរិកបានដាក់ចេញបញ្ជីទំនិញនាំចូលពីចិនមួយទៀតដែលមានតម្លៃ ១៦ប៊ីលានដុល្លារអាម៉េរិក ដោយដាក់ពន្ធគយ ២៥% ចាប់ពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨។ ភ្លាមៗនោះ ចិនបានប្រកាសដាក់ពន្ធគយ ២៥% លើការនាំចូលដែលមានតម្លៃស្មើគ្នាពីអាម៉េរិក។

បន្ថែមលើការវាយប្រហារលើពាណិជ្ជកម្មពហុភាគីតាមរយៈពន្ធគយ ដែលបានចាប់ផ្តើមដោយអាម៉េរិកនៅឆ្នាំ២០១៨ លោកប្រធានាធិបតីត្រាំបានដកសមាជិកភាពរបស់ខ្លួនចេញពីស្ថាប័នឧទ្ធរណ៍របស់អង្គការពាណិជ្ជកម្មពិភពលោក ដែលស្ថាប័ននេះមានតួនាទីជួយសម្របសម្រួលក្នុងការដោះស្រាយវិវាទពាណិជ្ជកម្មពហុភាគី។ ក្រោមយន្តការរបស់ GATT ឬWTO ស្ថាប័នឧទ្ធរណ៍នេះបានជួយដោះស្រាយបញ្ហា នៅពេលមានវិវាទកើតឡើងរវាងប្រទេសនិងប្រទេសជុំវិញដោយអនុលោមតាមច្បាប់គ្រប់គ្រងពាណិជ្ជកម្មពហុភាគី។ ទោះបីជាប្រទេសមួយចំនួនបានដាក់ពាក្យបណ្តឹងលើវិវាទពាណិជ្ជកម្មមិនសំខាន់ជាច្រើនទៅកាន់អង្គការពាណិជ្ជកម្មពិភពលោក ដែលទម្លាក់បន្ទុកច្រើនហួសកម្រិតលើយន្តការដោះស្រាយវិវាទក៏ដោយ ក៏បណ្តាប្រទេសសមាជិកនៅតែផ្តល់សារៈសំខាន់បំផុតលើការការពារប្រព័ន្ធនេះ ដែលជាហេតុនាំឲ្យពួកគេគោរពតាមរាល់សេចក្តីសម្រេចនានា។ ជាទូទៅប្រទេសសមាជិកក៏ជៀសវាងការបង្កើតរបាំងពាណិជ្ជកម្មផងដែរ លើកលែងតែនៅក្រោមលក្ខខណ្ឌការពារផ្សេងៗរបស់ GATT-WTO ហើយនៅពេលមានការរំលោភបំពានកើតឡើង ជាទូទៅប្រទេសសមាជិកស្វែងរកយន្តការសម្របសម្រួលតាមរយៈ GATT និងWTO ជាជាងការវាយបកវិញជាឯកតោភាគី។ ប៉ុន្តែសកម្មភាពពាណិជ្ជកម្មនាពេលថ្មីៗរបស់អាម៉េរិកមានលក្ខណៈឯកតោភាគីខ្លាំង ដែលជាហេតុធ្វើឲ្យប៉ះពាល់ដល់មូលដ្ឋានគោលនៃរបបពាណិជ្ជកម្មពហុភាគីតែម្តង។ ដូចនេះហើយទើបសំណួរដែលបានលើកឡើងថា "តើវិធីសាស្ត្រដែលអាចទទួលយកបានចំពោះដំណើរការដោះស្រាយវិវាទរបស់អង្គការពាណិជ្ជកម្មពិភពលោកនឹងត្រូវកែសម្រួលឲ្យបានឆាប់ ឬរង់ចាំបន្តិចទៀត" គឺជាសំណួរមួយមិនទាន់មានចម្លើយនៅឡើយក្នុងដំណាក់កាលនេះ។

ទោះបីជាជម្លោះពាណិជ្ជកម្មរវាងអាម៉េរិកនិងចិនធ្ងន់ធ្ងរក៏ដោយ ក៏មានលេចឡើងនូវសញ្ញាគួរឲ្យមានសង្ឃឹមមួយចំនួនដែរ។ នៅដើមឆ្នាំ២០២០ ប្រទេសទាំងពីរបានចុះហត្ថលេខាលើកិច្ចព្រមព្រៀង "ដំណាក់កាលទីមួយ" ដែលរួមមានការសន្យាពីចិនក្នុងការបង្កើនការនាំចូលផលិតផលកសិកម្មរបស់អាម៉េរិកនិងទំនិញផ្សេងទៀត ព្រមទាំងផ្តល់ការការពារដល់បច្ចេកវិទ្យាអាម៉េរិក និងបង្កើតយន្តការអនុវត្តថ្មីនានា។ អាម៉េរិកបានលុបចោលពន្ធគយថ្មីដែលអាចបង្ករខូចខាតច្រើនដែលខ្លួនគ្រោងដាក់ ហើយបានសន្យាកាត់បន្ថយពន្ធគយពាក់កណ្តាល ប្រមាណ ១៥% ដែលបានដាក់ពីមុនលើមុខទំនិញប្រើប្រាស់ដូចជាសម្លៀកបំពាក់។ ចិនក៏បានយល់ព្រមនាំចូលផលិតផលអាម៉េរិកចំនួន ២០០ ប៊ីលានដុល្លារអាម៉េរិកបន្ថែមទៀតក្នុងរយៈពេល ២ឆ្នាំ រួមទាំងផលិតផលកសិកម្មចំនួន ៣២ប៊ីលានដុល្លារអាម៉េរិកបន្ថែមទៀត ចំនួននេះផងដែរ គឺលើសពីទឹកប្រាក់១៨៧ ប៊ីលានដុល្លារអាម៉េរិកនៃការនាំចូលក្នុងឆ្នាំ២០១៧ មុនពេលជម្លោះពាណិជ្ជកម្មបានចាប់ផ្តើម។ អ្នកជំនាញជាច្រើនជឿជាក់ថា កិច្ចព្រមព្រៀងពាណិជ្ជកម្ម "ដំណាក់កាលទីមួយ" មិនមែនជាសន្តិភាពពាណិជ្ជកម្មរវាងប្រទេសទាំងពីរទេ គឺគ្រាន់តែជាការផ្អាកសង្គ្រាមតែប៉ុណ្ណោះ។

## ការឆ្លើយតបរបស់អាស៊ី

ជាទូទៅបណ្តាប្រទេសអាស៊ីភាគច្រើនបានរក្សាជំហរអព្យាក្រឹត ក្នុងជម្លោះពាណិជ្ជកម្មរវាងមហាអំណាចសេដ្ឋកិច្ចពិភពលោកលេចធ្លោទាំងពីរ ដែលឆ្លុះបញ្ចាំងពីសម្ព័ន្ធភាពភូមិសាស្ត្រនយោបាយខុសៗគ្នារបស់ប្រទេសទាំងនេះ។ ទោះជាយ៉ាងណា បណ្តាប្រទេសនៅអាស៊ីជាច្រើនលើកច្រើនសារបានបញ្ជាក់ពីតម្រូវការ និងការប្តេជ្ញារបស់ខ្លួនក្នុងការថែរក្សាប្រព័ន្ធពាណិជ្ជកម្មពហុភាគីដែលពិភពលោកបានយកចិត្តទុកដាក់ការពារអស់ជាច្រើនទសវត្សរ៍មកហើយ។

ទន្ទឹមនឹងនេះដែរ ប្រទេសជាច្រើននៅអាស៊ីបានបន្តអនុវត្តកិច្ចផ្តួចផ្តើមសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ និងអន្តរតំបន់។ កិច្ចផ្តួចផ្តើមប្រភេទនេះដំបូងគេគឺ ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយនិងវឌ្ឍនភាពសម្រាប់ភាពជាដៃគូអន្តរប៉ាស៊ីហ្វិក (CPTPP) ដែលជាគំនិតផ្តួចផ្តើមសមាហរណកម្មពាណិជ្ជកម្ម និងសេដ្ឋកិច្ចឆ្លងតំបន់ (ដែលរួមមានប្រទេសចំនួន ១១ ជុំវិញពិភពលោកដូចជាជប៉ុន ម៉ាឡេស៊ី សិង្ហបុរី វៀតណាម ព្រុយណេ អូស្ត្រាលី នូវែលសេឡង់ កាណាដា ស៊ីលី ប៉េរូ និងម៉ិកស៊ិក) បន្ទាប់ពីអាម៉េរិកដកខ្លួនចេញពីភាពជាដៃគូអន្តរប៉ាស៊ីហ្វិក (TPP) ដែលមាន ១២ ប្រទេសជាសមាជិក ភ្លាមៗក្រោយលោកប្រធានាធិបតីត្រាំចូលកាន់តំណែងនៅខែមករា ឆ្នាំ២០១៧។ កិច្ចព្រមព្រៀង CPTPP ត្រូវបានចុះហត្ថលេខានៅខែមីនា ឆ្នាំ២០១៨ ហើយត្រូវបានផ្តល់សច្ចាប័នពីសមាជិកភាគច្រើន។ កិច្ចព្រមព្រៀងនេះបានចូលជាធរមាននៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៨។ ប្រទេសកូរ៉េខាងត្បូងត្រូវបានគេមើលឃើញថា នឹងអាចក្លាយជាសមាជិកនាពេលអនាគតរបស់ CPTPP ខណៈដែលថ្មីៗនេះ ប្រទេសថៃ និងកូឡុំប៊ីបានបង្ហាញចំណាប់អារម្មណ៍ក្នុងការចូលរួមផងដែរ។

ថ្មីៗនេះ ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ (RCEP) ដែលជាភាពជាដៃគូសេដ្ឋកិច្ចក្នុងតំបន់ និងមាន

សមាជិកចំនួន ១៦ ដែលរួមមានសមាជិកអាស៊ានទាំង ១០ បូកនឹងជប៉ុន ចិន កូរ៉េខាងត្បូង អូស្ត្រាលី នូវែលសេឡង់ និងឥណ្ឌា កំពុងឈានដល់ដំណាក់កាលចុងក្រោយ។ ប្រទេសជាសមាជិកទាំងអស់ លើកលែងឥណ្ឌា មានបំណងចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះនៅឆ្នាំ២០២០ និងចាប់ផ្តើមអនុវត្តនៅដើមឆ្នាំ២០២១។ គំនិតផ្តួចផ្តើម RCEP បានចាប់ផ្តើមនៅឆ្នាំ២០១២ ដើម្បីធ្វើសមាហរណកម្មកិច្ចព្រមព្រៀងពាណិជ្ជកម្មរវាងប្រទេសសមាជិកអាស៊ាន និងដៃគូពាណិជ្ជកម្មសំខាន់ៗរបស់ខ្លួនទៅជាកិច្ចព្រមព្រៀងរួមមួយ ដែលនឹងក្លាយជាកិច្ចព្រមព្រៀងពាណិជ្ជកម្មធំបំផុតរបស់ពិភពលោក បើគិតពីចំនួនប្រជាជន និងប្រាក់ចំណូល។

RCEP មានសក្តានុពលធំធេងក្នុងការបង្កើនប្រាក់ចំណូលសកល ( Reinsch et. al., ២០១៩ ) ។ ការសិក្សាមួយរបស់វិទ្យាស្ថានប្រ៊ូកឃីង ( Brookings Institute ) ដែលជាក្រុមអ្នកផ្តល់យោបល់មួយនៅសហរដ្ឋអាម៉េរិកបានប៉ាន់ប្រមាណថា RCEP មានសក្តានុពលក្នុងការបង្កើនប្រាក់ចំណូលសកលចំនួន ២៨៥ ប៊ីលានដុល្លារអាម៉េរិកជារៀងរាល់ឆ្នាំ ដែលបើគិតក្នុងតម្លៃជាក់ស្តែងដាច់ខាត វាស្មើនឹងទ្វេដងនៃចំណូលដែលត្រូវបានគេប៉ាន់ស្មានថានឹងបានពី CPTPP ( ដកស្រង់ពីក្នុង Reinsch et. al., ២០១៩ ) ។ កិច្ចព្រមព្រៀងនេះធ្វើឲ្យមានការរីកចម្រើនគួរឲ្យកត់សម្គាល់ក្នុងការដោះស្រាយវិធាននៃប្រភពដើមទំនិញ ( rules of origin ) កម្មសិទ្ធិបញ្ញា និងការកាត់បន្ថយពន្ធគយ ខណៈពេលដែលនៅមានភាពខ្វះខាតនៅក្នុងផ្នែកផ្សេងទៀតដូចជាផ្នែកពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច។ ក្នុងអំឡុងពេលនៃការចរចាចុងក្រោយ មានឧបសគ្គកើតឡើងនៅពេលដែលឥណ្ឌាដកខ្លួនចេញពីកិច្ចព្រមព្រៀង។ ទោះជាការចាកចេញរបស់ឥណ្ឌាមិនគួរឲ្យនឹកស្មានដល់ក៏ដោយ តែវាមិនបានប៉ះពាល់ដល់វឌ្ឍនភាពរបស់ RCEP ឡើយ។

បទបញ្ញត្តិរបស់ RCEP ដែលបញ្ជាក់ដោយឡែកពីការចូលរួមរបស់ឥណ្ឌានឹងត្រូវផ្អាក ហើយការផ្លាស់ប្តូរតិចតួចមួយចំនួនអាចនឹងត្រូវធ្វើឡើងសម្រាប់ការចាកចេញរបស់ឥណ្ឌា។ RCEP នឹងនៅតែបើកចំហរសម្រាប់ឥណ្ឌាចូលរួមម្តងទៀតនៅពេលណាមួយ ( RCEP ក៏មានបទបញ្ញត្តិសម្រាប់ការចូលរួមជាទូទៅផងដែរ ) ប៉ុន្តែការដែលឥណ្ឌានឹងពិចារណាចូលរួម RCEP ម្តងទៀតហាក់ដូចជាមិនអាចទៅរួចមុនពេលដែលមានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ។

## សេចក្តីសន្និដ្ឋាន

ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ស្ទើរតែគ្រប់ប្រទេសនៅអាស៊ីទាំងអស់បានទទួលផលប្រយោជន៍យ៉ាងច្រើនពីប្រព័ន្ធពាណិជ្ជកម្មពហុភាគីក្រោយសង្គ្រាម និងស្ថាប័នអភិបាលកិច្ចសំខាន់របស់ប្រព័ន្ធនេះ ពោលគឺអង្គការពាណិជ្ជកម្មពិភពលោក។ របបពាណិជ្ជកម្មពិភពលោកដែលបើកចំហ និងអាស្រ័យច្បាប់បានធ្វើឲ្យប្រទេសមួយហើយមួយទៀតនៅអាស៊ីអនុវត្តតាមគោលនយោបាយពាណិជ្ជកម្មដែលឆ្ពោះទៅខាងក្រៅ ( ដែលផ្តោតលើការនាំចេញ ) និងធ្វើសមាហរណកម្មទៅក្នុងទីផ្សារពិភពលោកដ៏ធំ។ លទ្ធផលមានដូចជាការកើនឡើងនៃការនាំចេញ ការបង្កើតការងាររាប់លាននៅក្នុងប្រទេស និងការអភិវឌ្ឍដែលកើនឡើងជាលំដាប់។ ប្រទេសចិនប្រហែល គឺជាឧទាហរណ៍ច្បាស់មួយនៃវឌ្ឍនភាពនេះ ដោយទទួលបានអត្ថប្រយោជន៍តាមរយៈការអនុវត្តយុទ្ធសាស្ត្រកំណើនដោយផ្អែកលើការនាំចេញចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ១៩៨០។

ជាការដោះដូរ អ្នកប្រើប្រាស់នៅអឺរ៉ុប សហរដ្ឋអាម៉េរិក និងតំបន់ផ្សេងទៀតទទួលបានផលប្រយោជន៍ពីទំនិញ និងសេវាកម្មទាំងឡាយដែលនាំចូលពីអាស៊ីក្នុងតម្លៃទាបជាងបើផលិតនៅក្នុងប្រទេស។ ប្រព័ន្ធពាណិជ្ជកម្មពហុភាគីផ្តល់ផលប្រយោជន៍ដូចគ្នាដល់ប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍។ នៅពេលដែលមានការប៉ះទង្គិចខាងផ្នែកពាណិជ្ជកម្មរវាងប្រទេសនិងប្រទេស ការដោះស្រាយអាចធ្វើបានតាមរយៈប្រព័ន្ធដោះស្រាយវិវាទពហុភាគីអាស្រ័យច្បាប់ក្រោមកិច្ចព្រមព្រៀងទូទៅ ស្តីពីពន្ធគយនិងពាណិជ្ជកម្ម ឬអង្គការពាណិជ្ជកម្មពិភពលោក។ ទោះជាយ៉ាងណាការតម្លើងពន្ធជាឯកតោភាគីដោយអាម៉េរិកដែលចាប់ផ្តើមនៅឆ្នាំ២០១៨ និងការដកសមាជិកភាពរបស់ខ្លួនចេញពីស្ថាប័នឧទ្ធរណ៍របស់អង្គការពាណិជ្ជកម្មពិភពលោក បានបង្ហាញពីភាពតានតឹងយ៉ាងខ្លាំងលើប្រព័ន្ធពាណិជ្ជកម្មពហុភាគី។ ក្នុងពេលជាមួយគ្នានេះដែរ អ្នកសង្កេតការណ៍ជាច្រើនបានកត់សម្គាល់ថា ចិនក៏បានដាក់ចេញនូវគោលនយោបាយដែលអាចបង្កបញ្ហា និងមានទំនោរធ្វើឲ្យខូចខាតដល់របបពាណិជ្ជកម្មពហុភាគីអាស្រ័យច្បាប់។

សហគមន៍អន្តរជាតិមានចំណាប់អារម្មណ៍ចង់ឲ្យចិន និងអាម៉េរិកដោះស្រាយជម្លោះពាណិជ្ជកម្មរបស់ខ្លួនប្រកបដោយមេត្រីភាពនិងឆាប់រហ័ស ដើម្បីធ្វើឲ្យប្រព័ន្ធពាណិជ្ជកម្មពហុភាគីក្រោយសង្គ្រាមដែលទទួលបានការថែរក្សាយ៉ាងយកចិត្តទុកដាក់បំផុតក្នុងរយៈពេលជាច្រើនទសវត្សរ៍កន្លងមក នឹងវិលត្រលប់ទៅរកស្ថានភាពល្អប្រសើរវិញ។ បណ្តា

ប្រទេសនៅអាស៊ីភាគច្រើនបានឆ្លើយតបជាមួយនឹងអភិក្រមផ្លូវពីរ (dual-track approach) ក្រោយពីមានជម្លោះពាណិជ្ជកម្មរវាងអាមេរិក និងចិន។ ខណៈដែលប្រទេសនៅអាស៊ីទាំងនេះបានប្រកាសពីការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះប្រព័ន្ធពាណិជ្ជកម្មពហុភាគី ពួកគេក៏បានសម្របសម្រួលសេរីភាវូបនីយកម្មពាណិជ្ជកម្មតាមរយៈគំនិតផ្តួចផ្តើមសមាហរណកម្មអន្តរតំបន់ និងក្នុងតំបន់ដូចជា CPTPP និង RCEP។ ទស្សនៈផ្លូវពីររបស់អាស៊ីនេះ ហាក់ដូចជាការឆ្លើយតបសមស្របទៅនឹងការប្រេះស្រាំដែលបន្តប្រែប្រួលនៅក្នុងប្រព័ន្ធពាណិជ្ជកម្មពហុភាគីបច្ចុប្បន្ន។ អភិក្រមផ្លូវពីរនេះគួរតែពង្រឹងការធ្វើសមាហរណកម្មពាណិជ្ជកម្មពិភពលោកតាមមធ្យោបាយមួយ ឬផ្សេងទៀត។

**ផែនទី ១៖ ពាណិជ្ជកម្មអឺរ៉ុប-អាស៊ី**




***ប្រភព:*** *DG Trade ឆ្នាំ២០១៩*

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដែលបកដោយវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិនៃកម្ពុជា (NIDIR)។ អ្នកអានអាចទាញយកអត្ថបទដើមជាភាសាអង់គ្លេសពីគេហទំព័រ៖ https://www.pic.org.kh ។

# ៣.៣ ប្រព័ន្ធពាណិជ្ជកម្មពហុភាគី៖ ទស្សនៈមួយបែបអឺរ៉ុប

## មូលដ្ឋានប្រវត្តិសាស្ត្រ

> “ខណៈពេលដែលកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគីមិនសូវមានភាពស្មុគស្មាញ ប្រទេសដែលចូលរួមក្នុងកិច្ចព្រមព្រៀងនោះនៅតែប្រឈមមុខនឹងភាពតានតឹងជាមូលដ្ឋានរវាងអធិបតេយ្យភាព និងគោលការណ៍នៃសាកលភាវូបនីយកម្ម។”

ប្រព័ន្ធទំនើបនៃពាណិជ្ជកម្មពហុភាគីអាស្រ័យច្បាប់បានចាប់ផ្តើមនៅឆ្នាំ១៩៤១ ក្នុងអំឡុងពាក់កណ្តាលសង្គ្រាមលោកលើកទី២នៅពេលដែលលោកChurchillនិងលោក Roosevelt បានជួបគ្នានៅ Newfoundland ហើយបានធ្វើសេចក្តីថ្លែងការណ៍រួមមួយ ដែលក្រោយមកត្រូវបានគេស្គាល់ថាជាធម្មនុញ្ញអាត្លង់ទិក [១០]។ បើទោះជាមានបញ្ហាក្នុងសម័យសង្គ្រាមក៏ដោយ មាត្រាចំនួន២ ក្នុងចំណោមមាត្រាទាំង៨ (មាត្រា៤ និងមាត្រា៥) នៃធម្មនុញ្ញនេះបានផ្តោតសំខាន់លើពាណិជ្ជកម្ម [១១] ហើយធម្មនុញ្ញនេះបានធ្វើឲ្យមានការផ្តួចផ្តើមបង្កើតស្ថាប័ន ឆ្លងដែនមួយចំនួនរួមមានកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយនិងពាណិជ្ជកម្ម (GATT) និងប្រព័ន្ធ Bretton Woods [១២]។

ក្រោយសង្គ្រាម អឺរ៉ុបមានសមាហរណកម្មជាមួយគ្នាកាន់តែខ្លាំងឡើង ដោយផ្តើមដំបូង ដោយការបង្កើតសហគមន៍ធ្យូងថ្មនិងដែកថែបអឺរ៉ុបនៅឆ្នាំ១៩៥០ និងបន្ទាប់មកការបង្កើតសហគមន៍សេដ្ឋកិច្ចអឺរ៉ុប (European Economic Community) ក្នុងឆ្នាំ១៩៥៧។ ទោះយ៉ាងណា កិច្ចព្រមព្រៀងទាំងនេះ មិនគ្រាន់តែជាឯកសារសេដ្ឋកិច្ចដែលផ្តោតលើការដោះដូរពាណិជ្ជកម្មតែមួយមុខប៉ុណ្ណោះទេ តែវាក៏បង្ហាញពីគុណតម្លៃនយោបាយ និងសីលធម៌មូលដ្ឋានរបស់អឺរ៉ុប និងទំនាក់ទំនងអឺរ៉ុបជាមួយប្រជាជាតិដទៃទៀតផងដែរ។ សេចក្តីប្រកាស Schuman (ដែលនាំឲ្យមានការបង្កើតសហគមន៍ធ្យូងថ្ម និងដែកថែបអឺរ៉ុប) បានលើកឡើងថា“ការអភិវឌ្ឍទ្វីបអាហ្វ្រិក”ជា“ភារកិច្ចដ៏សំខាន់” មួយរបស់អឺរ៉ុប [១២] និងសន្ធិសញ្ញារ៉ូម (ដែលបានបង្កើត EEC) មានផ្នែកមួយទាំងមូល (ផ្នែក ៤) ដែលផ្តោតលើ “ប្រទេស និងទឹកដីនៅបរទេស” [១៣]។

ភស្តុតាងបន្ថែមដែលបង្ហាញថាមានកត្តាផ្សេងទៀតក្រៅពីកត្តាសេដ្ឋកិច្ចបានចូលរួមក្នុងការស្ថាបនាសហភាពអឺរ៉ុប នោះគឺ សហរដ្ឋអាម៉េរិកបានគាំទ្រយ៉ាងខ្លាំងក្នុងការបង្កើត EEC ទោះបីជាសហព័ន្ធគយ (customs union) មួយនេះនឹងបង្កការខាតបង់ផ្នែកសេដ្ឋកិច្ចដល់ជំនួញអាម៉េរិកខណៈពេលដែលខ្លួនគ្មានវត្តមាននៅក្នុងនោះក៏ដោយ។ យោងតាមអគ្គនាយករងអង្គការពាណិជ្ជកម្មពិភពលោកបច្ចុប្បន្នលោក Wolff បានលើកឡើងថា អាម៉េរិក (ដោយផ្នែក) បានគាំទ្រដល់សហគមន៍សេដ្ឋកិច្ចអឺរុបដើម្បី “បង្កើតជាកម្លាំងសេដ្ឋកិច្ចប្រឆាំងនឹងការរីកលូតលាស់របស់សហភាពសូវៀត” [១៤] នេះបញ្ជាក់ឲ្យឃើញថា ឧត្តមគតិនយោបាយមានឥទ្ធិពលជាងការ គិតគូរផ្នែកសេដ្ឋកិច្ច។ ខណៈពេលដែលសហភាពអឺរ៉ុបមានការលូតលាស់ទាំងទំហំ និងសេដ្ឋកិច្ចក្នុងរយៈពេលប៉ុន្មាន ទសវត្សរ៍នេះ គុណតម្លៃនយោបាយនិងសីលធម៌នៅតែជាមូលដ្ឋាននៃទស្សនវិជ្ជាពាណិជ្ជកម្មភាគច្រើនរបស់ខ្លួន។ ជាក់ស្តែងកំណើនសេដ្ឋកិច្ចរបស់សហភាពអឺរ៉ុបបានពង្រឹងបន្ថែមនូវ “ទស្សនាទាននៃតួនាទីរបស់ខ្លួនដែលជាអំណាចបែប “បទដ្ឋាន” និងឈានមុខគេ” [១៥,ទំ.៧៣]។ សហភាពអឺរ៉ុបអនុវត្តអំណាចនេះ ទាំងនៅក្នុងអង្គការ ពាណិជ្ជកម្មពិភពលោក ក៏ដូចជាតាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគី និងពហុភាគីផងដែរ។

> “ខណៈពេលដែលសហភាពអឺរ៉ុបមានការលូតលាស់ទាំងទំហំនិងសេដ្ឋកិច្ចក្នុងរយៈពេលប៉ុន្មានទសវត្សរ៍នេះគុណតម្លៃនយោបាយនិងសីលធម៌នៅតែជាមូលដ្ឋាននៃទស្សនវិជ្ជាពាណិជ្ជកម្មភាគច្រើនរបស់ខ្លួន។”

## អង្គការពាណិជ្ជកម្មពិភពលោក

សហភាពអឺរ៉ុប (ក៏ដូចជារដ្ឋជាសមាជិកទាំងអស់របស់ខ្លួន) គឺជាសមាជិករបស់អង្គការពាណិជ្ជកម្ម ពិភពលោក និងចាត់ទុកថាអង្គការពាណិជ្ជកម្មពិភពលោកជាអ្វីដែល "មិនអាចខ្វះបានក្នុងការធានាឲ្យមានពាណិជ្ជកម្មសេរី និងយុត្តិធម៌" [១៦,ទំ.១]។ សហភាពអឺរ៉ុបចាត់ទុកប្រព័ន្ធអាស្រ័យច្បាប់រឹងមាំ ជាបុរេលក្ខខណ្ឌ សម្រាប់កំណើនប្រកបដោយចីរភាព ពីព្រោះសេដ្ឋកិច្ចសហភាពអឺរ៉ុបបានចូលរួមយ៉ាងស៊ីជម្រៅទៅក្នុងខ្សែសង្វាក់ តម្លៃពិភពលោក (global value chains) ដែលទាមទារឲ្យមានស្ថិរភាព និងភាពដែលអាចព្យាករណ៍បាន [១៦]។ សក្ខីកម្មមួយដែលបង្ហាញពីសមត្ថភាពរបស់ប្រព័ន្ធពាណិជ្ជកម្មពហុភាគីអាស្រ័យច្បាប់ក្នុងការបង្កើតឲ្យមានស្ថិរភាពនោះគឺវិបត្តិហិរញ្ញវត្ថុពិភពលោកឆ្នាំ២០០៨-២០០៩ មិនបាននាំឲ្យមានសង្គ្រាមពាណិជ្ជកម្ម ឬឈានដល់ ការកើនឡើងនៃវិធានការណ៍គាំពារនិយម ដូចវិបត្តិកាលពីទសវត្សរ៍ឆ្នាំ១៩៣០ ឡើយ [១៦, ១៧, ១៨]។

ទោះជាយ៉ាងនេះក៏ដោយ មួយទសវត្សរ៍ក្រោយមក ប្រព័ន្ធពាណិជ្ជកម្មពហុភាគីអាស្រ័យលើច្បាប់ហាក់ ដូចជាកំពុងប្រឈមនឹងបញ្ហា ជាមួយនឹងការកើនឡើងនូវការគំរាមកំហែងនៃវិធានការណ៍បែបគាំពារនិយម ឯកតោភាគី ដូចជាសង្គ្រាមពាណិជ្ជកម្មរវាងអាមេរិកនិងចិន និងការគំរាមកំហែងពីអាមេរិកក្នុងការដកខ្លួនចេញពី អង្គការពាណិជ្ជកម្មពិភពលោក [១៦, ១០]។ ប្រព័ន្ធដោះស្រាយវិវាទ (Dispute Settlement System) ដែល សហភាពអឺរ៉ុបចាត់ទុកថាជា "ត្បូងនៃមកុដ" របស់អង្គការពាណិជ្ជកម្មពិភពលោក [១៩, ទំ.២] កំពុងប្រឈមនឹងការ ដួលរលំនៅពេលដែលអាមេរិកកំពុងរារាំងការតែងតាំងតំណាងថ្មីទៅកាន់ស្ថាប័នឧទ្ធរណ៍ (Appellate Body) ដែល បានបង្កើតឲ្យមានភាពជាប់គាំង [១៩]។ ការរារាំងពីសំណាក់អាមេរិកនេះគឺដោយសារតែកង្វល់មួយចំនួន ដែលខ្លួនមានចំពោះអង្គការពាណិជ្ជកម្មពិភពលោក និង"អភិក្រមសកម្មនៃស្ថាប័នឧទ្ធរណ៍" (activist approach of the Appellate Body)

> "សហភាពអឺរ៉ុបចាត់ទុកប្រព័ន្ធអាស្រ័យច្បាប់រឹងមាំជាបុរេលក្ខខណ្ឌសម្រាប់កំណើនប្រកបដោយចីរភាពពីព្រោះសេដ្ឋកិច្ចសហភាពអឺរ៉ុបបានចូលរួមយ៉ាងស៊ីជម្រៅទៅក្នុងខ្សែសង្វាក់តម្លៃពិភពលោកដែលទាមទារឲ្យមានស្ថិរភាព និងភាពដែលអាចព្យាករណ៍បាន។"

[២០, ទំ.២៨] ដែលក្នុងនោះចំណុចសំខាន់ (និងស្មុគស្មាញបំផុត) គឺទាក់ទងនឹងភាពតានតឹង រវាងអធិបតេយ្យភាពរបស់អាមេរិក និងយុត្តាធិការជាសកលរបស់អង្គការពាណិជ្ជកម្មពិភពលោក។ អាមេរិកជំទាស់ ការដែលស្ថាប័នឧទ្ធរណ៍ពិនិត្យច្បាប់ក្នុងស្រុករបស់ខ្លួនឡើងវិញ និងការដែលស្ថាប័នឧទ្ធរណ៍ចាត់ទុករបាយការណ៍ របស់ខ្លួនជាគំរូសម្រាប់ការអនុវត្តទៅថ្ងៃអនាគត [២០]។

បន្ថែមលើបញ្ហាជាមួយស្ថាប័នឧទ្ធរណ៍ ការជាប់គាំងដែលបានកើតឡើងបន្ទាប់ពីរបៀបវារៈអភិវឌ្ឍន៍ដូហា (ឬហៅថា កិច្ចចរចា Doha Round ឆ្នាំ២០០១ តទៅក្នុងឯកសារនេះហៅកាត់ថា DDA) បាននាំឲ្យមានការកើនឡើងទ្វេភាគីនិយម នៅពេលដែលសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ព្យាយាមបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មក្រៅប្រព័ន្ធពហុភាគីរបស់អង្គការពាណិជ្ជកម្មពិភពលោក [១៩]។ ផ្នែកមួយនៃហេតុផលសម្រាប់ការជាប់ គាំងបច្ចុប្បន្នគឺ "អភិក្រមអនុវត្តទាំងស្រុង (Single Undertaking Approach)" របស់អង្គការពាណិជ្ជកម្មពិភពលោក ដែលមានន័យថាកិច្ចព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មពិភពលោក (ដូចជា DDA) ត្រូវតែអនុម័តទាំងស្រុង បើមិនដូច្នេះទេ គឺមិនអនុម័តតែម្តង ហើយក៏គ្មានជម្រើសក្នុងការជ្រើសអនុម័តតែបទបញ្ញត្តិជាក់លាក់ ណាមួយឡើយ [២១]។ ការពន្យល់មួយទៀតលើការបរាជ័យនៃ DDA គឺជាការបែងចែកភាគខាងជើង-ខាងត្បូង ដោយប្រទេសអភិវឌ្ឍន៍នៅភាគខាងជើងមើលឃើញថា ការផ្តល់ទីផ្សារជាហានិភ័យសេដ្ឋកិច្ចដែលគួរតែមានការសម្របសម្រួលពីអ្នកទទួលផល តែប្រទេសកំពុងអភិវឌ្ឍន៍នៅភាគខាងត្បូងស្តីបន្ទោសផ្នត់គំនិតបែបពាណិជ្ជកម្មនេះ ហើយផ្ទុយទៅវិញមើលឃើញថា DDA ជាផ្លូវមួយដើម្បីផ្លាស់ប្តូរច្បាប់មិនយុត្តិធម៌មានស្រាប់ដែលកំណត់ដោយ ប្រទេសអភិវឌ្ឍន៍ [១៨]។ បញ្ហានេះកាន់តែស្មុគស្មាញដោយសារតែទស្សនាទានចាស់របស់អង្គការពាណិជ្ជកម្មពិភពលោក ដែលយល់ថាប្រទេសបែកចេញជាប្រទេសអភិវឌ្ឍន៍ ឬកំពុងអភិវឌ្ឍន៍ (ឬមានការអភិវឌ្ឍតិចតួចបំផុត) កំពុងក្លាយជាទស្សនៈដែលហួសសម័យ ស្របពេលប្រទេស BRIC [A] រីកចម្រើនរហូតធ្វើឲ្យប្រទេស អភិវឌ្ឍន៍លែងចង់ផ្តល់សម្បទាននានា ដែលមិនទទួលបានអ្វីតបស្នងពីប្រទេសទាំងនោះវិញសោះ [១៧]។

ខណៈពេលដែលសភាអឺរ៉ុបនៅតែចាត់ទុកអង្គការពាណិជ្ជកម្មពិភពលោកជាជម្រើសល្អបំផុតសម្រាប់ពាណិជ្ជកម្មអន្តរជាតិ [១៩] សហភាពអឺរ៉ុបកំពុងព្យាយាមកែទម្រង់អង្គការនេះ ក្នុងនោះរួមមានតាមរយៈការពង្រឹងយន្តការ

អនុវត្តការផ្តល់អំណាចបន្ថែមឲ្យគណៈកម្មាធិការនានាដើម្បីផ្លាស់ប្តូរវិធាន និងការដោះស្រាយកង្វល់ របស់អាម៉េរិក អំពីស្ថាប័នឧទ្ធរណ៍ [១៦]។ ទោះយ៉ាងណា ខណៈពេលដែលអាម៉េរិកបាននិងកំពុងធ្វើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTAs) មួយចំនួនរបស់ខ្លួន សហភាពអឺរ៉ុបមិនបានអង្គុយស្ងៀមនោះទេ ផ្ទុយទៅវិញនៅក្នុងឆ្នាំ២០០៦ សហភាពអឺរ៉ុបបានបំពានការហាមឃាត់របស់ខ្លួនក្នុងការបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មថ្មី ហើយបានបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាច្រើន ដែលក្នុងនោះមួយចំនួនធ្វើជាមួយប្រទេសអភិវឌ្ឍន៍[១៧]។"ពាណិជ្ជកម្មសម្រាប់ទាំងអស់គ្នា" (Trade for All) គឺជាឯកសារគោលនយោបាយពីឆ្នាំ២០១៥ធ្វើដោយស្នងការពាណិជ្ជកម្មអឺរ៉ុប (ឬពីមុនហៅថា Cecilia Malmström) បានបញ្ជាក់ថាកិច្ចព្រមព្រៀងពាណិជ្ជកម្ម សេរីត្រូវតែជាការចាំបាច់ អមជាមួយនឹងកិច្ចព្រមព្រៀងពហុភាគីរបស់អង្គការពាណិជ្ជកម្មពិភពលោក។ កិច្ចព្រមព្រៀងពហុភាគីអាចមានឥទ្ធិពលធំជាងនេះ ប៉ុន្តែក៏មានលក្ខណៈស្មុគស្មាញផងដែរ ហើយគណៈកម្មការអឺរ៉ុបជឿជាក់ថា ការបង្រួបបង្រួមបទប្បញ្ញត្តិធ្វើឲ្យមានភាពងាយស្រួលក្នុងការសម្រេចបានតាមរយៈការចរចាទ្វេភាគី [២២]។ ទស្សនវិជ្ជានេះហាក់ដូចជាបានអនុវត្តនៅក្នុងអាស៊ាន ប៉ុន្តែអំឡុងពេលដែលមានការចរចាទ្វេភាគីរវាងតំបន់ ជាមួយអាស៊ាន ការចរចានោះក្លាយជាមានភាពស្មុគស្មាញខ្លាំងទៅវិញ។ ចាប់តាំងពីពេលនោះមក សហភាពអឺរ៉ុប បានធ្វើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីជាមួយសិង្ហបុរីនិងវៀតណាម ហើយកំពុងចរចាជាមួយសមាជិក អាស៊ានទាំងអស់ (លើកលែងអនាគតសមាជិក-ទីម័រខាងកើត)។ សេរីភាវូបនីយកម្មពាណិជ្ជកម្ម ហាក់មានភាព បន្ទាន់និងមានសារៈសំខាន់ខ្លាំង ដែលសហភាពអឺរ៉ុបហាក់មិនអាចរង់ចាំរហូតដល់បញ្ហានៃប្រព័ន្ធអង្គការ ពាណិជ្ជកម្មពិភពលោកត្រូវបានដោះស្រាយ [១៥]។

## អធិបតេយ្យភាព និងពិភពពាណិជ្ជកម្មបែបថ្មី

បញ្ហាមួយចំនួននៃអង្គការពាណិជ្ជកម្មពិភពលោកបានផ្តើមចេញពីភាពតានតឹងរវាងតម្រូវការរបស់រដ្ឋនានាដើម្បីរក្សាអធិបតេយ្យភាព និងតម្រូវការនៃប្រព័ន្ធពហុភាគីដែលមានច្បាប់ដើម្បីគ្រប់គ្រងពាណិជ្ជកម្មរវាងប្រទេស។ យោងតាមគំរូរដ្ឋប្រជាជាតិ Westphalian ប្រទេសមានអធិបតេយ្យភាពពេញលេញទាំងស្រុងលើអ្វី ដែលកើតឡើងក្នុងព្រំដែនរបស់ខ្លួន។ គំរូនេះកាន់តែពិបាកក្នុងការរក្សានៅក្នុងពិភពសកលភាវូបនីយកម្ម ដែលផលិតផលត្រូវបានផលិតនៅក្នុងប្រទេសប្រាំឬប្រាំមួយផ្សេងគ្នា (ដោយក្រុមហ៊ុនដែលចុះឈ្មោះនៅក្នុងប្រទេសតែមួយរួមគ្នា)។ ខណៈពេលដែលកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគីមិនសូវមានភាពស្មុគស្មាញ ប្រទេសដែលចូលរួមក្នុងកិច្ច ព្រមព្រៀងនោះនៅតែប្រឈមមុខនឹងភាពតានតឹងជាមូលដ្ឋានរវាងអធិបតេយ្យភាព និងគោលការណ៍សាកលភាវូបនីយកម្ម។

លោក Pascal Lamy អតីតអគ្គនាយកនៃអង្គការពាណិជ្ជកម្មពិភពលោក និងជាអតីតស្នងការសហភាព អឺរ៉ុបសម្រាប់ពាណិជ្ជកម្មបានចាត់ទុក ហើយហៅបញ្ហានេះជា "ពិភពពាណិជ្ជកម្មចាស់" ធៀបនឹង "ពិភពពាណិជ្ជកម្មថ្មី" ដោយពិភពលោកបច្ចុប្បន្នកំពុងស្ថិតក្នុងដំណាក់កាលផ្លាស់ប្តូររវាងពិភពទាំងពីរ [១៧, ២៣, ២៤]។

នៅក្នុងទស្សនាទាននេះ "ពិភពលោកបែបចាស់" គឺជាទស្សនាទានដែលអ្នកបង្កើតគោលនយោបាយ ព្យាយាមការពារផលិតករក្នុងស្រុកពីការប្រកួតប្រជែងពីខាងក្រៅតាមរយៈវិធានការណ៍គាំពារនិយម (ដូចជាពន្ធ គយនិងកូតាជាដើម)។ នៅក្នុងពិភពលោកបែបនេះ ការចរចាពាណិជ្ជកម្មគឺមានអត្ថន័យដោយត្រង់ៗ ពោលគឺការធ្វើពាណិជ្ជកម្មបែបបើកចំហមានន័យថា កាត់បន្ថយឬដកចេញនូវវិធានការណ៍គាំពារនិយមដែលអាចផ្តល់នូវសម្បទានទៅវិញទៅមកណាមួយ (ប្រសិនបើប្រទេស A កាត់បន្ថយពន្ធគយលើផលិតផល X នោះប្រាសមក វិញប្រទេស B អាចកាត់បន្ថយពន្ធគយលើផលិតផល Y) ហើយគោលដៅចុងក្រោយគឺពន្ធគយស្មើសូន្យ (ឧទាហរណ៍ដូចជាមិនមានពន្ធគយឬកូតាជាដើម)។ ផ្ទុយមកវិញនៅក្នុង "ពិភពលោកបែបថ្មី" ការគាំពារនិយម គឺ មិនមានប្រយោជន៍ទេ ព្រោះវាធ្វើឲ្យប៉ះពាល់ដល់សង្វាក់ផលិតកម្មពិភពលោកដែលផលិតករក្នុងស្រុកជាផ្នែកមួយក្នុងនោះផងដែរ។ ការគាំពារនិយមនេះត្រូវបានជំនួសដោយការប្រុងប្រយ័ត្ន ពោលគឺអ្នករៀបចំគោលនយោបាយ ព្យាយាមការពារអ្នកប្រើប្រាស់ (ជាជាងអ្នកផលិត) ដោយកំណត់បទបញ្ញត្តិនិងបទដ្ឋានរបស់ទំនិញនិងសេវាកម្ម ដែលដាក់លក់នៅលើទីផ្សារក្នុងស្រុក។ ការលុបបំបាត់ភាពខុសគ្នានៅក្នុងបទបញ្ញត្តិ គឺជាផ្នែកសំខាន់មួយនៃការធ្វើពាណិជ្ជកម្មបើកចំហនៅក្នុងពិភពលោកបែបថ្មីនេះ។ ទោះយ៉ាងណាបទបញ្ញត្តិមិនអាចត្រូវដោះដូរបានងាយស្រួលដូចពន្ធគយនោះទេ ដោយហេតុថា ប្រទេសមួយចំនួនទំនងជាមិនបន្ទាបបទប្បញ្ញត្តិសុខភាព និងសុវត្ថិភាព ដើម្បីជាថ្នូរនឹងដៃគូពាណិជ្ជកម្មឡើយ។ ការចរចាពាណិជ្ជកម្មនៅក្នុងពិភពលោកបែបចាស់គឺទាញ (ការគាំពារនិយម) ឲ្យធ្លាក់ចុះ ឯនៅក្នុងពិភពលោកបែបថ្មីគឺ ទាញ (ការប្រុងប្រយ័ត្ន) ឲ្យកើនឡើង [២៣, ២៤]។

វិធីនៃការធ្វើពាណិជ្ជកម្មបែបទំនើបនេះនឹងពន្យល់ពីភាពស្មុគស្មាញនៃប្រព័ន្ធពាណិជ្ជកម្មពហុភាគីអាស្រ័យច្បាប់។ ខណៈពេលដែលបណ្ដាប្រទេសអាចបន្ទាបបទដ្ឋាន (ហើយអ្នកផលិតប្រហែលជាគាំទ្រលើការអនុវត្តបែបនេះ) អ្នកប្រើប្រាស់ និងក្រុមការពារអ្នកប្រើប្រាស់នឹងជំទាស់បះបោរ ដូចនេះគ្មានប្រទេសណាអាចធ្វើបែបនេះទេ បើខ្លួនចង់រក្សាធម្មានុរូបភាពតាមបែបប្រជាធិបតេយ្យ។ ពន្ធគយនិងកូតាមិនមានគុណតម្លៃជាបទដ្ឋានទេ ប៉ុន្តែវិធានការណ៍បង្ការទុកជាមុន (ឧទាហរណ៍ដូចជាបទប្បញ្ញត្តិជាដើម) គឺជាការគ្រប់គ្រងហានិភ័យនិងជាការទទួលយកគុណតម្លៃធំធេង (value-laden) [២៣, ២៤]។ ដោយសារគុណតម្លៃទទួលឥទ្ធិពលពីវប្បធម៌ ហើយប្រទេសផ្សេងគ្នាមានវប្បធម៌ខុសៗគ្នា ការធ្វើពាណិជ្ជកម្មបើកចំហនៅក្នុងពិភពលោកថ្មី (ឧទាហរណ៍ដូចជាការធ្វើសុខដុមនីយកម្មនៃបទប្បញ្ញត្តិជាដើម) បានក្លាយជាបញ្ហាដ៏លំបាកមួយ (Gordian knot) [១៧]។

សារៈសំខាន់នៃធម្មានុរូបភាពតាមបែបប្រជាធិបតេយ្យត្រូវបានកត់សម្គាល់ដោយសហភាពអឺរ៉ុបក្នុងអំឡុងពេលនៃកិច្ចចរចាភាពជាដៃគូពាណិជ្ជកម្មនិងវិនិយោគអាត្លង់ទិក (Transatlantic Trade and Investment Partnership, TTIP)។ គោលបំណងនៃ TTIP គឺការរួមបញ្ចូលគ្នានៃក្របខ័ណ្ឌគតិយុត្តិរបស់សហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក ប៉ុន្តែទោះបីភាគីទាំងពីរមានបទដ្ឋានខ្ពស់រួចហើយក៏ដោយ ក៏វាហាក់បញ្ជាក់ឲ្យឃើញថា មានភាពស្មុគស្មាញខ្លាំងនៅក្នុងការចុះសម្រុងគ្នា។ លើសពីនេះទៀតពលរដ្ឋអឺរ៉ុបជាច្រើនយល់ឃើញថា TTIP ជាការគំរាមកំហែងដល់គំរូបទបញ្ញត្តិរបស់សហភាពអឺរ៉ុប ដែលត្រូវបានប្រើក្នុងសុន្ទរកថាជាសាធារណៈនៃការតវ៉ាប្រឆាំង "ការសម្អាតមាន់ដោយប្រើទឹកក្លរ" (chlorinated chicken) ដែលមានការអនុញ្ញាតិឲ្យលក់នៅសហរដ្ឋអាមេរិក តែត្រូវបានហាមឃាត់នៅសហភាពអឺរ៉ុប [២៥]។ ឯកសារគោលនយោបាយ "ពាណិជ្ជកម្មសម្រាប់ទាំងអស់គ្នា" ដែលបានរៀបរាប់ខាងលើបានចេញផ្សាយនៅឆ្នាំ២០១៥ ប៉ុន្តែដោយសារការរិះគន់ជាសាធារណៈអំពី TTIP កំពុងឡើងដល់កម្រិតកំពូល បានធ្វើឲ្យការចរចារបស់ TTIP ឈានទៅរកការជួលលំ (ការចរចាបានបញ្ចប់ក្នុងឆ្នាំ២០១៦ ហើយក្រុមប្រឹក្សាសហភាពអឺរ៉ុបបានចេញសេចក្ដីណែនាំថាការចរចានេះផុតកំណត់នៅឆ្នាំ២០១៩ [២៦])។ នៅក្នុង "ពាណិជ្ជកម្មសម្រាប់ទាំងអស់គ្នា" គណៈកម្មការសហភាពអឺរ៉ុបបានលើកឡើងពីអ្វីដែលបានរៀនពីបញ្ហានេះ ហើយបានប្ដេជ្ញាថា នឹងមានតម្លាភាពថែមទៀតក្នុងការចរចាពាណិជ្ជកម្មនាពេលអនាគតដោយធ្វើសេចក្ដីណែនាំស្ដីពីការចរចា និងលទ្ធផលជាសាធារណៈឲ្យទាន់ពេលវេលា [២២]។

## គុណតម្លៃ និងភាពអនុគ្រោះរបស់សហភាពអឺរ៉ុប

ដូចដែលបានបញ្ជាក់ខាងលើសហភាពអឺរ៉ុបបានដាក់បញ្ចូលគ្នានូវគោលនយោបាយពាណិជ្ជកម្មជាមួយនឹងអំណាចបទដ្ឋាន និងបំណងក្នុងការអភិវឌ្ឍពិភពលោក។ ឧទាហរណ៍នៃគោលការណ៍នេះគឺ "ប្រព័ន្ធអនុគ្រោះទូទៅ" (General System of Preferences) ដែលកាត់បន្ថយឬដកពន្ធគយលើការនាំចូលផលិតផលពីបណ្ដាប្រទេសកំពុងអភិវឌ្ឍន៍ ក៏ដូចជាប្រព័ន្ធអនុគ្រោះពន្ធគ្រប់មុខទំនិញលើកលែងតែសព្វាវុធ (Everything But Arms) ដែលដកចេញនូវកាតព្វកិច្ចនិងកូតាទាំងអស់ (លើកលែងតែសព្វាវុធ) សម្រាប់ប្រទេសមានការអភិវឌ្ឍតិចតួចបំផុតចំនួន៤៩ [១៧]។ ឯកសារគោលនយោបាយអឺរ៉ុបបានលើកឡើងយ៉ាងច្បាស់ពីសារៈសំខាន់នៃការអនុវត្ត "យុត្តិធម៌សង្គម ការគោរពសិទ្ធមនុស្ស បទដ្ឋានការងារខ្ពស់ និងបរិស្ថាន និងការការពារសុខភាពនិងសុវត្ថិភាព" តាមរយៈគោលនយោបាយពាណិជ្ជកម្ម [២២, ទំ.២២]។

អ្នកសិក្សាខ្លះបានជំទាស់ថាភាសាដែលជាបទដ្ឋាននៅក្នុងឯកសារគោលនយោបាយរបស់សហភាពអឺរ៉ុប គឺគ្រាន់តែជាកិច្ចសន្ទនាដែលគ្មានខ្លឹមសារជាមួយនឹងការរំលេចពីតថភាពតិចតួចដែលប្រែប្រួលឡើងឬចុះ អាស្រ័យលើអ្នកណាជាស្នងការសហភាពអឺរ៉ុបសម្រាប់ពាណិជ្ជកម្ម [១៥]។ ទោះយ៉ាងណា នៅក្នុងគណៈកម្មការសហភាពអឺរ៉ុប កិច្ចសន្ទនាអំពី "ការតម្រង់គោលនយោបាយពាណិជ្ជកម្មជាមួយនឹងគុណតម្លៃរបស់អឺរ៉ុប" [២២, ទំ.២៤] ហាក់ដូចជាមានឥទ្ធិពលពិតប្រាកដនៅក្នុងអាស៊ាន។ ការចូលរួមរបស់សហភាពអឺរ៉ុបក្នុងគំនិតផ្ដួចផ្ដើម ដើម្បីលើកកម្ពស់សិទ្ធិការងារ និងការអនុវត្តការងារជាមូលដ្ឋាននៅប្រទេសមីយ៉ាន់ម៉ាត្រូវបានលើកឡើងនៅក្នុង "ពាណិជ្ជកម្មសម្រាប់ទាំងអស់គ្នា" ដែលជាមធ្យោបាយនៃ "ការគ្រប់គ្រងប្រកបដោយទំនួលខុសត្រូវលើខ្សែសង្វាក់ផ្គត់ផ្គង់ជាសកល" [២២] ។ ការដកផ្នែកខ្លះនៃប្រព័ន្ធអនុគ្រោះពន្ធ EBA សម្រាប់កម្ពុជាបន្ទាប់ពីគណៈកម្មការសហភាពអឺរ៉ុបបានសម្រេចថា រាជរដ្ឋាភិបាលកម្ពុជាមិនបានអនុវត្តគ្រប់គ្រាន់ដើម្បីបន្ធូរបន្ថយ "កង្វល់ធ្ងន់ធ្ងរ" លើករណីមិនទាន់ដោះស្រាយដែលពាក់ព័ន្ធនឹងសហជីពកម្មករ [២៨] គឺជាឧទាហរណ៍មួយរបស់សហភាពអឺរ៉ុបដែលប្រើប្រាស់គោលនយោបាយពាណិជ្ជកម្មជាឧបករណ៍នយោបាយ។

ទោះជាយ៉ាងណា គោលនយោបាយបែបនេះហាក់មិនសូវមានប្រសិទ្ធភាព នៅពេលដែលពិភពលោកឈានទៅរកការធ្វើពាណិជ្ជកម្មនៃពិភពលោកមួយដែល លោក Lamy ឲ្យឈ្មោះថា“ពិភពលោកបែបថ្មី”ហើយប្រព័ន្ធអនុគ្រោះពន្ធ EBA និងប្រព័ន្ធអនុគ្រោះផ្សេងទៀត (ឬការបដិសេធមិនផ្តល់ប្រព័ន្ធទាំងនេះ) កាន់តែពិបាកបង្ហាញឲ្យឃើញថាសមហេតុផល នៅក្នុងពិភពលោកបែបថ្មីនេះ។ គេមិនអាចផ្តល់អត្ថប្រយោជន៍នៃបទបញ្ញត្តិដល់អ្នកផលិតមកពីប្រទេសមួយចំនួន និងមិនផ្តល់ដល់អ្នកផលិតមកពីប្រទេសដទៃទៀតទេ ព្រោះវានឹងធ្វើឲ្យផ្ទុយគោលបំណងទាំងមូលនៃបទបញ្ញត្តិជាប្រព័ន្ធ (ឧទាហរណ៍ដូចជាការគ្រប់គ្រងហានិភ័យសម្រាប់អ្នកប្រើប្រាស់ជាដើម) [២៣,២៤]។ ជាលទ្ធផលខណៈដែលកិច្ចព្រមព្រៀងពាណិជ្ជកម្មទាំងអស់របស់សហភាពអឺរ៉ុបក្នុងទសវត្សរ៍ចុងក្រោយមានជំពូកមួយស្តីពី “ការអភិវឌ្ឍប្រកបដោយចីរភាព” [១៥] សម្ពាធបទដ្ឋានខាងក្រៅ (external normative pressure) ធ្វើឲ្យពិបាកក្នុងការអនុវត្តគោលនយោបាយពាណិជ្ជកម្ម ហើយជំពូកទាំងនោះមានហានិភ័យក្នុងការក្លាយជាកិច្ចសន្ទនាដែលមិនអាចប្រតិបត្តិបាន។

## តួនាទីរបស់សហភាពអឺរ៉ុបនាពេលអនាគតក្នុងពាណិជ្ជកម្មដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាបន្ន

សហភាពអឺរ៉ុបនឹងនៅតែជាអ្នកគាំទ្រយ៉ាងខ្លាំងនៃប្រព័ន្ធពាណិជ្ជកម្មពហុភាគីអាស្រ័យច្បាប់ដ៏រឹងមាំ។ សេដ្ឋកិច្ចរបស់សហភាពអឺរ៉ុបត្រូវបានធ្វើសមាហរណកម្មយ៉ាងស៊ីជម្រៅទៅក្នុងខ្សែសង្វាក់តម្លៃជាសកលដែលធ្វើឲ្យខ្លួនមិនអាចមិនគាំទ្រប្រព័ន្ធនេះបាន។ ទោះជាយ៉ាងណា ដរាបណាអង្គការពាណិជ្ជកម្មពិភពលោកនៅតែស្ថិតក្នុងជំហរជាប់គាំងមួយដែលខ្លួនមិនអាចអភិវឌ្ឍកិច្ចព្រមព្រៀងថ្មី ឬតែងតាំងសមាជិកថ្មីទៅកាន់ស្ថាប័នឧទ្ធរណ៍ សហភាពអឺរ៉ុបទំនងជានឹងនៅតែបន្តពង្រីកកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី និងពហុភាគី។

លើសពីនេះទៀតខណៈពេលដែលគុណតម្លៃបទដ្ឋាននៅតែមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងរាល់កិច្ចព្រមព្រៀងពាណិជ្ជកម្មថ្មីរបស់សហភាពអឺរ៉ុប ការអនុវត្តទិដ្ឋភាពបទដ្ឋាននៃកិច្ចព្រមព្រៀងនេះក៏ប្រហែលជាការអនុវត្តតែខាងក្រៅប៉ុណ្ណោះ។

ទីបំផុត (អំឡុងពេលសរសេរអត្ថបទនេះ) ការចរចា Brexit ដែលកំពុងបន្តនិងការរះឡើងនៃការរិះគន់លើសហភាពអឺរ៉ុបនិងសមាហរណកម្មរបស់ខ្លួន (Euroscepticism) (ក្រុមសមាជិកសភាដែលរិះគន់លើសហភាពអឺរ៉ុប “អត្តសញ្ញាណនិងប្រជាធិបតេយ្យ” ពេលនេះមាន ៧៦ ក្នុងចំណោម ៧០៥ អាសនៈនៅក្នុងសភានៃសហភាពអឺរ៉ុបបន្ទាប់ពីសមាជិកសភាអង់គ្លេសបានចាកចេញ) ធ្វើឲ្យជំហររបស់សហភាពអឺរ៉ុបមានភាពមិនច្បាស់លាស់។ សហភាពអឺរ៉ុបទំនងជាចង់រក្សាចក្រភពអង់គ្លេសនៅក្នុងបរិវេណបទប្បញ្ញត្តិរបស់ខ្លួន។ ស្របពេលនេះដែរ ដូចដែលកំហឹងសាធារណៈជុំវិញ TTIP បានបង្ហាញថា សហភាពអឺរ៉ុបមិនមានលទ្ធភាពបង្កើតកិច្ចព្រមព្រៀងទ្វេភាគី ដែលត្រូវការការកែទម្រង់បទប្បញ្ញត្តិដោយគ្មានតម្លាភាពនិងការចូលរួមតាមបែបប្រជាធិបតេយ្យទេ ប្រសិនបើចង់ឲ្យការរិះគន់លើសហភាពអឺរ៉ុបនិងសមាហរណកម្មនៅនឹងមួយកន្លែង។

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដែលបកដោយវិទ្យាស្ថានសភាកម្ពុជា (PIC)។
អត្ថបទដើមជាភាសាអង់គ្លេសអាចទាញយកពីគេហទំព័រ៖ https://www.pic.org.kh ។

## FOOTNOTES

A. ប្រទេស BRIC (ប្រេស៊ីល រុស្ស៊ី ឥណ្ឌា និងចិន ឧទាហរណ៍ដូចជា បណ្ដាប្រទេសដែលកំពុងនឹងក្លាយជាប្រទេសអភិវឌ្ឍន៍)

## REFERENCES


១. WTO. (N/A). What is the WTO [Online]. Geneva: WTO. Available at: https://www.wto.org/english/thewto_e/whatis_e/whatis_e.htm [Accessed 15 Jan 2020].

២. Economic Online. (N/A). Why do countries trade? [Online]. Economics Online. Available at: http://www.economicsonline.co.uk/Global_economics/Why_do_countries_trade.html [Accessed 07 Jan 2020].

៣. ASEAN. (N/A). ASEAN Economic Community [Online]. ASEAN. Available at: https://asean.org/asean-economic-community/ [Accessed 07 Jan 2020].

៤. WTO, (2019). World Trade Statistical Review 2019. Geneva: WTO, Available at: https://www.wto.org/english/res_e/statis_e/wts2019_e/wts2019_e.pdf.

៥. WTO. (2019). WTO Lowers Trade Forecast as Tensions Unsettle Global Economy [Online]. Geneva: WTO. Available at: https://www.wto.org/english/news_e/pres19_e/pr840_e.htm [Accessed 07 Jan 2020].

៦. Harte, R., (2018). Multilateralism in international trade. Reforming the WTO. European Parliament

៧. Inter-Parliamentary Union. (2018). 2018 Annual Session of the parliamentary Conference on the WTO. Highlight of the Session. WTO: The Way Forward. Geneva.

៨. Basedow, R. (2018) „Strengthening the World Trade Organisation„, Bertelsmann Stiftung, Gütersloh.

៩. Panagariya, Arvind (2018). President Donald Trump's Trade War: Multilateralism at Risk, Working Paper no. 2018-03, Columbia University (Deepak and Neera Raj Center on Indian Economic Policies (SIPA), 23 August.

១០. Nottage, H. (2018). Trade in War's Darkest Hour: Churchill and Roosevelt's Daring 1941 Atlantic Meeting that Linked Global Economic Cooperation to Lasting Peace and Security. Victoria University of Wellington Law Review, 49(4), pp. 595-606, Available at: https://doi.org/10.26686/vuwlr.v49i4.5342 [Accessed 27 February 2020].

១១. Atlantic Charter. (1941). [online] Available at: https://www.unmultimedia.org/searchers/yearbook/page.jsp?volume=1946-47&page=37&searchType=advanced [Accessed 27 February 2020].

១២. The Schuman Declaration. (1950). [online] Available at: https://europa.eu/european-union/about-eu/symbols/europe-day/schuman-declaration_en [Accessed 27 February 2020].

១៣. Treaty of Rome. (1950). [online]. CM3/NEGO, opened for signatire 25 March 1957, entered into force 1 January 1958. Available at: https://www.europarl.europa.eu/about-parliament/en/in-the-past/the-parliament-and-the-treaties/treaty-of-rome [Accessed 27 February 2020].

១៤. Wolff, A. (2018). DDG Wolff: Trade and foreign policy have always been intertwined. [online] Available at: https://www.wto.org/english/news_e/news18_e/ddgra_09feb18_e.htm [Accessed 27 February 2020].

១៥. Orbie, J. and Martens, D. (2016) EU Trade Policy and Developing Countries: Towards a more Ethical Agenda? In: P. Garcia-Duran and M. Millet, ed., Different Glances at EU Trade Policy, Barcelona: CIDOB, pp. 73-82.

១៦. EU Commission (2018). EU concept paper on WTO reform. [online] Available at: https://trade.ec.europa.eu/doclib/docs/2018/september/tradoc_157331.pdf [Accessed 27 February 2020].

១៧. Jara, A. (2016) EU Trade Policy in the Multilateral Trading System. In: P. Garcia-Duran and M. Millet, ed., Different Glances at EU Trade Policy, Barcelona: CIDOB, pp. 11-22.

១៨. Cho, S. (2010). The Demise of Development in the Doha Round Negotiations. Texas International Law Journal, 45, pp. 573-601.

១៩. Edward, R. and Harte, N. (2018) Multilateralism in international trade: Reforming the WTO. [online] European Parliamentary Research Service. Available at: https://www.europarl.europa.eu/thinktank/en/document.html?reference=EPRS_BRI(2017)603919 [Accessed 27 February 2020].

២០. US Trade Representative (2018) The President's Trade Policy Agenda. [online] US Trade Representative (USTR). Available at: https://ustr.gov/sites/default/files/files/Press/Reports/2018/AR/2018%20Annual%20Report%20I.pdf [Accessed 27 February 2020].

២១. Dickinson, E.M. (2013). The Doha Development Dysfunction: Problems of the WTO Multilateral Trading System. Global Business Law Review, 3(2), pp. 229-250.

២២. European Commission (2015). Trade for All: Towards a more responsible trade and investment policy. [online] European Union. Available at: https://trade.ec.europa.eu/doclib/docs/2015/october/tradoc_153846.pdf [Accessed 27 February 2020].

២៣. Lamy, P. (2015). The new world of trade: The third Jan Tumlir Lecture, Jan Tumlir Policy Essays, No. 01/2015, Brussels: European Centre for International Political Economy(ECIPE). Available at: http://hdl.handle.net/10419/174861 [Accessed 27 February 2020].

២៤. Lamy, P. (2015). Colloquium on Business and Society: A Conversation with Pascal Lamy, Former Director General World Trade Organization. [video] Yale School of Management. Available at: https://www.youtube.com/watch?v=QOOBQhTE57o [Accessed 27 February 2020].

២៥. Lawrence, F. (2020). Why chlorinated chicken is centre of the table in UK-EU talks. The Guardian, [online]. Available at: https://www.theguardian.com/politics/2020/feb/25/why-chlorinated-chicken-is-centre-of-the-table-in-uk-eu-talks [Accessed 27 Feb 2020].

២៦. Council of the European Union (2019). COUNCIL DECISION authorising the opening of negotiations with the United States of America for an agreement on the elimination of tariffs for industrial goods. 6052/19. Available at: https://www.consilium.europa.eu/media/39180/st06052-en19.pdf [Accessed 27 Feb 2020].

២៧. Fontaine, P. (2014) Europe in 12 lessons. Brussels: European Commission.

២៨. European Commission, (2020). Trade/Human Rights: Commission decides to partially withdraw Cambodia's preferential access to the EU market. [online] Available at: https://ec.europa.eu/commission/presscorner/detail/en/ip_20_229 [Accessed 27 February 2020].


## BIBLIOGRAPHY


Basedow, Robert (2017). Strengthening the World Trade

Organization – Critical Demands for Imperative Success, Global Economic Dynamics, Bertelsmann-Stiftung, 27 April (https://www.bertelsmann-stiftung.de/fileadmin/files/BSt/Publikationen/GrauePublikationen/MT_Strengthening_the_WTO.pdf

Panagariya, Arvind (2018). President Donald Trump's Trade War: Multilateralism at Risk, Working Paper no. 2018-03, Columbia University (Deepak and Neera Raj Center on Indian Economic Policies (SIPA), 23 August.

Reinsch, William Alan, Jack Caporal and Lydia Murray (2018). At Last, An RCEP Deal, Center for Strategic and International Studies (CSIS), 3 December (Link: http://www.csis.org/analysis/least-rcep-deal )


## សម្គាល់

១ កិច្ចព្រមព្រៀងនេះរួមមាន ១១ប្រទេស៖ ជប៉ុន ម៉ាឡេស៊ី សិង្ហបុរី វៀតណាម ព្រុយណេ អូស្ត្រាលី ណូវែស៊ីឡង់ កាណាដា ឈីលី ប៉េរូ និងម៉ិកស៊ិក។

២ ភាពជាដៃគូសេដ្ឋកិច្ចក្នុងតំបន់នេះរួមមាន សមាជិកអាស៊ានទាំងអស់ និងប្រទេសជប៉ុន ចិន កូរ៉េខាងត្បូង អូស្ត្រាលី ណូវែស៊ីឡង់ និងឥណ្ឌា។



ទួរប៊ីនដើរដោយខ្យល់ជាផ្នែកមួយនៃការបញ្ចូលគ្នារបស់ប្រព័ន្ធថាមពលកកើតឡើងវិញ
SSUAphotos

ជំពូកទី

# ០៤

# ការដោះស្រាយទំនាក់ទំនងរវាងសន្តិសុខទឹក ស្បៀង និងថាមពល ក្រោមលក្ខណ្ឌនៃការប្រែប្រួលអាកាសធាតុ


ទំ.៨៦ | ៤.១ សន្តិសុខស្បៀង និងការប្រែប្រួលអាកាសធាតុ៖ ទស្សនៈមួយពីប្រទេសសិង្ហបុរី
*ដោយ ឯកអគ្គរដ្ឋទូត តាំង យុក ចូវ*

ទំ.៩០ | ៤.២. បណ្តាទីក្រុងនៅអាស៊ានប្រឈមនឹងហានិភ័យបរិស្ថាន និងការប្រែប្រួលអាកាសធាតុ
*ដោយ មីហ្សែល ហ្វូសហ្សេ*

ទំ.៩៦ | ៤.៣ ការប្រែប្រួលអាកាសធាតុ និងការការពារតំបន់ព្រៃធម្មជាតិ៖ ទស្សនៈពីខាងតំបន់អាស៊ីអាគ្នេយ៍
*ដោយ បណ្ឌិត គឹម សុធន*

ទំ.១០០ | ៤.៤ ប្រសិទ្ធភាពនៃច្បាប់ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមដែលបណ្តាលមកពីបម្រែបម្រួលអាកាសធាតុ
*ដោយ ហ៊្សាវីយ៉េ នូទីន*

ទំ.១០៧ | ៤.៥. សន្តិសុខថាមពលអឺរ៉ុប៖ បញ្ហាប្រឈមក្នុងការធ្វើ ពិពិធកម្ម និងការបំបែកកាបូនឌីអុកស៊ីតចេញ ពីរបាយឥន្ធនៈ
*ដោយ បណ្ឌិត ឡុតហ្ស ម៉េហ្ស៍*

ទំ.១១២ | ៤.៦ សហភាពអឺរ៉ុប និងបញ្ហាប្រឈមទៅនឹងការប្រែប្រួលអាកាសធាតុ៖ អំណាចកំពូលក្នុងការចេញបទបញ្ញត្តិ
*ដោយ មីហ្សែល ហ្វូសហ្សេ*

# ៤.១ សន្តិសុខស្បៀង និងការប្រែប្រួលអាកាសធាតុ៖ ទស្សនៈមួយពីប្រទេសសិង្ហបុរី

ការប្រែប្រួលអាកាសធាតុ ជាពិសេសកម្តៅភពផែនដី និងផលប៉ះពាល់ដែលមិនអាចទប់ស្កាត់បានបង្កឲ្យមានបញ្ហាប្រឈមដ៏ធ្ងន់ធ្ងរសម្រាប់ប្រទេសជាច្រើន។ កំណើននីវ៉ូទឹកសមុទ្រ គឺជាបញ្ហាស្លាប់រស់សម្រាប់ ប្រទេសជាកោះតូចៗដូចជាសិង្ហបុរី។ ហេតុនេះហើយ ប្រទេសសិង្ហបុរីបានធ្វើការយ៉ាងសកម្ម ដើម្បីឲ្យមានការមូលមតិជាអន្តរជាតិ ដែលក្រោយមកត្រូវបានសម្រេចក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីស ដើម្បីឲ្យភាគីប្រទេស នីមួយៗធ្វើ «សកម្មភាពដើម្បីអាកាសធាតុ» និងដើម្បីកាត់បន្ថយការបញ្ចេញនូវឧស្ម័នផ្ទះកញ្ចក់។ ប្រទេសសិង្ហបុរីបានដើរតួក្នុងការព្យាយាមកាត់បន្ថយជាតិកាបូន និងបង្កើននិរន្តរភាពលើគ្រប់វិស័យទាំងអស់ រាប់ពីសម្ភារៈប្រើប្រាស់ក្នុងផ្ទះ និងការដឹកជញ្ជូន រហូតដល់ឧស្សាហកម្ម ធុរកិច្ច និងក្នុងគ្រួសារ៖ វាជាកិច្ចប្រឹងប្រែងដែលទាមទារការចូលរួមពីអ្នកពាក់ព័ន្ធទាំងអស់។ បច្ចេកវិទ្យាអាចជាកម្លាំងចលករក្នុងការផ្លាស់ប្តូរស្ថានការណ៍ប្រទេសសិង្ហបុរី ដោយមិនត្រឹមតែបង្កើនប្រសិទ្ធភាពថាមពលដែលខ្ពស់ស្រាប់ និងការប្រើប្រាស់ថាមពលកកើត ឡើងវិញរបស់ខ្លួននោះទេ ប៉ុន្តែថែមទាំងជួយដល់ការរំកិលខ្លួនទៅកាន់សេដ្ឋកិច្ចវិលជុំដែលមិនមានកាកសំណល់ (Zero waste) ដោយការប្រើប្រាស់ឡើងវិញ (Re-using) គ្រប់សម្ភារៈ និងធនធាននៅពេលណាមួយដែលអាចធ្វើបាន។

ក្នុងរបាយការណ៍ជាបន្តបន្ទាប់ ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ (IPCC) បានចេញផ្សាយការវាយតម្លៃបន្ទាន់ពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើភពផែនដីយើង។ របាយការណ៍ចុងក្រោយរបស់ពួកគេមិនបានផ្តល់សញ្ញាល្អសម្រាប់តំបន់អាស៊ីអាគ្នេយ៍នោះទេ ដែលជាហេតុនាំឲ្យអគ្គលេខាធិការអង្គការសហប្រជាជាតិ លោក អាន់តូនីញ៉ូ ហ្គូទែរែស (Antonio Guterres) ថ្លែងនៅក្នុង សុន្ទរកថាបើករបស់លោកនៅឯកិច្ចប្រជុំកំពូលអាស៊ាន-យូអិន (ASEAN-UN) នាថ្ងៃទី៣ ខែវិច្ឆិកាឆ្នាំ២០១៩ នៅទីក្រុងបាងកកថា៖ «ភាពអាសន្ននៃអាកាសធាតុ គឺជាបញ្ហាកំណត់ជោគវាសនានៃយុគសម័យរបស់យើង។ប្រទេសចំនួន៤ក្នុងចំណោមប្រទេសទាំង១០ ដែលរងផលប៉ះពាល់ខ្លាំងបំផុតពីការប្រែប្រួលអាកាសធាតុ គឺជាប្រទេសដែលជាសមាជិកអាស៊ាន។ តំបន់នេះគឺជាតំបន់ងាយរងផលប៉ះពាល់ ខ្ពស់ដោយសារកំណើននីវ៉ូ ទឹកសមុទ្រ ដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សហគមន៍ដែលនៅតំបន់ទាបៗ។

## ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុចំពោះសន្តិសុខស្បៀងពិភពលោក

ការសិក្សាជាច្រើនបានបង្ហាញថា ត្រឹមតែការកើនឡើងកម្តៅតែមួយមុខក៏អាចនឹងបង្កឲ្យមានការធ្លាក់ ចុះទិន្នផលស្រូវ (យោងតាមការប្រមូលផលនាពេលបច្ចុប្បន្ននេះ) ក្នុងប្រទេសឥណ្ឌូនេស៊ី ហ្វីលីពីន ថៃ និង វៀតណាម រហូតដល់ ៥០% ដោយចាប់គិតពីឆ្នាំ១៩៩០ ដល់ឆ្នាំ២១០០។ ដោយសារសកម្មភាពកសិកម្ម សំខាន់ធ្វើឡើងក្នុងតំបន់ទាបៗ ក្នុងនោះមានដូចជាតំបន់ដីសណ្តមេគង្គ និងតំបន់មាត់សមុទ្រដែលងាយទទួលរងនូវទឹកជំនន់ និងការឡើងជាតិប្រៃដែលកើតចេញពីកំណើននីវ៉ូទឹកសមុទ្រ ដូច្នេះផលិតផលដំណាំស្រូវ និងផលិតផលផ្សេងៗអាចនឹងងាយរងផលប៉ះពាល់ផងដែរ។ អង្គការស្បៀង និងកសិកម្មនៃអង្គការសហប្រជាជាតិ (FAO) និងក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ (IPCC) បានប៉ាន់ស្មានថា ការប្រែប្រួល អាកាសធាតុអាចនឹងបង្កឲ្យមានការធ្លាក់ចុះទិន្នផលស្រូវពី១០-១៥% ត្រឹមឆ្នាំ២០៥០។ ការធ្លាក់ចុះទិន្នផលដ៏គួរឲ្យកត់សម្គាល់នេះនឹងក្លាយជាការគំរាមកំហែងយ៉ាងខ្លាំងចំពោះសន្តិសុខស្បៀងពិភពលោក ដែលកំពុងរងសម្ពាធស្រាប់ពីការកើនឡើងនៃចំនួនប្រជាជននៅលើពិភពលោក ដែលអាចកើនឡើងដល់ ១០ប៊ីលាន ត្រឹមឆ្នាំ២០៥០ ពីចំនួន ៧.៣ប៊ីលាន នាពេលបច្ចុប្បន្ននេះ។

## អភិក្រមរបស់ប្រទេសសិង្ហបុរីចំពោះសន្តិសុខស្បៀង

ប្រទេសសិង្ហបុរី គឺជាទីក្រុងស៊ីវិល័យ និងជាឋានសួគ៌ចំណីអាហារដែលគេអាចរកបានអាហារសឹងតែគ្រប់ប្រភេទ និងគ្រប់តម្លៃទាំងអស់។ សន្ទស្សន៍សន្តិសុខស្បៀងពិភពលោកដែលបានចេញផ្សាយដោយអង្គភាពស៊ើបការណ៍សេដ្ឋកិច្ច (Economist Intelligence Unit) បានចាត់ចំណាត់ថ្នាក់សិង្ហបុរីថា ជាប្រទេសដែល មានសន្តិសុខស្បៀងខ្ពស់ជាងគេក្នុងឆ្នាំ២០១៨ និង២០១៩។ ដូច្នេះ យើងអាចយល់បានថា ប្រជាពលរដ្ឋសិង្ហបុរីជាច្រើនមិនបារម្ភអំពីរឿងការទទួលបានអាហារនោះទេ។ ទោះយ៉ាងណាក៏ដោយអ្នកធ្វើគោលនយោបាយមិនអាចមិនខ្វល់ពីការគំរាមកំហែងជាក់ស្តែងលើសន្តិសុខស្បៀងរបស់សិង្ហបុរី

នាពេលអនាគតនោះទេ។ ក្រោយពីបានដើរចេញពីវិស័យកសិកម្មតាំងពីមួយជំនាន់មុន ដើម្បីងាកទៅប្រើប្រាស់ដី និងធនធាន ដែលមានកម្រិតរបស់ខ្លួនឲ្យមានផលិតភាពសេដ្ឋកិច្ចជាងមុន ប្រទេសសិង្ហបុរី បច្ចុប្បន្ននេះកំពុងធ្វើការស្វែងរកយ៉ាងយកចិត្តទុកដាក់នូវវិធីសាស្ត្រ ដែលមានប្រសិទ្ធភាពក្នុងតម្លៃសមស្រប និងប្រកបដោយនិរន្តរភាព ដើម្បីផលិតចំណីអាហារ មិនត្រឹមតែសម្រាបផ្គត់ផ្គង់ទីក្រុងរបស់ខ្លួនប៉ុណ្ណោះទេតែក៏អាចចូលរួមចំណែកក្នុងការផលិតចំណីអាហារសម្រាប់ផ្គត់ផ្គង់ពិភពលោកផងដែរ។ ស្របពេលជាមួយគ្នានេះដែរ វិធីសាស្ត្ររបស់សិង្ហបុរីអាចនឹងជួយឲ្យប្រជាពលរដ្ឋពាក់កណ្ដាលពិភពលោក ដែលបច្ចុប្បន្នរស់នៅក្នុងតំបន់ទីប្រជុំជន អាចចូលរួមចំណែកក្នុង ការកាត់បន្ថយកង្វះសន្តិសុខស្បៀងពិភពលោកនាពេលអនាគត។

នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩ សភាសិង្ហបុរីបានអនុម័តច្បាប់មួយ ដើម្បីបង្កើតក្រុមប្រឹក្សាស្របច្បាប់ថ្មីមួយដែលមានឈ្មោះថា ភ្នាក់ងារស្បៀងសិង្ហបុរី (Singapore Food Agency) ដែលស្ថិតនៅក្រោមឱវាទក្រសួងបរិស្ថាន និងធនធានទឹកសិង្ហបុរី (Singapore's Ministry of the Environment and Water Resources)។ បេសកកម្មរបស់ភ្នាក់ងារស្បៀងសិង្ហបុរី (SFA)នេះ គឺដើម្បីធានា និងរក្សាឲ្យបានការផ្គត់ផ្គង់ចំណីអាហារសុវត្ថិភាពសម្រាប់ប្រទេសសិង្ហបុរី។ ជាការប្រមូលផ្ដុំមុខងារពាក់ព័ន្ធនឹងចំណីអាហារ ដែលពីមុនគ្រប់គ្រងដោយភ្នាក់ងារជាច្រើនមកធ្វើការរួមគ្នាតាមវិធីសាស្ត្រគ្រប់ជ្រុងជ្រោយដើម្បីពង្រឹងសុវត្ថិភាព និងសន្តិសុខស្បៀង នាពេលនេះភ្នាក់ងារស្បៀងសិង្ហបុរី (SFA) ដែលមានអំណាចអនុញ្ញាតដោយច្បាប់ក្នុងការត្រួតពិនិត្យខ្សែសង្វាក់ផលិតកម្មចំណីអាហារទាំងមូល «ចាប់ពីការផលិតទិន្នផលកសិកម្មរហូតដល់ការប្រើប្រាស់ (from farm to fork)»។ ទីភ្នាក់ងារនេះកំពុងធ្វើការជាមួយដៃគូធុរកិច្ច ដើម្បីប្រែក្លាយឧស្សាហកម្ម កសិម្ហូបអាហារជាតិ និងដើម្បីបង្កើតការងារល្អៗសម្រាប់ជនជាតិសិង្ហបុរី។ ដើម្បីពង្រឹងភាពរឹងមាំនៃការផ្គត់ផ្គង់ ចំណីអាហាររបស់ប្រទេសសិង្ហបុរី ភ្នាក់ងារស្បៀងសិង្ហបុរី (SFA) កំពុងតែព្យាយាមសម្រេចគោលដៅ «៣០ គុណ ៣០» ដើម្បីផលិតឲ្យបាន ៣០% នៅក្នុងស្រុកនូវផលិតផលអាហារូបត្ថម្ភដែលជាតម្រូវការរបស់ប្រទេសសិង្ហបុរីត្រឹមឆ្នាំ២០៣០ ដែលនឹងធ្វើឲ្យមានការកើនឡើងច្រើនដងនូវផលិតភាពក្នុងស្រុកបើប្រៀបនឹងកម្រិតបច្ចុប្បន្ន។ ដើម្បីសម្រេចគោលដៅ ៣០ គុណ ៣០ ឧស្សាហកម្មកសិម្ហូបអាហារត្រូវមានការស្រាវជ្រាវ និងអភិវឌ្ឍន៍ (R&D) ក្នុងការបង្កើតនូវដំណោះស្រាយសម្រាប់ជំនះឧបសគ្គផ្នែកធនធាន បង្កើនផលិតភាព និងពង្រឹងភាពធន់នឹងអាកាសធាតុ។

ភ្នាក់ងារស្បៀងសិង្ហបុរី (SFA) ធ្វើការលើកទឹកចិត្តកសិដ្ឋានក្នុងស្រុកដែលមានស្រាប់ឲ្យធ្វើនវានុវត្តន៍ និងធ្វើការអភិវឌ្ឍខ្លួនឯង (ឧទាហរណ៍៖ ការធ្វើសមាហរណកម្មការទៅក្នុងដំណើរការពីការគ្រប់គ្រងអាកាសធាតុ និងការប្រើម៉ាស៊ីនស្វ័យប្រវត្តិ) ដើម្បីបង្កើនផលិតភាព។ ភ្នាក់ងារស្បៀងសិង្ហបុរី (SFA) បានលើកទឹកចិត្តឲ្យមានកសិដ្ឋាននៅក្នុងអគារបែបទាន់សម័យ (state-of-art indoor farms) ដែលជួយធ្វើឲ្យរុក្ខជាតិ លូតលាស់បានកាន់តែប្រសើរ និងបង្កើនទិន្នផលបានកាន់តែឆាប់រហ័ស តាមរយៈមធ្យោបាយដែលមានបច្ចេកវិទ្យាខ្ពស់ ដូចជាការប្រើប្រាស់ពន្លឺ អិល អ៊ី ឌី (LED) និងការគ្រប់គ្រងអាកាសធាតុជាដើម។ ដោយគ្រប់គ្រងការលូតលាស់ពីកត្តាផ្សេងៗ កសិដ្ឋានទាំងនេះមានភាពធន់នឹងអាកាសធាតុ និងអាចរក្សាស្តង់ដារ គុណភាពបានខ្ពស់។ ស្រដៀងគ្នានេះដែរ ភ្នាក់ងារស្បៀងសិង្ហបុរី (SFA) ក៏បានលើកទឹកចិត្តឲ្យមានកសិដ្ឋានចិញ្ចឹមត្រីដែលមានភាពធន់មាននិរន្តភាពជាងមុន និងអាចផ្ដល់ផលិតផលកាន់តែច្រើនពីព្រោះកសិដ្ឋានចិញ្ចឹមត្រីបែបប្រពៃណីដែលប្រើសំណាញ់ហ៊ុំព័ទ្ធ ងាយនឹងរងគ្រោះដោយសារឧប្បត្តិហេតុពីខាងក្រៅក្នុងនោះរួមមាន៖ ឆាប់មានស្លែលើផ្ទៃទឹក និងងាយរងផលប៉ះពាល់ពីការកំពប់ប្រេងជាដើម។ ក្រុមហ៊ុនមួយឈ្មោះថា បច្ចេកវិទ្យា វារីវប្បកម្មសិង្ហបុរី (Singapore Aquaculture Technologies) បានប្រើប្រាស់ប្រព័ន្ធបែបបិទជិតចាប់តាំងពីឆ្នាំ២០១២ ក្នុងការចិញ្ចឹមត្រីដូចជា ត្រីស្ពង់ស (baramundi) ត្រីស្ពង់ (sea bass) និងត្រីអាំងកឹយក្រហម (red snapper)។

## ដំណើរឆ្ពោះទៅរកនិរន្តរភាព

ភ្នាក់ងារស្បៀងសិង្ហបុរី (SFA) កំពុងធ្វើការជាមួយស្ថាប័នសិក្សាជាន់ខ្ពស់ជាច្រើនក្នុងការផ្ដល់នូវចំណេះដឹង និងជំនាញទៅឲ្យក្មេងជំនាន់ក្រោយឲ្យក្លាយខ្លួនជាអ្នកបច្ចេកទេសកសិកម្ម និងវារីវប្បកម្ម អ្នកជំនាញផ្នែកកសិដ្ឋានបែបទីក្រុង និងអ្នកស្រាវជ្រាវ។ អង្គភាពនេះក៏ផ្ដល់ការគាំទ្រដល់អ្នកដែលមានចំណាប់អារម្មណ៍ ក្នុងការធ្វើកសិដ្ឋានបែបទីក្រុង ដោយប្រើប្រាស់កន្លែងទំនេរដូចជា រានហាល និងលើដំបូល ដើម្បីធ្វើការដាំដុះ។ គម្រោងបែបនេះជួយប្រមូលផ្ដុំសហគមន៍ធ្វើឲ្យប្រជាពលរដ្ឋចូលរួមដោយផ្ទាល់ក្នុងការផលិតកម្មម្ហូបអាហារ បង្កើនការយល់ដឹងពីបញ្ហាសន្តិសុខស្បៀង ជួយកែផ្នត់គំនិតឲ្យចេះផ្ដល់តម្លៃទៅលើអាហារ និងចេះកាត់បន្ថយសំណល់អាហារ។ ដោយសារតែអាហារងាយនឹងផ្អូមឬរលួយ ចំនួនអាហារមួយចំនួនធំត្រូវបានបាត់បង់ក្នុងខ្សែ ចង្វាក់តម្លៃសកលមុនពេលដែលអាហារទាំងនោះបានទៅដល់អតិថិជន។ អង្គការស្បៀង និងកសិកម្មនៃអង្គការ

សហប្រជាជាតិ (FAO) បានប៉ាន់ប្រមាណថា ប្រហែល ១/៣ នៃអាហារដែលបានផលិតរួចត្រូវបានបាត់បង់ ឬខ្ជះខ្ជាយទៅក្នុងខ្សែសង្វាក់តម្លៃកសិម្ហូបអាហារសកលដែលចំនួននេះកើនឡើងបន្តិចម្តងៗ ក្នុងខណៈពេលដែលភាពអត់ឃ្លាននៅតែបន្តប៉ះពាល់ដល់មនុស្សជាច្រើននៅលើពិភពលោក។

ការកាត់បន្ថយការបាត់បង់ និងសំណល់អាហារច្បាស់ណាស់ គឺជាវិធីសាស្ត្រដែលមានប្រសិទ្ធិភាព បំផុតក្នុងការកាត់បន្ថយជានកាបូនក្នុងវិស័យកសិម្ហូបអាហារដោយមិនមានការខាតបង់អ្វីទាំងអស់។ ទោះបីជាបរិមាណនៃការខូចខាតអាហារ ឬសំណល់អាហារនៅក្នុងប្រទេសសិង្ហបុរីមានកម្រិតទាបជាងចំនួនជាមធ្យម ក៏ដោយ ដែលតាមការប៉ាន់ស្មានមានចំនួនប្រមាណ២០% តែតួលេខនេះគឺ នៅតែជាកម្រិតមួយខ្ពស់ខ្លាំង។ អតិថិជនទាំងអស់ត្រូវបានលើកទឹកចិត្តឲ្យទិញ ចំអិន និងបរិភោគអាហារក្នុងបរិមាណល្មម ខណៈពេលដែល សៀវភៅមគ្គុទេសក៍ស្តីពីការបង្កើតអាហារគ្រប់មុខ ការបង្កើតរោងចក្រផលិតចំណីអាហារ និងផ្សារទំនើបត្រូវ បានចេញផ្សាយ និងផ្សព្វផ្សាយដល់គ្រប់ឧស្សាហកម្មតាំងពីឆ្នាំ២០១៤។ កិច្ចខិតខំប្រឹងប្រែងជាច្រើនត្រូវបានធ្វើឡើងក្នុងការប្រមូល និងចែកចាយឡើងវិញនូវស្បៀងអាហារដែលនៅសេសសល់ និងលក់មិនដាច់។ ចំពោះការខូចខាតស្បៀង ការសិក្សាមួយបានបង្ហាញថា ស្បៀងអាហារចំនួន ៧.២ % ដែលប្រទេសសិង្ហបុរីនាំចូលតាមរយៈការដឹកជញ្ជូនគិតជាតោនក្នុងមួយឆ្នាំត្រូវបានបាត់បង់ (ឧទាហរណ៍.ដោយសារការរលួយ/ខូច) នៅតាមផ្លូវមកកាន់ប្រទេសសិង្ហបុរី និងក្នុងពេលចែកចាយក្នុងប្រទេសសិង្ហបុរីធ្វើឲ្យស្បៀងបាត់បង់ចំនួន ៥.៥% ថែមទៀត។ ការផលិតស្បៀងអាហារក្នុងស្រុកនឹងមិនត្រឹមតែពង្រឹងសន្តិសុខស្បៀងសម្រាប់ប្រទេសសិង្ហបុរីដោយផ្តល់ជាស្តុកក្នុងពេលមានវិបត្តិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយកាត់បន្ថយចម្ងាយក្នុងការដឹកជញ្ជូនស្បៀងដែលត្រូវប្រើប្រាស់ក្នុងប្រទេសសិង្ហបុរីផងដែរ។ ម្យ៉ាងវិញទៀត ខ្សែសង្វាក់ផ្គត់ផ្គង់ខ្លីក្នុងស្រុក ចាប់ពីការផលិត ទិន្នផលកសិកម្មរហូតដល់ការប្រើប្រាស់ (from farm to fork) ធ្វើឲ្យស្បៀងអាហារអាចទៅដល់អតិថិជនស្រស់ៗ និងជៀសវាងការខូចខាត ដែលមុខជានឹងកើតឡើង បើឆ្លងកាត់ខ្សែសង្វាក់តម្លៃអាហារនាំចូលដែលមានចម្ងាយឆ្ងាយ។

ដូចគ្នានឹងវិស័យផ្សេងៗក្នុងប្រទេសសិង្ហបុរី វិស័យកសិម្ហូបអាហារកំពុងតែផ្តោតទៅរកនិរន្តរភាព។ ការបង្កើតឲ្យមានភ្នាក់ងារស្បៀងសិង្ហបុរី (SFA) ជាផ្នែកមួយរបស់ក្រសួងបរិស្ថាន និងធនធានទឹកសិង្ហបុរី (MEWR) បានជួយសម្របសម្រួលឲ្យមាន “គ្រួសារបរិស្ថាន” ដោយប្រើប្រាស់នូវអភិក្រមរួបរួមគ្នាក្នុងការគ្រប់គ្រងទឹក ស្បៀង ប្រសិទ្ធិភាពនៃថាមពល និងការប្រើប្រាស់ភាពរួមគ្នារវាងទំនាក់ទំនងនៃថាមពល-ស្បៀង-ទឹក-កាកសំណល់។ ដោយភ្នាក់ងារស្បៀងសិង្ហបុរី (SFA) មានតួនាទីពង្រឹងសន្តិសុខស្បៀងសម្រាប់ប្រទេសសិង្ហបុរី អង្គភាពនេះគាំទ្រជានិច្ចនូវអភិក្រមសេដ្ឋកិច្ចវិលជុំលើផលិតកម្មកសិម្ហូបអាហារ ដើម្បីធានាឲ្យមានការប្រើប្រាស់ធនធានឲ្យអស់លទ្ធភាព កាត់បន្ថយការបាត់បង់និងកាកសំណល់អាហារ និងជំរុញការកែច្នៃ (ឧទាហរណ៍ បំលែង) កាកសំណល់អាហារឲ្យទៅជាសារធាតុដើម្បីផលិតថាមពលក្នុងវិស័យកសិកម្ម ឬកែច្នៃធ្វើជីជាដើម។ អ្វីដែលជាកាកសំណល់នៅក្នុងវិស័យមួយជាទូទៅអាចប្រើប្រាស់ឡើងវិញ ឬបំលែងឲ្យទៅជាអ្វីផ្សេងសម្រាប់ប្រើប្រាស់ក្នុងវិស័យមួយទៀតបាន។

កសិដ្ឋានក្នុងស្រុកខ្លះបានប្រើប្រាស់គោលការណ៍សេដ្ឋកិច្ចវិលជុំនេះរួចហើយ។ កសិដ្ឋានក្នុងអាគារមួយកន្លែងមានឈ្មោះថា ស៊ុស្ទីនណា (Sustenir) កំពុងប្រើប្រាស់ឧស្ម័នកាបូនិក ដើម្បីបង្កើនទិន្នផលបន្លែរបស់ខ្លួន។ កសិដ្ឋានចិញ្ចឹមមាន់មួយបានអនុវត្តបច្ចេកទេសបំបែកជីវសាស្ត្រដោយយកកាកសំណល់ពីមាន់ដែលខ្លួនចិញ្ចឹមដើម្បីផលិតឲ្យទៅជាថាមពលក្នុងការសម្ងួតផលិតផលបន្ទាប់បន្សំ ដែលចេញពីឧស្សាហកម្មចំណីអាហារដើម្បីផលិតទៅជាចំណីមាន់។ ពងសត្វល្អិតខ្លះដូចជារុយ (Black Soldier Fly) ជាដើម ផ្សំជាមួយនឹងកាកសំណល់កសិម្ហូបអាហារអាចផលិតទៅជាជីខណៈពេលដែលពងសត្វល្អិតដែលលូតលាស់អាចធ្វើជាចំណីសម្រាប់ត្រី ឬមាន់បាន។

ការអភិវឌ្ឍបច្ចុប្បន្នក្នុងការផលិតអាហារថ្មីៗមានដូចជាជម្រើសក្នុងការចំរាញ់ប្រូតេអ៊ីនចេញពីរុក្ខជាតិរហូតដល់ពីសាច់សត្វ វិធីងាយស្រួលសម្រាប់ផលិតទឹកដោះគោ និងស៊ុតសម្រាប់លក់ និងការធ្វើកសិដ្ឋានបណ្តុះស្លែ និងចិញ្ចឹមសត្វល្អិត ដើម្បីធ្វើជាប្រភពផ្សេងៗនៃប្រូតេអ៊ីន អាចបើកផ្លូវប្រកបដោយនិរន្តរភាពសម្រាប់ប្រទេសសិង្ហបុរីក្នុងការធ្វើពិពិធកម្មប្រភពប្រូតេអ៊ីន ដើម្បីឈានទៅសម្រេចកាន់គោលដៅ ៣០ គុណ ៣០ របស់ខ្លួន។ ដោយការផលិតអាហារសំបូរទៅដោយប្រូតេអ៊ីនដែលផ្អែកលើសណ្តែកគ្រាប់ធញ្ញជាតិ ស្រូវសាលី មើមរុក្ខជាតិបញ្ចេញជានកាបូនទាបជាងផលិតកម្មចេញពីសាច់មកពីកសិដ្ឋានចិញ្ចឹមសត្វ វាប្រហែលជាអាចជួយស្តារឡើងវិញនូវឧស្សាហកម្មប្រូតេអ៊ីនសកល ដែលកំពុងជួបប្រទះបញ្ហាកាន់តែច្រើនឡើងៗចំពោះនិរន្តរភាពបរិស្ថានរបស់ខ្លួន។

## ការស្រាវជ្រាវ និងអភិវឌ្ឍ (R&D) រកដំណោះស្រាយប្រកបដោយនវានុវត្តន៍ និងស្បៀងអាហារនាពេលអនាគត

ដើម្បីពន្លឿនការស្រាវជ្រាវ និងអភិវឌ្ឍ (R&D)ក្នុងការរកដំណោះស្រាយបែបបច្ចេកវិទ្យាសម្រាប់វារីវប្បកម្មបែបត្រូពិច និងកសិកម្មបែបទីក្រុងក្នុងប្រទេសសិង្ហបុរីភ្ជាប់ជាមួយនឹងគោលដៅផ្សេងៗរួមមាន៖ ពង្រឹងការគ្រប់គ្រងសុខភាព និងជំងឺ (ឧទាហរណ៍. តាមរយៈការពង្រឹងសេនេទិចនៃប្រភេទដំណាំត្រូពិច និងពូជសំខាន់ៗជាមួយនឹងផេណូទីបដែលបន្សាំសម្រាប់កសិដ្ឋានក្នុងអាគារ) ភ្នាក់ងារស្បៀងសិង្ហបុរី (SFA) បានចេញប្រកាសនៅថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០១៩ ចំពោះការដាក់សំណើស្រាវជ្រាវដែលពាក់ព័ន្ធ។ គោលដៅ គឺដើម្បីបង្កើនផលិតភាពរបស់អ្នកផលិតអាហារក្នុងស្រុកឲ្យហួសពីអ្វីដែលអាចសម្រេចបានតាមបច្ចេកវិទ្យាជាច់គេនាពេលបច្ចុប្បន្ននេះ ដោយគិតផងដែរពីប្រសិទ្ធភាពនៃថ្លៃចំណាយ ចីរភាពបរិស្ថាន និងភាពធន់នឹងអាកាសធាតុ។ ស្របពេលនេះដែរ ទីភ្នាក់ងារវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងស្រាវជ្រាវបានចាប់ផ្តើមបើកគម្រោងផ្តល់ថវិកាសម្រាប់ការស្រាវជ្រាវពាក់ព័ន្ធនឹងការបង្កើតអាហារសម្បូរប្រូតេអ៊ីន ដើម្បីដោះស្រាយនូវបញ្ហាប្រឈមជាមូលដ្ឋាននានា ទាក់ទងនឹងជម្រើសផលិតប្រូតេអ៊ីនពីប្រភពផ្សេងៗ។ កត្តានេះត្រូវបានគេសង្ឃឹមថានឹងនាំឲ្យមានអភិក្រមនៃការស្រាវជ្រាវ និងអភិវឌ្ឍដ៏ថ្មីស្រឡាង និងបេកគំហើញបច្ចេកវិទ្យា «ដើម្បីអភិវឌ្ឍដំណោះស្រាយ និងបច្ចេកវិទ្យាដែលផ្អែកទៅលើភស្តុតាង និងទស្សនាទានដែលមានសម្អាង» សម្រាប់សុវត្ថិភាពស្បៀង ជីវជាតិរសជាតិ ថាមពលនិងប្រសិទ្ធិភាព និរន្តរភាពនិងការពិចារណាជាក់ស្តែងក្នុងពិភពលោកផ្សេងៗទៀត។

## ការផលិតថ្មី៖ ផលិតកម្មកសិម្ហូបអាហារ

ទោះបីជាវិស័យកសិកម្មត្រូវបានជំនួសដោយឧស្សាហកម្មនៅប្រទេសសិង្ហបុរីតាំងពីកាលពី ៣០-៤០ឆ្នាំ មុនក៏ដោយ បច្ចេកវិទ្យាកំពុងតែបំលែងការធ្វើកសិដ្ឋាន និងផលិតកម្មចំណីអាហារឲ្យត្រលប់មកវិញ ជាប្រភេទផ្សេងមួយនៅក្នុងការផលិត ជាមួយនឹងកសិករធ្វើជំនួញបែបបច្ចេកវិទ្យា (techno-preneur farmers) និងអ្នកបង្កើតនវានុវត្តន៍នៃអាហារ (novel food innovator-creators)។ ភាពជោគជ័យរបស់ប្រទេសសិង្ហបុរីនៅក្នុងវិស័យដ៏សកម្មក្នុងការពង្រឹងនូវសន្តិសុខស្បៀងតាមរយៈដំណោះស្រាយអាហារបែបទីក្រុងនឹងត្រូវចែករំលែកជាមួយប្រទេសដទៃ ដោយចាប់ផ្តើមពីទីក្រុងជិតខាងក្នុងអាស៊ីអាគ្នេយ៍ ដើម្បីឲ្យប្រទេសដទៃទៀតអាចធ្វើពិសោធន៍ក្នុងសកម្មភាពវិវត្តន៍ថ្មីស្រដៀងគ្នានេះ ក្នុងការពង្រឹងនូវសន្តិសុខស្បៀងក្នុងស្រុក ស្របពេលដែលជួយពង្រឹងការផ្គត់ផ្គង់ស្បៀងជាសកល។



សួនបន្លែនៅលើដំបូលផ្ទះនិងចំណតរថយន្តនៃក្រុមប្រឹក្សាភិបាលអភិវឌ្ឍន៍ និងលំនៅដ្ឋាន នៅទីក្រុងយូស៊ីនប្រទេសសិង្ហបុរី
Olivia Choong / https://tendergardener.com

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដែលបកដោយវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិនៃកម្ពុជា (NIDIR)។ អ្នកអានអាចទាញយកអត្ថបទដើមជាភាសាអង់គ្លេសពីគេហទំព័រ៖ https://www.pic.org.kh ។

# ៤.២ បណ្តាទីក្រុងនៅអាស៊ានប្រឈមនឹងហានិភ័យ បរិស្ថាននិងការប្រែប្រួលអាកាសធាតុ

## ការរកឃើញ

នៅក្នុងឆ្នាំ២០១១ ផ្នែកមួយនៃទន្លេចៅប្រាយ៉ាដែលហូរកាត់ទីក្រុងបាងកកមានទឹកហូរជោរជន់ ដែលបង្កឲ្យមានទឹកជំនន់លិចទីក្រុងលើផ្ទៃដី ៤០% ។ តំបន់ជិតខាងទាំងមូលត្រូវបានកកស្ទះរយៈពេលជាច្រើនថ្ងៃ ដែលនាំឲ្យប៉ះពាល់ដល់សេដ្ឋកិច្ចយ៉ាងខ្លាំង។ ទឹកជំនន់នេះបានបង្កឲ្យមានការចំណាយថវិកាជាង ៤៦ ប៊ីលានដុល្លារអាម៉េរិក ដើម្បីជួសជុល និងស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធ ក្នុងនោះទីក្រុងបាងកកតែមួយត្រូវការចំណាយចំនួន ៨ ប៊ីលានដុល្លារអាម៉េរិក។ កាន់តែធ្ងន់ធ្ងរជាងនេះ រាជធានីរបស់ប្រទេសថៃអាចនឹងស្រុតចុះក្នុងជម្រៅ ១,៨ ម៉ែត្រ គិតពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៥។

ហ្សាការតាដែលជារដ្ឋធានីដ៏ធំរបស់ប្រទេសឥណ្ឌូនេស៊ីទទួលរងការស្រុតចុះពី ៧,៥ស.មទៅ១០ស.ម ក្នុងមួយឆ្នាំ និង ៤០% នៃទីក្រុងដ៏ប្រជុំជនមួយនេះស្ថិតនៅក្រោមនីវ៉ូទឹកសមុទ្រ។ ការស្រុតចុះនេះបានធ្វើឲ្យប៉ះពាល់ភាគខាងជើងនៃរាជធានី កំពង់ផែ មូលដ្ឋាននាវាចរ ផ្សារត្រី និងផ្សារទំនើបធំៗជាច្រើន។ ដើម្បីជាការឆ្លើយតប លោកប្រធានាធិបតី ចូកូ វីដូដូ (Joko Widodo) បានផ្តួចផ្តើមផែនការនាខែមេសា ឆ្នាំ២០១៩កន្លងទៅនេះ ក្នុងការផ្លាស់ប្តូររដ្ឋធានីនេះទៅកាន់ឆ្នេរខាងកើតនៃទីក្រុងបូនេអូ។

ទីក្រុងហូជីមិញកំពុងទទួលរងការស្រុតចុះ ៨ស.ម ក្នុងមួយឆ្នាំ។ ក្នុងឆ្នាំ២០០៩ ក្រសួងបរិស្ថាន និងធនធានធម្មជាតិរបស់ប្រទេសវៀតណាមបានផ្តល់ដំណឹងដល់សាធារណជនថា ៦% នៃផ្ទៃលើរបស់ទីក្រុងត្រូវបានស្ថិតនៅក្រោមការគំរាមកំហែងពីការស្រុតចុះនេះ។ នៅប្រទេសហ្វីលីពីន មួយផ្នែកនៃទីក្រុងម៉ានីលដែលមានប្រជាពលរដ្ឋរស់នៅប្រមាណ១៣លាននាក់ កំពុងប្រឈមមហន្តរាយដែលជិតមកដល់ដោយសារការស្រុតចុះនៃទីក្រុងចំនួន ៤,៥ស.ម ក្នុងមួយឆ្នាំ។

ជាមួយនឹងប្រជាពលរដ្ឋចំនួន ៥៤% ដែលរស់នៅក្នុងតំបន់ជិត ឬក្រោមនីវ៉ូទឹកសមុទ្រ និងជាពិសេសក្នុងបណ្តាទីក្រុងធំៗ ទ្វីបអាស៊ីបានក្លាយជាកន្លែងដែលងាយរងគ្រោះងាយទទួលរងការគំរាមកំហែងពីការស្រុតដី និងកំណើននីវ៉ូទឹកសមុទ្រ ។

## កំណើនទីក្រុងប្រជុំជននៅអាស៊ីអាគ្នេយ៍

ក្នុងឆ្នាំ២០១៩ បណ្តាទីក្រុងនៅអាស៊ីអាគ្នេយ៍ដែលធ្លាប់មានប្រជាពលរដ្ឋរស់នៅជាង ២លាននាក់ បច្ចុប្បន្ននេះមានចំនួនប្រជាពលរដ្ឋបញ្ចូលគ្នាសរុប ១៦៧លាននាក់ នៃចំនួនប្រជាពលរដ្ឋសរុបចំនួន ៦៦៤លាននាក់។ ចំនួននេះស្មើនឹង ២៦,៣%។

**តារាង ១៖** ទីក្រុង និងទីក្រុងធំៗមានចំនួនប្រជាពលរដ្ឋដូចខាងក្រោម៖

| | |
|---|---|
| ចាបូដេតាតិក (ហ្សាការតា,បូហ្គ័រ, ដេប៉ុក,តាងហ្គឺរ៉ាង និង បេកាស៊ី) | ៣៥លាន |
| មេត្រូម៉ានីល | ២៤លាន |
| បាងកក (ក្រុងថេបមហាណាកន) | ១៨,៩លាន |
| ហូជីមិញ | ១៣,៦លាន |
| បានឌុង | ៨,៧លាន |
| គូឡាឡាំពួ | ៨,២លាន |
| សិង្ហបុរី | ៨,១លាន |
| ហាណូយ | ៧,៤លាន |
| យ៉ាងហ្គូន | ៧,៤លាន |
| ស៊ូរ៉ាកាតា | ៦លាន |
| មេតាន | ៥,២លាន |
| យ៉ូខ្យាកាតា | ៤លាន |
| ភ្នំពេញ | ៣,៣ លាន |
| សេប៊ូ | ២,៨ លាន |
| ម៉ាឡាង | ២,៨ លាន |
| ប៉ាឡេមបាង | ២,៥លាន |
| ស៊ីរេបុន | ២,៥លាន |
| ចូហ័រ បាហ្ស៊ូ | ២,៤លាន |
| ដេនប៉ាសា | ២,២លាន |
| ម៉ាន់ដាឡាយ | ២លាន |

## ផែនទី ២៖ ទីក្រុង និងទីក្រុងធំៗនៅអាស៊ីអាគ្នេយ៍



## កត្តាហានិភ័យបរិស្ថានរួមបញ្ចូលគ្នាជាពិសេសនៅអាស៊ីអាគ្នេយ៍៖ ការស្រុតដី និងផលប៉ះពាល់នៃកម្តៅភពផែនដីទៅលើនីវ៉ូទឹកសមុទ្រ

តំបន់ទីក្រុងនៅអាស៊ីអាគ្នេយ៍សុទ្ធសឹងតែស្ថិតនៅតំបន់ដីល្បាប់ដែលមានប្រជាពលរដ្ឋរស់នៅតាន់តាប់ និងជាតំបន់ដីសណ្តនៅលើដីទន់ជ្រាយ ដែលលាតសន្ធឹងដល់តំបន់វាលស្រែជិតខាង។ ការធ្វើនគរូបនីយកម្ម និងឧស្សាហូបនីយកម្មឆាប់រហ័សនៅក្នុងតំបន់បែបនេះបង្កឲ្យមានការស្រុតដី និងការស្រុតផ្ទៃខាងលើរបស់ដីដែលបង្កឲ្យមាននូវទឹកជំនន់ជាច្រើន ជាពិសេសក្នុងរដូវខ្យល់មូសុង។

ការស្រុតដីបង្កមកពីកត្តាច្រើនយ៉ាង។ តាមរយៈអ្នកជំនាញមកពីវិទ្យាស្ថានឌែលតារេស (Deltares) ដែលជាវិទ្យាស្ថានឯករាជ្យលើការស្រាវជ្រាវអនុវត្តន៍ ក្នុងជំនាញទឹក និងផ្ទៃខាងក្រោមបានឲ្យដឹងថា កត្តាធំបំផុត "នៅតែស្ថិតនៅលើការបូមទឹកក្រោមដី"។ ប៉ុន្តែ ពួកគេបន្ថែមថា "ទម្ងន់អគារពិតណាស់ចូលរួមចំណែកក្នុងការសង្កត់ស្រទាប់កំណស្ទើង។ តំបន់ឆ្នេរទាំងនេះបង្កើតឡើងដោយស្រទាប់ខ្សាច់ជាច្រើន រួមជាមួយនឹងដីឥដ្ឋ និងដីកំប៉ុស (Peat)ដែលពួកវាមានភាពទន់ជ្រាយជាពិសេស"។

ទីក្រុងស្រុតចុះពិតជាងាយនឹងរងគ្រោះដោយសារកំណើននីវ៉ូទឹកសមុទ្រណាស់។ យោងតាមរបាយការណ៍ពិសេសរបស់ ក្រុមការងារអន្តររដ្ឋាភិបាលទទួលបន្ទុកការប្រែប្រួលអាកាសធាតុ (IPCC) ស្តីពីមហាសមុទ្រ និងទឹកកក (Cryosphere) ក្នុងបរិបទការប្រែប្រួលអាកាសធាតុដែលត្រូវបានអនុម័តដោយរដ្ឋាភិបាលជាសមាជិកនៃក្រុមការងារអន្តររដ្ឋាភិបាលទទួលបន្ទុកការប្រែប្រួលអាកាសធាតុ (IPCC) នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៩ កន្លងទៅនេះ បានបង្ហាញថា នីវ៉ូទឹកសមុទ្រ និងមហាសមុទ្រអាចកើនឡើងដល់កម្ពស់១,១០មនៅត្រឹមឆ្នាំ២១០០ប្រសិនបើយើងមិនធ្វើអ្វីមួយនោះទេ។ ការព្យាករណ៍ខាងក្រោមនេះបង្ហាញពីផលវិបាកនៃកំណើននីវ៉ូទឹកសមុទ្រទៅលើបណ្តាទីក្រុងនានាក្នុងតំបន់អាស៊ី ក្នុងករណីកម្តៅភពផែនដី ស្ថិតក្នុងកម្រិត ២អង្សា ដែលជាកម្រិតត្រូវបានកំណត់នៅក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីសក្នុងឆ្នាំ២០១៥ និងប្រៀបធៀបនឹងករណីដែលកម្តៅដែលឡើងដល់ ៤អង្សា។

**រូបភាព ២៖** កំណើននីវ៉ូទឹកសមុទ្រសកល (SLR) និងការស្រុតដីជាមធ្យមសម្រាប់ទីក្រុងនៅតាមតំបន់ឆ្នេរ (សូមចំណាំថា ការស្រុតដីអាចមានភាពខុសគ្នានៅក្នុងតំបន់ទីក្រុងផ្សេងគ្នា អាស្រ័យទៅតាមកម្រិតទឹកក្រោមដី និងលក្ខណៈស្រទាប់ក្រោមដី) ការស្រុតដីនៅក្នុងទីក្រុងដែលកំពុងស្រុតចុះ




**ប្រភព៖** Deltares, 2015

**តារាងទី២** ចំនួនប្រជាជនបច្ចុប្បន្ននៅក្រោមការកើនឡើងនៃកម្រិតទឹកជំនន់ជាមធ្យមប្រចាំឆ្នាំក្នុងឆ្នាំ២០៥០ ប្រទេសចំណាត់ថ្នាក់ខ្ពស់ទាំង ៦ លើការកាត់បន្ថយការបញ្ចេញឧស្ម័នកម្រិតមធ្យម

| ប្រទេស | SRTM | Coastal DEM | ការប្រែប្រួល |
|---|---|---|---|
| ១. ចិន (ដីគោក) | ២៩ លាននាក់ | ៩៣ លាននាក់ | +៦៧ លាននាក់ |
| ២. បង់ក្លាដែស | ៥ លាននាក់ | ៤២ លាននាក់ | +៣៧ លាននាក់ |
| ៣. ឥណ្ឌា | ៥ លាននាក់ | ៣៦ លាននាក់ | +៣១ លាននាក់ |
| ៤. វៀតណាម | ៩ លាននាក់ | ៣១ លាននាក់ | +២២ លាននាក់ |
| ៥. ឥណ្ឌូនេស៊ី | ៥ លាននាក់ | ២៣ លាននាក់ | +១៨ លាននាក់ |
| ៦. ថៃ | ១ លាននាក់ | ១២ លាននាក់ | +១១ លាននាក់ |
| សរុបជាសកល | ៧៩ លាននាក់ | ៣០០ លាននាក់ | +២២១ លាននាក់ |

Moderate emissions cuts

(RCP 4.5), Kopp et al. 2014. median climate sensitivity, Population exposure estimates do not factor in potential coastal defenses, such as seawalls or levees

**ប្រភព៖** Climate Central, Oct. 2019

ហានិភ័យផ្សេងទៀតសម្រាប់ទីក្រុងទាំងនេះគឺការបំពុលផ្ទៃទឹក និងការរីងស្ងួតនៃទឹកក្រោមដី បើទោះជាមានភ្លៀងធ្លាក់ច្រើនក៏ដោយនោះ ដោយសារតែការបូមទឹកពីប្រភពក្រោមដីដើម្បីផ្គត់ផ្គង់ប្រជាពលរដ្ឋសម្រាប់ប្រើប្រាស់ និងការកើនឡើងនៃថ្នល់បេតុងជំនួសឲ្យដីមមោក និងដើមកោងកាងដែលជាប្រភពជួយរក្សាទឹក និងបំពេញឡើងវិញដែលផ្តល់ឲ្យដោយធម្មជាតិនោះ។ ហានិភ័យក៏អាចកើនឡើងចំពោះការប្រេះស្លាន និងទំនប់ ក៏ដូចជា ឧបទ្ទវហេតុដែលកើតចេញពីបណ្តាញអេឡិចត្រូនិច និងបំពង់ទឹកផងដែរ។ កត្តាមួយទៀតដែលមើលមិនសូវឃើញ ប៉ុន្តែនៅតែគួរឲ្យព្រួយបារម្ភនោះគឺ ការខូចខាតផ្លូវដែលអាចបង្កឲ្យមានការបាក់រលំផ្លូវ និងតំបន់ផ្លូវដើរផ្សេងៗ ក៏ដូចជាស្នាមប្រេះដែលពេលខ្លះមានប្រវែងច្រើនគីឡូម៉ែត្រ ដែលអាចគំរាមកំហែងដល់បណ្តាញថាមពល និងផ្លូវរថភ្លើងផងដែរ។ ការផ្អៀងអគារ និងការចុះខ្សោយនៃគ្រឹះអគារក៏អាចធ្វើឲ្យមានហានិភ័យក្នុងការដួលរលំអគារផងដែរ។

## យុទ្ធសាស្ត្របន្សាំ និងទប់ទល់ទៅនឹងហានិភ័យ

វិធានការដើម្បីទប់ទល់ទៅនឹងហានិភ័យទាំងនេះត្រូវបានផ្តួចផ្តើមឡើងយ៉ាងជោគជ័យក្នុងតំបន់ទីក្រុងមួយចំនួន។ ឧទាហរណ៍ ទីក្រុងតូក្យូ ដែលស្រុតចុះជម្រៅ ៤,២៥ម ក្នុងចន្លោះឆ្នាំ១៩០០ និង២០១៣ ពេលនេះមិនមានការស្រុតចុះទៀតទេ។ ក្នុងឆ្នាំ១៩៦៨ ដើម្បីពន្យឺតការស្រុតចុះ រដ្ឋាភិបាលបានដាក់ចេញនូវបទបញ្ញត្តិក្នុងការកម្រិតការបូមទឹកក្រោមដី និងបង្កើតប្រភពទឹកផ្សេងៗមានដូចជា បង្កើតទំនប់អាងទន្លេ និងការបោះទឹកកខ្វក់ឡើងវិញ។ ទីក្រុងសៀងហៃដែលស្រុតចុះ ២,៥ម ចាប់តាំងពីឆ្នាំ១៩២០

**រូបភាពទី១. ការស្រុតដីមើលពីទស្សនៈពហុវិស័យ**




ប្រភព: Deltares ឆ្នាំ ២០១៥

បានធ្វើការសាកល្បងដាក់បញ្ចូលឡើងវិញនូវស្រទាប់ទឹកក្នុងដីសិប្បនិម្មិត។ ទីក្រុងបាងកកដែលបានសង់លើកម្ពស់ ១,៥ ម ពីនីវ៉ូទឹកសមុទ្រពេលនោះបានស្រុតចុះ ១០ ស.ម ជារៀងរាល់ឆ្នាំរហូតដល់ប៉ុន្មានឆ្នាំមុននេះ។ សាលាក្រុងគ្រប់គ្រងបាននូវការពន្យឺតនូវការស្រុតចុះ ដែលសព្វថ្ងៃនេះគ្រប់គ្រងការស្រុតដីត្រឹមមួយ ឬពីរស.មប៉ុណ្ណោះ។ ម្យ៉ាងវិញទៀតការបង្កើតសួនធំៗដូចជាសួនសតវត្សរ៍ (Centenary Park) បានជួយទប់ទល់ទឹកជំនន់ និងជួយស្តុកទឹកនៅពេលមានព្រឹត្តិការណ៍គ្រោះធម្មជាតិ។

ខណៈដែលយុទ្ធសាស្ត្របន្សាំពេលខ្លះ គឺសម្រាប់តំបន់ទីប្រជុំជនតែមួយ វិធានការទប់ទល់ គឺជាផ្នែកមួយដែលតម្រូវឲ្យមានកិច្ចខិតខំប្រឹងប្រែងដែលធំជាងមុន ដើម្បីកម្រិតកំណើននីវ៉ូទឹកសមុទ្រតាមរយៈការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ ដើម្បីសម្រេចបានកិច្ចការនេះ វិធានការទាំងនេះទាមទារឲ្យមានសកម្មភាពស្របគ្នានៅថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ ថ្នាក់តំបន់ និងសកលក្នុងការគាំទ្រគោលនយោបាយថាមពលដែលមានប្រសិទ្ធភាព និងសន្សំសំចៃជាងមុនដែលផ្តល់អាទិភាពទៅលើថាមពលកកើតឡើងវិញតាមដែលអាចទៅរួច និងការប្រឹងប្រែងក្នុងការកាត់បន្ថយការប្រើប្រាស់ឥន្ធនៈហ្វូស៊ីល។

## តួនាទីរបស់សភា

ការត្រួតពិនិត្យ និងគ្រប់គ្រងទឹក គឺមានសារៈសំខាន់ណាស់ក្នុងប្រវត្តិសាស្ត្រនៃការកសាងប្រទេសនៅអាស៊ីអាគ្នេយ៍។ អ្វីដែលថ្មីនោះគឺ ឥទ្ធិពលដ៏សម្បើមនៃការប្រែប្រួលអាកាសធាតុ។ ដើម្បីលើកកម្ពស់យុទ្ធសាស្ត្របន្សាំ និងទប់ទល់ សភាអាចផ្តួចផ្តើមបង្កើតច្បាប់ ជួយលើកកម្ពស់ការយល់ដឹងរបស់សាធារណជន តាមដានពីប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងពង្រឹងកិច្ចសហប្រតិបត្តិការតំបន់។

### ក. ច្បាប់ និងបទបញ្ញត្តិ

ដើម្បីដាក់កម្រិតការប្រើប្រាស់ទឹកជាទូទៅ និងជាពិសេសទឹកក្រោមដី និងដើម្បីគ្រប់គ្រងនគរូបនីយកម្ម យើងត្រូវការច្បាប់ ជាពិសេសក្នុងករណីដែលរដ្ឋាភិបាលមានការស្ទាក់ស្ទើរក្នុងការធ្វើសកម្មភាព។ ប្រសិនបើប្រជាពលរដ្ឋមិនបានផលប្រយោជន៍ពីបណ្តាញចែកចាយទឹកស្អាតប្រកបដោយប្រសិទ្ធភាព (ដែលជាករណីរបស់ប្រជាពលរដ្ឋចំនួន ៦៥% នៅទីក្រុងហ្សាការតា) ពួកគេនឹងបន្តបូមទឹកពីស្រទាប់ទឹកក្នុងដីដែលវានឹងបង្កឲ្យបញ្ហាស្រុតដីក្នុងទីក្រុងនេះកាន់តែធ្ងន់ធ្ងរឡើង។ នៅទីក្រុងហ្សាការតាត្រូវបានគំរាមកំហែងខ្លាំងដោយសារបញ្ហា ២យ៉ាងគឺ បញ្ហាស្រុតដី និងកំណើននីវ៉ូទឹកសមុទ្រ។ ការឆ្លើយតបរបស់ប្រទេសនេះទៅនឹងបញ្ហា

ទាំងអស់នេះគឺ ការសាងសង់ជញ្ជាំងកម្ពស់ ៤ ម៉ែត្រដែលមានប្រវែង ៣២ គ.ម។ ដំណាក់កាលទីមួយជញ្ជាំងប្រវែង ៨ គ.ម ត្រូវបានចាប់ផ្តើមសាងសង់ក្នុងឆ្នាំ២០១៤ ហើយគ្រោងនឹងបញ្ចប់នៅឆ្នាំ២០២៥។ ការប្តេជ្ញាចិត្តនេះត្រូវបានអ្នកបរិស្ថានរិះគន់យ៉ាងខ្លាំង ដោយសារវាតម្រូវឲ្យមានការសង់ជញ្ជាំងបាំងឆ្នេរប្រវែង ៥០០ គ.ម ដែលរចនាឡើងដើម្បីការពារទីក្រុងរបស់ខ្លួនទប់ទល់នឹងសមុទ្រចារ៉ា។ តម្លៃនៃគម្រោងនេះ ដែលមានឈ្មោះថា ផែនការមេសម្រាប់ការអភិវឌ្ឍតំបន់ឆ្នេរចម្រុះរដ្ឋធានីជាតិ ត្រូវបានគេប៉ាន់ស្មានថាចំណាយអស់ទឹកប្រាក់ចំនួន ៤០ប៊ីលានដុល្លារអាមេរិក ដែលស្មើនឹងចំនួនថវិកាដែលអាចសាងសង់ទីក្រុងមួយថ្មីបាន។

អភិក្រមរបស់ប្រទេសថៃក្នុងការដោះស្រាយបញ្ហាស្រុតដីក្នុងរាជធានីរបស់គេគឺ ការប្រើប្រាស់នូវបទបញ្ញត្តិយ៉ាងតឹងរឹងបំផុត ដែលដំណោះស្រាយនេះស្រដៀងទៅនឹងអភិក្រមរបស់ជនជាតិជប៉ុននៅក្នុងទីក្រុងតូក្យូ។ ច្បាប់ស្តីពី ទឹកក្រោមដីរបស់ទីក្រុងបាងកកត្រូវបានអនុម័តក្នុងឆ្នាំ១៩៧៧ ដើម្បីគ្រប់គ្រងទឹកឲ្យបានប្រសើរជាងមុន ដែលច្បាប់នេះបានដាក់គោលដៅទៅលើតំបន់ដែលងាយរងគ្រោះបំផុត។ ចាប់ពីពេលនោះមកកម្រិតស្រុតដីក្នុងរាជធានីត្រូវបានកាត់បន្ថយ តែមិនទាន់បានឈប់នោះទេដោយសារតែការបូមទឹកខុសច្បាប់នៅតែបន្ត បើទោះបីជាមិនសូវមានច្រើនក៏ដោយ។

ខណៈកំពុងបង្កើតគោលនយោបាយ និងយុទ្ធសាស្ត្របន្សាំ រដ្ឋាភិបាលត្រូវតែពិចារណាអំពីហានិភ័យអាកាសធាតុនៅពេលសិក្សាវាយតម្លៃទៅលើផលប៉ះពាល់ជាសក្តានុពលទៅលើបុគ្គល និងភាគីពាក់ព័ន្ធផ្សេងទៀត។

## ខ. ការយល់ដឹងរបស់ប្រជាពលរដ្ឋ និងភាគីពាក់ព័ន្ធ

សភាអាចជួយលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋស្តីពី បញ្ហាប្រឈម និងគោលនយោបាយដែលចាំបាច់ត្រូវដឹងដើម្បីបន្សាំ និងទប់ទល់ទៅនឹងបញ្ហាប្រឈមនៃហានិភ័យនៃការប្រែប្រួលអាកាសធាតុ តាមរយៈការរៀបចំសន្និសីទកិច្ចពិគ្រោះយោបល់ជាមួយក្រុមអ្នកជំនាញ បេសកកម្មរបស់សភា និងការចុះអង្កេតក្នុងតំបន់ជាដើម។ កិច្ចការទាំងនេះចាំបាច់ត្រូវតែ៖

- កំណត់កត្តាដែលងាយរងគ្រោះចំពោះតំបន់ សេដ្ឋកិច្ច បរិស្ថាន និងប្រជាពលរដ្ឋដែលបង្កមកពីការប្រែប្រួលអាកាសធាតុ
- លើកកម្ពស់ការយល់ដឹងស្តីពី ហានិភ័យដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ និងតម្រូវការក្នុងការត្រៀមខ្លួនចំពោះហានិភ័យទាំងនោះ
- កំណត់ផលប៉ះពាល់ដែលអាចកើតមាន និងចាត់ចំណាត់ថ្នាក់លើភាពសំខាន់ លទ្ធភាពដែលអាចទៅរួច និងភាពបន្ទាន់របស់ផលប៉ះពាល់ទាំងនោះ
- តាមដាន និងវាយតម្លៃមើលថា តើមានការកើតឡើងនូវការផ្លាស់ប្តូរដែលគិតទុកជាមុនទៅលើបរិស្ថានឬទេ ហើយប្រសិនបើមាន តើវាស្ថិតនៅក្នុងល្បឿនណា
- គណនាការចំណាយ និងផលប្រយោជន៍នៃយុទ្ធសាស្ត្របន្សាំនានា (ការមិនធ្វើអ្វីសោះ ការប្តូរទីតាំង ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ការបំលែងសកម្មភាពសេដ្ឋកិច្ច ។ល។)
- វិភាគលើការឆ្លើយតបរបស់យុទ្ធសាស្ត្របន្សាំ និងលទ្ធផលរបស់វា
- បន្តសិក្សាវាយតម្លៃពីហានិភ័យ និងយុទ្ធសាស្ត្រដែលបានដាក់ចេញ។

## គ. ការតាមដានសមិទ្ធផល

គណៈកម្មាធិការចំពោះកិច្ចរបស់សភា គួរធ្វើសវនកម្ម និងអធិការកិច្ចប្រចាំឆ្នាំ ដើម្បីវាយតម្លៃពីកម្រិតនៃការអនុវត្តច្បាប់។

## ឃ. កិច្ចសហប្រតិបត្តិការក្នុងតំបន់

បណ្តាប្រទេសអាស៊ានមានបរិស្ថានធម្មជាតិដូចគ្នា ដំណើរការនគរូបនីយកម្មមាញឹកដូចគ្នា បញ្ហាទឹកដូចគ្នា និងការគំរាមកំហែងអាកាសធាតុដូចគ្នា។ ដូចនេះ វាផ្តល់ប្រយោជន៍ស៊ីជម្រៅឲ្យគ្នាទៅវិញទៅមកក្នុងស្មារតីរួមរបស់អាស៊ាន ដែលត្រូវមានការចែករំលែកបទពិសោធន៍ និងឧទាហរណ៍នៃការអនុវត្តល្អៗ ដើម្បីសន្សំសំចៃពេលវេលាក្នុងការទប់ទល់ទៅនឹងគ្រោះមហន្តរាយទាំងនេះ។

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដែលបកដោយវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិនៃកម្ពុជា (NIDIR)។ អ្នកអានអាចទាញយកអត្ថបទដើមជាភាសាអង់គ្លេសពីគេហទំព័រ៖ https://www.pic.org.kh ។

# ៤.៣ ការប្រែប្រួលអាកាសធាតុ និងការការពារតំបន់ព្រៃធម្មជាតិ៖ ទស្សនៈពីខាងតំបន់អាស៊ីអាគ្នេយ៍

## បរិបទ

ការប្រែប្រួលបម្រែបម្រួលអាកាសធាតុកំពុងបង្កឲ្យមានផលប៉ះពាល់អវិជ្ជមានជាច្រើនទៅដល់ ប្រព័ន្ធអេកូឡូស៊ី ផលិតកម្មកសិកម្មនិងសេដ្ឋកិច្ច [១, ២, ៣]។ ឥទ្ធិពលរបស់វាបានធ្វើឲ្យរដូវប្រាំងអូសបន្លាយវែងជាងមុន ការកើនឡើងនូវសីតុណ្ហភាពក្នុងបរិយាកាសនិងគ្រោះធម្មជាតិពាក់ព័ន្ធនឹងជំនន់ទឹកភ្លៀងកើតឡើងកាន់តែញឹកញាប់ [៤, ៥]។ បម្រែបម្រួលទាំងនេះបានប៉ះពាល់ជាខ្លាំងទៅលើប្រព័ន្ធផលិតកម្មស្បៀងរបស់ពិភពលោក ហើយទំហំនៃការប៉ះពាល់ទៀតសោតប្រែប្រួលទៅតាមតំបន់[៥]។

ការកាប់បំផ្លាញព្រៃឈើជាកត្តាចម្បងមួយដែលចូលរួមចំណែកធ្វើឲ្យមានការប្រែប្រួលអាកាសធាតុ។ ការបាត់បង់គំរបព្រៃឈើនាំទៅដល់ការប្រែប្រួលនៃវដ្តទឹកនៅក្នុងបរិយាកាស និងថយចុះនូវបរិមាណពពកដែលជាហេតុនាំឲ្យមានការប្រែប្រួលលក្ខខណ្ឌអាកាសធាតុ។ ការកាប់បំផ្លាញព្រៃឈើក៏ចូលរួមចំណែកទៅដល់ការកើនឡើងកំដៅផែនដីដោយវាបានបន្ថែមបរិមាណ $CO_2$ កាន់តែច្រើនទៅក្នុងបរិយាកាស[៦]។ ការរានដីព្រៃសម្រាប់កសិកម្មនិងការកាប់ឈើសម្រាប់ពាណិជ្ជកម្មគឺជាកត្តាចម្បងដែលធ្វើឲ្យបាត់បង់ព្រៃឈើ ហើយដែលភាគច្រើនឃើញមាននៅតំបន់អាម៉ាហ្សូន និងតំបន់ត្រូពិចផ្សេងទៀតដូចជាអាស៊ីអាគ្នេយ៍ជាដើម[៧, ៨]។ ជាឧទាហរណ៍ គ្រាន់តែការផ្លាស់ប្តូររបៀបនៃការប្រើប្រាស់ដីនៅតំបន់ត្រូពិចបានធ្វើឲ្យមានការបញ្ចេញឧស្ម័នផ្ទះកញ្ចក់បន្ថែមចូលទៅក្នុងបរិយាកាសប្រមាណពី១៤-២០% លើបរិមាណសរុបដែលបានបញ្ចេញទូទាំងពិភពលោករវាងឆ្នាំ២០០០-២០០៧ [៧]។ការកើនឡើងនូវតម្រូវការស្បៀងនិងផលិតផលកសិកម្មក្នុងពិភពលោកជំរុញនូវការអនុវត្តកសិកម្មបែបអតិផល ហើយការរានដីព្រៃសម្រាប់កសិកម្មក៏កាន់តែបន្ត[៩]។

ការកាត់បន្ថយការកាប់បំផ្លាញព្រៃឈើនិងការខិតខំស្តារព្រៃឈើឡើងវិញជាជម្រើសដែលមានប្រសិទ្ធភាពនិងចំណាយតិចក្នុងការកាត់បន្ថយការកើនឡើងកំដៅផែនដី និងការទប់ទល់ទៅនឹងការប្រែប្រួលអាកាសធាតុ[៦,៩]។ អត្ថបទនេះរៀបរាប់ អំពីស្ថានភាពរបស់ព្រៃត្រូពិចនៅអាស៊ីអាគ្នេយ៍ រួមជាមួយនឹងការពិភាក្សាពីផលប៉ះពាល់នានានៃការកាប់បំផ្លាញព្រៃឈើនិងការប្រែប្រួលអាកាសធាតុ និងសង្ខេបគោលនយោបាយដែលប្រទេសនីមួយៗបានដាក់ចុះដើម្បីដោះស្រាយបញ្ហាទាំងនេះ។

## ស្ថានភាពព្រៃឈើនៅអាស៊ីអាគ្នេយ៍

ផ្ទៃដីដែលគ្របដណ្តប់ដោយព្រៃឈើនៅអាស៊ីអាគ្នេយ៍បានធ្លាក់ចុះជាលំដាប់ ដោយសារកំណើននៃការរានដីព្រៃសម្រាប់ការធ្វើកសិកម្ម[១០,១១]។ ការអភិវឌ្ឍកសិកម្មក្នុងតំបន់ប្រព្រឹត្តិទៅយ៉ាងឆាប់រហ័សក្នុងអំឡុងពេលនៃបដិវត្តន៍បៃតងដែលជំរុញដោយការកើនឡើងនូវតម្រូវការផលិតផលកសិកម្ម[១២]។ ទាំងនេះអាចមើលឃើញយ៉ាងជាក់ច្បាស់តាមរយៈកំណើនផលិតកម្មដំណាំពាណិជ្ជកម្ម [១៣,១៤]។ ទិន្នន័យបានបង្ហាញពីការធ្លាក់ចុះនៃគំរបព្រៃឈើស្ទើរគ្រប់ប្រទេសទាំងអស់ក្នុងតំបន់លើកលែងតែប្រទេសវៀតណាម ឡាវ និងហ្វីលីពីន (រូបភាពទី១)។ សម្រាប់ប្រទេសឡាវ គោលនយោបាយប្រើប្រាស់ដីដែលបានរៀបចំដើម្បីកាត់បន្ថយកសិកម្មពនេចរ និងកំណត់តំបន់ព្រៃបម្រុងបានចូលរួមចំណែកសំខាន់ក្នុងការកាត់បន្ថយការរានដីព្រៃសម្រាប់ការធ្វើកសិកម្ម[១៥] ។

ផ្ទៃដីកសិកម្មរបស់ប្រទេសថៃបានកើនពី២៣% ក្នុងឆ្នាំ១៩៦០ ទៅដល់៤២% ក្នុងឆ្នាំ១៩៩៣ ដែលក្នុងរយៈពេលដូចគ្នាផ្ទៃដីកសិកម្មរបស់ប្រទេសម៉ាឡេស៊ីបានកើន ១១%[១៦]។ កំណើនតម្រូវការប្រេងឆា និងជីវៈឥន្ធៈសកលបានធ្វើឲ្យផលិតកម្មដូងប្រេងនៅប្រទេសម៉ាឡេស៊ី និងឥណ្ឌូនេស៊ីកើនឡើងយ៉ាងខ្លាំងក្នុងចន្លោះ ឆ្នាំ១៩៩០-២០០៧[១៧]។ ព្រៃឈើប្រមាណជា ៨លានហិកតាត្រូវបានកាប់ដើម្បីយកដីសម្រាប់ដាំដូងប្រេង ហើយមានការបម្រុងទុកដីព្រៃជាច្រើនលានហិកតាថែមទៀតសម្រាប់ការពង្រីកការដាំដុះដំណាំនៅពេលសម្រាប់អនាគត [១៨]។ ត្រឹមឆ្នាំ២០០៤ ប្រមាណជា៨៥% នៃប្រេងដូងក្នុងពិភពលោកត្រូវបានផលិតក្នុងប្រទេសទាំងពីរនេះ [១៣]។ ក្នុងឆ្នាំ២០១៤ ផ្ទៃដីសម្រាប់ផលិតកម្មដូងប្រេងកើនដល់ ១៥លានហិកតា[១៩]។

ការបាត់បង់ព្រៃឈើកើតមានគួរឲ្យកត់សម្គាល់ក្នុងប្រទេសកម្ពុជា ឥណ្ឌូនេស៊ី និងមីយ៉ាន់ម៉ា ក្នុងអំឡុងឆ្នាំ ១៩៩០-២០១៦។ គំរបព្រៃឈើធ្លាក់ចុះពី៧៣ ទៅ៥២% សម្រាប់កម្ពុជា ពី៦៥ ទៅ៤៩% ក្នុងប្រទេសឥណ្ឌូនេស៊ី និងពី៦០ទៅ៤៣% សម្រាប់ប្រទេសមីយ៉ាន់ម៉ា។ ប្រទេសកម្ពុជា និងឥណ្ឌូនេស៊ីជាប្រទេសដែលមានការពង្រីកផ្ទៃដីសម្រាប់កសិកម្មលឿនបំផុតក្នុងតំបន់ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយ[១៦]។ ក្រៅពីការរានដីព្រៃសម្រាប់វិស័យ

កសិកម្ម ការកាប់ព្រៃឈើសម្រាប់ពាណិជ្ជកម្ម គឺជាមូលហេតុចម្បងនៃការបាត់បង់ព្រៃឈើនៅប្រទេសមីយ៉ាន់ម៉ា[២០]។ ប្រទេសកម្ពុជាក៏ដូចជាប្រទេសឡាវ និងមីយ៉ាន់ម៉ាដែរ ការវិនិយោគលើវិស័យកសិកម្មយ៉ាងសន្ធឹកសន្ធាប់ពីប្រទេសចិនរួមជាមួយនឹងដីព្រៃដែលទំនេរ ហើយមានតំលៃថោកបានជំរុញឲ្យមានការដាំដុះនូវដំណាំពាណិជ្ជកម្មមួយចំនួនដូចជាកៅស៊ូនិងដំឡូងមីជាដើម[២១,២២]។ មានការប៉ាន់ស្មានថា ផ្ទៃដីដាំកៅស៊ូក្នុងតំបន់នឹងកើនឡើងបួនដងត្រឹមឆ្នាំ ២០៥០ ហើយភាគច្រើននៃដីទាំងនេះគឺបានមកពីការរានដីព្រៃធម្មជាតិ[២៣] ។

## ផលប៉ះពាល់បណ្ដាលមកពីការកាប់បំផ្លាញព្រៃឈើនិងការប្រែប្រួលអាកាសធាតុ

ដូចបានរៀបរាប់ពីខាងដើម ការកាប់បំផ្លាញព្រៃឈើបានចូលរួមចំណែកដល់ការកើនឡើងកំដៅផែនដីនិងជំរុញឲ្យមានការប្រែប្រួលអាកាសធាតុ[៦]។ អាស៊ីអាគ្នេយ៍កំពុងរងគ្រោះពីបាតុភូតធម្មជាតិដែលបណ្ដាលមកពីការប្រែប្រួលអាកាសធាតុដែលមានដូចជា ទឹកជំនន់ រលកកំដៅ ភាពរាំងស្ងួត ភ្លើងឆេះព្រៃ និងព្យុះស៊ីក្លូន។ល។ នៅឆ្នាំ២១០០ សីតុណ្ហភាពជាមធ្យមនៅប្រទេសឥណ្ឌូនេស៊ី ហ្វីលីពីន ថៃ និងវៀតណាមនឹងកើនប្រមាណជា ៤.៨0C ហើយនីវ៉ូទឹកសមុទ្រនឹងកើនបន្ថែម៧០សង់ទីម៉ែត្រ[២៤]។ ការកើនឡើងសីតុណ្ហភាពនេះនឹងបង្កឲ្យមានការផ្លាស់ប្ដូររបបភ្លៀងមូសុងក៏ដូចជាការមកដល់យឺតនៃរដូវវស្សា ហើយទឹកជំនន់រដូវវស្សាដែលមានលក្ខណៈកាន់តែធ្ងន់ធ្ងរខ្លាំងជាងមុន[២៥]។ តាំងពីឆ្នាំ២០០៩ ប្រទេសអាស៊ីអាគ្នេយ៍ដីគោកដូចជា កម្ពុជា វៀតណាម ថៃ មីយ៉ានម៉ា និងឡាវ បានទទួលកំរិតទឹកភ្លៀងធ្លាក់តិចជាងបរិមាណជាមធ្យមរយៈពេលវែងរបស់ខ្លួន ដោយក្នុងពេលជាមួយគ្នាប្រទេសហ្វីលីពីនបានរងនូវបាតុភូត El Nino ដែលបណ្ដាលឲ្យរដូវវស្សាមកយឺត ហើយមានរយៈពេលខ្លីជាងមុន[២៤]។

ភាពមិនទៀងទាត់របស់ដំណើរទឹកភ្លៀង ការកើនឡើងកំដៅ និងលក្ខខណ្ឌអាកាសធាតុមិនអំណោយផលផ្សេងទៀតដូចជាភាពរាំងស្ងួតនិងទឹកជំនន់បានប៉ះពាល់ជាខ្លាំងលើទិន្នផលដំណាំ ហើយដែលធ្វើឲ្យវិស័យកសិកម្មក្លាយជាវិស័យមួយដែលងាយរងគ្រោះបំផុតពីការប្រែប្រួលអាកាសធាតុ។ ការកើនឡើងកំដៅត្រូវបានគេរកឃើញថា មានទំនាក់ទំនងជាមួយនឹងការធ្លាក់ចុះនៃទិន្នផលដំណាំ[២៦,២៧]។ ការសិក្សាថ្មីៗបង្ហាញថា ការកើនឡើងកំដៅត្រឹម ១0Cអាចធ្វើឲ្យទិន្នផលស្រូវក្នុងតំបន់ធ្លាក់ចុះប្រមាណ១០%។ នៅក្នុងសេនារីយ៉ូនៃការប្រែប្រួលអាកាសធាតុក្នុងពេលបច្ចុប្បន្ន និងប្រសិនបើគ្មានវិធីសាស្រ្តនិងបច្ចេកទេសកសិកម្មសម្រាប់បន្សាំទៅនឹងការប្រែប្រួលអស់ទាំងនេះទេ ទិន្នផលស្រូវក្នុងប្រទេសហ្វីលីពីន ថៃ និងវៀតណាមត្រឹមឆ្នាំ២១០០ អាចនឹងធ្លាក់ចុះប្រមាណពាក់កណ្ដាល និងប្រហែលជា៣៤% សម្រាប់ប្រទេសឥណ្ឌូនេស៊ី [២៤]។ ក្នុងរយៈពេលថ្មីៗនេះ ភាពរាំងស្ងួតក្នុងប្រទេសថៃ និងហ្វីលីពីនបានបង្កឡើងជាបញ្ហាទាក់ទងទៅនឹងការខ្វះខាតទឹកប្រើប្រាស់ក្នុងវិស័យកសិកម្ម[២៤,២៨] ។

**រូបភាពទី ១៖** និន្នាការនៃការប្រែប្រួលគំរបព្រៃឈើ




**ប្រភព៖** World Development Indicators 2018

ភាពមិនទៀងទាត់របស់ដំណើរទឹកភ្លៀង ការកើនឡើងនីវ៉ូទឹកសមុទ្រ និងការកើនឡើងកំហាប់អំបិលក្នុងទឹកនៅតាមតំបន់ទំនាបទន្លេនៃប្រទេសវៀតណាម និងមីយ៉ាន់ម៉ាបានធ្វើឲ្យតំបន់ទាំងនេះងាយរងគ្រោះទៅនឹងការជ្រាំទឹកការលិចទឹកជាប្រចាំ និងការកើនសារជាតិអំបិលនៅក្នុងដី[២៤]។ ទឹកជំនន់នៅប្រទេសឥណ្ឌូនេស៊ីប៉ះពាល់ដីស្រែ២៦៨.៨២៣ ហិកតា និងខូចខាតផលស្រូវប្រមាណ១.៣៤៤លានតោន[២៤]។ ការកើនឡើងនីវ៉ូទឹកសមុទ្រនឹងបណ្តាលឲ្យលិចលង់ដីស្រែពី ១៥-២០លានហិចតា ទូទាំងអាស៊ីអាគ្នេយ៍ ហើយដែលបង្កជាការគំរាមកំហែងទៅដល់សន្តិសុខស្បៀងរបស់ប្រទេសក្នុងតំបន់[២៤]។ការកើនឡើងនីវ៉ូទឹកសមុទ្រត្រឹម៤០សង់ទីម៉ែត្រ អាចធ្វើឲ្យប្រជាជន ២១លានអ្នកដែលរស់នៅតាមតំបន់ឆ្នេរនិងតាមដងទន្លេនៅអាស៊ីអាគ្នេយ៍បាត់បង់ទីលំនៅ។ តាមការព្យាករណ៍ ១១% នៃជនជាតិវៀតណាមនឹងរងផលប៉ះពាល់ប្រសិនបើនីវ៉ូទឹកសមុទ្រឡើងមួយម៉ែត្រ[២៩]។ បច្ចុប្បន្ននេះ ផ្នែកខ្លះរបស់ទីក្រុងចាការតាគឺស្ថិតនៅក្រោមនីវ៉ូសមុទ្ររួចទៅហើយ ដែលក្នុងពេលជាមួយគ្នានេះទីក្រុងបាងកក និងម៉ានីលកំពុងរងការគំរាមកំហែងពីការកើនឡើងកំពស់ទឹកសមុទ្រ ភ្លៀងធ្លាក់គំហុកជាប្រចាំ និងព្យុះស៊ីក្លូនត្រូពិច[៣០]។

ការប្រែប្រួលអាកាសធាតុធ្វើឲ្យមានការប្រែប្រួលលក្ខណៈរបស់មូសុងវស្សា។ ការប្រែប្រួលនេះគួបផ្សំជាមួយនឹងការកសាងទំនប់វារីអគ្គិសនីជាច្រើននៅតាមដងទន្លេមេគង្គបានធ្វើឲ្យប៉ះពាល់ដល់ដំណើរលំហូរ និង លក្ខណៈរបស់ទឹកទន្លេ និងការកើនកំដៅក្នុងអាងទន្លេ[២៤,៣១]។ បើតាមគណៈកម្មការទន្លេមេគង្គកម្រិតទឹក ទន្លេមេគង្គក្នុងឆ្នាំ២០២០បានធ្លាក់ចុះដល់កម្រិតទាបបំផុត មិនធ្លាប់មានក្នុងរយៈពេល៦០ឆ្នាំ។ ផលិតភាពនិងសេវាអេកូឡូស៊ីរបស់បឹងទន្លេសាបនឹងទទួលផលប៉ះពាល់អវិជ្ជមានខ្លាំងពីការប្រែប្រួលនិងការអភិវឌ្ឍទាំងនេះ[៣២]។រដូវប្រាំងដែលយូរជាងមុន ការកើនឡើងកំដៅផែនដី និងការផ្លាស់ប្តូររបៀបប្រើប្រាស់ដីបានផ្តល់នូវលក្ខខណ្ឌដែលងាយបង្កឲ្យមានភ្លើងឆេះព្រៃ[៣៣]។ ភ្លើងឆេះព្រៃនៅកាលីម៉ាន់តាននិងកោះស៊ូម៉ាត្រារបស់ឥណ្ឌូនេស៊ីបានបំផ្លាញសេវាអេកូឡូស៊ីព្រៃឈើ ជីវៈចម្រុះ និងធ្វើឲ្យមានការប្រែប្រួលវដ្តទឹកក្នុងបរិយាកាស និងលក្ខខណ្ឌអាកាសធាតុក្នុងតំបន់[៣៣]។ ការប្រែប្រួលអាកាសធាតុនិងការកើនឡើងកំដៅផែនដីជាកត្តាដែលធ្វើឲ្យពូជដើមឈើមួយចំនួនដូចជាស្រល់និងកោងកាងពិបាកលូតលាស់និងរីកសាយ[៣៤,៣៥]។ ស្រដៀងគ្នានេះដែរ ការប្រែប្រួលអាកាសធាតុបាននាំទៅដល់ការផ្លាស់ប្តូរលក្ខណៈគីមីនិងរូបសាស្ត្ររបស់សមុទ្រដែលបណ្តាលអោយមានការប្រែប្រួលលក្ខខណ្ឌរដូវកាលរបស់ត្រី និងបរិមាណត្រីពីតំបន់មួយទៅតំបន់មួយ។ ការប្រែប្រួលនេះអាចនឹងធ្វើឲ្យធ្លាក់ចុះនូវបរិមាណត្រីនៅតំបន់អាស៊ីអាគ្នេយ៍ប្រហែលជា១០% នៅឆ្នាំ២០៥០[៣៦]។

## គោលនយោបាយសម្រាប់ការអភិរក្សតំបន់ព្រៃធម្មជាតិ

ការការពារធនធានព្រៃឈើ គឺជាចំណុចស្នូលរបស់គោលនយោបាយបរិស្ថាននិងការប្រែប្រួលអាកាសធាតុរបស់ប្រទេសស្ទើរតែទាំងអស់នៅក្នុងតំបន់អាស៊ីអាគ្នេយ៍[៣៧]។ ក្របខ័ណ្ឌគតិយុត្តិនិងអភិក្រមផ្សេងៗត្រូវបានអនុវត្ត[៣៨]។ នៅថ្នាក់តំបន់ សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍បានបង្កើតក្រុមការងារបច្ចេកទេសពីរដែលធ្វើការលើ (១)ការអភិរក្សធនធានធម្មជាតិនិងជីវៈចម្រុះ(AWGNCB)(២)ការគ្រប់គ្រងធនធានទឹក (AWGWRM)។ ក្រុមការងារទាំងពីរនេះជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងក្នុងតំបន់ដើម្បីប្រយុទ្ធប្រឆាំងទៅនឹងការកាប់បំផ្លាញព្រៃឈើ និងជំរុញការដាំដុះនិងស្តារព្រៃធម្មជាតិឡើងវិញ។ បន្ថែមពីលើនេះអាស៊ានក៏បានផ្តួចផ្តើមឲ្យមានក្របខ័ណ្ឌយុទ្ធសាស្ត្រមួយចំនួនទៀតដូចជា ក្របខ័ណ្ឌពហុវិស័យអាស៊ានលើការប្រែប្រួលអាកាសធាតុ ផែនការយុទ្ធសាស្ត្រអាស៊ានសម្រាប់ដោះស្រាយបញ្ហាក្នុងវិស័យកសិកម្ម ព្រៃឈើនិងជលផល និងគំនិតផ្តួចផ្តើម Heart of Borneo ជាដើម[៣៩]។ ក្រុមការងារពិសេសមួយត្រូវបានបង្កើតនៅឆ្នាំ២០០២ ដើម្បីរៀបចំគម្រោងវិញ្ញាបនកម្មព្រៃឈើសម្រាប់អាស៊ាន [៤០]។ សេចក្តីប្រកាសទាក់ទងនឹងនិរន្តរភាពបរិស្ថានត្រូវបានអនុម័តដោយអាស៊ានក្នុងឆ្នាំ២០០៧ ដែលគោលបំណងសំខាន់មួយរបស់សេចក្តីប្រកាស គឺដើម្បីពង្រឹងការអនុវត្តច្បាប់សម្រាប់ការប្រយុទ្ធប្រឆាំងជាមួយនឹងការកាប់បំផ្លាញ និងការជួញដូរឈើខុសច្បាប់។ សេចក្តីប្រកាសនេះបាននាំឲ្យមានការបង្កើតនូវបណ្តាញចែករំលែកព័ត៌មានក្នុងតំបន់ដើម្បីពង្រឹងការអនុវត្តច្បាប់និងអភិបាលកិច្ចព្រៃឈើ[៤០]។ ប្រទេសកម្ពុជា ឡាវ ម៉ាឡេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន និងថៃជាសមាជិកអង្គការព្រៃឈើត្រូពិចអន្តរជាតិ (ITTO) [៣៧]។សម្រាប់ថ្នាក់ជាតិ ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព(Sustainable Forest Management SFM) គឺជាស្នូលរបស់គោលនយោបាយគ្រប់គ្រងព្រៃឈើ[៣៧]។ នៅក្រោម SFM គោលការណ៍អនុវត្ត (Code of Practice COP) ត្រូវបានរៀបចំដើម្បីការអនុវត្តច្បាប់គ្រប់គ្រងព្រៃឈើ និងដើម្បីកាត់បន្ថយផលប៉ះពាល់ដែលបណ្តាលមកពីការកាប់បំផ្លាញព្រៃឈើដល់បរិស្ថាន និងសង្គម។ អាស៊ានអនុម័ត COP នៅឆ្នាំ២០០១។ ប្រទេសមួយចំនួនដូចជា កម្ពុជា ឥណ្ឌូនេស៊ី ឡាវ ម៉ាឡេស៊ី និងមីយ៉ាន់ម៉ាបានរៀបចំ COP

របស់ខ្លួនក្នុងឆ្នាំ២០០៩[៣៧]។ កំណែទម្រង់ចម្បងៗក្នុងវិស័យព្រៃឈើត្រូវបានចាប់អនុវត្តតាំងពីឆ្នាំ១៩៩៩ នៅក្នុងប្រទេសឥណ្ឌូនេស៊ី ហ្វីលីពីន ថៃ និងក្រោយមកកម្ពុជានិងវៀតណាម[៣៨]។ ប្រទេសថៃហាមឃាត់ការកាប់ព្រៃឈើចាប់តាំងពីឆ្នាំ១៩៨៨។ ដោយអនុវត្តតាមសេចក្តីប្រកាសទីក្រុងបាលីវិធានការស្រដៀងគ្នាដើម្បីទប់ស្កាត់ការលួចកាប់និងជួញដូរឈើខុសច្បាប់ត្រូវបានអនុវត្តក្នុងប្រទេសឥណ្ឌូនេស៊ី ម៉ាឡេស៊ី និង ហ្វីលីពីន [៤០]។ ប្រទេសឥណ្ឌូនេស៊ីបានអនុម័តច្បាប់មួយចំនួនដើម្បីការពារធនធានព្រៃឈើ[៤១]។ កម្ពុជាក៏ដូចជាបណ្តាប្រទេសអាស៊ានជិតខាងបានរៀបចំគោលការណ៍ណែនាំស្តីពីជីវចម្រុះគ្រប់ជ្រុងជ្រោយសម្រាប់ការគ្រប់គ្រងព្រៃសម្បទាន[៣៧]។

ជាការឆ្លើយតបទៅនឹង UNFCCC និងពិធីសារក្យូតូ បណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍បានបង្ហាញនូវការប្តេជ្ញាចិត្តខ្ពស់ក្នុងទប់ទល់នឹងការប្រែប្រួលអាកាសធាតុ តាមរយៈការរៀបចំ និងអនុវត្តកម្មវិធី REDD និង REDD+ មួយចំនួនធំនៃកម្មវិធីនេះគឺផ្តោតទៅលើការអភិរក្សព្រៃឈើនិងការលើកកម្ពស់ការប្រើប្រាស់ដីប្រកបដោយនិរន្តរភាព [៤២,៤៣,៤៤]។ នៅក្នុងយុទ្ធសាស្ត្រ REDD+ ថ្នាក់ជាតិ ជាឧទាហរណ៍ ប្រទេសហ្វីលីពីនបានអនុវត្តដោយយកចិត្តទុកដាក់នូវយន្តការការពារព្រៃឈើនៅទូទាំងតំបន់ការពារ។ កម្មវិធីនេះមានឥទ្ធិពលយ៉ាងខ្លាំងក្នុងការជំរុញសន្និធិកាបូនរបស់ប្រទេស បើទោះជាវាបានកាត់ផ្តាច់ប្រជាពលរដ្ឋនៅក្នុងតំបន់ពីប្រភពចំណូលរបស់ពួកគេក៏ដោយ។ លក្ខណៈស្រដៀងគ្នានេះត្រូវបានមើលឃើញពីការអនុវត្តគម្រោងការពារព្រៃឈើនៅក្នុងប្រទេសថៃ [៤៤]។ គម្រោងការពារព្រៃឈើនៅឥណ្ឌូនេស៊ីបានជះផលវិជ្ជមានយ៉ាងច្រើនទាំងក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័ន និងការផ្តល់ផលប្រយោជន៍ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមូលដ្ឋាន។ នេះក៏ដោយសារអត្ថប្រយោជន៍នានាដែលបានមកពីការគ្រប់គ្រងព្រៃឈើត្រូវបានផ្តល់ទៅឲ្យប្រជាពលរដ្ឋក្នុងតំបន់វិញ[៤៤] ។ សហគមន៍ ព្រៃឈើ ជាផ្នែកសំខាន់ក្នុងកម្មវិធីគ្រប់គ្រងព្រៃឈើរបស់ប្រទេសមីយ៉ាន់ម៉ា [៤៥] ។ ប្រទេសឡាវបានអនុវត្តដោយជោគជ័យនូវកម្មវិធី គ្រប់គ្រងការប្រើប្រាស់ដីតាមរយៈការកាត់បន្ថយការរានដីព្រៃដើម្បីកសិកម្ម និងការរក្សាព្រៃធម្មជាតិ[១៥]។ ប្រទេសកម្ពុជាបានអនុវត្តគម្រោង REDD ថ្នាក់ជាតិតាំងពីឆ្នាំ២០១១ ក្នុងគោលបំណងដើម្បីជំរុញការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព និងដើម្បីលក់ឥណទានកាបូន។ គម្រោងក៏មានគោលដៅដើម្បីទ្រទ្រង់សហគមន៍ព្រៃឈើ និងលើកកម្ពស់ការគ្រប់គ្រងតំបន់ព្រៃការពារ[៤៦]។

## តួនាទីរបស់សភា

ទោះបីជាមានកិច្ចខិតខំទាំងនេះប៉ុន្តែតំបន់ព្រៃធម្មជាតិនៅអាស៊ីអាគ្នេយ៍នៅតែបន្តធ្លាក់ចុះ ហើយឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុក៏កាន់តែកើនឡើង។ ប្រឈមទៅនឹងបញ្ហាទាំងនេះ តួនាទីរបស់សភាក្នុងការធានាឲ្យបាននូវប្រសិទ្ធភាពក្នុងការអនុវត្តច្បាប់និងគោលនយោបាយពាក់ព័ន្ធគឺរឹតតែមានសារៈសំខាន់។ជាមួយនឹងមុខងារត្រួតពិនិត្យ សភាអាចកោះប្រជុំជាប្រចាំជាមួយនឹងក្រសួងពាក់ព័ន្ធដើម្បីកំណត់ពីការប្រឈមនានាក្នុងការអនុវត្តនិងពង្រឹងការអនុវត្តច្បាប់។ សភាអាចយកឱកាសនេះសម្រាប់ផ្តល់ជាយោបល់និងគំនិតឲ្យបានទាន់ពេលវេលាមុននឹងសម្រេចអនុម័តច្បាប់ឬការធ្វើវិភាជថវិកា។

សភាអាចពិចារណាធ្វើវិសោធនកម្មច្បាប់ និងគោលនយោបាយគ្រប់គ្រងព្រៃឈើ តាមរយៈការផ្តល់នូវធាតុចូលសំខាន់ៗក្នុងដំណាក់កាលរៀបចំវិសោធនកម្ម ដើម្បីធានាឲ្យបានថា ការអនុវត្តច្បាប់ទាំងនោះនឹងចូលរួមដោះស្រាយបញ្ហាពិតប្រាកដមែន។ ការត្រួតពិនិត្យរបាយការណ៍វឌ្ឍនភាពពីក្រសួងពាក់ព័ន្ធក៏អាចផ្តល់នូវព័ត៌មានសំខាន់ៗទាក់ទិនទៅនឹងនិន្នាការអភិវឌ្ឍន៍ក្នុងវិស័យនីមួយៗ។ សភាអាចប្រមូលនូវធាតុចូលនិងបទពិសោធន៍ល្អៗបន្ថែមទាក់ទងទៅនឹងការអភិវឌ្ឍ វិស័យកសិកម្មនិងព្រៃឈើនិងការប្រែប្រួលអាកាសធាតុពីបណ្តាអង្គការសង្គមស៊ីវិលដែលធ្វើការផ្ទាល់ និងពីរបកគំហើញដែលបានមកពីការស្រាវជ្រាវថ្មីៗរបស់ស្ថាប័នស្រាវជ្រាវ។ ការដាក់បញ្ចូលនូវធាតុចូលទាំងនេះអាចធានាបានថា បញ្ហាដែលបានកើតឡើងនៅតំបន់មូលដ្ឋានត្រូវបានជ្រួតជ្រាបដល់ និងទទួលបានអន្តរាគមន៍ពីសភា។ ក្នុងន័យនេះ សមាជិកសភាអាចបន្តពាំនាំនិងចែករំលែកនូវព័ត៌មានដែលខ្លួនទទួលបានទៅដល់ថ្នាក់ដឹកនាំជាតិ។ សភាអាចប្រើប្រាស់មុខងារជាតំណាងរបស់ខ្លួនដើម្បីពិចារណារៀបចំការចុះមូលដ្ឋាននិងរៀបចំវេទិកាពិគ្រោះយោបល់សាធារណៈដើម្បីបង្កើន ការយល់ដឹងរបស់ប្រជាពលរដ្ឋទាក់ទងទៅនឹងការកាប់បំផ្លាញព្រៃឈើនិងការប្រែប្រួលអាកាសធាតុ។

បណ្តាសភាអាស៊ានអាចធ្វើការជាមួយគ្នាដើម្បីចែករំលែកបទពិសោធន៍និងមេរៀនល្អៗទាក់ទងទៅនឹងវិធីសាស្ត្រក្នុងការទប់ទល់និងបន្សាំជាមួយនឹងការប្រែប្រួលអាកាសធាតុ។ ការប្រឈមធំៗមួយចំនួនដូចជា ការកាប់បំផ្លាញព្រៃឈើរដូវប្រាំងដែលអូសបន្លាយយូរជាងមុន ទឹកជំនន់ ការកើនឡើងកំដៅ និងជោគជ័យក្នុងការអនុវត្តនូវកម្មវិធី REDD និង REDD+ ពិតជាធ្វើបានប្រសើរបំផុតជាមួយនឹងក្របខ័ណ្ឌពហុភាគី។

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដែលបកដោយវិទ្យាស្ថានសភាកម្ពុជា (PIC)។
អត្ថបទដើមជាភាសាអង់គ្លេសអាចទាញយកពីគេហទំព័រ៖ https://www.pic.org.kh ។

# ៤.៤ ប្រសិទ្ធភាពនៃច្បាប់ដើម្បីឆ្លើយតបទៅនឹងបញ្ហា ប្រឈមដែលបណ្ដាលមកពីបម្រែបម្រួលអាកាសធាតុ

## ការអនុវត្តច្បាប់បរិស្ថាននៅអាស៊ី ជាពិសេសនៅអាស៊ីអាគ្នេយ៍

ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុទៅលើទឹក ស្បៀង និងថាមពល មានភាពខុសគ្នារវាងតំបន់ និងប្រទេស ដោយហេតុផលភូមិសាស្ត្រអាកាសធាតុ (geoclimatic reasons) ក៏ដូចជា ហេតុផលប្រជាសាស្ត្រ និងហេតុផលសេដ្ឋកិច្ចសង្គម។

យោងតាមអង្គការសហប្រជាជាតិតំបន់អាស៊ីជាពិសេសតំបន់អាស៊ីអាគ្នេយ៍គឺជាតំបន់ដែលទទួលការគំរាមកំហែងខ្លាំងបំផុតពីការប្រែប្រួលអាកាសធាតុ។ ទោះយ៉ាងណាហាក់ដូចជាមិនទាន់ឃើញមានគំនិតផ្ដួចផ្ដើមបញ្ចូលគ្នានៅថ្នាក់តំបន់នៅអាស៊ីច្រើននៅឡើយទេ ដើម្បីឆ្លើយតបទៅនឹងការគំរាមកំហែងនេះ ជាពិសេសក្នុងក្របខ័ណ្ឌអាស៊ាន។ អនុតំបន់អាស៊ីអាគ្នេយ៍ដែលមានប្រជាជនជាង ៦២០លាននាក់ ដឹងច្បាស់ពីទំនាក់ទំនងរវាងវិបត្តិអាកាសធាតុ ការអភិវឌ្ឍប្រកបដោយចីរភាព និងសន្តិសុខប្រជាជន ដោយសារតែប្រទេសចំនួន៤ ក្នុងចំណោមប្រទេសចំនួន១០ ដែលទទួលរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុច្រើនជាងគេនៅលើពិភពលោកគឺជារដ្ឋជាសមាជិកអាស៊ាន (ប្រទេសឥណ្ឌូនេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន និងវៀតណាម) [៤៧]។ បណ្ដាប្រទេសទាំងនេះដូចជាបណ្ដាប្រទេសនៅអាស៊ីអាគ្នេយ៍ទាំងមូល តែងប្រឈមមុខជានិច្ចជាមួយព្យុះស៊ីក្លូននិងទឹកជំនន់។ យោងតាមអង្គការសហប្រជាជាតិ ប្រជាជនចំនួន ៧០%នៃចំនួនប្រជាជនពិភពលោកដែលនឹងរងផលប៉ះពាល់ខ្លាំងបំផុតពីការកើនឡើងកម្ពស់ទឹកសមុទ្រ គឺជាប្រជាជនដែលកំពុងរស់នៅក្នុងបណ្ដាប្រទេសអាស៊ាន [៤៨]។

អាស៊ានបានសម្ដែងការព្រួយបារម្ភជារួម អំពីការប្រែប្រួលអាកាសធាតុនៅក្នុងសេចក្ដីប្រកាសជាច្រើនហើយបានអនុម័តផែនការសកម្មភាពជាក់លាក់តាមវិស័យនិងធ្វើសេចក្ដីសម្រេចចិត្តក្នុងតំបន់ដើម្បីដោះស្រាយការបំពុលឆ្លងព្រំដែន [៤៩] និងការការពារជីវចម្រុះ [៥០]។ ទោះយ៉ាងណាផែនការតំបន់ដើម្បីដោះស្រាយបញ្ហាបរិស្ថានទាំងមូលមិនទាន់មានការឯកភាពគ្នាដោយសមាគមអាស៊ាននៅឡើយទេ។ ទោះយ៉ាងណាក៏ដោយ អាស៊ានបានប្រកាសថាផែនការយុទ្ធសាស្ត្រអាស៊ាននេះ នៅកំពុងរៀបចំឡើងដោយមានឈ្មោះថា ផែនការបរិស្ថានយុទ្ធសាស្ត្រអាស៊ាន (ASEAN Strategic Environmental Plan) [A] [៥១]។

ផែនការសកម្មភាពលម្អិតបន្ថែមនេះរៀបចំឡើងក្នុងគោលបំណងផ្ដល់ជាឯកសារណែនាំសម្រាប់អាស៊ានដើម្បីជំរុញកិច្ចសហប្រតិបត្តិការបរិស្ថានក្នុងចំណោមរដ្ឋជាសមាជិករបស់ខ្លួនរហូតដល់ឆ្នាំ២០២៥។ ទោះយ៉ាងណាគួរកត់សម្គាល់ថា ខណៈដែលអង្គការសហប្រជាជាតិអះអាងថាការតភ្ជាប់រវាងទឹក ស្បៀង និងថាមពល គឺជាស្នូលនៃការអភិវឌ្ឍប្រកបដោយចីរភាព[៥២] ហើយអង្គការស្បៀងអាហារនិងកសិកម្មរបស់អង្គការសហប្រជាជាតិ (FAO) បានណែនាំថា ការតភ្ជាប់ទឹក ស្បៀង និងថាមពលជាចំណុចដែលត្រូវតែយកមកពិចារណាជានិច្ច នៅពេលគិតពីជម្រើសវិធានការដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលបណ្ដាលមកពីការប្រែប្រួលអាកាសធាតុ[៥៣]។ ការតភ្ជាប់នេះហាក់ដូចជាមិនទាន់បានឃើញជាផ្នែកច្បាស់លាស់នៅក្នុងចំណោមចំណុចអាទិភាពទាំង៧ ដែលត្រូវបញ្ចូលក្នុងក្របខ័ណ្ឌនៃផែនការយុទ្ធសាស្ត្រនេះទេ [៥៤]។ សម្រាប់សហភាពអឺរ៉ុបវិញដោយមានកិច្ចសហការជាមួយដៃគូដទៃទៀត បានបង្កើតធនធានតាមអ៊ីនធឺណេត ដែលនេះបានបង្ហាញយ៉ាងច្បាស់នូវគោលការណ៍តភ្ជាប់ទឹក ស្បៀង និងថាមពលនេះ [៥៥]។

ពិតណាស់ ការប្រែប្រួលអាកាសធាតុត្រូវតែដោះស្រាយនៅកម្រិតពហុភាគី។ [B] ទោះយ៉ាងណា ខណៈដែលកិច្ចព្រមព្រៀងពហុភាគីជាសកលទទួលបានការយកចិត្តទុកដាក់ខ្លាំងនោះក៏ដោយក៏កិច្ចព្រមព្រៀងថ្នាក់តំបន់ និងអនុតំបន់នៅមានសារៈសំខាន់កាន់តែខ្លាំងឡើងៗជាពិសេសលើបញ្ហាបរិស្ថានសំខាន់ៗ ព្រោះចំណេះដឹងក្នុងតំបន់បានអនុញ្ញាតឲ្យរកជម្រើសដំណោះស្រាយជាក់លាក់បាន និងពីព្រោះកិច្ចព្រមព្រៀងថ្នាក់តំបន់និងអនុតំបន់នោះបានពង្រឹងកិច្ចសហប្រតិបត្តិការជាមួយប្រទេសជិតខាងជាមិនខានទៀតផង។ [៥៤ ទំ.៣៥] ក្នុងករណីខ្លះដូចជាការជួញដូរកាកសំណល់ (សំរាម) គ្រោះថ្នាក់និងការនាំចូលដោយគេចពន្ធនូវផលិតផលសត្វព្រៃ ការអនុវត្តការប្រយុទ្ធប្រឆាំងនឹងការជួញដូរនិងការនាំចូលដោយគេចពន្ធនោះមានការលំបាក ប្រសិនបើគ្មានកិច្ចសហប្រតិបត្តិការក្នុងតំបន់ ឬអនុតំបន់ ឬជាកិច្ចសហប្រតិបត្តិការទ្វេភាគី និងការចែករំលែកព័ត៌មានទៅវិញទៅមក [៥៦]។

ទោះយ៉ាងណារដ្ឋនីមួយៗនៅតែអាចអនុវត្តយុទ្ធសាស្ត្រកាត់បន្ថយផលប៉ះពាល់ទៅលើទឹកដី សេដ្ឋកិច្ច និងប្រជាជនរបស់ខ្លួន។ គិតត្រឹមឆ្នាំ២០១៧ ប្រទេសចំនួន១៧៦ បានអនុម័តក្របខ័ណ្ឌគតិយុត្តិបរិស្ថាន ១៥០ប្រទេសបានដាក់

ការការពារបរិស្ថាន ឬសិទ្ធិទទួលបានបរិស្ថានល្អនៅក្នុងរដ្ឋធម្មនុញ្ញរបស់ខ្លួន ហើយ ១៦៤ ប្រទេសបានបង្កើតស្ថាប័នរដ្ឋាភិបាលទទួលខុសត្រូវចំពោះការការពារបរិស្ថាន (សូមមើលតារាង "បណ្តាប្រទេសអាស៊ីដែលមានក្របខ័ណ្ឌគតិយុត្តបរិស្ថានក្នុងឆ្នាំ១៩៧២ ១៩៩២ និង២០១៧")។ [១៣] សិទ្ធិ ច្បាប់ និងស្ថាប័នបរិស្ថានទាំងនេះបានចូលរួមចំណែកក្នុងការកាត់បន្ថយការកើនឡើងនៃការបំផ្លាញបរិស្ថាន ហើយក្នុងករណីខ្លះបានចូលរួមចំណែកក្នុងការធ្វើអោយការបំផ្លាញនោះថយចុះតែម្តង។ សិទ្ធិ ច្បាប់ និងស្ថាប័នបរិស្ថានទាំងនោះក៏បានចូលរួមចំណែកក្នុងការនាំប្រយោជន៍ដល់ប្រជាជនឲ្យទទួលបានផលសុខភាពសាធារណៈ សេដ្ឋកិច្ចសង្គម និងសិទ្ធិមនុស្សល្អៗ ដែលតែងតែរួមចំណែកការពារបរិស្ថាន [៥៧ ទំ.៨]។

ទោះយ៉ាងណា ការអនុវត្តច្បាប់និងបទបញ្ញត្តិបរិស្ថានច្រើនតែមិនគ្រប់គ្រាន់ ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមបរិស្ថាន។ ពេលខ្លះច្បាប់ខ្វះស្តង់ដារច្បាស់លាស់ឬអាណត្តិអំណាចចាំបាច់។ ច្បាប់ខ្លះទៀតមិនសមស្របនឹងបរិបទជាតិ និងមូលដ្ឋាន ដូច្នេះប្រឈមនឹងបញ្ហាដែលមិនបានមើលឃើញទុកជាមុន។ ប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនផ្តល់អាទិភាពដល់ម៉ាក្រូសេដ្ឋកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចនៅពេលបែងចែកមូលនិធិសាធារណៈ និងកំណត់អាទិភាពសម្រាប់សកម្មភាពរបស់រដ្ឋាភិបាល។ [C] ដោយមូលហេតុនេះ ក្រសួងបរិស្ថានខ្វះធនធាន និងជាស្ថាប័នខ្សោយផ្នែកនយោបាយ បើប្រៀបធៀបទៅនឹង ក្រសួងដែលទទួលខុសត្រូវក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងគ្រប់គ្រងធនធានធម្មជាតិ។[៥៧ ទំ.៨] ខណៈជំនួយបច្ចេកទេស និងហិរញ្ញវត្ថុអន្តរជាតិបានជួយប្រទេសជាច្រើនក្នុងការបង្កើតក្របខ័ណ្ឌគតិយុត្តិស្តីពីបរិស្ថាន ប៉ុន្តែទាំងថវិកាជាតិនិងជំនួយអន្តរជាតិមិនមានភាពគ្រប់គ្រាន់ដើម្បីបង្កើតភ្នាក់ងារបរិស្ថានរឹងមាំដែលចាំបាច់ដើម្បីពង្រឹងឲ្យបានគ្រប់គ្រាន់នូវសមត្ថភាពរបស់បុគ្គលិកស្ថាប័នបរិស្ថានផ្សេងៗដូចជា សមត្ថភាពរបស់ចៅក្រមជាតិផងដែរ ក្នុងការងារពាក់ព័ន្ធនឹងច្បាប់បរិស្ថាន ឬដើម្បីរៀបចំឡើងនូវការអប់រំអំពីច្បាប់ និងការអនុវត្តច្បាប់នោះប្រកបដោយចីរភាព [៥៧ ទំ.៣]។

កង្វះខាតក្នុងការអនុវត្តច្បាប់បរិស្ថានមិនត្រូវបានឃើញតែក្នុងប្រទេសកំពុងអភិវឌ្ឍន៍តែប៉ុណ្ណោះទេ។ យោងតាមលទ្ធផលនៃការពិនិត្យឡើងវិញជារៀងរាល់ឆ្នាំរបស់ប្រទេសសមាជិកសហភាពអឺរ៉ុបដែលបានចេញផ្សាយនៅឆ្នាំ២០១៧ ដោយគណៈកម្មការអឺរ៉ុប បណ្តាប្រទេសអភិវឌ្ឍន៍ជាច្រើនបានអនុម័តច្បាប់ស្តីពី បរិស្ថានយ៉ាងតឹងរឹង (តឃ្លើន) និងគ្រប់ជ្រុងជ្រោយ ដែលឆ្លើយតបគ្រប់បញ្ហាបរិស្ថាន ប៉ុន្តែការអនុវត្តច្បាប់ទាំងនោះរបស់ប្រទេសអភិវឌ្ឍន៍ទាំងនោះប្រឈមមុខនឹងការលំបាកជាច្រើនដែលធ្វើឲ្យការអនុវត្តនេះមានការរារាំង [D] [៥៧ ទំ.១៣]។

ចុងបញ្ចប់ការបង្កើតសារពើភ័ណ្ឌពេញលេញនៃច្បាប់និងបទបញ្ញាជាតិ គឺជាកិច្ចការដែលមិនអាចធ្វើទៅរួចនោះទេ ព្រោះបរិស្ថានជាបញ្ហាអន្តរវិស័យដែលគ្របដណ្តប់លើវិស័យជាច្រើន (កសិកម្ម នគរូបនីយកម្ម ការដឹកជញ្ជូន ថាមពល ការប្រើប្រាស់ស្បៀង ប្រព័ន្ធជាពាសាស្ត្រ ឧស្សាហកម្ម ការបណ្តុះបណ្តាល។ល។) ច្បាប់ស្តីពី បរិស្ថានក៏រួមបញ្ចូលគ្នាជាមួយទម្រង់ និងបទដ្ឋានច្បាប់ផ្សេងៗ ជាច្រើនផងដែរ (រាប់ពីបទដ្ឋានភូមិ និងសង្គមតាមបែបប្រពៃណីរហូតដល់ច្បាប់របស់ប្រទេសនានា និងបទដ្ឋានដែលត្រូវបានអនុម័តដោយក្រុមហ៊ុន និងអង្គការផ្សេងៗដោយស្ម័គ្រចិត្ត)។ ច្បាប់ស្តីពីបរិស្ថានក៏គ្របដណ្តប់ លើកម្រិតអភិបាលកិច្ចជាច្រើន (រាប់ពីអភិបាលកិច្ចទំនៀមទម្លាប់ ក្នុងចំណោមប្រជាជនជនជាតិដើមភាគតិច និងជនបទ រហូតដល់អភិបាលកិច្ចថ្នាក់ក្រោមជាតិ និងអភិបាលកិច្ចជាតិ រួមទាំងបទបញ្ញត្តិរដ្ឋាភិបាលក្នុងតំបន់និងអន្តរជាតិ)។លើសពីនេះទៀត ការអនុវត្តច្បាប់បរិស្ថាន ជាការទទួលខុសត្រូវរបស់ក្រសួងស្ថាប័ន ភ្នាក់ងារ ឬមន្ទីរមួយចំនួននៅកម្រិតរដ្ឋាភិបាលជាច្រើន។

## អាស៊ីជាតំបន់ដែលប្រឈមបំផុតនឹងការប្រែប្រួលអាកាសធាតុ

បញ្ជីនៃហានិភ័យអាកាសធាតុដែលបណ្តាប្រទេសអាស៊ីត្រូវបានប្រឈមមុខគឺមានហានិភ័យអាកាសធាតុនោះជាច្រើន។ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិអាល្លឺម៉ង់ដែលមានឈ្មោះថា Germanwatch Global Climate Risk Index បានបង្ហាញថា ប្រទេសចំនួន៦ ក្នុងចំណោមប្រទេសចំនួន ១០ ដែលរងផលប៉ះពាល់ខ្លាំងបំផុតក្នុងរយៈពេល ១០ឆ្នាំចុងក្រោយនេះ គឺនៅអាស៊ី (ភូមា ហ្វីលីពីន បង់ក្លាដែស ប៉ាគីស្ថាន វៀតណាម និងថៃ)។ ជាងនេះទៅទៀត ទីក្រុងអាស៊ីជាច្រើន គឺជាទីក្រុង នៅតាមឆ្នេរសមុទ្រ ដូចជាបុមបៃ ម៉ានីល ហ្សាការតា សៀងហៃ បាងកក ឬសិង្ហបុរី។ រដ្ឋធានីខ្លះដូចជា រដ្ឋធានីឥណ្ឌូណេស៊ី ស្ថិតនៅក្រោមកម្រិតទឹកសមុទ្ររួចទៅហើយ។ យោងតាមធនាគារពិភពលោក ការកើនឡើងទឹកសមុទ្រនៅអាស៊ីខាងកើត និងអាស៊ីអាគ្នេយ៍នឹងប៉ះពាល់ប្រជាជនពី ៣៧ ទៅ ៥០លាននាក់ (អាស្រ័យលើកំរិតនៃការកើនឡើងនេះ៖ ពី១ទៅ៣ម៉ែត្រ) ជាពិសេសនៅប្រទេសវៀតណាម ចិន និងឥណ្ឌូនេស៊ី។ អាស៊ីខាងត្បូងកាន់តែរងផលប៉ះពាល់ ជាពិសេសប្រទេសបង់ក្លាដែស និងឥណ្ឌា។

ចំណែកការកើនឡើងនៃសីតុណ្ហភាព ការកើនឡើងនេះនឹងប៉ះពាល់ជាពិសេសអាស៊ីខាងត្បូង។ នៅឆ្នាំ២០៥០ ប្រជាជនឥណ្ឌាមួយភាគបី អាចរងនូវសីតុណ្ហភាពយ៉ាងខ្លាំង (លើសពី ៣៥ អង្សាសេ) យ៉ាងហោចណាស់បីខែក្នុងមួយឆ្នាំ។ ការឡើងកម្តៅផែនដីត្រូវបានគេរំពឹងថានឹងជះឥទ្ធិពលដល់ទិន្នផលដំណាំក្នុងសមាមាត្រគួរឲ្យកត់សម្គាល់ ជាពិសេសនៅឧបទ្វីបឥណ្ឌា(ក្នុងចន្លោះពី៨-១០%អាស្រ័យលើប្រភេទពូជ)។បញ្ហាស្បៀងគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ខ្លួនឯង (food self-sufficiency) កំពុងក្លាយជាកង្វល់ដ៏ធំនៅក្នុងតំបន់នេះ ដែលកំណើនប្រជាជននៅតែខ្ពស់បំផុតនៅអាស៊ី។

ប្រភេទគ្រោះមហន្តរាយអាកាសធាតុដ៏សាហាវមួយទៀត (ព្យុះទីហ្វុង) កំពុងបោកបក់ដល់ឆ្នេរសមុទ្រអាស៊ីជាមួយនឹងការកើនឡើងនូវទំហំ (magnitude)គួរឲ្យកត់សម្គាល់ ជាពិសេសនៅក្នុងប្រទេសហ្វីលីពីន ជប៉ុន ចិន និងឥណ្ឌូនេស៊ី។ ការយល់ដឹងអំពី ហានិភ័យច្រើនប្រភេទ ពីប្រជាជននិងមតិសាធារណៈ កំពុងកើនឡើង និងអាចនាំឲ្យមានការសម្រេចចិត្តនយោបាយថ្មីនិងសកម្មជាងមុន [៥៩]។

ក្នុងចំណោមតំបន់នានាក្នុងពិភពលោកដែលទទួលរងនូវការខ្វះខាតទឹក អាស៊ីកំពុងប្រឈមនឹងកង្វះ ធនធានមនុស្ស ស្ថាប័ន និងហិរញ្ញវត្ថុដែលរឹតត្បិតការទទួលបានទឹក ទោះបីជាតំបន់នេះមានធនធានធម្មជាតិសម្បូរបែបយ៉ាងក៏ដោយ។ ការទទួលបានទឹកដែលមានកំរិតនេះ មានផលវិបាកធ្ងន់ធ្ងរដល់ផលិតកម្មកសិកម្ម [៦០ ទំ.៣៦]។ ទឹកទន្លេតិចក្រោម ២៥% នៃទឹកទន្លេសរុបត្រូវបានដកយកទៅប្រើដើម្បីបំពេញតម្រូវការរបស់ប្រជាជនហើយអាហារូបត្ថម្ភមានការខ្វះខាតកាន់តែធ្ងន់ធ្ងរ។ ផ្ទុយទៅវិញ មានការកើនឡើងនូវការទទួលបានធនធានទឹកនៅអឺរ៉ុបខាងជើង នៅប្រទេសរុស្ស៊ី និងនៅអាមេរិកខាងជើង ដែលធ្វើឲ្យអាចមានការកើនឡើងនូវផលិតកម្មកសិកម្មនៅឯទីនោះ [៦០ ទំ.៣៦]។

## អាស៊ីជាប្រភពពាក់កណ្តាលនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នៅក្នុងពិភពលោក

នៅឆ្នាំ២០១៨ ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នៅទ្វីបអាស៊ីស្មើនឹងចំនួនជិតពាក់កណ្តាលនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នៅក្នុងពិភពលោក និងស្មើនឹង២ភាគ៣នៃការកើនឡើងនៃការបញ្ចេញឧស្ម័នកាបូនិកក្នុងឆ្នាំ២០១៧ ដែលជាសមាមាត្រមួយដែលអាចនៅបន្តក្នុងរយៈពេលមួយទសវត្សរ៍ទៀត។ ជនជាតិអាស៊ីបានវិនិយោគយ៉ាងច្រើនក្នុងថាមពលកកើតឡើងវិញ (renewable_energy) និងក្នុងថាមពលដែលមានប្រសិទ្ធភាព (energy_efficiency) ប៉ុន្តែការប្តេជ្ញាចិត្តបច្ចុប្បន្នរបស់ពួកគេនៅតែមិនទាន់គ្រប់គ្រាន់ដើម្បីបញ្ចៀសនិន្នាការនេះ។ សកម្មភាពបន្ថែម ដូចជាការកាត់បន្ថយការកាប់បំផ្លាញព្រៃឈើ និងការបំផ្លាញព្រៃឈើនៅអាស៊ី ជាពិសេសនៅឥណ្ឌូណេស៊ី ក៏មានសារៈសំខាន់ផងដែរ ក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នក្នុងពិភពលោក [៦១]។

ការផ្ទុះឡើងនៃការបញ្ចេញឧស្ម័ន បណ្តាលភាគច្រើនមកពីដំណើរការអភិវឌ្ឍសេដ្ឋកិច្ចយ៉ាងខ្លាំងនៅអាស៊ីដើម្បីតាមឲ្យទាន់ប្រទេសអភិវឌ្ឍន៍ក្នុងរយៈពេល៥០ឆ្នាំ កន្លងមកនេះ ដែលផ្អែកលើឧស្សាហកម្មហេដ្ឋារចនាសម្ព័ន្ធ និងការនាំចេញ ជាមួយនឹងការប្រើប្រាស់ថាមពលហួសកំរិត។ ទោះបីជា អត្រានៃការបញ្ចេញឧស្ម័ននោះក្នុងមនុស្សម្នាក់នៅក្នុងប្រទេសអាស៊ីមួយចំនួនដូចជាឥណ្ឌា និងឥណ្ឌូនេស៊ីនៅតែទាបជាងមធ្យមភាគពិភពលោកក៏ដោយ ក៏ការបញ្ចេញឧស្ម័ននោះនៅតែខ្ពស់ជាងមធ្យមភាគនៅក្នុងប្រទេសអភិវឌ្ឍន៍នៅក្នុងតំបន់អាស៊ីដូចជា ប្រទេសចិន និងម៉ាឡេស៊ី [៦៣]។ សូមមើលតារាង “ការវិវឌ្ឍន៍នៃការបញ្ចេញឧស្ម័នកាបូនិចក្នុងមនុស្សម្នាក់ចន្លោះពីឆ្នាំ១៩៧០-២០១៤”)។ ទោះយ៉ាងណាអាស៊ីក៏ជាទ្វីបដែលងាយទទួលរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុដែលអាចបង្កអន្តរាយដល់ចក្ខុវិស័យសម្រាប់កំណើននាពេលអនាគត។

លើសពីនេះទៀត ត្រឹមឆ្នាំ២១០០ កំដៅអាចធ្វើឲ្យមនុស្សមិនអាចរស់នៅបាននៅអាស៊ីខាងត្បូង។ នេះបើយោងតាមការស្រាវជ្រាវថ្មីៗនេះដោយវិទ្យាស្ថានបច្ចេកវិទ្យាម៉ាសាឈូសេត (MIT) ដែលបានចេញផ្សាយនៅក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រ Sciences Advances។ អ្នកវិទ្យាសាស្ត្រព្រមានថា ប្រសិនបើមិនមានវិធានការណាមួយដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទេនោះ "ការកើនឡើងសីតុណ្ហភាព និងសំណើមនៅរដូវក្តៅអាចឈានដល់កម្រិតមួយដែលហួសពីសមត្ថភាពរបស់រាងកាយមនុស្សក្នុងការរស់រាន ដោយគ្មានការការពារ"។

តំបន់ជនបទមានផលប៉ះពាល់ច្រើនជាងទីក្រុង បើទោះបីជាទីក្រុង (ដែលមានចំនួនប្រជាជនខ្ពស់) នេះហើយដែលផលិតការបំពុលភាគច្រើន។ ហានិភ័យខ្លាំងបំផុតនៃអំឡុងពេលអនាគតនៃកំដៅខ្លាំង ត្រូវបានប្រមូលផ្តុំនៅជុំវិញតំបន់កសិកម្មដែលមានប្រជាជនច្រើនបំផុតនៅអាងគង្គា (The Ganges Basin) និងអាង Indus។ អាស៊ីខាងត្បូងដែលជាតំបន់មួយដែលមានប្រជាជនប្រមាណ ១ភាគ៥ នៃចំនួនប្រជាជនពិភពលោក ប្រឈមមុខនឹងហានិភ័យនៃការប្រែប្រួលអាកាសធាតុ ដែលមិនមានការកត់សំគាល់ ដោយសារតែការរួមផ្សំគ្នាដែលមិនធ្លាប់មានពីមុនមកនៃគ្រោះមហន្តរាយធម្មជាតិធ្ងន់ធ្ងរ និងភាពងាយរងគ្រោះខ្លាំងបំផុត [៦២]។

**ផែនទី ៣៖** ផូស៊ីលឥន្ធនៈ និងការបញ្ចេញឧស្ម័ន $CO_2$ តាមប្រទេស



## អាស៊ីជាតំបន់ដែលមានតម្រូវការស្បៀងអាហារច្រើនជាងគេ

បើយោងតាមការព្យាករណ៍នៅឆ្នាំ២០៥០ពិភពលោកនឹងមានប្រជាជនប្រមាណ៩ពាន់លាននាក់ ហើយស្បៀងអាហារនឹងក្លាយជាបញ្ហាធំមួយនៅទូទាំងពិភពលោក។ បច្ចុប្បន្នប្រជាជន៨៥០លាននាក់ មិនទាន់បានទទួលស្បៀងអាហារគ្រប់គ្រាន់ ដើម្បីបំពេញតម្រូវការចាំបាច់របស់ពួកគេនៅឡើយទេ ដូច្នេះ ផលិតកម្មស្បៀងអាហារត្រូវតែកើនឡើងយ៉ាងខ្លាំងទៅដល់ពេលនោះ [E] [៦៣]។

នៅទ្វីបអាស៊ីមានតម្រូវការស្បៀងអាហារធំបំផុត និងច្រើនជាងនៅទ្វីបអាហ្វ្រិកទៅទៀត។ ដើម្បីឲ្យប្រជាជនដែលមានការកើនឡើងនេះអាចទទួលបាននូវស្បៀងអាហារដែលពួកគេត្រូវការ ការធ្វើកសិកម្មត្រូវតែមានការកែលម្អជាច្រើនដើម្បីប្រសិទ្ធភាពនៃការធ្វើកសិកម្មនោះឲ្យប្រសើរឡើង ទាំងសម្រាប់កសិកម្មអាស្រ័យទឹកភ្លៀង (rain_fed_agriculture) ក៏ដូចជាកសិកម្មដែលអាស្រ័យលើប្រព័ន្ធធារាសាស្ត្រ (irrigated_agriculture) ប៉ុន្តែនេះមិនគ្រប់គ្រាន់ទេ ពីព្រោះដីទំនងជាមានតម្លៃថ្លៃជាងមុន (តម្លៃនីត្រាតកំណត់តាមតម្លៃប្រេងនិងផូស្វាត (phosphate)ហើយទុនបម្រុងអាចអស់)។ ទោះយ៉ាងណាក៏ដោយ ហាក់ដូចជា (ដូចដែលបានបង្ហាញយ៉ាងច្បាស់នៅក្នុងតារាង៦និង៧) តំបន់មួយចំនួនខ្លះមិនមានដីបង្កបង្កើនផល (arable_land) គ្រប់គ្រាន់ទេ ជាពិសេសនៅអាស៊ី និងមជ្ឈឹម បូព៌ា/អាហ្វ្រិកខាងជើង (Middle_East/North_Africa) ដែលមានចំនួនប្រជាជនច្រើនជាងពាក់កណ្តាលនៃចំនួនប្រជាជនសរុបក្នុងពិភពលោក។ នៅអាស៊ី ៧៥% នៃដីបង្កបង្កើនផល (arable_land) បានត្រូវគេធ្វើអាជីវកម្មរួចហើយ។ សេណារីយ៉ូនេះតម្រូវឲ្យមានការផ្លាស់ប្តូរបច្ចេកវិជ្ជាសំខាន់ៗដើម្បីបង្កើនប្រសិទ្ធភាព (+៥០% នៃកសិកម្មដែលផ្គត់ផ្គង់ដោយទឹកភ្លៀង និងស្រោចស្រពនៅទ្វីបអាស៊ី) ជាមួយនឹងការវិនិយោគដែលមានការគ្រប់គ្រង និងការកំណត់ទៅលើប្រព័ន្ធធារាសាស្ត្រ [៦០ ទំ.២០]។

## ការវិភាគហិរញ្ញប្បទាននៃគម្រោងដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុនៅអាស៊ី

ទិន្នន័យដកស្រង់ពីគេហទំព័ររបស់អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ (Climate_Fund_Update) បង្ហាញថា សម្រាប់ប្រទេសចំនួន១៨ នៅអាស៊ី [៦៤] មានសរុបទឹកប្រាក់ចំនួន៤,៥ពាន់លានដុល្លារអាម៉េរិក ត្រូវបានផ្តល់ដោយកម្មវិធីនិងមូលនិធិឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុពហុភាគីចំនួន១៨សម្រាប់អនុវត្តគម្រោង និងកម្មវិធីចំនួន៤៥៣។ ទោះយ៉ាងណាថវិកាយ៉ាងច្រើនត្រូវបានផ្តល់ដល់បណ្តាប្រទេសដែលមានកំណើនសេដ្ឋកិច្ចខ្ពស់ ដូចជាឥណ្ឌានិងឥណ្ឌូនេស៊ី ជាពិសេសសម្រាប់ការកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ (mitigation) ប៉ុន្តែមិនមែនសម្រាប់ឆ្លើយតបទៅនឹងបញ្ហាផលប៉ះពាល់នេះដោយចីរភាពទេ (adaptation)។ម៉្យាងវិញទៀត ប្រទេសមួយចំនួនដែលមានហានិភ័យពីការប្រែប្រួលអាកាសធាតុដូចជាប្រទេសស្រីលង្កាបានទទួលថវិកាតិចតួច។

នៅក្នុងឆ្នាំ២០១៩ ចំនួនទឹកប្រាក់ ៧៤៩លានដុល្លារអាម៉េរិកដែលត្រូវផ្តល់ហិរញ្ញប្បទានដល់គម្រោង ចំនួន១០ត្រូវបានអនុម័ត។ ហិរញ្ញប្បទាននេះភាគច្រើនបានមកពីមូលនិធិបៃតងសម្រាប់អាកាសធាតុ (Green_Climate_Fund)[៦៥] ហើយជាងពាក់កណ្តាលនៃគម្រោងទាំងនេះគឺជាគម្រោងសម្រាប់ការកាត់បន្ថយ (mitigation) ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ មូលនិធិបៃតងសម្រាប់អាកាសធាតុ (Green_Climate_Fund) បានអនុម័តផ្តល់ហិរញ្ញប្បទានក្នុងតំបន់អាស៊ីឲ្យគម្រោងចំនួនមួយសម្រាប់ឆ្លើយតបទៅនឹងបញ្ហាផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុដោយចីរភាព (adaptation) និងគម្រោងពហុគ្រួសារចំនួនបួនបន្ថែមលើគម្រោងកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ (mitigation) ចំនួន៥ ដែលស្មើនឹងទឹកប្រាក់សរុបចំនួន ៦១៩លានដុល្លារ នៅឆ្នាំ២០១៨ [E] [៦៦]។

ហិរញ្ញប្បទានលក្ខណៈទ្វេភាគីទៅទ្វីបអាស៊ីក៏បានបំពេញបន្ថែមលំហូរនៃហិរញ្ញប្បទានលក្ខណៈពហុភាគីផងដែរ។ នេះរួមបញ្ចូលទាំងមូលនិធិអាកាសធាតុទ្វេភាគីមកពីប្រទេសអូស្រ្តាលី អាល្លឺម៉ង់ និង ចក្រភពអង់គ្លេសដែលសកម្មនៅក្នុងតំបន់[G][៦៦]។សន្ធិសញ្ញាមិត្តភាពនិងកិច្ចសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ក៏ត្រូវបានចុះហត្ថលេខារវាងប្រទេសអាល្លឺម៉ង់ និងអាស៊ាន នៅថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩។ ចំណុចសំខាន់ក្នុងការប្តេជ្ញាចិត្តរួមគ្នានេះ គឺការប្តេជ្ញាចិត្តក្នុងការដោះស្រាយបញ្ហាប្រឈមជាសកលរួមគ្នា-ដូចជាការគ្រប់គ្រងសកលភាវូបនីយកម្មការប្រែប្រួលអាកាសធាតុនិងបញ្ហាពាណិជ្ជកម្ម [៦៦]។

លើសពីនេះទៀតដោយសារតែអាស៊ីជាតំបន់មានចំនួនប្រជាជនទីក្រុងធំជាងគេបំផុតនៅលើពិភពលោក ហើយទីក្រុងនិងទីប្រជុំជននៅអាស៊ីកំពុងមានការអភិវឌ្ឍ និងកំណើនមិនធ្លាប់មានពីមុនមកធ្វើឲ្យយល់ច្បាស់ថា ហិរញ្ញវត្ថុជាង៣០០លានដុល្លារ ត្រូវបានអនុម័តសម្រាប់តំបន់នេះលើគម្រោងនានាដែលមានគោលបំណងគាំទ្រដល់ទិដ្ឋភាពផ្សេងៗនៃការអភិវឌ្ឍទីក្រុងដែលប្រើកាបូនទាប និងមាន

**ផែនទី ៤៖** កម្រិតហានិភ័យនៃការប្រែប្រួលអាកាសធាតុ




| ចំណាត់ថ្នាក់ | ប្រទេស | ប្រភេទ |
|---|---|---|
| ១ | បង់ក្លាដេស | ខ្ពស់ |
| ២ | សៀរ៉ាឡេអូន | ខ្ពស់ |
| ៣ | ស៊ូដង់ខាងត្បូង | ខ្ពស់ |
| ៤ | នីហ្សេរីយ៉ា | ខ្ពស់ |
| ៥ | ឆាត | ខ្ពស់ |
| ៦ | ហៃទី | ខ្ពស់ |
| ៧ | អេត្យូពី | ខ្ពស់ |
| ៨ | ហ្វីលីពីន | ខ្ពស់ |
| ៩ | សាធារណរដ្ឋអាហ្វ្រិកកណ្ដាល | ខ្ពស់ |
| ៩ | អេរីទ្រា | ខ្ពស់ |

**ប្រភព**: Maplecroft 2014|1 Henry Street, Bath BA1 1JS, United Kingdom| t: +44(0)1225420000|www.maplecroft.com|info@maplecroft.com

ភាពធន់នឹងអាកាសធាតុ។ [៣២]

បញ្ហាប្រឈមហាក់ដូចជាមានពីរសម្រាប់អាស៊ី។ ទីមួយ ដើម្បីអនុវត្តតាមកិច្ចព្រមព្រៀងទីក្រុងប៉ារីស ឆ្នាំ២០១៥ ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នៅអាស៊ីត្រូវការឲ្យកាត់បន្ថយ ដើម្បីសហគមន៍អន្តរជាតិអាចទប់ទល់នឹងការកើនឡើងសីតុណ្ហភាពបានយ៉ាងល្អក្រោម២អង្សាសេ។ ទីពីរបណ្តាប្រទេសនៅអាស៊ី ត្រូវការបង្កើតយុទ្ធសាស្ត្រ ដើម្បីធានាបានវិបុលភាព និងសន្តិសុខក្នុងតំបន់។

## តើសភានិងសមាជិក សមាជិកាសភា មានតួនាទីអ្វីខ្លះ?

សភានិងសមាជិក សមាជិកាសភាមានតួនាទីពីរ។ ដោយសារបញ្ហាការប្រែប្រួលអាកាសធាតុ ឆ្លងកាត់ព្រំដែនប្រទេស គឺសភានិងសមាជិក សមាជិកាសភាអាចដាក់បញ្ហាការប្រែប្រួលអាកាសធាតុនោះ នៅក្នុងរបៀបវារៈសម្រាប់កិច្ចពិភាក្សាថ្នាក់ជាតិនិងការប្រជុំអន្តរសភា។ សភាត្រូវការរួមជាមួយអំណាចរដ្ឋធម្មនុញ្ញផ្សេងៗទៀត ដើម្បីផ្តល់ការឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះបញ្ហាប្រឈមនៃការផ្លាស់ប្តូរអាកាសធាតុ និងសន្តិសុខ ទឹក ស្បៀង ថាមពល នៅលើទឹកដីរបស់ខ្លួន។

## នៅថ្នាក់តំបន់

ទាក់ទងទៅនឹងការទូតសភានៅថ្នាក់តំបន់ និងសមាជិក សមាជិកាសភាអាស៊ានអាចបង្កើតផែនការក្នុងតំបន់ ដើម្បីដោះស្រាយបញ្ហាបរិស្ថានទាំងមូល។

បន្ទាប់មក សមាជិក សមាជិកាសភាអាស៊ាននឹងអាចពង្រីកវិធីសាស្ត្ររបស់ខ្លួនបន្ថែមទៀត ដើម្បីពិចារណាលើបណ្តាញភ្ជាប់ទឹក ស្បៀង ថាមពល នៅពេលបង្កើតទស្សនវិស័យយុទ្ធសាស្ត្រសម្រាប់អាស៊ាន។ អត្ថប្រយោជន៍នៃការមានផែនការប្រកបដោយប្រសិទ្ធភាពគឺជាក់ស្តែង ព្រោះអាស៊ី គឺជាតំបន់ដែលប្រឈមនឹងហានិភ័យដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុច្រើនជាងគេ។

នៅកម្រិតអន្តរតំបន់ ការសន្ទនារវាងអង្គការក្នុងតំបន់ (ដូចជាអាស៊ាន សហភាពអឺរ៉ុប។ល។) ជាពិសេសរវាងអង្គការអន្តរសភាក្នុងតំបន់ (ដូចជា AIPA, សភាអឺរ៉ុប។ល។) ក៏ដូចជាការប្រជុំអន្តរសភាដែលរៀបចំឡើងសម្រាប់ត្រៀមកិច្ចប្រជុំកំពូលថ្នាក់អន្តរតំបន់ (ដូចជា ASEP) គឺជាឱកាសផ្លាស់ប្តូរយោបល់និងជំហរដ៏សំខាន់ ដើម្បីជំរុញនិងពង្រឹងកិច្ចព្រមព្រៀងសាមគ្គីភាពអន្តរតំបន់។ នៅក្នុងបរិបទទាំងនេះ ដំណោះស្រាយថ្មីអាចលេចឡើង។ ឧទាហរណ៍ អឺរ៉ុបអាចជួយអាស៊ីទប់ទល់ នឹងឱនភាពផលិតកម្មកសិកម្ម និងតម្រូវការស្បៀងអាហាររបស់ខ្លួនដោយផ្តល់នូវការគាំទ្រផ្នែកបច្ចេកវិទ្យាក្នុងវិស័យកសិអាហារ (agro_food_sector) ហើយអាស៊ីក៏អាចឆ្លើយតបទៅវិញដោយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់តិច ដោយសារតែការកាត់បន្ថយការបញ្ចេញឧស្ម័ននៅអាស៊ីនេះ គឺជាអាទិភាពចម្បងរបស់សហភាពអឺរ៉ុបតែម្តង។

## នៅថ្នាក់ជាតិ

ទោះបីការប្រែប្រួលអាកាសធាតុពិតជាបញ្ហាប្រឈមពិភពលោកក៏ដោយ វិធីសាស្ត្រដែលត្រូវបានអនុម័តដោយសភានៃប្រទេសនីមួយៗ មិនចាំបាច់ដូចគ្នាទេ។ បច្ចុប្បន្នមូលនិធិអឺរ៉ុបសម្រាប់អាស៊ី មាននិន្នាការគាំទ្រកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយ (mitigation) ជាជាងការខិតខំដើម្បីដោះស្រាយបញ្ហាតាមរបៀបប្រកបដោយចីរភាព (adaptation)។ សភាអាស៊ី អាចពិចារណា លើជម្រើសគោលនយោបាយដើម្បីដោះស្រាយបញ្ហា ដែលកើតឡើងពីការប្រែប្រួលអាកាសធាតុប្រកបដោយចីរភាពនិងដោយគិតពីកាលៈទេសៈជាក់លាក់នៅប្រទេសនីមួយៗ។

បច្ចុប្បន្ននេះ ច្បាប់ខ្លះខ្វះស្តង់ដារច្បាស់លាស់ ឬអាណត្តិ និងសិទ្ធិអំណាចចាំបាច់ ឬមិនសមស្របក្នុងការឆ្លើយតបទៅនឹងបញ្ហាប្រឈមជាក់ស្តែងនានា។ បញ្ហានេះអាចមានផលវិបាកធំធេងណាស់ព្រោះបរិស្ថាន គឺជាបញ្ហាអន្តរវិស័យដែលគ្របដណ្តប់លើវិស័យជាច្រើន (កសិកម្ម នគរូបនីយកម្ម ការដឹកជញ្ជូន ថាមពល ស្បៀង ប្រព័ន្ធធារាសាស្ត្រ ឧស្សាហកម្ម ការបណ្តុះបណ្តាល។ល។)។ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ គឺធំធេង ដូច្នេះការអនុវត្តច្បាប់និងបទបញ្ញត្តិបរិស្ថាននោះ ច្រើនតែមិនគ្រប់គ្រាន់ដើម្បីឆ្លើយតបទៅនឹងបញ្ហាបរិស្ថានឲ្យគ្រប់ជ្រុងជ្រោយ។ លើសពីនេះទៅទៀត ដោយសារតែឧបសគ្គថវិកាតែងតែមានជានិច្ច ការសម្របសម្រួលគ្នាមានភាពចាំបាច់។ នេះជាមូលហេតុដែលសមាជិក សមាជិកាសភាក្នុងមុខងារជាតំណាង មុខងារនីតិកម្ម (ធ្វើការអនុម័តច្បាប់ថ្មីបន្ទាប់ពីការវាយតម្លៃផលប៉ះពាល់ ឬការធ្វើវិសោធនកម្មច្បាប់) និងមុខងារត្រួតពិនិត្យ ដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាថាដំណោះស្រាយត្រូវបានរៀបចំឡើងនិងអនុវត្តប្រកបដោយប្រសិទ្ធភាពដើម្បីនាំមកនូវផលប្រយោជន៍ដល់ប្រជាជនដែលត្រូវរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដែលបកដោយវិទ្យាស្ថានសភាកម្ពុជា (PIC)។
អត្ថបទដើមជាភាសាអង់គ្លេសអាចទាញយកពីគេហទំព័រ៖ https://www.pic.org.kh ។

# ៤.៥ សន្តិសុខថាមពលអឺរ៉ុប៖ បញ្ហាប្រឈមក្នុងការធ្វើពិពិធកម្ម និងការបំបែកកាបូនឌីអុកស៊ីតចេញពីរបាយឥន្ធនៈ

## ថាមពលចម្រុះ

ពាក្យថា “សន្តិសុខថាមពល” រួមបញ្ចូលនូវបញ្ហាជាច្រើន។ បញ្ហាទាំងនោះរួមមានការប្រែប្រួលអាកាសធាតុពិភពលោក លក្ខណៈធម្មជាតិនៃឥន្ធនៈផូសស៊ីលដែលមិនអាចកកើតឡើងវិញបាន និងការព្រួយបារម្ភជុំវិញការផលិតថាមពលនុយក្លេអ៊ែរ។ បញ្ហាប្រឈមបន្ថែមកើតចេញពីការរំខានដល់ការផ្គត់ផ្គង់ថាមពល ជាពិសេសការប្រើថាមពលទាំងនោះជាអាវុធ និងតម្លៃខ្ពស់ក្នុងការនាំចូលថាមពល។ ជាទូទៅគេតែងតែឃើញមានការយកចិត្តទុកដាក់តែទៅលើការផ្គត់ផ្គង់ថាមពល តែពេលនេះគេក៏គួរតែគិតគូរផងដែរពីបញ្ហាតម្រូវការថាមពល ជាពិសេសក្រោយពេលដែលមានការលេចចេញនូវ "Prosumer" នៃថាមពល ដែលមានន័យថាបុគ្គលដែលជាអ្នកប្រើប្រាស់ផង និងផលិតផង។

បន្ទាប់ពីប្រទេសចិន និងសហរដ្ឋអាម៉េរិក សហភាពអឺរ៉ុបមានការប្រើប្រាស់ថាមពលសរុបក្នុងស្រុកធំជាងគេក្នុងលេខរៀងទីបីនៅលើពិភពលោក។ សហភាពអឺរ៉ុបជួបប្រទះនឹងការប្រឈមលើបញ្ហាគោលនយោបាយជាច្រើនទាក់ទងទៅនឹងការផ្គត់ផ្គង់ថាមពលនាពេលអនាគតរបស់ខ្លួន។ គោលនយោបាយទាំងនោះរួមមានការផ្លាស់ប្តូរទីផ្សារថាមពល និងរចនាសម្ព័ន្ធតម្រូវការថាមពល ក៏ដូចជាការធ្វើពិពិធកម្ម និងការបំបែកកាបូនឌីអុកស៊ីតចេញពីរបាយឥន្ធនៈដើម្បីឆ្ពោះទៅកាន់ប្រព័ន្ធថាមពលស្អាត និងមាននិរន្តរភាពជាងមុន។ ដើម្បីជួយដោះស្រាយការផ្លាស់ប្តូរនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងប្រជាសាស្ត្រ គឺទាមទារចាំបាច់នូវបច្ចេកវិទ្យាថ្មីដែលការដោះស្រាយនេះជាវិធីដែលឈានទៅកំរិតការបញ្ចេញឧស្ម័នផ្ទះកញ្ចក់(GHG) និងការបញ្ចេញចោលកាកសំណល់នុយក្លេអ៊ែរ។

ថាមពលចម្រុះដែលប្រើនៅក្នុងប្រទេសទាំង ២៨ របស់អឺរ៉ុប ភាគច្រើនលើសលប់ គឺប្រេង និងឧស្ម័ន។ ចាប់តាំងពីឆ្នាំ១៩៨០មក អឺរ៉ុបមិនមានសមត្ថភាពក្នុងការផ្គត់ផ្គង់ប្រេងឆៅដោយខ្លួនឯងទេ។ ស្ថានភាពប្រហែលគ្នានេះក៏ចាប់ផ្តើមកើតមានក្នុងការផ្គត់ផ្គង់ឧស្ម័នធម្មជាតិដែរ ចាប់តាំងពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០ដែរ។ នៅឆ្នាំ២០១៧ ការពឹងផ្អែកលើការនាំចូលថាមពលរបស់សហភាពអឺរ៉ុបបានឈានដល់ ៥៥,១% (ឧស្ម័នធម្មជាតិ ធ្យូងថ្ម និងប្រេងរួមបញ្ចូលគ្នា)។ បណ្តាប្រទេសដែលជាប្រភពនៃការផ្គត់ផ្គង់ថាមពលក៏មានការផ្លាស់ប្តូរនៅក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ប៉ុន្តែប្រទេសរុស្ស៊ីនៅតែរក្សាបាននូវទីតាំងរបស់ខ្លួនជាអ្នកនាំមុខក្នុងការផ្គត់ផ្គង់ប្រេងឆៅ និងឧស្ម័នធម្មជាតិ ហើយពេលនេះក៏ជាក្លាយជាអ្នកផ្គត់ផ្គង់ឥន្ធនៈរឹង (ធ្យូងថ្ម) ដ៏សំខាន់ផងដែរ។ ទោះយ៉ាងណាក៏ដោយចាប់តាំងពីឆ្នាំ២០០៤ មក ប្រទេសដៃគូនាំចូលថ្មីៗបានលេចរូបរាងឡើង ឧទាហរណ៍ដូចជាប្រទេសមកពីតំបន់កាសព្យែន (Caspian) ជាដើម។

បញ្ហាសន្តិសុខនៃការផ្គត់ផ្គង់ថាមពលរបស់សហភាពអឺរ៉ុបបានក្លាយជាបញ្ហាភូមិសាស្ត្រនយោបាយ និងភូមិសាស្ត្រសេដ្ឋកិច្ចដ៏ធំ។ អ្វីដែលសំខាន់ចំពោះសន្តិសុខក្នុងការផ្គត់ផ្គង់ថាមពលអឺរ៉ុបដែរនោះគឺថា តួអង្គខាងក្រៅ មានដូចជារុស្ស៊ី ចិន និងសហរដ្ឋអាម៉េរិកកំពុងតែសម្លឹងមើលតំបន់នេះក្នុងក្រសែភ្នែកដើម្បីស្វែងរកផលប្រយោជន៍ភូមិសាស្ត្រនយោបាយ។ សក្តានុពលនៃតំបន់នេះគឺធំខ្លាំងណាស់ នៅពេលដែលតំបន់មួយនេះត្រូវបានធ្វើសមាហរណកម្មទៅក្នុងទីផ្សារពិភពលោក ប៉ុន្តែគន្លងប្រវត្តិសាស្ត្ររបស់តំបន់នេះបានរាំងយ៉ាងខ្លាំងដល់ដំណើរការប្រែប្រួលដ៏ងាយមួយនេះ។

សហភាពអឺរ៉ុបបានឯកភាពលើការធ្វើបច្ចុប្បន្នភាពគ្រប់ជ្រុងជ្រោយទៅលើក្របខ័ណ្ឌគោលនយោបាយថាមពលរបស់ខ្លួន ដើម្បីសម្រួលដល់ការផ្លាស់ប្តូរពីការប្រើឥន្ធនៈផូសស៊ីលឆ្ពោះទៅរកការប្រើថាមពលស្អាតជាងមុន និងដើម្បីគោរពតាមការប្តេជ្ញារបស់ខ្លួនចំពោះកិច្ចព្រមព្រៀងទីក្រុងប៉ារីសក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។

ផលិតកម្មថាមពលបឋមឬថាមពលក្នុងទម្រង់ធម្មជាតិ និងទម្រង់មិនទាន់កែច្នៃនៅក្នុងសហភាពអឺរ៉ុបមានចំនួនសរុបចំនួន ៧៥៨ Mtoe ក្នុងឆ្នាំ [I] ២០១៧។ បើយើងសង្កេតមើលពីរយៈពេលជាយូរកន្លងទៅ ផលិតកម្មក្នុងឆ្នាំ២០១៧ មានកម្រិតទាបជាងកាលពីរយៈពេលមួយទសវត្សរ៍មុនចំនួន ១២,១%។ ប្រទេសជាសមាជិកសហភាពអឺរ៉ុបដែលមានផលិតកម្មថាមពលបឋមកំរិតខ្ពស់ជាងគេ គឺមានប្រទេសបារាំង (១៧,៤%) បន្ទាប់មកចក្រភពអង់គ្លេស (១៥,៦%) និងអាល្លឺម៉ង់ (១៥,៣%) ។

ផលិតកម្មថាមពលបឋមក្នុង EU-28 បានមកពីប្រភពថាមពលផ្សេងៗគ្នាជាច្រើន។ បើយើងមើលពីទំហំនៃការរួម

ចំណែកនៃប្រភពថាមពល គឺប្រភពដែលសំខាន់ជាងគេ គឺបានមកពីប្រភពថាមពលកកើតឡើងវិញដែលមានចំនួន ២៩,៩% នៃផលិតកម្មសរុបរបស់ EU-២៨ ក្នុងឆ្នាំ២០១៧។

កម្តៅពីប្រភពនុយក្លេអ៊ែរស្ថិតនៅលំដាប់ទី ២ ក្នុងអត្រា ២៧,៨% នៃផលិតកម្មថាមពលបឋមសរុប។ នៅប្រទេសបារាំង កម្តៅបានមកពីនុយក្លេអ៊ែរមានអត្រា ៧៩% នៃផលិតកម្មថាមពលជាតិបឋម។ នៅបែលហ្ស៊ិក និងស្លូវ៉ាគី មានចំណែកច្រើនជាងពាក់កណ្តាលនៃផលិតកម្មកម្តៅបានពីនុយក្លេអ៊ែរនេះ ហើយប្រទេសសមាជិក ១១ ដទៃទៀត មានផលិតកម្មកម្តៅបានមកពីនុយក្លេអ៊ែរតិចជាងពាក់កណ្តាលនៃផលិតកម្មកម្តៅដែលបានមកពីថាមពលដំបូងសរុប។ ប្រទេសជាសមាជិកចំនួន ១៤ ទៀតរបស់ EU មិនមានការផលិតថាមពលពីនុយក្លេអ៊ែរទេ។

ចំណែកនៃធ្យូងថ្ម (Solid fossil fuel) ក្នុងឆ្នាំ ២០១៧ មានអត្រាចំនួន ១៦,៤% ហើយចំណែកនៃឧស្ម័នធម្មជាតិមានអត្រាចំនួន ១៣,៦%។ ចំណែកនៃប្រេងឆៅមានក្នុងអត្រា ៨,៨%។ ប្រភពថាមពលកកើតឡើងវិញមានអត្រាកំណើនប្រហែលគ្នាក្នុងអំឡុងពីឆ្នាំ២០០៧-២០១៧ ហើយបានកើនលើសពីអត្រាកំណើននៃប្រភេទថាមពលដទៃទៀតដែលរួមបញ្ចូលគ្នា។ ផលិតកម្មនៃថាមពលចេញពីប្រភពដែលកកើតឡើងវិញបានកើនឡើងចំនួន ៦៥,៦% ក្នុងអំឡុងពេលនេះ។ កម្រិតផលិតកម្មចេញពីប្រភពថាមពលដំបូងផ្សេងៗទៀតបានធ្លាក់ចុះ។ ឧទាហរណ៍៖ ផលិតកម្មថាមពលនុយក្លេអ៊ែរបានធ្លាក់ចុះចំនួន ១២,៨%។

## ភាពពឹងផ្អែកផ្នែកថាមពល

ការធ្លាក់ចុះនៃផលិតកម្មបានមកពីប្រភពថាមពលដំបូងបានបង្កឲ្យមានស្ថានភាពមួយ ដែលសហភាពអឺរ៉ុបត្រូវពឹងផ្អែកកាន់តែខ្លាំងឡើងៗលើការនាំចូលប្រភពថាមពលបឋម និងផលិតផលបន្ទាប់បន្សំសម្រាប់ផលិត ថាមពល (ឧ. ឧស្ម័ន/ប្រេងម៉ាស៊ូត)។ ការនាំចូលថាមពលរបស់ EU-២៨ មានកំរិតលើសពីការនាំចេញក្នុងចំនួន ៩៤៨ Mtoe ក្នុងឆ្នាំ២០១៧។ ប្រទេសនាំចូលសុទ្ធសាធ និងធំបំផុតគឺ អាល្លឺម៉ង់ អ៊ីតាលី បារាំង និងអេស្ប៉ាញ។ កាលពីមុនប្រទេសដាណឺម៉ាក និងចក្រភពអង់គ្លេស គឺជាប្រទេសដែលនាំចេញសុទ្ធសាធនូវថាមពល ប៉ុន្តែសព្វថ្ងៃនេះ គ្មានប្រទេសជាសមាជិកនៃសហភាពអឺរ៉ុបណាមួយអាចទទួលនូវឈ្មោះនេះបានទៀតទេ។ ចាប់តាំងពីឆ្នាំ២០១៣ នៅពេលដែលការនាំចូលថាមពលរបស់ប្រទេសដាណឺម៉ាកបានផ្តើមកើនលើសពីការអត្រានៃការនាំចេញ គ្រប់ប្រទេសជាសមាជិកសហភាពអឺរ៉ុបទាំងអស់បានក្លាយជាអ្នកនាំចូលថាមពលសុទ្ធសាធទាំងអស់គ្នា។ បើធៀបទៅនឹងទំហំប្រជាជនប្រទេសនាំចូលឈានមុខគេក្នុងឆ្នាំ២០១៧ គឺ ប្រទេសលុចសំបួ ម៉ាល់តា និងបែលហ្ស៊ិក។

តែទោះជាយ៉ាងណាប្រភពចម្បងនៃការនាំចូលថាមពលរបស់សហភាពអឺរ៉ុបពិតជាមានការផ្លាស់ប្តូរ។ ប្រទេសរុស្ស៊ីបានរក្សាតំណែងជាអ្នកផ្គត់ផ្គង់ថាមពលឈានមុខដល់សហភាពអឺរ៉ុប ក្នុងអំឡុងឆ្នាំ២០០៧-២០១៧ ហើយប្រទេសនោះ គឺជាអ្នកផ្គត់ផ្គង់ប្រេងឆៅដ៏ចម្បងក្នុងឆ្នាំ២០១៧ ក្នុងចំណែក ៣០,៣%។ អ្នកផ្គត់ផ្គង់ធំជាងគេទី២ គឺ ប្រទេសន័រវែស (១១,៤%)។ ប្រេងឆៅដែលផ្គត់ផ្គង់ដោយប្រទេសអ៊ីរ៉ាក់ និងកាហ្សាក់ស្ថាន មានការកើនឡើងគួរឲ្យកត់សម្គាល់ដែលមានចំនួនឈានដល់ ៨,២% និង ៧,៤% ដែលធ្វើឲ្យប្រទេសទាំងពីរនេះក្លាយជាអ្នកផ្គត់ផ្គង់ធំទី៣ និងទី៤ របស់សហភាពអឺរ៉ុប ដែលនាំមុខប្រទេសអារ៉ាប៊ីសាអូឌីត។

ការនាំចូលឧស្ម័នធម្មជាតិរបស់សហភាពអឺរ៉ុប គឺមកពីប្រទេសរុស្ស៊ី (៣៨,៧%ភាគរយ) និងន័រវែស (២៥,៣%)។ ចំណែកនៃអ្នកផ្គត់ផ្គង់ធំជាងគេទីបី គឺអាល់ហ្សេរី (១០,៦%) ដែលបានធ្លាក់ចុះចាប់តាំងពីឆ្នាំ២០០៧ មក ខណៈដែលចំណែកមកពីប្រទេសកាតាបានកើនឡើងលើសពីទ្វេដង (៥,២%)។

នៅឆ្នាំ២០១៧ ចំណែកចម្បងនៃការនាំចូលធ្យូងថ្មរឹងរបស់សហភាពអឺរ៉ុប គឺមកពីប្រទេសរុស្ស៊ី (៣៨,៩%)។ ប្រទេសផ្គត់ផ្គង់ធំជាងគេទី២ គឺកូឡុំប៊ី (១៦,៩%)។ សហរដ្ឋអាមេរិកបានក្លាយជាប្រទេសផ្គត់ផ្គង់ធំជាងគេទី៣ ក្នុងឆ្នាំ២០១៧ ដែលក្នុងអត្រា ១៦,៩%។

សន្តិសុខនៃការផ្គត់ផ្គង់ថាមពលដំបូងរបស់សហភាពអឺរ៉ុបកំពុងតែមានហានិភ័យ ដោយសារការនាំចូលរបស់ខ្លួនបានមកតែពីដៃគូមួយចំនួនប៉ុណ្ណោះ។ ចំនួនជិត ៣/៤ (៧៤,៦%) នៃការនាំចូលឧស្ម័នធម្មជាតិរបស់ EU-២៨ គឺបានមកពីប្រទេសរុស្ស៊ី ន័រវែស និងអាល់ហ្សេរី ហើយ ៧២,៧% នៃការនាំចូលធ្យូងថ្មរឹងមានប្រភពមកពីប្រទេសរុស្ស៊ី កូឡុំប៊ី និងសហរដ្ឋអាមេរិក។ ការនាំចូលប្រេងឆៅពុំសូវប្រមូលផ្តុំក្នុងចំណោមប្រទេសផ្គត់ផ្គង់ធំៗ ដូចជា រុស្ស៊ី ន័រវែស និងអ៊ីរ៉ាក់ (៤៩,៩%) ទេ។

ការពឹងផ្អែករបស់សហភាពអឺរ៉ុបទៅលើការនាំចូលថាមពលបានកើនឡើងពី ៤៤% ក្នុងឆ្នាំ១៩៩០ ដល់ ៥៥,១% ក្នុងឆ្នាំ២០១៧ ដែលនេះជាកម្រិតមួយខ្ពស់បំផុតក្នុងពេលបច្ចុប្បន្ន។ ចាប់តាំងពីឆ្នាំ២០០៤ ការនាំចូលថាមពលសុទ្ធសាធមានទំហំធំជាងផលិតកម្មថាមពលបឋមរបស់សហភាពអឺរ៉ុប។ បើយើងមើលឲ្យបានលម្អិត យើងឃើញថា ក្នុងតាំងពីឆ្នាំ២០១៧ តាមការកត់ត្រា គឺមានអត្រាខ្ពស់បំផុតក្នុងការនាំចូលប្រេងឆៅ (៨៦,៧%) និង

ឧស្ម័នធម្មជាតិ (៧៤,៣%)។ អត្រានាំចូលធ្យូងថ្មបានឈានដល់ចំនួន ៤៣,៩% ។

## ការដោះស្រាយបញ្ហាប្រឈម

ថាមពលជាងពាក់កណ្ដាលរបស់ EU-២៨ បានការផ្គត់ផ្គង់មកពីប្រទេសក្រៅពីសហភាពអឺរ៉ុប ចំណែកនេះបានបន្តកើនឡើងក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ។ ដោយសារតែរុស្ស៊ីមានជម្លោះជាមួយនឹងប្រទេសឆ្លងកាត់ បញ្ហានេះបាននាំឲ្យមានការរំខានដល់ការផ្គត់ផ្គង់ថាមពលពីរុស្ស៊ីដែលជាប្រភពនាំចូលចម្បងក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ។ ការព្រួយបារម្ភពីសន្តិសុខនៃការផ្គត់ផ្គង់ថាមពលមានកាន់តែខ្លាំងឡើង ដោយសារជម្លោះរវាងប្រទេសរុស្ស៊ី និងប្រទេសអ៊ុយក្រែន។ បំពង់បង្ហូរថ្មីដើម្បីធានាដល់ការផ្គត់ផ្គង់បន្ថែម គឺមាន Nord Stream ១ និង Nord Stream ២។ បំពង់បង្ហូរ Nord Stream ឆ្លងកាត់ពីប្រទេសរុស្ស៊ីតាមរយៈសមុទ្របាល់តិច (ដោយមិនបាច់ឆ្លងប្រទេសដទៃ)ទៅកាន់សហភាពអឺរ៉ុប។ បំពង់បង្ហូរ Trans Adriatic ភ្ជាប់ពីតួកគីទៅប្រទេសអ៊ីតាលី ឆ្លងកាត់ប្រទេសក្រិក និងប្រទេសអាល់បានី ដែលបង្ហូរឧស្ម័នមកពីតំបន់សមុទ្រកាសព្យែនទៅសហភាពអឺរ៉ុប។ ហើយវិធានការណ៍ថ្មីសម្រាប់ទីផ្សារប្រេង និងឧស្ម័នត្រូវបានរៀបចំឡើងដើម្បីបង្ការកុំឲ្យមានភាពរំខានដល់ការផ្គត់ផ្គង់។

ភាពស្មុគស្មាញខាងភូមិសាស្ត្រនយោបាយក្នុងតំបន់ដែលបណ្ដាលមកពីការប្រកួតប្រជែងផលប្រយោជន៍រវាងតួអង្គទាំងអស់ បានរារាំងការធ្វើសមាហរណកម្មដោយរលូននៃតំបន់កូកាស៊ីសខាងត្បូង និងតំបន់កាសព្យែនទៅក្នុងទីផ្សារពិភពលោក។ ការពឹងផ្អែករបស់តំបន់ទៅលើប្រទេសឆ្លងកាត់សម្រាប់ការធ្វើទីផ្សារផលិតកម្មអ៊ីដ្រូកាបូនបាននាំឲ្យមានចម្ងល់ថា តើកត្តានយោបាយអនុញ្ញាតឲ្យមានការធ្វើពិពិធកម្មផ្លូវដឹកជញ្ជូន ក្នុងខណៈដែលមានការកើនឡើងនៃផលិតកម្មឬទេ? នៅដើមទសវត្សរ៍ឆ្នាំ១៩៩០ ប្រទេសរុស្ស៊ី កាហ្សាក់ស្ថាន តួកម៉េនីស្ថាន អាស៊ែបៃហ្សង់ និងអ៊ូសបេគីស្ថានបានយល់ឃើញថា ទុនអ៊ីដ្រូកាបូនដ៏ច្រើនដែលពួកគេមានអាចក្លាយជាមូលដ្ឋានដ៏ល្អសម្រាប់ការប្រកួតប្រជែងនាពេលអនាគតរបស់ពួកគេនៅក្នុងពិភពលោក ដែលការអភិវឌ្ឍនៅតែពឹងផ្អែកលើការផ្គត់ផ្គង់ឥន្ធនៈផូសស៊ីល។

សហគមន៍ថាមពល (Energy Community) បានដាក់សំណើនៅក្នុងខែតុលា ឆ្នាំ២០០៥ ដើម្បីស្នើសុំឲ្យប្រទេសជិតខាងធ្វើសមាហរណកម្មទៅក្នុងទីផ្សារថាមពលផ្ទៃក្នុង។ប្រភពនៃថាមពលចម្រុះដ៏ទូលំទូលាយនិងពិពិធកម្មនៃអ្នកផ្គត់ផ្គង់ ផ្លូវដឹកជញ្ជូន និងយន្តការនានាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការធានានូវការផ្គត់ផ្គង់ថាមពល។

នៅខែឧសភា ឆ្នាំ២០១៤ គណៈកម្មការអឺរ៉ុបបានចេញនូវយុទ្ធសាស្ត្រសន្តិសុខថាមពលរបស់ខ្លួន ក្នុងគោលបំណងធានាឲ្យមានស្ថិរភាពក្នុងការផ្គត់ផ្គង់ថាមពលឲ្យបានគ្រប់គ្រាន់។

ក្រៅពីទស្សនៈដែលផ្តោតលើផ្នែកផ្គត់ផ្គង់ដើម្បីធានាសន្តិសុខថាមពល វិធានការខាងតម្រូវការ ឧទាហរណ៍ដូចជា ការសន្សំថាមពល និងការប្រើថាមពលដែលប្រកបដោយប្រសិទ្ធភាពនិងការសន្សំសំចៃក៏ដើរតួនាទីយ៉ាងច្បាស់ប្រាកដនៅក្នុងយុទ្ធសាស្ត្រសន្តិសុខថាមពលរបស់សហភាពអឺរ៉ុបដែរ។

សេចក្តីណែនាំស្តីពី ប្រសិទ្ធភាពដោយការសន្សំសំចៃថាមពលឆ្នាំ២០១២ (២០១២/២៧/EU) បានបង្កើតនូវវិធានការចងជាកាតព្វកិច្ចដើម្បីជួយសហភាពអឺរ៉ុបក្នុងការសម្រេចឲ្យបាននូវគោលដៅនៃប្រសិទ្ធភាពដោយការសន្សំសំចៃនូវថាមពលឲ្យបាន២០%របស់ខ្លួនត្រឹមឆ្នាំ២០២០។ នេះមានន័យថា ការប្រើប្រាស់ថាមពលរបស់សហភាពអឺរ៉ុបទាំងមូលមិនគួរលើសពី ១៤៨៣ Mtoe នៃថាមពលដំបូង ឬ ១.០៨៦ Mtoe នៃថាមពលចុងក្រោយឡើយ។ ក្រោមការណែនាំនេះ រាល់ប្រទេសជាសមាជិកសហភាពអឺរ៉ុបទាំងអស់ត្រូវប្រើប្រាស់ថាមពលឲ្យកាន់តែមានប្រសិទ្ធិភាពដោយការសន្សំសំចៃនៅគ្រប់ដំណាក់កាលទាំងអស់ក្នុងចង្វាក់ថាមពល ក្នុងនោះរួមមានការផលិតថាមពល ការបញ្ជូន ការចែកចាយ និងការប្រើប្រាស់ចុងក្រោយ។

ក្នុងបរិបទនៃសេចក្តីណែនាំឆ្នាំ២០១២ នេះដដែល វិធានការសំខាន់ៗជាច្រើនត្រូវបានអនុម័តនៅទូទាំងសហភាពអឺរ៉ុប ដើម្បីបង្កើននូវប្រសិទ្ធភាពដោយការសន្សំសំចៃនៃការប្រើថាមពលនៅអឺរ៉ុបក្នុងនោះរួមមាន៖

- ការកាត់បន្ថយការលក់ថាមពលជាតិប្រចាំឆ្នាំឲ្យបាននៅត្រឹម ១.៥%
- ការកែលម្អឡើងវិញឲ្យមានប្រសិទ្ធភាពប្រកបដោយការសន្សំសំចៃលើការប្រើថាមពលក្នុងចំណោមប្រទេសនៃសហភាពអឺរ៉ុបឲ្យបាននៅត្រឹមអត្រាយ៉ាងហោច ៣% ក្នុងមួយឆ្នាំ សម្រាប់អគារដែលជាកម្មសិទ្ធិរបស់ និងកាន់កាប់ដោយរដ្ឋាភិបាលកណ្ដាល
- ការរៀបចំយុទ្ធសាស្ត្រកែលម្អឡើងវិញរយៈពេលវែងថ្នាក់ជាតិ អំពីការប្រមូលព័ត៌មានទាក់ទងនឹងអគារទាំងអស់នៅគ្រប់ប្រទេសនៅអឺរ៉ុប
- ការបង្កើតឲ្យមានវិញ្ញាបនបត្រចាំបាច់បញ្ជាក់ពីការប្រើថាមពលដោយប្រសិទ្ធភាពនិងសន្សំសំចៃ ដែលត្រូវភ្ជាប់ជាមួយនឹងរាល់ការលក់ និងជួលអគារ

- ការរៀបចំផែនការសកម្មភាព ស្តីពីការប្រើថាមពលប្រកបដោយប្រសិទ្ធភាព និងការសន្សំសំចៃថាមពលថ្នាក់ជាតិ (NEEAP) រៀងរាល់បីឆ្នាំម្តង
- ការបង្កើតស្តង់ដារប្រសិទ្ធភាព និងការសន្សំសំចៃនៃការប្រើប្រាស់ថាមពលអប្បបរមា និងបិទស្លាកលើផលិតផលជាច្រើន ដូចជា ម៉ាស៊ីនដាំទឹក គ្រឿងប្រើប្រាស់ក្នុងផ្ទះ អំពូលភ្លើង និងទូរទស្សន៍ (ស្លាកថាមពល និងការរចនាដោយបញ្ចូលនូវលក្ខណៈវិនិច្ឆ័យសម្រាប់ការពារបរិស្ថាន [eco design])
- ការដាក់ចេញនូវផែនការបង្កើតកុងទ័រវៃឆ្លាត (smart meters) សម្រាប់កត់ត្រាថាមពលដែលប្រើប្រាស់ ចំនួន ២០០លាន សម្រាប់ភ្ជាប់ទៅនឹងឧបករណ៍អគ្គិសនី និង ៤៥លាន សម្រាប់ភ្ជាប់ទៅនឹងឧបករណ៍ប្រើឧស្ម័ននៅត្រឹមឆ្នាំ២០២០
- កម្មវិធីកាតព្វកិច្ចដែលតម្រូវឲ្យក្រុមហ៊ុនផលិតថាមពលត្រូវតែសន្សំឲ្យបានថាមពលប្រចាំឆ្នាំនូវអត្រា១,៥% នៃការលក់ប្រចាំឆ្នាំដល់អ្នកប្រើប្រាស់ចុងក្រោយ
- សវនកម្មថាមពលចំពោះក្រុមហ៊ុនធំៗត្រូវតែធ្វើឡើងយ៉ាងតិចណាស់រៀងរាល់បួនឆ្នាំម្តង
- ការពារសិទ្ធិអ្នកប្រើប្រាស់ដើម្បីទទួលបានទិន្នន័យប្រើប្រាស់ថាមពលក្នុងពេលភ្លាមៗ (Real-time) និងពីពេលមុនៗដោយងាយស្រួល និងឥតគិតថ្លៃ។

គណៈកម្មការនេះក៏បានផ្សព្វផ្សាយនូវគោលការណ៍ណែនាំស្តីពី ការអនុវត្តល្អនៃការប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធិភាពដោយការសន្សំសំចៃ។ការបញ្ចប់នូវគម្រោងសៀវភៅអំពី វិធានថាមពល ដែលមានឈ្មោះថា “កញ្ចប់ថាមពលស្អាតសម្រាប់ជនជាតិអឺរ៉ុបគ្រប់រូប” គឺជាជំហានដ៏សំខាន់ឆ្ពោះទៅកេការអនុវត្តយុទ្ធសាស្រ្តសហភាពថាមពលដែលត្រូវបានអនុម័តក្នុងឆ្នាំ២០១៥។

ការផ្លាស់ប្តូរនេះនឹងនាំមកនូវផលប្រយោជន៍យ៉ាងច្រើន បើយោងតាមទស្សនៈរបស់អ្នកប្រើប្រាស់ អ្នកបរិស្ថាន និងសេដ្ឋកិច្ច។ នេះក៏ជាការបញ្ជាក់ពីភាពជាអ្នកដឹកនាំរបស់ EU ក្នុងការដោះស្រាយការកើនឡើងនៃកម្តៅផែនដី និងជាការផ្តល់នូវការចូលរួមដ៏សំខាន់ដល់យុទ្ធសាស្ត្ររយៈពេលវែងរបស់សហភាពអឺរ៉ុប ក្នុងការសម្រេចឲ្យបាននូវអព្យាក្រឹតកាបូន នៅត្រឹមឆ្នាំ២០៥០។

សំណង់អគារមានការប្រើប្រាស់ថាមពលប្រហែល ៤០% និង មានការបញ្ចេញឧស្ម័នកាបូនិចប្រមាណ ៣៦% នៃនៅក្នុងសហភាពអឺរ៉ុប ជាហេតុដែលធ្វើឲ្យសំណង់អគារជាផ្នែកដែលប្រើប្រាស់ថាមពលធំជាងគេតែឯងនៅអឺរ៉ុប។ ដោយការគ្រប់គ្រងឲ្យកាន់តែប្រសើរឡើងនូវការប្រើប្រាស់ថាមពលនៅក្នុងអគារសហភាពអឺរ៉ុបអាចត្រៀមខ្លួនជាស្រេចក្នុងការឈានទៅសម្រេចនូវគោលដៅថាមពល និងអាកាសធាតុ។ សេចក្តីណែនាំស្តីពីការគ្រប់គ្រងការប្រើប្រាស់ថាមពលនៅក្នុងអគារ (EPBD) បានបង្ហាញពីវិធានការណ៍ដាក់លាក់សម្រាប់វិស័យគ្រប់គ្រងអគារ ដើម្បីដោះស្រាយនូវបញ្ហាប្រឈម ផ្តល់នូវព័ត៌មានបច្ចុប្បន្នភាព និងការធ្វើវិសោធនកម្មទៅលើបទបញ្ញត្តិជាច្រើនទៅលើសេចក្តីណែនាំដែលចេញកាលពីឆ្នាំ២០១០។

ការដាក់ប្រសិទ្ធភាពប្រកបដោយការសន្សំសំចៃនៅក្នុងការប្រើប្រាស់ថាមពលជាអាទិភាពមុនគេ គឺជាគោលដៅគន្លឹះនៅក្នុងកញ្ចប់យុទ្ធសាស្ត្រនៃថាមពលស្អាត ព្រោះថាការសន្សំថាមពល គឺជាមធ្យោបាយងាយស្រួលបំផុតសម្រាប់អ្នកប្រើប្រាស់ក្នុងការសន្សំប្រាក់ និងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ ដូច្នេះសហភាពអឺរ៉ុបបានកំណត់គោលដៅដែលចងជាកាតព្វកិច្ចក្នុងការគ្រប់គ្រងការប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាពនិងការសន្សំសំចៃឲ្យបានយ៉ាងតិច ៣២,៥% នៅត្រឹមឆ្នាំ២០៣០ ទៅតាមសេណារីយ៉ូ "តាមទម្លាប់ធម្មតា"។ សេចក្តីណែនាំពីប្រសិទ្ធភាពប្រកបដោយការសន្សំសំចៃនៃការប្រើប្រាស់ថាមពលដែលបានធ្វើវិសោធនកម្មត្រូវបានដាក់ឲ្យអនុវត្តចាប់តាំងពីខែធ្នូឆ្នាំ២០១៨មកម្ល៉េះ។

ដើម្បីសម្រេចតាមគោលដៅថាមពល និងអាកាសធាតុរបស់សហភាពអឺរ៉ុបសម្រាប់ឆ្នាំ២០៣០ ប្រទេសសមាជិកសហភាពអឺរ៉ុបទាំងអស់ចាំបាច់ត្រូវបង្កើតផែនការ ១០ឆ្នាំ ដោយធ្វើសមាហរណកម្មផែនការថាមពលជាតិ និងអាកាសធាតុថ្នាក់ជាតិ (NECP) សម្រាប់ឆ្នាំ២០២១ដល់ឆ្នាំ២០៣០។ NECP បានដាក់ចេញដោយបទបញ្ញត្តិ ស្តីពីអភិបាលកិច្ចលើសកម្មភាពនៃសហភាពថាមពល និងអាកាសធាតុ (EU/២០១៨/១៩៩៩)។ ផែនការថ្នាក់ជាតិនេះគូសបញ្ជាក់ពីវិធីទាក់ទងនឹងអ្វីដែលប្រទេសសមាជិកសហភាពអឺរ៉ុបមានបំណងដោះស្រាយ៖

- ប្រសិទ្ធភាពដោយការសន្សំសំចៃនៃថាមពល
- ការប្រើប្រាស់ថាមពលកកើតឡើងវិញ
- ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់
- អន្តរទំនាក់ទំនង
- ការស្រាវជ្រាវ និងនវានុវត្តន៍។

អភិក្រមនេះទាមទារឲ្យមានការសម្របសម្រួលនូវគ្រប់គោលដៅទាំងអស់របស់ក្រសួងស្ថាប័ននៅក្នុងរដ្ឋាភិបាល។

អភិក្រមនេះក៏ផ្តល់នូវកម្រិតផែនការមួយដែលនឹងអាចជួយសម្រួលដល់ការវិនិយោគសាធារណៈ និងឯកជន។ ការពិតការណ៍ដែលប្រទេសជាសមាជិកសហភាពអឺរ៉ុបទាំងអស់កំពុងតែប្រើប្រាស់គំរូស្រដៀងគ្នាបែបនេះ មានន័យថា ពួកគេអាចធ្វើការជាមួយគ្នាដើម្បីទទួលបាននូវប្រសិទ្ធភាពប្រកបដោយការសន្សំសំចៃនូវការប្រើប្រាស់ថាមពល ដែលពួកគេអាចសម្រេចបានច្រើនជាង ពេលដែលប្រទេសនីមួយៗធ្វើការតែឯង។

នៅពេលប្រឈមទៅនឹងបញ្ហាលំបាកផ្នែកថាមពលជាសកលនៃសតវត្សរ៍ទី២១ សហភាពអឺរ៉ុបកំពុងតែនាំមុខនូវការផ្លាស់ប្តូរទៅរកថាមពលស្អាត កំពុងខិតខំធ្វើឲ្យមានប្រព័ន្ធថាមពលដែលមានសន្តិសុខ ការប្រកួតប្រជែង និងមាននិរន្តភាពជាងមុន ដែលនេះនឹងអាចដោះស្រាយបាននូវបញ្ហាដែលយើងកំពុងប្រឈមគឺការប្រែប្រួលអាកាសធាតុ។ ការកំណត់នូវគោលដៅដែលប្រកបដោយមហិច្ឆតាលើថាមពល និងអាកាសធាតុសម្រាប់ឆ្នាំ២០៣០ ធ្វើឲ្យសហភាពអឺរ៉ុបមានទិសដៅដ៏ច្បាស់លាស់។ បន្ថែមពីលើគោលដៅទាំងនេះ វាក៏ផ្តល់ផងដែរនូវក្របខ័ណ្ឌច្បាប់ដែលប្រកបដោយស្ថិរភាពសម្រាប់ជំរុញការវិនិយោគដែលចាំបាច់។ ប៉ុន្តែគោលដៅនេះពុំមែនជាចុងបញ្ចប់នៃផ្លូវរបស់ EU ឡើយ៖ ជាមួយនឹងយុទ្ធសាស្ត្រអព្យាក្រឹតអាកាសធាតុឆ្នាំ២០៥០ រយៈពេលយូរអង្វែងរបស់ខ្លួន (យុទ្ធសាស្ត្រគ្មានការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ត្រឹមឆ្នាំ២០៥០) សហភាពអឺរ៉ុបក៏កំពុងសម្លឹងឆ្ពោះទៅមុខ លើសពីឆ្នាំ២០៣០ទៅទៀត និងកំពុងកំណត់នូវមូលដ្ឋានគ្រឹះនៃអ្វីដែលថា ជាភពផែនដីស្អាតឲ្យបានត្រឹមពាក់កណ្តាលសតវត្សរ៍នេះ និងបន្តទៅមុខទៀត។



រោងចក្រថាមពលដើរដោយពន្លឺព្រះអាទិត្យ និងនុយក្លេអ៊ែរ Dukovany នៅសាធារណរដ្ឋឆែក

Martin Lisner

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដែលបកដោយវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិនៃកម្ពុជា (NIDIR)។ អ្នកអានអាចទាញយកអត្ថបទដើមជាភាសាអង់គ្លេសពីគេហទំព័រ៖ https://www.pic.org.kh ។

# ៤.៦ សហភាពអឺរ៉ុប និងបញ្ហាប្រឈមទៅនឹងការប្រែប្រួលអាកាសធាតុ៖ អំណាចកំពូលក្នុងការចេញបទបញ្ញត្តិ

អ្នកវិទ្យាសាស្ត្រមិនមានមន្ទិលសង្ស័យទៀតឡើយទៅលើបញ្ហាអាកាសធាតុរបស់ពិភពលោកដែលកំពុងផ្លាស់ប្តូរ។ ដើម្បីទប់ទៅនឹងការកើនឡើងសីតុណ្ហភាពពិភពលោកក្នុងសតវត្សរ៍នេះក្រោមកម្រិត ២0C ពីកំរិតមុនពេលមានឧស្សាហកម្ម ការបញ្ចេញឧស្ម័នកាបូនក្នុងពិភពលោកត្រូវតែធ្លាក់ចុះ ២៥% នៅត្រឹមឆ្នាំ២០៣០។ តួលេខដ៏គួរឲ្យព្រួយបារម្ភបានបង្ហាញថា ការបញ្ចេញឧស្ម័នកាបូនបានកើនឡើង ១.៥% ក្នុងឆ្នាំ២០១៧ និង២០១៨ [៦៧] ៧៧។ ដូច្នេះសកម្មភាពសម្របសម្រួលជាសកល គឺមានភាពចាំបាច់ណាស់។

## កំណត់ត្រាតាមដានរបស់សហភាពអឺរ៉ុប

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ សហភាពអឺរ៉ុបបានក្លាយជាអ្នកដឹកនាំសកលក្នុងការប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ។ សកម្មភាពធំថ្មីៗទាំងនោះរួមមាន៖

- កិច្ចព្រមព្រៀងក្រុងប៉ារីសដែលត្រូវបានអនុម័តក្នុងសន្និសីទស្តីពី ការប្រែប្រួលអាកាសធាតុរបស់អង្គការសហប្រជាជាតិ (COP) លើកទី ២១ ជាជំហាននយោបាយដ៏សំខាន់មួយ ដែលប្រទេសចូលរួមបានធ្វើការប្តេជ្ញាកាត់បន្ថយការបញ្ចេញឧស្ម័នដើម្បីប្រឹងប្រែងរក្សាកំរិតក្រោម ២0C នៃការកើនឡើងសីតុណ្ហភាពពិភពលោក
- សន្និសីទ ស្តីពី ការប្រែប្រួលអាកាសធាតុរបស់អង្គការសហប្រជាជាតិ ឬសន្និសីទរបស់ភាគី (COP ២៣) នៅ ទីក្រុង Bonn (អាល្លឺម៉ង់ ឆ្នាំ២០១៧) COP ២៤ នៅ Katowice (ប៉ូឡូញ ឆ្នាំ២០១៨) COP ២៥ នៅ ម៉ាឌ្រីត (អេស្ប៉ាញ ឆ្នាំ២០១៩) និង COP ២៦ នៅ Glasgow (ចក្រភពអង់គ្លេស ឆ្នាំ២០២០)។

ជាលទ្ធផល សហភាពអឺរ៉ុបបានទទួលភាពជោគជ័យក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ខណៈរក្សាបាននូវអត្រាកំណើនសេដ្ឋកិច្ចដ៏ល្អ [៦៨]។

សហភាពអឺរ៉ុបដឹងថា ការដោះស្រាយការប្រែប្រួលអាកាសធាតុតម្រូវឲ្យមានការខិតខំប្រឹងប្រែងផ្នែកនយោបាយ និងមានលក្ខណៈជាសមូហភាព ដែលមិនធ្លាប់មានពីមុនមក៖ ការវិនិយោគត្រូវតែគិតគូរដល់កម្រិតនៃការកើនឡើងសីតុណ្ហភាព ២0C។ ក្នុងផ្នែកនេះសហភាពអឺរ៉ុបមានសមត្ថភាពក្នុងធ្វើឲ្យគម្រោងពាណិជ្ជកម្មនៃការបញ្ចេញឧស្ម័ន (Emissions Trading Scheme) មានដំណើរការម្តងទៀតបន្ទាប់ពីអស់រយៈពេលមួយទសវត្សរ៍ដែលឧស្ម័នកាបូនមានតម្លៃទាប។ បន្ថែមពីនេះទៀតសហភាពអឺរ៉ុបក៏ទទួលបានជោគជ័យផងដែរក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នពីការផលិតថាមពលអគ្គិសនី។ ប៉ុន្តែការកាត់បន្ថយការបញ្ចេញឧស្ម័នកាបូនពីការដឹកជញ្ជូន សំណង់អគារ និងកសិកម្មមានការលំបាកកាន់តែខ្លាំង ដែលមនុស្សជាច្រើនជឿថាកិច្ចការនេះអាចធ្វើទៅបានលុះត្រាតែមានការគិតពន្ធលើកាបូន និងដាក់ពិន័យរាល់ទម្រង់នៃការបញ្ចេញឧស្ម័នទាំងអស់។ ការឯកភាពផ្នែកនយោបាយអាចធ្វើទៅបាន ប្រសិន

**រូបភាព ១៖** រវាងឆ្នាំ១៩៩០ និង២០១៨ ការបំភាយឧស្ម័នផ្ទះកញ្ចក់បានថយចុះ ២៣% ខណៈដែលសេដ្ឋកិច្ចមានការកើនឡើងដល់ ៦១%



**រូបភាព ២៖** គោលដៅដើម្បីបំពេញឲ្យបានតាមការប្តេជ្ញាចិត្តនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស




**EU គឺជាអ្នកឈានមុខសេដ្ឋកិច្ចតែមួយគត់ក្នុងពិភពលោកដែលបានដាក់ចេញនូវច្បាប់គ្របដណ្តប់គ្រប់វិស័យក្នុងការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ស្របទៅតាមកិច្ចព្រមព្រៀងទីក្រុងប៉ារីស**

បើប្រាក់ចំណូលពីពន្ធកាបូនត្រូវបានចែកចាយដោយប្រសិទ្ធភាព និងយុត្តិធម៌។ អ្នកចូលរួមខ្លះជឿថា សហភាពអឺរ៉ុបគួរតែដាក់ពិន័យលើរាល់ការនាំចូលកាបូនទ្រង់ទ្រាយធំទាំងអស់ពីពិភពលោក ដើម្បីបង្ខំឲ្យមានការចាត់វិធានការជាសកល។

## បញ្ហាប្រឈមនៃការមូលមតិគ្នារួមតែមួយ

ដូចបានសង្កេតឃើញនៅក្នុងសន្និសីទស្តីពី ការប្រែប្រួលអាកាសធាតុ COP ២៥ នៅទីក្រុងម៉ាឌ្រីត ការប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុប្រឈមនឹងការគំរាមកំហែងដ៏ធំមួយ ដោយសារការតាំងចិត្តរបស់សហរដ្ឋអាម៉េរិកក្នុងការដកខ្លួនចេញពីកិច្ចព្រមព្រៀងទីក្រុងប៉ារីស នៅឆ្នាំ២០២០។ បញ្ហាចម្បងមួយទៀត ចំពោះដំណើរឆ្ពោះទៅកាន់ដំណោះស្រាយគ្រប់ជ្រុងជ្រោយនូវវិបត្តិអាកាសធាតុ គឺការមិនទទួលបាននូវការមូលមតិគ្នារួមតែមួយ លើបញ្ហាអភិបាលកិច្ចពាណិជ្ជកម្មកាបូន។ ឧបសគ្គក្នុងកិច្ចការនេះរួមមាន ការមិនយកចិត្តទុកដាក់របស់ចិននិងសហរដ្ឋអាម៉េរិក និងភាពមានះរបស់បណ្តាប្រទេសដូចជា ប្រេស៊ីល និងអូស្ត្រាលី ចំពោះលទ្ធផលដែលគេយល់ថា មានមហិច្ឆិតាខ្លាំងហួសហេតុពេក។

កិច្ចព្រមព្រៀងទីក្រុងប៉ារីសធ្វើប្រតិបត្តិការដោយផ្អែកតាមការមូលមតិគ្នារួមតែមួយ ដែលកិច្ចការនេះធ្វើឲ្យកាន់តែស្មុគស្មាញដោយសារការងាកចេញពីពហុភាគីនិយមនិងការកើនឡើងនូវការប្រឆាំងរបស់សហរដ្ឋអាម៉េរិក។ ឆ្លើយតបនឹងការលំបាកទាំងនេះ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ António Guterres បានធ្វើការកត់សម្គាល់នៅក្នុងពិធីបិទ COP ២៥ ថា «សហគមន៍អន្តរជាតិបានបាត់បង់ឱកាសដ៏សំខាន់ក្នុងការបង្ហាញមហិច្ឆតារបស់ខ្លួនលើការកាត់បន្ថយ ការបន្សាំ និងការផ្តល់ហិរញ្ញប្បទានដើម្បីដោះស្រាយវិបត្តិអាកាសធាតុ»។គណៈប្រតិភូសហភាពអឺរ៉ុបបាននិយាយថា ខ្លួនពិតជាខកចិត្តចំពោះកង្វះការព្រមព្រៀងទៅលើទីផ្សារកាបូន ហើយខ្លួនមាន «ការព្រួយបារម្ភយ៉ាងខ្លាំង» ដែលគោលដៅពាក់ព័ន្ធនឹងអាកាសធាតុនៃប្រទេសនីមួយៗ មិនត្រូវបានអនុវត្តតាមផែនការក្នុងការឈានដល់ការសម្រេចគោលដៅនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស [៦៩]។

## កិច្ចព្រមព្រៀងបៃតងអឺរ៉ុប

កិច្ចព្រមព្រៀងបៃតងអឺរ៉ុប (EGD) បានបង្ហាញវត្តមានរបស់ខ្លួននៅថ្ងៃពុធ ទី១១ ខែធ្នូ ឆ្នាំ២០១៩ នៅទីក្រុងព្រុចសែល ដោយគណៈកម្មការអឺរ៉ុបនៅមុនពេលកិច្ចប្រជុំ

COP ២៥[៦៨]។ ផែនការនេះមានមហិច្ឆតាខ្ពស់ និងចាំបាច់ណាស់។ ជាមួយផែនការនេះ អឺរ៉ុបដើរតួឈានមុខគេក្នុងការប្រយុទ្ធប្រឆាំងជាបន្ទាន់ទៅនឹងការប្រែប្រួលអាកាសធាតុ ដែលនេះជាជំហានមួយដ៏លឿន ដើម្បីឆ្លើយតបនឹងគោលដៅក្នុងការបំបាត់ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទាំងស្រុងត្រឹមឆ្នាំ២០៥០ [៦៩]។ រហូតមកដល់ពេលនេះ មិនមានប្រទេសសេដ្ឋកិច្ចជឿនលឿនណាមួយបានធ្វើសកម្មភាពដ៏អង់អាចតាមរបៀបនេះទេក្នុងការប្រឈមមុខនឹងបញ្ហាអាកាសធាតុនេះ។ Ursula von der Leyen ប្រធានគណៈកម្មការអឺរ៉ុបបានប្រៀបធៀបបេសកកម្មនេះទៅនឹងពាក្យថា «មនុស្សអឺរ៉ុបនៅឋានព្រះចន្ទ» [៦៩]។

គោលបំណងចម្បងរបស់កិច្ចព្រមព្រៀងបៃតងអឺរ៉ុប (EGD) គឺដើម្បីសម្រេចឲ្យបាននូវគោលដៅធ្វើឲ្យមានអព្យាក្រឹតកាបូនក្នុងរយៈពេលបីទសវត្សរ៍ខាងមុខ។ នេះមានន័យថា យើងត្រូវគិតឡើងវិញនូវគោលនយោបាយស្ដីពីថាមពលស្អាត ឧស្សាហកម្ម ហេដ្ឋារចនាសម្ព័ន្ធនិងការដឹកជញ្ជូនស្បៀងអាហារនិងកសិកម្ម [៦៩]។ រាល់ឧបករណ៍គោលនយោបាយដែលមានទាំងអស់ចាំបាច់ត្រូវដាក់ឲ្យអនុវត្ត ហើយត្រូវប្រើប្រាស់ហិរញ្ញវត្ថុសាធារណៈ និងឯកជនដើម្បី «ផ្លាស់ប្ដូរទៅជាគំរូមួយដែលធ្វើឲ្យមានកំណើនសេដ្ឋកិច្ចដោយកាត់ផ្ដាច់ពីការប្រើប្រាស់ធនធានដែលមានផលប៉ះពាល់បរិស្ថាន»[៦៩]។ ព័ត៌មានលម្អិតពីកាលបរិច្ឆេទកំណត់និងគោលនយោបាយមិនទាន់ត្រូវបានគេសម្រេចចិត្តនៅឡើយទេ ទោះបីជាទីក្រុងព្រុចសែលគ្រោងនឹងដាក់ចេញច្បាប់ក្នុងខែមីនា ឆ្នាំ២០២០ ដើម្បីឈានទៅសម្រេចគោលដៅឆ្នាំ២០៥០[៦៩]ក៏ដោយ។ EGD នឹងត្រូវបានផ្ដល់ហិរញ្ញប្បទានដោយការប្រើប្រាស់មូលនិធិចម្រុះសាធារណៈការចូលរួមចំណែករបស់វិស័យឯកជន ក៏ដូចជាប្រាក់កម្ចី ដែលមានចំនួនសរុបចន្លោះពី ១៨០ ប៊ីលានទៅ ៣០០ ប៊ីលានអឺរ៉ូជារៀងរាល់ឆ្នាំ[៦៩]។ សហភាពអឺរ៉ុបនឹងរួមគ្នាបញ្ចូលនូវមូលនិធិមួយដែលមានចំនួន ១០០ ប៊ីលានអឺរ៉ូ ក្នុងរយៈពេលជាច្រើនឆ្នាំ ដើម្បីជួយអតីតប្រទេសកុម្មុយនីស្ត ដែលមានឧស្សាហកម្មធន់ធ្ងន់ពឹងផ្អែកលើធ្យូងថ្ម ដើម្បីធ្វើការសម្របខ្លួន ប៉ុន្តែប្រទេសប៉ូឡូញ ហុងគ្រី និងសាធារណរដ្ឋឆែក ដែលជាទូទៅមានការគាំទ្រកិច្ចព្រមព្រៀងបៃតងនេះ ត្រូវបានគេនិយាយថា ប្រទេសទាំងនេះត្រូវការមើលទៅលើផលប្រយោជន៍បន្ថែមទៀតដែលបានមកពីកញ្ចប់ថវិកាជាច្រើនឆ្នាំរបស់សហភាពអឺរ៉ុបជាមុនសិន មុននឹងផ្ដល់ការគាំទ្រពេញលេញលើគម្រោងនេះ។

បើក្រឡេកមើលឲ្យបានស៊ីជម្រៅអំពីការចង់បានរបស់កិច្ចព្រមព្រៀងបៃតង ដែលត្រូវសម្រេចបាន សហភាពអឺរ៉ុបទំនងជាចាំបាច់ត្រូវកំណត់ស្ដង់ដារបរិស្ថានឲ្យបានតឹងរ៉ឹងជាងមុនលើប្រភេទជាច្រើន រាប់ចាប់ពីការបញ្ចេញឧស្ម័នពីយានយន្ត អាគុយរថយន្ត និងការវេចខ្ចប់ដែលអាចកែច្នៃប្រើឡើងវិញ រហូតដល់ផលិតផលហិរញ្ញវត្ថុ[៦៩]។ ប៉ុន្តែការពិតដែលបន្ទុកនៃការកាត់បន្ថយការបញ្ចេញឧស្ម័នត្រូវធ្លាក់លើដៃគូពាណិជ្ជកម្មរបស់សហភាពអឺរ៉ុបនោះ ដែលអាចនឹងបង្កជាការលំបាកក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផងដែរ។ ទីក្រុងព្រុចសែលកំពុងពង្រីកប្រព័ន្ធគ្រប់គ្រងពាណិជ្ជកម្មលើការបញ្ចេញឧស្ម័នរបស់ខ្លួនក្នុងប្រព័ន្ធដឹកជញ្ជូននិងអាកាសចរណ៍ដោយរៀបចំផែនការនៅឆ្នាំ២០២១ សម្រាប់ «យន្តការកែតម្រូវលើកាបូន ដើម្បីធានាថាថ្លៃនាំចូលសមស្របចំពោះធាតុចូលនៃកាបូនរបស់ពួកគេ» ដែលបន្ថែមបន្ទុកចំពោះការប្រមូលពន្ធទៅលើការនាំចូលពីប្រទេសដែលមិនអាចបំពេញកាតព្វកិច្ចរបស់ខ្លួនបាន[៦៩]។

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដែលបកដោយវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិនៃកម្ពុជា (NIDIR)។ អ្នកអានអាចទាញយកអត្ថបទដើមជាភាសាអង់គ្លេសពីគេហទំព័រ៖ https://www.pic.org.kh ។

# លេខយោង

A. នៅក្នុងកិច្ចប្រជុំកំពូលអាស៊ានចុងក្រោយនៅទីក្រុងបាងកក (ខែវិច្ឆិកា ឆ្នាំ២០១៩) មានតែពីរទៅបីវគ្គ និងអាហារថ្ងៃត្រង់មួយពេលប៉ុណ្ណោះ ដែលត្រូវបានធ្វើឡើងដើម្បីការប្រយុទ្ធប្រឆាំងនឹងការឡើងកម្តៅផែនដី ដែលតាមពីក្រោយការពិភាក្សាជុំវិញសន្ធិសញ្ញាពាណិជ្ជកម្មសេរី (RCEP)។ សេចក្តីប្រកាសត្រូវបានធ្វើឡើង ប៉ុន្តែត្រូវបានចាត់ទុកថាមិនគ្រប់គ្រាន់ដោយសមាគមការពារបរិស្ថាននានា។

B. Il existe aujourd’hui, à l’échelle mondiale, de nombreux accords internationaux sur l’environnement : plus de 1 100 accords multilatéraux et plus de 1 500 accords bilatéraux.

C. ជាញឹកញាប់ មានការយល់ឃើញថា ច្បាប់បរិស្ថាននានានឹងបន្ថយល្បឿន ឬរារាំងការអភិវឌ្ឍដោយដែលការយល់ឃើញបែបនេះមិនបានគិតដិតដល់ពីការដែលច្បាប់បរិស្ថានចូលរួមចំណែកដល់ការអភិវឌ្ឍប្រកបដោយចីរភាពក្នុងរយៈពេលវែង។ ជាលទ្ធផលក្រសួងបរិស្ថានច្រើនតែត្រូវបានគេដាក់កម្រិត និងខ្វះខាតមូលនិធិ។

D. ជាពិសេស ការពិនិត្យឡើងវិញបានរកឃើញថា រដ្ឋជាសមាជិកទទួលរងគ្រោះពី៖ ការសម្របសម្រួលគ្មានប្រសិទ្ធភាពរវាងអាជ្ញាធរមូលដ្ឋាន តំបន់ និងថ្នាក់ជាតិ។ កង្វះសមត្ថភាពនិងថវិកា រដ្ឋបាលកង្វះចំណេះដឹងនិងទិន្នន័យ យន្តការជានាការអនុលោមភាពតាមច្បាប់នៅមិនគ្រប់គ្រាន់ និងកង្វះនៃការធ្វើសមាហរណកម្មនិងភាពស៊ីគ្នានៃគោលនយោបាយ។

E. Le tableau 6 donne l’augmentation nécessaire de la production alimentaire en tenant compte des changements anticipés des régimes alimentaires (voir Tableau 10) et de la distribution des âges dans la population.

F. ឥណ្ឌា ឥណ្ឌូនេស៊ី វៀតណាម និងចិន បានទទួលថវិកាចំនួន ៥៨% នៃមូលនិធិដែលបានអនុម័តសម្រាប់អាស៊ីចាប់តាំងពីឆ្នាំ២០០៣ (តារាងទី ២)។ ក្រៅពីនេះ មានគម្រោងក្នុងតំបន់ និងពហុប្រទេសចំនួន ១៥ ទៀតដែលស្មើនឹង ២,២% នៃថវិកាសរុបដែលបានអនុម័ត។ ថវិកាជំនួយកាត់បន្ថយហានិភ័យភាគច្រើនគាំទ្រដល់គម្រោងខ្នាតធំនៅក្នុងវិស័យថាមពលកកើតឡើងវិញ ប្រសិទ្ធភាពថាមពល និងដឹកជញ្ជូន។ CTF, មូលនិធិបៃតង, GEF និង SREP គឺជាម្ចាស់ជំនួយកាត់បន្ថយហានិភ័យធំបំផុតនៅក្នុងតំបន់។ ពួកគេបានអនុម័តថវិកាចំនួន ២,៨ ពាន់លានដុល្លារសម្រាប់គម្រោងជំនួយកាត់បន្ថយហានិភ័យ ចាប់តាំងពីឆ្នាំ២០០៣។ ខណៈពេលដែលគម្រោង និងកម្មវិធីបន្សាំក្នុងតំបន់ទទួលបានតែប្រហែល ១/៣ នៃចំនួនថវិកាកាត់បន្ថយហានិភ័យ ចំនួនជំនួយដែលច្រើនបំផុតសម្រាប់គម្រោងបន្សាំត្រូវបានផ្តល់ដោយ កម្មវិធីសាកល្បងលើភាពធន់នឹងអាកាសធាតុ (PPCR) ដើម្បីគាំទ្រកម្មវិធីនៅប្រទេសបង់ក្លាដែស កម្ពុជា និងនេប៉ាល់ ដែលមានទឹកប្រាក់សរុបចំនួន ២៦៩ លានដុល្លារអាម៉េរិក និងមូលនិធិប្រទេសអភិវឌ្ឍន៍តិចតួច ដែលមានទឹកប្រាក់សរុបចំនួន ២០៤ លានដុល្លារអាម៉េរិក។

# REFERENCES


១. Rosenzweig, C. and Parry, M. L. (1994). Potential impact of climate change on world food supply. Nature, 367(6459), p.133.

២. Hoegh-Guldberg, O. and Bruno, J. F. (2010). The impact of climate change on the world’s marine ecosystems. Science, 328(5985), pp.1523-1528.

៣. Mendelsohn, R., Dinar, A. and Williams, L. (2006). The distributional impact of climate change on rich and poor countries. Environment and Development Economics, 11(2), pp.159-178.

៤. MRC, (2019). Drought Management Strategy For the Lower Mekong Basin 2020-2025. Vientiane, Lao PDR.

៥. Rosenzweig, C. and Tubiello, F. N. (2007). Adaptation and mitigation strategies in agriculture: an analysis of potential synergies. Mitigation and adaptation strategies for global change, 12(5), pp. 855-873.

៦. Bala, G., Caldeira, K., Wickett, M., Phillips, T., Lobell, D., et al. (2007). Combined climate and carbon-cycle effects of large-scale deforestation. Proceedings of the National Academy of Sciences, 104(16), pp.6550-6555.

៧. Arima, E. Y., Barreto, P., Araújo, E. and Soares-Filho, B. (2014). Public policies can reduce tropical deforestation: Lessons and challenges from Brazil. Land use policy, 41465-473.

៨. Nepstad, D., Soares-Filho, B. S., Merry, F., Lima, A., Moutinho, P., et al. (2009). The end of deforestation in the Brazilian Amazon. Science, 326(5958), pp.1350-1351.

៩. DeFries, R. S., Rudel, T., Uriarte, M. and Hansen, M. (2010). Deforestation driven by urban population growth and agricultural trade in the twenty-first century. Nature Geoscience, 3(3), p.178.

១០. Meyfroidt, P., Vu, T. P. and Hoang, V. A. (2013). Trajectories of deforestation, coffee expansion and displacement of shifting cultivation in the Central Highlands of Vietnam. Global Environmental Change, 23(5), pp.1187-1198.

១១. Sayer, J., Ghazoul, J., Nelson, P. and Boedhihartono, A. K. (2012). Oil palm expansion transforms tropical landscapes and livelihoods. Global Food Security, 1(2), pp.114-119.

១២. Hall, D. (2009). The 2008 World Development Report and the political economy of Southeast Asian agriculture. The Journal of Peasant Studies, 36(3), pp.603-609.

១៣. Hall, D. (2011). Land grabs, land control, and Southeast Asian crop booms. Journal of peasant studies, 38(4), pp.837-857.

១៤. Rola, A. C. and Coxhead, I. (2005). Economic development and environmental management in the uplands of Southeast Asia: challenges for policy and institutional development. Agricultural economics, 32(n.a), pp.243-256.

១៥. Thongmanivong, S., Fujita, Y., Phanvilay, K. and Vongvisouk, T. (2009). Agrarian Land Use Transformation in Northern Laos. Japanese Journal of Southeast Asian Studies, 47(3), pp.330-347.

១៦. World Bank (2016). World Development Indicator, ed. Washington DC,: the World Bank.

១៧. McCarthy, J. F. (2010). Processes of inclusion and adverse incorporation: oil palm and agrarian change in Sumatra, Indonesia. The Journal of peasant studies, 37(4), pp.821-850.

១៨. Jayed, M., Masjuki, H. H., Saidur, R., Kalam, M. and Jahirul, M. I. (2009). Environmental aspects and challenges of oilseed produced biodiesel in Southeast Asia. Renewable and Sustainable Energy Reviews, 13(9), pp.2452-2462.

១៩. Kaba, A. (2017). The Oil Palm Complex. Smallholders, Agribusiness and the State in Indonesia and Malaysia, Rob Cramb & John McCarthy, éd.. Singapour, National University of Singapore Press, 2016, 512 p, Presses Universitaires de Provence.

២០. Enters, T., (2017). Drivers of deforestation and forest degradation in Myanmar. UN-REDD/ Myanmar Programme.

២១. LUO, P. M., Donaldson, J. A. and Zhang, Q. F. (2011). The transformation of China's agriculture system and its impact on Southeast Asia. International Journal of China Studies, 2(2), p.289.

២២. Mills, E. (2015). Chinese agricultural and land investments in Southeast Asia: A preliminary overview of trends. Rotterdam: BRICS Initiatives for Critical Agrarian Studies (BICAS).

២៣. Fox, J. and Castella, J.-C. (2013). Expansion of rubber (Hevea brasiliensis) in Mainland Southeast Asia: what are the prospects for smallholders? The Journal of Peasant Studies, 40(1), pp.155-170.

២៤. Redfern, S. K., Azzu, N. and Binamira, J. S. (2012). Rice in Southeast Asia: facing risks and vulnerabilities to respond to climate change. Build Resilience Adapt Climate Change Agri Sector, 23(n.a), p.295.

២៥. Loo, Y. Y., Billa, L. and Singh, A. (2015). Effect of climate change on seasonal monsoon in Asia and its impact on the variability of monsoon rainfall in Southeast Asia. Geoscience Frontiers, 6(6), pp.817-823.

២៦. Matthews, R., Kropff, M., Horie, T. and Bachelet, D. (1997). Simulating the impact of climate change on rice production in Asia and evaluating options for adaptation. Agricultural systems, 54(3), pp.399-425.

២៧. Zhai, F. and Zhuang, J. (2012). Agricultural impact of climate change: A general equilibrium analysis with special reference to Southeast Asia. Climate change in Asia and the Pacific: How can countries adapt, pp.17-35.

២៨. Marks, D. (2011). Climate change and Thailand: Impact and response. Contemporary Southeast Asia: A Journal of International and Strategic Affairs, 33(2), pp.229-258.

២៩. Francisco, H. A. (2008). Adaptation to climate change: needs and opportunities in Southeast Asia. ASEAN Economic Bulletin, pp.7-19.

៣០. Firman, T., Surbakti, I. M., Idroes, I. C. and Simarmata, H. A. (2011). Potential climate-change related vulnerabilities in Jakarta: Challenges and current status. Habitat International, 35(2), pp.372-378.

៣១. Lauri, H., Moel, H. d., Ward, P., Räsänen, T., Keskinen, M., et al. (2012). Future changes in Mekong River hydrology: impact of climate change and reservoir operation on discharge.

៣២. Arias, M. E., Cochrane, T. A., Kummu, M., Lauri, H., Holtgrieve, G. W., et al. (2014). Impacts of hydropower and climate change on drivers of ecological productivity of Southeast Asia's most important wetland. Ecological modelling, 272(n.a), pp.252-263.

៣៣. Taylor, D. (2010). Biomass burning, humans and climate change in Southeast Asia. Biodiversity and conservation, 19(4), pp.1025-1042.

៣៤. Van Zonneveld, M., Koskela, J., Vinceti, B. and Jarvis, A. (2009). Impact of climate change on the distribution of tropical pines in Southeast Asia. Unasylva, 231(232), pp.24-29.

៣៥. Alongi, D. M. (2015). The impact of climate change on mangrove forests. Current Climate Change Reports, 1(1), pp.30-39.

៣៦. Barange, M., Merino, G., Blanchard, J., Scholtens, J., Harle, J., et al. (2014). Impacts of climate change on marine ecosystem production in societies dependent on fisheries. Nature Climate Change, 4(3), p.211.

៣៧. Dennis, R. A., Meijaard, E., Nasi, R. and Gustafsson, L. (2008). Biodiversity conservation in Southeast Asian timber concessions: a critical evaluation of policy mechanisms and guidelines.

៣៨. Poffenberger, M. (2006). People in the forest: community forestry experiences from Southeast Asia. International Journal of Environment and Sustainable Development, 5(1), pp.57-69.

៣៩. Letchumanan, R. (2010). Climate change: is Southeast Asia up to the challenge?: is there an ASEAN policy on climate change?

៤០. Speechly, H. and Van Helden, F. (2012). 3.2 Forest governance in southeast asia. Moving Forward With Forest Governance, 101.

៤១. Inoue, M. (2003). Participatory forest management policy in South and Southeast Asia. People and forest—policy and local reality in Southeast Asia, the Russian Far East, and Japan. Springer.

៤២. Ziegler, A. D., Phelps, J., Yuen, J. Q., Webb, E. L., Lawrence, D., et al. (2012). Carbon outcomes of major land cover transitions in SE Asia: great uncertainties and REDD+ policy implications. Global Change Biology, 18(10), pp.3087-3099.

៤៣. Dressler, W., McDermott, M., Smith, W. and Pulhin, J. (2012). REDD policy impacts on indigenous property rights regimes on Palawan Island, The Philippines. Human ecology, 40(5), pp.679-691.

៤៤. Mohammed, A. J., Inoue, M., Shivakoti, G. P., Nath, T. K., Jashimuddin, M., et al. (2016). Analysis of national forest programs for REDD+ implementation in six South and Southeast Asia countries. Forest systems, 25(2), p.5.

៤៥. Own Lwin, (2015). Study on criteria and indicators of international standards for certification contributing sustainable forest management in natural and planted forests in Myanmar. Ministry of Environmenal Conservation and Forestry.

៤៦. Ian, G. B. (2014). Reduced emissions from deforestation and forest degradation (REDD) and access and exclusion: Obstacles and opportunities in Cambodia and Laos. Southeast Asian Studies, 3(3), pp.643-668.

៤៧. ONU Info. (2019). L'Asie du Sud-Est, région la plus menacée par le changement climatique (ONU) [Online]. Nations Unies. Available at: https://news.un.org/fr/story/2019/11/1055301 [Accessed 10 Jan. 2020].

៤៨. UN News (2019). Far more needed to 'confront the world's climate emergency', Guterres tells ASEAN-UN Summit [Online]. United Nations. Available at: https://news.un.org/en/story/2019/11/1050501 [Accessed 10 Jan. 2020].

៤៩. ASEAN (2002). ASEAN Agreement on Transboundary Haze Pollution [Online]. ASEAN Cooperation on Environment. Available at: http://environment.asean.org/wp-content/uploads/2015/06/ASEANAgreementonTransboundaryHazePollution.pdf [Accessed 12 Jan. 2020].

៥០. ASEAN (2005). Agreement on the Establishment of the ASEAN Centre for Biodiversity [Online]. ASEAN Cooperation on Environment. Available at: http://environment.asean.org/wp-content/uploads/2015/07/Agreement-on-the-Establishment-of-ACB.pdf [Accessed 12 Jan. 2020].

៥១. Philips, R. (2019). Sommet de l'Asean: l'écologie au second plan des négociations [Online]. RFI. Available at : http://www.rfi.fr/asie-pacifique/20191105-asean-asie-sud-est-indonesie-vietnam-chine-malaisie-rechauffement-climatique [Accessed 8 Jan. 2020].

៥២. UN Water (No Date). Water, Food and Energy [Online]. United Nations. Available at: https://www.unwater.org/water-facts/water-food-and-energy/ [Accessed 9 Jan. 2020].

៥៣. Food and Agriculture Organization of the United Nations (2014). The Water-Energy-Food Nexus
A new approach in support of food security and sustainable agriculture [Online]. FAO. Available at: http://www.fao.org/3/a-bl496e.pdf [Acessed 6 Jan. 2020].

៥៤. UNEP (2014). Enforcement of Environmental Law: Good Practices from Africa, Central Asia,
ASEAN Countries and China [Online]. United Nations. Available at: https://environment.asean.org/about-asean-cooperation-on-environment/ [Accessed 10 Jan. 2020].

៥៥. Nexus Resource Platform. (No Date). The Water, Energy & Food Security Resource Platform [Online]. Water-energy-food.org. Available at: https://www.water-energy-food.org/nexus-platform-the-water-energy-food-nexus/ [Accessed 11 Jan. 2020].

៥៦. Moursa, H. (2019). Overview of plastic issues in ASEAN, focusing on marine debris and microplastics in the region. Phnom Penh: Parliamentary Institute of Cambodia.57. Bruch C., et al. (2019). Environmental Rule of Law First Global Report [Online], pp. 4-5. UN environment programme. Available at: https://wedocs.unep.org/bitstream/handle/20.500.11822/27279/Environmental_rule_of_law.pdf [Accessed 12 Jan. 2020].

៥៧. Bruch C., et al. (2019). Environmental Rule of Law First Global Report [Online]. UN environment programme. Available at: https://wedocs.unep.org/bitstream/handle/20.500.11822/27279/Environmental_rule_of_law.pdf [Accessed 12 Jan 2020].

៥៨. European Commission (2017). The EU Environmental Implementation Review (EIR) Package: Common Challenges and How to Combine Efforts to Deliver Better Results [Online]. Available at: http://ec.europa.eu/environment/eir/pdf/full_report_en.pdf [Accessed 8 Jan. 2020].

៥៩. Testard, H. (2018). Climat: l'Asie détermine notre avenir [Online]. Asialyst. Available at: https://asialyst.com/fr/2018/12/01/climat-asie-determine-notre-avenir/ [Accessed 12 Jan. 2020].

៦០. Marsily, G. d. (2008). Eau, changements climatiques, alimentation et évolution démographique [Online]. Erudit. Available at: https://www.erudit.org/fr/revues/rseau/2008-v21-n2-rseau2316/018460ar/ [Accessed 10 Jan. 2020].

៦១. Shepherd, A., Mitchell, T., Lewis, K., Lenhardt, A., Jones, L., Scott, L. and Caravani, A. (2013). The geography of poverty, disasters and climate extremes in 2030. London: Overseas Development Institute

៦២. Im, E. S.,Pal, J. S. and Eltahir, E. A. B. (2017). Deadly heat waves projected in the densely populated agricultural regions of South Asia. Science Advances, [Online] 3(8). Available at: https://advances.sciencemag.org/content/3/8/e1603322.full [Accessed 12 Jan. 2020].

៦៣. Voir COLLOMB, P. (1999). Une voie étroite pour la sécurité alimentaire d'ici à 2050. FAO, Economica, Paris ; GRIFFON, M. (2006). Nourrir la planète. Odile Jacob, Paris, France, available at : https://books.google.com.kh/books?hl=en&lr=&id=dKebju0bDwwC&oi=fnd&pg=PA15&dq=Griffon,+M.+(2006).+Nourrir+la+plan%C3%A8te.+Odile+Jacob,+Paris,+France.&ots=yN4nCGqfgL&sig=xaR_XD5ddgeWK5cXHZRJoIE3TU4&redir_esc=y#v=onepage&q=Griffon%2C%20M.%20(2006).%20Nourrir%20la%20plan%C3%A8te.%20Odile%20Jacob%2C%20Paris%2C%20France.&f=false [Accessed 9 Jan 2020].

៦៤. The World Bank (2020). Classification de la Banque mondiale Asie et Pacifique et Asie du sud à l'exception des petits États insulaires développés [Online]. World Bank Country and Lending Groups. Available at : http://data.worldbank.org/about/country-classifications/country-and-lending-groups#East_Asia_and_Pacific, et http://data.worldbank.org/region/SAS [Accessed 10 Jan.2020].

៦៥. African Development Bank Group (AFDB). (No Date). Green Climate Fund [Online]. AFDB. Available at: https://www.afdb.org/en/topics-and-sectors/initiatives-partnerships/green-climate-fund. [Accessed 11 Jan. 2020].

៦៦. Watson, C. and Schalatek, L. (2019). Note régionale sur le financement climatique: Asie. [Online] Climate Funds Update, Available at: https://climatefundsupdate.org/wp-content/uploads/2019/03/CFF8-2018-FR.pdf [Accessed 8 Jan. 2020].

៦៧. Jackson RB, Le Quéré C, Andrew RM , Canadell JG, Korsbakken JI , Liu Z, Peters GP , Zheng B, Friedlingstein P (2019). Global Energy Growth Is Outpacing Decarbonization. A special report for the United Nations Climate Action Summit September 2019. (Online) Global Carbon Project, International Project Office, Canberra Australia. Available at: https://www.globalcarbonproject.org/global/pdf/GCP_2019_Global%20energy%20growth%20outpace%20decarbonization_UN%20Climate%20Summit_HR.pdf [Accessed 12 Jan 2020]

៦៨. European Commission (2019). A European Green Deal, Striving to be the first climate-neutral continent (Online), EU Commission, Available at: https://ec.europa.eu/info/strategy/priorities-2019-2024/european-green-deal_en [Accessed 6 Jan 2019]

៦៩. Hook L. (2019). Splits over climate policy threaten to derail UN summit in Madrid (Online). Financial Times. Available at: https://www.ft.com/content/637b58e8-1c2d-11ea-9186-7348c2f183af [Accessed 18 Jan 2020].

## BIBLIOGRAPHY


១. Desakota Area, McGee, 1991

២. Sinking Cities, An integrated approach towards solutions, Deltares, 2015

៣. De Jakarta à Bangkok, les grandes villes asiatiques bientôt sous les eaux? Cyrielle Cabot, Asialyst novembre 2019

៤. Alexandra Tracy, Kate Trumbull and Christine Loh, « L'impact de l'évolution climatique à Hong Kong et dans le delta de la rivière des Perles », Perspectives chinoises [Online], 2007/1 http://journals.openedition.org/perspectiveschinoises/1873

៥. Climate Central, Report: Flooded Future: Global vulnerability to sea level rise worse than previously understood, 29th October 2019

៦. IPCC, International Panel on Climate Change, Report, 25 9 2019

៧. Land Subsidence and Groundwater Management in Tokyo, In IRES Vol.6 No.2, Chikafusa Sato, Michiko Haga, Jiro Nishino, IGES, Institute for Global Environmental Strategies, March 2006

៨. Carbon Atlas (2019). Global Carbon Atlas Release 2019. Global Carbon Project. Available at: http://www.globalcarbonatlas.org/en/content/welcome-carbon-atlas [Accessed 28 Dec 2019].

# “សំខាន់គឺការទូតសភាជាការទូតនៃឥទ្ធិពល”

## ទស្សនវិស័យពីអាស៊ី

### តួនាទីរបស់ការទូតសភា

*ការប្រជុំអន្តរសភាដែលរៀបចំឡើងសម្រាប់ត្រៀមកិច្ចប្រជុំកំពូលថ្នាក់អន្តរតំបន់ (ដូចជា ASEP) គឺជាឱកាសផ្លាស់ប្តូរយោបល់ និងជំហរដ៏សំខាន់ ដើម្បីជំរុញនិងពង្រឹងកិច្ចព្រមព្រៀងសាមគ្គីភាពអន្តរតំបន់។ នៅក្នុងបរិបទទាំងនេះ ដំណោះស្រាយថ្មីអាចលេចឡើង។*

*បណ្តាសភាអាស៊ានអាចធ្វើការជាមួយគ្នាដើម្បីចែករំលែកបទពិសោធន៍ និងមេរៀនល្អៗទាក់ទងទៅនិងវិធីសាស្ត្រក្នុងការទប់ទល់និងបន្សាំ ជាមួយនិងការប្រែប្រួលអាកាសធាតុ។*

### តួនាទីរបស់សភា

*សមាជិកសភាដែលធ្វើការជាពិសេសលើបញ្ហាការបរទេសអាចអញ្ជើញថ្នាក់ដឹកនានានៃរដ្ឋាភិបាល ក្រសួង និងភ្នាក់ងាររដ្ឋ ដើម្បីសង្ខេប និងឆ្លើយសំណួរដេញដោលលើបញ្ហាអន្តរជាតិ កិច្ចការការបរទេស និងគោលនយោបាយពាណិជ្ជកម្ម ដែលប៉ះពាល់ដល់ប្រជាពលរដ្ឋរបស់ខ្លួន។*

*ស្របពេលដែលការផ្តល់គំនិតយោបល់តាមបែបប្រជាធិបតេយ្យមានការកើនឡើងដោយសារតែវត្តមានរបស់បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ (ICT) សមាជិកសភាត្រូវតែទំនាក់ទំនងជាមួយម្ចាស់ឆ្នោតឲ្យកាន់តែមានប្រសិទ្ធភាព ដើម្បីសម្រេចនូវការរំពឹងទុករបស់ប្រជាជនដែលកើនឡើងជារៀងរាល់ថ្ងៃ។*

*ស្ថាប័នសភា ក៏អាចរៀបចំផងដែរនូវសិក្ខាសាលាផ្សព្វផ្សាយព័ត៌មាននៅថ្នាក់មូលដ្ឋាន ដើម្បីពន្យល់ដល់សាធារណៈជន អំពីសារៈសំខាន់នៃប្រព័ន្ធពាណិជ្ជកម្មដែលពឹងផ្អែកលើនីតិវិធី។*

*ដើម្បីមានភាពបុរេសកម្ម សភានៅអាស៊ីចាំបាច់ត្រូវពង្រឹងតួនាទីដែលមានស្រាប់ទាំងនេះតាមរយៈការកសាងសមត្ថភាពដើម្បីឈានទៅគ្រប់គ្រង និងកំណត់បរិយាកាសសន្តិសុខតំបន់ក្នុងកម្រិតខ្ពស់បំផុតតាមដែលអាចទៅរួច ជាជាងគ្រាន់តែឆ្លើយតបនឹងការគម្រាមកំហែងដែលកើតឡើងរួចហើយ។*

*ជាមួយនឹងមុខងារត្រួតពិនិត្យ សភាអាចកោះប្រជុំជាប្រចាំជាមួយនឹងក្រសួងពាក់ព័ន្ធដើម្បីកំណត់នូវការប្រឈមនានាក្នុងការអនុវត្ត និងពង្រឹងការអនុវត្តច្បាប់។ សភាអាចយកឱកាសនេះសម្រាប់ផ្តល់ជាយោបល់ និងគំនិតឲ្យបានទាន់ពេលមុននឹងសម្រេចអនុម័តច្បាប់ឬក៏ថវិកា។*

*បច្ចុប្បន្ន មូលនិធិអឺរ៉ុបសម្រាប់អាស៊ី មាននិន្នាការគាំទ្រកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយ (**mitigation**) ជាជាងការខិតខំ ដើម្បីដោះស្រាយ បញ្ហាតាមរបៀប ប្រកបដោយចីរភាព(**adaptation**)។ សភាអាស៊ីអាចពិចារណា លើជម្រើសគោលនយោបាយ ដើម្បីដោះស្រាយបញ្ហាដែលកើតឡើងពីការប្រែប្រួលអាកាសធាតុ ប្រកបដោយចីរភាព និងដោយគិតពីកាលៈទេសៈជាក់លាក់នៅប្រទេសនីមួយៗ។*

# ទស្សនវិស័យពីសហភាពអឺរ៉ុប

## តួនាទីរបស់ការទូតសភា

*សមាជិកសភាដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការសម្រេចចិត្តថ្នាក់ជាតិ។ ដូចគ្នានេះដែរ ពួកគេត្រូវតែក្លាយជាអ្នកដើរតួយ៉ាងសំខាន់នៅក្នុងវេទិកាសម្ព័ន្ធក្នុងតំបន់នានា ដែលជាវេទិកាសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តសំខាន់ៗ ហើយត្រូវបានធ្វើឡើងកាន់តែច្រើនឡើងៗ។*

*សភាថ្នាក់តំបន់និងសកលដូចជា ASEP ត្រូវតែទទួលបានអំណាច ដើម្បីធ្វើឲ្យវេទិកាទាំងនោះមានគណនេយ្យភាព និងបន្ថែមភាពស្របច្បាប់លើការសម្រេចចិត្តរបស់ពួកគេ។*

*សមាជិកសភាអាចប្រាស្រ័យទាក់ទងគ្នាពីសារ និងលើកកម្ពស់ផលប្រយោជន៍ជាតិនៃរដ្ឋនីមួយៗរបស់ខ្លួន។ អាស្រ័យហេតុផលនោះ សភាការទូតគួរតែជាឧបករណ៍ដែលត្រូវដោះស្រាយជាបញ្ហាសន្តិសុខបរិស្ថាន។*

## តួនាទីរបស់សភា

*សមាជិកតំណាងសភាកាន់តែចម្រុះ នោះសភាកាន់តែមានប្រសិទ្ធិភាពដើម្បីប្រាប់ទៅប្រជាពលរដ្ឋពីអភិវឌ្ឍន៍អភិក្រមនានាដែលពាក់ព័ន្ធគោលនយោបាយការបរទេស។*

*ក្នុងការលើកកម្ពស់យុទ្ធសាស្ត្របន្សាំ និងការកាត់បន្ថយសភាអាចធ្វើការលើកឡើងការបង្កើតច្បាប់លើកកម្ពស់ការយល់ដឹងរបស់សាធារណជន តាមដានការប្រតិបត្តិដែលមានប្រសិទ្ធភាពច្បាប់ និងធ្វើសហប្រតិបត្តិការក្នុងតំបន់ផងដែរ។*

*ដើម្បីការពារការត្រួតពិនិត្យតាមបែបប្រជាធិបតេយ្យ លើកម្លាំងយោធា និងការប្រើប្រាស់កម្លាំងយោធាសមាជិកសភា ត្រូវតែជាផ្នែកមួយនៃដំណើរការក្នុងការធ្វើផែនការយុទ្ធសាស្ត្រ។*

*សភាមានទំនួលខុសត្រូវផ្ទាល់នៅក្នុងក្របខ័ណ្ឌនៃនម្មាបនកម្មសន្តិសុខនៅអាស៊ី។ តួនាទីដំបូងបង្អស់របស់សភាដើម្បីធានាថាកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខាដោយរដ្ឋាភិបាល គឺអនុលោមទៅតាមផលប្រយោជន៍ជាតិ និងការចូលរួមអន្តរជាតិ។ សភាក៏មានតួនាទីគ្រប់គ្រង និងត្រួតពិនិត្យលើគោលនយោបាយការបរទេស និងសន្តិសុខដែលអនុវត្តដោយរដ្ឋាភិបាល តាមរយៈគណៈកម្មាការកិច្ចការការបរទេស និងការពារជាតិ។*

*សភានៅតែអាចជាឧបករណ៍មានអំណាចមួយសម្រាប់រដ្ឋាភិបាល ដើម្បីតទល់នឹងសម្ពាធនៃគម្លាតឆ្ងាយពីគ្នាដែលអាស៊ីកំពុងជួបប្រទះ។ ដូច្នេះហើយ សភាអាចចូលរួមយ៉ាងសំខាន់ដើម្បីសន្តិសុខតំបន់ និងពិភពលោក។*

*ក្រុមប្រឹក្សាសភាពិសេស* **Ad hoc** *គួរអនុវត្តការធ្វើសវនកម្ម និងអធិការកិច្ចប្រចាំឆ្នាំទៅលើកម្រិតនៃច្បាប់ដែលបានដាក់ចេញអនុវត្តន៍។*



# ភាគទី ២

# ការទូតសភា
# ក្នុងបរិបទអាស៊ាន



# សេចក្តីផ្តើម

សៀវភៅផែនទីតំបន់ស្តីពី ការទូតសភាក្នុងបរិបទអាស៊ាន បានបង្ហាញនិងពិនិត្យពីតួនាទីនិងដំណើរការដែលកំពុងប្រែប្រួលនៃការទូតសភាក្នុងតំបន់អាស៊ាន។ ជាឧបករណ៍សម្រាប់បង្រៀនផង និងជាឧបករណ៍សម្រាប់ការផ្លាស់ប្តូរចំណេះដឹងនិងព័ត៌មានជាបន្តបន្ទាប់ផង សៀវភៅផែនទីនេះបានឆ្លុះបញ្ចាំងពីគោលដៅរួមរបស់ស្ថាប័នទាំងពីរដែលជាស្ថាបនិកនៃសៀវភៅនេះគឺ វិទ្យាស្ថានសភាកម្ពុជា (PIC) និងលេខាធិការដ្ឋានអន្តរសភាអាស៊ាន (AIPA) ។

ក្នុងអំលុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ការទូតសភាបានក្លាយជាឧបករណ៍កាន់តែសំខាន់ ដើម្បីសម្របសម្រួលកិច្ចសហប្រតិបត្តិការអន្តរជាតិ និងដោះស្រាយបញ្ហា។ ក្នុងការជួយបំពេញបន្ថែមទៅលើផ្នែកនីតិប្រតិបត្តិ ដែលជាប្រពៃណីជាអ្នកធ្វើការលើការងារការទូតអន្តរជាតិ បន្តិចម្តងៗការទូតដែលធ្វើដោយសភាកំពុងក្លាយជាឧបករណ៍ដែលមិនអាចខ្វះបានដើម្បីជួយដោះស្រាយបញ្ហាប្រឈមតំបន់និងសកល។ បញ្ហាប្រឈមរួមមានដូចជា ការសម្រេចឲ្យបាននូវចក្ខុវិស័យសហគមន៍អាស៊ាន២០២៥ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ (UNSDGs) គឺតម្រូវឲ្យមានការឆ្លើយតបជាសមូហភាព និងមានការសម្របសម្រួលរួម។

មជ្ឈមណ្ឌលរួមសម្រាប់ការប្រាស្រ័យឆ្លើយឆ្លងអន្តរសភាដែលចាំបាច់ក្នុងការជួយដល់ការសម្របសម្រួលការងាររួមរបស់សភានៃបណ្តារដ្ឋជាសមាជិកអាស៊ាន ដើម្បីប្រឈមទៅនឹងបញ្ហាដែលកំពុងជួបប្រទះនៅអាស៊ីអាគ្នេយ៍ គឺលេខាធិការដ្ឋានអាយប៉ា។ ទោះបីជាមានភាពខុសគ្នាខ្លះក៏ដោយក៏ប្រទេសទាំងនេះមានចំនុចរួមមួយចំនួនដែលផ្សារភ្ជាប់ដោយចំណងប្រវត្តិសាស្ត្រ វប្បធម៌ និងសេដ្ឋកិច្ច។ អាយប៉ាបានបង្កើតកន្លែងប្រជុំមួយសម្រាប់សមាជិក សមាជិកាសភាមកពីប្រទេសជាសមាជិក ដើម្បីធ្វើការរួមគ្នា តំណាងឲ្យប្រជាពលរដ្ឋអាស៊ាន ដើម្បីដោះស្រាយកង្វល់រួម។

ដូចទៅនឹងសភានានាដែលកំពុងប្រកាន់យកវិធីសាស្ត្រផ្លាស់ប្តូរនៅក្នុងកិច្ចសហប្រតិបត្តិការតំបន់ដែរ តួនាទីរបស់ PIC មិនត្រឹមតែការជួយបង្កើនសមត្ថភាពរបស់សភាកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែជួយជម្រុញឲ្យមានការចែករំលែកចំណេះដឹង និងជំនាញជាមួយបណ្តាសភានៅអាស៊ាន និងសភាដទៃទៀត។ កន្លងមក PIC និងលេខាធិការដ្ឋានអាយប៉ាមានការសហការគ្នាប្រកបដោយផ្លែផ្កា ព្រោះថា អង្គការអន្តរសភានានាអាចទទួលបានជោគជ័យលុះត្រាតែសភានៃរដ្ឋជាសមាជិកមានមន្ត្រីដែលមានសមត្ថភាព និងមានការយល់ដឹងខ្ពស់ទាក់ទងទៅនឹងបញ្ហាជាច្រើន។ ដោយឈរលើស្មារតីនេះ PIC និងលេខាធិការដ្ឋាន AIPA បានផ្តួចផ្តើមបង្កើតកម្មវិធីថ្នាក់តំបន់ថ្មីមួយ ស្តីពី "ការទូតសភា" ដែលបានចាប់ផ្តើមនៅឆ្នាំ២០១៩។ កិច្ចសហប្រតិបត្តិការរួមនេះ ទាមទារឲ្យមានការមើលជាថ្មីទៅលើតំបន់អាស៊ាន និងការពង្រីកការទទួលខុសត្រូវរបស់សភា ដូច្នេះហើយទើបយើងផលិតសៀវភៅផែនទីនេះឡើង។

សៀវភៅមួយក្បាលដែលបង្កើតឡើងមុនសៀវភៅនេះដែលបានចេញផ្សាយក្នុងឆ្នាំ២០១៧ មានចំណងជើងថា "ផែនទីភូមិសាស្ត្រនយោបាយរបស់កម្ពុជានៅក្នុងអាស៊ី និងពិភពលោក"។ សៀវភៅនោះត្រូវបានផលិតដើម្បីជាការឆ្លើយតបទៅនឹងសំណើពិសេសមួយរបស់អគ្គលេខាធិការនៃព្រឹទ្ធសភាកម្ពុជា ដែលមានបំណងជួយឲ្យមន្ត្រីសភាត្រៀមខ្លួនជាស្រេច ដើម្បីគាំទ្រសមាជិក សមាជិកាសភាឲ្យបានកាន់តែប្រសើរជាងមុន ក្នុងការចូលរួមក្នុងកិច្ចការការទូតសភា ដូចដែលបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា។

ក្នុងបរិបទនេះ PIC ដែលជាវិទ្យាស្ថានឯករាជ្យ និងមិនលំអៀង ដំបូងត្រូវបានបង្កើតឡើងដើម្បីជួយពង្រឹងសភាកម្ពុជា តាមរយៈការជួយអភិវឌ្ឍសមត្ថភាពរបស់មន្ត្រី និងសមាជិក សមាជិកាសភា បានបង្កើតកម្មវិធីថ្នាក់ជាតិស្តីពី "ការទូតសភា"។ ដើម្បីជាឯកសារយោងសម្រាប់សិក្ខាកាមជាមន្ត្រីសភា ជាពិសេសសម្រាប់អ្នកដែលធ្វើការនៅក្នុងសភា និងអ្នកដែលចាប់អារម្មណ៍អំពីកម្ពុជា និងទីតាំងរបស់កម្ពុជានៅក្នុងពិភពលោក PIC បានតាក់តែងសៀវភៅផែនទីដំបូងរបស់ខ្លួននេះឡើង។

គោលបំណងនៃសៀវភៅទាំងនេះមានពីរគឺ - ជាឧបករណ៍គរុកោសល្យសម្រាប់កម្មវិធីស្តីពី ការទូតសភា និងជាឯកសារយោងដែលផ្តល់ព័ត៌មានជូនសមាជិក សមាជិកាសភា និងមន្ត្រីសភាមកពីបណ្តារដ្ឋជាសមាជិកអាយប៉ា។ ដោយមានការណែនាំបែបវិទ្យាសាស្ត្រពីលោក Michel Foucher អ្នកភូមិសាស្ត្រ អ្នកការទូត និងអ្នកសរសេរអត្ថបទ និងដោយមានការចូលរួមសរសេរពីអ្នកជំនាញមកពីតំបន់នានា សៀវភៅផែនទីតំបន់ស្តីពី "ការទូតសភាក្នុងបរិបទអាស៊ាន" បានចាប់ផ្តើមដោយពិនិត្យមើលលើភូមិសាស្ត្រ និងភូមិសាស្ត្រនយោបាយនៃអាស៊ីអាគ្នេយ៍។ បន្ទាប់ទៀត សៀវភៅនេះងាកទៅពិនិត្យមើលលើការបង្កើតអាស៊ាន រួមទាំងគោលនយោបាយការបរទេសរបស់សមាជិកអាស៊ាន និងការផ្លាស់ប្តូរស្ថានភាពរបស់អង្គការនេះនៅក្នុងពិភពលោក។ សៀវភៅនេះធ្វើការស្រង់ព័ត៌មានពីប្រព័ន្ធ និងរចនាសម្ព័ន្ធសភារបស់បណ្តារដ្ឋដែលជាសមាជិក AIPA ដោយបន្ទាប់មកពណ៌នាពីប្រវត្តិ និងនិន្នាការបច្ចុប្បន្ននៃការទូតសភា រួមទាំងស្ថាប័នធំៗដែលទាក់ទងនឹងការងារនេះ ។ ជាចុងក្រោយសៀវភៅផែនទីនេះបានបង្ហាញនូវទិដ្ឋភាពទូទៅនៃបញ្ហាឆ្លងដែននានាក្នុងតំបន់។

សៀវភៅផែនទីតំបន់ស្តីពីការទូតសភាក្នុងបរិបទអាស៊ាន ត្រូវបានរៀបចំជារបៀបឯកសាររស់ ដោយការធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់ទៅលើឯកសារទម្រង់ជាអេឡិចត្រូនិច និងធ្វើការបោះពុម្ពទៅតាមដំណាក់កាល ដែលធ្វើឲ្យសៀវភៅនេះក្លាយជាឯកសារយោងដ៏មានតម្លៃ និងជាឧបករណ៍សម្រាប់កិច្ចសហប្រតិបត្តិការប្រកបដោយនិរន្តរភាព។ ដោយសារការទទួលបានព័ត៌មានទាន់ហេតុការណ៍មិនមែនជារឿងងាយស្រួល ដូច្នេះការធ្វើការរួមគ្នាគឺជាវិធីសាស្ត្រដែលល្អបំផុត។ ដោយហេតុនេះហើយ យើងបានស្នើសុំជំនួយពីថ្នាក់ដឹកនាំ អ្នកជំនាញ និងអ្នកដែលបានយល់ដឹងពីព័ត៌មានតាមរយៈការអានដទៃទៀត ដើម្បីស្នើសុំឲ្យមានការចែករំលែកចំណេះដឹងពាក់ព័ន្ធ ដែលនឹងត្រូវយកទៅបញ្ចូលក្នុងការធ្វើបច្ចុប្បន្នភាពសៀវភៅនេះនាពេលអនាគត។ យើងខ្ញុំសូមថ្លែងអំណរគុណដ៏ស្មោះអស់ពីចិត្ត ចំពោះអ្នកគ្រប់គ្នាដែលបានចំណាយពេលវេលា និងប្រើប្រាស់ជំនាញរបស់ខ្លួនក្នុងការចូលរួមផលិតឯកសារដ៏រស់រវើក ដែលត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំមួយនេះ។ យើងទាំងអស់គ្នាសង្ឃឹមថា សៀវភៅនេះនឹងនៅតែជាធនធានដ៏មានអត្ថប្រយោជន៍សម្រាប់សិក្ខាកាមជាមន្ត្រីសភា ដែលធ្វើការនៅក្នុងសភាជាសមាជិកអាយប៉ា និងសម្រាប់អ្នកគ្រប់គ្នាដែលចាប់អារម្មណ៍លើតួនាទីការទូតសភា និងតំបន់អាស៊ានជាទូទៅ។

ដើម្បីជួយវិទ្យាស្ថានសភាកម្ពុជា និងលេខាធិការដ្ឋានអាយប៉ាអាចផ្តល់សៀវភៅផែនទី ដែលតែងតែមានព័ត៌មានបច្ចុប្បន្នភាព និងពាក់ព័ន្ធ សូមផ្ញើយោបល់ និងការចែករំលែកនានាតាមរយៈអ៊ីមែល digital.atlas@pic.org.kh ។



**គឹមយាត ដារ៉ារិទ្ធ**
**នាយកប្រតិបត្តិ វិទ្យាស្ថានសភាជាតិកម្ពុជា**



**Isra SUNTHORNVUT**
**អគ្គលេខាធិការនៃ AIPA**



ការធ្វើស្រែដែលជាប្រភពស្បៀងអាហារចម្បងនៅក្នុងប្រទេសសមាជិកអាស៊ានទាំងអស់នៅតែជាផ្នែកសំខាន់មួយនៃសេដ្ឋកិច្ចក្នុងតំបន់
Agus Sudharnoko

ជំពូកទី

# ០៥

# បរិបទអាស៊ាន


ទំ.១២៨ ៥.១ ទិដ្ឋភាពទូទៅនៃតំបន់អាស៊ានៈ ភូមិសាស្ត្រ និងភូមិសាស្ត្រនយោបាយ

ទំ.១៣១ ៥.២ ការចូលជាសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន)

ទំ.១៣៣ ៥.៣ ទំនាក់ទំនងការបរទេសនៃបណ្តារដ្ឋសមាជិកអាស៊ាន

ទំ.១៣៩ ៥.៤ អាស៊ាននៅក្នុងបរិបទអន្តរជាតិ



*អ្នករួមចំណែកៈ បណ្ឌិត ឈីវ យីស៊ាង*
*មីហ្សែល ហួសហ្សេ*
*លោក អូថារ៉ាំ ភីរីយ៉ូសាមី*

# ៥.១ ទិដ្ឋភាពទូទៅនៃតំបន់អាស៊ានៈ ភូមិសាស្ត្រ និងភូមិសាស្ត្រនយោបាយ

អាស៊ីអាគ្នេយ៍បច្ចុប្បន្នមានប្រជាជន ៦៤៧ លាននាក់។ ចំនួននេះនឹងកើនដល់ ៨៣៩ លាននាក់នៅឆ្នាំ ២០៥០ដែលស្មើនឹង ៨,៥%នៃចំនួនប្រជាជនពិភពលោកដូចនឹងអត្រាបច្ចុប្បន្ននេះដែរ។

តាមទស្សនៈជាសកល ភូមិសាស្ត្ររបស់តំបន់អាស៊ីអាគ្នេយ៍មានទាំងគុណសម្បត្តិនិងហានិភ័យ។ តំបន់នេះគឺជាជីជុះដ៏ធំមួយនៃពិភពលោក ដែលស្ថិតនៅចន្លោះមហាសមុទ្រប៉ាស៊ីហ្វិកនិងមហា សមុទ្រឥណ្ឌា ដែលមានន័យថាតំបន់នេះដែលមានផ្ទៃទ្វីប កោះ និងឧបទ្វីបទំហំ ៤,៤ លានគីឡូម៉ែត្រការ៉េ ក៏ជាតួអង្គ ដ៏សំខាន់នៃសកម្មភាពតាមផ្លូវសមុទ្រផងដែរ។ ផ្លូវទឹកភ្ជាប់ទៅសមុទ្រ គឺជាកត្តាសំខាន់ក្នុងការជំរុញសាកលភាវូបនីយកម្មសេដ្ឋកិច្ច ៩០% នៃពាណិជ្ជកម្មពិភពលោកត្រូវបានធ្វើឡើងតាមផ្លូវសមុទ្រ ហើយការធ្វើបដិវត្តឧស្សាហកម្មទីបីដែលកំពុងបន្ត និងបដិវត្តបច្ចេកវិទ្យាពឹងផ្អែកទៅលើបណ្ដាញដ៏ទូលំទូលាយនៃការតភ្ជាប់គ្នានៅក្រោមទឹកដែលលាតសន្ធឹងពាសពេញពិភពលោក៖ អាស៊ីអាគ្នេយ៍ គឺជាបណ្ដាញនៃចំណុចឆ្លងកាត់សំខាន់ៗជាច្រើន។ តំបន់នេះពិតជាមានការតភ្ជាប់គ្នាផ្នែកភូមិសាស្ត្ររវាងបណ្ដារដ្ឋដែលផ្ដល់អត្ថប្រយោជន៍ដល់គ្រប់ប្រទេសទាំងអស់ដែលមានព្រំប្រទល់ជាប់នឹងសមុទ្រ លើកលែងតែប្រទេសឡាវ។ ប្រទេសចំនួនបីមានទឹកដីនៅជាប់ដោយឡែកពីគ្នា។សមុទ្រដែលលយចូលជ្រៅទៅក្នុងមានភាពស្មុគស្មាញជាងមហាសមុទ្រ ហេតុនេះធ្វើឲ្យមានកំពង់ផែមួយចំនួននៅទីនោះមានសកម្មភាពមមាញឹក។ ផ្នែកសមុទ្រនិងផ្នែកកោះរបស់អាស៊ី មានការរួបរួមគ្នាជាងផ្នែកទ្វីប។ ពួកឈ្មួញបានឆ្លងកាត់ដែនទឹករបស់ពួកគេនេះរាប់សតវត្សមកហើយ ដើម្បីតភ្ជាប់ពីតំបន់នេះទៅពាណិជ្ជកម្មនានាលើពិភពលោក។ ពួកគេបានលើកទឹកចិត្តការផ្សព្វផ្សាយព្រះពុទ្ធសាសនាតាំងពីដើមសតវត្សរ៍ទី៣ មកម្ល៉េះ និងបន្ទាប់មកគឺសាសនាឥស្លាមពីសតវត្សរ៍ទី១៣។ សម័យអាណានិគមបានបង្រួបបង្រួមការគ្រួតត្រាតំបន់ឆ្នេរសមុទ្រ ដែលរួមទាំងផ្លូវពាណិជ្ជកម្មអន្តរជាតិ (Malacca និង Luzon) និងមជ្ឈមណ្ឌលធំៗពីរ គឺប្រទេសសិង្ហបុរី និងបន្តទៅខាងជើង គឺហុងកុង។ ច្រកសមុទ្រ Malacca គឺជាច្រករបៀងមួយដែលមានចម្ងាយ ៨០០ គីឡូម៉ែត្រ ឆ្លងកាត់ដោយនាវាចំនួន ៧០.០០០ គ្រឿងជារៀងរាល់ឆ្នាំ - ពាក់កណ្ដាលនៃពាណិជ្ជកម្មពិភពលោក។

> “ មានការតភ្ជាប់គ្នាផ្នែកភូមិសាស្ត្ររវាងបណ្ដារដ្ឋ ដែលផ្ដល់អត្ថប្រយោជន៍ដល់គ្រប់ប្រទេសទាំងអស់ដែលមានព្រំប្រទល់ជាប់នឹងសមុទ្រ លើកលែងតែប្រទេសឡាវ។ ”

ធនធានមហាសមុទ្រមានសារៈសំខាន់សម្រាប់សេដ្ឋកិច្ចតំបន់ផ្ដល់ការផ្គត់ផ្គង់ប្រេងឧស្ម័ន និងការជម្រុកត្រី ដែលអាស្រ័យទៅនឹងប្រភេទនៃទីជម្រកធម្មជាតិ (ស្មៅភ្លោះ សណ្ឋាន ប្រព័ន្ធទន្លេ និងព្រៃកោងកាង)។ ផ្លូវចររួមគ្នារបស់ពួកឈ្មួញពីមុន ធ្លាប់មានតួនាទីជារចនាសម្ព័ន្ធដូចគ្នាដែរនៅទ្វីបអាស៊ីអាគ្នេយ៍ ជាពិសេសផ្លូវចររវាង Kunming ទៅ Bangkok និង Mawlamyine និងផ្លូវដែលផ្ដើមចេញពី Red River Delta ទៅកាន់បណ្ដាអាណាចក្រនៃជ្រលងទន្លេមេគង្គ។ លំហូរទាំងនេះត្រូវបានកាត់ផ្ដាច់នៅក្នុងសម័យអាណានិគម និងនៅក្នុងការបែងចែកទឹកដីជាបន្តបន្ទាប់ (ប្រទេសឡាវ និងប្រទេសវៀតណាម)។

អាស៊ីអាគ្នេយ៍ត្រូវបានបង្កើតឡើងដោយបណ្ដារដ្ឋឧបទ្វីប និងបណ្ដារដ្ឋប្រជុំកោះ ដែលប្រវត្តិសាស្ត្រនិងភូមិសាស្ត្របានសន្ទុតប្រឌិតដាក់នៅចន្លោះពិភពជនជាតិចិន និងឥណ្ឌា។ តំបន់នេះមានរដ្ឋសរុបចំនួន ១១ ហើយពួកគេបង្កើតនូវអ្វីដែលភូមិសាស្ត្រវិទូជនជាតិបារាំង Elisée Reclus បានហៅថា «Angle of Asia» ជាផ្លូវប្រសព្វ និងចំណុចប្រទាក់រវាងវប្បធម៌ពីរដ៏អស្ចារ្យ។

> “ ផ្នែកសមុទ្រនិងផ្នែកកោះនៃអាស៊ី មានការរួបរួមគ្នាជាងផ្នែកទ្វីប។ ពួកឈ្មួញបានឆ្លងកាត់ដែនទឹករបស់ពួកគេរាប់សតវត្សរ៍មក ហើយ ដែលតភ្ជាប់តំបន់នេះទៅនឹងពាណិជ្ជកម្មពិភពលោក។ ”

# ផែនទី ៥៖ ឯករាជ្យ ប្រវត្តិសាស្ត្រ និងប្រជាជន




| ប្រទេស | ផ្ទៃដី (ពាន់គីឡូម៉ែត្រការ៉េ) | ចំនួនប្រជាជននៅពាក់កណ្ដាលឆ្នាំ ២០១៧ (លាននាក់) | អត្រាកំណើត (ក្នុង ១,០០០ នាក់) | អត្រាមរណៈ (ក្នុង ១,០០០ នាក់) | ចំនួនប្រជាជនក្នុងឆ្នាំ ២០៥០ (លាននាក់) | អត្រាមរណភាពរបស់ទារក (ក្នុង ១,០០០ នាក់) | អត្រាកុមារស្លាប់មុនអាយុ ៥ ឆ្នាំ (ក្នុង ១,០០០ នាក់) | ក្រោម ១៥ ឆ្នាំ (%) | +៦៥ ឆ្នាំ (%) | សង្ឃឹមរស់សម្រាប់ប្រុស (ឆ្នាំ) | សង្ឃឹមរស់សម្រាប់ស្រី (ឆ្នាំ) | ផលិតផលក្នុងស្រុកសរុបក្នុងមនុស្សម្នាក់ក្នុងឆ្នាំ ២០១៦ (US$) |
|---|---|---|---|---|---|---|---|---|---|---|---|---|
| អាស៊ីអាគ្នេយ៍ | ៤,៤៩៥ | ៦៤៤ | ១៨ | ៧ | ៧៨៩ | ២៣ | ២៣ | ២៧ | ៦ | ៦៨ | ៧៣ | ១១,៣៤៩ |
| ព្រុយណេ | ៦ | 0.៤៣ | ១៦ | ៤ | 0.៥៤ | ៦ | ៦ | ២៤ | ៤ | ៧៥ | ៧៩ | ៨៣,២៥០ |
| កម្ពុជា | ១៨១ | ១៥.៩ | ២៤ | ៦ | ២២ | ២៥ | ២៥ | ៣២ | ៤ | ៦៦ | ៧១ | ៣,៥១០ |
| ឥណ្ឌូនេស៊ី | ១,៩០៥ | ២៦៤ | ១៩ | ៧ | ៣២២ | ២៣ | ២៣ | ២៨ | ៥ | ៦៧ | ៧១ | ១១,២២០ |
| ឡាវ | ២៣៧ | ៧ | ២៤ | ៧ | ៩ | ៤៣ | ៤៣ | ៣៤ | ៤ | ៦៥ | ៦៨ | ៥,៩២០ |
| ម៉ាឡេស៊ី | ៣៣0 | ៣១.៦ | ១៧ | ៥ | ៤២ | ៧ | ៧ | ២៥ | ៦ | ៧៣ | ៧៧ | ២៦,៩00 |
| មីយ៉ាន់ម៉ា | ៦៧៧ | ៥៣.៤ | ១៨ | ៨ | ៦២ | ៥២ | ៥២ | ២៨ | ៥ | ៦៤ | ៦៩ | ៦,0១0* |
| ហ្វីលីពីន | ៣00 | ១0៥ | ២៣ | ៧ | ១៥១ | ២១ | ២១ | ៣២ | ៥ | ៦៦ | ៧៣ | ៩,៤00 |
| សិង្ហបុរី | 0.៧ | ៥.៧ | ៩ | ៥ | ៧ | ២ | ២ | ១៥ | ១២ | ៨១ | ៨៥ | ៨៥,0៥0 |
| ថៃ | ៥១៣ | ៦៦.១ | ១១ | ៨ | ៦៣ | ១0 | ១0 | ១៨ | ១១ | ៧២ | ៧៩ | ១៦,0៧0 |
| ទីម័រឡេស្តេ | ១៥ | ១.៣ | ៣៨ | ១0 | ២.៤ | ៣៩ | ៣៩ | ៤៤ | ៣ | ៦៧ | ៧0 | ៤,៣៤0 |
| វៀតណាម | ៣៣២ | ៩៣.៧ | ១៦ | ៧ | ១0៨ | ១៥ | ១៥ | ២៤ | ៨ | ៧១ | ៧៦ | ៦,0៥0 |

ប្រភព: G.Pison, "The Population of the world (2017), " The French Institute for Demographic Studies,2017.
*IMF, "Asia Development Outlook,"2018. [online]. Available:https://data.worldbank.org/indicator/ny.gnp.pcap.pp.cd.[Accessed Feb 2019].

ពីប្រទេសឥណ្ឌា តំបន់នេះបានទទួលមរតកអក្សរនិងវាក្យសព្ទមកពីសំស្ក្រឹត រឿងនិទានវីរកថា ព្រះពុទ្ធសាសនា “យានតូច”(ហិនយាន) ផ្លូវរបៀងពីអ៊ីស្លាមចូលទៅក្នុងពិភពនិយាយភាសាម៉ាឡេ និងលក្ខណៈស្ថាបត្យកម្មជាច្រើន។ ចិនបានផ្សព្វផ្សាយឥទ្ធិពលរបស់ខ្លួនពីខាងជើងទៅខាងត្បូងតាមបណ្ដោយឆ្នេរសមុទ្រនិងផ្លូវទឹកដែលភ្ជាប់ទៅសមុទ្រ ដោយបានពាំនាំនូវប្រលោមលោកចិន និងសហគមន៍ជនភៀសខ្លួនជាច្រើនគួរឲ្យកត់សម្គាល់។ ចក្រភពសំខាន់ៗ និងរដ្ឋបុរាណនានា និងក្រោយមកទៀតសំណង់អាណានិគមបានបន្សល់ទុកនូវកេរដំណែលមួយដែលស្ថិតស្ថេររួមមានប្រាសាទអង្គរ Borobudur និង Bagan ទីក្រុងនានារដ្ឋថ្មីៗ (សហព័ន្ធម៉ាឡេយ៉ា និងសិង្ហបុរី) និងដាក់ស្ដែងគឺព្រំដែននាពេលបច្ចុប្បន្ន។

រដ្ឋនានាត្រូវបានបង្កើតនៅទីនេះតាំងពីដំណាក់កាលដំបូង ដោយកសាងរដ្ឋធានីរបស់ពួកគេនៅលើវាលទំនាបដីល្បាប់ធំៗ ដែលជាទីកន្លែងសំខាន់សម្រាប់ប្រជាជន និងផលិតកម្មស្រូវ។ តំបន់កណ្ដាលទាំងនេះ គឺនៅតែស្ថិតស្ថេរគួរឲ្យកត់សម្គាល់ (លើកលែងករណីមួយចំនួនដូចជា Pagan និងអង្គរ) ហើយនៅទូទាំងតំបន់ រដ្ឋនានាមានភាពរឹងមាំនិងមានការប្រមូលផ្តុំ។ ដោយសារតែប្រវត្តិសាស្ត្ររបស់ពួកគេ បណ្ដារដ្ឋអាស៊ីអាគ្នេយ៍មានការផ្សារភ្ជាប់ខ្លាំងទៅនឹងអធិបតេយ្យភាពជាតិរបស់ពួកគេហើយនេះជាសម្បត្តិជាតិមួយសម្រាប់គោលនយោបាយអភិវឌ្ឍរបស់ពួកគេ។

អាស៊ីអាគ្នេយ៍ត្រូវបានត្រួតត្រាដោយមហាអំណាចចក្រភពអឺរ៉ុប ចាប់តាំងពីការចូលកាន់កាប់យកទីក្រុងម៉ានីលពីសំណាក់អេស្ប៉ាញនៅឆ្នាំ១៥៧១ រហូតដល់ការដកថយពីម៉ាកាវពីសំណាក់ព័រទុយហ្គាល់នៅឆ្នាំ១៩៩៩។ ចក្រភពអឺរ៉ុបទាំងអស់ - ចក្រភពអង់គ្លេស បារាំង ហូឡង់ អេស្ប៉ាញ និងព័រទុយហ្គាល់ - បានរីកលូតលាស់ដោយសារមូលហេតុដូចៗគ្នា នោះគឺការកេងប្រវ័ញ្ចពាណិជ្ជកម្មលើធនធានធម្មជាតិនៅអាស៊ី ដោយចាប់ផ្ដើមជាមួយគ្រឿងទេស។ អាណានិគម ត្រូវបានដឹកនាំដោយក្រុមហ៊ុនឯកជន និង«រោងចក្រ» គ្រឿងទេសនានារបស់ពួកគេ។ បន្ទាប់មកនៅចុងសតវត្សរ៍ទី១៩ បណ្ដារដ្ឋអឺរ៉ុបបានបែងចែកអាស៊ីទៅក្នុងដែនឥទ្ធិពលរៀងៗខ្លួន និងចាប់ផ្ដើមគ្រប់គ្រងដោយផ្ទាល់។ មានតែសៀមទេដែលអាចរក្សាអព្យាក្រឹតភាពរបស់ខ្លួនដោយបានពីកិច្ចព្រមព្រៀងបារាំង-អង់គ្លេស (១៨៩៦)។ ជប៉ុនបានកសាងចក្រភពអាស៊ីមួយសម្រាប់ខ្លួនឯងនៅរវាងឆ្នាំ១៩៤២ ហើយការបរាជ័យរបស់ជប៉ុនក្នុងឆ្នាំ១៩៤៥ ជាការចាប់ផ្ដើមនៃដំណើរការដួលរលំនៃរបបអាណានិគមបន្តិចម្ដងៗ។

> **ចក្រភពសំខាន់ៗនិងរដ្ឋបុរាណនានា និងក្រោយមកទៀតសំណង់អាណានិគមបានបន្សល់ទុកនូវកេរដំណែលមួយដែលស្ថិតស្ថេរ។**

ផែនទីភូមិសាស្ត្រនយោបាយបច្ចុប្បន្ន គឺជាលទ្ធផលនៃដំណើរដ៏វែងនៃការអភិវឌ្ឍមុនសម័យអាណានិគមនិងក្នុងសម័យអាណានិគម។ ប្រជាជាតិនីមួយៗក្នុងតំបន់នេះមានទ្រង់ទ្រាយនិងស្ថានភាពដូចពេលបច្ចុប្បន្ននេះ ចាប់ពីចុងបញ្ចប់នៃយុគសម័យអាណានិគម (សិង្ហបុរី និងព្រុយណេ គឺជាកំពង់ផែនិងប៉ុស្តិ៍ជំនួញនៅលើច្រកសមុទ្រ និងជាផ្លូវសមុទ្រមួយដ៏សំខាន់)។ ប្រវត្តិសាស្ត្រដ៏យូរអង្វែងនេះប្រាកដជាត្រួសត្រាយផ្លូវដល់ការបង្កើតគោលនយោបាយការបរទេស មិនខុសពីការយល់ដឹងអំពីភូមិសាស្ត្រតំបន់នោះទេ។

> **បណ្ដារដ្ឋអាស៊ីអាគ្នេយ៍មានការផ្សារភ្ជាប់ខ្លាំងទៅនឹងអធិបតេយ្យភាពជាតិរបស់ពួកគេ ហើយនេះជាសម្បត្តិជាតិមួយសម្រាប់គោលនយោបាយអភិវឌ្ឍរបស់ពួកគេ។**

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដែលបកដោយវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិនៃកម្ពុជា (NIDIR)។ អ្នកអានអាចទាញយកអត្ថបទដើមជាភាសាអង់គ្លេសពីគេហទំព័រ៖ https://www.pic.org.kh ។

**ផែនទី ៦៖** ការធ្វើសមាហរណកម្មតំបន់អាស៊ាន(១៩៦៧-២០១៨)



## ៥.២ ការចូលជាសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន)

**១៩៦៧**: សេចក្តីថ្លែងការណ៍ទីក្រុងបាងកក (ព្រមព្រៀងដោយប្រទេសសមាជិកអាស៊ានដំបូងទាំងប្រាំ៖ ថៃ ហ្វីលីពីន ម៉ាឡេស៊ី ឥណ្ឌូណេស៊ី និងសិង្ហបុរីនៅពេលដែលសង្គ្រាមវៀតណាមកំពុងស្ថិតក្នុងសភាពក្តៅគគុក)

**១៩៦៧**: កិច្ចប្រជុំកំពូលអាស៊ានលើកទី១នៅបាលី

**១៩៧៧**: អង្គការអន្តរសភាអាស៊ាន (AIPO) ត្រូវបានបង្កើតឡើង

**១៩៧៨**: កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ាន-EEC (សហគមន៍សេដ្ឋកិច្ចអឺរ៉ុប) លើកទីមួយ នៅទីក្រុងព្រុចសែល

**១៩៨៤**: ព្រុយណេចូលជាសមាជិកអាស៊ាន

**១៩៩៤**: អាស៊ានបង្កើតវេទិកាតំបន់អាស៊ាន (ARF) ដែលផ្តោតលើភាពពឹងអាស្រ័យគ្នាទៅវិញទៅមកផ្នែកសន្តិសុខ នៅក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក។ ក្រៅពីរដ្ឋសមាជិកអាស៊ានដៃគូចូលរួមបច្ចុប្បន្នរួមមាន អូស្ត្រាលី កាណាដា ចិន សហភាពអឺរ៉ុប ឥណ្ឌា ជប៉ុន កូរ៉េខាងត្បូង កូរ៉េខាងជើង ម៉ុងហ្គោលី នូវែលសេឡង់ ប៉ាគីស្ថាន ប៉ាពួញូហ្គីណេ សហព័ន្ធ រុស្ស៊ី និងសហរដ្ឋអាម៉េរិក

**១៩៩៧**: កិច្ចប្រជុំអាស៊ានបូកបីលើកដំបូងចូលរួមដោយថ្នាក់ដឹកនាំនៃសមាជិកអាស៊ានទាំង ១០រូប និងសមភាគីដែលមកពីអាស៊ីបូព៌ា-ចិន ជប៉ុន និងកូរ៉េខាងត្បូង

**១៩៩៧**: កិច្ចប្រជុំកំពូលអាស៊ាន-ចិនលើកទី ១ កោះប្រជុំនៅប្រទេសម៉ាឡេស៊ី

**១៩៩៥**: វៀតណាម ចូលជាសមាជិកអាស៊ាន

**១៩៩៧**: សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និង មីយ៉ាន់ម៉ា ចូលជាសមាជិកអាស៊ាន

**១៩៩៩**: កម្ពុជា ចូលជាសមាជិកអាស៊ាន

**២០០៣**: សហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC)

**២០០៥**: កិច្ចប្រជុំអាស៊ានបូកប្រាំមួយលើកដំបូង ឬហៅម្យ៉ាងទៀតថា កិច្ចប្រជុំកំពូលអាស៊ីបូព៌ា រួមមានប្រទេសអាស៊ាន បូកចិន ជប៉ុន កូរ៉េខាងត្បូង ឥណ្ឌា អូស្ត្រាលី និងនូវែលសេឡង់

**២០០៥**: AIPO ចាប់ផ្តើមការផ្លាស់ប្តូរ ទៅជាអន្តរសភាអាស៊ាន(AIPA)

**២០០៧**: អាស៊ានចុះហត្ថលេខាលើធម្មនុញ្ញមួយ ដែលផ្តល់ឲ្យរដ្ឋជាសមាជិកទាំង១០ នូវអត្តសញ្ញាណច្បាប់ ដែលនេះជាជំហានដំបូងឆ្ពោះទៅរកគោលដៅនៃការបង្កើតតំបន់ពាណិជ្ជកម្មសេរីនៅឆ្នាំ២០១៥

**២០១៥**: សហគមន៍អាស៊ានត្រូវបានដាក់ឲ្យដំណើរការជាអង្គភាពមួយដែលឈរលើសសរស្តម្ភ៣៖ សហគមន៍សន្តិសុខ-នយោបាយ (APSC) សហគមន៍សេដ្ឋកិច្ច (AEC) និងសហគមន៍សង្គម-វប្បធម៌ (ASCC) [A]

**២០១៥**: ផែនការលម្អិតសម្រាប់សហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០២៥ ៖ វិធានការណ៍ណែនាំសម្រាប់ដំណាក់កាលបន្ទាប់នៃសមាហរណកម្មសេដ្ឋកិច្ចអាស៊ានពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២៥

**២០១៦**: ថ្នាក់ដឹកនាំអាស៊ានបានអនុម័តផែនការមេស្តីពីការតភ្ជាប់អាស៊ាន (MPAC) ២០២៥ ។

អាស៊ាន ដែលមានទីស្នាក់ការកណ្តាលនៅទីក្រុងហ្សាការតា ធ្វើប្រតិបត្តិការដោយផ្អែកលើគោលការណ៍កុងសង់ស៊ីសក្នុងចំណោមរដ្ឋជាសមាជិករបស់ខ្លួន ដោយក្នុងនោះតួនាទីជាប្រធានអាស៊ានត្រូវវិលជុំវៀងរាល់មួយឆ្នាំម្តង។ បន្ទាប់ពីប្រទេសសិង្ហបុរីនៅឆ្នាំ២០១៨ ប្រទេសថៃធ្វើជាប្រធាននៅឆ្នាំ២០១៩ ហើយបន្ទាប់មកគឺប្រទេសវៀតណាមនៅឆ្នាំ២០២០។

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដែលបកដោយវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិនៃកម្ពុជា (NIDIR)។ អ្នកអានអាចទាញយកអត្ថបទដើមជាភាសាអង់គ្លេសពីគេហទំព័រ៖ https://www.pic.org.kh ។

## ៥.៣ ទំនាក់ទំនងការបរទេសនៃបណ្តារដ្ឋសមាជិកអាស៊ាន

ផែនទីនយោបាយបច្ចុប្បន្ន គឺបានមកពីការវិវត្តន៍ដ៏យូរអង្វែងនៃសម័យមុនអាណានិគមនិងសម័យអាណានិគម។ បណ្តារដ្ឋប្រជាជាតិនីមួយៗ ដែលមានរូបសណ្ឋានដូចបច្ចុប្បន្ននេះ គឺត្រូវបានរៀបចំឡើងនៅក្នុងសម័យអាណានិគម។ រយៈពេលដ៏វែងនៃការធ្វើអាណានិគមនេះ នៅតែជាគ្រឹះនៃទំនាក់ទំនងការបរទេស។ កត្តាថ្មីៗ និងទូទៅបំផុតនោះច្បាស់ណាស់ គឺការលេចឡើងរបស់ប្រទេសចិនទៅជាមហាអំណាចមួយដ៏រឹងមាំក្នុងតំបន់ដែលកំពុងតែធ្វើឲ្យមានសំណួរពីភាពស្អិតរមួតរបស់អាស៊ាន ។

### ព្រុយណេ



ព្រុយណេ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាយូរមកហើយជាមួយម៉ាឡេស៊ី សិង្ហបុរី សហរដ្ឋអាម៉េរិក ចក្រភពអង់គ្លេស និងជាមួយប្រទេសអារ៉ាប៊ីសាអូឌីត។ ទំនាក់ទំនងជាមួយប្រទេសចិន គឺមានសារៈសំខាន់បំផុត (ប្រទេសចិនគឺជា វិនិយោគិនចម្បងមួយនៅប្រទេសព្រុយណេ ជាម្ចាស់ជំនួយទី២ បន្ទាប់ពីប្រទេសសិង្ហបុរី និងជាដៃគូកិច្ចសហប្រតិបត្តិការក្នុងវិស័យការពារជាតិ)។ ទស្សនរបស់ទីក្រុងប៉េកាំង ប្រទេសព្រុយណេមានទីតាំងយុទ្ធសាស្ត្រនៅតាមបណ្តោយផ្លូវសមុទ្រចន្លោះរវាងសមុទ្រចិនខាងត្បូង និងច្រកសមុទ្រ Malayan (ហើយប្រទេសចិនបានចូលរួមក្នុងការផ្តត់ផ្គង់កំពង់ផែ និងគ្រឿងបរិក្ខារប្រើប្រាស់ដល់កងទ័ពជើងទឹក)។ ស្តេចស៊ុលតង់ Hassanal Bolkiah បានបំពេញទស្សនកិច្ចផ្លូវការលើកទី៥ នៅប្រទេសចិនក្នុងឆ្នាំ២០១៧។ នៅខែវិច្ឆិកា ឆ្នាំ២០១៨ ក្នុងដំណើរទស្សនកិច្ចរបស់ប្រធានាធិបតី Xi Jinping ទៅកាន់ប្រទេសព្រុយណេ ប្រទេសទាំងពីរបានឯកភាពគ្នាពង្រឹងបន្ថែមលើទំនាក់ទំនងរបស់ពួកគេឲ្យទៅជា «ដៃគូសហប្រតិបត្តិការយុទ្ធសាស្ត្រ» ។

## កម្ពុជា



គោលបំណងសំខាន់មួយនៃគោលនយោបាយការបរទេសរបស់ប្រទេសកម្ពុជា គឺការពារឯករាជ្យនិងអធិបតេយ្យភាពជាតិ។ ដើម្បីសម្រេចគោលដៅនេះ កម្ពុជារៀបចំតម្រូវគោលនយោបាយការបរទេសរបស់ខ្លួន តាមវិធីដែលឆ្លើយតបយ៉ាងមានប្រសិទ្ធិភាពទៅនឹងការកើនឡើងនូវភាពស្មុគស្មាញ និងមិនអាចទាយទុកជាមុននៃភូមិសាស្ត្រនយោបាយក្នុងតំបន់ ដោយប្រើប្រាស់យុទ្ធសាស្ត្រចាក់ខ្សែ និងពិពិធកម្ម។ ការកសាងភាពខ្លាំងផ្នែកខាងក្នុង និងបង្កើតមិត្តអន្តរជាតិ បានធ្វើឲ្យព្រះរាជាណាចក្រកម្ពុជាទទួលបាននូវសន្តិភាពដ៏យូរអង្វែងនិងការអភិវឌ្ឍសង្គមសេដ្ឋកិច្ចប្រកបដោយចីរភាព។ ប្រទេសកម្ពុជាបានបង្កើតទំនាក់ទំនងការទូតជាមួយប្រទេសចំនួន ១៧២ នៅជុំវិញពិភពលោក ក្នុងនោះបានបង្កើតកិច្ចព្រមព្រៀងភាពជាដៃគូយុទ្ធសាស្ត្រចំនួន ២ គឺជាមួយប្រទេសចិននៅឆ្នាំ២០១០ និងប្រទេសជប៉ុននៅឆ្នាំ២០១៣។ ប្រទេសកម្ពុជាក៏ចូលរួមយ៉ាងសកម្មផងដែរនៅក្នុងស្ថាប័នពហុភាគី ដូចជា អាស៊ាន និងអង្គការសហប្រជាជាតិ។

ជាប្រទេសដែលមានសេដ្ឋកិច្ចតូចនិងបើកចំហ កម្ពុជាគាំទ្រជានិច្ចនូវប្រព័ន្ធអន្តរជាតិដែលបើកចំហ បរិយាប័ន្ន និងផ្អែកលើច្បាប់ ដោយរក្សាការប្រុងប្រយ័ត្នខ្ពស់ចំពោះហានិភ័យដែលកើតចេញពីការប្រកួតប្រជែងភូមិសាស្ត្រនយោបាយរវាងប្រទេសមហាអំណាច។ ដើម្បីជៀសផុតពីការជាប់អន្ទាក់នៅក្នុងការប្រកួតប្រជែងដែលកំពុងកើនឡើងនេះ ព្រះរាជាណាចក្រកម្ពុជាប្រកាន់ខ្ជាប់យ៉ាងម៉ឺងម៉ាត់នូវគោលការណ៍អព្យាក្រឹតជាអចិន្ត្រៃយ៍។ ទោះជាយ៉ាងណាក៏ដោយអព្យាក្រឹតភាពនេះមិនអាចត្រូវបានបកស្រាយថា ជាគោលនយោបាយអសកម្មនោះទេ។ ប្រទេសកម្ពុជាខិតខំចូលរួមចំណែកដល់ការថែរក្សាសន្តិភាពពិភពលោក។ នៅក្រោមសសរស្តម្ភនៃការទូតសន្តិភាព ប្រទេសកម្ពុជាបានបញ្ជូនកងទ័ពរបស់ខ្លួនយ៉ាងសកម្ម ដើម្បីចូលរួមនៅក្នុងបេសកកម្មថែរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិនៅទូទាំងពិភពលោក។ ចាប់តាំងពីឆ្នាំ២០០៦មក កងរក្សាសន្តិភាពកម្ពុជាចំនួនប្រមាណ ៦000 នាក់ ត្រូវបានដាក់ពង្រាយនៅក្នុងប្រទេសចំនួន ៨ នៅទ្វីបអាហ្វ្រិក និងមជ្ឈឹមបូព៌ា ក្រោមឆ័ត្រអង្គការសហប្រជាជាតិ។ ម្យ៉ាងទៀត ប្រទេសកម្ពុជាក៏ជាអ្នកផ្តួចផ្តើមដ៏សំខាន់នៃការបង្កើតមជ្ឈមណ្ឌលតំបន់អាស៊ានសម្រាប់សកម្មភាពមីន (ARMAC) ផងដែរ។

## ឥណ្ឌូនេស៊ី



ប្រទេសឥណ្ឌូនេស៊ីតំណាងឲ្យជាងមួយភាគបីនៃប្រជាជនអាស៊ាន និង៤០% នៃផលិតផលក្នុងស្រុកសរុបរបស់អាស៊ាន។ អគ្គលេខាធិការដ្ឋានអាស៊ានមានទីតាំងនៅទីក្រុងហ្សាការតា ដែលអាទិភាពដំបូងនៅក្នុងគោលនយោបាយការបរទេស គឺការរក្សានូវឯកភាព និងមជ្ឈភាពរបស់អាស៊ាន។ ដូចគ្នាទៅនឹងសមាជិកអាស៊ានដទៃទៀតដែរ ប្រទេសឥណ្ឌូនេស៊ីក៏បានកំណត់កម្រិតនៃកិច្ចសហប្រតិបត្តិការជាមួយប្រទេសចិន ដែលខ្លួនគិតថា ជាកម្រិតមួយសមល្មម (ដោយហេតុថា ប្រទេសចិនគឺជាដៃគូសេដ្ឋកិច្ចដ៏សំខាន់របស់ខ្លួន) និងស្របជាមួយកម្មវិធីផ្លូវមួយខ្សែក្រវ៉ាត់មួយរបស់ប្រទេសចិន ដែលបានបើកសម្ពោធដោយប្រធានាធិបតី Xi នៅហ្សាការតា (ឆ្នាំ២០១៣)។ ប្រធានាធិបតី Joko Widodo បានបង្ហាញនូវការប្តេជ្ញាចិត្តក្នុងការធ្វើឲ្យប្រទេសឥណ្ឌូនេស៊ីក្លាយជា "មជ្ឈមណ្ឌលជើងទឹកដ៏មានឥទ្ធិពលរបស់ពិភពលោក (Global Maritime Fulcrum)» (២០១៧) ដើម្បីធានានូវការរួបរួមនៅក្នុងប្រទេសប្រជុំកោះមួយនេះ (wasasan nusantara ឬ ចក្ខុវិស័យប្រជុំកោះ) តែដើរស្របគ្នាទៅនឹងយុទ្ធសាស្ត្រការពារជាតិ និងកិច្ចសហប្រតិបត្តិការជាមួយប្រទេសជិតខាង។ ឥណ្ឌូណេស៊ីកំពុងព្យាយាមធ្វើពិពិធកម្មទំនាក់ទំនងការបរទេសរបស់ខ្លួនជាមួយប្រទេសឥណ្ឌា (តាមរយៈសមាគមបណ្តាប្រទេសនៅបណ្តោយមហាសមុទ្រឥណ្ឌា [Indian Ocean Rim Association, IORA])។ ប្រទេសឥណ្ឌូនេស៊ីក៏បានចូលរួមយ៉ាងសកម្មជាមួយអូស្ត្រាលី សិង្ហបុរី និងសហរដ្ឋអាម៉េរិកក្នុងកិច្ចសហប្រតិបត្តិការប្រឆាំងភេរវកម្ម។ ប្រទេសសិង្ហបុរី និងឥណ្ឌូនេស៊ីក៏បង្ហាញផងដែរនូវចំណាប់អារម្មណ៍ដូចគ្នាចំពោះសន្តិសុខតាមច្រកសមុទ្រ។ ប្រទេសជប៉ុន គឺជាអ្នកផ្តល់ជំនួយចម្បង ហើយកំពុងជំរុញឲ្យមានការធ្វើឲ្យប្រសើរឡើងនូវភាពជាដៃគូលើបញ្ហានៃការតភ្ជាប់រវាងមហាសមុទ្រឥណ្ឌានិងមហាសមុទ្រប៉ាស៊ីហ្វិក។

## សាធារណរដ្ឋប្រជាមានិតឡាវ



អស់រយៈពេលជាច្រើនទសវត្សរ៍បន្ទាប់ពីការដួលរលំនៃសហភាពសូវៀតសាធារណរដ្ឋប្រជាមានិតឡាវបានផ្លាស់ប្តូរឆ្ពោះទៅរកទំនាក់ទំនងកាន់តែរឹងមាំជាមួយបណ្តាប្រទេសនៅភាគខាងត្បូង និងនៅតំបន់ឆ្ងាយៗដូចជាជប៉ុន និងអូស្ត្រាលី។ ក្នុងនាមជាប្រទេសមួយនៅក្នុងឥណ្ឌូចិន សាធារណរដ្ឋប្រជាមានិតឡាវបានរក្សាមិត្តភាពជិតស្និទ្ធជាមួយវៀតណាម (ជាឧទាហរណ៍ សន្ធិសញ្ញាពិសេសស្តីពីមិត្តភាពនិងកិច្ចសហប្រតិបត្តិការដែលបានចុះហត្ថលេខាក្នុងឆ្នាំ១៩៩៧ហើយប្រទេសវៀតណាមគឺជាវិនិយោគិនធំទី២ នៅក្នុងប្រទេសនេះ និងទទួលបន្ទុកផងដែរក្នុងការបណ្តុះបណ្តាលកម្មាភិបាលគណបក្ស) និងជាមួយប្រទេសកម្ពុជា ខណៈដែលប្រទេសខ្លួនក៏ជាទីតាំងច្រករបៀងភ្ជាប់ពីយូណានទៅប្រទេសថៃ ដែលប្រទេសថៃបច្ចុប្បន្នជាដៃគូសេដ្ឋកិច្ចដ៏សំខាន់(អគ្គិសនីនិងទំនិញ)។ ថ្មីៗនេះ សាធារណរដ្ឋប្រជាមានិតឡាវបានពង្រឹងទំនាក់ទំនងសេដ្ឋកិច្ចមិនត្រឹមតែជាមួយប្រទេសថៃប៉ុណ្ណោះទេ ថែមទាំងជាមួយប្រទេសចិនផងដែរ ហើយការវិនិយោគនៃប្រទេសទាំងពីរនេះបានកើនឡើងយ៉ាងខ្លាំង នាប៉ុន្មានឆ្នាំចុងក្រោយនេះ។ យុទ្ធសាស្ត្របច្ចុប្បន្ន គឺការបង្កើនប្រសិទ្ធភាព និងធ្វើឲ្យមានតុល្យភាពទំនាក់ទំនងជាមួយដៃគូក្នុង និងក្រៅអាស៊ាន រួមទាំងប្រទេសចិនផងដែរ។ សាធារណរដ្ឋប្រជាមានិតឡាវបានធ្វើជាប្រធានអាស៊ាននៅឆ្នាំ២០១៦ ។

## ម៉ាឡេស៊ី



ប្រទេសម៉ាឡេស៊ីក៏កំពុងស្វែងរកតុល្យភាពនៅក្នុងទំនាក់ទំនងការបរទេសរបស់ខ្លួនផងដែរ។ បន្ទាប់ពីរយៈពេលជាច្រើនឆ្នាំនៃ «ទំនាក់ទំនងដ៏មានតម្លៃ» រវាងអតីតនាយករដ្ឋមន្ត្រី Najib Razak និងប្រទេសចិន រដ្ឋាភិបាលជាប់ឆ្នោតថ្មីដឹកនាំដោយលោក Mahatir bin Mohamad (ដែលបានក្លាយជានាយករដ្ឋមន្ត្រីម្តងទៀតចាប់តាំងពីឆ្នាំ២០១៨) បានធ្វើការពិនិត្យស៊ីជម្រៅលើការប្តេជ្ញាទ្វេភាគីមុនៗឡើងវិញ ដើម្បីកាត់បន្ថយការពឹងផ្អែករបស់ប្រទេសលើបំណុលពីដៃគូធំតែមួយ។ ភាពជាដៃគូសកលត្រូវបានបង្កើតឡើងជាមួយសហរដ្ឋអាមេរិក ហើយជប៉ុននៅតែជាវិនិយោគិនសំខាន់។ ក្នុងឱកាសធ្វើជាប្រធានអាស៊ានក្នុងឆ្នាំ២០១៥ ទីក្រុង Kuala Lumpur បានដាក់ចេញនូវ «ទស្សនវិស័យក្រោយឆ្នាំ២០១៥» ដែលជាផែនទីបង្ហាញផ្លូវរបស់សមាគមនាទសវត្សបន្ទាប់។ ប្រទេសម៉ាឡេស៊ីក៏ជាសមាជិកនៃចលនាមិនចូលបក្សសម្ព័ន្ធ និងជាសមាជិកនៃអង្គការសន្និសីទអ៊ីស្លាម។

ជំពូកទី
០៥

បរិបទអាស៊ាន
ការចូលជាសមាជិកនៃសមាគមប្រជាជាតិ អាស៊ីអាគ្នេយ៍(អាស៊ាន)

## មីយ៉ាន់ម៉ា



មីយ៉ាន់ម៉ាដែលបានចូលជាសមាជិកអាស៊ានក្នុងឆ្នាំ១៩៩៧ និងជាប្រធានអាស៊ាននៅឆ្នាំ២០១៤ បានបង្ហាញពី ភាពជម្មតានៃស្ថានភាពរបស់ខ្លួននៅក្នុងអង្គការតំបន់មួយនេះ។ ប្រទេសចិន គឺជាដៃគូសេដ្ឋកិច្ចដ៏ធំមួយជាមួយនឹងការវិនិយោគដ៏ច្រើន (២,៨ ប៊ីលានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៦-១៧) លើផ្នែកថាមពល និងហេដ្ឋារចនាសម្ព័ន្ធ។ ចាប់តាំងពីឆ្នាំ២០១៣ មក បំពង់បង្ហូរប្រេងនិងឧស្ម័នចំនួនពីរបានភ្ជាប់មហាសមុទ្រឥណ្ឌាទៅផ្នែកកណ្តាលនៃប្រទេសចិន។ មីយ៉ាន់ម៉ាក៏មានទំនាក់ទំនងជិតស្និទ្ធជាមួយឥណ្ឌាដែរ ដែលមានទំហំពាណិជ្ជកម្មគិតជាទឹកប្រាក់ជាង ២,១ ប៊ីលានដុល្លារអាមេរិក។ នាយករដ្ឋមន្ត្រីឥណ្ឌាបានបញ្ជាក់ជាថ្មីនូវការគាំទ្រចំពោះការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ Arakan ក្នុងពិធីអបអរសាទរនាកិច្ចប្រជុំកំពូលនៃចំណងមិត្តភាព ២៥ឆ្នាំ រវាងអាស៊ាននិងឥណ្ឌា (ញូដេលី, ២៥/០១/២០១៨)។ ប្រទេសជប៉ុនកំពុងពង្រឹងវត្តមានរបស់ខ្លួនជាតួអង្គសំខាន់ក្នុងជំនួយអភិវឌ្ឍន៍ (លុបចោល ៦០ភាគរយនៃបំណុលក្នុងឆ្នាំ២០១៣ ដោយផ្តល់ប្រាក់កម្ចី ៥០០លានដុល្លារអាមេរិកជារៀងរាល់ឆ្នាំ បូកជាមួយនឹង ១ ប៊ីលានដុល្លារអាមេរិក ដែលបានប្រកាសដោយ Shinzo Abe ក្នុងឆ្នាំ២០១៧ ដើម្បីគាំទ្រសេដ្ឋកិច្ចជនបទ)។ នៅឆ្នាំ២០១៧ កិច្ចព្រមព្រៀងមួយត្រូវបានចុះហត្ថលេខាជាមួយបង់ក្លាដែស សម្រាប់ការវិលត្រឡប់របស់ជនភៀសខ្លួនដោយសុវត្ថិភាព (ជនជាតិភាគតិច Rohingya នៅរដ្ឋ Rakhine)។ មីយ៉ាន់ម៉ា គឺជាប្រទេសធំទី២ដែលទទួលជំនួយពីសហភាពអឺរ៉ុបនៅក្នុងតំបន់អាស៊ី (៦៥៦ លានដុល្លារអាមេរិកសម្រាប់ឆ្នាំ២០១៦-២០២០)។

## ហ្វីលីពីន



ប្រទេសហ្វីលីពីនបានធ្វើជាប្រធានអាស៊ានក្នុងឆ្នាំ២០១៧ សម្រាប់ខួបលើកទី៥០ ហើយប្រធានាធិបតីរបស់ខ្លួនបានធ្វើដំណើរទស្សនកិច្ចទៅកាន់ដៃគូទាំង៩ ដើម្បីឈានដល់កិច្ចព្រមព្រៀងគាំទ្រកិច្ចសហប្រតិបត្តិការពាក់ព័ន្ធនឹងបញ្ហាដែនសមុទ្រ (ការល្បាតរួមគ្នាជាមួយប្រទេសម៉ាឡេស៊ី និងឥណ្ឌូនេស៊ីនៅសមុទ្រ Sulu និងសមុទ្រ Celebes) និងដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើភេរវកម្ម និងការជួញដូរគ្រឿងញៀន។ នៅឆ្នាំ២០១៧ អាស៊ាន និងចិនបានទទួលយកក្របខ័ណ្ឌទូទៅនៃសេចក្ដីថ្លែងការណ៍ស្ដីពី ការប្រតិបត្តិរបស់បណ្ដាភាគីនៅសមុទ្រចិនខាងត្បូង(២០០២)។ ទស្សនៈផ្សេងគ្នាអំពីដែនដីបានបន្ថយកម្រិតវិសាលភាពនៃកិច្ចសហប្រតិបត្តិការ និងការវិនិយោគរវាងទីក្រុងម៉ានីល និងទីក្រុងប៉េកាំង។ សហរដ្ឋអាម៉េរិកដែលមានចំនួនសហគមន៍ជនបរទេសជនជាតិហ្វីលីពីនច្រើនបំផុតបានតាំងនៅ (ជាង ៤លាននាក់) ធ្លាប់ជាដៃគូដំបូងគេបង្អស់ក្នុងវិស័យការពារជាតិ ដោយផ្អែកលើកិច្ចព្រមព្រៀងមួយចំនួន។ ជប៉ុនគឺជាប្រទេសតែមួយគត់ដែលមានភាពជាដៃគូយុទ្ធសាស្ត្រជាមួយហ្វីលីពីន និងជាដៃគូសេដ្ឋកិច្ចធំទី២ និងជាអ្នកផ្ដត់ផ្គង់ជំនួយទីមួយ។

## សិង្ហបុរី



ក្នុងឱកាសធ្វើជាប្រធានអាស៊ានក្នុងឆ្នាំ២០១៨ ប្រទេសសិង្ហបុរីបានអភិវឌ្ឍបន្ទាត់សកម្មភាពពីរ៖ នវានុវត្តន៍ (ជាពិសេសផ្នែកហិរញ្ញវត្ថុ) និងភាពធន់ (ដើម្បីប្រឈមនឹងការគំរាមកំហែងឆ្លងប្រទេស)។ ប្រទេសសិង្ហបុរីក៏ជាអ្នកសម្របសម្រួលទំនាក់ទំនងរវាងអឺរ៉ុប-អាស៊ាន សម្រាប់ឆ្នាំ២០១៨-២០២០។ កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសនៃសហភាពអឺរ៉ុប-អាស៊ានលើកទី២២ បានធ្វើឡើងនៅទីក្រុងព្រុចសែល នាថ្ងៃទី២១ ខែមករា ២០១៩ ហើយកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយសហភាពអឺរ៉ុបត្រូវបានចុះហត្ថលេខានៅឆ្នាំ២០១៩ (សហភាពអឺរ៉ុបមានក្រុមហ៊ុនចំនួន ១០,០០០ នៅប្រទេសសិង្ហបុរី)។

រដ្ឋនេះមានភាពសកម្មនៅក្នុងវិស័យសន្តិសុខ និងក្នុងការទប់ស្កាត់ជម្លោះ៖ សិង្ហបុរី បានបង្កើតវេទិកាតំបន់អាស៊ានក្នុងឆ្នាំ១៩៩៤ ហើយជារៀងរាល់ឆ្នាំ សិង្ហបុរីបានធ្វើជាម្ចាស់ផ្ទះនៃកិច្ចសន្ទនា Shangri-La ដែលជាវេទិកាសំខាន់សម្រាប់សន្តិសុខអាស៊ី។ ទោះបីជាមានទំហំតូច សិង្ហបុរីតែងតែមានទំនោរធ្វើឲ្យមានតុល្យភាពទំនាក់ទំនងរវាងទីក្រុងប៉េកាំងនិងវ៉ាស៊ីនតោន និងរវាងប្រទេសម៉ាឡេស៊ីនិងឥណ្ឌូនេស៊ី។ ដូច្នេះសិង្ហបុរីបានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធជាមួយថាមវន្តនិយម (dynamism) របស់តំបន់។ ទស្សនៈអំពី «ប្រទេសតូច» បានជំរុញឲ្យមានការជជែកវែកញែកយ៉ាងខ្លាំងនៅសិង្ហបុរី រវាងអ្នកជំនាញនិងអ្នកការទូតអំពី អនាគតនៃប្រទេសនេះ ពីព្រោះយុគសម័យលីក្វាន់យូដែលជាស្ថាបនិកប្រទេស និងអ្នកជំរុញទឹកចិត្តដែលនៅពីក្រោយភាពជោគជ័យបច្ចុប្បន្ននេះ កំពុងតែសាបរលាប។

## ថៃ



ប្រទេសថៃ គឺជាស្ថាបនិកអាស៊ាន ដែលត្រូវបានបង្កើតឡើងនៅទីក្រុងបាងកកក្នុងឆ្នាំ ១៩៦៧ នៅក្នុងបរិបទនៃសង្គ្រាមវៀតណាម។ ថៃជាប្រទេសតែមួយគត់ដែលអាចរក្សាបាននូវឯករាជ្យភាពជាផ្លូវការនៅក្នុងសម័យអាណានិគម។ ប្រទេសថៃ គឺជាអ្នកចូលរួមយ៉ាងសកម្មនៅក្នុងអង្គការអន្តរជាតិ និងអង្គការតំបន់ និងថៃរក្សាបាននូវទំនាក់ទំនងសន្តិសុខយ៉ាងជិតស្និទ្ធ និងយូរអង្វែងជាមួយសហរដ្ឋអាមេរិក (សមយុទ្ធយោធា Cobra Gold ធ្វើឡើងជារៀងរាល់ឆ្នាំនៅប្រទេសថៃ ជាមួយសិង្ហបុរី ជប៉ុន ឥណ្ឌា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី និងកូរ៉េខាងត្បូង)។ អស្ថិរភាពនយោបាយផ្ទៃក្នុងមិនមែនជាកត្តាកំណត់ក្នុងការបន្តគោលនយោបាយការបរទេសថៃទេ។ ក្រុមប្រឹក្សាជាតិដើម្បីសន្តិភាពនិងសណ្តាប់ធ្នាប់(NCOP) ដឹកនាំដោយប្រមុខកងយោធពលខេមរភូមិន្ទ លោក Prayuth Chan-ocha បានធ្វើទស្សនកិច្ចផ្លូវការជាច្រើនលើក ដើម្បីបញ្ចុះបញ្ចូលវិនិយោគិនបរទេសឲ្យត្រលប់មកប្រទេសថៃវិញ (សហរដ្ឋអាមេរិក ចិន និងជប៉ុន) និងដើម្បីផ្តល់ទំនុកចិត្តដល់បណ្តាប្រទេសអាស៊ាន (មីយ៉ាន់ម៉ា និងហ្វីលីពីន)។ ការនាំចេញមានចំនួនស្មើនឹង ២/៣ នៃផលិតផលក្នុងស្រុកសរុប ហើយវិស័យទេសចរណ៍មានចំនួនស្មើនឹង ១២ ភាគរយ។ ប្រទេសចិនបានអញ្ជើញប្រទេសថៃចូលរួមកិច្ចប្រជុំកំពូលប្រេស៊ីល-រុស្ស៊ី-ឥណ្ឌា-ចិន(BRIC) នៅទីក្រុង Xiamen ក្នុងឆ្នាំ២០១៧ ព្រោះចិនចង់បានផលប្រយោជន៍ទីតាំងភូមិសាស្ត្ររបស់ប្រទេសថៃ (ឧ.ទីតាំងកណ្តាលជាមជ្ឈមណ្ឌលស្នូលអាស៊ីអាគ្នេយ៍) សម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធពីគុនមីងទៅបាងកក។ កិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងយោធាជាមួយចិនកំពុងមានការកើនឡើង។

## វៀតណាម



គោលនយោបាយការបរទេសរបស់វៀតណាម គឺដើម្បីជំរុញការអភិវឌ្ឍរបស់ប្រទេសដោយរក្សាឲ្យបាននូវសន្តិសុខ និងសំឡេងរបស់ខ្លួននៅក្នុងកិច្ចការពិភពលោក។ ទីក្រុងហាណូយ បានចូលរួមក្នុងយុទ្ធសាស្ត្រនៃសមាហរណកម្មអន្តរជាតិ ដោយបានសម្របទៅតាមគោលនយោបាយបើកចំហរបស់ខ្លួន (Doi Moi) តាំងពីឆ្នាំ១៩៩១៖ នេះរួមបញ្ចូលទាំងការផ្សះផ្សាជាមួយប្រទេសជិតខាង និងជាមួយសហរដ្ឋអាមេរិក រួមទាំងការខិតជិតជាមួយនឹងអង្គការក្នុងតំបន់និងអន្តរជាតិ (អាស៊ានឆ្នាំ១៩៩៥) កិច្ចប្រជុំអាស៊ី-អឺរ៉ុប (ASEM) (១៩៩៦) អង្គការអន្តរជាតិ "ហ្វ្រង់កូហ្វូនី" (ក្នុងកិច្ចប្រជុំកំពូលទីក្រុងហាណូយឆ្នាំ១៩៩៧) ចូលជាសមាជិក APEC (១៩៩៨) និងអង្គការពាណិជ្ជកម្មពិភពលោក(WTO)(២០០៧) និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាច្រើន។ ការបង្កើតបាននូវកិច្ចព្រមព្រៀងនៃភាពជាដៃគូយុទ្ធសាស្ត្រសំខាន់ៗចំនួន១២ គឺជាធាតុផ្សំនៃរចនាសម្ព័ន្ធគោលនយោបាយការបរទេសរបស់វៀតណាម។ នៅឆ្នាំ២០០៨-២០០៩ ប្រទេសវៀតណាមបានក្លាយជាសមាជិកមិនអចិន្ត្រៃយ៍របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ (UNSC) និងជាផ្នែកមួយនៃក្រុមប្រទេស G20 ក្នុងនាមជាប្រធានអាស៊ាន។ វៀតណាមបានរៀបចំកិច្ចប្រជុំកំពូល APEC លើកទី២៨ នៅ Danang ក្នុងឆ្នាំ២០១៧ (Danang មានមូលដ្ឋានយោធាអាមេរិក និងស្ថិតនៅសមរភូមិជួរមុខក្នុងអំឡុងសង្គ្រាមវៀតណាម) ដែលបណ្តាមេដឹកនាំជាតិ លោកដូណាល់ត្រាំ លោកវ្លាឌីមៀពូទីន លោកស៊ីជីនពីង និងលោក Justin Trudeau បានមានវត្តមាន។ ដៃគូពាណិជ្ជកម្មសំខាន់របស់វៀតណាម រួមមាន ចិន អាមេរិក និងសហភាពអឺរ៉ុប។ បញ្ហាការប្រែប្រួលអាកាសធាតុ គឺជាធាតុសំខាន់នៃកិច្ចសហប្រតិបត្តិការអឺរ៉ុប-វៀតណាម។ គោលបំណងចម្បងរបស់វៀតណាម គឺរក្សាតុល្យភាពរវាងដៃគូសេដ្ឋកិច្ចសំខាន់ទាំងពីរ សហរដ្ឋអាមេរិក និងចិន ដោយបន្តភាពប្រក្រតីជាមួយវ៉ាស៊ីនតោន និងយកឈ្នះក្នុងការគ្រប់គ្រងការប៉ះទង្គិចនានាជាមួយចិន។

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដែលបកដោយវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិនៃកម្ពុជា (NIDIR)។ អ្នកអានអាចទាញយកអត្ថបទដើមជាភាសាអង់គ្លេសពីគេហទំព័រ៖ https://www.pic.org.kh ។

# ៥.៤ អាស៊ាននៅក្នុងបរិបទអន្តរជាតិ

> “ អាស៊ាន គឺជាក្រុមតំបន់ចំណាស់ជាងគេបំផុតនៃពិភពលោកខាងត្បូង។ ភាពយូរអង្វែងដែលជៀសផុតពីការប្រកួតប្រជែងនានាអាចពន្យល់បានថា មកពីសមត្ថភាពរបស់អាស៊ានដែលចេះ «រស់នៅជាមួយគ្នាប្រកបដោយសុខដុមរមនា»។ ”

អាស៊ីអាគ្នេយ៍ដែលជាតំបន់មួយស្ថិតនៅផ្លូវប្រសព្វ និងសម្បូរទៅដោយវត្ថុធាតុដើម បានក្លាយជាទីតាំងដ៏សំខាន់មួយនៃសាកលភាវូបនីយកម្មអស់រយៈពេលជាច្រើនសតវត្សរ៍មកហើយ ការធ្វើសមាហរណកម្មរបស់អាស៊ានទៅក្នុងកិច្ចការពិភពលោក ជាសំខាន់គឺផ្តោតទៅលើសេដ្ឋកិច្ច។ ទោះជាយ៉ាងណាក៏ដោយ តំបន់នេះត្រូវបានបំផ្លាញដោយជម្លោះដែលគេហៅថា សង្គ្រាមត្រជាក់។ តំបន់នេះបានមើលឃើញនូវការអនុវត្តប្រកបដោយសោកនាដកម្ម នៃទ្រឹស្តីភូមិសាស្ត្រនយោបាយរបស់សហរដ្ឋអាម៉េរិកអំពី«rimland» ដែលចែងថា ដែនដីដែលព័ទ្ធជុំវិញ «heartland»-សូវៀត គ្រប់គ្រងផ្ទៃខាងក្នុងនៃទ្វីប- ត្រូវគ្រប់គ្រងជាចាំបាច់ដើម្បីការពារការរីករាលដាលនៃឥទ្ធិពលសូវៀត និងចលនាកុម្មុយនីស្តដែលទទួលបានការគាំទ្រពីសូវៀត។ ក្នុងបរិបទប្រវត្តិសាស្ត្រនោះ អាស៊ានបានកើតនៅឆ្នាំ១៩៦៧ គឺជាក្រុមតំបន់ចំណាស់ជាងគេបំផុតនៃពិភពលោកខាងត្បូង។ ភាពយូរអង្វែងដែលជៀសផុតពីការប្រកួតប្រជែងនានានេះ អាចពន្យល់បានថា មកពីសមត្ថភាពរបស់អាស៊ានដែលចេះ «រស់នៅជាមួយគ្នាប្រកបដោយសុខដុមរមនា» និងដោយការគាំទ្រដែលទទួលបានពីប្រទេសជប៉ុនដែលចង់កាន់កាប់កន្លែងទំនេរដែលនៅសល់ពីវ៉ាស៊ីនតោនបន្ទាប់ពីឆ្នាំ១៩៧៥។

ចាប់តាំងពីអាស៊ានត្រូវបានបង្កើតឡើងដោយរដ្ឋទាំង ៥ (ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សិង្ហបុរី និងថៃ) ក្នុងឆ្នាំ១៩៦៧ ជាមួយសេចក្តីប្រកាសរួមចំនួនពីរទំព័រដែលធ្វើឡើងនៅទីក្រុងបាងកក បានកំណត់ពីគោលដៅរបស់កំណើន វឌ្ឍនភាព និងស្ថិរភាព។ គោលបំណងរបស់រដ្ឋជាសមាជិក គឺត្រូវជៀសវាងជម្លោះរវាងមហាអំណាច និងត្រូវគ្រប់គ្រងវាសនាតំបន់ជាមួយគ្នា។ សមិទ្ធផលមួយគឺការធ្លាក់ចុះនៃវោហារសាស្ត្រជាតិនិយម (nationalist rhetoric)។ អាស៊ីអាគ្នេយ៍មិនមែនអឺរ៉ុបខាងលិចទេ ហើយអាស៊ានក៏មិនដូចសហភាពអឺរ៉ុបដែរ ការប្រៀបធៀបត្រូវបានគេធ្វើជាញឹកញាប់ តាមរបៀបដូចខាងក្រោម។

> “ គោលបំណងរបស់រដ្ឋដែលជាសមាជិក គឺត្រូវជៀសវាងជម្លោះរវាងមហាអំណាច និងត្រូវគ្រប់គ្រងវាសនាតំបន់ជាមួយគ្នា។ ”

ដោយសារតែទើបទទួលបានឯករាជ្យថ្មីៗ អាស៊ានបានជ្រើសរើសនូវស្ថាប័នដែលមានលក្ខណៈក្រៅផ្លូវការជាជាងស្ថាប័នលើជាតិ (supranational) ដែលធ្ងន់ធ្ងរក្នុងនោះ ទំនាក់ទំនងផ្ទាល់ខ្លួនដើរតួនាទីយ៉ាងសំខាន់ ហើយអធិបតេយ្យភាពជាតិ គឺជាមធ្យោបាយមួយដែលត្រូវបានគាំទ្រ ដើម្បីទប់ទល់នឹងសម្ពាធពីខាងក្រៅ៖ មិនតម្រូវឲ្យមានភាពជាអ្នកដឹកនាំទេ សមាជិកទាំងអស់គឺស្មើគ្នា ហើយការសម្រេចចិត្តគឺផ្អែកលើការស្រុះស្រួលមតិគ្នាបែបកុងសង់ស៊ីស ។

ដំបូន្មានរបស់លោក Surin Pitsuwan អគ្គលេខាធិការអាស៊ាន ទៅកាន់អ្នកស្នងតំណែងរបស់គាត់ គឺលោក Le Luong Minh (ក្នុងខែមករា ឆ្នាំ២០១៣) គឺជាការឆ្លុះបញ្ចាំងយ៉ាងល្អអំពី អភិក្រមរបស់អង្គការនេះ៖ លោកបានជម្រុញថា អាស៊ានគួរតែអនុវត្តគោលនយោបាយនានាដោយឈរលើគោលការណ៍ “សាមគ្គីភាព និងភាពប្រទាក់ក្រឡាគ្នា” ហើយប្រទេសនេះក៏គួរតែទាញយកប្រយោជន៍

> “ គោលដៅគឺដើម្បីសម្រេចបាននូវគោលនយោបាយការទូតមួយដែលមាន «តុល្យភាពនិងការបើកចំហ» ដើម្បីកុំឲ្យស្ថិតនៅក្នុងស្ថានភាពមិនច្បាស់លាស់រវាងចិននិងសហរដ្ឋអាម៉េរិក។ ”

ពីជម្លោះរវាងភាគីទីបីទាំងឡាយ តាមរយៈការកសាងទំនាក់ទំនងដែលផ្តល់ផលប្រយោជន៍ចំពោះខ្លួន ដូចជាជាមួយសហរដ្ឋអាម៉េរិក ជប៉ុន ឥណ្ឌា អូស្ត្រាលី និងសហភាពអឺរ៉ុប។។

គោលដៅគឺដើម្បីសម្រេចបាននូវគោលនយោបាយការទូតដែលមាន «តុល្យភាពនិងការបើកចំហ» ដើម្បីកុំឲ្យស្ថិតនៅក្នុងស្ថានភាពមិនច្បាស់លាស់រវាងចិននិងសហរដ្ឋអាម៉េរិក (លោកបញ្ជាក់ថា គ្មាននរណាចាំបាច់ត្រូវតែជ្រើសរើសទេ ព្រោះនោះគឺជាសេណារីយ៉ូដ៏អាក្រក់មួយ)។ លោកបានបន្ថែមថា ទីក្រុងប៉េកាំង និងវ៉ាស៊ីនតោនដឹងរឿងនេះ និងធ្វើសកម្មភាពសម្របខ្លួនទៅតាមនោះដែរ។ ដូច្នេះ «យើងត្រូវតែមានភាពចាស់ទុំ និងដាក់ខ្លួនយើងឲ្យមានតម្លៃខ្ពស់»។ លោកបានបន្តទៀតថា ចិនបានផ្តល់ដល់អាស៊ាននូវការឆ្លុះបញ្ចាំងប្រាកដនិយមមួយអំពីសក្តានុពល ទំនួលខុសត្រូវ និងគុណវិបត្តិនានារបស់ខ្លួន ។«យើងគឺជាតំបន់តែមួយគត់នៃពិភពលោក ដែលគិតគូរដល់ផលប្រយោជន៍ជនជាតិចិន ហើយនោះមានអត្ថន័យអ្វីមួយទៅកាន់ទីក្រុងប៉េកាំង។

នយោបាយការបរទេសចិន បានផ្លាស់ប្តូរហួសពីកិច្ចព្រមព្រៀងទ្វេភាគីទាំងស្រុង ទៅជាការចរចាជាមួយអាស៊ានក្នុងនាមជាអង្គការសមូហភាព។អាស៊ានគឺជាដៃគូដ៏សំខាន់មួយ ព្រោះវាមានលក្ខណៈងាយបត់បែននិងចេះសម្របសម្រួល សម្រាប់ទំនាក់ទំនងមួយដែលមានតុល្យភាពដែលចាំបាច់សម្រាប់ការផ្លាស់ប្តូរមុខមាត់របស់ខ្លួននៅលើឆាកអន្តរជាតិ។ ទីតាំងភូមិសាស្ត្ររបស់ខ្លួនដែលស្ថិតនៅលើឬជិតនឹងផ្លូវពាណិជ្ជកម្មដ៏សំខាន់នានា ធានាបានថា អាស៊ានស្ថិតនៅក្នុងការប្រកួតប្រជែងជាមួយសហរដ្ឋអាម៉េរិក ហើយនេះបានអនុញ្ញាតឲ្យខ្លួនមានតួនាទីសំខាន់មួយ ដែលត្រូវបានទទួលស្គាល់ជាក់ស្តែងដោយសហរដ្ឋអាម៉េរិក និងសហភាពអឺរ៉ុប។ អាស៊ានមានទស្សនៈថា ផលប្រយោជន៍របស់ចិនគឺជាគុណប្រយោជន៍មួយ (ភាពស្វាហាប់ ភាពជិតជិត អំណាចទន់ ជាដើម។ល។) បើទោះបីជាភាពជាដៃគូនេះមានសភាពមិនស្មើគ្នាក៏ដោយ [១] ។

ប្រទេសឥណ្ឌាដែលបានជះឥទ្ធិពលវប្បធម៌ដ៏សំខាន់មួយនៅក្នុងអាស៊ីអាគ្នេយ៍កាលពីអតីតកាល បានផ្លាស់ប្តូរពី «គោលនយោបាយមើលឆ្ពោះទៅទិសខាងកើត» ទៅជា «គោលនយោបាយធ្វើសកម្មភាពទៅទិសខាងកើត» ហើយអ្នកសង្កេតការណ៍ខ្លះគិតថា ប្រទេសឥណ្ឌាដែលគេចាត់ទុកថាជា «កូនក្មេងដែលតែងតែមានបញ្ហាជាប់រហូតនៅអាស៊ីបានក្លាយទៅជាមានសក្តានុពលដ៏អស្ចារ្យមិនធម្មតា និងមានឱកាសក្នុងការដេកតំណែងប្រទេសចិន ប្រសិនបើប្រទេសឥណ្ឌាចង់ព្យាយាម» [១] ។

> “ នយោបាយការបរទេសចិនបានផ្លាស់ប្តូរហួសពីកិច្ចព្រមព្រៀងទ្វេភាគីទាំងស្រុង ទៅជាការចរចាជាមួយអាស៊ានក្នុងនាមជាអង្គការសមូហភាព។ ”

## REFERENCES

១. Eijas, A. (2018). Financing ASEAN’s infrastructure demand [Online]. The ASEAN Post. Available at: https://theaseanpost.com/article/financing-aseans-infrastructure-demand [Accessed 13 Feb. 2019].

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដែលបកដោយវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិនៃកម្ពុជា (NIDIR)។ អ្នកអានអាចទាញយកអត្ថបទដើមជាភាសាអង់គ្លេសពីគេហទំព័រ៖ https://www.pic.org.kh ។




ពិធីបើកសន្និបាតអន្តរសភាអាស៊ានលើកទី ៣២
ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១១ ភ្នំពេញ កម្ពុជា






# អាគារសភា
# នៃប្រទេស
# សមាជិកអាស៊ាន









ជំពូកទី

# ០៦

# សភានៃរដ្ឋជាសមាជិកអាស៊ាន


ទំ.១៨៤ ៦.១ បរិបទនយោបាយ៖ ពីការរីកលូតលាស់ផ្នែកសេដ្ឋកិច្ចទៅកាន់អន្តរកាលផ្នែកនយោបាយ

ទំ.១៨៥ ៦.២ សភាជាសមាជិកសភាអាយប៉ា (AIPA) ៖ ក្របខ័ណ្ឌ សមាសភាព និងនីតិវិធី


*អ្នករួមចំណែក៖ មីហ្សែល ហ្វូសហ្សេ*

# ៦.១ បរិបទនយោបាយ៖ ពីការរីកលូតលាស់ផ្នែកសេដ្ឋកិច្ចទៅកាន់អន្តរកាលផ្នែកនយោបាយ

> “ បន្ទាប់ពីការបិទបញ្ចប់សង្គ្រាមត្រជាក់ តំបន់នេះមានការរីកចម្រើនជាលំដាប់ឆ្ពោះទៅរកលទ្ធិប្រជាធិបតេយ្យខណៈដែលតំបន់នេះផ្ទាល់ពុំធ្លាប់មានប្រពៃណីនយោបាយបែបសេរីពីមុនឡើយ។ ”

ការរីកលូតលាស់ផ្នែកសេដ្ឋកិច្ច មានឥទ្ធិពលលើសពីការកើនឡើងនៃពាណិជ្ជកម្មនិងអាជីវកម្មនានាទៅទៀត។ វិទ្យាស្ថានស្រាវជ្រាវអំពីអាស៊ីអាគ្នេយ៍សហសម័យ(IRASEC) បានពិនិត្យមើលវិបត្តិនយោបាយនិងអន្តរកាលនៅក្នុងអាស៊ីអាគ្នេយ៍ និងបានបង្កើតការបែងចែកថ្នាក់នៃរបបនយោបាយ [១, ២]។

តំបន់អាស៊ីអាគ្នេយ៍មិនត្រឹមតែត្រូវបានបង្ហាញជាតំបន់ដែលកំពុងមានអព្ភូតហេតុសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែក៏ជាមន្ទីរពិសោធន៍នយោបាយគួរឲ្យកត់សម្គាល់ផងដែរ ពោលគឺតំបន់មួយដែលគួរឲ្យចាប់អារម្មណ៍បំផុតនៅលើពិភពលោកដែលគេអាចធ្វើការវិភាគអំពីនយោបាយអន្តរកាល។ បន្ទាប់ពីការបិទបញ្ចប់នៃសង្គ្រាមត្រជាក់ តំបន់នេះមានការរីកចម្រើនជាលំដាប់ឆ្ពោះទៅរកលទ្ធិប្រជាធិបតេយ្យ ខណៈដែលតំបន់នេះផ្ទាល់ពុំធ្លាប់មានប្រពៃណីនយោបាយបែបសេរីពីមុនឡើយ។

របាយការណ៍ដែលបានរៀបរាប់ខាងលើចាត់ទុកថាអន្តរកាលផ្នែកនយោបាយកំពុងប្រព្រឹត្តទៅយ៉ាងច្បាស់នៅអាស៊ីអាគ្នេយ៍៖ ទំនាក់ទំនងរវាងពលរដ្ឋនិងរដ្ឋ បែបបទនៃការពិភាក្សាដេញដោលការរីកលូតលាស់នៃគណបក្សនយោបាយនិងសកម្មជន(NGOs) បង្ហាញពីបំណងប្រាថ្នាយ៉ាងច្បាស់អំពីការផ្លាស់ប្តូរ។ ភាពក្តៀវក្លាបែបនេះមិនអាចត្រូវបានចាត់ទុកត្រឹមជាបាតុកម្មប្រឆាំងតវ៉ានោះទេ។ ច្បាស់ណាស់ថាបណ្តាប្រទេសទាំងនេះកំពុងដើរតាមមាគ៌ានយោបាយជាច្រើនផ្សេងៗគ្នា។ ការបែងចែកថ្នាក់នៃទម្រង់រដ្ឋនិងអភិបាលកិច្ចនៅក្នុងអាស៊ីអាគ្នេយ៍ រួមមាន រាជានិយមចំនួន៤ សាធារណរដ្ឋចំនួន៦ និងសហព័ន្ធចំនួន១។ ប្រព័ន្ធនយោបាយមានចាប់តាំងពីប្រព័ន្ធគ្មានគណបក្សប្រកួតប្រជែង (ព្រុយណេ) ប្រព័ន្ធមានគណបក្សតែមួយ (សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងវៀតណាម) ប្រព័ន្ធមានគណបក្សគ្រប់គ្រងដ៏រឹងមាំមួយនៅក្នុងប្រព័ន្ធនៃការបោះឆ្នោតដោយសេរី(កម្ពុជា ម៉ាឡេស៊ី និងសិង្ហបុរី) និងសម្ព័ន្ធគណបក្សដែលចែករំលែកផលប្រយោជន៍រួម (ឥណ្ឌូនេស៊ី ហ្វីលីពីន និងទីម័រខាងកើត) រួមទាំងប្រព័ន្ធដែលស្ថិតក្នុងស្ថានភាពអន្តរកាល(មីយ៉ាន់ម៉ា និងថៃ)។

អ្នកជំនាញអាចបន្តការពិភាក្សាដេញដោលអំពីទំនាក់ទំនងរវាងការអភិវឌ្ឍសេដ្ឋកិច្ច និងការទាមទារលទ្ធិប្រជាធិបតេយ្យ ប៉ុន្តែអន្តរកាលនេះត្រូវបានអមដំណើរនិងគាំទ្រដោយអត្រាកំណើនជាង ៥% ចាប់ពីឆ្នាំ២០០៣ ដល់ឆ្នាំ២០១៦។ លោកស្រី Sri Mulyani Indrawati ប្រធានធនាគារពិភពលោកមានប្រសាសន៍ថា កំណើននេះជំរុញដល់ការកើនឡើងនៃវណ្ណៈមធ្យម និងអំពាវនាវឲ្យមានប្រព័ន្ធពហុបក្សដ៏រាបណា «គេធានាថា កំណើននោះ គឺប្រកបដោយបរិយាបន្ន»។ ការអំពាវនាវដើម្បីលទ្ធិប្រជាធិបតេយ្យទាំងនេះមិនត្រឹមតែការអនុវត្តនិងប្រសិទ្ធភាពប៉ុណ្ណោះទេ គឺរួមមានការទាមទារឲ្យមានស្ថិរភាពស្ថាប័ននិងនីតិរដ្ឋ។ កិច្ចប្រជុំលើកដំបូងរបស់សភាមីយ៉ាន់ម៉ា នាថ្ងៃទី៣១ ខែមករា ឆ្នាំ២០១១ ត្រូវបានគេមើលឃើញថាបាននាំមកនូវយុគសម័យថ្មីមួយ។ ការបោះឆ្នោតនៅទីនោះ បង្ហាញអំពីធម្មានុរូបភាពរបស់ស្ថាប័ន។

> “ ច្បាស់ណាស់ថាបណ្តាប្រទេសទាំងនេះកំពុងដើរតាមមាគ៌ានយោបាយជាច្រើនផ្សេងៗគ្នា។ ការបែងចែកថ្នាក់នៃទម្រង់រដ្ឋនិងអភិបាលកិច្ចនៅក្នុងអាស៊ីអាគ្នេយ៍រួមមាន រាជានិយមចំនួន៤ សាធារណរដ្ឋចំនួន៦ និងសហព័ន្ធចំនួន១។ ”

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដែលបកដោយវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិនៃកម្ពុជា (NIDIR)។ អ្នកអានអាចទាញយកអត្ថបទដើមជាភាសាអង់គ្លេសពីគេហទំព័រ៖ https://www.pic.org.kh ។

# ៦.២ សភាជាសមាជិកអាយប៉ា ( AIPA ) ៖ ក្របខ័ណ្ឌ សមាសភាព និងនីតិវិធី

ផ្នែកនេះពឹងផ្អែកទាំងស្រុងលើឯកសារចំនួនពីរដែលបោះពុម្ពផ្សាយយ៉ាងទូលំទូលាយ និងល្អឥតខ្ចោះរបស់អាយប៉ាគឺ៖ ឯកសារស្តីពី អាស៊ានតែមួយ ប្រព័ន្ធច្រើន៖ នីតិវិធីធ្វើច្បាប់នៃសភាជាសមាជិកអាយប៉ា ដោយបណ្ឌិត **Stephen Sherlock** នៅខែកញ្ញាឆ្នាំ២០១៥ និងឯកសារសាលាកបត្រព័ត៌មានស្តីពីប្រព័ន្ធនយោបាយ និងប្រព័ន្ធសភានៃសភាជាសមាជិកអាយប៉ា ដោយបណ្ឌិត **Jan Seifert, PhD,** ខែកញ្ញា ឆ្នាំ២០១៥។

http://www.aipasecretariat.org/webassets/pdf/08.pdf

http://www.aipasecretariat.org/webassets/pdf/11.pdf

**ផែនទី ៧** ៖ ណាហ្គារ៉ា ព្រុយណេដារូសាឡាម



ភាពខុសគ្នានៃសភាជាសមាជិកនៃអន្តរសភាអាស៊ាន (AIPA) បានឆ្លុះបញ្ចាំងពីពិពិធភាពនៃប្រវត្តិសាស្ត្រនយោបាយ និងរដ្ឋធម្មនុញ្ញរបស់ប្រជាជាតិដែលបង្កើតសមាគមអាស៊ាន។ តុល្យភាពរវាងតួនាទីរបស់ស្ថាប័ននីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិនៅក្នុងដំណើរការធ្វើច្បាប់មានភាពខុសគ្នាខ្លាំងទៅតាមវិសាលភាពរដ្ឋធម្មនុញ្ញនៃប្រទេសក្នុងអាស៊ាន។ ដូច្នេះនីតិវិធីពិនិត្យ និងអនុម័តច្បាប់របស់សភាជាសមាជិកអាយប៉ាក៏ពិតជាមានលក្ខណៈខុសគ្នាច្រើនជៀសមិនផុតដែរ។ ទោះជាយ៉ាងណាក៏ដោយ វាមិនពិបាកនោះទេក្នុងការកត់កំណត់ពីលំនាំជាក់ច្បាស់ ពីភាពខុសគ្នានៅក្នុងនីតិធ្វើច្បាប់ទាំងនោះ។ ការអនុវត្តនៅក្នុងសភានីមួយៗមានចំណុចខ្លះដូចគ្នា និងចំណុចខ្លះមានលក្ខណៈដោយឡែកពីគ្នាស្របទៅតាមបរិបទនៅក្នុងប្រទេសរៀងៗខ្លួន។ ការអនុវត្តទាំងនេះមានប្រភពចេញពីប្រពៃណីនៃផ្នត់គំនិតនយោបាយ រដ្ឋធម្មនុញ្ញ និងច្បាប់ ដែលបានបន្សល់ទុកពីការអនុវត្តក្នុងសម័យអាណានិគម និងការអនុវត្តជាសាកល ពីការអនុវត្តរបស់ស្ថាប័នក្នុងស្រុក និងពីទំនៀមទម្លាប់ប្រពៃណី។ លក្ខណៈទាំងនេះមិនមែនមានភាពពិសេសសម្រាប់តែតំបន់អាស៊ានទេ ពីព្រោះគេឃើញថា ស្ថានភាពបែបនេះមាននៅពាសពេញសភាពិភពលោក ប៉ុន្តែគ្រាន់តែការអនុវត្តបានធ្វើឡើងទៅតាមវិធីពិសេសរៀងៗខ្លួនរបស់សភាជាសមាជិកអាយប៉ា ។

## ក្របខ័ណ្ឌរដ្ឋធម្មនុញ្ញ ៖ ប្រព័ន្ធប្រធានាធិបតីនិយម ឬប្រព័ន្ធសភានិយម

ជាទូទៅ រដ្ឋធម្មនុញ្ញទាំងអស់នៅក្នុងពិភពលោកតែងតែមានកំណត់ពីប្រព័ន្ធប្រធានាធិបតីនិយម ឬសភានិយម ឬជាប្រព័ន្ធដែលមានលក្ខណៈទាំងពីរ (ជាទូទៅហៅថាប្រព័ន្ធ «ពាក់កណ្តាលប្រធានាធិបតីនិយម»)។ អ្នកសិក្សាស្រាវជ្រាវផ្នែកនយោបាយបានទទួលស្គាល់ពីភាពផ្សេងគ្នានៅក្នុងការរួមផ្សំនៃប្រព័ន្ធទាំងពីរនេះជាច្រើនទសវត្សរ៍មកហើយ។ តារាងទី១ ខាងក្រោមនឹងបង្ហាញពីសភាជាសមាជិកអាយប៉ាទៅតាមប្រព័ន្ធសភានិយមឬប្រធានាធិបតីនិយម ។

**តារាង១៖** សភាជាសមាជិកអាយប៉ា ៖ រដ្ឋធម្មនុញ្ញសភានិយម និងប្រធានាធិបតីនិយម

| | |
|---|---|
| សភានិយម | ព្រុយណេ កម្ពុជា ឡាវ ម៉ាឡេស៊ី សិង្ហបុរី ថៃ វៀតណាម |
| ប្រធានាធិបតីនិយម | ឥណ្ឌូនេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន |

ភាពខុសគ្នាសំខាន់រវាងប្រព័ន្ធប្រធានាធិបតីនិយម និងប្រព័ន្ធសភានិយម គឺវិធីសាស្ត្រជ្រើសរើសប្រមុខរដ្ឋាភិបាល និងថាតើគណៈរដ្ឋមន្ត្រីទទួលខុសត្រូវចំពោះសភាឬអត់។ ប្រព័ន្ធដែលមានការបោះឆ្នោតចំនួនពីរដាច់ដោយឡែកពីគ្នាសម្រាប់ប្រមុខរដ្ឋាភិបាល (ហៅថាប្រធានាធិបតី) និងសភា និងមានការបែងចែកអំណាចដាច់ពីគ្នារវាងស្ថាប័នទាំងពីរត្រូវបានចាត់ទុកថាជា «ប្រព័ន្ធប្រធានាធិបតីនិយម» ។ ប្រព័ន្ធដែលមានការបោះឆ្នោតមួយសម្រាប់សភា ហើយបន្ទាប់មកសភាជាអ្នកបោះឆ្នោតជ្រើសរើសប្រមុខរដ្ឋាភិបាល (ជាទូទៅត្រូវបានគេស្គាល់ថា ជានាយករដ្ឋមន្ត្រី ឬអធិការបតី) ដែលត្រូវឆ្លើយចំពោះមុខសភា ប្រព័ន្ធនេះត្រូវបានចាត់ទុកជា «ប្រព័ន្ធសភានិយម» ។

ការរៀបចំខុសគ្នាទាំងនេះ គឺជាកត្តាកំណត់ដ៏សំខាន់ពីតួនាទីរបស់សភាក្នុងការធ្វើច្បាប់។ គេសង្កេតឃើញថា ចំណុចស្នូលនៃការងាររបស់សភានៅក្នុងប្រព័ន្ធសភានិយម គឺការពិនិត្យ និងអនុម័តច្បាប់ ដែលស្នើឡើងដោយអង្គនីតិប្រតិបត្តិ ចំណែកការងាររបស់សភានៅក្នុងប្រព័ន្ធប្រធានាធិបតីនិយម គឺផ្តោតទាំងទៅលើការពិនិត្យលើសេចក្តីព្រាងច្បាប់របស់រដ្ឋាភិបាល (government legislation) និងការផ្តួចផ្តើមធ្វើសេចក្តីស្នើច្បាប់ដោយខ្លួនឯង។ ផ្ទុយគ្នាស្រឡះ សភានៅក្នុងប្រព័ន្ធសភានិយមជាទូទៅមានលក្ខណៈទន់ខ្សោយទាក់ទងនឹងការធ្វើច្បាប់បើធៀបនឹងសភានៅក្នុងប្រព័ន្ធប្រធានាធិបតីនិយម។

ក្នុងករណីអាស៊ាន សភាចំនួន ៧ ដែលអាចត្រូវបានចាត់ក្នុងប្រព័ន្ធ«សភានិយម»។ប្រព័ន្ធនេះត្រូវបានគេមើលឃើញច្បាស់បំផុត តាមរយៈឧទាហរណ៍នៃប្រទេសម៉ាឡេស៊ី សិង្ហបុរី និងព្រុយណេ ដែលទទួលឥទ្ធិពលពីបទពិសោធន៍នៃអាណានិគមអង់គ្លេស ដែលបាននាំឲ្យមានការបង្កើតសភាបែបវេសមីនស្ទ័ (Westminster) នៅពេលទទួលបានឯករាជ្យ ឬក្នុងករណីប្រទេសព្រុយណេដែលបានបង្កើតក្នុងពេលមួយក្រោយពីទទួលបានឯករាជ្យ។ ប្រព័ន្ធសភានិយមបែបផ្សេងៗគ្នាក៏ត្រូវបានបង្កើតនៅពេលថ្មីៗក្រោយមកទៀតនៅក្នុងរដ្ឋជាសមាជិកអាស៊ានដែលរួមមាន៖ប្រទេសថៃ កម្ពុជា វៀតណាម និងឡាវ។ សភាចំនួនបីផ្សេងទៀតនៃសមាជិកអាយប៉ាត្រូវបានចាត់ថ្នាក់នៅក្នុងក្រុមដែលមានប្រព័ន្ធប្រធានាធិបតីនិយម រួមមាន ប្រទេសហ្វីលីពីន ឥណ្ឌូនេស៊ី និងមីយ៉ាន់ម៉ា។

នៅក្នុងក្រុមទី ១ នៃរដ្ឋជាសមាជិកអាស៊ាន សភាគឺពិតជាមានឥទ្ធិពលតិចតួចក្នុងការតាក់តែងសេចក្តីស្នើច្បាប់ ការពិនិត្យ និងការអនុម័តច្បាប់ បើប្រៀបទៅនឹងក្រុមទី២។ ឧទាហរណ៍នៅក្នុងប្រព័ន្ធសភានិយមនៃប្រទេសដូចជា

## ផែនទី ៨ ៖ ព្រះរាជាណាចក្រកម្ពុជា




**គំណត់សម្គាល់**

- រាជធានី
- រាជធានីមានចំនួនប្រជាជនច្រើនជាង ១លាននាក់
- រាជធានីមានចំនួនប្រជាជនច្រើនជាង ៣សែននាក់
- ទីក្រុងធំៗនៅក្នុងប្រទេស
- អាកាសយានដ្ឋានអន្តរជាតិ
- ទំនប់វារីអគ្គិសនី (លើសពី ១០០ មេហ្គាវ៉ាត់)
- កំពង់ផែសមុទ្រ
- តំបន់សេដ្ឋកិច្ចពិសេស
- តំបន់ទីក្រុងសំខាន់ៗនៅក្នុងប្រទេស ដែលមានប្រជាជនរាប់លាននាក់
- ផ្លូវដែកមានស្រាប់
- ផ្លូវជាតិ
- ព្រំដែនខេត្ត
- ព្រំដែនអន្តរជាតិ
- ផ្លូវល្បឿនលឿន ភ្នំពេញ - ព្រះសីហនុ បានគ្រោងទុក
- មជ្ឈមណ្ឌលប្រវត្តិសាស្ត្រ និងប្រជាសាស្ត្រតាមតំបន់
- បរិមណ្ឌលដំបូង៖ តំបន់ឆ្នេរ និងតំបន់ត្រួសត្រាយចាស់
- តំបន់នៅក្រោមចម្ងាយ ១០០ម៉ែត្រ
- តំបន់ទីក្រុង
- សម្បទានដីសេដ្ឋកិច្ច

## ផែនទី ៩ ៖ សាធារណរដ្ឋឥណ្ឌូនេស៊ី



ផែនទី ១០ ៖ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ




**កំណត់សម្គាល់**

- ★ រាជធានី
- រាជធានីមានចំនួនប្រជាជនច្រើនជាង ១លាននាក់
- រាជធានីមានចំនួនប្រជាជនច្រើនជាង ៣សែននាក់
- ទីក្រុងធំៗនៅក្នុងប្រទេសផ្សេងទៀត
- អាកាសយានដ្ឋានអន្តរជាតិ
- ទំនប់វារីអគ្គិសនីដែលត្រូវបានអនុញ្ញាតឲ្យសាងសង់
- ទំនប់ដែលបានគ្រោងទុកនៅតាមដងទន្លេមេគង្គ
- ផ្លូវជាតិ
- ព្រំដែនខេត្ត
- ព្រំដែនអន្តរជាតិ
- តំបន់ទីក្រុងសំខាន់ៗនៅក្នុងប្រទេសដែលមានប្រជាជនរាប់លាននាក់

ដង់ស៊ីតេប្រជាជននៅឆ្នាំ២០១៥ (ម្នាក់ក្នុងមួយ គម²)

- <១៥
- [១៥-៣០[
- [៣០-១០០[
- >១០០
- តំបន់ទីក្រុង

ផ្លូវដែកល្បឿនលឿនដែលបានស្នើឡើង៖ គុនមីញ-យូស៊ី-ម៉ូហាន-លួងព្រះបាង-វៀងច័ន្ទ-ណងខៃ-គូឡាឡាំពួ

ជំពូកទី
០៦

សភានៃរដ្ឋជាសមាជិកអាស៊ាន

សភាជាសមាជិកអាយប៉ា (AIPA) ៖ ក្របខ័ណ្ឌ សមាសភាព និងតួនាទី

ព្រុយណេ សិង្ហបុរី ម៉ាឡេស៊ី ឬ កម្ពុជា ច្បាប់ភាគច្រើនត្រូវបានព្រាងឡើងដោយអង្គនីតិប្រតិបត្តិ ហើយត្រូវអនុម័តដោយមានធាតុចូលតិចតួចពីសភា។ នេះគឺជាលក្ខណៈនៃប្រព័ន្ធសភានិយម ជាពិសេសសភាដែលយកតាមប្រពៃណី Westminster រួមមានដូចជា ចក្រភពអង់គ្លេស អូស្ត្រាលី ជាដើម។ ផ្ទុយទៅវិញនៅក្នុងប្រព័ន្ធដែលអង្គនីតិប្រតិបត្តិដឹកនាំដោយប្រធានាធិបតី គឺមានអង្គនីតិប្បញ្ញត្តិដែលទទួលបានអណត្តិដែលប្រគល់ឲ្យដោយផ្ទាល់ពីពលរដ្ឋ ហើយដែលមានឯករាជ្យក្នុងការពិនិត្យ និងឲ្យយោបល់លើខ្លឹមសារនៃអត្ថបទច្បាប់។ ការអនុវត្តបែបនេះត្រូវបានគេមើលឃើញយ៉ាងច្បាស់នៅក្នុងសភាដែលមានឥទ្ធិពលដូចជាសភានៃប្រទេសឥណ្ឌូនេស៊ី និងហ្វីលីពីន ដែលអង្គនីតិប្បញ្ញត្តិ និងអង្គនីតិប្រតិបត្តិជាញឹកញាប់តែងមានទស្សនៈផ្ទុយគ្នាទៅលើការធ្វើច្បាប់ ហើយដែលភាគច្រើននៃច្បាប់ត្រូវបានព្រាងនៅក្នុងសភាជាជាងនៅក្នុងក្រសួងរបស់រដ្ឋាភិបាល។

ជាការពិតណាស់វិសាលភាពនៃ ( spectrum ) ប្រព័ន្ធសភានិយម ឬប្រព័ន្ធប្រធានាធិបតីនិយម គឺគ្រាន់តែជាអញ្ញតិ មួយប៉ុណ្ណោះ ក្នុងចំណោមអញ្ញតិផ្សេងៗទៀត ដែលអាចកំណត់នូវអំណាចរបស់សភា។ អញ្ញតិសំខាន់ទីពីរ គឺរបៀបដែលសភាត្រូវបានបោះឆ្នោតជ្រើសរើស និងលំនាំយូរអង្វែងនៅក្នុងការបោះឆ្នោត។ ចំណុចទាំងនេះត្រូវបានពិភាក្សានៅក្នុងផ្នែកខាងក្រោម។

## សមាសភាពសភា៖ ឯកបក្ស ពហុបក្ស ឬគណបក្សមានប្រៀបផ្តាច់មុខតែមួយ

អញ្ញតិទី២នៅក្នុងចំណោមសភាជាសមាជិកអាយប៉ា ហើយដែលមានឥទ្ធិពលយ៉ាងខ្លាំងទៅលើលក្ខណៈនៃតួនាទីរបស់សភាក្នុងនីតិវិធីធ្វើច្បាប់ គឺវិធានក្នុងការជ្រើសរើសសមាជិក សមាជិកាសភា។ នៅក្នុងអាស៊ាន គឺមាន៖ ការបោះឆ្នោតដែលមានការប្រកួតប្រជែងនៅប្រទេសសិង្ហបុរី ម៉ាឡេស៊ី ឥណ្ឌូនេស៊ី ថៃ (មុនឆ្នាំ២០១៤) ហ្វីលីពីន មីយ៉ាន់ម៉ា( ចាប់តាំងពីឆ្នាំ២០១០ ) និងកម្ពុជា។ ការបោះឆ្នោតក្នុងគណបក្សតែមួយនៅវៀតណាម និងឡាវ និងការតែងតាំងដោយព្រះមហាក្សត្រករុណាប្រទេសព្រុយណេ។

សភានៅក្នុងប្រព័ន្ធឯកបក្សឬក្រោមការគ្រប់គ្រងរបស់ប្រព័ន្ធរាជានិយម ទំនងជាមិនមានតួនាទីសំខាន់ក្នុងដំណើរការធ្វើច្បាប់នោះទេ ពីព្រោះគណបក្សកាន់អំណាច ឬព្រះមហាក្សត្រតែងតែមានអំណាចគ្របដណ្តប់ទាំងអង្គនីតិប្បញ្ញត្តិ និងអង្គនីតិប្រតិបត្តិរបស់រដ្ឋាភិបាល។ ក្នុងកាលៈទេសៈទាំងនេះ គេអាចរំពឹងឃើញបានថាច្បាប់ភាគច្រើន គឺត្រូវបានព្រាងដោយអង្គនីតិប្រតិបត្តិ ហើយសមាជិក សមាជិកាសភានឹងមិនជំទាស់ទៅនឹងសេចក្តីព្រាងច្បាប់ដែលរៀបចំដោយរដ្ឋាភិបាលលើបញ្ហាដែលជាគោលការណ៍ចម្បងនៅក្នុងសេចក្តីព្រាងច្បាប់ ហើយនឹងមិនបោះឆ្នោតប្រឆាំងនឹងសេចក្តីព្រាងច្បាប់ដែលព្រាងដោយអង្គនីតិប្រតិបត្តិឡើយ។ នៅក្នុងប្រព័ន្ធបែបនេះ ឧទាហរណ៍ដូចជានៅប្រទេសវៀតណាម និងឡាវ សភាគឺជាស្ថាប័នដែលផ្តល់យោបល់ដល់រដ្ឋាភិបាលលើខ្លឹមសារ និងពាក្យពេចន៍នៃច្បាប់ ខណៈដែលក្នុងរបបសភាពហុបក្សដូចជា នៅប្រទេសថៃមុនឆ្នាំ ២០១៤ គេអាចរំពឹងឃើញថា មានការជជែកពិភាក្សាជេញដោលនយោបាយ និងការរិះគន់ច្រើនលើសេចក្តីព្រាងច្បាប់របស់រដ្ឋាភិបាល។ វិធីមួយទៀតដើម្បីបង្ហាញពីភាពផ្ទុយគ្នាខាងលើនេះ គឺការពិនិត្យមើលលើធាតុចូលពីសភានៅក្នុងប្រព័ន្ធឯកបក្ស/ប្រព័ន្ធរាជានិយមច្រើនតែ (...) មានលក្ខណៈបច្ចេកទេស និងមិនមែននយោបាយ ចំណែកឯប្រព័ន្ធពហុបក្ស ការផ្តល់ធាតុចូលគឺអាចភាគច្រើនមានទំនោរជាលក្ខណៈនយោបាយ និង/ឬ មនោគមវិជ្ជា រួមជាមួយនឹងបច្ចេកទេសផងដែរ។

ការបោះឆ្នោតពហុបក្សមានឥទ្ធិពលខ្លាំងទៅលើការជជែកជេញដោលនៅក្នុងដំណើរការពិនិត្យពិភាក្សាច្បាប់ដែលធ្វើឡើងនៅក្នុងសភា។ ប៉ុន្តែអ្នកសិក្សាស្រាវជ្រាវផ្នែកនយោបាយបានសង្កេតឃើញថា ការបោះឆ្នោតពហុបក្សមួយចំនួនបង្កើតបានជាសភាដែលមានគណបក្សច្រើនដែលមានការប្រកួតប្រជែងគ្នា ខណៈពេលដែលសភាផ្សេងទៀតហាក់ដូចជាត្រូវបានគ្រប់គ្រងផ្តាច់មុខជាអចិន្ត្រៃយ៍ដោយគណបក្សតែមួយ។ នៅក្នុងអាយប៉ា ប្រទេសឥណ្ឌូនេស៊ី ហ្វីលីពីន និងថៃ (មុនឆ្នាំ២០១៤) មានសភាដែលមានការប្រកួតប្រជែងខ្ពស់ ខណៈដែលប្រទេសសិង្ហបុរីមានគណបក្សកាន់អំណាចដដែលៗចាប់តាំងពីទទួលបានឯករាជ្យមក រីឯប្រទេសម៉ាឡេស៊ីវិញទើបតែបញ្ចប់ស្ថានភាពដែលស្ថិតនៅក្រោមការគ្រប់គ្រងអស់រយៈពេល ៦១ឆ្នាំ របស់គណបក្សបារីសានជាតិ ( Barisan National ) និងសភាកម្ពុជាដែលត្រូវបានត្រួតត្រាផ្តាច់មុខដោយគណបក្សតែមួយក្នុងការបោះឆ្នោតជាច្រើនដង។ ពាក្យថា «ប្រព័ន្ធគណបក្សតែមួយដែលមានប្រៀបផ្តាច់មុខ» ( one-dominant party system ) ( សាតូរី ១៩៧៦ ) ត្រូវបានប្រើជាញឹកញាប់ដើម្បីពិព័រណ៌នាអំពីប្រព័ន្ធទាំងនេះ។ ពាក្យនេះត្រូវបានប្រើដំបូងដោយអ្នកវិទ្យាសាស្ត្រនយោបាយជនជាតិបារាំង លោក Maurice Duverger ( ១៩៥១ ) និងត្រូវបានប្រើជាទូទៅនៅប្រទេសឥណ្ឌា រហូតដល់ពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៧០ ដែលនៅពេលនោះ គណបក្សសមាជ ( Congress Party )

## ផែនទី ១១ ៖ ម៉ាឡេស៊ី




### កំណត់សម្គាល់

- ★ រាជធានី
- ● រាជធានីមានចំនួនប្រជាជនច្រើនជាង ១លាននាក់
- ● រាជធានីមានចំនួនប្រជាជនច្រើនជាង ៣សែននាក់
- ● ទីក្រុងធំៗផ្សេងទៀត
- អាកាសយានដ្ឋានអន្តរជាតិ
- កំពង់ផែសមុទ្រ
- ផ្លូវដែកមានស្រាប់
- ផ្លូវជាតិ
- ព្រំដែនខេត្ត
- ព្រំដែនអន្តរជាតិ
- តំបន់ទីក្រុង
- តំបន់ទីក្រុងធំៗក្នុងប្រទេស (ប្រជាជនរាប់លាននាក់)

### ចម្ការ

- ចម្ការដូងប្រេង
- ចម្ការដូងប្រេងចម្រុះជាមួយដំណាំផ្សេងទៀត
- ចម្ការកៅស៊ូ
- ចម្ការកៅស៊ូចម្រុះជាមួយដំណាំផ្សេងទៀត

### ប្រេង និងឧស្ម័ន

- បំពង់បង្ហូរឧស្ម័ន
- បំពង់បង្ហូរប្រេង
- តំបន់ឧស្ម័ន
- តំបន់ប្រេង

បានបង្កើតរដ្ឋាភិបាល បន្ទាប់ពីការបោះឆ្នោតតាំងពីក្រោយពេលទទួលបានឯករាជ្យនៅឆ្នាំ១៩៤៧ ( កូឋារី ១៩៦៤ )។ ទស្សនាទាននេះអាចត្រូវបានប្រើដើម្បីលើកកម្ពស់ការវិភាគរបស់យើងអំពី សមាសភាពគណបក្សនៅក្នុងសភា។

បើនិយាយពីដំណើរការធ្វើច្បាប់នៅក្នុងសភា អង្គនីតិប្បញ្ញត្តិដែលមានគណបក្សមួយមានប្រៀបផ្តាច់មុខក្នុងការគ្រប់គ្រងយូរអង្វែង មានលក្ខណៈខ្លះដូចសភាឯកបក្ស។ នៅក្នុងប្រទេសទាំងនេះ ការផ្តល់ធាតុចូលរបស់សភាទៅក្នុងការតាក់តែងច្បាប់ច្រើនតែផ្តោតលើការផ្តល់យោបល់បច្ចេកទេសទៅលើខ្លឹមសារ និងការប្រើប្រាស់ពាក្យពេចន៍នៅក្នុងសេចក្តីព្រាងច្បាប់ដែលតាក់តែងដោយរដ្ឋាភិបាល ហើយមិនសូវមានការពាក់ព័ន្ធក្នុងការជជែកដេញដោលផ្នែកនយោបាយ និងរិះគន់ទៅលើគោលនយោបាយរបស់រដ្ឋាភិបាលទេ។ ជាធម្មតា មតិដែលយល់ឃើញខុសប្លែកពីគ្នាគឺនៅត្រង់ថា តើនេះជាអ្វីដែលគួរឲ្យចង់បានឬមិនចង់បានប៉ុណ្ណោះ។ មានការអះអាងមួយបានលើកឡើងថា សភាបែបនេះមិនខ្ជះខ្ជាយពេលវេលាលើ «ការផ្តល់ពិន្ទុ» ផ្នែកនយោបាយទេ តែសភាបែបនេះបង្កើតបានច្បាប់មួយដែលមានគុណភាពបច្ចេកទេសល្អប្រសើរ ខណៈដែលមតិជំទាស់បានលើកឡើងវិញថាការជជែកដេញដោលបែបនយោបាយបង្កើតបានច្បាប់មួយដែលមានភាពល្អប្រសើរ ដោយបានឆ្លុះបញ្ចាំងនូវគំនិត និងផលប្រយោជន៍ផ្សេងៗជាច្រើនសម្រាប់ប្រទេសជាតិ។

ប៉ុន្តែឥឡូវនេះទុកអំណះអំណាងខាងលើនេះមួយឡែកសិន។ ការពិតគឺថា ពិតជាមានភាពខុសគ្នានៃសភាពហុបក្សនៅក្នុងអាស៊ាន ហើយការស្វែងយល់អំពីអង្គហេតុនេះជួយយើងឲ្យយល់ពីមូលហេតុដែលសភានានានៅក្នុងអាយប៉ាមានការចូលរួមតាមបែបផ្សេងៗគ្នានៅក្នុងដំណើរការធ្វើច្បាប់។ សភាដែលមានគណបក្សមួយមានប្រៀបផ្តាច់មុខមានវិសាលភាពច្រើនបែប។ រាប់ចាប់ពីប្រទេសសិង្ហបុរីដែលមានអាសនៈភាគច្រើននៅក្នុងសភាត្រូវបានគ្រប់គ្រងដោយគណបក្សកាន់អំណាចតែមួយចាប់តាំងពីទទួលបានឯករាជ្យរហូតដល់ប្រទេសម៉ាឡេស៊ីដែលរហូតមកដល់ឆ្នាំ២០១៨ មានគណបក្សតែមួយបានគ្រប់គ្រងសម្លេងភាគច្រើនចាប់តាំងពីទទួលបានឯករាជ្យ ប៉ុន្តែមានគណបក្សប្រឆាំងដែលតែងតែមានឥទ្ធិពល និងតែងតែធ្វើការរិះគន់ជារឿយៗ និងធ្វើការប្រឆាំងជាញឹកញាប់ទៅនឹងគោលនយោបាយរបស់រដ្ឋាភិបាល។ នៅក្នុងប្រទេសទាំងពីរសភាកម្រនឹងផ្តួចផ្តើមបង្កើតច្បាប់ណាស់ ( មូលហេតុមួយគឺដោយសារប្រទេសទាំងពីរមានប្រព័ន្ធសភានិយមដូចគ្នា ) និងមូលហេតុមួយទៀត គឺដោយសារការមានប្រៀបផ្តាច់មុខជាប្រពៃណីរបស់គណបក្សតែមួយបានកម្រិតលទ្ធភាពរបស់គណបក្សនៅក្រៅរដ្ឋាភិបាលក្នុងការស្នើធ្វើវិសោធនកម្មច្បាប់ ឬមានឥទ្ធិពលលើគោលនយោបាយរបស់រដ្ឋាភិបាល។ ប៉ុន្តែនៅក្នុងប្រទេសសិង្ហបុរី ឥទ្ធិពលដ៏លើសលុបរបស់គណបក្សកាន់អំណាចមានន័យថា ការពិភាក្សាភាគច្រើនក្នុងដំណើរការពិនិត្យនិងពិភាក្សាច្បាប់ គឺច្រើនផ្តោតលើលក្ខណៈបច្ចេកទេសនិងមិនផ្តោតសំខាន់លើការជជែកដេញដោលរបស់គណបក្សទេ ខណៈដែលក្រុមប្រឆាំងដ៏មានឥទ្ធិពលខ្លាំងនៅក្នុងសភាម៉ាឡេស៊ីតែងតែធ្វើឲ្យមានការជជែកដេញដោលនយោបាយយ៉ាងខ្លាំងក្លាជានិច្ច។

ពេលខ្លះសភាកម្ពុជាត្រូវបានគេមើលឃើញថា កំពុងបង្ហាញសញ្ញានៃការគ្រប់គ្រងដោយគណបក្សមួយ ដែលមានប្រៀបផ្តាច់មុខ។ ក្នុងករណីប្រទេសមីយ៉ាន់ម៉ា ការបោះឆ្នោតឆ្នាំ២០១០ បានបង្កើតសភាមួយដែលគ្រប់គ្រងដោយគណបក្សមួយ និងតំណាងយោធាជាច្រើន ប៉ុន្តែវាហាក់ដូចជាលឿនពេកហើយក្នុងការធ្វើសេចក្តីសន្និដ្ឋានច្បាស់លាស់អំពីរបៀបដែលសភាមីយ៉ាន់ម៉ាដំណើរការទាក់ទងនឹងការតាក់តែងសេចក្តីស្នើច្បាប់ ការពិនិត្យ និងការអនុម័តច្បាប់។

សភាជាសមាជិកអាយប៉ា ដែលរាប់ចាប់ពីសភាឯកបក្សសភាដែលគ្របដណ្តប់ផ្តាច់មុខដោយគណបក្សតែមួយរហូតដល់សភាពហុបក្ស គឺត្រូវបានបង្ហាញនៅក្នុងតារាងទី ២ ខាងក្រោម។

តារាងទី៣ បង្ហាញអញ្ញតិពីរ ( ១ ) ប្រព័ន្ធសភានិយម និងប្រព័ន្ធប្រធានាធិបតីនិយម និង ( ២ ) សមាសភាពគណបក្សនយោបាយនៅក្នុងសភា ។

តារាងទី៤ បង្ហាញពីលក្ខណៈពិសេសចំនួន៥ នៃលទ្ធភាពក្នុងការចូលរួមរបស់សភាក្នុងដំណើរការធ្វើច្បាប់ ( ការពិនិត្យគោលនយោបាយក្នុងសេចក្តីព្រាងច្បាប់របស់រដ្ឋាភិបាល ការផ្តល់យោបល់និងការផ្តល់ធាតុចូលបច្ចេកទេសលើសេចក្តីព្រាងច្បាប់ ការរិះគន់និងជជែកដេញដោលលើសេចក្តីព្រាងច្បាប់របស់រដ្ឋាភិបាល ការអភិវឌ្ឍជម្រើសគោលនយោបាយនានា និងការផ្តួចផ្តើម និងការធ្វើសេចក្តីស្នើច្បាប់ ) និងការកំណត់ថាតើនៅក្នុងសភាជាសមាជិកអាយប៉ា សកម្មភាពខាងលើណាខ្លះដែលអាច ឬមិនអាចនឹងកើតឡើង។ សភាត្រូវបានចាត់ថ្នាក់ទៅតាមការរួមបញ្ចូលគ្នានៃលក្ខណៈគន្លឹះពីររបស់សភា ដូចដែលបានរៀបរាប់លម្អិតខាងលើគឺ៖ អត្តសញ្ញាណដែលកំណត់ដោយរដ្ឋធម្មនុញ្ញរបស់ពួកគេជាប្រព័ន្ធប្រធានាធិបតីនិយម ឬសភានិយម ជាមួយគ្នានឹងវិធីសាស្ត្រនៃការជ្រើសរើសសមាសភាពថា ជាសភាឯកបក្ស/រាជានិយមសភាដែលគ្របដណ្តប់ផ្តាច់មុខដោយគណបក្សតែមួយ ឬពហុបក្ស។

## ផែនទី ១២ ៖ សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា



## តួនាទីរបស់គណៈកម្មាធិការ/គណៈកម្មការ

អញ្ញតិសំខាន់ទី៣នៃការចូលរួមរបស់សភាជាសមាជិកអាយប៉ានៅក្នុងដំណើរការធ្វើច្បាប់ គឺតួនាទីរបស់គណៈកម្មាធិការ/គណៈកម្មការ។ គណៈកម្មាធិការ/គណៈកម្មការគឺជាមធ្យោបាយមួយសម្រាប់សភាក្នុងការបែងចែកការងារដ៏ធំស្មុគស្មាញរបស់សភាទៅជាផ្នែកៗដែលអាចគ្រប់គ្រងបាន។ គណៈកម្មាធិការ/គណៈកម្មការជំរុញឲ្យសមាជិកសមាជិកាសភាយកចិត្តទុកដាក់លើលើវិស័យគោលនយោបាយដែលពួកគេមានឯកទេស និងអភិវឌ្ឍជំនាញឯកទេសនិងចំណេះដឹងរបស់ពួកគេ។គួរតែត្រូវបានកត់សម្គាល់នូវ....

គួរកត់សម្គាល់ថាគណៈកម្មាធិការ/គណៈកម្មការសភាមិនត្រឹមតែចូលរួមក្នុងដំណើរការធ្វើច្បាប់ប៉ុណ្ណោះទេ ថែមទាំងមានតួនាទីសំខាន់ផងដែរក្នុងមុខងារត្រួតពិនិត្យលើការអនុវត្តគោលនយោបាយរបស់រដ្ឋាភិបាល និងការវិភាជមូលនិធិសាធារណៈ។ តាមពិតនៅក្នុងសភា គណៈកម្មាធិការ/គណៈកម្មការមិនចូលរួមច្រើនក្នុងការតាក់តែងច្បាប់ទេ ការងារសំខាន់ៗរបស់គណៈកម្មាធិការ/គណៈកម្មការច្រើនតែជាទូទៅទាក់ទងនឹងការត្រួតពិនិត្យរដ្ឋាភិបាល ការស៊ើបអង្កេត និងការពិនិត្យរបាយការណ៍អំពីបញ្ហាគោលនយោបាយ។ ប៉ុន្តែនៅក្នុងជំពូកនេះ គឺផ្តោតតែលើនីតិវិធីធ្វើច្បាប់ ដូច្នេះតួនាទីធ្វើច្បាប់របស់គណៈកម្មាធិការ/គណៈកម្មការតែមួយប៉ុណ្ណោះដែលត្រូវលើកយកមកពិភាក្សា។

តារាងទី៤ ខាងលើបង្ហាញថា សភាដែលមានតួនាទីច្រើនជាងគេក្នុងដំណើរការធ្វើច្បាប់នៅក្នុងអាយប៉ា គឺសភាក្នុងប្រព័ន្ធប្រធានាធិបតីនិយមពហុបក្ស ដូចជាប្រទេសឥណ្ឌូណេស៊ី និងហ្វីលីពីន។ សភាទាំងនេះមិនត្រឹមតែផ្តួចផ្តើមនិងធ្វើសេចក្តីស្នើច្បាប់ប៉ុណ្ណោះទេ ថែមទាំងស្នើធ្វើវិសោធនកម្មច្បាប់របស់រដ្ឋាភិបាលជារឿយៗផងដែរ។ ដោយសារតែការធ្វើសេចក្តីស្នើច្បាប់ និងការស្នើធ្វើវិសោធនកម្ម គឺមានការពិបាកក្នុងការសម្រេចឲ្យបាននៅក្នុងសម័យ

តារាងទី២. សភាអាយប៉ា ៖ ឯកបក្ស គណបក្សតែមួយគ្រប់គ្រងផ្តាច់មុខ និងសមាសភាពពហុបក្ស

| បក្សតែមួយ/ រាជានិយម | គណបក្សតែមួយគ្រប់គ្រងផ្តាច់មុខ | ពហុបក្ស |
|---|---|---|
| ប្រ៊ុយណេ<br>វៀតណាម<br>ឡាវ | កម្ពុជា<br>ម៉ាឡេស៊ី *<br>មីយ៉ាន់ម៉ា (ចាប់ពីឆ្នាំ២០១០)<br>សិង្ហបុរី | ឥណ្ឌូនេស៊ី<br>ហ្វីលីពីន<br>ថៃ (មុនឆ្នាំ២០១៤) |

* បន្ទាប់ពីការបោះឆ្នោតចុងក្រោយ (ខែឧសភា ឆ្នាំ២០១៨) គណបក្សសម្ព័ន្ធប៉ាកាតាន់ហារ៉ាបាន់ the Pakatan Harapan (សម្ព័ន្ធភាពដើម្បីក្តីសង្ឃឹម) របស់អតីតនាយករដ្ឋមន្ត្រី Mahathir Mohamad បានបញ្ចប់ការកាន់កាប់អំណាចអស់រយៈពេល ៦១ឆ្នាំ របស់បារីសានជាតិ (រណសិរ្សជាតិ)។

តារាងទី៣. សភាជាសមាជិកអាយប៉ា ៖ ក្របខ័ណ្ឌរដ្ឋធម្មនុញ្ញ និងសមាសភាពគណបក្ស

| | បក្សតែមួយ/ រាជានិយម | គណបក្សតែមួយមានប្រៀបផ្តាច់មុខ | គណបក្សតែមួយមានប្រៀបផ្តាច់មុខ |
|---|---|---|---|
| សភានិយម | ព្រុយណេ<br>វៀតណាម<br>ឡាវ | កម្ពុជា<br>ម៉ាឡេស៊ី *<br>សិង្ហបុរី | ថៃ (មុនឆ្នាំ២០១៤) |
| ប្រធានាធិបតីនិយម | | មីយ៉ាន់ម៉ា<br>(ចាប់ពីឆ្នាំ២០១០) | ឥណ្ឌូនេស៊ី<br>ហ្វីលីពីន |

* បន្ទាប់ពីការបោះឆ្នោតចុងក្រោយ (ខែឧសភា ឆ្នាំ២០១៨) គណបក្សសម្ព័ន្ធប៉ាកាតាន់ហារ៉ាបាន់ the Pakatan Harapan (សម្ព័ន្ធភាពដើម្បីក្តីសង្ឃឹម) របស់អតីតនាយករដ្ឋមន្ត្រី Mahathir Mohamad បានបញ្ចប់ការកាន់កាប់អំណាចរយៈពេល ៦១ឆ្នាំ របស់បារីសានជាតិ (រណសិរ្សជាតិ)។

ផែនទី ១៣ ៖ សាធារណរដ្ឋហ្វីលីពីន




ជំពូកទី
០៦

សភានៃរដ្ឋ ជាសមាជិកអាស៊ាន

សភាជាសមាជិកអាស៊ាន (AIPA) ៖ ប្រវត្តិ សមាសភាព និងតួនាទី

តារាង ៤៖ សភាជាសមាជិកអ៉ាយប៉ា៖ លក្ខណៈនៃការចូលរួមរបស់សភាក្នុងដំណើរការធ្វើច្បាប់ តាមក្របខ័ណ្ឌរដ្ឋធម្មនុញ្ញ និងសមាសភាពគណបក្ស

| | ឯកបក្ស / រាជានិយម<br><br>ប្រ៊ុយណេ ដារូសាឡឹម<br>វៀតណាម<br>ឡាវ | គណបក្សតែមួយ មានប្រៀបផ្ដាច់មុខ សភានិយម<br><br>កម្ពុជា<br>ម៉ាឡេស៊ី<br>សិង្ហបុរី | គណបក្សតែមួយ មានប្រៀបផ្ដាច់មុខ ប្រធានាធិបតីនិយម<br><br>មីយ៉ាន់ម៉ា (ចាប់ពីឆ្នាំ២០១០) | ពហុបក្ស<br><br>សភានិយម<br>ថៃ (មុនឆ្នាំ២០១៤) | ពហុបក្ស ប្រធានាធិបតីនិយម<br><br>ឥណ្ឌូនេស៊ី<br>ហ្វីលីពីន |
|---|---|---|---|---|---|
| ត្រួតពិនិត្យ គោលនយោបាយ | កម្រ | លុះត្រាតែគណបក្សប្រឆាំងមានតំណាងគ្រប់គ្រាន់ | ម្ដងម្កាល | ភាគច្រើនធ្វើឡើងដោយគណបក្សប្រឆាំង | ជាញឹកញាប់ |
| ផ្ដល់យោបល់ និងធាតុចូលបច្ចេកទេស | មាន | មាន | មាន | មាន | មាន |
| រិះគន់ និង ជជែកដេញដោល | កម្រ | លុះត្រាតែគណបក្សប្រឆាំងមានតំណាងគ្រប់គ្រាន់ | ម្ដងម្កាល | ភាគច្រើនធ្វើឡើងដោយគណបក្សប្រឆាំង | ជាញឹកញាប់ |
| ការបង្កើតជម្រើសគោលនយោបាយ | ការបង្កើតជម្រើសគោលនយោបាយ | លុះត្រាតែគណបក្សប្រឆាំងមានតំណាងគ្រប់គ្រាន់ | ម្ដងម្កាល | ភាគច្រើនធ្វើឡើងដោយគណបក្សប្រឆាំង | ជាញឹកញាប់ |
| ផ្ដួចផ្ដើម ឬ រៀបចំសេចក្ដីស្នើច្បាប់ | គ្មាន | កម្រ | មាន | គ្មាន | មាន |

ប្រជុំពេញអង្គ ជាធម្មតាកិច្ចការនេះត្រូវបានធ្វើប្រតិភូកម្មទៅឲ្យគណៈកម្មាធិការ/គណៈកម្មការ។ ដូច្នេះគណៈកម្មាធិការ/គណៈកម្មការនៃអង្គនីតិប្បញ្ញត្តិនៅក្នុងប្រព័ន្ធប្រធានាធិបតីនិយម ជាទូទៅជាយន្តការដែលមានឥទ្ធិពលខ្លាំងក្នុងការកំណត់ជោគវាសនានៃសេចក្ដីស្នើ/សេចក្ដីព្រាងច្បាប់ទាំងលើខ្លឹមសារ និងលើការសម្រេចអនុម័តឬមិនអនុម័ត។

ផ្ទុយទៅវិញ តួនាទីរបស់គណៈកម្មាធិការ/គណៈកម្មការក្នុងការធ្វើសេចក្ដីស្នើច្បាប់ និងធ្វើវិសោធនកម្មសេចក្ដីព្រាងច្បាប់នៅក្នុងសភានៃប្រព័ន្ធសភានិយមគឺនៅមានកម្រិត ជាពិសេសសភាឯកបក្ស ឬសភាដែលមានគណបក្សតែមួយដែលមានប្រៀបផ្ដាច់មុខ។ ជាធម្មតានីតិវិធីនៃការធ្វើច្បាប់នៅក្នុងសភាបែបនេះជាផ្លូវការមានការជជែកពិភាក្សានៅក្នុងកំរិតគណៈកម្មាធិការ/គណៈកម្មការ (committee stage) នៅក្នុងដំណើរការធ្វើច្បាប់ ប៉ុន្តែខ្លឹមសារគោលនយោបាយជាមូលដ្ឋាន និងការប្រើពាក្យពេចន៍នៅក្នុងកថាខណ្ឌនៃសេចក្ដីព្រាងច្បាប់កម្រផ្លាស់ប្ដូរណាស់ នៅក្នុងដំណាក់កាលនៃកិច្ចពិភាក្សានៅកម្រិតគណៈកម្មាធិការ/គណៈកម្មការ។ នៅកម្រិតគណៈកម្មាធិការ/គណៈកម្មការអាចមានឱកាសរៀបចំឲ្យមានពិគ្រោះយោបល់ជាសាធារណៈដើម្បីប្រមូលធាតុចូលលើសេចក្ដីព្រាងច្បាប់ ប៉ុន្តែជាទូទៅសេចក្ដីព្រាងច្បាប់ត្រូវបានព្រាងដោយក្រសួងរបស់រដ្ឋាភិបាលហើយកិច្ចពិគ្រោះយោបល់សាធារណៈភាគច្រើនត្រូវបានបញ្ចប់ក្នុងអំឡុងពេលដំណើរការធ្វើសេចក្ដីព្រាងច្បាប់ដោយសាមីក្រសួងរួចទៅហើយ។

## ផែនទី ១៤ ៖ សាធារណរដ្ឋសិង្ហបុរី



ប្រាកដណាស់ ក្នុងចំណោមប្រទេសអាស៊ានដែលមានប្រព័ន្ធបែបសភានិយមតួនាទីនីតិកម្មរបស់គណៈកម្មាធិការ/គណៈកម្មការនានារបស់សភាមានភាពខុសគ្នាខ្លះ។ ក្នុងករណីប្រទេសវៀតណាម គណៈកម្មាធិការសភាចូលរួមក្នុងការអភិវឌ្ឍកម្មវិធីនីតិកម្ម មុនពេលសេចក្តីព្រាងច្បាប់នានាត្រូវបានដាក់ជូនទៅសភា។ នៅប្រទេសថៃមុនឆ្នាំ២០១៤ ការប្រជុំរបស់គណៈកម្មាធិការ គឺជាកន្លែងដែលមានការជជែកដេញដោលសំខាន់ជាច្រើនរវាងរដ្ឋាភិបាល និងគណបក្សមិននៅក្នុងរដ្ឋាភិបាល។ នៅប្រទេសម៉ាឡេស៊ី សិង្ហបុរី និងប្រ៊ុយណេ ដំណាក់កាលនៅកម្រិតគណៈកម្មាធិការ (committee stage) ក្នុងការពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ ជាញឹកញាប់ធ្វើឡើងក្នុងទម្រង់ជាគណៈកម្មាធិការមួយនៃសភាទាំងមូលតែម្តង ដែលមានប្រសិទ្ធភាពដូចគ្នានឹងការពិនិត្យពិភាក្សានៅក្នុងសម័យប្រជុំពេញអង្គដែរ ព្រោះក្នុងកិច្ចពិភាក្សានេះមានការចូលរួមពីសមាជិកសមាជិកាទាំងអស់ ហើយធ្វើឡើងនៅក្នុងសាលប្រជុំធំរបស់សភា (main chamber)។ នៅក្នុងសភាទាំងនេះមិនមានគណៈកម្មាធិការអចិន្ត្រៃយ៍ (standing legislative committees) ទទួលបន្ទុកផ្នែកជាក់លាក់ណាមួយនៃគោលនយោបាយ ឬមានគណៈកម្មាធិការ «ជ្រើសតាំង» ឬ “ចំពោះកិច្ច” ត្រូវបង្កើតឡើងទេ។ នៅប្រទេសកម្ពុជា គណៈកម្មការអចិន្ត្រៃយ៍ (Permanent Standing Committee) មានតួនាទីធ្វើសេចក្តីសម្រេចចិត្តលើធាតុចូលនៃសេចក្តីព្រាង/សេចក្តីស្នើច្បាប់ ដែលគ្របដណ្តប់លើគណៈកម្មការដែលទទួលបន្ទុកតាមវិស័យ។

## ចំណាប់អារម្មណ៍សរុប

នីតិវិធីធ្វើច្បាប់នៅក្នុងសភាដែលជាសមាជិកអាយប៉ាមានភាពខុសៗគ្នា ដូចគ្នាទៅនឹងភាពខុសៗគ្នារវាងបណ្តារដ្ឋ ដែលជាសមាជិកអាស៊ានដូច្នេះដែរ។ បណ្តាប្រទេសជាសមាជិកអាស៊ានមានរបបនយោបាយខុសៗគ្នារួមមាន៖ របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ របបប្រព័ន្ធសភានិយមបែប Westminster ប្រទេសនីមួយៗមានប្រព័ន្ធសភាបែបផ្សេងៗជាច្រើនរួមមាន សាធារណរដ្ឋសង្គមនិយមឯកបក្សរដ្ឋដែលមានសភាដែលគ្របដណ្តប់ដោយគណបក្សតែមួយមានប្រៀបផ្តាច់មុខ និងសាធារណរដ្ឋដែលមានប្រព័ន្ធប្រធានាធិបតីនិយម។ ការរៀបចំរដ្ឋធម្មនុញ្ញផ្សេងៗគ្នាកេរ្តិ៍ដំណែលនយោបាយនិងប្រវត្តិសាស្ត្រខុសៗគ្នា និងប្រព័ន្ធបោះឆ្នោតផ្សេងៗគ្នា បាននាំឲ្យមានកំរិតនៃភាពខុសគ្នាខ្ពស់រវាងសភា ក្នុងនោះក៏នាំឲ្យមានភាពខុសគ្នានៃទំនាក់ទំនងជាមួយអង្គនីតិប្រតិបត្តិ និងមានភាពខុសៗគ្នាក្នុងការចូលរួមរបស់សភានៅក្នុងដំណើរការធ្វើច្បាប់ផងដែរ។ សភាជាសមាជិកអាយប៉ាមួយចំនួនផ្តួចផ្តើមធ្វើ និងតាក់តែងសេចក្តីស្នើច្បាប់ ខណៈដែលសភាផ្សេងទៀតមានការចូលរួមច្រើនជាងនៅក្នុងដំណើរការនៃការពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ដែលផ្តួចផ្តើមដោយរដ្ឋាភិបាល។ ម៉្យាងវិញទៀតមានសភាជាសមាជិកអាយប៉ាខ្លះផ្តល់ធាតុចូលលើសេចក្តីព្រាងច្បាប់ក្នុងទម្រង់ជាការផ្តល់យោបល់ដល់រដ្ឋាភិបាល ដែលក្នុងករណីនៃការផ្តល់ធាតុចូលគឺផ្តោតសំខាន់លើបញ្ហាបច្ចេកទេស និងការធ្វើឲ្យមានភាពប្រសើរនូវចំណុចលម្អិតនៃគោលនយោបាយ។ តែការផ្តល់ធាតុចូលរបស់សភាជាសមាជិកអាយប៉ាខ្លះទៀតច្រើនមានលក្ខណៈនយោបាយ ហើយពាក់ព័ន្ធច្រើនទៅនឹងការរៀបចំធ្វើសេចក្តីស្នើវិសោធនកម្ម ដែលពេលខ្លះមានការជំទាស់ទៅនឹងអភិក្រមទាំងមូលដែលរដ្ឋាភិបាលព្យាយាមតស៊ូមតិ។

ភាពខុសគ្នានេះគឺជាលក្ខណៈលេចធ្លោមួយរបស់អាស៊ាន ប៉ុន្តែវាក៏ជាបញ្ហាប្រឈមសម្រាប់ការអភិវឌ្ឍជំហររួមលើបញ្ហាគោលនយោបាយនានា និងការពង្រឹងនីតិវិធីសម្រាប់ការអនុវត្តកិច្ចព្រមព្រៀងអាស៊ានផងដែរ។ បញ្ហានេះរួមបញ្ចូលទាំងបញ្ហាដែលទាក់ទងទៅនឹងស្ថាប័ននីតិប្បញ្ញត្តិ និងកិច្ចការរបស់អាយប៉ា ជាសមភាគីនៃស្ថាប័ននីតិប្រតិបត្តិនៅក្នុងអាស៊ាន។ នៅពេលមានការស្នើឡើងនូវអនុសាសន៍សម្រាប់ការអភិវឌ្ឍប្រព័ន្ធអាស៊ាននិងប្រព័ន្ធអាយប៉ាបន្ថែម គោលការណ៍នៃការមិនជ្រៀតជ្រែកចូលក្នុងកិច្ចការផ្ទៃក្នុងរបស់ប្រទេសជាសមាជិក និងការធ្វើសេចក្តីសម្រេចចិត្តផ្អែកលើការមូលមតិគ្នាទាំងស្រុងបានបញ្ជាក់ថា អនុសាសន៍ដែលស្នើឡើងមិនត្រូវដើរផ្ទុយទៅនឹងអ្វីដែលអាចទទួលយកបាន និងអាចសម្រេចបាននៅក្នុងចំណោមរដ្ឋ និងសភាជាសមាជិកឡើយ។

អនុសាសន៍ខាងក្រោម គឺជាអនុសាសន៍ដែលអាចត្រូវបានផ្តួចផ្តើមឡើងដោយសភាខ្លួនឯងផ្ទាល់ ហើយដែលពាក់ព័ន្ធនឹងការវិវឌ្ឍនស្មារតីផ្លាស់ប្តូរថ្មីសម្រាប់ការពង្រឹងអាយប៉ា ក៏ដូចជាការបង្កើតប្រព័ន្ធថ្មី។

> “ ភាពខុសគ្នានេះ គឺជាផ្នែកមួយនៃចំណុចលេចធ្លោរបស់អាស៊ាន ប៉ុន្តែវាក៏ជាបញ្ហាប្រឈមសម្រាប់ការអភិវឌ្ឍជំហររួមលើបញ្ហាគោលនយោបាយផងដែរ។ ”

## ផែនទី ១៥ ៖ ព្រះរាជាណាចក្រថៃ



# ផែនទី ១៦ ៖ សាធារណរដ្ឋសង្គមនិយមវៀតណាម




ជំពូកទី
០៦

សភានៃរដ្ឋ ជាសមាជិកអាស៊ាន

សភាជាសមាជិកអាយប៉ា (AIPA) ៖ ក្របខ័ណ្ឌ សមាសភាព និងតួនាទី

១. លើកកម្ពស់តួនាទីមានស្រាប់របស់ប្រធានសភានៅក្នុងសភាជាសមាជិកសភាអាយប៉ានីមួយៗ ក្នុងការសម្របសម្រួលការផ្ដល់សច្ចាប័ន ការអនុវត្ត និងការត្រួតពិនិត្យ កិច្ចព្រមព្រៀងអាស៊ាន និងសេចក្ដីសម្រេចរបស់អាយប៉ា។ ឧបករណ៍អាស៊ាននិងអាយប៉ា (Asean and AIPA instrument) អាចទទួលបាននូវឋានៈ និងទម្រង់សមស្រប ប្រសិនបើពួកគេត្រូវបានឧបត្ថម្ភ និងគាំទ្រយ៉ាងសកម្មពីថ្នាក់ដឹកនាំនៃសភា (chamber)។

២. ជំរុញការបង្កើតគណៈកម្មាការសម្រាប់កិច្ចការអាស៊ាននៅក្នុងសភាជាសមាជិកសភាអាយប៉ានីមួយៗ។ ប្រការនេះនឹងផ្ដល់សារដ៏រឹងមាំអំពីសារៈសំខាន់ដែលត្រូវព្រមព្រៀងក្នុងកិច្ចការអាស៊ានរួមជាមួយស្ថាប័នដែលមានស្រាប់ព្រមទាំងការទទួលខុសត្រូវសម្រាប់កិច្ចការអន្តរជាតិ សន្ធិសញ្ញា និងទំនាក់ទំនងអន្តរសភា។

៣. គាំទ្រការបញ្ជាក់ជាថ្មីលើតួនាទីរបស់អាយប៉ា Caucus (AIPA Caucus) ជាយន្តការមួយដែលសកម្មភាពលើឧបករណ៍អាស៊ាន និងអាយប៉ា (Asean and AIPA instrument) ត្រូវបានពង្រឹង។

៤. ធ្វើការបែងចែកធនធានបុគ្គលិកនៅក្នុងសភាជាសមាជិកសភាអាយប៉ានីមួយៗ ក្នុងកិច្ចប្រឹងប្រែងគាំទ្រដល់ការអនុវត្តឧបករណ៍អាស៊ាន និងអាយប៉ា។

៥. គាំទ្រដល់ការអភិវឌ្ឍបណ្ដាញបុគ្គលិក ដែលកំពុងលេចចេញជារូបរាងនៅទូទាំងសមាជិកសភាអាយប៉ា។

៦. បង្កើតនីតិវិធីប្រតិបត្តិការស្តង់ដារ (SOP) នៅក្នុងសភាជាសមាជិកអាយប៉ានីមួយៗ សម្រាប់ការធ្វើសេចក្ដីព្រាងនូវសេចក្ដីសម្រេចសម្រាប់វេទិកាអាយប៉ា ដើម្បីលើកកម្ពស់បណ្ដឹងឧទ្ធរណ៍ និងប្រយោជន៍រួមដល់សភាដែលជាសមាជិក។ នីតិវិធីបែបនេះ នឹងបង្កើតសេចក្ដីព្រាង ដែលមានឱកាសកាន់តែច្រើនក្នុងការស្វែងរកកិច្ចព្រមព្រៀងរួម។

៧. ពង្រឹងទំនាក់ទំនងរវាងស្ថាប័នអាយប៉ា និងអាស៊ាន។

## ឯកសារយោង


១. Pesses, A. and Robinne, F. (2015). L’Asie du Sud-Est,ed.,L’Asie du Sud-Est 2015 : bilan, enjeux et perspectives,2 ed. Bangkok: Institut de recherche sur l’Asie du Sud-Est contemporaine.

២. Pesses, A. (2016). L’Asie du Sud-Est,ed.,L’Asie du Sud-Est 2016 : bilan, enjeux et perspectives,3 ed. Bangkok: Institut de recherche sur l’Asie du Sud-Est contemporaine.


**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដែលបកដោយវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិនៃកម្ពុជា (NIDIR)។ អ្នកអានអាចទាញយកអត្ថបទដើមជាភាសាអង់គ្លេសពីគេហទំព័រ៖ https://www.pic.org.kh



អគ្គលេខាធិការដ្ឋានអាស៊ាន នៅ ចាឡាំងស៊ីស៊ីងហ្គាងម៉ាន់ហ្កាវ៉ាយ៉ា ទីក្រុងហ្សាការតា ប្រទេសឥណ្ឌូនេស៊ី

ជំពូកទី

# ០៧

# សមាគមសភា និងអាស៊ាន


ទំ.១៦៤ ៧.១ ការទូតសភា៖ ការអភិវឌ្ឍ និងនិន្នាការថ្មីៗ

ទំ.១៦៦ ៧.២ សភាជាសមាជិកអាយប៉ាដែលចូលរួមក្នុងសមាគមការទូតសភា

ទំ.១៦៨ ៧.៣ កិច្ចប្រជុំ

ទំ.១៦៨ ៧.៣.១ កិច្ចប្រជុំនៅក្នុងឆ្នាំ២០១៩

ទំ.១៧០ ៧.៣.២ កិច្ចប្រជុំនៅក្នុងឆ្នាំ២០២០



*អ្នករួមចំណែក៖ មីហ្សែល ហ្វូសហ្សេ*

*លោក ស្រី គង់ គន្ធា*

*អង់ទាន់ ភីរីឡាត ឆាលឡាហ្យ៍*

# ៧.១ ការទូតសភា៖ ការអភិវឌ្ឍ និងនិន្នាការថ្មីៗ

> “ ពិតជាមានសារៈសំខាន់ណាស់ដែលគួររំលឹកថា ការទូតសភាគឺជាការទូតដោយផ្ទាល់។ សមាជិក សមាជិកាសភា គឺជាតំណាងរបស់ប្រជាពលរដ្ឋ។
> ការទូតសភា គឺជាការទូតរបស់ប្រជាពលរដ្ឋ។
> ដូច្នេះការទូតសភាមានលក្ខណៈស្របច្បាប់គ្រប់កាលៈទេសៈ។
>
> *Ricardo Lagos អតីតប្រធានាធិបតីស៊ីលី*
> *ប្រធាន IPU, សម័យប្រជុំពេញអង្គលើកទី ១០៨ ឆ្នាំ២០០៣* ”

តើការទូតសភាមានន័យដូចម្តេច? ការទូតសភាគឺជាទស្សនទានទើបតែលេចចេញថ្មីមួយ [A] [១] ដែលទទួលបានចំណាប់អារម្មណ៍ស្របជាមួយនឹងការកើនឡើងនៃកិច្ចសហប្រតិបត្តិការអន្តរសភា។

តាមទម្លាប់ការទូត គឺជាបុព្វសិទ្ធិរបស់អង្គនីតិប្រតិបត្តិ ហើយមិនមែនជាសកម្មភាពស្នូលរបស់សភានោះទេ។ ការចរចាគឺជាការងាររបស់មនុស្សម្នាក់ ចំណែកឯការពិភាក្សាគឺជាការងាររបស់មនុស្សច្រើននាក់។ ដូចនេះ គេមិនគួរមានការយល់ច្រលំរវាងការងារទាំងពីរនេះទេ។

ការទូតសភាសំដៅទៅលើសកម្មភាពការទូតរបស់សន្និបាតសភាទាំងមូល ឬដោយសមាជិក សមាជិកាសភាមួយចំនួននៅក្នុងវិស័យទំនាក់ទំនងអន្តរជាតិ។ វាជាការបំពេញបន្ថែមដល់ការទូតអធិបតេយ្យ ឬការទូតផ្នែកនីតិប្រតិបត្តិ និងជាផ្នែកដ៏សំខាន់មួយនៃគោលនយោបាយការបរទេស [B]។

បើតាមន័យចង្អៀតការទូតសភាមិនរាប់បញ្ចូលសកម្មភាពការទូតនៅក្នុងអង្គការអន្តរជាតិធំៗមួយចំនួនដែលរៀបចំឡើងស្រដៀងនឹងសន្និបាតសភា (អង្គការសហប្រជាជាតិ អង្គការយូណេស្កូ) នោះទេ។ វាជាការពិពណ៌នាពីសកម្មភាពការទូតនៃឥស្សរជនសភា ឬស្ថាប័នសភាតូចៗមួយចំនួនដូចជាក្រុមមិត្តភាពជាដើម។

និយមន័យទូលាយជាងនេះរួមបញ្ចូលមធ្យោបាយនៃសកម្មភាពរបស់សន្និបាតសភា និងទំនាក់ទំនងអន្តរជាតិមួយដែលសកម្មភាពការទូតរបស់រដ្ឋមានពាក់ព័ន្ធទៅនឹងនីតិវិធីសភា ហើយអាចត្រូវបំពេញបន្ថែមដោយសកម្មភាពជាក់លាក់បន្ថែមទៀត។ នៅក្នុងប្រទេសជាច្រើន រដ្ឋមន្ត្រីការបរទេសឬរដ្ឋមន្ត្រីការពារជាតិអាចត្រូវហៅឲ្យមកឆ្លើយនៅមុខគណៈកម្មការចំពោះកិច្ចរបស់សភា ហើយគណៈប្រតិភូសភាប្រចាំនៅប្រទេសនានាអាចដាក់របាយការណ៍ជូនអង្គនីតិប្រតិបត្តិ។ ឧបករណ៍ទាំងនេះ (សវនាការ គណៈប្រតិភូ) គឺជាការផ្សារភ្ជាប់គ្នារវាងនយោបាយក្នុងស្រុក (វិស័យចម្បងនៃសកម្មភាពរបស់សភា) និងគោលនយោបាយការបរទេស។

ភាពខុសគ្នាគួរតែត្រូវបែងចែកឲ្យដាច់រវាងដំណើរការផ្លូវការ និងក្រៅផ្លូវការ។

ដំណើរការផ្លូវការរួមមាន ការផ្តល់សច្ចាប័នលើសន្ធិសញ្ញាអន្តរជាតិ និងនីតិវិធីជាក់លាក់ផ្សេងៗ។ ពេលខ្លះសភាបានបដិសេធក្នុងការផ្តល់សច្ចាប័នលើសន្ធិសញ្ញាមួយ (ឧទាហរណ៍ដូចជា សភាអាមេរិកមិនបានផ្តល់សច្ចាប័នលើសន្ធិសញ្ញា Versailles នៅឆ្នាំ១៩១៩)។ រដ្ឋធម្មនុញ្ញជាតិកំណត់វិសាលភាពនៃការផ្តល់សច្ចាប័នរបស់សភាដែលអាចមានលក្ខណៈទូលំទូលាយ ឬចង្អៀត ហើយរួមបញ្ចូលទាំងសន្ធិសញ្ញាសន្តិភាព និងកិច្ចព្រមព្រៀងនានាទាក់ទងនឹងសណ្តាប់ធ្នាប់អន្តរជាតិផងដែរ។

នីតិវិធីរបស់សភារាប់ចាប់ពីការស្នើសុំពន្យារពេលការត្រួតពិនិត្យអត្ថបទច្បាប់រហូតដល់ការផ្ទៀងផ្ទាត់ការអនុលោមតាមរដ្ឋធម្មនុញ្ញជាតិនៃច្បាប់នោះ។ នីតិវិធីជាក់លាក់អាចនឹងចាំបាច់សម្រាប់ការចរចានៅក្នុងក្របខ័ណ្ឌតំបន់អាស៊ាន។ នីតិវិធីច្បាប់ទូទៅរួមមាន ការជជែកដេញដោលអំពីថវិកា ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ នីតិវិធីអនុវត្តមុខងារត្រួតពិនិត្យរបស់សភា និងសេចក្តីសម្រេចរបស់សភា។

ដំណើរការក្រៅផ្លូវការនៃការទូតសភាមានលក្ខណៈខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ។ ដំណើរការដែលត្រូវបានគេស្គាល់ច្រើនជាងគេ គឺក្រុមមិត្តភាព។ ក្រុមនេះជួយសម្របសម្រួលការអញ្ជើញ និងកិច្ចប្រជុំរវាងសមាជិកសមាជិកាសភា និងរវាងសមាគមការទូតសភា (AIPA, IPU, APPF ជាដើម)។

ក្រុមមិត្តភាព គឺជាក្រុមរបស់សភាដែលត្រូវបានបង្កើតឡើង ដើម្បីបង្កើត ឬពង្រឹងចំណងមិត្តភាពជាមួយសភាដទៃទៀត។អតីតយុទ្ធជនបារាំង និងអង់គ្លេសបានផ្តួចផ្តើមបង្កើតឲ្យមានអង្គការបែបនេះជាលើកដំបូងបន្ទាប់ពីសង្គ្រាមលោកលើកទី១។ សកម្មភាពរបស់ក្រុមនេះរួមមានដំណើរទស្សនកិច្ច សន្និសីទ និងការថែរក្សាបណ្តាញនៃឥទ្ធិពល និងកិច្ចសន្ទនារវាងក្រុមទាំងនេះជាមួយឥស្សរជនសាធារណៈ។

សាកលភាវូបនីយកម្ម និងការកើនឡើងច្រើននៃវេទិកានានា បានធ្វើឲ្យចំនួននៃការអញ្ជើញ និងកិច្ចប្រជុំកាន់តែកើនឡើងផងដែរ។ ការទូតសភាធ្វើឡើងតាមរយៈប្រធាន និងអគ្គលេខាធិការទាំងឡាយរបស់សភា។

ការទូតអន្តរសភា មានភាពចាំបាច់នៅតាមតំបន់នានានៃពិភពលោក ដែលកំពុងស្ថិតនៅក្នុងដំណើរការនៃការធ្វើសមាហរណកម្ម ដូចជាសហភាពអឺរ៉ុប (EP) និងអាស៊ាន (AIPA)។ សហភាពអន្តរសភា (IPU) និងសភានិយាយភាសាបារាំង (APF) គឺជាអង្គការអន្តរសភាដែលមានលក្ខណៈពិសេសដោយឡែក (sui generis)។

IPU គឺជាអង្គការពិភពលោកនៃសភាជាតិដែលមានអធិបតេយ្យភាព។ អង្គការនេះ គឺជាអង្គការនយោបាយអន្តរជាតិចំណាស់ជាងគេ [C][២] ដែលបានបង្កើតឡើងនៅឆ្នាំ១៨៨៩ និងកើនឡើងពីចំនួនប្រាំបួនប្រទេសនៅឆ្នាំ១៨៨៩ ដល់ ១៧៧ ប្រទេសនៅសព្វថ្ងៃនេះ។ បាវចនារបស់ IPU គឺ «ដើម្បីប្រជាធិបតេយ្យ ដើម្បីគ្រប់គ្នា» និង «សភាល្អប្រសើរ ប្រជាធិបតេយ្យកាន់តែរឹងមាំ» [៣]។

សភានិយាយភាសាបារាំង(បានបង្កើតឡើងជាសមាគមនៅឆ្នាំ១៩៦៧ ហើយបានក្លាយជាសភានៃប្រទេសនិយាយភាសាបារាំងនៅឆ្នាំ១៩៨៩) ប្រមូលផ្តុំសភាចំនួន ៨៧។ គណៈកម្មាធិការរបស់ APF ផ្តោតលើសិទ្ធិ និងសេរីភាព ការកសាងសមត្ថភាពសម្រាប់សភា ពិពិធកម្មនៃវប្បធម៌ និងកិច្ចសន្ទនាអន្តរវប្បធម៌។

ក្នុងការប្រឈមនឹងបញ្ហាសកលបន្ទាន់ដែលកាន់តែការកើនឡើង (អាកាសធាតុ ឃេនឌ័រ ពាណិជ្ជកម្មអន្តរជាតិ សន្តិសុខ ការអភិវឌ្ឍប្រកបដោយចីរភាព) យើងសង្កេតឃើញថា ទម្រង់មួយនៃ “សាកលភាវូបនីយកម្ម” សភាដើរទន្ទឹមគ្នាជាមួយនឹងសាកលភាវូបនីយកម្មសេដ្ឋកិច្ច បច្ចេកវិទ្យា និងវប្បធម៌។

នៅចុងបញ្ចប់ ទោះបីជាពិបាកក្នុងការវាយតម្លៃលទ្ធផលនៃការទូតសភាក៏ដោយ វាច្បាស់ណាស់ថា ការទូតសភាដើរតួតំណាងឲ្យប្រទេសមួយនៅបរទេស និងបង្កើតការផ្សារភ្ជាប់និងទំនុកចិត្តកាន់តែជិតស្និទ្ធរវាងប្រទេសជិតខាងជាមួយនឹងគុណតម្លៃ និងអត្ថប្រយោជន៍ដូចគ្នា។

ពង្រឹងបន្ថែមទៅលើភាពស្របច្បាប់របស់សភា ការទូតសភាខិតខំកាត់បន្ថយឱនភាពប្រជាធិបតេយ្យក្នុងទំនាក់ទំនងអន្តរជាតិ និងនាំមកនូវតថភាពមួយ ដែលត្រូវបានស្វាគមន៍ក្នុងពិភពសាកលភាវូបនីយកម្មថ្មី [៣]។

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដែលបកដោយវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិនៃកម្ពុជា (NIDIR)។ អ្នកអានអាចទាញយកអត្ថបទដើមជាភាសាអង់គ្លេសពីគេហទំព័រ៖ https://www.pic.org.kh ។

# ៧.២ សភាជាសមាជិកអាយប៉ាដែលចូលរួមក្នុងសមាគមការទូតសភា

| សមាគម | គោលបំណង | ឆ្នាំបង្កើត | សភាជាសមាជិក | សភាអាយប៉ាដែលចូលរួម | តំណភ្ជាប់សម្រាប់ព័ត៌មានបន្ថែម |
|---|---|---|---|---|---|
| សន្និបាតអន្តរសភាអាស៊ាន (AIPA) | លើកទឹកចិត្តឲ្យមានការយោគយល់គ្នា កិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងជិតស្និទ្ធក្នុងចំណោមសភាជាសមាជិកក៏ដូចជាសភាជាសមាជិកសង្កេតការណ៍ និងអង្គការសភាផ្សេងទៀត។ មានតួនាទីជាឧបករណ៍ក្នុងការផ្សព្វផ្សាយពីគោលនយោបាយទៅកាន់ប្រជាពលរដ្ឋនៅអាស៊ីអាគ្នេយ៍។ | ១៩៧៧ | ១០ | ទាំងអស់ | http://www.aipasecretariat.org/ |
| វេទិកាសភាអាស៊ីប៉ាស៊ីហ្វិក (APPF) | វេទិកាសន្ទនាប្រមូលផ្តុំសមាជិក សមាជិកាសភាមកពីតំបន់អាស៊ីប៉ាស៊ីហ្វិកដែលមានបំណងពិភាក្សាអំពីបញ្ហាដែលប៉ះពាល់ដល់តំបន់និងសមភាគីរដ្ឋាភិបាលនៅជុំវិញពិភពលោក។ | ១៩៩៣ ការអនុម័តសេចក្តីថ្លែងការណ៍ក្រុងតូក្យូ | ២៧ | កម្ពុជា ឥណ្ឌូនេស៊ី ឡាវ ម៉ាឡេស៊ី ហ្វីលីពីន សិង្ហបុរី ថៃ និងវៀតណាម | http://www.appf27.org.kh/ |
| វេទិកាអាស៊ីសម្រាប់សមាជិកសភាស្តីពីប្រជាជន និងការអភិវឌ្ឍ (AFPPD) | ពង្រឹងបណ្តាញក្នុងតំបន់នៃសមាជិក សមាជិកាសភាដែលប្តេជ្ញាអនុវត្តតាមរបៀបវារៈស្តីពីប្រជាជន និងការអភិវឌ្ឍ ជាពិសេសកម្មវិធីសកម្មភាពនៃសន្និសីទអន្តរជាតិស្តីពីប្រជាជននិងការអភិវឌ្ឍ (ICPD PoA) និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព(SDGs)។ | ១៩៨១ | គណៈកម្មាធិការជាតិនៃសមាជិកសភាចំនួន ២៩(មកពីអាស៊ីកណ្តាល ប៉ាស៊ីហ្វិកខាងកើត ប៉ាស៊ីហ្វិក អាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍) | កម្ពុជា ឥណ្ឌូនេស៊ី ឡាវ ម៉ាឡេស៊ី ហ្វីលីពីន ថៃ និងវៀតណាម | https://www.afppd.org/ |

| សមាគម | គោលបំណង | ឆ្នាំបង្កើត | សភាជាសមាជិក | សភាអាយប៉ាដែលចូលរួម | តំណភ្ជាប់សម្រាប់ព័ត៌មានបន្ថែម |
|---|---|---|---|---|---|
| មហាសន្និបាតសភាអាស៊ី (APA) | លើកកម្ពស់សាមគ្គីភាពឆ្ពោះទៅរកគោលបំណងរួមមួយនៃសន្តិភាពនិងក្របខ័ណ្ឌជាក់លាក់មួយសម្រាប់កិច្ចសហប្រតិបត្តិការក្នុងតំបន់ដើម្បីពង្រឹងការការពារសិទ្ធិមនុស្សនិងប្រជាធិបតេយ្យ។ | ២០០៦ | សភាជាសមាជិកចំនួន ៤២ និងអ្នកសង្កេតការណ៍ចំនួន ១៦ | កម្ពុជា ឥណ្ឌូនេស៊ី ឡាវ ម៉ាឡេស៊ី ហ្វីលីពីន សិង្ហបុរី ថៃ និងវៀតណាម | http://www.asianparliament.org/ |
| មហាសន្និបាតសភាហ្វ្រង់កូហ្វូនី (PAF) | វេទិកាសន្ទនានយោបាយសម្រាប់ក្រុមសភានិយាយភាសាបារាំងក្នុងការជំរុញផលប្រយោជន៍ទៅវិញទៅមក នីតិរដ្ឋ កិច្ចសហប្រតិបត្តិការ សាមគ្គីភាពប្រជាធិបតេយ្យ និងការលើកកម្ពស់តួនាទីអន្តរជាតិរបស់សភា។ | ១៩៦៧ | សភា ឬអង្គការសភាចំនួន ៧៨ | កម្ពុជា ឡាវ និងវៀតណាម | http://apf.francophonie.org/ |
| សមាគមសភានៃប្រទេស Common-wealth (CPA) | ផ្សារភ្ជាប់ អភិវឌ្ឍ លើកកម្ពស់ និងគាំទ្រសមាជិកសភានិងជំនួយការរបស់ពួកគេដើម្បីកំណត់នូវចំណុចគោលនៃអភិបាលកិច្ចល្អនិងការអនុវត្តគុណតម្លៃ ដ៏យូរអង្វែងរបស់ប្រទេស Commonwealth។ | ១៩១១ | សភាចំនួន ៦៦(មិនរាប់បញ្ចូលសភាថ្នាក់ក្រោមជាតិ) | ម៉ាឡេស៊ី និងសិង្ហបុរី | http://www.cpahq.org |
| សហភាពអន្តរសភា (IPU) | ការពារនិងកសាងប្រជាធិបតេយ្យជាសកលតាមរយៈកិច្ចសន្ទនានិងសកម្មភាពជាក់ស្តែង។ | ១៨៨៩ | សភាជាសមាជិកចំនួន ១៧៨ និងសមាជិកមិនពេញសិទ្ធិចំនួន ១២ | ទាំងអស់ លើកលែងតែព្រុយណេ | https://www.ipu.org/ |

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដែលបកដោយវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិនៃកម្ពុជា (NIDIR)។ អ្នកអានអាចទាញយកអត្ថបទដើមជាភាសាអង់គ្លេសពីគេហទំព័រ៖ https://www.pic.org.kh ។

## ៧.៣ កិច្ចប្រជុំ

### ៧.៣.១ កិច្ចប្រជុំនៅក្នុងឆ្នាំ២០១៩

| ល.រ | សមាគម | កិច្ចប្រជុំនៅក្នុងឆ្នាំ២០១៩ |
|---|---|---|
| ១ | AIPA | • ប្រទេសថៃបានធ្វើជាម្ចាស់ផ្ទះមហាសន្និបាតអាយប៉ាលើកទី ៤០ ចាប់ពីថ្ងៃទី ២៥ ដល់ថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០១៩ នៅទីក្រុងបាងកក។ |
| ២ | APPF | • ប្រទេសកម្ពុជាបានធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំប្រចាំឆ្នាំ APPF ចាប់ពីថ្ងៃទី ១៤ ដល់ថ្ងៃទី ១៧ ខែមករា ឆ្នាំ២០១៩ នៅខេត្តសៀមរាប។ |
| ៣ | AFPPD | • មិនមានព្រឹត្តិការណ៍ក្នុងឆ្នាំ២០១៩។ |
| ៤ | APA | • កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ APA ស្តីពីកិច្ចការសង្គមនិងវប្បធម៌ឆ្នាំ២០១៩ នៅថ្ងៃទី ១២-១៥ ខែកុម្ភៈ ឆ្នាំ២០១៩ នៅទីក្រុងបាងកក។<br>• កិច្ចប្រជុំសម្របសម្រួល APA ស្តីពីកិច្ចការបន្ថែមរបស់ IPU លើកទី ១៤០ នៅថ្ងៃទី៦ ខែមេសា ឆ្នាំ២០១៩ នៅទីក្រុងដូហា។<br>• កិច្ចប្រជុំនៃគណៈកម្មាធិការអចិន្ត្រៃយ៍ស្តីពីសេដ្ឋកិច្ចនិងការអភិវឌ្ឍប្រកបដោយចីរភាពនៅថ្ងៃទី ១៨-២១ ខែមេសា ឆ្នាំ២០១៩ នៅទីក្រុង ណារ៉្យាន-ម៉ា(Naryan-Mar) ប្រទេសរុស្ស៊ី។<br>• កិច្ចប្រជុំនៃគណៈកម្មាធិការអចិន្ត្រៃយ៍ស្តីពីកិច្ចការនយោបាយនៅថ្ងៃទី ២៥-២៨ ខែមិថុនា ឆ្នាំ២០១៩ នៅទីក្រុងអ៊ីហ្វាហាន (Isfahan) ប្រទេសអ៊ីរ៉ង់។<br>• កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ស្តីពីថវិកា និងផែនការនៅថ្ងៃទី ៣-៥ ខែកញ្ញា ឆ្នាំ២០១៩ នៅទីក្រុងបាដាដ។<br>• កិច្ចប្រជុំលើកទី១ នៃក្រុមប្រឹក្សាប្រតិបត្តិ នៅថ្ងៃទី ២៥-២៨ ខែតុលា ឆ្នាំ២០១៩ នៅទីក្រុង រីស(Rize) ប្រទេសតួកគី។<br>• ប្រជុំពេញអង្គរបស់ APA លើកទី ១២ នៅថ្ងៃទី ១៣-១៨ ខែធ្នូ ឆ្នាំ២០១៩ នៅទីក្រុង អង់តាលីយ៉ា (Antalya) ប្រទេសតួកគី។ |
| ៥ | PAF | • កិច្ចប្រជុំបណ្តាញសមាជិកសភាស្ត្រី នៅថ្ងៃទី ២៤-២៨ ខែកុម្ភៈ ឆ្នាំ២០១៩ ប្រទេសវៀតណាម។<br>• កិច្ចប្រជុំគណៈកម្មការអប់រំ ការទំនាក់ទំនង និងវប្បធម៌ នៅថ្ងៃទី ២៤-២៨ ខែកុម្ភៈ ឆ្នាំ២០១៩ ប្រទេសវៀតណាម។<br>• កិច្ចប្រជុំគណៈកម្មការនយោបាយ នៅថ្ងៃទី ៥-៦ ខែមីនា ឆ្នាំ២០១៩ប្រទេសជីប៊ូទី(Djibouti)។<br>• កិច្ចប្រជុំគណៈកម្មការកិច្ចការសភា នៅថ្ងៃទី ២៦-២៨ ខែមេសា ឆ្នាំ២០១៩ ប្រទេសកាណាដា។<br>• កិច្ចប្រជុំគណៈកម្មការកិច្ចសហប្រតិបត្តិការនិងអភិវឌ្ឍន៍ នៅថ្ងៃទី៣-៤ ខែឧសភា ឆ្នាំ២០១៩ រាជធានីភ្នំពេញ។ |
| ៦ | CPA | • សន្និសីទ CPA លើកទី៤៨ស្តីពី កោះអង់គ្លេស និងតំបន់មេឌីទែរ៉ាណេលើកទី ផ្លូវភីធី ផត (Peter Port) កោះគឺនស៊ី (Guernsey) នៅថ្ងៃទី១៩-២២ ខែឧសភា ឆ្នាំ២០១៩។<br>• សន្និសីទប្រចាំឆ្នាំនៃតំបន់ការីបៀន អាម៉េរិក និងអាត្លង់ទិចនៃសមាគមសភារបស់ប្រទេស Commonwealth កំពង់ផែអេស្ប៉ាញ ប្រទេស ទ្រីនីដាដនិងតូបាហ្គោTrinidad and Tobago នៅថ្ងៃទី១២-១៩ ខែកក្កដា ឆ្នាំ២០១៩។<br>• សន្និសីទសភារបស់ប្រទេស Commonwealth (CPC) លើកទី ៦៤ ទីក្រុងកាំប៉ាឡា ប្រទេសអ៊ូហ្គង់ដា នៅខែកញ្ញា ឆ្នាំ២០១៩ (កាលបរិច្ឆេទនឹងកំណត់ពេលក្រោយ)។<br>• សភាយុវជនរបស់ប្រទេស Commonwealth លើកទី ១០ ទីក្រុងញូវដេលី នៅថ្ងៃទី២៤-២៨ ខែវិច្ឆិកា ឆ្នាំ២០១៩។ |

| ល.រ | សមាគម | កិច្ចប្រជុំនៅក្នុងឆ្នាំ២០១៩ |
|---|---|---|
| ៧ | IPU | • សម័យប្រជុំលើកទី ១៥៨ នៃគណៈកម្មាធិការសិទ្ធិមនុស្សនៃសមាជិកសភា នៅថ្ងៃទី២៩ ខែមករា ដល់ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៩ ទីក្រុងហ្សឺណែវ ប្រទេសស្វីស។<br>• កិច្ចប្រជុំលើកទី១ របស់គណៈកម្មាធិការត្រៀមសម្រាប់សន្និសីទពិភពលោកលើកទី ៥ នៃប្រធានសភា នៅថ្ងៃទី៨-៩ ខែកុម្ភៈ ឆ្នាំ២០១៩ ទីក្រុងហ្សឺណែវ ប្រទេសស្វីស។<br>• សវនាការសភាប្រចាំឆ្នាំនៅអង្គការសហប្រជាជាតិ នៅថ្ងៃទី ២១-២២ ខែកុម្ភៈ ឆ្នាំ២០១៩ ទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក។<br>• សម័យប្រជុំលើកទី ៤៤ នៃ គណៈកម្មាធិការអចិន្ត្រៃយ៍ (steering) នៃសន្និសីទសភាស្តីពីអង្គការពាណិជ្ជកម្មពិភពលោក ចាប់ពីខែកុម្ភៈដល់មីនា ឆ្នាំ២០១៩ ទីក្រុងប្រ៊ុចសែល ប្រទេសបែលហ្សិក។<br>• កិច្ចប្រជុំសភាក្នុងឱកាសនៃសម័យប្រជុំលើកទី ៦៣ របស់គណៈកម្មការស្តីពីស្ថានភាពស្ត្រី នៅថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០១៩ ទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក។<br>• មហាសន្និបាតលើកទី ១៤០ និងកិច្ចប្រជុំពាក់ព័ន្ធថ្ងៃទី ៦-១០ ខែមេសា ឆ្នាំ២០១៩ ទីក្រុងដូហា ប្រទេសកាតា។<br>• ព្រឹត្តិការណ៍របស់សភានៅក្នុងវេទិកានយោបាយជាន់ខ្ពស់សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព (HLPF) នៅខែកក្កដា ឆ្នាំ២០១៩ ទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក។<br>• មហាសន្និបាតលើកទី ១៤១ និងកិច្ចប្រជុំពាក់ព័ន្ធថ្ងៃទី ១៣-១៧ ខែតុលា ឆ្នាំ២០១៩ ទីក្រុងបែលក្រាត ប្រទេសសែប៊ី។<br>• កិច្ចប្រជុំលើកទី ២ របស់គណៈកម្មាធិការត្រៀមសម្រាប់សន្និសីទពិភពលោកលើកទី ៥ នៃប្រធានសភា នៅថ្ងៃទី ១៨-១៩ ខែវិច្ឆិកា ឆ្នាំ២០១៩ ទីក្រុងហ្សឺណែវ ប្រទេសស្វីស។<br>• កិច្ចប្រជុំសភាក្នុងឱកាសនៃសន្និសីទស្តីពី ការប្រែប្រួលអាកាសធាតុរបស់អង្គការសហប្រជាជាតិលើកទី ២៥ (COP25) នៅថ្ងៃទី ១០ ខែធ្នូ ឆ្នាំ២០១៩ ទីក្រុងម៉ាឌ្រីត ប្រទេសអេស្ប៉ាញ។ |

## អាណត្តិជោគជ័យតាមរយៈភាពជាដៃគូយូរអង្វែង

ដោយទទួលស្គាល់ពីតួនាទីសំខាន់របស់វិទ្យាស្ថានសភាកម្ពុជា ក្នុងការជួយគាំទ្រដល់ការលើកកម្ពស់សមត្ថភាពរបស់មន្ត្រី នៃសភាជាសមាជិកអាយប៉ា សេចក្តីសម្រេចស្តីពី ការបន្តអនុស្សារណៈនៃការយោគយល់គ្នារវាងអាយប៉ា និងវិទ្យាស្ថានសភាកម្ពុជា (វ.ស.ក) ស្តីពី “កម្មវិធីអភិវឌ្ឍន៍សមត្ថភាពសម្រាប់មន្ត្រី នៃសភាជាសមាជិកអាយប៉ា” ត្រូវបានអនុម័ត នៅក្នុងកិច្ចប្រជុំពេញអង្គលើកទី២ នៃមហាសន្និបាតលើកទី ៤០ របស់អាយប៉ា នៅទីក្រុងបាងកក ប្រទេសថៃ កាលពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩ ។

ដោយទទួលបានការលើកទឹកចិត្តតាមរយៈការផ្តល់សេចក្តីទុកចិត្តពីសភាជាសមាជិកអាយប៉ា វិទ្យាស្ថានសភាកម្ពុជាបន្តប្តេជ្ញាចិត្តឲ្យក្លាយជាមជ្ឈមណ្ឌលឈានមុខក្នុងការជួយអភិវឌ្ឍសភានៅក្នុងតំបន់ តាមរយៈការជួយគាំទ្រ និងជួយពង្រឹងសមត្ថភាពរបស់មន្ត្រីសភា ការជួយជំរុញឲ្យមានការចែករំលែកចំណេះដឹង បទពិសោធន៍ និងការអនុវត្តល្អៗ ដើម្បីជួយលើកកម្ពស់ការអនុវត្តការងាររបស់សភាឲ្យកាន់តែប្រសើរ ជាពិសេសសម្រាប់សភាកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា ។

**កាលបរិច្ឆេទការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដែលបកដោយវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិនៃកម្ពុជា (NIDIR)។ អ្នកអានអាចទាញយកអត្ថបទដើមជាភាសាអង់គ្លេសពីគេហទំព័រ៖ https://www.pic.org.kh ។

## ៧.៣.២ កិច្ចប្រជុំនៅក្នុងឆ្នាំ២០២០

នៅឆ្នាំ២០២០ ពិភពលោកបានជួបប្រទះនឹងបញ្ហាប្រឈមនៃជំងឺកូវីដ-១៩ ដែលមិនធ្លាប់មានពីមុនមក ហើយជាវិបត្តិមួយដែលបានធ្វើឲ្យអ្វីដែលយើងធ្លាប់ដឹង និងធ្លាប់ធ្វើមានការក្រឡាប់ចាក់អស់។ ការផ្លាស់ប្តូរដ៏ធំសម្បើមនេះបានបង្ខំឲ្យយើងសម្របខ្លួន កែប្រែឡើងវិញជាថ្មី និងគិតរកវិធីថ្មីសម្រាប់ការរស់នៅ និងសម្រាប់ធ្វើការ។

សភាដែលមានតួនាទីយ៉ាងសំខាន់នៅក្នុងការឆ្លើយតប និងប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាតសកលនេះក៏ចាំបាច់ត្រូវធ្វើការកែសម្រួលនូវរបៀបបំពេញការងារ និងកែសម្រួលសកម្មភាពដែលបានគ្រោងទុករបស់ខ្លួនដែរ។ កិច្ចប្រជុំការទូតសភាមួយចំនួនដែលគ្រោងរៀបចំក្នុងឆ្នាំ២០២០ត្រូវបានធ្វើឡើងតាមផែនការ ខណៈដែលកិច្ចប្រជុំខ្លះត្រូវបានពន្យារពេល និងផ្សេងទៀតត្រូវបានកែប្រែទៅជាព្រឹត្តិការណ៍ដែលធ្វើឡើងពីចម្ងាយដោយប្រើប្រាស់បច្ចេកវិទ្យាដូចជាការប្រជុំតាមប្រព័ន្ធទូរគមនាគមន៍ជាដើម។

| ល.រ | សមាគម | កិច្ចប្រជុំនៅក្នុងឆ្នាំ២០២០ |
|---|---|---|
| ១ | AIPA | ប្រទេសវៀតណាមបានធ្វើជាម្ចាស់ផ្ទះមហាសន្និបាតអាយប៉ាលើកទី ៤១ នៅនៅថ្ងៃទី ០៨-១០ ខែកញ្ញាឆ្នាំ២០២០ តាមប្រព័ន្ធអនឡាញ ពីទីក្រុងហាឡុង ខេត្ត Quang Ninh។ |
| ២ | APPF | សភាអូស្ត្រាលីបានធ្វើជាម្ចាស់ផ្ទះនៃវេទិកាសភាអាស៊ីប៉ាស៊ីហ្វិកលើកទី ២៨ នៅថ្ងៃទី ១៣-១៦ ខែមករា ឆ្នាំ២០២០ និងបានស្វាគមន៍ប្រតិភូ អ្នកសង្កេតការណ៍ និងសហសេវិកទៅកាន់វិមានសភានៅទីក្រុងកង់បេរ៉ា ដែលជារដ្ឋធានីនៃប្រទេសអូស្ត្រាលី។ |
| ៣ | AFPPD | វេទិកាអាស៊ីនៃសមាជិកសភាស្តីពីប្រជាជន និងការអភិវឌ្ឍ (AFPPD) គឺជាអង្គការក្រៅរដ្ឋាភិបាលថ្នាក់តំបន់ ដែលមានទីស្នាក់ការនៅទីក្រុងបាងកក ប្រទេសថៃ។ បើគិតត្រឹមកាលបរិច្ឆេទនៃការសរសេរអត្ថបទនេះ គឺមិនមានព្រឹត្តិការណ៍ដែលគ្រោងទុកសម្រាប់ឆ្នាំ២០២០ ទេ។ |
| ៤ | APA | ក្រុមការងាររបស់សន្និបាតសភាអាស៊ី (APA) ស្តីពី ឯកសារលក្ខន្តិកៈ ដែលកំណត់ធ្វើឡើងនៅថ្ងៃទី ៨-១១ ខែកុម្ភៈ ឆ្នាំ២០២០ ប្រទេសគុយវ៉ែត ត្រូវបានលើកពេល។<br>សម័យប្រជុំពេញអង្គ APA ដែលនៅក្នុងឆ្នាំ២០២០នេះ គឺជាកិច្ចប្រជុំលើកទី ១៣ ជាទូទៅធ្វើឡើងក្នុងខែធ្នូ។ |
| ៥ | ASEP | ប្រទេសកម្ពុជាបានត្រៀមធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុបលើកទី ១១ ដោយរំពឹងថាមានការចូលរួមពីតំណាងសភាជាសមាជិក ចំនួន ៥២ ក្នុងកិច្ចប្រជុំដែលគ្រោងពីថ្ងៃទី២៥-២៨ ខែតុលា ឆ្នាំ២០២០ នៅរាជធានីភ្នំពេញ ប៉ុន្តែព្រឹត្តិការណ៍នេះត្រូវបានលើកពេល។ |
| ៦ | NATO PA | សម័យប្រជុំនិទាឃរដូវនៃសន្និបាតសភាអូតង់ដែលបានគ្រោងរៀបចំឡើងនៅទីក្រុងគៀវ (Kyiv) ប្រទេសអ៊ុយក្រែន ពីថ្ងៃទី ២២-២៥ ខែឧសភា ឆ្នាំ២០២០ ត្រូវបានពន្យារពេល។ ទោះយ៉ាងណាក៏ដោយ សម័យប្រជុំលើកទី ៦៦ (រដូវស្លឹកឈើជ្រុះ) ត្រូវបានរៀបចំឡើងតាមប្រព័ន្ធអនឡាញកាលពីថ្ងៃទី១៨-២៣ ខែវិច្ឆិកា ឆ្នាំ២០២០។ |
| ៧ | PAF | កិច្ចប្រជុំគណៈកម្មការសន្និបាតសភានៃបណ្តាប្រទេសនិយាយភាសាបារាំងត្រូវបានធ្វើឡើងតាមប្រព័ន្ធអនឡាញក្នុងឆ្នាំ២០២០ ខណៈដែលសន្និបាតពេញអង្គលើកទី១៤៦ ដែលគ្រោងធ្វើនៅទីក្រុង Rabat នៃប្រទេសម៉ារ៉ុក ត្រូវបានពន្យារពេលរហូតដល់ចុងខែ មករា ឆ្នាំ២០២១។ |
| ៨ | CPA | សមាគមសភារបស់ប្រទេស Commonwealth បង្កើតឡើងដើម្បីអភិវឌ្ឍន៍ លើកកម្ពស់ និងគាំទ្រសមាជិកសភា និងបុគ្គលិករបស់ខ្លួននៅក្នុងប្រទេស Commonwealth។ សន្និសីទសភារបស់ប្រទេស Commonwealth លើកទី៦៥ ដែលគ្រោងធ្វើឡើងនៅក្រុង Halifax នៃខេត្ត Nova Scotia ប្រទេសកាណាដា ត្រូវបានពន្យារទៅថ្ងៃទី២១-២៧ ខែសីហា ឆ្នាំ២០២១ វិញ។ |
| ៩ | IPU | សន្និបាតនៃ IPU លើកទី ១៤២ ដែលគ្រោងនឹងប្រព្រឹត្តទៅនៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ពីថ្ងៃទី ១៦-២០ ខែមេសា ឆ្នាំ២០២០ ត្រូវបានពន្យារពេលទៅឆ្នាំ២០២១ វិញ ដែលនឹងប្រព្រឹត្តទៅនៅទីក្រុងគីហ្គាលី (Kigali) ប្រទេសរវ៉ាន់ដា (Rwanda) វិញ។ |

## ប្រវត្តិរូបសមាគម

AIPA

**អន្តរសភាអាស៊ាន (AIPA)**

បង្កើតឡើងដំបូងនៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៧៧ ក្នុងនាមជាអង្គការអន្តរសភាអាស៊ាន (AIPO) ដោយមានថ្នាក់ដឹកនាំនៃគណៈប្រតិភូសភាឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សិង្ហបុរី និងថៃ បានចូលរួមសន្និសីទអន្តរសភាអាស៊ានលើកទី ៣ នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន [៤]។

AIPA មានគោលបំណងជំរុញការយោគយល់ កិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងជិតស្និទ្ធក្នុងចំណោមសភាជាសមាជិកនិងរវាងសភានៃប្រទេសដែលមានឋានៈជាអ្នកសង្កេតការណ៍ និងអង្គការសភាដទៃទៀត។

*AIPA ក៏ដើរតួនាទីជាឧបករណ៍ក្នុងការផ្សព្វផ្សាយពីគោលនយោបាយទៅកាន់ប្រជាជននៅអាស៊ីអាគ្នេយ៍ ក្នុងបំណងដើម្បីពន្លឿនការសម្រេចបាននូវសហគមន៍អាស៊ានមួយ។*

## លេខយោង

A. ពាក្យនេះបានបង្កើតឡើងក្នុងពិធីបើកសន្និសីទដែលរៀបចំឡើងនៅប្រទេសបារាំង ឆ្នាំ២០០១ ដោយរដ្ឋសភានិងព្រឹទ្ធសភាជាតិបារាំង។ នៅក្នុងឆ្នាំ២០១១ ទិទានុប្បវត្តិគោលនយោបាយការបរទេស បានដាក់បញ្ចូលពាក្យនេះជាលើកដំបូងក្នុងភាសាអង់គ្លេស ហើយការសិក្សាលម្អិតដំបូងគេបានបោះពុម្ពផ្សាយនៅឆ្នាំ២០១៧។

B. Livre blanc sur la politique étrangère et européenne, Paris 2008. [No [B] translation]

C. រកឃើញដោយអ្នកឈ្នះពានរង្វាន់ណូបែល ២រូប គឺ the Frenchman Frederic Passy និង the Englishman William Randal Cremer។

## REFERENCES


១. Noulas, G. (2011). The role of parliamentary diplomacy in foreign policy. Foreign Policy Journal.

២. Stavridis, S. and Jancic, D. (2017). Parliamentary Diplomacy in European and Global Governance, ed. Leiden.

៣. Péjo, P. (2018). La diplomatie parlementaire, actrice émergente de communications diplomatiques démocratisées. Hermès, La Revue, 81(2), p.81.

៤. AIPA. Profile of AIPA. Available at: https://www.aipasecretariat.org/static_page/detail/1/profile-of-aipa [Accessed 14 August 2019]


**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដែលបកដោយវិទ្យាស្ថានសភាកម្ពុជា (PIC)។
អត្ថបទដើមជាភាសាអង់គ្លេសអាចទាញយកពីគេហទំព័រ៖ https://www.pic.org.kh ។



ផ្លូវអេយស្ម័យយានឆ្លងកាត់នៅស៊ីនហ្គាង ចាយ៉ា ប្រទេសឥណ្ឌូនេស៊ី នៅខាងក្រៅទីក្រុងហ្សាការតា
Tom Fisk

ជំពូកទី

# ០៨

# ទិដ្ឋភាពទូទៅនៃបញ្ហាឆ្លងដែននានានៅក្នុងតំបន់


ទំ.១៧៤ ៨.១ ភាពជាតំណាងរបស់ស្ត្រីនៅក្នុងសភាអាស៊ាន
*ដោយ លោកស្រី គឹម កែវធីតា*

ទំ.១៧៩ ៨.២ ការវិវត្តក្របខ័ណ្ឌគតិយុត្តិស្តីអំពីអាកាសធាតុនៅអាស៊ាន
*ដោយ បណ្ឌិត រតនា ពៅ នូប៊ីត មុនហ្ស៍*

ទំ.១៨៤ ៨.៣ ទេសន្តរប្រវេសន៍ *ដោយ មីហ្សែល ហ្វូសហ្សេ*

ទំ.១៨៦ ៨.៤ ការអប់រំនៅអាស៊ានក្នុងដំណាក់កាលដំបូងនៃបដិវត្តន៍ឧស្សាហកម្មលើកទី ៤ *ដោយ លោក មូសារ អ៊ីស្សាម*

ទំ.១៩០ ៨.៥ សេដ្ឋកិច្ចនិងពាណិជ្ជកម្ម *ដោយ មីហ្សែល ហ្វូសហ្សេ*

ទំ.១៩២ ៨.៦ ហេដ្ឋារចនាសម្ព័ន្ធ *ដោយ មីហ្សែល ហ្វូសហ្សេ*

ទំ.១៩៥ ៨.៧ សន្តិភាព និងសន្តិសុខ *ដោយ មីហ្សែល ហ្វូសហ្សេ*

ទំ.១៩៩ ៨.៨ បញ្ហាផ្សេងៗ

ទំ.១៩៩ ៨.៨.១ អាស៊ានវិវឌ្ឍឆ្ពោះទៅកាន់សេដ្ឋកិច្ចបៃតង និងឌីជីថល
*ដោយ សូ សុវណ្ណារិទ្ធិ*

ទំ.២០៨ ៨.៨.២ សហគ្រាសធុនតូច និងមធ្យមនៅអាស៊ាន
*ដោយ លោក ស្កុត ខេមឺរូន & បណ្ឌិត ឈូ ស្រ៊ុីនាថ*

ទំ.២១០ ៨.៨.៣ ម៉ូដែលថ្មីក្នុងការធ្វើធុរកិច្ច និងកម្លាំងចលករសម្រាប់ប្រទេសក្នុងតំបន់អាស៊ាន
*ដោយ លោក ស្កុត ខេមឺរូន & បណ្ឌិត លី យ៉ាសាក់*

ទំ.២១៣ ៨.៨.៤ ការបណ្តុះបណ្តាលជំនាញ ការចាប់ផ្តើមអាជីវកម្ម និងនវានុវត្តន៍ *ដោយ ហ្វ្រូរិន ហ្សីយើស្ស៍*

ទំ.២១៧ ៨.៨.៥ ហេដ្ឋារចនាសម្ព័ន្ធនិងទីក្រុងឆ្លាតវៃ នៅអាស៊ីអាគ្នេយ៍ *By*
*ដោយ បណ្ឌិត គឹម សុធន*

# ៨.១ ភាពជាតំណាងរបស់ស្ត្រីនៅក្នុងសភាអាស៊ាន

## ទិដ្ឋភាពទូទៅ

ទោះបីជាការពិតស្ត្រីមានចំនួនពាក់កណ្ដាលនៃចំនួនប្រជាជនពិភពលោក ហើយក៏មានការកើនឡើងនូវការទទួលស្គាល់តួនាទីសំខាន់ៗរបស់ស្ត្រីដែលដើរតួនាទីជាអ្នកដឹកនាំទាំងក្នុងវិស័យសាធារណៈ និងឯកជនក៏ដោយ ក៏ស្ត្រីនៅតែមានចំនួនតិចតួចនៅឡើយនៅក្នុងវិស័យទាំងពីរនេះនៅក្នុងពិភពលោកនៅថ្នាក់តំបន់ និងថ្នាក់ជាតិ[១]។ ជាពិសេសទៅទៀតនោះ សភាមានតួនាទីតំណាងឲ្យគ្រប់ផ្នែកទាំងអស់នៃសង្គមប៉ុន្តែសភាភាគច្រើននៅក្នុងពិភពលោកគឺគ្រប់គ្រងដោយបុរស [២,p.៣៨]។ ក្នុងរយៈពេល២០ឆ្នាំកន្លងមកនេះ ចំនួនស្ត្រីនៅក្នុងសភាបានកើនឡើងជិតទ្វេដង ប៉ុន្តែចំនួននេះមានអត្រាត្រឹមតែ២៤,៥% ប៉ុណ្ណោះនៃតំណាងរាស្ត្រទាំងអស់នៅក្នុងសភាទូទាំងពិភពលោក គិតត្រឹមខែតុលា ឆ្នាំ២០១៩ ដែលអត្រានេះកើនឡើងពី ១១,៣% ពីឆ្នាំ១៩៩៥[៣]។ នៅលើពិភពលោកសព្វថ្ងៃនេះ នៅមានរដ្ឋចំនួន ២៧ទៀត ដែលមានស្ត្រីជាសមាជិកាសភាតិចជាង១០% នៅក្នុងសភាមួយថ្នាក់ ឬសភាជាន់ទាបរួមទាំងរួមទាំងសភាគ្រប់ថ្នាក់ដែលមិនមានសមាជិកសភាជាស្ត្រីសោះតែម្តង[៤]។

នៅក្នុងអាស៊ានភាពជាតំណាងរបស់ស្ត្រីនៅក្នុងជីវិតនយោបាយនៅតែជាបញ្ហាប្រឈមនៅឡើយ។ នៅសភាក្នុងតំបន់ ការចូលរួមរបស់ស្ត្រីជាមធ្យមគឺត្រឹមតែ២០% ប៉ុណ្ណោះដែលទាបជាងកម្រិតមធ្យមរបស់ពិភពលោកនៅឡើយ[៣]។ កង្វះការចូលររបស់ស្ត្រីនៅតាមស្ថាប័ននីតិប្បញ្ញត្តិត្រូវបានលើកឡើងនៅទូទាំងប្រទេសជាសមាជិកអាស៊ាន លើកលែងតែប្រទេសហ្វីលីពីន វៀតណាម និងឡាវ ដែលមានស្ត្រីនៅក្នុងសភានីមួយៗលើសពី២៧%[៣]។ អាស៊ានបានចាត់ថ្នាក់ជាសហគមន៍ដែលមានតំណាងស្ត្រីមិនគ្រប់គ្រាន់នៅក្នុងសភាបើប្រៀបធៀបទៅនឹងសភាអាម៉េរិក អឺរ៉ុប និងអនុតំបន់ អាហ្វ្រិកសាហារ៉ា ប៉ុន្តែអត្រានេះនៅតែខ្ពស់ជាងនៅតំបន់ប៉ាស៊ីហ្វិក និងអារ៉ាប់[៣]។

ក្នុងចំណោមប្រទេសជាសមាជិកអាស៊ានទាំង១០ប្រទេស ហ្វីលីពីនបានបង្ហាញនូវវឌ្ឍនភាពខ្លាំងជាង គេក្នុងការដាក់បញ្ចូលស្ត្រីក្នុងវិស័យនយោបាយ ដែលមានអត្រា២៩,៥% ជាកម្រិតខ្ពស់បំផុតជាងបណ្តាប្រទេសសមាជិកផ្សេងៗទៀត [៣]។ ប្រទេសថៃ ព្រុយណេ មីយ៉ាន់ម៉ា និងប្រទេស

> “ស្ត្រីមានតួនាទីជាអ្នកដឹកនាំនយោបាយ ជួយជំរុញឲ្យមានការដាក់បញ្ចូលស្ត្រីទៅក្នុងទីផ្សារការងារដើម្បីលើកកម្ពស់កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍ”

ម៉ាឡេស៊ីមានភាគរយទាបបំផុតជាបន្តបន្ទាប់គឺ ៤% ៩% ១០% និង១៣%។ ទិន្នន័យចុងក្រោយសម្រាប់ប្រទេសកម្ពុជាបង្ហាញថា ភាពជាតំណាងរបស់ស្ត្រីមានចំនួនប្រហែលជា២០% គឺទាបជាងប្រទេសឥណ្ឌូនេស៊ីបន្តិចប៉ុណ្ណោះដែលមានចំនួន២១%[៣]។ ទោះបីជាភាពជាតំណាងរបស់ស្ត្រីមានអត្រាទាបនៅក្នុងសភាសិង្ហបុរី ព្រុយណេ និងម៉ាឡេស៊ីក៏ដោយ ប៉ុន្តែប្រជាជាតិទាំងនេះទទួលបានចំណាត់ថ្នាក់ខ្ពស់នៅក្នុងសន្ទស្សន៍វិសមភាពយេនឌ័រ (GII) និងសន្ទស្សន៍ការអភិវឌ្ឍធនធានមនុស្ស(HDI)[៥]។ ដោយតែប្រទេសទាំងនេះមានវឌ្ឍនភាពគួឲ្យកត់សម្គាល់ក្នុងការលុបបំបាត់គម្លាតវិសមភាពយេនឌ័រលើចំនុចសំខាន់ៗបី នៃការអភិវឌ្ឍធនធានមនុស្សសុខភាពបន្តពូជ[A] ការពង្រឹងភាពអង់អាច[B] និងស្ថានភាពសេដ្ឋកិច្ច[C] ទាំងស្ត្រី និងបុរស។

ទោះបីជាប្រទេសជាសមាជិកអាស៊ានភាគច្រើនមានវឌ្ឍនភាពល្អក្នុងការរួមបញ្ចូលស្ត្រីក្នុងនយោបាយក៏ដោយក៏នៅតែមានកិច្ចការជាច្រើនទៀតត្រូវតែបន្តធ្វើផងដែរ។ ស្ត្រីនៅតែមានចំនួនតិចតួចនៅឡើយក្នុងសភា នេះបង្ហាញថាស្ត្រីនៅតែមានដំណើរវែងឆ្ងាយទៀតដើម្បីទទួលបានសមភាពក្នុងឆាកនយោបាយ[៦]។ ការកើនឡើងនូវចំនួនស្ត្រីនៅក្នុងសភាធ្វើឲ្យប្រសើរឡើងនូវលទ្ធផលនៃគោលនយោបាយ និងជួយលើកកម្ពស់ការដាក់បញ្ចូលក្រុមជនជាតិភាគតិចទៅក្នុងវិស័យសាធារណៈ ដែលមាននិន្នាការអាចជួយទប់ស្កាត់អំពើពុករលួយ។ លើសពីនេះទៅទៀត ដូចដែលបានបង្ហាញដោយការសិក្សាមួយនាពេលថ្មីៗនេះ ស្តីពី ផលប៉ះពាល់នៃភាពជាតំណាងរបស់ស្ត្រីនៅក្នុងសភា «ស្ត្រីមានតួនាទីជាអ្នកដឹកនាំនយោបាយជំរុញឲ្យមានការដាក់បញ្ចូលស្ត្រីទៅក្នុងទីផ្សារការងារដើម្បីលើកកម្ពស់កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍ»[៧, p.២]។

មិនមានសង្គមណាមួយអាចអភិវឌ្ឍឲ្យអស់សក្តានុពលទេ (ទាំងលើផ្នែកសេដ្ឋកិច្ច នយោបាយ ឬសង្គម) នៅពេលដែលប្រជាពលរដ្ឋពាក់កណ្តាលរបស់ខ្លួនមិនត្រូវបានគេចាត់បញ្ចូលទៅក្នុងគ្រប់សកម្មភាពនៅក្នុងសង្គម (margi-nalized) ហេតុដូច្នេះយើងមិនត្រូវទុកនរណាម្នាក់ចោលនោះឡើយ[៧]។ ការចូលរួមរបស់ស្ត្រីនៅក្នុងសភាមានសារៈសំខាន់ខ្លាំងណាស់ដើម្បីធានាថា ការប្តេជ្ញាចិត្ត និងក្របខ័ណ្ឌសកម្មភាពអន្តរជាតិត្រូវបានយកមករៀបចំជាឧបករណ៍ដែលអាចជឿទុកចិត្តបានសម្រាប់ការប្រមូលផ្តុំសង្គមស៊ីវិល និងរៀបចំគោលនយោបាយ[៨]។ ស្ត្រីហាក់បីដូចជាមានការយកចិត្តទុកដាក់ខ្លាំងលើបញ្ហាសង្គម ជីវភាព និងសុខុមាលភាពនៅក្នុងសហគមន៍របស់ពួកគេ ហើយកត្តាទាំងនេះនឹងត្រូវដាក់បញ្ចូលទៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត។ ស្ត្រីជួយលើកកម្ពស់ការអនុវត្តគោលនយោបាយ និងសកម្មភាពដើម្បីជួយពង្រឹងសហគមន៍ និងលើកទឹកចិត្តឲ្យមានការចូលរួមរបស់ភាគីពាក់ព័ន្ធ ដោយសារស្ត្រីឲ្យតម្លៃទៅលើសារៈសំខាន់នៃប្រាស្រ័យឆ្លើយឆ្លងល្អជាមួយសហគមន៍។ អ្នកចូលរួមជាស្ត្រីតែងមានការលះបង់ ការទទួលខុសត្រូវ និងធ្វើតាមអ្វីដែលពួកគេនិយាយ ដោយធ្វើការជំរុញ និងលើកទឹកចិត្តដល់ស្ត្រីដទៃទៀតឲ្យចូលរួមក្នុងការអភិវឌ្ឍ[៩]។

ហេតុដូច្នេះហើយការចូលរួមរបស់ស្ត្រីក្នុងឆាកនយោបាយមានសារៈសំខាន់ណាស់ក្នុងការជំរុញការធ្វើសេចក្តីសម្រេចចិត្ត ដែលមានភាពជាតំណាង មានបរិយាបន្ន និងប្រសិទ្ធិភាព។ មានភស្តុតាងកាន់តែច្រើនឡើងៗដែលបង្ហាញថា ភាពជាអ្នកដឹកនាំរបស់ស្ត្រីធ្វើឲ្យមានភាពកាន់តែប្រសើរនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តក្នុងឆាកនយោបាយ។ ទោះបីជានៅក្នុងបរិយាកាសស្មុគស្មាញផ្នែកនយោបាយខ្លាំងយ៉ាងក៏ដោយ ក៏ស្ត្រីនៅតែបង្ហាញភាពជាអ្នកដឹកនាំផ្នែកនយោបាយ ដោយស្ត្រីអាចបន្តធ្វើការជាមួយគ្រប់បណ្តាញគណបក្សតាមរយៈក្រុមសមាជិកាសភា និងដើរតួនាំមុខក្នុងការតស៊ូមតិលើបញ្ហាសមភាពយេនឌ័រ ដូចជាការលុបបំបាត់អំពើហិង្សាលើស្ត្រី ការទាមទារឲ្យមានការឈប់សម្រាករបស់ឪពុកម្តាយ និងការឈប់សម្រាកមើលថែទាំកូន ការផ្តល់ប្រាក់សោធននិវត្តន៍ ច្បាប់សមភាពយេនឌ័រ និងការកែទម្រង់ការបោះឆ្នោត[១០]។

លើសពីនេះទៀត ស្ត្រីជាក្បាលម៉ាស៊ីនរបស់រដ្ឋាភិបាល [D] អង្គការរបស់ស្ត្រី (women's organizations) និងបណ្តាញស្ត្រី គឺជាកម្លាំងដ៏មានឥទ្ធិពលក្នុងការប្រមូលផ្តុំ និងលើកកម្ពស់សម្លេងរបស់ស្ត្រីនៅក្នុងឆាកនយោបាយ និងសង្គម ប៉ុន្តែពួកគេតែងតែខ្វះខាតនូវហិរញ្ញប្បទាន។ សម្លេងរបស់ ស្ត្រីវ័យក្មេង និងបុរសក៏មានឥទ្ធិពលសំខាន់ផងដែរក្នុងការធ្វើយោធូបនីយកម្មមណ្ឌលបោះឆ្នោត សម្រាប់ការផ្លាស់ប្តូរ និងក្នុងការជំរុញការចូលរួមរបស់ស្ត្រីក្នុងឆាកនយោបាយឲ្យកាន់តែសកម្ម។

## បញ្ហាប្រឈមដែលមាន ភាពជាតំណាងរបស់ស្ត្រីតិចតួចនៅក្នុងសភាអាស៊ាន

ការបង្កើនការចូលរួមរបស់ស្ត្រីក្នុងឆាកនយោបាយមានបញ្ហាប្រឈមចំពោះមុខមួយចំនួននៅទូទាំងតំបន់។ តាមការវិភាគរបស់ធនាគារអភិវឌ្ឍន៍អាស៊ីបានបង្ហាញថា តំបន់នេះមានការរីកចម្រើនមួយចំនួនឆ្ពោះទៅរកការសម្រេចបាននូវសមភាពនៅក្នុងរយៈពេលពីរទសវត្សរ៍កន្លងទៅនេះ ប៉ុន្តែការផ្លាស់ប្តូរនេះនៅតែមានភាពយឺតយ៉ាវនៅឡើយ[១០]។ ហេតុដូច្នេះហើយ ចាំបាច់ណាស់ក្នុងការកំណត់បញ្ហាប្រឈម និងឱកាសដែលបណ្តាប្រទេសក្នុងតំបន់ជួបប្រទះ ព្រោះថា ប្រទេសនីមួយៗមានបញ្ហាខុសប្លែកពីគ្នាដែលត្រូវដោះស្រាយ។ ក្នុងករណីបណ្តាប្រទេសជាសមាជិកអាស៊ាន បញ្ហាទាំងនោះរួមមាន បទដ្ឋានសង្គម និងគុណតម្លៃ ហើយនឹងឧបសគ្គស្ថាប័ន[១១]។

បទដ្ឋានសង្គម និងគុណតម្លៃតែងតែមានការផ្សារភ្ជាប់ប្រពៃណីជាមួយនឹងបទដ្ឋានយេនឌ័រ តុល្យភាពជីវិតនិងការងារ (work-life Balance) (ការងារគ្រួសារ និងឧបសគ្គពេលវេលា) ឧបសគ្គខាងសេដ្ឋកិច្ចសង្គម កង្វះទំនុកចិត្ត និងការគាំទ្រពីសង្គម និងសមាជិកគ្រួសារ កម្រិតនៃការអប់រំ និងកង្វះព័ត៌មាន[១២]។ ឧបសគ្គផ្នែកស្ថាប័នសំដៅទៅលើគំរូនយោបាយបែបបុរស[E] កង្វះការគាំទ្ររបស់គណបក្ស រួមមានដូចជាការគាំទ្រផ្នែកហិរញ្ញវត្ថុដល់បេក្ខភាពជាស្ត្រី ភាពមានកម្រិតនៃការចូលរួមរបស់តំណាងស្ត្រីទាក់ទងនឹងប្រភេទនៃប្រព័ន្ធបោះឆ្នោត និងការកំណត់ក្នុងរដ្ឋធម្មនុញ្ញ ឬក្នុងគោលនយោបាយរបស់ គណបក្ស ឬក្នុងក្របខ័ណ្ឌច្បាប់ ភាពមានកំណត់នៃបណ្តាញនយោបាយស្ត្រី និងភាពតឹងតែងនៃបទដ្ឋានស្តង់ដា និងលក្ខណៈសម្បត្តិដែលត្រូវអនុវត្តចំពោះស្ត្រី[៧]។

## ជោគជ័យដែលសម្រេចបានក្នុងការលើកកម្ពស់តំណាងរបស់ស្ត្រីនៅក្នុងសភាអាស៊ាន

ទោះបីមានវឌ្ឍនភាពយឺតយ៉ាវក្នុងការបង្កើនចំនួនស្ត្រីជាតំណាងនៅក្នុងសភាអាស៊ានក៏ដោយក៏សហគមន៍អាស៊ានសម្រេចបានសមិទ្ធិផលសំខាន់ៗមួយចំនួនក្នុងការលើកកម្ពស់

សមភាពយេនឌ័រនៅថ្នាក់ជាតិផងដែរ។ សហគមន៍អាស៊ានបានផ្តល់អាទិភាពដល់ការលើកកម្ពស់សមភាពយេនឌ័រការផ្តល់ភាពអង់អាចដល់ស្ត្រី និងកុមារី ហើយបានកំណត់នូវការប្តេជ្ញាចិត្តផ្នែកនយោបាយកម្រិតខ្ពស់ដើម្បីលើកកម្ពស់សិទ្ធិ និងសុខុមាលភាពរបស់ស្ត្រី និងក្មេងស្រី តាមរយៈកិច្ចសហប្រតិបត្តិការក្នុងតំបន់អាស៊ាន និងតាមរយៈគោលនយោបាយ និងកម្មវិធីជាតិ[១៣]។

អាស៊ានបានអនុម័តសេចក្តីប្រកាសស្តីពី សិទ្ធិមនុស្សរបស់ខ្លួនជាមួយនឹងគោលការណ៍ទូទៅដែលចែងថា សិទ្ធិរបស់ស្ត្រីក្នុងចំណោមសិទ្ធិផ្សេងៗទៀត គឺមិនអាចដកហូតបានទេ វាជាផ្នែកមួយដ៏សំខាន់ ហើយក៏មិនអាចកាត់ផ្តាច់ចេញពីសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានផងដែរ [១៣]។ លើសពីនេះទៅទៀត សហគមន៍អាស៊ានបានអនុម័តចក្ខុវិស័យសហគមន៍អាស៊ាន២០២៥ នៅក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី២៧ ក្នុងខែវិច្ឆិកា ឆ្នាំ២០១៥ ដែលចង់បាន «សហគមន៍មួយប្រកបដោយបរិយាបន្នដែលលើកកម្ពស់គុណភាពជីវិត ទទួលបានឱកាសស្មើភាពគ្នាសម្រាប់មនុស្សគ្រប់រូប លើកកម្ពស់និងការពារសិទ្ធិមនុស្ស សិទ្ធិស្ត្រី...» ក្នុងចំណោមចំណុចដទៃទៀត។ ក្នុងពេលជាមួយគ្នានេះដែរ អាស៊ានបានអនុម័តផែនការលម្អិតនៃសហគមន៍វប្បធម៌សង្គមអាស៊ាន (ASCC) ២០២៥ ដែលបានកំណត់នូវវិធានការណ៍យុទ្ធសាស្ត្រ ដែលស្វែងរកការកាត់បន្ថយឧបសគ្គនានាដែលស្ត្រី និងក្មេងស្រីប្រឈម ដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្សនិងធានាឲ្យបាននូវការទទួលបានសមធម៌សម្រាប់ពួកគេទាំងអស់គ្នា[១៤]។

## ទិសដៅបន្ត

ជាជំហានបន្ត ប្រទេសជាសមាជិកអាស៊ានចាំបាច់ត្រូវតែខិតខំប្រឹងប្រែងលើកកម្ពស់ការឆ្លើយតបឲ្យកាន់តែទាន់ពេលវេលាទៅនឹងបញ្ហាយេនឌ័រនៅក្នុងចំណោមអ្នកធ្វើសេចក្តីសម្រេចចិត្ត និងក្នុងស្ថាប័ន ដើម្បីបង្កើនការចូលរួមរបស់ស្ត្រីនៅក្នុងសភា។ ការដាក់បញ្ចូលស្ត្រីពិតជារួមចំណែកដល់ការគាំទ្រថ្នាក់ជាតិ តាមរយៈការជំរុញកិច្ចខិតខំប្រឹងប្រែងបង្កើនថវិកាជាតិ ដើម្បីគាំទ្រជាមូលនិធិដល់គំនិតផ្តួចផ្តើមយេនឌ័រ និងជួយគណៈកម្មាធិការក្នុងការបន្តនិន្នាការនៃការតាមដានត្រួតពិនិត្យការអនុវត្តរបស់សហគមន៍ អាស៊ានពាក់ព័ន្ធនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ការលើកកម្ពស់សមភាពយេនឌ័រ គឺជាកត្តាស្នូលក្នុងការសម្រេចឲ្យបាននូវចក្ខុវិស័យសហគមន៍អាស៊ានឆ្នាំ២០២៥។ បណ្តាប្រទេសជាសមាជិកទាំងអស់ត្រូវធានាឲ្យមានការចូលរួមរបស់ស្ត្រីនិងក្មេងស្រីគ្រប់រូប។ ដូច្នេះហើយជំហានសំខាន់គឺត្រូវពង្រឹងឲ្យមានគណនេយ្យភាព ក្នុងការអនុវត្តតាមការប្តេជ្ញាចិត្តដើម្បីលើកកម្ពស់សមភាពយេនឌ័រនៅគ្រប់កម្រិត។

នៅក្នុងស្ថាប័ននីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ ការឈានទៅសម្រេចតុល្យភាពយេនឌ័រអាចធ្វើបានតាមរយៈវិធានការណ៍ជាក់លាក់ដែលគាំទ្រដល់របៀបវារៈឆ្នាំ២០៣០ សម្រាប់គោលដៅដែលបានកំណត់ទី៥.៥.១នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព[F] ដែលមានបំណងសម្រេចឲ្យបាននូវសមភាព យេនឌ័រក្នុងឆ្នាំ២០៣០ និងសម្រេចឲ្យបានផងដែរនូវចក្ខុវិស័យសហគមន៍អាស៊ានឆ្នាំ២០២៥ គឺសហគមន៍ដែលប្រកបដោយភាពស្អិតរមួតផ្នែកនយោបាយ សមាហរណកម្មផ្នែកសេដ្ឋកិច្ច ការទទួល ខុសផ្នែកសង្គម និងផ្តោតពិតប្រាកដលើផលប្រយោជន៍របស់ប្រជាពលរដ្ឋជាធំដែលលើកកម្ពស់ដល់ការធ្វើឲ្យទទួលបានឱកាសស្មើៗគ្នា និងការការពារសិទ្ធិរបស់ស្ត្រី។ អ្នកតាក់តែងទាំងបុរស និងស្ត្រី និងអ្នកធ្វើសេចក្តីសម្រេចចិត្តនៅក្នុងជួររដ្ឋាភិបាល អាចចាំបាច់ត្រូវបំពាក់ចំណេះដឹង និងជំនាញថ្មីៗ ដើម្បីជំរុញការសម្រេចនូវរបៀបវារៈសមភាពយេនឌ័រ។ ជាងនេះទៅទៀត វាជាចំណុចគន្លឹះផងដែរ ក្នុងការប្រមូលផ្តុំអ្នកដឹកនាំស្ត្រីមកពីគ្រប់ស្ថាប័ននយោបាយក្នុងប្រទេស ដើម្បីរួមគ្នាបញ្ចុះបញ្ចូលឲ្យមានការដាក់ជាអាទិភាពរួមនូវបញ្ហាដែលទាក់ទងនឹងយេនឌ័រ។ ដើម្បីជំរុញការចូលរួម ការអនុវត្តឲ្យបាននូវតុល្យភាពជីវិត និងការងារ (work-life Balance) និងគោលនយោបាយស្ត្រីមេត្រី (women-friendly policies) នៅក្នុងសភាជាតិ និងថ្នាក់ក្រោមជាតិចាំបាច់ត្រូវតែលើកកម្ពស់ក្នុងនោះរួមមាន ទាំងដំណោះស្រាយគោលនយោបាយឈប់សម្រាកមើលថែទាំកូនរបស់ឪពុកម្តាយ (parental leave policies) ប្រកបដោយសមធម៌យេនឌ័រ ការថែទាំកុមារ ភាពជាម្តាយប្រកបដោយសុវត្ថិភាព និងពេល វេលាផ្លូវការសម្រាប់ការចរចា និងការបោះឆ្នោត។

ជាចុងក្រោយនេះ គណបក្សនយោបាយគួរលើកទឹកចិត្តដើម្បីផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុឲ្យបានគ្រប់គ្រាន់ដល់បេក្ខជនជាស្ត្រី។ ប្រជាជាតិនានា គួរតែធ្វើការកែលម្អប្រព័ន្ធបោះឆ្នោតរបស់ខ្លួន និងរបៀបរៀបចំសមាសភាពស្ត្រីនៅក្នុងរដ្ឋធម្មនុញ្ញជាតិ និងបទបញ្ជាផ្ទៃក្នុងគណបក្ស និងក្នុងច្បាប់នានាដើម្បី លើកម្ពស់ការចូលរួមរបស់អ្នកតំណាងជាស្ត្រី និងដោះស្រាយនូវបញ្ហាស្តង់ដាមិនស្មើគ្នា និងលក្ខណៈសម្បត្តិដែលយកទៅអនុវត្តចំពោះស្ត្រីនៅក្នុងឆាកនយោបាយ។

## សេចក្តីសន្និដ្ឋាន

សហគមន៍អាស៊ានបានបង្កើនឱកាសសម្រាប់ស្ត្រី និងកុមារីឲ្យមានឱកាសដើម្បីចូលរួមក្នុងឆាកនយោបាយ និងក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តក្នុងវិស័យសេដ្ឋកិច្ច។ ទោះបីជាយ៉ាងណាវឌ្ឍនភាពក្នុងការបង្កើនភាពជាតំណាងរបស់ស្ត្រីនៅក្នុងសភាអាស៊ាននៅតែមានភាពយឺតយ៉ាវនៅឡើយ ដោយសារបទដ្ឋានយេនឌ័រនៅតែត្រូវបានគេចាត់ទុកថាជាបញ្ហារបស់ថ្នាក់មូលដ្ឋាននៅក្នុងសហគមន៍អាស៊ាន។ ការយល់ឃើញបែបនេះបានរាំងដល់ឱកាសរបស់បេក្ខនារីក្នុងការទទួលបានការបោះឆ្នោត និងធ្វើឲ្យបាត់បង់ឱកាសក្នុងការបំពេញតួនាទីទទួលខុសត្រូវរបស់ពួកគេនៅក្នុងជីវិតនយោបាយ។ ឱកាសនៃ ការអប់រំ និងកង្វះការយល់ដឹង គឺជាឧបសគ្គបន្ថែមដែលត្រូវដោះស្រាយឲ្យខានតែបាន។

ដើម្បីជានាឲ្យបាននូវសិទ្ធិពេញលេញ និងបង្កើនភាពអង់អាចដល់ស្ត្រីទាំងអស់នៅក្នុងសហគមន៍អាស៊ាន ការប្តេជ្ញាចិត្តដ៏រឹងមាំ គឺជាតម្រូវការចាំបាច់បំផុតរវាងប្រទេសជាសមាជិកអាស៊ាន ក្នុងការអនុវត្តទិសដៅយុទ្ធសាស្ត្រក្នុងតំបន់ដែលអាស៊ានកំពុងឆ្ពោះទៅរកការលើកកម្ពស់ការយល់ដឹង និងការបង្កើនភាពអង់អាចដល់ស្ត្រី និងក្មេងស្រី។ គោលនយោបាយគឺគួតែមាននៅគ្រប់វិស័យពាក់ព័ន្ធដោយផ្តោតលើការចូល រួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងក្នុងតួនាទីនៅថ្នាក់ជាតិ ដើម្បីដោះស្រាយនូវការអនុវត្តបទដ្ឋានយេនឌ័រដែលបានបង្ហាញខាងលើ ដែលជាឧបសគ្គដល់ការចូលរួមរបស់ស្ត្រីក្នុងឆាកនយោបាយ។

ដូច្នេះមានការងារជាច្រើនទៀតដែលត្រូវធ្វើដោយសហគមន៍អាស៊ាន។ អាស៊ានត្រូវខិតខំធ្វើការរួមគ្នាដើម្បីតំណាងឲ្យស្ត្រី និងក្មេងស្រី ក្នុងការជំនះឲ្យបានទៅនឹងស្ត្រីភាវូបនីយកម្មនៃភាពក្រីក្រ (challenge the feminization of poverty) លើកកម្ពស់សុវត្ថិភាពមនុស្សជាតិ បង្កើនឱកាសការងារលុបបំបាត់ការរើសអើង និងអំពើហិង្សាលើស្ត្រី។



ក្រុមសភាជាតិកម្ពុជានៃអ្នកនយោបាយសភាស្ត្រី (CWPC) បានរៀបចំព្រឹត្តិការណ៍មួយនៅឆ្នាំ២០១៩ ដែលជាផ្នែកមួយនៃគំនិតផ្តួចផ្តើមរបស់ យុទ្ធនាការនារីវ័យក្មេងឆ្ពោះទៅភាពជាអ្នកដឹកនាំ (Girl2Leader) ក្នុងគោលបំណងលើកទឹកចិត្ត នារីវ័យក្មេងនៅកម្ពុជាឲ្យសកម្មចូលរួមក្នុងឆាកនយោបាយ។

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដែលបកដោយវិទ្យាស្ថានសភាកម្ពុជា (PIC)។
អត្ថបទដើមជាភាសាអង់គ្លេសអាចទាញយកពីគេហទំព័រ៖ https://www.pic.org.kh ។

## ផែនទី ១៧៖ តំណាងស្ត្រីនៅក្នុងសភានៅអាស៊ាន




**តំណាងស្ត្រីនៅក្នុងសភា**

| ចំណាត់ថ្នាក់ | ប្រទេស | សភាជាន់ទាប ឬឯកសភា | | សភាជាន់ខ្ពស់ ឬព្រឹទ្ធសភា | |
|---|---|---|---|---|---|
| | | % ស្ត្រី | ស្ត្រី/កៅអី | % ស្ត្រី | ស្ត្រី/កៅអី |
| ៥១ | ហ្វីលីពីន | ២៩.៥ | ៨៦/២៩២ | ២៥ | ៦/២៤ |
| ៥៩ | ឡាវ | ២៧.៥ | ៤១/១៤៩ | - | -/- |
| ៦៤ | វៀតណាម | ២៦.៧ | ១៣២/៤៩៤ | - | -/- |
| ៨១ | សិង្ហបុរី | ២៣ | ២៣/១០០ | - | -/- |
| ១០៣ | កម្ពុជា | ២០ | ២៥/១២៥ | ១៧.៧ | ១១/៦២ |
| ១១៤ | ឥណ្ឌូណេស៊ី | ១៨.២ | ១០២/៥៦០ | - | -/- |
| ១៤១ | ម៉ាឡេស៊ី | ១៤.៤ | ៣២/២២២ | ១៩.៤ | ១៣/៦៧ |
| ១៥៩ | មីយ៉ាន់ម៉ា | ១១.៣ | ៤៩/៤៣៣ | ១២.១ | ២៧/២២៤ |
| ១៧០ | ព្រុយណេ | ៩.១ | ៣/៣៣ | - | -/- |
| ១៨២ | ថៃ | ៥.៤ | ១៣/២៤០ | - | -/- |

# ៨.២ ការវិវត្តក្របខ័ណ្ឌគតិយុត្តិស្តីអំពីអាកាសធាតុនៅអាស៊ាន

> “ប្រទេសចំនួនបួនក្នុងចំណោមប្រទេសចំនួនដប់នៅលើពិភពលោកដែលទទួលរងផលប៉ះពាល់ដោយការប្រែប្រួលអាកាសធាតុគឺស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលរួមមាន៖ ប្រទេសភូមា ហ្វីលីពីន ថៃ និងវៀតណាម។”

ការប្រែប្រួលអាកាសធាតុគឺជាក្តីព្រួយបារម្ភជាសកលហើយមានជាប់ពាក់ព័ន្ធជាពិសេសនឹងតំបន់អាស៊ីអាគ្នេយ៍ដែលស្ថិតក្នុងចំណោមតំបន់ងាយទទួលរងគ្រោះបំផុតពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនិងជាតំបន់ដែលមានការបញ្ចេញឧស្ម័នផ្ទះកញ្ចក់កើនឡើងយ៉ាងឆាប់រហ័ស។ ចាប់ពីឆ្នាំ១៩៩០រហូតដល់ឆ្នាំ២០១០ការបញ្ចេញឧស្ម័នកាបូនិកនៅអាស៊ីអាគ្នេយ៍ បានកើនឡើងលឿនជាងតំបន់ផ្សេងទៀតនៅលើពិភពលោក [១៥]។

យោងតាមសន្ទស្សន៍ហានិភ័យអាកាសធាតុពិភពលោកប្រទេសចំនួនបួនក្នុងចំណោមប្រទេសចំនួនដប់នៅលើពិភពលោកដែលទទួលរងផលប៉ះពាល់ដោយការប្រែប្រួលអាកាសធាតុ គឺស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលមានដូចជា៖ ប្រទេសភូមា ហ្វីលីពីន ថៃ និងវៀតណាម។ ទន្ទឹមនឹងនេះ ប្រទេសចំនួន៥ ដូចជា៖ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន ថៃ និងវៀតណាមបច្ចុប្បន្នបានបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ៩០% នៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សរុបនៅតំបន់អាស៊ីអាគ្នេយ៍។

ការស្រាវជ្រាវភាគច្រើនដែលធ្វើឡើងនៅក្នុងតំបន់អាស៊ីអាគ្នេយ៍បានផ្តោតទៅលើភាពងាយទទួលរងគ្រោះក្នុងតំបន់ និងផលប៉ះពាល់ភ្លាមៗ និងក្នុងរយៈពេលមធ្យម ប៉ុន្តែមិនសូវផ្តោតទៅលើការបង្កើតគោលនយោបាយនិងច្បាប់អាកាសធាតុនៅក្នុងតំបន់ឡើយ។ «ការសិក្សារបស់ Salamanca and Nguyen (២០១៦: ១) បានចាត់ថ្នាក់ប្រទេសក្នុងតំបន់អាស៊ានដោយផ្អែកទៅលើគោលនយោបាយបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុចំនួន៣ប្រភេទ៖ ប្រទេសនាំមុខ (ហ្វីលីពីន និង វៀតណាម) ប្រទេសជើងឯកដែលទើបលេចឡើងថ្មី (កម្ពុជា ឥណ្ឌូនេស៊ី និងភូមា) និងប្រទេសដែលនៅរង់ចាំមើល (ឡាវ ម៉ាឡេស៊ី និងថៃ)» [១៦, ទំ.៤]។ អត្ថបទនេះមានគោលបំណងផ្តល់ទិដ្ឋភាពទូទៅស្តីពី ថាមវន្តនៃច្បាប់ទាក់ទងនឹងអាកាសធាតុនៅក្នុងតំបន់។

## ច្បាប់អាកាសធាតុ

«ទោះបីជាចំណេះដឹងផ្នែកវិទ្យាសាស្រ្តស្តីពី ផលប៉ះពាល់នៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់មានតាំងពីជាង១០០ឆ្នាំមុនមកហើយក្តី ការប្រែប្រួលអាកាសធាតុទើបតែក្លាយជាបញ្ហាដែលជាក្តីព្រួយបារម្ភធំធេងរបស់គោលនយោបាយនៅក្នុងទសវត្សរ៍៩០ ប៉ុណ្ណោះ បន្ទាប់ពីក្រុមការងារអន្តររដ្ឋាភិបាលទទួលបន្ទុកការប្រែប្រួលអាកាសធាតុបានចេញរបាយការណ៍វាយតម្លៃទីមួយរបស់ខ្លួន និងបន្ទាប់ពីមានប្រទេសជាច្រើនចាប់ផ្តើមចរចាទៅលើអ្វីដែលនាំឲ្យមានអនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ។ មានប្រទេសពីរឬបីប៉ុណ្ណោះដែលបានអនុវត្តការប្តេជ្ញាចិត្ត (បែបទន់ភ្លន់) ស្របទៅតាម UNFCC ១៩៩២ ដោយការបង្កើតឲ្យមានច្បាប់ក្នុងប្រទេស» [១៧, ទំ.៨] ។ សព្វថ្ងៃស្ថានភាពមានការប្រែប្រួល «បច្ចុប្បន្នក្នុងពិភពលោកមាន

> “ការប្រែប្រួលអាកាសធាតុទើបតែក្លាយជាបញ្ហាដែលជាក្តីព្រួយបារម្ភធំធេងរបស់គោលនយោបាយនៅក្នុងទសវត្សរ៍៩០ ប៉ុណ្ណោះ បន្ទាប់ពីក្រុមការងារអន្តររដ្ឋាភិបាលទទួលបន្ទុកការប្រែប្រួលអាកាសធាតុបានចេញរបាយការណ៍វាយតម្លៃទីមួយរបស់ខ្លួន និងបន្ទាប់ពីមានប្រទេសជាច្រើនចាប់ផ្តើមចរចាទៅលើអ្វីដែលនាំឲ្យមានអនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពី ការប្រែប្រួលអាកាសធាតុ។”

> **“ បច្ចុប្បន្នពិភពលោកមានច្បាប់ស្តីពីការប្រែប្រួលអាកាសធាតុ ឬពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុជាង ១.២០០ ដែលចំនួននេះគឺកើនឡើង ២០ដងច្រើនជាងមុន ក្នុងរយៈពេលជាង២០ឆ្នាំកន្លងមកនេះ។ ”**

ច្បាប់ស្តីពី ការប្រែប្រួលអាកាសធាតុ ឬពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុជាង ១.២០០ ដែលចំនួននេះ គឺកើនឡើង ២០ដង ច្រើនជាងមុន ក្នុងរយៈពេលជាង២០ ឆ្នាំកន្លងមកនេះ៖ នៅឆ្នាំ១៩៩៧ មានច្បាប់អាកាសធាតុប្រមាណតែ ៦០ ប៉ុណ្ណោះ» [១៨]។

ចាប់ពីឆ្នាំ២០១០ រហូតដល់ឆ្នាំ២០១៨ ប្រទេសចំនួនប្រាំគឺ វៀតណាម ហ្វីលីពីន កម្ពុជា ឥណ្ឌូនេស៊ី និងថៃ បានអនុម័តច្បាប់ និងគោលនយោបាយជាតិចំនួន៦៧ ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។ ប្រទេសទាំងប្រាំនេះទទួលរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុខ្លាំងជាងគេនៅអាស៊ាន និងជាប្រទេសដែលបានធ្វើផ្តល់សច្ចាប័នមុនគេលើកិច្ចព្រមព្រៀងទីក្រុងប៉ារីសក្រោមអនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ។

ច្បាប់អាកាសធាតុត្រូវបានបង្កើតឡើងក្នុងទម្រង់ផ្សេងៗដូចជា បទបញ្ញត្តិ ច្បាប់ ផែនការសកម្មភាព សេចក្តីណែនាំ ផែនទីបង្ហាញផ្លូវ សេចក្តីសម្រេច គោលនយោបាយ កម្មវិធី និងការធ្វើសច្ចាប័នលើកិច្ចព្រមព្រៀងតំបន់និងអន្តរជាតិជាដើម។

**តារាងទី១៖** ប្រទេស៥ដែលងាយទទួលរងគ្រោះបំផុតនៅអាស៊ាន

| | កម្ពុជា | វៀតណាម | ហ្វីលីពីន | ឥណ្ឌូនេស៊ី | ថៃ |
|---|---|---|---|---|---|
| ប្រទេសតាមក្រុមប្រាក់ចំណូល (ធនាគារពិភពលោក) | ប្រាក់ចំណូលមធ្យមកម្រិតទាប | ប្រាក់ចំណូលមធ្យមកម្រិតទាប | ប្រាក់ចំណូលមធ្យមកម្រិតទាប | ប្រាក់ចំណូលមធ្យមកម្រិតទាប | ប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ |
| ការបាត់បង់ប្រចាំឆ្នាំជាមធ្យមដោយគ្រោះធម្មជាតិ ជាភាគរយនៃផលិតផលសរុបក្នុងស្រុក | ១,៩២៧% | ០,២៤៨% | ៤,៦១% | ០,៦៩១% | ១,៧៧% |
| ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់( MtCO2e, including LULUCG),២០១៣ | ៥១,៦៦ | ២១៦០,៦៤ | ១១១,២៩ | ៣៨៤,៣៧ | ២៣៩,០៩ |
| ចំណាត់ថ្នាក់ពិភពលោកជាប្រទេសបញ្ចេញឧស្ម័ន | ក្រោមលេខរៀងទី៥០ខ្ពស់ជាងគេ | លេខរៀងទី៥ខ្ពស់ជាងគេ | ក្រោមលេខរៀងទី៥០ខ្ពស់ជាងគេ | លេខរៀងទី ២១-៥០ | លេខរៀងទី ២១-៥០ |
| ការផ្តល់សច្ចាលើកិច្ចព្រមព្រៀងទីក្រុងប៉ារីស | ធ្វើសច្ចាប័ន(០៦/០២/២០១៧) | ធ្វើសច្ចាប័ន(៣១/១០/២០១៦) | ធ្វើសច្ចាប័ន(៣១/១០/២០១៦) | ធ្វើសច្ចាប័ន(២១/០៩/២០១៦) | ធ្វើសច្ចាប័ន(០៣/១១/២០១៦) |
| ចំនួនច្បាប់អាកាសធាតុ | ១ | ៤ | ៦ | ២ | ៣ |
| ចំនួនគោលនយោបាយអាកាសធាតុ | ៥ | ១៧ | ៩ | ៨ | ១២ |

## ផែនទី ១៨៖ ភូមិសាស្ត្ររូបវន្ត និងគ្រោះមហន្តរាយធម្មជាតិ




### កំណត់សម្គាល់

| | | | |
|---|---|---|---|
| ▲ ភ្នំភ្លើងសកម្ម | 0-២០០ម | ព្រៃក្រាស់ |
| ស្នាមប្រេះផែនដីធំៗ | ២០០-១,០០០ម | |
| គន្លងនៃខ្យល់ព្យុះធំៗ | > ១,០០០ម | |

## របកគំហើញបឋមនៃការវិភាគច្បាប់

របកគំហើញបឋមនេះបានមកពីការសិក្សាវិភាគលើច្បាប់និងគោលនយោបាយជាង៣០[A] ដែលមានការពាក់ព័ន្ធផ្ទាល់ទៅនឹងការបន្សាំនិងការទប់ទល់ទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុក្នុងប្រទេសចំនួន៥។

ច្បាប់អាកាសធាតុដែលបានពិនិត្យទាំងនោះភាគច្រើនមានជាប់ពាក់ព័ន្ធផ្ទាល់ទៅនឹងក្របខ័ណ្ឌអភិវឌ្ឍន៍ប្រកបដោយចីរភាពដូចជា៖

- សន្តិសុខ និងសុវត្ថិភាពស្បៀង
- កសិកម្ម/ភាពប្រកួតប្រជែងកសិកម្ម
- ថាមពល/ការផ្លាស់ប្តូរថាមពល
- ការគ្រប់គ្រងធនធានធម្មជាតិ និងប្រព័ន្ធអេកូឡូស៊ី
- ព្រៃឈើ
- ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ

ដោយពិនិត្យមើលទៅលើគោលនយោបាយ និងច្បាប់ដែលបានអនុម័តរួចចាប់ពីឆ្នាំ២០១០ កន្លងទៅ នៅក្នុងបណ្តាប្រទេសដែលបានជ្រើសរើសសម្រាប់ការវិភាគ លទ្ធផល

> ចំនួនគោលនយោបាយស្តីពីការប្រែប្រួលអាកាសធាតុមានការកើនឡើង ជាពិសេសបន្ទាប់ពីមានកិច្ចព្រមព្រៀងទីក្រុងប៉ារីស។

ដំបូងបង្ហាញថា ចំនួនគោលនយោបាយស្តីពីការប្រែប្រួលអាកាសធាតុមានការកើនឡើង ជាពិសេសបន្ទាប់ពីមានកិច្ចព្រមព្រៀងទីក្រុងប៉ារីស (២០១៥)។

គួរកត់សម្គាល់ដែរថា គោលនយោបាយភាគច្រើនត្រូវបានបង្កើតឡើងដោយអង្គនីតិប្រតិបត្តិរបស់ប្រទេសទាំងនោះជាពិសេសដោយក្រសួងដែលទទួលបន្ទុកលើការរៀបចំវិធានការណ៍បន្សាំនិងទប់ទល់ទៅនឹងការប្រែប្រួលអាកាសធាតុ។ អង្គនីតិប្រតិបត្តិជាអ្នកនាំមុខក្នុងការបង្កើតច្បាប់អាកាសធាតុនៅក្នុងប្រទេសទាំងប្រាំ ក្នុងនោះ៧៦%នៃច្បាប់បានបង្កើតនិងអនុម័តដោយអង្គនីតិប្រតិបត្តិ ចំណែកឯសភាភាគច្រើនមានតែតួនាទីគាំទ្រប៉ុណ្ណោះ។

ទោះបីជាក្របខ័ណ្ឌគតិយុត្តិរឹងមាំ គឺជាសូចនាករគន្លឹះសម្រាប់ការវាស់វែងកម្រិតនៃការប្តេជ្ញាចិត្តថ្នាក់ជាតិ ក្នុងការជម្រុញការអនុវត្តកម្មវិធី និងការវិនិយោគនានាក៏ដោយ ការស្រាវជ្រាវបន្ថែមគួរតែត្រូវធ្វើឡើង ដើម្បីកំណត់ពីថវិកាដែលត្រូវវិភាជជាក់ស្តែង ការវិនិយោគ និងប្រភេទគម្រោងដែលត្រូវអនុវត្ត ឆ្ពោះទៅធ្វើការបន្សាំ និងទប់ទល់ទៅនឹងការប្រែប្រួលអាកាសធាតុនៅក្នុងបណ្តាប្រទេសនីមួយៗ។

> អង្គនីតិប្រតិបត្តិបានក្លាយជាអ្នកបង្កើតច្បាប់អាកាសធាតុនៅក្នុងប្រទេសទាំងប្រាំ ក្នុងនោះ ៧៦ភាគរយ នៃច្បាប់ទាំងនោះបានបង្កើត និងអនុម័តដោយស្ថាប័នអង្គនីតិប្រតិបត្តិ ចំណែកសភានៅតែមានតួនាទីសំខាន់តែក្នុងការគាំទ្រ។

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដែលបកដោយវិទ្យាស្ថានសភាកម្ពុជា (PIC)។ អត្ថបទដើមជាភាសាអង់គ្លេសអាចទាញយកពីគេហទំព័រ៖ https://www.pic.org.kh ។

## ផែនទី ១៩៖ ច្បាប់អាកាសធាតុ



## ៨.៣ ទេសន្តរប្រវេសន៍

តំបន់អាស៊ីអាគ្នេយ៍ក្នុងប្រវត្តិសាស្ត្រគឺជាតំបន់មួយដែលមានភាពចល័តទេសន្តរប្រវេសន៍ទាំងចូលមកក្នុងតំបន់ និងចេញទៅក្រៅតំបន់។ យោងតាមអង្គការអន្តរជាតិទេសន្តរប្រវេសន៍ (International Organization for Migration) (មានទីស្នាក់ការនៅទីក្រុងហ្សឺណែវ) ប្រជាជនចំនួនច្រើនជាង ២៨,៥លាននាក់ មកពីតំបន់នេះកំពុងរស់នៅក្រៅប្រទេសកំណើតរបស់ខ្លួន(២០១៦) [២២]។

ទេសន្តរប្រវេសន៍ឆ្លងប្រទេសក្នុងតំបន់អាស៊ាននេះមានចំនួនមួយភាគបួននៃទិន្នន័យសរុប ហើយប្រទេសគោលដៅសំខាន់ពីរ គឺម៉ាឡេស៊ី និងថៃ។ ម៉ាឡេស៊ីស្រូបយកប្រជាជនមកពីឥណ្ឌូនេស៊ី (១,៦លាននាក់) មីយ៉ាន់ម៉ា(០,៣លាននាក់) ហ្វីលីពីន (០,១លាននាក់) និងវៀតណាម (០,០៨៩លាននាក់)។ ថៃទទួលជនទេសន្តប្រវេសន៍មកពីមីយ៉ាន់ម៉ា (១,៨លាននាក់) ឡាវ (១,៣លាននាក់) និងកម្ពុជា (០,៧លាននាក់)។ សិង្ហបុរីទទួលពលករមកពីឥណ្ឌូណេស៊ី និងហ្វីលីពីន។ ប្រហែល ១៦% នៃប្រជាជនឡាវកំពុងរស់នៅបរទេស។ ពលករទេសន្តរប្រវេសន៍មានចំនួន ៣៩% នៃកម្លាំងពលកម្មសរុបក្នុងប្រទេសសិង្ហបុរី ១៧% ក្នុងប្រទេសម៉ាឡេស៊ី និង៨%ក្នុងប្រទេសថៃ [២២]។ ទេសន្តប្រវេសន៍បច្ចុប្បន្នមកពីប្រទេសចិនពុំមានរបាយការណ៍ច្បាស់លាស់ទេ ប៉ុន្តែវាឆ្លុះបញ្ចាំងពីកំណើនឥទ្ធិពលនៃប្រទេសនេះ។

បីភាគបួននៃប្រជាជន ដែលធ្វើចំណាកស្រុកពីតំបន់នេះធ្វើដំណើរទៅកាន់បណ្តាប្រទេសអតីតមហាអំណាចអាណានិគម (បារាំង ចក្រភពអង់គ្លេស ហូឡង់ និងសហរដ្ឋអាមេរិក) និងបណ្តាប្រទេសទទួលជនភៀសខ្លួន (ប្រទេសដែលបានរៀបរាប់ខាងលើបូកបន្ថែមជាមួយអាល្លឺម៉ង់ និងអូស្ត្រាលី)និងទៅកាន់ឧបទ្វីបអារ៉ាប់(ប្រជាជនឥណ្ឌូនេស៊ីចំនួន២លាននាក់ និងប្រជាជនហ្វីលីពីនក្នុងចំនួនដូចគ្នា) ទៅតាមលំហូរនៃសាកលភាវូបនីយកម្ម គួបផ្សំទៅនឹងការហូរចូលពីសមភាគីរបស់ពួកគេមកពីតំបន់អាស៊ីខាងត្បូង។ វៀតណាម និងហ្វីលីពីនមានជនចំណូលស្រុកបរទេសចម្រុះជាតិសាសន៍មកពីជប៉ុន និងកូរ៉េខាងត្បូងបូករួមនឹងអូស្ត្រាលីកាណាដា អឺរ៉ុប និងរដ្ឋជាប់ឈូងសមុទ្រផ្សេងៗ។

> “ប្រជាជនចំនួនច្រើនជាង២៨.៥លាននាក់មកពីតំបន់នេះកំពុងរស់នៅក្រៅប្រទេសកំណើតរបស់ខ្លួន។”

ការវាយតម្លៃនានាដោយធនាគារពិភពលោក (World Bank) (ផ្អែកលើការវិភាគរបស់អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ (International Monetary Fund) បង្ហាញថា ការផ្ទេរសាច់ប្រាក់ទៅកាន់តំបន់អាស៊ីអាគ្នេយ៍មានចំនួន ៧៣ប៊ីលានដុល្លារ អាម៉េរិកក្នុងឆ្នាំ២០១៨ ដែលស្មើនឹង ១១%នៃចំនួនសរុបពិភពលោក និងច្រើនជាងចំនួនដែលបានផ្ទេរទៅកាន់ប្រទេសចិន (៦៤ប៊ីលានដុល្លារអាម៉េរិក) ដែលនៅក្នុងនោះរួមមាន ហ្វីលីពីន (៣៨ប៊ីលានដុល្លារអាម៉េរិក) វៀតណាម (១៦ប៊ីលានដុល្លារអាម៉េរិក) ឥណ្ឌូណេស៊ី (១១,៥ ប៊ីលានដុល្លារអាម៉េរិក) ថៃ (៧,៤ប៊ីលានដុល្លារអាម៉េរិក) មីយ៉ាន់ម៉ា (២,៧ ប៊ីលានដុល្លារអាម៉េរិក) ម៉ាឡេស៊ី (១,៨ប៊ីលានដុល្លារអាម៉េរិក) កម្ពុជា (០,៤១៤ ប៊ីលានដុល្លារអាម៉េរិក) និងឡាវ (០,១៤៩ ប៊ីលានដុល្លារអាម៉េរិក) [២៣] ។

> “ពលករទេសន្តរប្រវេសន៍មានចំនួន ៣៩% នៃកម្លាំងពលកម្មសរុបក្នុងប្រទេសសិង្ហបុរី ១៧% ក្នុងប្រទេសម៉ាឡេស៊ី និង ៨% ក្នុងប្រទេសថៃ។”

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដែលបកដោយវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិនៃកម្ពុជា (NIDIR)។ អ្នកអានអាចទាញយកអត្ថបទដើមជាភាសាអង់គ្លេសពីគេហទំព័រ៖ https://www.pic.org.kh ។

# ផែនទី ២០៖ ទេសន្តប្រវេសន៍ក្នុងអាស៊ាន







| | ប្រទេសគោលដៅលំដាប់ខ្ពស់ជាងគេទាំង៥ នៃទេសន្តប្រវេសន៍ឆ្លងតំបន់ក្នុងឆ្នាំ២០១៧ | | | | | ប្រទេសគោលដៅលំដាប់ខ្ពស់ទាំង៥ នៃទេសន្តប្រវេសន៍ក្នុងតំបន់ក្នុងឆ្នាំ២០១៧ | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ទី១ | ទី២ | ទី៣ | ទី៤ | ទី៥ | ទី១ | ទី២ | ទី៣ | ទី៤ | ទី៥ |
| ព្រុយណេ | ឥណ្ឌា | ម៉ាឡេស៊ី | ចក្រភពអង់គ្លេស | កាណាដា | អូស្ត្រាលី | ម៉ាឡេស៊ី | ថៃ | ហ្វីលីពីន | ឥណ្ឌូណេស៊ី | ឥណ្ឌា |
| កម្ពុជា | ថៃ | សហរដ្ឋអាមេរិក | បារាំង | អូស្ត្រាលី | កាណាដា | វៀតណាម | ថៃ | ចិន | បារាំង | ឡាវ |
| ឥណ្ឌូណេស៊ី | អារ៉ាប៊ីសាអូឌីត | ម៉ាឡេស៊ី | សហព័ន្ធអារ៉ាប់រួម | សិង្ហបុរី | បង់ក្លាដេស | ចិន | កូរ៉េ | ចក្រភពអង់គ្លេស | ថៃ | សិង្ហបុរី |
| ឡាវ | ថៃ | សហរដ្ឋអាមេរិក | បង់ក្លាដេស | បារាំង | កាណាដា | វៀតណាម | ចិន | កម្ពុជា | ថៃ | មីយ៉ាន់ម៉ា |
| ម៉ាឡេស៊ី | សិង្ហបុរី | បង់ក្លាដេស | អូស្ត្រាលី | សហរដ្ឋអាមេរិក | ចក្រភពអង់គ្លេស | ឥណ្ឌូណេស៊ី | បង់ក្លាដេស | មីយ៉ាន់ម៉ា | ឥណ្ឌា | ហ្វីលីពីន |
| មីយ៉ាន់ម៉ា | ថៃ | ម៉ាឡេស៊ី | អារ៉ាប៊ីសាអូឌីត | បង់ក្លាដេស | សហរដ្ឋអាមេរិក | ចិន | ឥណ្ឌា | បង់ក្លាដេស | | |
| ហ្វីលីពីន | សហរដ្ឋអាមេរិក | អារ៉ាប៊ីសាអូឌីត | សហព័ន្ធអារ៉ាប់រួម | កាណាដា | ជប៉ុន | ចិន | សហរដ្ឋអាមេរិក | ជប៉ុន | ឥណ្ឌា | កូរ៉េ |
| សិង្ហបុរី | ម៉ាឡេស៊ី | អូស្ត្រាលី | ចក្រភពអង់គ្លេស | សហរដ្ឋអាមេរិក | ឥណ្ឌូណេស៊ី | ម៉ាឡេស៊ី | ចិន | ឥណ្ឌូណេស៊ី | ឥណ្ឌា | បង់ក្លាដេស |
| ថៃ | សហរដ្ឋអាមេរិក | អាឡឺម៉ង់ | អូស្ត្រាលី | ជប៉ុន | ចក្រភពអង់គ្លេស | មីយ៉ាន់ម៉ា | ឡាវ | កម្ពុជា | ចិន | ឥណ្ឌា |
| វៀតណាម | សហរដ្ឋអាមេរិក | អូស្ត្រាលី | កាណាដា | បារាំង | កូរ៉េ | ថៃ | មីយ៉ាន់ម៉ា | បង់ក្លាដេស | ឥណ្ឌូណេស៊ី | ឡាវ |

# ៨.៤ ការអប់រំនៅអាស៊ានក្នុងដំណាក់កាលដំបូងនៃបដិវត្តន៍ឧស្សាហកម្មលើកទី ៤

នៅឆ្នាំ២០១៩ ប្រធានអាស៊ានដែលជាប្រទេសថៃ បានកំណត់គោលដៅរបស់អាស៊ានថា“ ជំរុញភាពជាដៃគូដើម្បីនិរន្តរភាព”។ យោងទៅតាមប្រធានអាស៊ាន បញ្ហាមួយដែលចាំបាច់ត្រូវដោះស្រាយជាបន្ទាន់ គឺការគ្រប់គ្រងផលប៉ះពាល់នៃបដិវត្តន៍ឧស្សាហកម្មទី ៤ (៤IR) ដោយជួយឲ្យអាស៊ានមានលទ្ធភាពអាចតាមទាន់ការវិវត្តនៃនវានុវត្តន៍សកល និងយកការច្នៃប្រឌិតនោះទៅប្រើប្រាស់ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍប្រកបដោយចីរភាព [២៤] ។

ប្រទេសជាសមាជិកអាស៊ានទាំង ១០ បានដឹងហើយថា បញ្ហាប្រឈមរបស់បដិវត្តន៍ឧស្សាហកម្មលើកទី ៤ ទាមទារឲ្យមានយុទ្ធសាស្ត្រអប់រំមួយដែលស្របទៅនឹងមនុស្សជំនាន់ថ្មី។ រដ្ឋមន្ត្រីក្រសួងអប់រំអាស៊ានបានប្រកាសរួមគ្នាជាបន្ទាប់នៅចុងបញ្ចប់នៃកិច្ចប្រជុំផ្លូវការមួយ កាលពីថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០១៨ នៅទីក្រុងណៃពិដោ (ប្រទេសមីយ៉ាន់ម៉ា) ថា “យើងត្រូវតែមានចក្ខុវិស័យនៅក្នុងអភិក្រមរបស់យើង ហើយយើងត្រូវពិចារណារកវិធីថ្មីៗ និងប្រកបដោយនវានុវត្តក្នុងការផ្តល់ការអប់រំ។ ដើម្បីសម្រេចគោលដៅនេះ យើងប្តេជ្ញាថា នឹងធានាឲ្យមានការអប់រំប្រកបដោយបរិយាបន្ន (inclusive education) នៅក្នុងអាស៊ាន ក៏ដូចជាជួយហាត់ពត់ប្រជាពលរដ្ឋឲ្យមានទម្លាប់ចេះស្រឡាញ់ការរៀនសូត្រពេញមួយជីវិត តាមរយៈការបន្តកែទម្រង់វិស័យអប់រំបន្ថែមទៀត” [២៥] ។

> “ យើងត្រូវតែមានចក្ខុវិស័យនៅក្នុងអភិក្រមរបស់យើង ហើយត្រូវពិចារណារកវិធីថ្មីៗ និងប្រកបដោយនវានុវត្តក្នុងការផ្តល់ការអប់រំ។ ”

បច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ (ICTs) ត្រូវបានដាក់បញ្ចូលក្នុងសូចនាករមួយចំនួននៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) [២៦]។ ការបញ្ចូលបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ ទៅក្នុងវិស័យអប់រំបានក្លាយជាយន្តការចាំបាច់មួយដែលអាចជួយលើកកម្ពស់គុណភាពនៃការបង្រៀននិងការសិក្សា ខណៈពេលកំពុងដោះស្រាយបញ្ហានានាដែលរួមមានដូចជា បញ្ហាការធានាឲ្យមានបរិយាបន្នសមភាព និងគុណភាពនៅក្នុងវិស័យអប់រំ [២៧]។ សេចក្តីថ្លែងការណ៍ទីក្រុងឈីងដាវ (Qingdao) ស្តីពី បច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ក្នុងវិស័យអប់រំ ដែលត្រូវបានអនុម័តនៅវេទិកាអប់រំពិភពលោក (World Education Forum) នៅទីក្រុងអ៊ិនឈុន (Incheon) ក្នុងឆ្នាំ២០១៥ បានថា បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍បានផ្តល់នូវមធ្យោបាយផ្សេងៗ ក្នុងការទទួលបានឱកាសរៀននិងបង្រៀន ដូចជាការផ្តល់ធនធានសម្រាប់ការសិក្សា [២៨]។ ការលើកកម្ពស់គុណភាពនៃការសិក្សាតម្រូវឲ្យមានការប្តេជ្ញាចិត្តខ្ពស់ ហើយរដ្ឋាភិបាលមានតួនាទីសំខាន់ក្នុងការបញ្ចូលជំនាញមូលដ្ឋានបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ទៅក្នុងកម្មវិធីអប់រំ ចាប់តាំងពីកម្រិតបឋមសិក្សាដើម្បីឲ្យសិស្សមានចំណេះដឹងលើផ្នែកនេះ។

ក្នុងអំឡុងពេលនៃបដិវត្តឧស្សាហកម្មលើកទី៤ ដែលអាចកើតមានទៅបានដោយសារការប្រើប្រាស់ទិន្នន័យក្នុងចំនួនដ៏ច្រើន (big data) នៅក្នុងសេដ្ឋកិច្ច – តាមរយៈដំណើរការធ្វើឌីជីថលនីយកម្ម ការបង្កើតបញ្ញាសិប្បនិម្មិត ការប្រើបច្ចេកវិទ្យាផ្ទុក និងចែករំលែកបណ្តុំឯកសារ (block-chain)– មុខវិជ្ជាសំខាន់ៗដែលជាគោលនៃកម្មវិធីសម្រាប់វាយតម្លៃសិស្សអន្តរជាតិ (PISA) ដូចជា ការអាន គណិតវិទ្យា និងវិទ្យាសាស្ត្រ ពិតជាមានសារៈសំខាន់ខ្លាំងសម្រាប់ការពិនិត្យមើលពីស្ថានភាពនៃការអប់រំនៅក្នុងបណ្តាប្រទេសនានាលើពិភពលោកទាក់ទងនឹងការរៀបចំខ្លួនរបស់ពួកគេក្នុងការទទួលយកបដិវត្តនេះ ។

នៅក្នុងការសិក្សាស្ទង់មតិតាមកម្មវិធីវាយតម្លៃសិស្សអន្តរជាតិ (PISA) ចុងក្រោយ របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ចនិងការអភិវឌ្ឍ (OECD) ដែលបានផ្សព្វផ្សាយនៅឆ្នាំ២០១៥ [២៨] បានបង្ហាញថា ប្រទេសសិង្ហបុរីមានចំណាត់ថ្នាក់ល្អជាងប្រទេសផ្សេងៗនៅលើពិភពលោក ដោយមានលទ្ធផលប្រសើរជាងប្រទេសជប៉ុន អេស្តូនៀ ហ្វាំងឡង់ និងប្រទេសកាណាដា។ ទោះបីកាលដែលទើបតែទទួលបានឯករាជ្យដំបូង ប្រទេសសិង្ហបុរីគ្រាន់តែជាកោះក្រីក្រមួយដែលមានការអភិវឌ្ឍតិចតួចក៏ដោយ ធនធានមនុស្សតែងតែជាទ្រព្យសម្បត្តិដ៏មានតម្លៃបំផុតសម្រាប់ប្រទេសសិង្ហបុរី។ បច្ចុប្បន្ននេះ ប្រទេសសិង្ហបុរី គឺជាទីតាំងកណ្តាលល្បីល្បាញមួយក្នុងពិភពលោក ដែលពាណិជ្ជកម្មហិរញ្ញវត្ថុ និងការដឹកជញ្ជូន មានភាពរស់រវើក ហើយដែល

ប្រជាជនរបស់ខ្លួនក្លាយជាសហគមន៍មួយដែលមានជាតិពន្ធុនិងសាសនាខុសគ្នា ប្រកបដោយសុខដុមរមនា។ ការប្រែក្លាយខ្លួនពី “ប្រទេសក្រីក្រទៅប្រទេសជឿនលឿន” (from “third world to first world”) ដោយប្រើតែមួយជំនាន់ គឺជាជោគជ័យដ៏ធំមួយនៅអាស៊ី [២៨] ។

ប្រទេសអាស៊ានផ្សេងទៀតដែលស្ថិតនៅក្នុងចំណាត់ថ្នាក់ចុងក្រោយក្នុងការវាយតម្លៃតាមកម្មវិធី PISA គឺប្រទេសឥណ្ឌូណេស៊ី ថៃ និងប្រទេសវៀតណាម។ គួរកត់សំគាល់ថា ប្រទេសចិនដែលឈរនៅលំដាប់ទី១០ និងប្រទេសវៀតណាមនៅលំដាប់ទី២២ គឺនាំមុខប្រទេសសមាជិកអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិដទៃទៀត រួមមានសហរដ្ឋអាម៉េរិក ប្រទេសបារាំង ចក្រភពអង់គ្លេស និងប្រទេសរុស្ស៊ី ដែលមានលំដាប់លេខរៀងជាបន្តបន្ទាប់ ទី៣១ ទី២៥ ទី២៣ និងទី២៨។ ខណៈពេលដែលសិស្សវៀតណាមបានទទួលលទ្ធផលខ្ពស់ជាងមធ្យមភាគរបស់សិស្សនៃប្រទេសដែលជាសមាជិករបស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍ (OECD) ក្នុងមុខវិជ្ជាវិទ្យាសាស្រ្ត និងគណិតវិទ្យា និន្នាការក្នុងលទ្ធផលនៃការវាយតម្លៃតាមកម្មវិធី PISA ក៏បានបង្ហាញថា ជំនាញគណិតវិទ្យា វិទ្យាសាស្រ្ត និងជំនាញអំណានរបស់សិស្សថៃដែលភាគច្រើនមានអាយុ ១៥ឆ្នាំ និងបានបញ្ចប់ការសិក្សាដល់ថ្នាក់ទី ៩ នៅតែមានកម្រិតទាបជាងមធ្យមភាគតាមស្តង់ដារអន្តរជាតិ។

ការអប់រំមូលដ្ឋាននៅក្នុងប្រទេសថៃ ត្រូវបានរៀបចំឡើងវិញ ដើម្បីផ្លាស់ប្តូរជំនាញរបស់ប្រជាពលរដ្ឋសម្រាប់ឆ្លើយតបទៅនឹងតម្រូវការសេដ្ឋកិច្ចសកល និងការផ្លាស់ប្តូរសង្គម ដោយផ្តោតលើមុខវិជ្ជា STEM (វិទ្យាសាស្រ្ត បច្ចេកវិទ្យាវិស្វកម្ម និងគណិតវិទ្យា) ដែលត្រូវបានគេចាត់ទុកថា ជាមុខវិជ្ជាសំខាន់សម្រាប់សតវត្សរ៍ទី ២១ ក៏ដូចផ្តោតលើជំនាញភាសាអង់គ្លេស។ ទោះបីយ៉ាងនេះក្តី របាយការណ៍ពីវេទិកាសេដ្ឋកិច្ចពិភពលោក (World Economic Forum: WEF) និងវិទ្យាស្ថានអន្តរជាតិសម្រាប់អភិវឌ្ឍការគ្រប់គ្រង (International Institute for Management Development: IMD) បានចាត់ថ្នាក់ប្រទេសថៃក្នុងលំដាប់លេខក្រោមគេទាក់ទងនឹងគុណភាពនៃការអប់រំកម្រិតបឋមសិក្សា និងសមត្ថភាពក្នុងការប្រកួតប្រជែងលើផ្នែកជំនាញបច្ចេកវិទ្យា វិទ្យាសាស្រ្ត និងគណិតវិទ្យា ក៏ដូចជាជំនាញភាសាអង់គ្លេស។ ទោះបីការបង្កើនថវិកាជាតិរបស់ប្រទេសថៃសម្រាប់វិស័យអប់រំជាតិ មានកម្រិតខ្ពស់បំផុត ក្នុងចំណោមបណ្តាប្រទេសអាស៊ាន [២៩] និងការចុះឈ្មោះចូលរៀននៅបឋមសិក្សានិងមធ្យមសិក្សាមាន

> “ ប្រសិនបើប្រទេសឥណ្ឌូនេស៊ី អាចរក្សាបាននូវល្បឿននៃការកែលម្អនេះ កុមារដែលកើតនៅបច្ចុប្បន្ននេះ នឹងមានឱកាសពិតប្រាកដក្នុងការទទួលបាន នូវលទ្ធផលផ្នែកវិទ្យាសាស្រ្ត ដូចនៅប្រទេសឧស្សាហកម្មទំនើបផ្សេងៗ នៅឆ្នាំ២០៣០ ។ ”

ការកើនពីឆ្នាំ២០១២ ដល់ ២០១៥ ក៏ដោយ ការបង្កើនថវិកានេះ មិនបានធ្វើអោយប្រសើរឡើងនូវគុណភាពនៃសាលារៀនតូចៗ នៅតាមតំបន់ជនបទឲ្យដល់កម្រិតគុណភាពនៅទីក្រុងធំៗឡើយ។

ទោះបីប្រទេសឥណ្ឌូណេស៊ីស្ថិតនៅលំដាប់លេខរៀងទី៦២ ក្នុងចំណាត់ថ្នាក់នៃការវាយតម្លៃតាមកម្មវិធី PISA និងបើប្រៀបធៀបនឹងប្រទេសថៃ ដែលជាប់ចំណាត់ថ្នាក់ទី៥៦ ក៏ដោយ ក៏ការវិវត្តបច្ចុប្បន្នរបស់ប្រទេសឥណ្ឌូណេស៊ីបាននាំឲ្យមានការព្យាករណ៍អំពីវឌ្ឍនភាពដ៏ខ្ពស់ នាពេលអនាគតដ៏ខ្លីខាងមុខ។ យោងតាមអង្គការ OECD “ប្រសិនបើប្រទេសឥណ្ឌូនេស៊ីអាចរក្សាបាននូវល្បឿននៃការកែលម្អនេះ កុមារដែលកើតនៅពេលបច្ចុប្បន្ននេះនឹងមានឱកាសដ៏ប្រាកដប្រជា ក្នុងការទទួលបាននូវលទ្ធផល ផ្នែកវិទ្យាសាស្រ្ត ដូចនៅប្រទេសឧស្សាហកម្មទំនើបផ្សេងៗ នៅឆ្នាំ២០៣០ ដែលជាឆ្នាំដែលគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ (UN-SDGs) រំពឹងផងដែរថាសិស្ស និស្សិត គ្រប់រូបនៅក្នុងពិភពលោកនឹងទទួលបានអត្ថប្រយោជន៍ពីការអប់រំប្រកបដោយគុណភាព” [៣១]។

ទោះបីបណ្តាប្រទេសអាស៊ានផ្សេងទៀតមិនបានចូលរួមក្នុងការសិក្សា PISA នេះ នៅឆ្នាំ២០១៥ ក៏ដោយគួរឲ្យកត់សម្គាល់ ប្រទេសទាំងនោះ ដូចជាប្រទេសម៉ាឡេស៊ី ដែលនៅដើមទសវត្សរ៍ឆ្នាំ១៩៩០ បានផ្តួចផ្តើមណែនាំការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យាក្នុងបឋមសិក្សានិងមធ្យមសិក្សា។នៅឆ្នាំ១៩៩៩ កម្មវិធី “សាលារៀនឆ្លាតវៃ” (Smart School Flagship) ត្រូវបានបង្កើតឡើង។ ផែនការនៃសាលារៀនឆ្លាតវៃ (Smart School Roadmap) និងគោលនយោបាយឆ្នាំ២០១០ ស្តីពីបច្ចេកវិទ្យាព័ត៌មានវិទ្យាក្នុងវិស័យអប់រំ បានជួយឲ្យមានការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍មូលដ្ឋាន និងការធ្វើសមាហរណកម្មបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ (ICT) ទៅក្នុងដំណើរការបង្រៀននិងការរៀន [៣១]។ ការអនុវត្តកម្មវិធី

"សាលារៀនឆ្លាតវៃ (Smart School Flagship)" ត្រូវបានពង្រឹងក្នុងឆ្នាំ២០១០ ដោយផ្តល់លទ្ធភាពឲ្យសាលារៀនចំនួន ១០,០០០ ក្លាយជាសាលារៀនឆ្លាតវៃ ដោយផ្តល់ឲ្យសាលារៀនទាំងនោះ នូវទីតាំងនិងអគារបច្ចេកវិទ្យាព័ត៌មានវិទ្យាឧបករណ៍និងសម្ភារៈបច្ចេកវិទ្យាព័ត៌មាន ដូចជាជំនាញបច្ចេកវិទ្យាព័ត៌មាន។ ក្នុងឆ្នាំ២០១៦ ប្រទេសម៉ាឡេស៊ីសម្រេចបានអត្រាអត្តិសនី ១០០ ភាគរយ ដោយសារភាពជោគជ័យគួរឲ្យកត់សម្គាល់ក្នុងការអភិវឌ្ឍជនបទ។ រដ្ឋាភិបាលម៉ាឡេស៊ីបានចំណាយថវិកាចំនួន ៣៦ ពាន់លានរីងហ្គីត (ស្មើនឹង៨,៥៨ ពាន់លានដុល្លារអាម៉េរិក) ដើម្បីអភិវឌ្ឍសាលារៀនឆ្លាតវៃ និងការអប់រំជាមូលដ្ឋានក្នុងគោលបំណងពង្រឹងប្រព័ន្ធអប់រំទាំងមូល និងអភិវឌ្ឍដំណើរការរបស់ខ្លួន[៣២]។

ការចំណាយរបស់រដ្ឋាភិបាលម៉ាឡេស៊ីលើការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សា ដែលបានបង្ហាញជាភាគរយនៃផលិតផលក្នុងស្រុកសរុប (GDP) គឺមានអត្រាខ្ពស់បំផុតនៅអាស៊ីប៉ូព៌ាចាប់តាំងពីឆ្នាំ១៩៨០ មក។ ក្នុងឆ្នាំ២០១១ ចំនួនទឹកប្រាក់ដែលបានចំណាយនៅប្រទេសម៉ាឡេស៊ី (៣,៨% GDP ឬ ១៦%នៃការចំណាយសាធារណៈសរុប) ស្មើនឹងចំនួនទឹកប្រាក់ដែលបានចំណាយនៅតាមប្រព័ន្ធអប់រំដែលដំណើរការល្អបំផុត ដូចជានៅប្រទេសសិង្ហបុរី ជប៉ុន និងប្រទេសកូរ៉េ [៣២] ។

ទោះបីជាកម្រិតនៃការចំណាយសាធារណៈទៅលើការអប់រំ ការចុះឈ្មោះចូលរៀន ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការកែលំអកម្មវិធីសិក្សា មានកម្រិតប្រហាក់ប្រហែលទៅនឹងការចំណាយសាធារណៈ នៅប្រទេសដែលមានសេដ្ឋកិច្ចអភិវឌ្ឍន៍ក្នុងតំបន់ក៏ដោយ និងទោះបីជាសិស្សម៉ាឡេស៊ីទទួលបានលទ្ធផលល្អប្រសើរជាងសិស្សឥណ្ឌូនេស៊ី ក៏ដោយ បើយោងតាមលទ្ធផលនៃការសិក្សាវាយតម្លៃតាមកម្មវិធី PISA ឆ្នាំ២០១២ ក៏សិស្សម៉ាឡេស៊ីនៅតែស្ថិតនៅចំណាត់ថ្នាក់ក្រោម សិស្សនៃប្រទេសដែលមានប្រាក់ចំណូលទាប ដូចជា ប្រទេសវៀតណាម ដែលបច្ចុប្បន្ននេះមានអត្រាចំណាយខ្ពស់បំផុតលើវិស័យអប់រំ គិតជាភាគរយធៀបទៅនឹងGDP ក្នុងអាស៊ាន ។

សារព័ត៌មានមួយចំនួនមានការងឿងឆ្ងល់អំពី ភាពខុសគ្នានៅក្នុងអាស៊ាន និងងឿងឆ្ងល់អំពីគោលបំណងរបស់ប្រធានអាស៊ានដែលជាប្រទេសថៃ ដោយលើកឡើងថា៖ “ខណៈពេលដែលកិច្ចខិតខំប្រឹងប្រែងនិងការវិនិយោគយ៉ាងហ្មត់ចត់នឹងត្រូវបានទាមទារដើម្បីឈានដល់ប្រទេសថៃ ៤.0 តើបញ្ហានេះនឹងជះឥទ្ធិពលអ្វីខ្លះដល់ពលករចំណាកស្រុកក្រីក្រទាំងអស់នៅក្នុងប្រទេសកម្ពុជាឡាវនិងប្រទេសមីយ៉ាន់ម៉ាដែលពឹងផ្អែកលើប្រទេសថៃសម្រាប់ការងាររបស់ពួកគេ?”

> **“ តើបញ្ហានេះនឹងជះឥទ្ធិពលអ្វីខ្លះដល់ពលករចំណាកស្រុកក្រីក្រទាំងអស់ដែលមកពី ប្រទេសកម្ពុជាឡាវនិងប្រទេសមីយ៉ាន់ម៉ាដែលពឹងផ្អែកលើប្រទេសថៃសម្រាប់ការងាររបស់ពួកគេ ? ”**

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដែលបកដោយវិទ្យាស្ថានសភាកម្ពុជា (PIC)។
អត្ថបទដើមជាភាសាអង់គ្លេសអាចទាញយកពីគេហទំព័រ៖ https://www.pic.org.kh ។

## ផែនទី ២១៖ ការអប់រំក្នុងអាស៊ាន



# ៨.៥ សេដ្ឋកិច្ចនិងពាណិជ្ជកម្ម

ជាមួយនឹងផលិតផលក្នុងស្រុកសរុបចំនួន ២,៧ប៊ីលានដុល្លារអាមេរិកក្នុងឆ្នាំ២០១៧ អាស៊ានគឺជាក្រុមសេដ្ឋកិច្ចពិភពលោកធំជាងគេទីប្រាំ បន្ទាប់ពីសហភាពអឺរ៉ុប សហរដ្ឋអាមេរិក ចិន និងជប៉ុន។ កម្រិតនៃការអភិវឌ្ឍមានគម្លាតពីគ្នាច្រើន ដោយគិតជាមធ្យមផលិតផលក្នុងស្រុកសរុបសម្រាប់ប្រជាពលរដ្ឋម្នាក់គឺ ៤.០០០ដុល្លារអាមេរិក ក្នុងនោះចាប់ពី ១.១០០ដុល្លារអាមេរិកសម្រាប់ប្រជាពលរដ្ឋម្នាក់ក្នុងប្រទេសកម្ពុជា រហូតដល់ ៥២.០០០ដុល្លារអាមេរិកសម្រាប់ប្រជាពលរដ្ឋម្នាក់ក្នុងប្រទេសសិង្ហបុរី។ ជាមួយនឹងសេដ្ឋកិច្ចបើកចំហ ប្លុកនេះមានតម្លៃស្មើនឹង៨%នៃពាណិជ្ជកម្មពិភពលោក។ វិនិយោគទុនបរទេសសរុបមានចំនួន ១៣៤ប៊ីលានដុល្លារអាមេរិកនៅចុងឆ្នាំ២០១៧ ដែលជិតស្មើនឹងតួលេខវិនិយោគទុនរបស់ចិន។ អាស៊ានបានធ្វើសមាហរណកម្មយ៉ាងល្អនូវទៅក្នុងខ្សែសង្វាក់តម្លៃឆ្លងដែន (រថយន្ត គ្រឿងអេឡិចត្រូនិច កុំព្យូទ័រ និងដំណើរការទិន្នន័យ)។កំណើនប្រចាំឆ្នាំជាមធ្យមកើនដល់៥,១%ចាប់តាំងពីឆ្នាំ២០១១ ហើយអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិបានព្យាករថា នឹងមានកំណើន ៥,២% សម្រាប់ឆ្នាំ២០១៩ [៣៥]។

តំបន់អាស៊ានមានមូលដ្ឋានគ្រឹះរឹងមាំគ្រប់គ្រាន់សម្រាប់កំណើន៖ តំបន់នេះសម្បូរដោយប្រជាពលរដ្ឋវ័យក្មេង (៥០% មានអាយុ ២៨ឆ្នាំឬទាបជាងនេះ) មានរបាយប្រជាជនប្រមូលផ្តុំក្នុងតំបន់ទីក្រុង (ប្រជាពលរដ្ឋ ៩០លាននាក់នឹងធ្វើចំណាកស្រុកទៅកាន់ទីក្រុង ជាមួយនឹងអ្នករស់នៅក្នុងទីក្រុងចំនួនច្រើនជាង ២០០.០០០ ក្នុងទសវត្សរ៍ក្រោយ) និងមានការភ្ជាប់ទំនាក់ទំនងល្អ (ការជ្រៀតចូលនៃទូរស័ព្ទចល័តគឺ ១៣៣%)។ ស្របគ្នានេះដែរ តម្រូវការក្នុងការពង្រីកហេដ្ឋារចនាសម្ព័ន្ធមានទំហំធំ ដែលត្រូវបានព្យាករដោយធនាគារអភិវឌ្ឍន៍អាស៊ី (Asian Development Bank) ថា ស្ថិតក្នុងចំនួនទឹកប្រាក់ ២១០ ប៊ីលានដុល្លារអាមេរិក ក្នុងរវាងពីឆ្នាំ២០១៦ ដល់ឆ្នាំ២០៣០ [៣៦]។

កំណើនសេដ្ឋកិច្ចមានឧត្តមភាពពីរគឺ ទីមួយសម្រាប់ការអភិវឌ្ឍក្នុងស្រុក និងទីពីរដើម្បីពង្រីកឥទ្ធិពលភូមិសាស្ត្រនយោបាយរបស់តំបន់។ សមាហរណកម្មអាស៊ាន គឺជាឧត្តមភាពមួយ។ តារាងពិន្ទុ «ឆ្ពោះទៅឲ្យហួសឆ្នាំ២០១៥» មានមន្ទិលថា តើអាស៊ានគួរតែឆ្ពោះទៅកាន់សហភាពគយមួយជាមួយនឹងការបើកឲ្យមានបម្លាស់ទីដោយសេរីនៃកម្លាំងពលកម្មនិងរូបិយវត្ថុឬទេ? របាយការណ៍មួយចេញដោយលេខាធិការដ្ឋានអាស៊ានបានបង្ហាញអំពីវឌ្ឍភាពនៃរបាំងពន្ធគយ (០%សម្រាប់ប្រទេសអភិវឌ្ឍន៍ចំនួន ០៦ និងអតិបរមា ៥% សម្រាប់ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម (ក្រុមប្រទេស CLMV) ប៉ុន្តែពាណិជ្ជកម្មក្នុងតំបន់នាពេលបច្ចុប្បន្នកំពុងជាប់គាំងក្នុងអត្រាទាបជាង ២៥%នៃពាណិជ្ជកម្មសរុបរបស់សមាជិកទាំងអស់ [៣៧]។ សេរីភាវូបនីយកម្មដែលមានដែនកំណត់ត្រូវបានបន្លឹងចំពោះតែវិស័យប្រាំប៉ុណ្ណោះ ហើយការតភ្ជាប់ថ្នាក់អនុតំបន់និងតំបន់នៅមានកម្រិតទាបនៅឡើយ។ សេដ្ឋកិច្ចនិងស្ថាប័ននៅមានគម្លាតគួរឲ្យកត់សម្គាល់ ប៉ុន្តែស្ថាប័នតំបន់ពិតជាបានផ្តល់មូលនិធិសម្រាប់គម្រោងសមាហរណកម្ម។ អ្វីដែលត្រូវតាមដានបន្តនោះគឺថា តើធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី (Asian Infrastructure Investment Bank) នឹងសម្របសម្រួលហិរញ្ញវត្ថុដែលត្រូវបានផ្តល់ដោយធនាគារអភិវឌ្ឍន៍អាស៊ី (មានទីស្នាក់ការកណ្តាលនៅទីក្រុងម៉ានីល និងក្រោមឥទ្ធិពលខ្លាំងពីជប៉ុន) និងធនាគារពិភពលោក នៅទីក្រុងវ៉ាស៊ីនតោន ដោយរបៀបណា។

សមាហរណកម្មតំបន់ជាលទ្ធផលនៃការបញ្ចូលប្រទេសអាស៊ានទៅក្នុងខ្សែសង្វាក់តម្លៃសកលដែលជម្រុញដោយក្រុមហ៊ុនឆ្លងប្រទេសនៅក្នុងវិស័យគន្លឹះរាប់ចាប់ពីឧស្សាហកម្មគ្រឿងអេឡិចត្រូនិចរថយន្តរហូតដល់សម្លៀកបំពាក់ជាជាងជាលទ្ធផលនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន (ASEAN Free Trade Area)។ ជប៉ុននិងកូរ៉េខាងត្បូង គឺជាគំរូសម្រាប់ប្រទេសដទៃដែលចង់បានកំណើនរយៈពេលយូរអង្វែង។ ប្រទេសធំៗអាចធ្វើការផ្លាស់ប្តូរចាំបាច់នានាដើម្បីទទួលបានប្រយោជន៍ពីសកលភាវូបនីយកម្ម៖ ការអភិវឌ្ឍកសិកម្មឲ្យក្លាយជាមូលដ្ឋានចំណូល ការផ្តល់សេវាសាធារណៈក្នុងវិស័យអប់រំនិងសុខភាព និងការបើកផ្លូវទៅកាន់ទីផ្សារអន្តរជាតិដែលផ្តល់កាលានុវត្តភាព ទោះបីជាមានការគំរាមកំហែងក៏ដោយ។

ដោយសារពាណិជ្ជកម្មក្នុងតំបន់មានអត្រាតែ ២៥% កំណើនមិនពឹងផ្អែកលើតម្រូវការក្នុងតំបន់នោះទេ ប៉ុន្តែអាស្រ័យលើទីផ្សារធំៗក្នុងសហរដ្ឋអាមេរិក អឺរ៉ុប ជប៉ុន និងចិន។ អាស៊ានមិនអាចជៀសផុតពីផលប៉ះពាល់នៃជម្លោះពាណិជ្ជកម្មរវាងទីក្រុងវ៉ាស៊ីនតោន និងទីក្រុងប៉េកាំងបាន

ឡើយ ដែលអាចរាំងស្ទះដល់ទំនាក់ទំនងក្នុងតំបន់ និងឈានទៅពុះចែករវាងរដ្ឋអាស៊ីអាគ្នេយ៍ដីគោកក្រោមឥទ្ធិពលចិន និងរដ្ឋអាស៊ីអាគ្នេយ៍ដែនកោះដែលតភ្ជាប់នឹងនឹងសិង្ហបុរី និងឥណ្ឌូនេស៊ី [៣៥]។

សមាជិកអាស៊ានបានចូលរួមក្នុងសេដ្ឋកិច្ចសកលមុនពេលពួកគេធ្វើសមាហរណកម្មទៅក្នុងសេដ្ឋកិច្ចតំបន់ទៅទៀត។ គម្រោងផ្តួចផ្តើមក្រៅតំបន់ (ប្រទេសមួយចំនួនកំពុងចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយសហរដ្ឋអាម៉េរិក ជប៉ុននិងចិន) ជាញឹកញាប់ធ្វើឡើងមុនផែនការនៅក្នុងតំបន់។ ហេតុនេះសហគមន៍សេដ្ឋកិច្ចអាស៊ាន គឺគ្រាន់តែជាចំណែកតូចមួយក្នុងរូបភាពទាំងមូលនៃគម្រោងប្រកួតប្រជែងដែលរួមមាន អាស៊ានបូកប្រាំមួយ (ASEAN +6) សម្រាប់ប្រទេសជប៉ុន កិច្ចព្រមព្រៀងភាពជាដៃគូអន្តរប៉ាស៊ីហ្វិក (Trans Pacific Partnership Agreement) សម្រាប់សហរដ្ឋអាម៉េរិក (អនុម័តក្នុងឆ្នាំ២០១៥និងលុបចោលក្នុងឆ្នាំ២០១៧) និងតំបន់ពាណិជ្ជកម្មសេរីសម្រាប់ប្រទេសចិន។ សហភាពអឺរ៉ុបដែលជាដៃគូពាណិជ្ជកម្មធំបំផុតទីបីរបស់តំបន់នេះក៏កំពុងស្ថិតនៅក្នុងការចរចាដែរ (២០១៨)។

**ផែនទី ២២៖** ផលិតផលក្នុងស្រុកសរុប និងផលិតផលជាតិសរុបតាមប្រទេស




កំណត់សម្គាល់
ផសស សម្រាប់មនុស្សម្នាក់($,២០១៦)
>៥០,០០០
២៥,០០០-៣០,០០០
១៥,០០០-២០,០០០
១០,០០០-១៥,០០០
<១០,០០០
៤.៤ អត្រាកំណើន (%,២០១៦)
ផជស (ពាន់លានដុល្លារ,២០១៦)
៩៥០
៤២៥
៥០
១០

| ប្រទេស | ផជស ឆ្នាំ២០១៦ |
|---|---|
| អាស៊ីអាគ្នេយ៍ | ២៥៥៤ |
| ព្រុយណេ | ១៣ |
| កម្ពុជា | ២០ |
| ឥណ្ឌូណេស៊ី | ៩៤៣ |
| ឡាវ | ១៤ |
| ម៉ាឡេស៊ី | ២៩៧ |
| មីយ៉ាន់ម៉ា | ៦៨ |
| ហ្វីលីពីន | ៣០៣ |
| សិង្ហបុរី | ២៩៥ |
| ថៃ | ៣៩៦ |
| វៀតណាម | ២០៥ |

ប្រភព៖ IMF; ចក្ខុវិស័យការអភិវឌ្ឍអាស៊ី

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដែលបកដោយវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិនៃកម្ពុជា (NIDIR)។ អ្នកអានអាចទាញយកអត្ថបទដើមជាភាសាអង់គ្លេសពីគេហទំព័រ៖ https://www.pic.org.kh ។

# ៨.៦ ហេដ្ឋារចនាសម្ព័ន្ធ

> “ ប្រសិនបើគម្រោងហេដ្ឋារចនាសម្ព័ន្ធធំៗទាំងអស់នេះត្រូវបានសម្រេចក្នុងទសវត្សរ៍ក្រោយនេះ តំបន់អាស៊ីអាគ្នេយ៍ដែលយើងធ្លាប់ស្គាល់ អាចនឹងវិវឌ្ឍទៅជាប្លុកនៃបណ្តាប្រទេសអភិវឌ្ឍ។ ទោះបីជាមានផែនការគម្រោងហេដ្ឋារចនាសម្ព័ន្ធធំៗដែលត្រូវបានគ្រោងសម្រាប់តំបន់ក៏ដោយ តម្រូវការហេដ្ឋារចនាសម្ព័ន្ធនៅតែត្រូវបានរំពឹងថានឹងមានការកើនឡើង។ ”

ដូចដែលបានលើកឡើងដោយគេហទំព័រអាស៊ានប៉ុស្តិ៍ (The ASEAN Post)៖ ក្នុងតំបន់អាស៊ីអាគ្នេយ៍នាពេលថ្មីៗនេះ ការយកចិត្តទុកដាក់បានផ្តោតសំខាន់លើគម្រោងហេដ្ឋារចនាសម្ព័ន្ធប្រកបដោយមហិច្ឆិតាជាច្រើនដែលកំពុងប្រតិបត្តិការនៅទូទាំងតំបន់។ ក្នុងប្រទេសហ្វីលីពីន ផែនការហេដ្ឋារចនាសម្ព័ន្ធ «កសាង! កសាង! កសាង!» របស់ប្រធានាធិបតី ឌុយទែរតេ (Duterte) កំពុងដំណើរការគម្រោងចំនួន៧៥ផ្សេងគ្នាដែលរំពឹងថានឹងចំណាយអស់ទឹកប្រាក់ចំនួន១៨០ប៊ីលានដុល្លារអាម៉េរិក។ ក្នុងប្រទេសឥណ្ឌូនេស៊ីប្រព័ន្ធផ្លូវដែកល្បឿនលឿនដែលគ្របដណ្តប់លើចម្ងាយផ្លូវ ១៤០គីឡូម៉ែត្រ តភ្ជាប់ពីទីក្រុងហ្សាការតា ទៅទីក្រុងបាងដុងកំពុងស្ថិតក្នុងដំណើរការសាងសង់។ ម៉ាឡេស៊ី និងសិង្ហបុរីកំពុងដំណើរការគម្រោងសាងសង់ផ្លូវដែកល្បឿនលឿនដែលនឹងជួយកាត់បន្ថយពេលវេលាធ្វើដំណើររវាងប្រទេសទាំងពីរ។ ជាលទ្ធផលប្រសិនបើគម្រោងហេដ្ឋារចនាសម្ព័ន្ធធំៗទាំងអស់នេះត្រូវបានសម្រេចក្នុងទសវត្សរ៍ក្រោយនេះតំបន់អាស៊ីអាគ្នេយ៍ដែលយើងធ្លាប់ស្គាល់អាចនឹងវិវឌ្ឍទៅជាប្លុកនៃបណ្តាប្រទេសអភិវឌ្ឍ។ ទោះបីជាមានផែនការគម្រោងហេដ្ឋារចនាសម្ព័ន្ធធំៗដែលត្រូវបានគ្រោងសម្រាប់តំបន់ក៏ដោយតម្រូវការហេដ្ឋារចនាសម្ព័ន្ធនៅតែត្រូវបានរំពឹងថានឹងមានការកើនឡើង [៣៨]។

យោងតាមធនាគារអភិវឌ្ឍន៍អាស៊ីប្រទេសកំពុងអភិវឌ្ឍនៅអាស៊ីនឹងត្រូវការវិនិយោគជាទឹកប្រាក់ចំនួន ២៦ទ្រីលានដុល្លារអាម៉េរិកសម្រាប់រយៈពេល១៥ឆ្នាំ ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០៣០ ឬ ១,៧ទ្រីលានដុល្លារអាម៉េរិកក្នុងមួយឆ្នាំ [៣៩] ប្រសិនបើតំបន់នេះចង់រក្សាបានសន្ទុះកំណើនរបស់ខ្លួន លុបបំបាត់ភាពក្រីក្រ និងឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ (ការប៉ាន់ស្មានដោយគិតបញ្ចូលបញ្ហាអាកាសធាតុ) (climate-adjusted estimate)។ បើសិនមិនគិតបញ្ចូលបញ្ហាអាកាសធាតុ (ការចំណាយលើការបន្សាំខ្លួន និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ) គេត្រូវការទឹកប្រាក់ចំនួន២២,៦ទ្រីលានដុល្លារអាម៉េរិក ឬ១,៥ទ្រីលានដុល្លារអាម៉េរិកក្នុងមួយឆ្នាំ (ការប៉ាន់ស្មានមូលដ្ឋាន)។ ក្នុងចំណោមការវិនិយោគសរុប (ដោយគិតបញ្ចូលបញ្ហាអាកាសធាតុ) ដែលចាំបាច់សម្រាប់អំឡុងពេលពីឆ្នាំ២០១៦ ដល់ឆ្នាំ២០៣០ ទឹកប្រាក់ចំនួន ១៤,៧ទ្រីលានដុល្លារអាម៉េរិកនឹងត្រូវការសម្រាប់វិនិយោគលើវិស័យថាមពល និងចំនួន ៨,៤ទ្រីលានដុល្លារអាម៉េរិកលើវិស័យដឹកជញ្ជូន។ការវិនិយោគក្នុងវិស័យទូរគមនាគមន៍នឹងកើនដល់ ២,៣ ទ្រីលានដុល្លារអាម៉េរិក និងវិស័យផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យ ចំនួន ៨០០ប៊ីលានដុល្លារអាម៉េរិក ក្នុងអំឡុងពេលដូចគ្នា។

- តំបន់អាស៊ីខាងកើតនឹងរួមចំណែក ៦១% នៃតម្រូវការវិនិយោគ (ដោយគិតបញ្ចូលបញ្ហាអាកាសធាតុ) រហូតដល់ឆ្នាំ២០៣០។ទោះយ៉ាងណាបើធៀបនឹងផលិតផលក្នុងស្រុកសរុប តំបន់ប៉ាស៊ីហ្វិកនាំមុខអនុតំបន់ទាំងអស់ដែលត្រូវការការវិនិយោគរហូតដល់តម្លៃ៩,១% នៃផលិតផលក្នុងស្រុកសរុប។ លំដាប់បន្ទាប់គឺ តំបន់អាស៊ីខាងត្បូងត្រូវការ៨,៨% អាស៊ីកណ្តាល៧,៨% អាស៊ីអាគ្នេយ៍៥,៧% និងអាស៊ីខាងកើត៥,២% នៃផលិតផលក្នុងស្រុកសរុប។
- បច្ចុប្បន្ននេះ តំបន់នេះវិនិយោគទឹកប្រាក់ចំនួនប្រមាណ ៨៨១ ប៊ីលានដុល្លារអាម៉េរិកជារៀងរាល់ឆ្នាំលើហេដ្ឋារចនាសម្ព័ន្ធ (សម្រាប់ ២៥ ប្រទេសដែលមានទិន្នន័យគ្រប់គ្រាន់ ដែលស្មើនឹង ៩៦% នៃប្រជាជនសរុបក្នុងតំបន់)។ នៅពេលគិតបញ្ចូលការចំណាយលើការកាត់បន្ថយ និងការបន្សាំខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ គម្លាតវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ (ភាពខុសគ្នារវាងតម្រូវការវិនិយោគនិងកម្រិតវិនិយោគបច្ចុប្បន្ន) ស្មើនឹង ២,៤% នៃផលិតផលក្នុងស្រុកសរុបដែលត្រូវបានព្យាករសម្រាប់រយៈពេល៥ឆ្នាំ ចាប់ពីឆ្នាំ២០១៦ ដល់ ឆ្នាំ ២០២០ ។

- បើមិនរាប់បញ្ចូលសាធារណរដ្ឋប្រជាមានិតចិន គម្លាតខាងលើនេះសម្រាប់ប្រទេសផ្សេងៗទៀតនៅអាស៊ី នឹងកើនខ្ពស់ជាង៥% នៃផលិតផលក្នុងស្រុកសរុបដែលត្រូវបានព្យាករ។ កំណែទម្រង់សារពើពន្ធអាចផ្តល់ចំណូលបន្ថែមប្រមាណ ២% នៃផលិតផលក្នុងស្រុកសរុបដើម្បីបង្រួមគម្លាតខាងលើបានក្នុងរង្វង់៤០% សម្រាប់ប្រទេសទាំងនេះ។ ដើម្បីបំពេញបន្ថែម៦០% ដែលនៅសល់ ឬ៣% នៃផលិតផលក្នុងស្រុកសរុបវិស័យឯកជនត្រូវបង្កើនការវិនិយោគពីបច្ចុប្បន្នចំនួន ៦៣ ប៊ីលានដុល្លារអាម៉េរិក ទៅចំនួនខ្ពស់រហូតដល់ ២៥០ ប៊ីលានដុល្លារអាម៉េរិកក្នុងមួយឆ្នាំ សម្រាប់រយៈពេលពីឆ្នាំ២០១៦ដល់ឆ្នាំ២០២០។

រដ្ឋាភិបាលចិនកំពុងបង្កើនការយកចិត្តទុកដាក់របស់ខ្លួនលើការតភ្ជាប់ជាសកល ក្នុងកិច្ចខិតខំប្រឹងប្រែងជំរុញពាណិជ្ជកម្ម ដូចជាការអនុវត្តគំនិតផ្តួចផ្តើមខ្សែក្រវ៉ាត់និងផ្លូវ (Belt and Road Initiative) ជាគំរូស្រាប់។ ដោយសារតំបន់អាស៊ីអាគ្នេយ៍កាន់តែមានសារៈសំខាន់កើនឡើងក្នុងវេទិកាសកល និងមានភូមិសាស្ត្រជិតប្រទេសចិន មូលធនវិនិយោគចិនមួយភាគធំបានផ្តោតសំខាន់លើតំបន់នេះ។ យុទ្ធសាស្ត្រចិនឆ្ពោះទៅកាន់តំបន់អាស៊ីអាគ្នេយ៍ គឺមានគោលបំណងកាត់បន្ថយការពឹងផ្អែករបស់ខ្លួនទៅលើច្រកម៉ាឡាកា និងធានាការតភ្ជាប់ផ្ទាល់ទៅកាន់សមុទ្រឥណ្ឌាតាមរយៈប្រទេសមីយ៉ាន់ម៉ា (ដោយកំពង់ផែថ្មីមួយកំពុងត្រូវបានដំណើរការសាងសង់នៅទីក្រុងចារព្យូរ (kyaukpyu) បន្ទាប់ពីបញ្ចប់ការសាងសង់បំពង់បង្ហូរប្រេងភ្ជាប់ទៅខេត្តយិនណានក្នុងឆ្នាំ២០១៧) ដែលយុទ្ធសាស្ត្រនេះឆ្លុះបញ្ចាំងពីការបំពេញគ្នាទៅវិញទៅមករវាងគំនិតផ្តួចផ្តើមខ្សែក្រវ៉ាត់និងផ្លូវ គម្រោងអនុតំបន់ទន្លេមេគង្គ។ អ្វីដែលជាអាទិភាពចម្បងនោះគឺ ច្រករបៀងសេដ្ឋកិច្ចរវាងប្រទេសចិននិងតំបន់អាស៊ីអាគ្នេយ៍ [៤០]។

ប្រទេសថៃជាប្រទេសដ៏សំខាន់មួយក្នុងការពង្រឹងការតភ្ជាប់ក្នុងប្រទេសអាស៊ីអាគ្នេយ៍ដីគោក (កម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម) ជាពិសេសតាមរយៈច្រករបៀងសេដ្ឋកិច្ចខាងកើតដែលប្រកបដោយមហិច្ឆតា និងគំនិតផ្តួចផ្តើមយុទ្ធសាស្ត្រកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចមេគង្គ-ចៅប្រាយ៉ា-អេយ៉ាវ៉ាឌី (Ayeyawady-Chao Pharaya-Mekong Economic Cooperation Strategy) ដែលបានចាប់ផ្តើមក្នុងឆ្នាំ២០០៣ ដើម្បីគាំទ្រការអភិវឌ្ឍក្នុងតំបន់មេគង្គ [៤១]។

ប្រទេសចិនបានចាប់ផ្តើមការវិនិយោគក្នុងទឹកប្រាក់ចំនួន ២៣ប៊ីលានដុល្លារអាម៉េរិក លើបណ្តាញផ្លូវដែករួមទាំងបណ្តាញផ្លូវដែកសិង្ហបុរី-គុនមិញ (the Singapore-Kunming Rail Link)។ ការវិនិយោគដំបូងពង្រីកបណ្តាញផ្លូវដែកល្បឿនលឿនដែលមានស្រាប់ក្នុងប្រទេសចិន ឆ្លងកាត់ប្រទេសឡាវទៅកាន់ទីក្រុងវៀងចន្ទន៍។ បណ្តាញនេះនឹងតភ្ជាប់ទៅខ្សែក្នុងទីក្រុងបាងកក-ណោងខាយ ដែលកំពុងស្ថិតក្នុងដំណើរការសាងសង់ក្នុងកម្រិតរដ្ឋាភិបាល និងរដ្ឋាភិបាលរវាងថៃនិងចិន [៤២]។

ស្របគ្នានេះដែរ រដ្ឋាភិបាលសិង្ហបុរីនិងម៉ាឡេស៊ី បានចាប់ផ្តើមដំណើរការសាងសង់សម្រាប់បណ្តាញផ្លូវដែកល្បឿនលឿនទីក្រុងគូឡាឡាំពួ-សិង្ហបុរី។ គម្រោងទ្រង់ទ្រាយធំនេះមិនត្រឹមតែនឹងលើកកម្ពស់ការតភ្ជាប់រវាងតំបន់អាស៊ាន និងប្រទេសចិនប៉ុណ្ណោះទេ ថែមទាំងអាចជំរុញកំណើនសេដ្ឋកិច្ច បណ្តុះបណ្តាលកម្មករជំនាញ និងបង្កើតការងារផងដែរ [៤៣]។

ក្នុងឆ្នាំ២០១៦ ថ្នាក់ដឹកនាំតំបន់របស់អាស៊ានបានអនុម័តផែនការមេថ្មីមួយនៃការតភ្ជាប់នៅក្នុងតំបន់។ ផែនការនេះមានគោលបំណងបង្កើតយន្តការសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រកបដោយចីរភាព ការពង្រឹងនវានុវត្តន៍ឌីជីថល ការបង្កើតប្រព័ន្ធឡូជីស្ទិកបើកចំហ ការអនុម័តស្តង់ដារថ្មី និងការជំរុញបន្ថែមលើបម្លាស់ទីរបស់ប្រជាជន។ ដោយសារគំនិតផ្តួចផ្តើមខ្សែក្រវ៉ាត់និងផ្លូវមានគោលបំណងរួមដូចគ្នានេះដែរ ប្រទេសអាស៊ានកំពុងព្យាយាមចាប់យកនូវកាលានុវត្តភាពប្រកបដោយសក្តានុពលតាមរយៈគំនិតផ្តួចផ្តើមនេះ។ ជាឧទាហរណ៍ វេទិកាតភ្ជាប់គំនិតផ្តួចផ្តើមខ្សែក្រវ៉ាត់និងផ្លូវ ត្រូវបានបើកដំណើរការដោយសហព័ន្ធធុរកិច្ចសិង្ហបុរី (Singapore Business Federation) និងសមាគមសហគ្រាសចិន (Chinese Enterprise Association) ក្នុងខែសីហា ឆ្នាំ២០១៧។ វេទិកានេះមានគោលបំណងជួយសម្របសម្រួលការតភ្ជាប់រវាងក្រុមហ៊ុនក្នុងប្រទេសសិង្ហបុរី ដែលមានបំណងផ្តល់សេវាកម្មជំនាញ និងវិជ្ជាជីវៈផ្សេងៗ និងក្រុមហ៊ុនដែលទទួលធ្វើគម្រោងខ្សែក្រវ៉ាត់និងផ្លូវ [៤៣]។ កម្មវិធីមួយទៀត ដែលត្រូវបានរៀបចំដោយអាស៊ានគឺ «ច្រកចេញចូលតែមួយ» ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍការផ្លាស់ប្តូរឯកសារទាក់ទងនឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច ក្នុងចំណោមសមាជិកអាស៊ាន។ កម្មវិធីនេះ ត្រូវបានដាក់ចេញក្នុងឆ្នាំ២០១៨ និងត្រូវបានអនុវត្តក្នុងរដ្ឋចំនួន៥ (ឥណ្ឌូនេស៊ី ម៉ាឡេស៊ី សិង្ហបុរី និងវៀតណាម) និងប្រទេសថៃ បានចូលរួមក្នុងឆ្នាំ២០១៩ [៤៤]។ លើសពីនេះទៀត ក្នុងឆ្នាំ២០១៨ ដោយមានការផ្តល់មូលនិធិពីធនាគារអភិវឌ្ឍន៍អាស៊ី បណ្តាញផ្លូវដែក

មួយដែលតភ្ជាប់ពីប្រទេសថៃទៅប្រទេសកម្ពុជាត្រូវបានសាងសង់ឡើងវិញ ហើយសេវាកម្មទូទៅបានចាប់ផ្តើមដំណើរការក្នុងខែកក្កដា ឆ្នាំ២០១៩។ ទោះយ៉ាងនេះក្តី មានសំណួរមួយបានលើកឡើងថា តើគំនិតផ្តួចផ្តើមខ្សែក្រវ៉ាត់និងផ្លូវដែលផ្តោតលើច្រករបៀងជើង-ត្បូងនេះ ស្ថិតក្នុងការប្រកួតប្រជែងកម្រិតណាជាមួយនឹងកម្មវិធីតំបន់ដែលផ្តល់អាទិភាពដល់ការតភ្ជាប់លិច-កើតដើម្បីលើកកម្ពស់សមាហរណកម្មក្នុងតំបន់។

### ផែនទី ២៣៖ ហេដ្ឋារចនាសម្ព័ន្ធ៖ការតភ្ជាប់តំបន់




**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដែលបកដោយវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិនៃកម្ពុជា (NIDIR)។ អ្នកអានអាចទាញយកអត្ថបទដើមជាភាសាអង់គ្លេសពីគេហទំព័រ៖ https://www.pic.org.kh ។

# ៨.៧ សន្តិភាព និងសន្តិសុខ

នៅភាគឦសាន និងភាគអាគ្នេយ៍នៃតំបន់អាស៊ីប៉ាស៊ីហ្វិកដ៏ធំធេងនេះ គឺពុំមានយន្តការសន្តិសុខរួមទេ ។ ទោះជាយ៉ាងនេះក្តី គេឃើញនៅក្នុងតំបន់នេះក៏មានវេទិកាសម្រាប់កិច្ចសន្ទនាមានស្រាប់ ដែលមានលក្ខណៈមិនផ្លូវការ តែពិតជាមានប្រយោជន៍ខ្លាំងណាស់។ វេទិកាទាំងនេះរួមមាន វេទិកាតំបន់អាស៊ានឆ្នាំ១៩៩៤ (1994 ASEAN Regional Forum) ដែលមានបញ្ចូលដៃគូដូចជាសហភាពអឺរ៉ុប កិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ាន កិច្ចសន្ទនាសាំងគ្រី-ឡា (the Shangri-La Dialogue) ដែលរៀបចំក្នុងប្រទេសសិង្ហបុរី និងវេទិកាផ្សេងៗទៀតសម្រាប់កិច្ចសន្ទនាថ្នាក់តំបន់(អាស៊ានបូកមួយ និងបូកបី)។

អាស៊ាន ដែលមានលក្ខណៈបែបជាដំណើរការច្រើនជាងគោលដៅ ពោលគឺជាកន្លែងសម្រាប់ការជជែកដេញដោល និងជាកន្លែងសម្រាប់ធ្វើការងារការទូតក្រៅផ្លូវការកម្រិតទីពីរ និងទីបី [Track II and III diplomacy] ត្រូវបានគេចាត់ទុកជាកម្លាំងចលករមួយសម្រាប់រក្សាសន្តិភាព និងស្ថិរភាព។ អាស៊ានត្រូវបានបង្កើតឡើងក្នុងកាលៈទេសៈដ៏តានតឹង (ការប្រឈមមុខដាក់គ្នារវាងឥណ្ឌូនេស៊ី និងម៉ាឡេស៊ី ការទទួលបានឯករាជ្យរបស់សិង្ហបុរីក្នុងឆ្នាំ១៩៦៥ និងការទាមទារកាន់កាប់រដ្ឋសាបាពីសំណាក់ទីក្រុងម៉ានីល)។ ទោះជាយ៉ាងនេះក៏ដោយ អង្គការនេះមានភាពវៃឆ្លាតគ្រប់គ្រាន់ក្នុងការបើកច្រកទទួលយកប្រទេសជាសមាជិក ដែលអង្គការនេះខ្លួនឯងប្រឆាំងកាលពីពេលទើបបង្កើតដំបូង (វៀតណាម)។ អាស៊ានអាចដើរតួនាទីបង្រួបបង្រួមក្នុងតំបន់ ដើម្បីទប់ទល់ទៅនឹងការព្រួយបារម្ភពីការងើបឡើងរបស់ចិន។ ការជជែកពិភាក្សាក្នុងអាស៊ាននៅតែបន្តទាក់ទងនឹងលទ្ធភាព និងមធ្យោបាយនៃការបង្កើតនិម្មាបនកម្មសន្តិសុខមួយទប់ទល់ប្រឆាំងនឹងការគំរាមកំហែងទាំងបែបប្រពៃណី និងបែបមិនប្រពៃណី ដែលភាគច្រើននៃការគំរាមកំហែងទាំងនោះជាបញ្ហាឆ្លងដែន។

ភាពតានតឹងកើតមានឡើងសារជាថ្មី លើបញ្ហាព្រំដែនទឹកក្នុងសមុទ្រចិនខាងត្បូង ម្ខាងរវាងចិន (ជាមួយ តៃវ៉ាន់) និងម្ខាងទៀតរវាងចិនជាមួយវៀតណាម និងហ្វីលីពីន។ ព្រំដែនទាំងនេះស្ថិតនៅតាមផ្លូវទឹកដ៏មមាញឹកបំផុតមួយចំនួនរបស់ពិភពលោក។ ដោយសារប្រទេសចិនកំពុងបន្តពង្រីកឥទ្ធិពលរបស់ខ្លួន ប្រទេសជាសមាជិក អាស៊ានមួយចំនួនកំពុងស្វែងរកកិច្ចព្រមព្រៀងសន្តិសុខជាមួយនឹងសហរដ្ឋអាមេរិក និងកំពុងអភិវឌ្ឍសមត្ថភាពការពារជាតិរបស់ពួកគេផ្ទាល់។ អាស៊ីអាគ្នេយ៍គឺជាតំបន់ដ៏សំខាន់មួយ ហើយអ្វីដែលកើតឡើងក្នុងតំបន់នេះនឹងធ្វើឲ្យមានផលប៉ះពាល់ជាសកល ដោយសារតែជម្លោះផលប្រយោជន៍នៃមហាអំណាចពីខាងក្រៅតំបន់។ ហេតុនេះ ហើយទើបអាស៊ានមានតួនាទីស្នូលនិងជាដៃគូដ៏គួរឲ្យទាក់ទាញសម្រាប់ប្រទេសក្រៅតំបន់។

ទស្សនៈស្តីពី សហគមន៍សន្តិសុខត្រូវបានលើកឡើងដំបូងបង្អស់នៅទីក្រុងបាលីក្នុងឆ្នាំ២០០២។ ទំនាក់ទំនងសន្តិសុខកាន់តែត្រូវបានពង្រឹងឲ្យខ្លាំងក្លានៅក្នុងតំបន់នេះ ដែលមានឧទាហរណ៍ជាក់ស្តែងដូចជា មានសន្និសីទប្រចាំឆ្នាំនៃមេដឹកនាំការពារជាតិ រួមមានកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ាន (ADMM)តាំងពីឆ្នាំ២០០៦ កិច្ចប្រជុំនៃមន្ត្រីជាន់ខ្ពស់ផ្នែកការពារជាតិអាស៊ាន (ADSOM) ចាប់តាំងពីឆ្នាំ២០០៩ និងវេទិកាដែនទឹក និងមជ្ឈមណ្ឌលបញ្ចូលព័ត៌មានអាស៊ាន (ASEAN Maritime Forum and Fusion Center)។ វេទិកាទាំងអស់នេះមានគោលបំណងរួមមួយគឺជំរុញរដ្ឋជាសមាជិកអាស៊ានទាំងអស់ឲ្យលើកកម្ពស់ការទូតប្រកបដោយតុល្យភាពដើម្បីជៀសវាងការជាប់អន្ទាក់រវាងមហាអំណាចពីរ។

## បញ្ហាព្រំដែន និងដែនដីដែលចម្រូងចម្រាស់ និងអូសបន្លាយ

គោលការណ៍ព្រំដែនដែលមិនអាចកែប្រែបាន ដែលបន្សល់ទុកពីសម័យអាណានិគមត្រូវបានគោរព និងអនុវត្តតាមនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ ប៉ុន្តែបញ្ហាតានតឹងមួយចំនួននៅតែបន្តកើតមានទាក់ទងនឹងការគូសបន្ទាត់ព្រំដែនជាក់លាក់នៃផ្នែកមួយចំនួននៃព្រំដែនអន្តរជាតិ (រវាងវៀតណាមនិងកម្ពុជា កម្ពុជានិងឡាវ ឡាវនិងថៃ ឥណ្ឌូនេស៊ី និងម៉ាឡេស៊ី និងទីម័រខាងកើតនិងឥណ្ឌូនេស៊ី)។ ជាឧទាហរណ៍មួយ គឺបញ្ហាព្រះវិហារដែលត្រូវបានបិទបញ្ចប់ជាស្ថាពរដោយសាលក្រមតុលាការយុត្តិធម៌អន្តរជាតិក្នុងខែវិច្ឆិកា ឆ្នាំ២០១៣។

បញ្ហាជម្លោះព្រំដែនគោក និងព្រំដែនទឹកនៅតែបន្តកើតមានដូចគ្នា។ ទោះយ៉ាងនេះក្តី តំបន់អភិវឌ្ឍន៍រួមផ្សេងៗត្រូវបានបង្កើតឡើងដោយជោគជ័យនៅក្នុងតំបន់នានាដែលមានសញ្ញាច្បាស់ថា អត្ថប្រយោជន៍មានច្រើនលើសលុប បើសិនជម្លោះត្រូវបានផ្អាក។ ឧទាហរណ៍ជាក់ស្តែងទាក់ទងនឹងករណីនេះ គឺការចុះកិច្ចព្រមព្រៀងក្នុងឆ្នាំ១៩៧៩ ដោយអាជ្ញាធររួមម៉ាឡេស៊ីនិងថៃ (MTJA ដែលបានធ្វើបច្ចុប្បន្នភាពក្នុងឆ្នាំ១៩៩០) ដើម្បីគ្រប់គ្រងតំបន់ទំហំ ៧២៥០គីឡូម៉ែត្រការ៉េ សម្រាប់ប្រតិបត្តិការជីករកឧស្ម័ន និងប្រេងរួមដោយក្រុមហ៊ុន Hess Oil ក្រុមហ៊ុន PTT Exploration and Production Public Company Limited និងក្រុមហ៊ុន Petronas។

បញ្ហាព្រំដែនទឹកដីតានតឹងជាបញ្ហាស្មុគស្មាញផ្នែកការទូត [៤៦] ដោយសារតែសណ្ឋាននៃភូមិសាស្ត្រ (រដ្ឋប្រជុំកោះពីរក្នុងនោះមានមួយត្រូវបានបែងចែកជាពីរផ្នែក និងច្រកសមុទ្រមួយចំនួនដែលបម្រើផលប្រយោជន៍ធំៗ) បញ្ហាប្រយោជន៍សេដ្ឋកិច្ច (ប្រេងនិងឧស្ម័ន និងនេសាទ) និងឥរិយាបថដាច់ខាតផ្នែកយុទ្ធសាស្ត្ររបស់ប្រទេសចិន ដែលចង់ប្រើប្រាស់តំបន់នេះដោយពេលខ្លះមិនខ្វល់ពីច្បាប់សមុទ្រ។ កោះ និងតំបន់ថ្មប៉ប្រះទឹកជាច្រើនត្រូវបានទាមទារកាន់កាប់ដោយរដ្ឋមួយចំនួននៅជាប់សមុទ្រ។ លើសពីនេះទៀត ៥០%នៃការឆ្លងកាត់តាមសមុទ្ររបស់ពិភពលោកគឺសុទ្ធតែកាត់តាមសមុទ្រចិនខាងត្បូង និងច្រកសមុទ្រ។ ម្យ៉ាងទៀតចរាចរណ៍តាមផ្លូវទឹកបានកើនឡើងប្រាំបីដងក្នុងរយៈពេល៣០ឆ្នាំនេះ។ ជារួមពុំទាន់មានដំណោះស្រាយណាមួយលេចឡើងនៅឡើយទេ។

តំបន់នេះស្ថិតនៅក្នុងទីតាំងដ៏សំខាន់មួយនៃទ្វីបអាស៊ី ដែលកំពុងផ្លាស់ប្តូរយ៉ាងឆាប់រហ័សក្រោមឥទ្ធិពលនៃមហាអំណាចដែលបានចាក់គ្រឹះ និងមហាអំណាចសេដ្ឋកិច្ចដែលកំពុងងើបឡើងថ្មី។ ក្នុងន័យនេះ គម្រោង «ខ្សែក្រវ៉ាត់មួយ ផ្លូវមួយ» ថ្មីដែលមានសក្តានុពលសម្រាប់នាពេលអនាគតរបស់ចិនបានផ្តល់នូវការរំពឹងទុកថ្មីច្រើន។ រូបភាពពីក្រោយគម្រោងនេះគឺការលេចឡើងនូវពិភពទ្វេប៉ូលមួយ មិនថាពិតប្រាកដ ឬក៏ជាការសន្មត់ទេ គឺស្ថិតនៅក្រោមឥទ្ធិពលគ្របដណ្តប់របស់ប្រទេសចិន និងសហរដ្ឋអាមេរិក។ បរិការណ៍នេះបានផ្តល់នូវឱកាសថ្មីសម្រាប់ប្រទេសនៅតំបន់អាស៊ីអាគ្នេយ៍ក្នុងការទាញយកប្រយោជន៍ពីការប្រឈមដាក់គ្នារវាងមហាអំណាចទាំងពីរ។ «ការប្រកួតប្រជែងរវាងប្រទេសចិន និងសហរដ្ឋអាមេរិកបានក្លាយជាកត្តាកំណត់រចនាសម្ព័ន្ធនៅក្នុងទិដ្ឋភាពយុទ្ធសាស្ត្ររបស់តំបន់អាស៊ីអាគ្នេយ៍ ដោយសាររដ្ឋនានាក្នុងតំបន់នេះមើលឃើញការប្រឈមដាក់គ្នានេះថា ជាកាលានុវត្តភាពដើម្បីធ្វើពិពិធកម្មដៃគូរបស់ខ្លួនឲ្យស្របជាមួយនឹងប្រពៃណីការទូតមួយដែលបង្កប់ជ្រៅក្នុងយុទ្ធសាស្ត្រផ្សេងៗនៅក្នុងតំបន់។ ជាងនេះទៅទៀត រដ្ឋក្នុងអាស៊ានក៏អាចយកការប្រឈមមុខដាក់គ្នានៃដៃគូប្រកួតប្រជែងនេះ ជាឱកាសដើម្បីរក្សាសេរីភាពក្នុងការបត់បែនក្នុងនយោបាយការបរទេសរបស់ពួកគេដែរ» [៤៧]។

### ផែនទី ២៤៖ បញ្ហាព្រំដែនគោកអាស៊ាន




**ប្រភព៖** For a complete list of sources see page 224

This map is for discussion purposes only. The designations employed and the presentation of the material on this map do not imply the expression of any opinion whatsoever on the part of the Parliamentary Institute of Cambodia or any parties involved in the production of this atlas concerning the legal status of any country, territory, city or area or of its authority, or concerning the delimitation of its frontiers or boundaries.

## ផែនទី ២៥៖ បញ្ហាសមុទ្រចិនខាងត្បូង




**ប្រភព៖** I Made Andi Arsana, Department of Geodetic Engineering, Gadjah Mada University, Indonesia

This map is for discussion purposes only. The designations employed and the presentation of the material on this map do not imply the expression of any opinion whatsoever on the part of the Parliamentary Institute of Cambodia or any parties involved in the production of this atlas concerning the legal status of any country, territory, city or area or of its authority, or concerning the delimitation of its frontiers or boundaries.

## ផែនទី ២៦៖ បញ្ហាឈូងសមុទ្រថៃ




**ប្រភព៖** J.R.V. Prescott, The Gulf of Thailand: maritime limits to conflict and cooperation, MIMA, Kuala Lumpur, Malaysia, 1998, p. 9-11

This map is for discussion purposes only. The designations employed and the presentation of the material on this map do not imply the expression of any opinion whatsoever on the part of the Parliamentary Institute of Cambodia or any parties involved in the production of this atlas concerning the legal status of any country, territory, city or area or of its authority, or concerning the delimitation of its frontiers or boundaries.

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដែលបកដោយវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិនៃកម្ពុជា (NIDIR) ។ អ្នកអានអាចទាញយកអត្ថបទដើមជាភាសាអង់គ្លេសពីគេហទំព័រ៖ https://www.pic.org.kh ។

# ៨.៨ បញ្ហាផ្សេងៗ

## ៨.៨.១ អាស៊ានវិវឌ្ឍឆ្ពោះទៅកាន់សេដ្ឋកិច្ចបៃតង និងឌីជីថល

### សក្តានុពលកំណើន

អាស៊ានដែលមានប្រជាជនជាង ៦៥៧លាននាក់ នៅឆ្នាំ២០១៩ សម្រេចបានកំណើនសេដ្ឋកិច្ចយ៉ាងលឿនជាមធ្យម ៥,៣% ក្នុងមួយឆ្នាំចាប់តាំងពីឆ្នាំ២០០០ និងទទួលបានផលិតផលក្នុងស្រុកសរុប (ផ.ស.ស. ឬ GDP) ចំនួន ២,៨ ទ្រីលានដុល្លារអាមេរិកនៅឆ្នាំ២០១៧ (តារាងទី ១) ហើយបានក្លាយជាតំបន់ដែលមានសេដ្ឋកិច្ចធំទី៥នៃពិភពលោក និងធំទី៣នៅអាស៊ី [៤៨]។ កំណើននេះបានធ្វើឲ្យប្រជាជនរាប់រយលាននាក់ចាកផុតពីភាពក្រីក្រស្របពេលជាមួយនឹងភាពរីកចម្រើនយ៉ាងឆាប់រហ័សនៃនគរូបនីយកម្មនៅទូទាំងតំបន់។ មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ព្យាករថាកំណើននេះនឹងបន្តស្ថេរភាពត្រឹមប្រហែល ៥% ក្នុងមួយឆ្នាំនារយៈពេលកន្លះទសវត្សរ៍ខាងមុខ ដែលមានល្បឿនយឺតជាងបណ្តាប្រទេសក្នុងតំបន់រួមមានប្រទេសចិន (៥,៧%) និងឥណ្ឌា (៧,៣%)។ កំណើនក្នុងតំបន់បាននឹងកំពុងនាំមុខដោយសមាជិកអាស៊ាន ៥ (ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន ថៃ និងវៀតណាម) ដែលមានចំណែក ៨៤% នៃ GDP អាស៊ានសរុបនៅឆ្នាំ២០១៧ និងប្រហែល ៨៦% នៅឆ្នាំ២០២៤ បើប្រៀបធៀបទៅនឹងបណ្តាប្រទេស CLM ( កម្ពុជា ឡាវ និង មីយ៉ាន់ម៉ា) ដែលមានចំណែកសរុបប្រហែល ៣,៦% នៅឆ្នាំ២០១៧ និង ៣,៩%សម្រាប់ឆ្នាំដូចគ្នា។

**តារាងទី ១**: GDP បច្ចុប្បន្ននិងព្យាករណ៍ នៃបណ្តាប្រទេសអាស៊ាន, ២០១៧ - ២០២៤

| | GDP in Billions (Current prices in US$) | | GDP per Capita (Current price in US$) | | Real GDP growth (Annual percent change) | | | |
|---|---|---|---|---|---|---|---|---|
| | 2017 | 2024 | 2017 | 2024 | 2017 | 2018 | 2019 | Av. 2020-24 |
| ចិន | 12.062 | 20.979 | 8.677 | 14.812 | 6,8 | 6,6 | 6,1 | 5,7 |
| ឥណ្ឌា | 2.652 | 4.632 | 2.014 | 3.210 | 7,2 | 6,8 | 6,1 | 7,3 |
| អាស៊ាន | 2.777 | 4.375 | 4.323 | 6.342 | 5,3 | 5,2 | 4,6 | 5,1 |
| **អាស៊ាន 5** | **2.324** | **3.744** | **5.184** | **7.804** | **5,7** | **5,5** | **4,9** | **5,3** |
| 1. ឥណ្ឌូនេស៊ី | 1.015 | 1.596 | 3.885 | 5.667 | 5,1 | 5,2 | 5 | 5,2 |
| 2. ម៉ាឡេស៊ី | 319 | 505 | 9.960 | 14.468 | 5,7 | 4,7 | 4,5 | 4,8 |
| 3. ហ្វីលីពីន | 314 | 548 | 2.989 | 4.674 | 6,7 | 6,2 | 5,7 | 6,4 |
| 4. ថៃ | 455 | 700 | 6.731 | 10.257 | 4 | 4,1 | 2,9 | 3,5 |
| 5. វៀតណាម | 220 | 395 | 2.353 | 3.952 | 6,8 | 7,1 | 6,5 | 6,5 |
| **ព្រុយណេ និងសិង្ហបុរី** | **351** | **455** | **44.267** | **53.023** | **2,5** | **1,6** | **1,2** | **2,6** |
| 6. ព្រុយណេ | 12 | 14 | 28.237 | 30.414 | 1,3 | 0,1 | 1,8 | 3,3 |
| 7. សិង្ហបុរី | 338 | 441 | 60.297 | 75.632 | 3,7 | 3,1 | 0,5 | 1,9 |
| **CLM Countries** | **101** | **172** | **1.669** | **2.664** | **6,7** | **6,9** | **6,5** | **6,5** |
| 8. កម្ពុជា | 22 | 40 | 1.386 | 2.260 | 7 | 7,5 | 7 | 6,6 |
| 9. ឡាវ | 17 | 30 | 2.455 | 3.856 | 6,8 | 6,3 | 6,4 | 6,7 |
| 10. មីយ៉ាន់ម៉ា | 61 | 102 | 1.166 | 1.875 | 6,3 | 6,8 | 6,2 | 6,2 |

**ប្រភព៖** International Monetary Fund (October 2019) available https://www.imf.org/external/datamapper/datasets

> “ កិច្ចការនេះតម្រូវឲ្យមានការបង្កើតបរិស្ថានបទបញ្ញត្តិមួយដែលលក្ខណៈអំណោយផល និងលើកកម្ពស់ការរីកចម្រើនផ្នែកបច្ចេកវិទ្យា ដើម្បីធានាបានកំណើនប្រកបដោយបរិយាបន្ន។ ”

រដ្ឋសមាជិកអាស៊ាន (AMS) បាននឹងកំពុងធ្វើការរួមគ្នាដើម្បីឆ្លើយតបទៅនឹងផែនការលម្អិតនៃសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC Blueprint) ២០២៥ និងផែនការសកម្មភាពប្រកួតប្រជែងអាស៊ាន (ACAP) ២០១៦-២០២៥ ដើម្បីទាក់ទាញវិនិយោគផ្ទាល់ពីបរទេស (FDI) និងបង្កើនភាពជាដៃគូពាណិជ្ជកម្មក្នុងតំបន់និងពិភពលោក។ កិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់ AMS បាននាំមកនូវកំណើន FDI គួរឲ្យកត់សម្គាល់ ពីឆ្នាំ២០០០ ដល់ឆ្នាំ២០១៧ បើទោះបីជាមានការធ្លាក់ចុះជិត ៥០% ក្នុងអំឡុងពេលវិបត្តិហិរញ្ញវត្ថុសកលឆ្នាំ២០០៨-២០០៩ ក៏ដោយ។ FDI បានកើនឡើងដល់ ២៧ ប៊ីលានដុល្លារ អាម៉េរិកដែលមានប្រភពពីបណ្ដាប្រទេសសមាជិកអាស៊ាន និង ១០៨,៦ ប៊ីលានដុល្លារអាម៉េរិក ដែលមានប្រភពមកពីក្រៅតំបន់អាស៊ានក្នុងរយៈពេលនេះ (តារាងទី ២) ។ ភស្តុតាងនៃភាពជោគជ័យនេះអាចបញ្ជាក់បានផងដែរដោយតុល្យភាពវិជ្ជមាននៃពាណិជ្ជកម្ម ដែលមានការនាំចេញប្រមាណ ១ ៣២២ ប៊ីលានដុល្លារអាម៉េរិក ធៀបនឹងការនាំចូលប្រហែល ១ ២៥២ ប៊ីលានដុល្លារអាម៉េរិកនៅឆ្នាំ២០១៧ ពោលគឺបានកើនឡើងពី ៤២៥ប៊ីលានដុល្លារអាម៉េរិកនៃការនាំចេញ និង ៣៦៥ ប៊ីលានដុល្លារអាម៉េរិកនៃការនាំចូលក្នុងឆ្នាំ២០០០ [៤៩]។

**តារាង ២៖** ភាគីពាណិជកម្ម, ២០១៧

| | US$ Billion | Percentage Share |
|---|---|---|
| Intra-ASEAN | 310.8 | 24% |
| Trade Partners | 1,011.4 | 76% |
| ចិន | 186.5 | 14% |
| សហភាពអឺរ៉ុប-28 | 158.0 | 12% |
| សហរដ្ឋអាម៉េរិក | 142.7 | 11% |
| ជប៉ុន | 105.8 | 8% |
| កូរ៉េ | 55.0 | 4% |
| ឥណ្ឌា | 45.3 | 3% |
| អូស្ត្រាលី | 34.6 | 3% |
| កាណាដា | 7.8 | 1% |
| រុស្ស៊ី | 5.9 | 0% |
| នូវែលសេឡង់ | 5.5 | 0% |
| ផ្សេងៗ | 264.4 | 20% |

**ប្រភព៖** ASEAN year Book 2018 [៤៨, ទំ.៤៣]

កំណើនការនាំចេញនៃ AMS មិនស្មើគ្នាទេ អាស្រ័យទៅលើកម្រិតនៃការចូលរួមនៃបណ្ដាប្រទេសនីមួយៗនៅក្នុងបណ្ដាញផលិតកម្មសកល និងលទ្ធភាពជាក់ស្ដែងដែលពួកគេចាប់យកឱកាស និងប្រយោជន៍តាមរយៈប្រព័ន្ធពាណិជ្ជកម្មអាស្រ័យលើច្បាប់។ កំណើន GDP នៃប្រទេសសមាជិកអាស៊ានភាគច្រើនបានថយចុះនៅឆ្នាំ២០១៨ហើយនៅតែបន្តធ្លាក់ចុះនៅឆ្នាំ២០១៩ (តារាងទី ១) ដោយរងផលប៉ះពាល់ពីភាពមិនប្រាកដប្រជាដែលបណ្ដាលមកពីការកើនឡើងភាពតានតឹងពាណិជ្ជកម្ម ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុភាពមិនច្បាស់លាស់ផ្នែកនយោបាយ និងការពឹងផ្អែកច្រើនទៅលើពាណិជ្ជកម្មខាងក្រៅតំបន់ [៥០]។ ទោះបីជាមានកត្តាប្រឈមទាំងនេះក៏ដោយប្រទេសសមាជិកអាស៊ានមួយចំនួននៅតែមានភាពធន់ ដោយសារតែតម្រូវការក្នុងស្រុកមានភាពរឹងមាំ ស្របពេលជាមួយនឹងកំណើនយ៉ាងលឿននៃនគរូបនីយកម្ម និងការកើនឡើងនៃប្រជាជនចំណូលមធ្យម ដែលជាចលករទាក់ទាញ FDI ចូលមកតំបន់អាស៊ាននេះ។

អាស៊ានបន្តទាក់ទាញវិនិយោគិនពិភពលោកដោយសារថាមវន្តនៃតំបន់និងការប្ដេជ្ញាចិត្តខ្ពស់ដើម្បីពង្រីកសមាហរណកម្មសេដ្ឋកិច្ច។ សក្ដានុពលនេះត្រូវបានពង្រឹងដោយកម្លាំងពលកម្មដែលកំពុងកើនឡើងនៅក្នុងតំបន់។ ប្រជាជនប្រមាណជាង ១០០ លាននាក់ត្រូវបានប៉ាន់ប្រមាណថាបានចូលរួមក្នុងកម្លាំងពលកម្មរបស់អាស៊ានក្នុងរយៈពេល ២០ ឆ្នាំកន្លងមក និង ៥៩ លាននាក់ផ្សេងទៀតនឹងត្រូវបានបន្ថែមនៅឆ្នាំ២០៣០ ដែលនឹងធ្វើឲ្យតំបន់នេះមានកម្លាំងពលកម្មធំទី ៣ នៅលើពិភពលោកបន្ទាប់ពីប្រទេសចិននិងឥណ្ឌា [៥១] ។

អាស៊ានជាតំបន់ដែលមានប្រជាជនវ័យក្មេង មានចំណេះដឹង និងមានកំណើននគរូបនីយកម្មប្រកបដោយសុធន្ទៈ។ តម្រូវការក្នុងស្រុក ជាពិសេសការចំណាយក្នុងគ្រួសារត្រូវបានរំពឹងថា នឹងបន្តកើនឡើងដោយភាពសកម្មរស់រវើកនៃទីផ្សារការងារ [៥៨]។ ដើម្បីបន្តកសាងភាពជោគជ័យរបស់ខ្លួន បណ្ដាសមាជិកអាស៊ានបានប្ដេជ្ញារួមគ្នាលើកវិធានការលុបបំបាត់ភាពក្រីក្រ កាត់បន្ថយវិសមភាពសង្គម បង្កើតការងារសមរម្យបន្ថែមទៀត ជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ កែលម្អផលិតភាពកម្លាំងពលកម្ម និងពង្រឹងសមត្ថភាពរដ្ឋបាលនិងអភិបាលកិច្ចស្ថាប័នជាតិដើម្បីធានាចីរភាពកំណើនរយៈពេលវែង [៥៩]។ AMS បានប្ដេជ្ញារួមគ្នាបង្កើតបរិស្ថានបទបញ្ញត្តិមួយដែលមានលក្ខណៈ

អំណោយផល និងជំរុញការចាប់យកបច្ចេកវិទ្យាដើម្បីជានាកំណើនប្រកបដោយបរិយាបន្ន និងបង្កើនផលិតភាពកម្លាំងពលកម្មដែលកំពុងកើនឡើងនៅក្នុងតំបន់។ ថ្វីបើការអភិវឌ្ឍសេដ្ឋកិច្ចមានកម្រិតខុសៗគ្នាក៏ដោយ អាស៊ានកំពុងឆ្ពោះទៅមុខក្នុងការប្រើប្រាស់បច្ចេកវិទ្យាទំនើប និងឧបករណ៍ឌីជីថលដើម្បីទ្រទ្រង់កំណើននៅក្នុងតំបន់[៤៧,៥០,៥១]។ មេដឹកនាំនយោបាយនៃAMSក៏បានប្ដេជ្ញាជំរុញពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិចនិងសេដ្ឋកិច្ចឌីជីថលផងដែរ ដោយកំពុងសម្លឹងឆ្ពោះទៅមុខតាមរយៈការពង្រីកកិច្ចសហប្រតិបត្តិការរវាងបណ្ដាប្រទេសនៅក្នុងអាស៊ាននិងក្រៅអាស៊ាន ដោយការចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយចំនួន ស្ដីពីការផ្លាស់ប្ដូរឌីជីថលឆ្ពោះទៅរកឧស្សាហកម្ម ៤.០ [៦០]។

## សេដ្ឋកិច្ចឌីជីថល

អាស៊ីអាគ្នេយ៍កំពុងស្ថិតក្នុងដំណើរការចាប់យកសេដ្ឋកិច្ចឌីជីថល ដែលរួមមាន៖ ការប្រើប្រាស់អ៊ិនធឺណេតនិងប្រព័ន្ធផ្សព្វផ្សាយសង្គម ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច សេវាកម្មហិរញ្ញវត្ថុឌីជីថលនិងពាណិជ្ជកម្មសេវាកម្មឆ្លងដែន [៦១]។ ធនាគារពិភពលោក និង IMF បានផ្ដល់កិត្តិយសដល់តំបន់នេះថា កំពុងបង្កើតមូលដ្ឋានគ្រឹះដើម្បីក្លាយជាសេដ្ឋកិច្ចនិងសង្គមឌីជីថលនៅមួយទសវត្សរ៍ខាងមុខនេះ ហើយការប្រែប្រួលនេះនឹងជំរុញសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់និងសកលឲ្យកាន់តែស៊ីជម្រៅផងដែរ [៦២]។ អាស៊ាននឹងក្លាយជាតំបន់មានសេដ្ឋកិច្ចធំបំផុតទីបួននៅលើពិភពលោកនៅឆ្នាំ២០៣០ ដោយមានការប្រែប្រួលប្រជាសាស្ត្រឆ្ពោះទៅរកប្រជាជនវ័យក្មេង និយមជីវភាពស៊ីវិល័យ និងប្រើបច្ចេកវិទ្យាឌីជីថលយ៉ាងឆាប់រហ័ស ដែលអាចជួយក្នុងការគាំទ្រដល់កំណើនសេដ្ឋកិច្ចក្នុងតំបន់។ ដោយមានការរីកសាយនៃទីផ្សារទូរស័ព្ទចល័តជាច្រើននៅក្នុងតំបន់ ចំនួននៃការប្រើប្រាស់អ៊ិនធឺណេតនិងការប្រើប្រាស់បច្ចេកវិទ្យាមានការកើនឡើងយ៉ាងឆាប់រហ័ស (ឧបសម្ព័ន្ធ ១) ដែលនឹងបន្តជំរុញកំណើនសេដ្ឋកិច្ចឌីជីថលរហូតទៅដល់ជាង៧ដងពី ៣១ ប៊ីលានដុល្លារអាម៉េរិកក្នុងឆ្នាំ២០១៥ [៦៣] ដល់ ២៤០ ប៊ីលានដុល្លារអាម៉េរិកនៅឆ្នាំ២០២៥ (រូបភាពទី ១) [៦៤] ។

នៅឆ្នាំ២០១៦ សេដ្ឋកិច្ចឌីជីថលមានទំហំប្រហែល ៧%នៃ GDP របស់អាស៊ាន ធៀបទៅនឹងសហរដ្ឋអាម៉េរិក ៣៥% និង ចិនប្រហែល ១៦% ដែលទទួលបានពីគ្រប់ទម្រង់នៃដំណើរការសេដ្ឋកិច្ច ប្រតិបត្តិការ និងសកម្មភាពដែលដំណើរការដោយប្រើអ៊ិនធឺណេត។ទោះនៅយឺតជាងសហភាគីសកលក៏ដោយ ក៏សេដ្ឋកិច្ចឌីជីថលអាស៊ានបាននាំមកនូវចំណូលប្រមាណ ១៥០ ប៊ីលានដុល្លារអាម៉េរិកក្នុងមួយឆ្នាំ (៥៣ ទំព័រ២៥) ដែលប្រសិនបើដំណើរការបានពេញលេញអាចនឹងនាំចំណូលសរុបប្រហែល ១ ទ្រីលានដុល្លារអាម៉េរិកបន្ថែមទៀតដល់សេដ្ឋកិច្ចរបស់ខ្លួននៅឆ្នាំ ២០២៥ [៦២, ទំព័រ២៥]។

ប្រជាជនជាង ៤៥០ លាននាក់នៅក្នុងអាស៊ានបច្ចុប្បន្នទទួលបានសេវាប្រើប្រាស់អ៊ិនធឺណេតនៅឆ្នាំ២០១៩ ដែលចំនួននេះប្រហែលជា ១០% នៃអ្នកប្រើប្រាស់អ៊ិនធឺណេតទូទាំងពិភពលោក (ឧបសម្ព័ន្ធ ១) និងបានកើនឡើងយ៉ាងឆាប់រហ័សពី ១២៧ លាននាក់ក្នុងឆ្នាំ២០១១ [៦២, ទំ.៤២]។ គំលាតនៃលទ្ធភាពប្រើប្រាស់អ៊ិនធឺណេតនៅតែមាននៅតាមបណ្ដាប្រទេសក្នុងតំបន់ ប៉ុន្តែអត្រាជាមធ្យមនៃអ្នកប្រើប្រាស់នៅក្នុងប្រទេសអាស៊ានចំនួន៨ គឺខ្ពស់ជាងមធ្យមភាគសកល ៥៧%។ប្រទេសមួយចំនួនដូចជាប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា ថ្វីបើមិនទាន់មានសមត្ថភាពដូចប្រទេសជិតខាងនៅអាស៊ានក៏ដោយ ថ្មីៗនេះត្រូវបានសង្កេតឃើញថា មានការពង្រីកបណ្ដាញ និងការប្រើប្រាស់សេវាកម្មតាមអនឡាញ។

**រូបភាពទី១:** តម្លៃនៃសេដ្ឋកិច្ចតាមអ៊ិនធឺណេតនៅអាស៊ីអាគ្នេយ៍គិតជាពាន់លានដុល្លារឆ្នាំ២០១៩-២០២៥



គួរកត់សំគាល់ AMS បានបង្ហាញពីកំណើនវិនិយោគនៅក្នុងវិស័យសេដ្ឋកិច្ចឌីជីថលរបស់ពួកគេរួមមាន៖ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក បច្ចេកវិទ្យាហិរញ្ញវត្ថុ ការអភិវឌ្ឍមជ្ឈមណ្ឌលទិន្នន័យ និងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យា។ កំណើននេះបានកើតមាននៅក្នុងវិស័យឧស្សាហកម្ម និងពាណិជ្ជកម្ម ដូចជាសេវាកម្មហិរញ្ញវត្ថុ ទំនិញប្រើប្រាស់ សេវាកម្មវេជ្ជសាស្ត្រ និងឧបករណ៍ទូរគមនាគមន៍ និងដឹកជញ្ជូន ហើយនៅក្នុងប្រទេសមួយចំនួនមានផ្នែកស្វ័យប្រវត្តិកម្ម [៦១] ។

ការពង្រឹងបរិយាកាសវិនិយោគគឺជាតម្រូវការមួយសម្រាប់គាំទ្រសេដ្ឋកិច្ចឌីជីថលឈានឆ្ពោះទៅរកសមាហរណកម្មសេដ្ឋកិច្ចបរិយាបន្ននៅក្នុងបណ្តាប្រទេសអាស៊ាន។ បច្ចុប្បន្នមានតែប្រទេសសិង្ហបុរីទេដែលជាប់ចំណាត់ថ្នាក់ជាប្រទេសឌីជីថលជឿនលឿននៅតំបន់អាស៊ី បន្ទាប់មកគឺម៉ាឡេស៊ី។ ជោគជ័យនៃសេដ្ឋកិច្ចឌីជីថលនៅក្នុង AMS ផ្សេងទៀតអាស្រ័យលើសមត្ថភាពនៃបណ្តាប្រទេសនីមួយៗ ក្នុងការឆ្លើយតបទៅនឹងការវិវឌ្ឍគោលនយោបាយ និងទីផ្សារទាក់ទងនឹងមូលដ្ឋានគ្រឹះទាំង ៥ រួមមាន៖ ការតភ្ជាប់ ជំនាញ ការទូទាត់ ការដឹកជញ្ជូន និងគោលនយោបាយ និងបទបញ្ញត្តិពាណិជ្ជកម្មផ្សេងៗ ប្រសិនបើពួកគេប្តេជ្ញាថានឹងទាញយកប្រយោជន៍ពីសក្តានុពលនៃកំណើន ឌីជីថលនេះ (បង្ហាញក្នុងរូបភាព ១) ។

ការប្រែប្រួលឌីជីថល គឺស្ថិតនៅក្រោមធំត្រនៃកិច្ចព្រមព្រៀងជាច្រើនស្តីពី ការផ្លាស់ប្តូរឌីជីថលឆ្ពោះទៅរកបដិវត្តឧស្សាហកម្មទី ៤ (ឧស្សាហកម្ម ៤.០) ដែលបានចុះហត្ថលេខាដោយមេដឹកនាំនៃ AMS ។ គួរកត់សម្គាល់ថាកិច្ចព្រមព្រៀងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិចដំបូងបង្អស់ធ្វើឡើងនៅខែវិច្ឆិកា ឆ្នាំ២០១៨ ដែលបានកំណត់នូវសក្តានុពលនៃកំណើនសេដ្ឋកិច្ចឌីជីថលក្នុងតំបន់ សម្តៅជំរុញតំបន់អាស៊ានឲ្យក្លាយទៅជាមជ្ឈមណ្ឌលឌីជីថលពិភពលោក ពង្រឹងកិច្ចសហប្រតិបត្តិការដើម្បីលើកកម្ពស់ភាពប្រកួតប្រជែងនៃឧស្សាហកម្ម ICT ការអភិវឌ្ឍនៃអាជីវកម្មអេឡិចត្រូនិច និងការសម្របសម្រួលនៃការភ្ជាប់ឌីជីថល [៥៨] ។

ការចំណាយលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិចក្នុងតំបន់មានចំនួនលើស ៥០ ប៊ីលានដុល្លារអាមេរិកក្នុងឆ្នាំ២០១៨ ដែលបានកើនឡើងជាង ២០%ប្រចាំឆ្នាំ។ សេដ្ឋកិច្ចអ៊ិនធឺណេតនឹងឈានដល់ ៨% នៃ GDP អាស៊ីអាគ្នេយ៍នៅឆ្នាំ២០២៥ ដែលកើនឡើងពីប្រមាណ ៣% ក្នុងឆ្នាំ២០១៨ [៦៥] ។

បណ្តាប្រទេសអាស៊ាន កំពុងចាត់វិធានការនៅថ្នាក់ជាតិដើម្បីលើកទឹកចិត្តដល់ការផ្លាស់ប្តូរនេះ។ ជាឧទាហរណ៍ ប្រទេសសិង្ហបុរីបានអនុវត្តគំនិតផ្តួចផ្តើម ទីក្រុងវៃឆ្លាត (Smart City initiative) របស់ខ្លួន ខណៈដែលប្រទេសថៃមានផែនការអភិវឌ្ឍសមត្ថភាពឌីជីថលលើគ្រប់វិស័យសេដ្ឋកិច្ច។ ប្រទេសវៀតណាមបានអនុម័តគម្រោងនៃការផ្លាស់ប្តូរឌីជីថលជាតិនៅក្នុងខែវិច្ឆិកាឆ្នាំ២០១៩ ក្នុងគោលបំណងដាក់ប្រទេសខ្លួនជាសេដ្ឋកិច្ចឌីជីថលឈានមុខនៅអាស៊ាននៅត្រឹមឆ្នាំ២០៣០។ ប្រទេសម៉ាឡេស៊ីបង្កើតតំបន់ពាណិជ្ជកម្មសេរីឌីជីថលពិសេសនៅឆ្នាំ២០១៧ ស្របពេលដែលប្រទេសឥណ្ឌូនេស៊ី កំពុងតែកំណត់ខ្លួនឲ្យក្លាយជាសេដ្ឋកិច្ចឌីជីថលធំបំផុតនៅអាស៊ីអាគ្នេយ៍ក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខទៀត[៦៦] ។

បច្ចេកវិទ្យាឌីជីថលត្រូវបានទទួលយកកាន់តែខ្លាំងឡើងដោយអ្នកផ្តល់សេវាកម្មហិរញ្ញវត្ថុនៅទូទាំងប្រទេសអាស៊ានដើម្បីបង្កើនប្រសិទ្ធផលដែលបានផ្តល់ផលប្រយោជន៍ទាំងបុគ្គល (ឧបសម្ព័ន្ធ ១) និងវិស័យសហគ្រាសធុនតូចនិងមធ្យម។ ការសម្របសម្រួលបន្ថែមដល់ការធ្វើសមាហរណកម្មឌីជីថលដោយសហគ្រាសធុនតូច និងមធ្យមនឹងផ្តល់សក្តានុពលក្នុងការជំរុញសេដ្ឋកិច្ចរួមគ្នារបស់អាស៊ានចំនួន ១ ទ្រីលានដុល្លារអាមេរិកមុនឆ្នាំ២០២៥ [៥៥] ។ សហគ្រាសធុនតូចនិងមធ្យមបច្ចុប្បន្នតំណាងឲ្យប្រមាណ ៩៧% នៃសហគ្រាសសរុប ដែលស្មើនឹងជិត ៥០%នៃ GDP អាស៊ាននិងផ្តល់ការងារជាង ៨០% នៃកម្លាំងពលកម្មក្នុងតំបន់។

ទោះយ៉ាងណា សហគ្រាសធុនតូចនិងមធ្យមបានចូលរួមចំណែកត្រឹមតែ ២០%ប៉ុណ្ណោះនៃតម្លៃនាំចេញសរុបនៃប្រទេសអាស៊ាន។ មានសហគ្រាសធុនតូចនិងមធ្យមតែ ១៦%ប៉ុណ្ណោះដែលប្រើប្រាស់ឧបករណ៍ឌីជីថល ខណៈដែល ៧៥%មើលឃើញឱកាសសម្រាប់ការធ្វើសមាហរណកម្មឌីជីថលនៅក្នុងអាជីវកម្មរបស់ពួកគេ។ សហគ្រាសធុនតូចនិងមធ្យមអាចយកគម្រូបទពិសោធន៍ជោគជ័យនៃវិស័យនាំចេញដែលការប្រើប្រាស់ឧបករណ៍ឌីជីថលត្រូវបានទទួលយកជាទូទៅ [៥៥] ។

ការជំរុញការបណ្តុះបណ្តាលជំនាញឌីជីថលសម្រាប់កម្លាំងពលកម្ម និងការបណ្តុះបណ្តាលវិជ្ជាជីវៈនៃសហគ្រាសធុនតូចនិងមធ្យម ស្របគ្នានឹងការជានា ថាមពលដែលអាចទុកចិត្តបាន និងមានតំលៃសមរម្យគឺជាគន្លឹះសម្រាប់ការរីកចម្រើនប្រកបដោយជោគជ័យនៃសេដ្ឋកិច្ច សង្គមឌីជីថល និងទីក្រុងវៃឆ្លាតនៅអាស៊ាន។

ថ្មីៗនេះ AMS បានបង្កើតយុទ្ធសាស្ត្រជាតិសម្រាប់រដ្ឋាភិបាលអេឡិចត្រូនិក (តារាងទី ៣)។ ប្រទេសឡាវ ម៉ាឡេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន ថៃ និងវៀតណាមបានអនុវត្តយុទ្ធសាស្ត្រឌីជីថលទាំងនេះ នៅថ្នាក់ក្រោមជាតិ (sub-national level) ខណៈដែលប្រទេសកម្ពុជា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន ថៃ និងវៀតណាមកំពុងអនុវត្តតាមរដ្ឋបាលមូលដ្ឋាន (local level) [៦៧]។

ទោះបីជាមានការរីកចម្រើនគួរឲ្យកត់សម្គាល់ទាំងនេះក៏ដោយ ការធ្វើសមាហរណកម្ម និងការទទួលយកបច្ចេកវិទ្យា ឌីជីថល តាមផ្នែកនានានៃសេវាកម្មសាធារណៈមានលក្ខណៈខុសៗគ្នា និងនៅមិនទាន់មានការរីកចម្រើនស្មើគ្នានៅឡើយ ហើយទាមទារឲ្យមានការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព ដើម្បីធ្វើឲ្យមានភាពស៊ីគ្នានូវយុទ្ធសាស្ត្រឌីជីថលទាំងក្នុងនិងនៅទូទាំងរដ្ឋអាស៊ាន។ ការប្តេជ្ញានេះគឺជាសញ្ញាវិជ្ជមាន ជាឧទាហរណ៍មួយនៃកិច្ចសហប្រតិបត្តិការនិងសមាហរណកម្មក្នុងតំបន់ដែលសម្របសម្រួលដោយការតភ្ជាប់ឌីជីថលទាំងក្នុង និងទូទាំងរដ្ឋសមាជិកជាអាស៊ានក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកាន់ឲ្យកាន់តែមានលក្ខណៈឌីជីថល។

**តារាងទី៣**: លក្ខណៈពិសេសនៃយុទ្ធសាស្ត្រអភិបាលកិច្ចឌីជីថល,២០១៨

| | កម្រិតរដ្ឋបាល | | | វិសាលភាពគោលនយោបាយ | | | | | | មូលនិធិសំខាន់ៗ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ថ្នាក់ជាតិ | ថ្នាក់ខេត្ត | ថ្នាក់មូលដ្ឋាន | សេវាសាធារណៈទូទៅ | អប់រំ | សេដ្ឋកិច្ច | សុខាភិបាល | វប្បធម៌ និងសាសនា សេវាកំសាន្ត | សេវាគាំពារសង្គម | ក្រសួងទទួលភារៈកិច្ច សម្របសម្រួល | ក្រសួងនិងអង្គភាព ពាក់ព័ន្ធ | ថវិកាកម្មវិធីរបស់ រដ្ឋាភិបាល | ប្រភពថវិកាសម្រាប់ ទ្រទ្រង់យុទ្ធសាស្ត្រ ITC |
| Brunei Darussalam | ● | ○ | ○ | ● | ● | ○ | ● | ● | ● | ○ | ● | ● | ○ |
| កម្ពុជា | ● | ○ | ● | ● | ● | ● | ● | ● | ● | ● | ● | ○ | ○ |
| ឥណ្ឌូនេស៊ី | ● | ○ | ● | ● | ○ | ○ | ○ | ○ | ○ | ● | ● | ○ | ● |
| ឡាវ | ● | ● | ○ | ● | ○ | ○ | ○ | ○ | ○ | ○ | ○ | ● | ● |
| ម៉ាឡេស៊ី | ● | ● | ● | ● | ● | ● | ● | ● | ● | ● | ● | ○ | ○ |
| មីយ៉ាន់ម៉ា | ● | ● | ● | ● | ● | ● | ○ | ○ | ○ | ● | ● | ● | ○ |
| ហ្វីលីពីន | ● | ● | ● | ● | ● | ● | ● | ● | ● | ● | ● | ○ | ○ |
| សិង្ហបុរី | ● | ○ | ○ | ● | ● | ● | ● | ● | ● | ● | ● | ● | ○ |
| ថៃ | ● | ● | ● | ● | ● | ● | ● | ● | ● | ● | ● | ● | ● |
| វៀតណាម | ● | ● | ● | ● | ● | ● | ● | ● | ● | ○ | ○ | ○ | ○ |
| **SEA Total** | 10 | 6 | 7 | 10 | 8 | 7 | 7 | 7 | 7 | 7 | 8 | 5 | 3 |
| អូស្ត្រាលី | ● | ○ | ○ | ● | ● | ● | ○ | ● | ● | ○ | ● | ○ | ○ |
| ជប៉ុន | ○ | ● | ● | ● | ● | ● | ● | ● | ● | ○ | ● | ● | ○ |
| កូរ៉េ | ● | ● | ● | ● | ● | ● | ● | ● | ● | ○ | ● | ○ | ○ |
| នូវែលសេឡង់ | ○ | ○ | ○ | ● | ● | ● | ● | ● | ● | ● | ● | ○ | ● |
| **OECD Total** | 25 | 12 | 10 | 25 | 16 | 15 | 13 | 9 | 14 | 14 | 19 | 4 | 8 |

***សម្គាល់៖*** តារាងនេះដកស្រង់ចេញពី OECD/ADB (2019), p. 91 មាន = ●, មិនមាន = ○

ថ្វីបើតំបន់អាស៊ីអាគ្នេយ៍មានការីកចំរើនយ៉ាងឆាប់រហ័ស ប្រជាជនប្រមាណ ១០% នៃប្រជាជនសរុបនៅតែខ្វះអគ្គិសនីប្រើប្រាស់នៅឡើយនាឆ្នាំ២០១៧ ហើយប្រហែល ២០% មិនទាន់ទទួលបានអគ្គិសនីដែលមានស្ថេរភាពនៅឡើយ។ ដើម្បីសម្រេចបាននូវការប្រើប្រាស់អគ្គិសនីជាសកល និងជានាការផ្គត់ផ្គង់ថាមពលនៅឆ្នាំ២០៤០ ដើម្បីឆ្លើយតបទៅនឹងកំណើននៃតម្រូវការអគ្គិសនីប្រមាណ៦% ក្នុងមួយឆ្នាំនៅអាស៊ីអាគ្នេយ៍ តំបន់នេះត្រូវទាមទារនូវការ

វិនិយោគប្រមាណ ១០៤ ប៊ីលានដុល្លារអាមេរិកដើម្បីពង្រីកការផ្គត់ផ្គង់ប្រេងឥន្ធនៈ និងអគ្គិសនីនៅទូទាំងតំបន់ [៧០]។ AMS ត្រូវវិភាគរកយុទ្ធវិធីដើម្បីបង្កើនការផ្គត់ផ្គង់ថាមពលប្រកបដោយចីរភាពដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងការបំពុលបរិយាកាសគ្រប់ប្រភេទដូចជាការបំពុលខ្យល់ ទឹកសាប ទឹកក្រោមដី និងដី។ នៅក្នុងអាស៊ានហានិភ័យដែលបង្កឡើងដោយការដុតធ្យូងថ្មនិងការប្រើប្រាស់ជីវៈឥន្ធនៈគឺលេចធ្លោជាពិសេស។

## ផ្នែកសេដ្ឋកិច្ចបៃតង

សេដ្ឋកិច្ចបៃតងសំដៅទៅលើសកម្មភាព និងការអភិវឌ្ឍសេដ្ឋកិច្ចបែបអព្យាក្រឹតកាបូន (carbon neutral) ដែលកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (CO2) ទៅក្នុងបរិយាកាស ឬនវានុវត្តន៍បច្ចេកវិទ្យាដែលដើរដោយថាមពលស្អាតនិងកកើតឡើងវិញ។ កិច្ចការនេះទាមទារការវិនិយោគលើមូលធនធម្មជាតិសេដ្ឋកិច្ចនិងការបង្កើតការងារបៃតង។ សេដ្ឋកិច្ចបៃតងចាំបាច់ត្រូវអនុវត្តក្នុងសកម្មភាពផ្សេងៗ និងការងារបរិស្ថាន រួមមាន៖ កសិកម្ម ទីក្រុង ព្រៃឈើ ថាមពលកកើតឡើងវិញ ការដឹកជញ្ជូន ការផ្គត់ផ្គង់ទឹក សំណង់អាគារ ជលផល ឧស្សាហកម្ម ទេសចរណ៍ និងការគ្រប់គ្រងកាកសំណល់។ នវានុវត្តន៍បច្ចេកវិទ្យារួមមានការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលហេដ្ឋារចនាសម្ព័ន្ធឌីជីថល បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ (ICT) ការបង្កើតមាតិកាឌីជីថល និងការពង្រឹងជំនាញឌីជីថល។

ការធ្វើសមាហរណកម្មសេដ្ឋកិច្ចបៃតង និងឌីជីថលដែលជាថាមពលរួមសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពបានក្លាយជាអាទិភាពសកលនៃសកម្មភាពគោលនយោបាយឆ្លើយតបទៅនឹងសន្និសីទអង្គការសហប្រជាជាតិ Rio-២០ ស្តីពី ការអភិវឌ្ឍប្រកបដោយចីរភាពក្នុងឆ្នាំ២០១២ [៥៤]។ កត្តាជោគជ័យនៃសេដ្ឋកិច្ចបៃតងភាគច្រើនពឹងផ្អែកលើល្បឿននៃការផ្លាស់ប្តូរឆ្ពោះទៅរកថាមពលកកើតឡើងវិញ និងស្អាតសម្រាប់គាំទ្រដល់សកម្មភាពសេដ្ឋកិច្ច និងការអភិវឌ្ឍ (ឧបសម្ព័ន្ធ ២) ជាពិសេសសេដ្ឋកិច្ចឌីជីថលនិងបច្ចេកវិទ្យាជឿនលឿន។ កាលានុវត្តភាពដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់អាចកើតឡើងតាមរយៈការផ្លាស់ប្តូរពីការប្រើឥន្ធនៈ ទៅជាការប្រើប្រភពថាមពលដែលមានកាបូនទាបសម្រាប់កំដៅនិងផលិតកម្ម។

នៅក្នុងអាស៊ាន ការប្តេជ្ញាចិត្តជំរុញការអភិវឌ្ឍថាមពលកកើតឡើងវិញ និងវិធានការបង្កើនប្រសិទ្ធភាព និងអភិរក្សថាមពល (EE&C) ត្រូវបានកំណត់នៅក្នុងផែនការអាស៊ាននៃ APAEC ២០១៦-២០២៥ "ពង្រឹងបណ្តាញតភ្ជាប់ថាមពល និងការធ្វើសមាហរណកម្មទីផ្សារនៅអាស៊ានដើម្បីធានាសន្តិសុខ ការទទួលបានតំលៃសមស្រប និងនិរន្តរភាពថាមពលសម្រាប់ទាំងអស់គ្នា"។ សម្រាប់សេដ្ឋកិច្ចបៃតង អាស៊ានកំណត់គោលដៅសម្រេចឲ្យបាន ២៣% នៃការប្រើប្រាស់ថាមពលកកើតឡើងវិញនៅឆ្នាំ២០២៥ ដែលបច្ចុប្បន្នមានប្រហែល ១៥% ដោយមិនគិតបញ្ចូលការប្រើប្រាស់ជីវម៉ាស់រឹងតាមប្រពៃណី [៧០]។ គំនិតផ្តួចផ្តើមសំខាន់ៗនៅដំណាក់កាលទី ១ ឆ្នាំ១៩៩៦ - ២០២០ រួមមាន៖ (១) ចាប់ផ្តើមធ្វើពាណិជ្ជកម្មអគ្គិសនីពហុភាគីដើម្បីពន្លឿនការធ្វើឲ្យប្រសើរនៃបណ្តាញអគ្គិសនីអាស៊ាន (២) បង្កើនការតភ្ជាប់ឧស្ម័នដោយពង្រីកការផ្តោតលើបំពង់បង្ហូរឧស្ម័នឆ្លងអាស៊ាន និងស្ថានីយ៍ឧស្ម័នធម្មជាតិ និង (៣) លើកកម្ពស់បច្ចេកវិទ្យាធ្យូងថ្មស្អាត។ APAEC ក៏មានបំណងដើម្បីសម្រេចបាននូវគោលដៅប្រកបដោយឆន្ទៈខ្ពស់ ដើម្បីបង្កើនប្រសិទ្ធផលថាមពលនិងបង្កើនការផ្លាស់ប្តូរទៅប្រភពថាមពលកកើតឡើងវិញ បន្ថែមលើការកសាងសមត្ថភាពថាមពលនុយក្លេអ៊ែរស៊ីវិល [៥៥]។

ជំហានត្រូវបានអនុវត្តបន្តក្នុងការធ្វើទំនើបកម្មបទបញ្ញត្តិហិរញ្ញប្បទាន រួមទាំងនៅក្នុងវិស័យដឹកជញ្ជូនក្នុងការលើកកម្ពស់ការប្រើប្រាស់យានយន្តអគ្គិសនី។ AMS ក៏បានចាប់ផ្តើមដំណើរការកាត់បន្ថយថាមពលអាំងតង់ស៊ីតេថាមពល (ចំនួនថាមពលដែលត្រូវបានប្រើដើម្បីទទួលបាន GDP១ដុល្លារ) និងផ្អែកលើតម្លៃទីផ្សារដើម្បីបង្កើនជម្រើសឲ្យកាន់តែមានប្រសិទ្ធផល និងបៃតងជាងមុនដើម្បីបង្កើតថាមពលទ្រទ្រង់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងបរិស្ថានប្រកបចីរភាព។

នៅពេលអនាគត ការពង្រីកសេដ្ឋកិច្ចបៃតង និងឌីជីថលទំនងជានាំមកនូវការបន្សីគ្នាកាន់តែជិតស្និទ្ធថែមទៀត។ សកម្មភាពសេដ្ឋកិច្ចអ៊ិនធឺណេតកំពុងតែលេចចេញជាមាគ៌ាឆ្ពោះទៅរកសេដ្ឋកិច្ចបៃតង និងជាមធ្យោបាយមួយដើម្បីប្រើប្រាស់ថាមពលកាន់តែមានប្រសិទ្ធិផល និងកាត់បន្ថយការបញ្ចេញឧស្ម័នកាបូនិចផងដែរនៅពេលដំណើការដោយអគ្គិសនីស្អាត ដែលកាន់តែនាំមកនូវការចំណាយតិចបំផុតពីការប្រើថាមពលកកើតឡើងវិញ[៥២]។ សេដ្ឋកិច្ចបៃតងនៃអ៊ិនធឺណេតនេះ មិនត្រឹមតែផ្តល់ឱកាសកាត់បន្ថយគ្រោះថ្នាក់បរិស្ថានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងលើកកម្ពស់សុខុមាលភាពរបស់ប្រជាជន និងសមភាព ព្រមជាមួយការដោះស្រាយបាននូវភាពកម្រនៃធនធាន អេកូឡូស៊ី [៥៣]។

## ឧបសម្ព័ន្ធ ១: ទិដ្ឋភាពទូទៅនៃសេដ្ឋកិច្ចឌីជីថលនៅអាស៊ានក្នុងឆ្នាំ២០១៩/២០២០

| | ចំនួនប្រជាជន គិតជាលាននាក់ [៥៦] | ភាគរយនៃចំនួនប្រជាជនដែលរស់នៅក្នុងតំបន់ទីក្រុង [៥៦] | សន្ទស្សន៍ឌីជីថលសកលឆ្នាំ២០១៨ (ក្នុងចំណោម ១៨៣ ប្រទេស) * | អ្នកប្រើប្រាស់អ៊ិនធឺណេត[៨] | | ល្បឿននៃការភ្ជាប់ អ៊ិនធឺណេត[៨] | | | | បរិយាបន្នផ្នែកហិរញ្ញវត្ថុ[៨] | | | | ភាពងាយស្រួលក្នុងការធ្វើអាជីវកម្ម (១៩០ ប្រទេស [១០]) | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | អ្នកប្រើប្រាស់អ៊ិនធឺណិតសមាមាត្រនៃចំនួនប្រជាជន | ការផ្លាស់ប្តូរអ្នកប្រើប្រាស់អ៊ិនធឺណេតចន្លោះឆ្នាំ២០១៨-២០១៩ | ល្បឿនមធ្យមនៃការភ្ជាប់អ៊ិនធឺណេតតាមទូរស័ព្ទចល័ត (MBPS) | ការផ្លាស់ប្តូរពីមួយឆ្នាំទៅមួយឆ្នាំនៃល្បឿនជាមធ្យមនៃការភ្ជាប់អ៊ិនធឺណេតតាមទូរស័ព្ទ | ល្បឿនជាមធ្យមនៃការភ្ជាប់អ៊ិនធឺណេតមានខ្សែ(MBPS) | ការផ្លាស់ប្តូរពីមួយឆ្នាំទៅមួយឆ្នាំនៃល្បឿនជាមធ្យមនៃការភ្ជាប់អ៊ិនធឺណេតមានខ្សែ | គណនីធនាគារ | កាតឥណទាន | គណនីទឹកប្រាក់ចល័ត | ធ្វើការទិញតាមអ៊ិនធឺណេតនិង / ឬទូទាត់វិក្កយបត្រតាមអ៊ិនធឺណេត | ចំណាត់ថ្នាក់ពីតូច(ចំណាត់ថ្នាក់ល្អ) ទៅធំ (ចំណាត់ថ្នាក់មិនល្អ) | ពិន្ទុសន្ទស្សន៍ (អតិបរមា ១០០, ល្អបំផុត) |
| ពិភពលោក | 7,676 | 55% | N/A | 57% | 10.0% | | | | | | | | | | |
| អាស៊ីអាគ្នេយ៍ | 662 | 49% | N/A | 63% | n/a | | | | | | | | | | |
| អាស៊ាន | 657.7 | 53% | N/A | 69% | 12% | | | | | | | | | | |
| សិង្ហបុរី | 5.8 | 100% | 8 | 84% | 1.9% | 61 | 13% | 190.9 | 18% | 98% | 49% | 10% | 57% | 2 | 86 |
| ម៉ាឡេស៊ី | 32.3 | 76% | 41 | 80% | 3.0% | 19.9 | 25% | 63.5 | 187% | 85% | 21% | 11% | 39% | 12 | 82 |
| ប្រ៊ុយណេ | 0.4 | 78% | 58 | 94% | 0.2% | 15 | 13% | 14.9 | 8% | n/a | n/a | n/a | n/a | 66 | 70 |
| ថៃ | 69.2 | 50% | 61 | 82% | 0.0% | 17.6 | 29% | 57.6 | 48% | 82% | 10% | 8% | 19% | 21 | 80 |
| វៀតណាម | 97 | 36% | 91 | 66% | 0.0% | 21.6 | 6.1% | 27.2 | 10% | 31% | 4% | 4% | 21% | 70 | 70 |
| ហ្វីលីពីន | 107.3 | 47% | 101 | 71% | 13.0% | 15.1 | 12% | 19 | 25% | 34% | 2% | 5% | 10% | 95 | 63 |
| ឥណ្ឌូនេស៊ី | 268.2 | 55% | 109 | 56% | 13.0% | 10.5 | 7.2% | 15.5 | 13% | 49% | 2% | 3% | 11% | 73 | 70 |
| កម្ពុជា | 16.4 | 23% | 123 | 76% | 56.0% | 14.3 | -14% | 15.9 | 27% | 22% | 1% | 6% | 4% | 144 | 54 |
| ឡាវ | 7 | 35% | 159 | 39% | 13.0% | 22.8 | 76% | 20.5 | 107% | 29% | 1% | N/A | 7% | 154 | 51 |
| មីយ៉ាន់ម៉ា | 54.1 | 31% | 160 | 39% | 17.0% | 24.2 | 60% | 11.1 | 50% | 26% | 0% | 1% | 4% | 165 | 47 |

**ប្រភព៖** * The ASEAN Post Team. (2019). A digital ASEAN for everyone. [online] available at https://theaseanpost.com/article/digital-asean-everyone

## ឧបសម្ព័ន្ធ ២: សេដ្ឋកិច្ចអាស៊ានក្នុងបរិបទសេដ្ឋកិច្ចឌីជីថលនិងបៃតងនៃបណ្តាប្រទេសសមាជិកអាស៊ាន

| | ប្រភពថាមពលនៃផលិតកម្មអគ្គិសនី ឆ្នាំ២០១៥ * | | ភាគរយប្រជាជនប្រើប្រាស់អគ្គិសនី ** | | ការប្រើប្រេង និងបច្ចេកវិទ្យាស្អាតសម្រាប់ការចម្អិនអាហារ (% ប្រជាជន) | | គុណភាពនៃការផ្គត់ផ្គង់អគ្គិសនី (១=ទាប; ៧=ខ្ពស់) ** | | ការបំភាយឧស្ម័នផ្ទះកញ្ចក់ (CO2 ១ដុល្លារ GDP) ** | | សន្ទស្សន៍ការផ្លាស់ប្តូរថាមពល ឆ្នាំ២០១៩៖ ពិន្ទុពី 0-១០០% (ក្នុងចំណោម ១១៥ ប្រទេស) *** | | | | ២០១៩ ចំណាត់ថ្នាក់នៃសន្ទស្សន៍ ENERGY TRILEMMA INDEX RANKING (១២៨ប្រទេស) **** | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | % ផលិតកម្មប្រេងឧស្ម័ននិងធ្យូងថ្ម | % អគ្គិសនីពីវារីអគ្គិសនី | ២០១៩ | ការប្រែប្រួល ២០១៤ - ២០១៩ | ២០១៩ | ការផ្លាស់ប្តូរ ២០១៤ - ២០១៩ | តម្លៃ ២០១៩ | ការផ្លាស់ប្តូរ ២០១៤ - ២០១៩ | តម្លៃ ២០១៩ | ការផ្លាស់ប្តូរ ២០១៤ - ២០១៩ * | ចំណាត់ថ្នាក់ (ទី១ គឺល្អជាងគេ) | ពិន្ទុ ETI | ប្រព័ន្ធដំណើការ | ភាពរួចរាល់នៃការផ្លាស់ប្តូរ | ពិន្ទុ Trilemma (ពី 0 ទៅ ១០០) | ចំណាត់ថ្នាក់សន្ទស្សន៍ (ចំណាត់ថ្នាក់ទី១ គឺល្អជាងគេ) | ចំណាត់ថ្នាក់សុវត្ថិភាពថាមពល | ចំណាត់ថ្នាក់សមធម៌ថាមពល | ចំណាត់ថ្នាក់ចីរភាពបរិស្ថាន |
| សិង្ហបុរី | 96.9% | 0.0% | 100 | 0% | 100 | 0% | 6.85 | 3% | 199.0 | +41% | 13 | 67% | 68% | 65% | 71.2 | 43 | 123 | 10 | 37 |
| ប្រុយណេ | 100.0% | 0.0% | 100 | 0% | 100 | 0% | 5.41 | 4% | 585.9 | +23% | 39 | 59% | 67% | 52% | 67.7 | 56 | 92 | 44 | 66 |
| ម៉ាឡេស៊ី | 90.0% | 9.3% | 100 | -0.3% | 96.3 | -0.3% | 5.88 | 2% | 463.1 | -10% | 31 | 61% | 68% | 55% | 68.5 | 51 | 41 | 52 | 87 |
| ថៃ | 91.5% | 2.7% | 100 | 2.2% | 74.4 | 2.2% | 5.18 | -1% | 420.8 | -7% | 51 | 57% | 63% | 51% | 64.6 | 68 | 76 | 71 | 79 |
| ឥណ្ឌូនេស៊ី | 89.3% | 5.9% | 98.14 | 32.9% | 58.4 | 32.9% | 4.43 | 4% | 239.8 | -32% | 63 | 55% | 64% | 46% | 64.1 | 69 | 34 | 88 | 85 |
| ហ្វីលីពីន | 74.6% | 10.5% | 93 | 3% | 43.2 | 3% | 4.21 | 5% | 281.0 | -13% | 59 | 55% | 62% | 49% | 58.6 | 94 | 48 | 102 | 68 |
| ឡាវ | n/a | n/a | 93.6 | 12% | 5.6 | 12% | 4.8 | -8% | 328.9 | -19% | n/a | n/a | n/a | n/a | n/a | n/a | n/a | n/a | n/a |
| វៀតណាម | 63.3% | 36.6% | 100 | 33% | 66.9 | 33% | 4.34 | 10% | 648.5 | -7% | 56 | 55% | 62% | 49% | 58.9 | 91 | 21 | 97 | 110 |
| កម្ពុជា | 53.6% | 45.5% | 89.07 | 47% | 17.7 | 47% | 3.47 | 9% | 636.7 | -26% | 100 | 45% | 46% | 44% | 51.6 | 105 | 77 | 110 | 92 |
| មីយ៉ាន់ម៉ា | 41.1% | 58.9% | 69.81 | 52% | 18.4 | 52% | 2.72 | -7% | 449.1 | -16% | n/a | n/a | n/a | n/a | 51.9 | 104 | 42 | 111 | 62 |

**ប្រភព៖** *World Bank Statistics,

** World Energy Trilemma Index - Country Rankings available at https://knoema.com/ETI2017/world-energy-trilemma-index-country-rankings

***World Economic Forum (2019). Fostering Effective Energy Transition 2019 edition. [online] Avaiable at http://www3.weforum.org/docs/WEF_Fostering_Effective_Energy_Transition_2019.pdf (Accessed on 19 December 2019)

**Note:** The Energy Transition Index benchmarks countries on the performance of their energy system, as well as their readiness for transition to a secure, sustainable, a ordable, and reliable energy future. ETI 2019 score on a scale from 0 to 100%.

**** World Energy Council.(2019). World Energy Trilemma Index 2019. [online]. Available at https://www.worldenergy.org/assets/downloads/WETrilemma_2019_Full_Report_v4_pages.pdf (Accessed on 20 December 2019)

**ផែនទី ២៧៖** កំណើន បច្ចេកវិទ្យាឌីជីថល និងសេដ្ឋកិច្ចពណ៌បៃតង



## ៨.៨.២ សហគ្រាសធុនតូច និងមធ្យម នៅអាស៊ាន

### ទិដ្ឋភាពទូទៅ

សហគ្រាសធុនតូច និងមធ្យម ឬហៅកាត់ជាភាសាអង់គ្លេសថា SMEs (Small and medium sized enterprises) ដើរតួនាទីយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ចអាស៊ាន។ SMEs មានចំនួនច្រើនជាង ៩៧% នៃអាជីវកម្មសរុបទូទាំងប្រទេសជាសមាជិកអាស៊ានទាំងអស់ (លើកលែងប្រទេសមីយ៉ាន់ម៉ា) និងចូលរួមចំណែកធំក្នុងការផ្តល់ការងារធ្វើ ដែលមានប្រមាណចាប់ពី ៥២% នៅប្រទេសវៀតណាម ដល់ ៩៧% នៅប្រទេសឥណ្ឌូនេស៊ី [៧១, ៧២]។

ទោះបីជាមានសារៈសំខាន់ក្នុងសេដ្ឋកិច្ចអាស៊ាន SMEs ភាគច្រើននៅតែស្ថិតក្នុងវិស័យដែលពឹងផ្អែកលើកម្លាំងពលកម្ម និងមានតម្លៃបន្ថែមទាបដែលភាគច្រើនគឺវិស័យលក់រាយ និងកសិកម្ម [៧៣]។ ដោយហេតុនេះ SMEs ចូលរួមចំណែកទាបជាង ៥០%នៃផលិតផលក្នុងស្រុកសរុបទូទាំងប្រទេសទាំងអស់ជាសមាជិក និងចូលរួមមួយចំណែកតូចប៉ុណ្ណោះក្នុងការនាំចេញ ពោលគឺប្រមាណពី ១០% ទៅ ៣០% នៃការនាំចេញសរុប [៧១]។ ការបង្កើត SMEs ដែលពឹងផ្អែកលើជំនាញ និងមានតម្លៃបន្ថែមខ្ពស់ជាងមុន គឺជាអាទិភាពកាន់តែសំខាន់សម្រាប់ប្រទេសជាសមាជិក ស្របពេលដែលប្រទេសទាំងនោះស្វះស្វែងពង្រីកមូលដ្ឋានសេដ្ឋកិច្ច ខណៈធានាផងដែរនូវកំណើនដោយបរិយាបន្ន។

រដ្ឋជាសមាជិកអាស៊ាន កំពុងស្ថិតក្នុងដំណាក់កាលផ្សេងៗគ្នាក្នុងការអនុវត្តគោលនយោបាយគាំទ្រ SMEs ដែលឆ្លុះបញ្ចាំងតាមរយៈពិន្ទុមធ្យមនៃសន្ទស្សន៍គោលនយោបាយ SME (SME policy index) សម្រាប់ប្រទេសនីមួយៗ ដែលសន្ទស្សន៍នេះត្រូវបានបង្កើតឡើងដោយអង្គការដើម្បីការអភិវឌ្ឍ និងសហប្រតិបត្តិការសេដ្ឋកិច្ច (OECD) [៧៣, ៧៥]។ SMEs នៅក្នុងប្រទេសណាដែលមានសន្ទស្សន៍ទាប ជួបប្រទះបញ្ហាប្រឈមច្រើនក្នុងការទទួលបានបច្ចេកវិទ្យា មានការគាំទ្រផ្នែកហិរញ្ញប្បទានទន់ខ្សោយ និងជួបនូវរបាំងច្រើនទាំងផ្នែកច្បាប់និងផ្នែករដ្ឋបាល បើធៀបទៅនឹងសហគ្រាសខ្នាតធំ [៧៣, ៧៤]។ ចំណាត់ថ្នាក់នៃសន្ទស្សន៍នេះបង្ហាញថា ប្រទេសសិង្ហបុរី និងម៉ាឡេស៊ី អនុវត្តបានល្អជាងគេក្នុងគោលនយោបាយគាំទ្រ SMEs ខណៈប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា មានភាពយឺតយ៉ាវជាងគេ និងនៅតែផ្តោតលើដំណាក់កាលដំបូងក្នុងការលើកកម្ពស់ការចូលទីកាន់ទីផ្សារសហគ្រាសធុនតូច និងមធ្យម។

### ផែនការឆ្ពោះទៅខាងមុខ

សហគមន៍សេដ្ឋកិច្ចអាស៊ាន (ASEAN Economic Community) បានបង្កើតនូវ **ផែនការសកម្មភាពយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម** (Strategic Action Plan for SME Development) ដែលមានទស្សនៈវិស័យក្នុងការលើកកម្ពស់ "សហគ្រាសធុនតូចនិងមធ្យមដែលមានលក្ខណៈច្នៃប្រឌិត និងប្រកួតប្រជែងជាសកល" (globally competitive and innovative SMEs) [៧៦]។

ផែនការសកម្មភាពនេះមានគោលដៅយុទ្ធសាស្ត្រចំនួនប្រាំ សម្រាប់ឆ្នាំ២០១៦ ដល់ឆ្នាំ២០២៥៖

១. លើកកម្ពស់ផលិតភាព បច្ចេកវិទ្យា និងនវានុវត្តន៍៖ សកម្មភាពរួមមាន ជំរុញការវិនិយោគមូលធន ជំរុញការប្រមូលផ្តុំឧស្សាហកម្ម និងលើកទឹកចិត្តកិច្ចសហការរវាងធុរកិច្ច និងការអប់រំ។

២. បង្កើនលទ្ធភាពទទួលបានហិរញ្ញវត្ថុ៖ សកម្មភាពរួមមាន ពង្រឹងការផ្តល់ហិរញ្ញប្បទានសម្រាប់ការនាំចេញ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុបែបប្រពៃណី។

៣. លើកកម្ពស់ការចូលទៅកាន់ទីផ្សារ និងអន្តរភាវូបនីយកម្ម៖ សកម្មភាពរួមមាន ជំរុញភាពជាដៃគូជាមួយក្រុមហ៊ុនពហុជាតិធំៗ និងលើកកម្ពស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច។

៤. លើកកម្ពស់បរិយាកាសគោលនយោបាយ និងបទប្បញ្ញត្តិ៖ សកម្មភាពរួមមាន លើកកម្ពស់ប្រសិទ្ធភាពក្នុងការចេញលិខិតអនុញ្ញាត និងការចុះឈ្មោះ ដើម្បីធ្វើឲ្យការបង្កើតអាជីវកម្មមានចំណាយតិច និងលឿនជាងមុន។

៥. លើកកម្ពស់ភាពជាសហគ្រិន និងការអភិវឌ្ឍធនធានមនុស្ស៖ សកម្មភាពរួមមាន ជំរុញការអប់រំផ្នែកភាពជាសហគ្រិន និងលើកកម្ពស់ជំនាញការគ្រប់គ្រងនិងបច្ចេកទេស ដល់ស្ត្រីនិងយុវជនដែលកំពុងចូលក្នុងទីផ្សារពលកម្ម។

សូចនាករនៃការអនុវត្តសំខាន់ៗត្រូវបានកំណត់សម្រាប់គោលដៅនីមួយៗខាងលើ ដើម្បីជួយរដ្ឋជាសមាជិកទាំងអស់វាយតម្លៃគោលនយោបាយ SME រៀងៗខ្លួន និងផ្តល់អាទិភាពដល់ផ្នែកណាមួយដែលតម្រូវឲ្យមានការយកចិត្តទុកដាក់បន្ថែម។ ខណៈពេលដែលការអនុវត្តទទួលបាននូវវឌ្ឍនភាព បញ្ហាប្រឈមនៅតែមាននៅឡើយ។

## ផែនទី ២៨៖ សហគ្រាសធុនតូច និងមធ្យម



## ៨.៨.៣ ទម្រង់ថ្មីក្នុងការធ្វើធុរកិច្ច និងកម្លាំងចលករសម្រាប់ប្រទេសក្នុងតំបន់អាស៊ាន

### ទិដ្ឋភាពទូទៅ

បដិវត្តន៍ឧស្សាហកម្មទី៤ ត្រូវបានរំពឹងថានឹងធ្វើការផ្លាស់ប្តូរទម្រង់សេដ្ឋកិច្ច និងរបៀបដែលមនុស្សបំពេញការដោយសារបច្ចេកវិទ្យាឌីជីថលដែលរួមមានបញ្ញាសិប្បនិម្មិត (AI), មនុស្សយន្ត (robotics) និង ការបោះពុម្ពដែលមានវិមាត្របី (3D Printing) [៧៧]។

បច្ចេកវិទ្យាទាំងនេះអាចនឹងផ្តល់នូវអត្ថប្រយោជន៍យ៉ាងច្រើនសម្បើមសម្រាប់សហគមន៍ធុរកិច្ចក្នុងតំបន់អាស៊ាន។ ឧទាហរណ៍កម្មវិធីទូរស័ព្ទចល័តអាចធ្វើឲ្យមានសេរីភាវូនីកម្មហិរញ្ញវត្ថុ ជំរុញឲ្យទុនដែលមានត្រូវបានប្រើប្រាស់កាន់តែប្រសើរ និងផ្តល់នូវការលើកទឹកចិត្តដល់ម្ចាស់ជំនួញខ្នាតតូចអំពីវិធីសាស្ត្រដំណើរការធុរកិច្ចរបស់ពួកគេ។ បច្ចេកវិទ្យាវៃឆ្លាតផ្សេងៗទៀត អាចជួយសម្រួលបន្ទុកផ្នែករដ្ឋបាល និងធ្វើឲ្យមានភាពប្រសើរឡើងលើការដឹកជញ្ជូន និងផ្តល់នូវកាលានុវត្តភាពទូលំទូលាយក្នុងការពង្រីកទីផ្សារសម្រាប់ធុរកិច្ចអាស៊ាន។

ប៉ុន្តែវាក៏មានសក្តានុពលនៃបញ្ហាប្រឈមផងដែរ។ ជំនាញដែលត្រូវការប្រើប្រាស់បច្ចេកវិទ្យាបានធ្វើឲ្យមានការកើនឡើងនូវវិសមភាពចំណូល បើសិនមិនធ្វើការវិនិយោគជាយុទ្ធសាស្ត្រលើវិស័យអប់រំ[៧៨]។ ផលប៉ះពាល់លើវិសមភាពនេះអាចនឹងកើនឡើង បើសិនមានការផ្លាស់ប្តូរទៅប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ហើយបោះបង់ចោលការវិនិយោគលើកម្លាំងផលិតកម្មដែលមានជំនាញទាបដែលត្រូវបានព្យាករថានឹងក្លាយជាកំលាំងការងារដ៏ធំបំផុតនៅក្នុងតំបន់អាស៊ានក្នុងរយៈពេល១៥ឆ្នាំក្រោយ។ យោងតាមអង្គការពលកម្មអន្តរជាតិរបស់អង្គការសហប្រជាជាតិ៖ ៥៦% នៃការងារនៅក្នុងប្រទេសកម្ពុជា ឥណ្ឌូនេស៊ី ហ្វីលីពីន ថៃ និងប្រទេសវៀតណាមប្រឈមនឹងហានិភ័យខ្ពស់ នៅពេលដែលការងារទាំងនោះត្រូវជំនួសដោយបច្ចេកវិទ្យាស្វ័យប្រវត្តិ[៧៩]។ ការបារម្មណ៍ជាពិសេស គឺថាការងារទាំងអស់នោះគឺជាការងារដែលធ្វើឡើងដោយស្ត្រី។

> “ យោងតាមអង្គការពលកម្មអន្តរជាតិ របស់អង្គការសហប្រជាជាតិ៖ ៥៦% នៃការងារនៅក្នុងប្រទេសកម្ពុជា ឥណ្ឌូនេស៊ី ហ្វីលីពីន ថៃ និងប្រទេសវៀតណាមប្រឈមនឹងហានិភ័យខ្ពស់ នៅពេលដែលការងារទាំងនោះត្រូវជំនួសដោយបច្ចេកវិទ្យាស្វ័យប្រវត្តិ ”

> “ មានការរំពឹងថា ការអនុវត្តយុទ្ធសាស្ត្របដិវត្តន៍ឧស្សាហកម្មទី៤ ដោយជោគជ័យ ក្រុមហ៊ុនទាំងនេះអាចបន្ថែមទឹកប្រាក់ មួយទ្រីលានដុល្លារអាម៉េរិកក្នុងសេដ្ឋកិច្ច ប្រសិនបើមានការអនុវត្តបដិវត្តន៍ឧស្សាហកម្មទី៤ឲ្យបានពេញលេញក្នុងឆ្នាំ២០២៥ ”

បច្ចេកវិទ្យាឌីជីថលអាចផ្លាស់ប្តូរនូវទម្រង់លំហូរពាណិជ្ជកម្មពិភពលោក។ ឧទាហរណ៍ ផលិតកម្ម បច្ចេកវិទ្យាថ្មីដូចជា៖ 3D Printing អាចធ្វើឲ្យផលិតកម្ម ត្រូវបានបង្វែរទៅទីផ្សារប្រទេសអភិវឌ្ឍន៍ [៨០]។ បច្ចេកវិទ្យាផ្សេងទៀត ដូចជា មនុស្សយន្តចេះនិយាយ (AI Chat bots) និង មនុស្សយន្តជាជំនួយការ (Voice Assistants) គឺបាននឹងកំពុងគម្រាមកំហែងឧស្សាកម្មផ្នែក ដែលហៅថាសេវាទូរស័ព្ទនៅក្នុងប្រទេសដែលមានការផលិតថ្លៃដើមថោក [៨១]។

បច្ចុប្បន្នក្រុមហ៊ុនឌីជីថលមានចំនួនប្រមាណ ៧% នៃផលិតផលក្នុងស្រុកសរុប (ផ.ស.ស) របស់អាស៊ាន និងរកចំណូលបាន ១៥០ ប៊ីលានដុល្លារអាម៉េរិកប្រចាំឆ្នាំ។ មានការរំពឹងថា ការអនុវត្តយុទ្ធសាស្ត្របដិវត្តន៍ឧស្សាហកម្មទី៤ដោយជោគជ័យ ក្រុមហ៊ុនទាំងនេះអាចបន្ថែមទឹកប្រាក់មួយទ្រីលានដុល្លារអាម៉េរិកក្នុងសេដ្ឋកិច្ច ប្រសិនបើមានការអនុវត្តបដិវត្តន៍ឧស្សាហកម្មទី ៤ ឲ្យបានពេញលេញក្នុងឆ្នាំ២០២៥ [៨២]។

### ស្ថានភាពនៃការត្រៀមខ្លួន

សន្ទស្សន៍នៃភាពជាសហគ្រិនសាកល (Global Entrepreneurship Index) បានធ្វើការវាយតម្លៃទៅលើការត្រៀមខ្លួនសម្រាប់សម្រាប់ផលិតកម្មនាពេលអនាគតដែលមានបង្ហាញនៅក្នុងតារាងនៃផែនទី២៥៖ ទម្រង់ថ្មីក្នុងការធ្វើធុរកិច្ច និងកម្លាំងចលករ[៨៣]។ សន្ទស្សន៍នេះធ្វើការវាស់ស្ទង់នូវរចនាសម្ព័ន្ធផលិតកម្មដែលជាជាទិន្នន័យគោលនាពេលបច្ចុប្បន្ន អំពីភាពស្មុគស្មាញរបស់ផលិតកម្ម (ការផ្សំ និងភាពប្លែកគេនៃផលិតផល) និងខ្នាត (ទំហំនិងតម្លៃបន្ថែមនៃផលិតផលដែលផលិត)។

> ប្រទេសម៉ាឡេស៊ី និងប្រទេសសិង្ហបុរី ឈរនៅកម្រិតខ្ពស់ក្នុងការត្រៀមខ្លួន ខណៈដែលប្រទេសកម្ពុជា ប្រទេសឥណ្ឌូណេស៊ី ប្រទេសវៀតណាមត្រូវការនូវការវិនិយោគ និងការធ្វើគោលនយោបាយកែទម្រង់ខ្លាំង ដើម្បីត្រៀមរៀបចំសម្រាប់អនាគត។

សន្ទស្សន៍នេះក៏ធ្វើការវាស់ផងដែរនូវកម្លាំងចលករនៃផលិតកម្មដែលជាកត្តាជំរុញសំខាន់ៗ អាចអនុញ្ញាតឲ្យប្រទេសនានាទទួលបានផលប្រយោជន៍ពីបដិវត្តន៍ឧស្សាហកម្មទី ៤ ។ កត្តាជំរុញទាំងនោះរួមមាន៖ ព័ត៌មាន និងហេដ្ឋារចនាសម្ព័ន្ធប្រាស្រ័យឆ្លើយឆ្លង ស្ថាប័នអប់រំ និងធនធានធម្មជាតិ ថាតើវាមាននិរន្តរភាពឬក៏អត់។ ប្រទេសដែលនៅលើគេចំនួនបួននៅផ្នែកខាងស្តាំនៃតារាង គឺស្ថិតចំណោមប្រទេសដែលត្រូវបានចាត់ទុកថា មានស្ថានភាពល្អប្រសើរសម្រាប់បដិវត្តន៍ឧស្សាហកម្មទី៤ ខណៈប្រទេសដែលមានទីតាំងនៅជ្រុងបួនខាងឆ្វេងផ្នែកខាងក្រោម គឺស្ថិតនៅក្នុងហានិភ័យខ្ពស់ពីការមិនបានត្រៀមខ្លួនសម្រាប់អនាគតនៃផលិតកម្ម។

ក្នុងចំណោមប្រទេសអាស៊ាន ប្រទេសម៉ាឡេស៊ី និងប្រទេសសិង្ហបុរី ឈរនៅកម្រិតខ្ពស់ក្នុងការត្រៀមខ្លួន ខណៈដែលប្រទេសកម្ពុជា ប្រទេសឥណ្ឌូណេស៊ី ប្រទេសវៀតណាមត្រូវការនូវការវិនិយោគ និងការធ្វើគោលនយោបាយកែទម្រង់ខ្លាំង ដើម្បីត្រៀមរៀបចំសម្រាប់អនាគត។

## ការឆ្ពោះទៅមុខ

ក្នុងគោលការណ៍ណែនាំស្តីពី គោលនយោបាយនវានុវត្តន៍សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ធនាគារពិភពលោកបានប្រដូចរដ្ឋាភិបាលទៅនឹងអ្នកថែសួន ដែលត្រូវផ្តល់នូវលក្ខខណ្ឌនានាសម្រាប់កំណើននៃភាពលូតលាស់ផ្នែកបច្ចេកវិទ្យា[៨៤]។ ក្នុងន័យធៀបនេះ យើងអាចទាញបាននូវចំណុចសកម្មភាពចំនួន ០៤ ដែលត្រូវអនុវត្ត៖

១. **រៀបចំគ្រឹះ** ដោយធ្វើការវិនិយោគទៅលើធនធានមនុស្ស

២. **ដាក់ជីធ្វើឲ្យដីមានជីជាតិ** ដោយជំរុញការស្រាវជ្រាវ និងការអភិវឌ្ឍ

៣. **ស្រោចទឹកដល់រុក្ខជាតិ** ដោយផ្តល់នូវការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់នវានុវត្តន៍

៤. **ជម្រុះចោលរុក្ខជាតិ** ដោយដាក់ចេញនូវបទបញ្ញត្តិ គោលនយោបាយពន្ធ និងការលុបបំបាត់នូវឧបសគ្គនានាក្នុងការប្រកួតប្រជែង។

ប៉ុន្តែបន្ថែមលើការលើកទឹកចិត្តក្នុងការបង្កើនការអនុវត្តដោយប្រើបច្ចេកវិទ្យា រដ្ឋាភិបាលត្រូវត្រៀមដោះស្រាយការរំខានដោយបច្ចេកវិទ្យាផងដែរ ដោយធ្វើការវិនិយោគលើបណ្តាញសុវត្ថិភាពសង្គមដូចជា៖ ផលប្រយោជន៍ដែលត្រូវផ្តល់នៅពេលបាត់បង់ការងារ និងប្រាក់សោធននិវត្តន៍សាធារណៈ រួមទាំងវិធានការកាត់បន្ថយវិសមភាពដូចជា៖ ការគាំពារសុខភាព និងកំណែទម្រង់ពន្ធ[៨៥]។

ពេលរៀបចំយុទ្ធសាស្ត្រសម្រាប់បដិវត្តន៍ឧស្សាហកម្មទី៤ រដ្ឋាភិបាល ក៏ដូចជាក្រុមហ៊ុនឯកជនត្រូវចាំថាថា៖ បញ្ហាប្រឈមក្នុងការដឹកនាំអាស៊ាន គឺភាពខុសគ្នាខ្លាំងផ្នែកវប្បធម៌ ភាសា សាសនា និងស្ថានភាពសេដ្ឋកិច្ច។ ឧទាហរណ៍ រនាំងនៃភាសា និងវប្បធម៌អាចធ្វើឲ្យរាំងស្ទះការចល័តការងារ ធ្វើឲ្យការខ្វះជំនាញមិនអាចអភិវឌ្ឍបានប្រសើរធ្វើឲ្យបរាជ័យក្នុងការបង្កើតផលិតផលថ្មី ប្រសិនបើឈ្មោះរបស់កម្មវិធីទូរស័ព្ទមួយ ដែលបង្កើតក្នុងប្រទេសមួយគឺជាពាក្យដែលមានលក្ខណៈជាការប្រមាថនៅក្នុងប្រទេសមួយទៀត[៨៥]។

ប៉ុន្តែភាពខុសគ្នាទាំងនេះក៏អាចជាកាលានុវត្តភាពដែរ។ ដោយការរៀបចំសេវាស្របទៅតាមភាសា និងវប្បធម៌ជាពិសេសសម្រាប់សហគមន៍អាស៊ាន ក្រុមហ៊ុនមួយអាចទទួលបាននូវអតិថិជនស្មោះស្ម័គ្រ និងចាប់យកចំណែកទីផ្សារពីអ្នកប្រកួតប្រជែងក្រៅប្រទេស[៨៦]។

មិនមានភាពច្បាស់លាស់ឡើយលើគោលនយោបាយអំពីអនាគតតែអ្វីដែលច្បាស់នោះ គឺថាយុទ្ធសាស្ត្ររួមមួយក្នុងការជំរុញដល់ធុរកិច្ច ផ្អែកលើបច្ចេកវិទ្យាឌីជីថលនៅក្នុងតំបន់អាស៊ាន គឺមិនអាចធ្វើបានឡើយ។ យុទ្ធសាស្ត្រគោលនយោបាយត្រូវតែមានភាពបត់បែនទៅតាមកាលៈទេសៈពិសេសរបស់ប្រទេសនីមួយៗ ដោយត្រូវចងចាំថា កំណើនគឺសម្រាប់ទាំងអស់គ្នា និងសម្រាប់ផលប្រយោជន៍សាធារណៈជាធំ [៨៧]។

> រដ្ឋាភិបាល ក៏ដូចជាក្រុមហ៊ុនឯកជនត្រូវចាំថាថា៖ បញ្ហាប្រឈមក្នុងការដឹកនាំអាស៊ានគឺភាពខុសគ្នាខ្លាំងផ្នែក វប្បធម៌ ភាសា សាសនា និងស្ថានភាពសេដ្ឋកិច្ច។

## ផែនទី ២៩៖ ទម្រង់ធុរកិច្ច និងកាតាលីករថ្មី



## ៨.៨.៤ ការបណ្ដុះបណ្ដាលជំនាញ ការចាប់ផ្ដើមធុរកិច្ច និងនវានុវត្តន៍

### សាវតាសង្ខេបពីការចាប់ផ្ដើមធុរកិច្ចនៅអាស៊ាន

> “ អ្នកប្រើប្រាស់អ៊ិនធឺណេតមានចំនួនដល់ទៅជាង ៣៥០លាននាក់ បើគិតតែក្នុងប្រទេសម៉ាឡេស៊ី ឥណ្ឌូនេស៊ី ហ្វីលីពីន សិង្ហបុរី ថៃ និងវៀតណាម។ ”

សេដ្ឋកិច្ចរបស់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) មិនត្រឹមតែមានទំហំធំ និងធំជាងគេទីបីក្នុងទ្វីបអាស៊ីប៉ុណ្ណោះទេ [៨៨,៨៩] តែថែមទាំងមានសក្ដានុពលខ្ពស់ក្នុងប៉ុន្មានឆ្នាំខាងមុខនេះ ដោយសារចំនួនប្រជាជនវ័យក្មេងដែលមាននៅក្នុងសមាគមនេះ។ ក្នុងចំណោមប្រជាជនសរុបប្រមាណ ៦៣០លាននាក់ នៅក្នុងអាស៊ាន ៧០% គឺមានអាយុទាបជាង៤០ឆ្នាំ [៣៦]។ ដោយមានអត្រានៃប្រជាជនវ័យក្មេងខ្ពស់ រួមផ្សំនឹងកំណើនសេដ្ឋកិច្ចលឿន វាមិនមែនជារឿងដែលគួរឲ្យភ្ញាក់ផ្អើលឡើយ ដែលអាស៊ានក្លាយជាតំបន់មួយមានភាពរីកចម្រើនលឿនលើប្រព័ន្ធអ៊ិនធឺណេត។អ្នកប្រើប្រាស់អ៊ិនធឺណេតមានចំនួនដល់ទៅជាង ៣៥០លាននាក់ បើគិតតែក្នុងប្រទេសម៉ាឡេស៊ី ឥណ្ឌូនេស៊ី ហ្វីលីពីន សិង្ហបុរី ថៃ និងវៀតណាម។ ការប្រើប្រាស់អ៊ិនធឺណេតត្រូវបានជំរុញជាចម្បងដោយសារការប្រើប្រាស់ជាទូទៅនូវទូរស័ព្ទចល័តស្មាតហ្វូន (smartphones) ដែលជាមធ្យោបាយក្នុងការភ្ជាប់ប្រព័ន្ធអ៊ិនធឺណេតសម្រាប់ប្រមាណ ៩០% នៃអ្នកប្រើប្រាស់ទាំងអស់នៅអាស៊ាន [៩០]។ ដោយឡែកការចាប់ផ្ដើមធុរកិច្ច និងទីផ្សារការងារនៅអាស៊ានជួបប្រទះការផ្លាស់ប្ដូរបែបប្រជាសាស្ត្រមួយទៀតគឺ៖ ការកើនឡើងនៃការចូលរួមរបស់ស្ត្រី។ អាស៊ានមានសហគ្រិនជាស្ត្រីចំនួនជាង ៦១លាននាក់ [៩១] ហើយប្រទេសជាសមាជិកទាំងអស់មានពិន្ទុខ្ពស់លើសមភាពយេនឌ័រក្នុងសហគ្រិនភាព នេះបើយោងតាមរបាយការណ៍តាមដានសហគ្រិនភាពសកល (សូមមើលផ្នែក “វិធីវាស់ស្ទង់ការចាប់ផ្ដើមធុរកិច្ច និងនវានុវត្តន៍” ខាងក្រោម] [៩២,៩៣])។ លទ្ធផលនេះអាចមានឥទ្ធិពលខ្លាំងទៅលើទីផ្សារការងារ ខណៈការស្រាវជ្រាវក្នុងតំបន់បានបង្ហាញថាសហគ្រិនស្ត្រីទំនងជាមានទំនោរទទួលយកនិយោជិតដែលជាស្ត្រីដូចគ្នា[៩៤]។

សរុបជារួមចំនួនប្រជាជនវ័យក្មេង កំណើនការតភ្ជាប់ប្រព័ន្ធអ៊ិនធឺណេត ចំណាត់ថ្នាក់ខ្ពស់លើសមភាពយេនឌ័រ និងកំណើនសេដ្ឋកិច្ចជាចំនុចទាក់ទាញនៅក្នុងអាស៊ានសម្រាប់ការចាប់ផ្ដើមធុរកិច្ច។ ទោះជាយ៉ាងណាក៏ដោយការចាប់ផ្ដើមធុរកិច្ចមានការប្រឈមនឹងឧបសគ្គមួយចំនួន។ ហេដ្ឋារចនាសម្ព័ន្ធអ៊ិនធឺណេត (ដែលចាំបាច់ដើម្បីឲ្យមានល្បឿនលឿន) មិនត្រូវបានបែងចែកស្មើៗគ្នាទេ រីឯទេពកោសល្យ និងមូលធនវិនិយោគក៏មិនមានច្រើនដែរ [៣៦]។ ជាក់ស្ដែងកម្រិតអប់រំដែលមិនស្មើគ្នាទូទាំងរដ្ឋសមាជិកអាស៊ានត្រូវបានគេមើលឃើញថា ជាឧបសគ្គដែលតម្រូវឲ្យមានការយកចិត្តទុកដាក់[៨៨]។ បញ្ហាមួយទៀតនោះគឺ ប្រជាជនអាស៊ានភាគច្រើនមិនមានលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីទទួលបានឥណទាន ឬមិនមានសូម្បីតែគណនីធនាគារ[៩៥]។

បញ្ហាប្រឈមចុងក្រោយនេះ(កង្វះខាតការប្រើប្រាស់ប្រព័ន្ធធនាគារ) ក៏អាចផ្ដល់នូវកាលានុវត្តភាពដល់ការចាប់ផ្ដើមធុរកិច្ចផងដែរ ដោយហេតុថា ការចាប់ផ្ដើមធុរកិច្ចភាគច្រើននៅអាស៊ានស្ថិតក្នុងវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច បច្ចេកវិទ្យាហិរញ្ញវត្ថុ និងសេវាកម្មតាមតម្រូវការ [៣៦]។ “សេដ្ឋកិច្ចតាមប្រព័ន្ធអ៊ិនធឺណេត” បានកើនឡើង ៣៧% ចន្លោះឆ្នាំ២០១៧ និង២០១៨ ពោលគឺកើនដល់ ៧២ប៊ីលានដុល្លារអាម៉េរិក គិតជាតម្លៃទំនិញសរុប (gross merchandise value) ក្នុងឆ្នាំ២០១៨[៨៩]។

ការចាប់ផ្ដើមធុរកិច្ចថ្មីត្រូវបានគេព្យាករថា មានចំនួនប្រមាណ ៧.០០០ នៅក្នុងអាស៊ាន[៩០]។ សហគ្រិនភាគច្រើនមានអាជីវកម្មខ្នាតតូច ពោលគឺចន្លោះពី ៩០ ទៅ ៩៩% នៃសហគ្រាសសរុបនៅក្នុងរដ្ឋសមាជិកអាស៊ាននីមួយៗ គឺជាសហគ្រាសធុនតូច និងមធ្យម ឬហៅកាត់ជាភាសាអង់គ្លេសថា SMEs (Small and Medium Enterprises) [៨៨, ៩៦, ៩៧]។ ការប្រៀបធៀប

> “ ហេដ្ឋារចនាសម្ព័ន្ធអ៊ិនធឺណេត (ដែលចាំបាច់ដើម្បីឲ្យមានល្បឿនលឿន) មិនត្រូវបានបែងចែកស្មើៗគ្នាទេ រីឯទេពកោសល្យ និងមូលធនវិនិយោគក៏មិនមានច្រើនដែរ។ ”

**តារាង០១៖** ក្របខ័ណ្ឌគោលនយោបាយអាស៊ានសម្រាប់ការចាប់ផ្ដើមធុរកិច្ចថ្មីថ្មោង

| រយៈពេល | ២០១៥ | | | ២០១៧ | | | ២០១៨ |
|---|---|---|---|---|---|---|---|
| **តួអង្គ** | អាស៊ាន | អាស៊ាន | អាស៊ាន | អាស៊ាន | ILO + អាស៊ាន | អាស៊ាន | ប្រធានអាស៊ាន |
| **ក្របខ័ណ្ឌ** | ផែនការ AEC ២០២៥ | ផែនការសកម្មភាពយុទ្ធសាស្ត្រអាស៊ានសម្រាប់ការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម (២០១៦-២០២៥) | APASTI (២០១៦-២០២៥) | សេចក្ដីប្រកាសស្ដីពីការច្នៃប្រឌិត | ILO ដឹងអំពីធុរកិច្ច | AMEN | ប្រធានបទ៖ ភាពធន់ និងការច្នៃប្រឌិត |
| **គោលបំណង** | សមាហរណកម្មសេដ្ឋកិច្ច | សហគមន៍ចម្រុះ | | ឧស្សាហកម្មមានការច្នៃប្រឌិតនវានុវត្តន៍ និងការប្រកួតប្រជែង | ការអភិវឌ្ឍន៍សហគ្រិនភាពសហគមន៍ | បណ្ដាញសហគ្រិន | សហគមន៍ដែលមានភាពធន់និងច្នៃប្រឌិត |
| **ការពន្យល់បន្ថែម** | សហគមន៍ប្រកបដោយនវានុវត្តន៍ និងថាមពល | ការអភិវឌ្ឍប្រកបដែលមានភាពប្រកួតប្រជែងសកល នវានុវត្តន៍ និង បរិយាបន្ន | | គោលនយោបាយ STI សម្រាប់កំណើនសេដ្ឋកិច្ចការបង្កើតការងារ សុខុមាលភាព ប្រព័ន្ធវិទ្យាសាស្ត្រ នវានុវត្តន៍ ការអប់រំ STEM, គោលនយោបាយហិរញ្ញវត្ថុ ក្របខ័ណ្ឌ IPR សម្រាប់ការស្រាវជ្រាវនិងអភិវឌ្ឍន៍ | ប្រទេសសាកល្បង៖ កម្ពុជា និងឡាវ | ជំរុញសហគ្រិនតាមរយៈ 3Ms | សិង្ហបុរី |

AEC ៖ សហគមន៍សេដ្ឋកិច្ចអាស៊ាន
AMEN៖ ការណែនាំអំពីអាស៊ានសម្រាប់បណ្ដាញសហគ្រិន
APASTI ៖ ផែនការសកម្មភាពអាស៊ានស្ដីពីវិទ្យាសាស្ត្របច្ចេកវិទ្យានិងនវានុវត្តន៍

IPR ៖ កម្មសិទ្ធិបញ្ញា
3Ms៖ អ្នកណែនាំ ប្រាក់ និងទីផ្សារ
R&D៖ ស្រាវជ្រាវ និងអភិវឌ្ឍន៍

SME៖ សហគ្រាសធុនតូចនិងមធ្យម
STEM៖ វិទ្យាសាស្ត្រ វិស្វកម្ម បច្ចេកវិទ្យា និងគណិតវិទ្យា
STI៖ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

ច្បាស់លាស់មួយមិនអាចធ្វើទៅបាន ដោយសារនិយមន័យ SMEs មានលក្ខណៈខុសៗគ្នានៅក្នុងរដ្ឋសមាជិកអាស៊ាន [៩៦]។ ទោះជាយ៉ាងណា សមាជិកស្ថាបនិកទាំង៥នៃអាស៊ាន និងប្រទេសព្រុយណេ មាននិយមន័យ SME រួមគ្នាមួយសម្រាប់ការបង្កើតគោលនយោបាយ[៨៩]។

> “ អាជីវកម្មចាប់ផ្តើមថ្មីត្រូវបានព្យាករថាមានចំនួនប្រមាណ ៧.០០០ នៅក្នុងអាស៊ាន។ ”

## ការវាស់ស្ទង់ការចាប់ផ្តើមធុរកិច្ច និងនវានុវត្តន៍

បរិយាកាសនៃការចាប់ផ្តើមធុរកិច្ចត្រូវបានពិចារណាតាមរយៈការឆ្លុះបញ្ចាំងចំនួនបួន ដែលមានរៀបរាប់សង្ខេបដូចខាងក្រោម៖

- “ការតាមដានសហគ្រិនភាពសកល”(Global Entrepreneurship Monitor [GEM]) គឺជាការវាស់ស្ទង់បែបបរិស័យទៅលើសកម្មភាពសហគ្រិនភាពក្នុងប្រទេសមួយ។ ការវាស់ស្ទង់នេះត្រូវបានប្រើនៅក្នុងប្រទេសចំនួន១២០ ផ្សេងៗគ្នា[៩២]។
- Startup Genome ជាអង្គការដែលសិក្សាទៅលើការចាប់ផ្តើមធុរកិច្ច និងបែងចែកការចាប់ផ្តើមថ្មី ជាបួនដំណាក់កាលនៃ “វដ្តនៃដំណើរការ” របស់ធុរកិច្ច[៩៨]។
- “សន្ទស្សន៍សហគ្រិនភាពសកល” (Global Entrepreneurship Index [GEI]) មិនត្រូវបានប្រើប្រាស់នៅច្រើនប្រទេសដូច GEM ទេ ប៉ុន្តែការវាស់ស្ទង់នេះពិនិត្យទៅលើការចាប់ផ្តើមធុរកិច្ចបែបស៊ីជម្រៅដោយពឹងផ្អែកលើសូចនាករចំនួន ១៤ ក្នុងប្រទេសនីមួយៗ[៩៩]។
- “សន្ទស្សន៍គោលនយោបាយសហគ្រាសធុនតូច និងមធ្យមអាស៊ាន” (ASEAN SME Policy Index) ត្រូវបានបង្កើតដោយអង្គការដើម្បីកិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច (OECD) ប៉ុន្តែត្រូវបានកែសម្រួលសម្រាប់អាស៊ាន។ សន្ទស្សន៍នេះផ្តោតសំខាន់ទៅលើគោលនយោបាយទាក់ទងនឹងការចាប់ផ្តើមធុរកិច្ច។

យោងលើលទ្ធផលនៃ”សន្ទស្សន៍សហគ្រិនភាពសកល” សម្រាប់អាស៊ាន គេសង្កេតឃើញថា ប្រទេសសិង្ហបុរីនាំមុខគេលើគ្រប់វិស័យ លើកលែងតែនវានុវត្តន៍លើផលិតផល (សូចនាករទី១០) និងជំនាញនៃការចាប់ផ្តើមធុរកិច្ច (សូចនាករទី២) ខណៈដែលប្រទេសហ្វីលីពីនមានលទ្ធផលល្អជាងសិង្ហបុរីបន្តិចចំពោះសូចនាករទាំងពីរនេះ។ ជាការគួរឲ្យកត់សម្គាល់ផងដែរថា មិនមានប្រទេសណាមួយក្នុងអាស៊ានមានពិន្ទុខ្ពស់ឡើយនៅលើ “ការយល់ឃើញអំពីកាលានុវត្តភាព” (សូចនាករទី១) ជំនាញនៃការចាប់ផ្តើមធុរកិច្ច (សូចនាករទី២) ឬបណ្តាញទំនាក់ទំនង (សូចនាករទី៤)។ សូចនាករចំនួនពីរដំបូងត្រូវបានវាស់ស្ទង់ដោយការចាត់ថ្នាក់របស់មនុស្សទៅលើកាលានុវត្តភាព និងជំនាញការចាប់ផ្តើមធុរកិច្ចរបស់ខ្លួន ខណៈសូចនាករទី៤ (បណ្តាញទំនាក់ទំនង) គឺជាការរួមបញ្ចូលគ្នារវាងការដែលសហគ្រិនស្គាល់គ្នាទៅវិញទៅមក និងស្គាល់អំពីទីតាំងភូមិសាស្ត្រដែលមានការប្រមូលផ្តុំសហគ្រិនច្រើន [១០០]។

## ការរំពឹងទុកនៅមុខ

> “ ការគៀរគរវិនិយោគទុនសម្រាប់អាជីវកម្មតាមប្រព័ន្ធអ៊ិនធឺណេតកំពុងមានកំណើន ដោយក្នុងឆ្នាំ២០១៥ វិនិយោគទុនដែលគៀរគរបានមានចំនួនដល់ទៅ ១ប៊ីលាន ដុល្លារអាម៉េរិកជាលើកដំបូង ហើយតួលេខនេះបានកើនឡើងយ៉ាងលឿន។ ”

ខណៈដែលអាស៊ានកំពុងមានភាពរីកចម្រើនសេដ្ឋកិច្ច ហើយសកម្មភាពបែបសហគ្រិនកំពុងមានការផុសផុលអត្រានវានុវត្តន៍នៅក្នុងសកម្មភាពបែបសហគ្រិនភាពទាំងនោះនៅមានកម្រិតទាបនៅឡើយ [៣៦,៩២,៩៣]។ “សន្ទស្សន៍គោលនយោបាយសហគ្រាសធុនតូច និងមធ្យមអាស៊ាន” ដែលបានលើកឡើងខាងលើ ដែលចាត់ថ្នាក់សូចនាករទាំងអស់ ពីកម្រិត ១ដល់៦ ធ្វើការចាត់ថ្នាក់ការលើកកម្ពស់នវានុវត្តន៍មានកម្រិតទាបខ្លាំងនៅប្រទេសព្រុយណេ កម្ពុជា ឡាវ និងម៉ាឡេស៊ី ដែលលទ្ធផលនេះបង្ហាញថា នវានុវត្តន៍ប្រហែលជាមានទំនាក់ទំនងនឹងការអភិវឌ្ឍសេដ្ឋកិច្ច។

## ផែនទី ៣០៖ ការបណ្ដុះបណ្ដាល ធុរកិច្ចថ្មី និងនវានុវត្តន៍



> “បញ្ហាប្រឈមដែលនៅសល់ធំជាងគេសម្រាប់រដ្ឋជាសមាជិកអាស៊ាន គឺការផ្តល់ឲ្យប្រជាជនរបស់ខ្លួននូវមធ្យោបាយដែលអាចទាញយកប្រយោជន៍ពីបច្ចេកវិទ្យា កំណើនទីផ្សារ និងថាមភាពនៃប្រជាជន។”

ដូចដែលបានលើកឡើងខាងលើ ការទាញយកមូលធនវិនិយោគ គឺជាបញ្ហាមួយដែលកើតមានយូរមកហើយក្នុងបណ្តាប្រទេសអាស៊ាន។ ក៏ប៉ុន្តែបន្តិចម្តងៗបញ្ហានេះបែរជាកំពុងប្រែក្លាយជាចំណុចខ្លាំងទៅវិញ[៩០]។ ការកៀរគរវិនិយោគទុនសម្រាប់អាជីវកម្មតាមប្រព័ន្ធអ៊ិនធឺណេតកំពុងមានកំណើនដោយក្នុងឆ្នាំ២០១៥ វិនិយោគទុនដែលកៀរគរបានមានចំនួនដល់ទៅ ១ប៊ីលានដុល្លារអាមេរិក ជាលើកដំបូង ហើយចំនួននេះបានកើនឡើងយ៉ាងឆាប់រហ័ស។ ក្នុងរយៈពេលបួនឆ្នាំ (ឆ្នាំ២០១៥ ២០១៦ ២០១៧ និង ២០១៨) វិនិយោគទុនជាង ២៤ប៊ីលានដុល្លារ ត្រូវបានកៀរគរសម្រាប់អាជីវកម្មតាមប្រព័ន្ធអ៊ិនធឺណេត។ ក្នុងចំណោមនោះ មូលធនចំនួន១៦ប៊ីលានដុល្លារបានចូលទៅក្នុងក្រុមហ៊ុនអ៊ិនធឺណេតធំៗ (internet unicorns សំដៅលើអាជីវកម្មឯកជនចាប់ផ្តើមថ្មីដែលមានតម្លៃជាង ១ប៊ីលានដុល្លារ) ចំនួនប្រាំបួនក្នុងតំបន់អាស៊ីអាគ្នេយ៍ (រួមមានក្រុមហ៊ុន៖ Bukalapak, Go-jek, Grab, Lazada, Razer, Sea Group, Traveloka, Tokopedia, និង VNG)[៩០]។

ជាមួយគ្នានេះផងដែរ បច្ចេកវិទ្យាហិរញ្ញវត្ថុ គឺជាវិស័យដែលមានថាមភាពខ្ពស់ក្នុងការវិនិយោគលើប្រព័ន្ធអ៊ិនធឺណេតក្នុងអាស៊ាន។ វិស័យនេះទទួលបានវិនិយោគទុនចំនួន ៥០០លានដុល្លារអាមេរិក ក្នុងឆមាសទីមួយនៃឆ្នាំ២០១៨ ដែលបានហូរចូលទៅអាជីវកម្មថ្មីថ្មោងចំនួនជាង ៣០០[៩០]។ ម្យ៉ាងទៀត ក្នុងកម្មវិធីបច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech Festival) របស់ប្រទេសសិង្ហបុរីបានទាក់ទាញអ្នកចូលរួមចំនួន ៤៥ ០០០នាក់ កាលពីខែវិច្ឆិកា ឆ្នាំ ២០១៨[៨០]។ ក្នុងកម្មវិធីនោះ វាគ្មិនសំខាន់ៗបានសង្កេតឃើញថា ប្រជាប្រិយភាពរបស់បច្ចេកវិទ្យាហិរញ្ញវត្ថុអាចពាក់ព័ន្ធនឹងចំនួនដ៏ច្រើននៃប្រជាជនអាស៊ានដែលមិនទាន់ប្រើប្រាស់សេវាធនាគារ (ដូចជាអ្នកដែលគ្មានគណនីធនាគារជាដើម) និងពាក់ព័ន្ធទៅនឹងកាលានុវត្តភាពដែលផ្តល់ឲ្យដោយការចាប់ផ្តើមធុរកិច្ចថ្មីដែលអាចធ្វើប្រតិបត្តិការឆ្លងព្រំដែនបាន ប៉ុន្តែស្ថិតតែនៅក្នុងរង្វង់សហគមន៍សេដ្ឋកិច្ចអាស៊ាន (ASEAN Economic Community)[៩៥] តែប៉ុណ្ណោះ។

បញ្ហាប្រឈមដែលនៅសល់ធំជាងគេសម្រាប់រដ្ឋជាសមាជិកអាស៊ាន គឺការផ្តល់ឲ្យប្រជាជនរបស់ខ្លួននូវមធ្យោបាយដែលអាចទាញយកប្រយោជន៍ពីបច្ចេកវិទ្យា កំណើនទីផ្សារ និងថាមភាពនៃប្រជាជន។ នេះមានន័យថា ត្រូវធ្វើការវិនិយោគលើការវិស័យអប់រំ និងខិតខំធ្វើឲ្យមានប្រព័ន្ធអប់រំមួយដែលប្រកបដោយសមាហរណកម្មនៅក្នុងអាស៊ាន [៨៨] និងផ្តោតលើការបណ្តុះបណ្តាលវិជ្ជាជីវៈដែលផ្តល់ឲ្យប្រជាពលរដ្ឋនូវជំនាញបែបសហគ្រិនដែលចាំបាច់ដើម្បីស្ថាបនា ឬបម្រើការងារក្នុងធុរកិច្ចថ្មី[៨៩]។

## ៨.៨.៥ ហេដ្ឋារចនាសម្ព័ន្ធ និងទីក្រុងឆ្លាតវៃ នៅអាស៊ីអាគ្នេយ៍

> “ភាពក្រីក្រនៅក្នុងទីក្រុងបានធ្លាក់ចុះ ប៉ុន្តែវិសមភាពរវាងប្រជាជនមានការកើនឡើង [៨៨]។ ភាពក្រីក្រនៅក្នុងទីក្រុងបានធ្លាក់ចុះ ប៉ុន្តែវិសមភាពរវាងប្រជាជនមានការកើនឡើង។”

អាស៊ីអាគ្នេយ៍ជាតំបន់មាន វប្បធម៌ ជនជាតិ ភាសា ប្រជាសាស្ត្រ និងប្រព័ន្ធសេដ្ឋកិច្ចនយោបាយបែបចម្រុះ។ កត្តាទាំងអស់នេះបានកំណត់ឲ្យកិច្ចអភិវឌ្ឍន៍ប្រទេសនីមួយៗក្នុងតំបន់ស្ថិតក្នុងដំណាក់កាលផ្សេងៗគ្នា[១០១]។ អាស៊ានជាតំបន់មួយក្នុងចំណោមតំបន់លូតលាស់លឿនជាងគេបំផុតក្នុងពិភពលោកពាក់ព័ន្ធនឹងកំណើនប្រជាជននិងទីក្រុង[១០២]។ ការរីកចម្រើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័សក្នុងតំបន់នេះកើតឡើងស្របគ្នានឹងនគរូបនីយកម្មយ៉ាងរហ័សរបស់តំបន់។ ទីក្រុងនានាតាមបណ្តាប្រទេសអាស៊ានបានចូលរួមចំណែកពីរភាគបីនៃផលិតផលសរុបក្នុងស្រុករបស់តំបន់ [១០១]។ ដោយសារការអភិវឌ្ឍសេដ្ឋកិច្ច និងការផ្លាស់ប្តូរប្រជាសាស្ត្រ ចំនួនប្រជាជននៅទីក្រុងបានកើនឡើងប្រចាំឆ្នាំចំនួន៣,៦% [១០៣]។ បច្ចុប្បន្នមានប្រជាជនក្នុងតំបន់អាស៊ានច្រើនជាងពាក់កណ្តាលបាននឹងកំពុងរស់នៅ

ក្នុងតំបន់ទីក្រុងនៅឆ្នាំ២០១៩។ តួលេខនេះនឹងកើនឡើងដល់ ៩០លាននាក់ ត្រឹមឆ្នាំ២០៣០ [១០៤,១០៥]។ ទីក្រុងធំៗ ដូចជា ចាការតា ម៉ានីល បាងកក និង កូឡាឡាំពួរ បានផ្តល់ជាជម្រកដល់មនុស្សជាង ២០% នៃប្រជាជនសរុបក្នុងប្រទេសទាំងនោះ [១០១]។ កម្រិតនគរូបនីយកម្មជាមធ្យមនៅក្នុងប្រទេសឡាវ មានចំនួន ៤,៩% និងឥណ្ឌូនេស៊ី មានចំនួន២%ក្នុងមួយឆ្នាំ ខណៈពេលដែលចំនួនប្រជាជននៅក្នុងទីក្រុងនៅប្រទេសវៀតណាម បានកើនឡើងប្រមាណ១៤%រវាងឆ្នាំ១៩៩០និងឆ្នាំ២០១៥ [១០៣, ១០៥]។

នគរូបនីយកម្មតំបន់អាស៊ាន បាននឹងកំពុងកើតឡើងយ៉ាងរហ័សជាងការធ្វើផែនការទីក្រុង [១០១] ខណៈពេលដែលទីក្រុងនានានៅតែបន្តផ្លាស់ប្តូរស្របទៅតាមសាកលភាវូបនីយកម្ម និងពហុជាតិនិយម[១០២]។ ភាគច្រើននៃការពង្រីកទីក្រុង គឺផ្អែកទៅលើទីផ្សារ ហើយការធ្វើផែនការសាធារណៈរយៈពេលវែង បានបរាជ័យរួចទៅហើយក្នុងការឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅលើការរីកលូតលាស់ទីក្រុងយ៉ាងរហ័ស[១០៣]។ ផលវិបាកនៃការពង្រីកទីក្រុងរួមមានលទ្ធផលមិនសមគ្នារវាងការផ្តល់ហេដ្ឋារចនាសម្ព័ន្ធគាំទ្រ និងសេវាឆ្លើយតបនឹងកំណើនប្រជាជននៅក្នុងទីក្រុង។ ស្ទើរតែគ្រប់ទីក្រុងធំៗរបស់បណ្តាប្រទេសអាស៊ានទាំងអស់ប្រឈមនឹងបញ្ហាការស្ទះចរាចរណ៍ ការបំពុលទឹកនិងខ្យល់ ថាមពលមិនទៀងទាត់ តម្លៃលំនៅដ្ឋានដែលមិនសមស្រប និងកង្វល់ផ្នែកសន្តិសុខ [១០១, ១០៣, ១០៤]។ ភាពក្រីក្រនៅក្នុងទីក្រុងបានធ្លាក់ចុះ ប៉ុន្តែវិសមភាពរវាងប្រជាជនមានការកើនឡើង [៨៨]។

ពាក់កណ្តាលនៃប្រជាជនដែលរស់នៅក្នុងទីក្រុងមិនអាចប្រើប្រាស់ទឹកស្អាត និង២០%ផ្សេងទៀត មិនអាចទទួលបានសេវាអនាម័យ[១០៣]។ ការតាំងទីលំនៅមិនផ្លូវការរបស់ប្រជាជនបានកើតមានឡើងនៅតាមបណ្តាទីក្រុងធំៗជាច្រើនក្នុងតំបន់អាស៊ាន ហើយលក្ខខណ្ឌរស់នៅមានកម្រិតទាប និងការទទួលបានសេវាសង្គមក៏នៅមានកង្វះខាតខ្លាំង[១០៦]។

កង្វះខាតប្រព័ន្ធដឹកជញ្ជូនសាធារណៈបានជម្រុញឲ្យអ្នកដំណើរនៅក្នុងទីក្រុងជាច្រើនប្រើប្រាស់យានជំនិះផ្ទាល់ខ្លួនដែលជាកត្តាបង្កឲ្យមានការកកស្ទះចរាចរណ៍[១០៧]។ ទីក្រុងចាការតា និងទីក្រុងបាងកកបានទទួលចំណាត់ថ្នាក់ក្នុងចំណោមទីក្រុងបីនៅលើពិភពលោកដែលមានបញ្ហាចរាចរណ៍អាក្រក់ជាងគេ[១០១]។ នៅឆ្នាំ២០១៥ ទីក្រុងចាការតាតែមួយបានបាត់បង់ទឹកប្រាក់ប្រមាណ៤៤៨ប៊ីលានដុល្លាអាម៉េរិក ឬស្មើនឹង ៣,៣% នៃផលិតផលសរុបក្នុងស្រុករបស់ទីក្រុងដោយសារបញ្ហាការកកស្ទះចរាចរណ៍ [១០៧]។ ដោយសារសំពាធកើនឡើងបណ្តាទីក្រុងនានារបស់ប្រទេសក្នុងតំបន់អាស៊ានបានប្រឈមនឹងបញ្ហាពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គមដើម្បីរក្សាកន្លែងសម្រាប់ការរីកលូតលាស់ទីក្រុង[១០២]។ សំនួរនៅត្រង់ថាតើគេត្រូវធ្វើផែនការដើម្បីដោះស្រាយបញ្ហាការរីកលូតលាស់ និងការអភិវឌ្ឍទីក្រុងនីមួយៗទៅថ្ងៃអនាគតយ៉ាងដូចម្តេច? [១០២]។ ស្ថានភាពនេះចាំបាច់ត្រូវធ្វើផែនការផ្តួចផ្តើមទីក្រុងឆ្លាតវៃសម្រាប់ការអភិវឌ្ឍទីក្រុងប្រកបដោយចីរភាព [៨៩]។ ទោះជាយ៉ាងនេះក្តី ធនាគារអភិវឌ្ឍន៍អាស៊ីបានប៉ាន់ប្រមាណថាការចំណាយសម្រាប់កិច្ចការលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធទីក្រុងនៅក្នុងតំបន់អាចមានចំនួនទឹកប្រាក់រហូតដល់ ៦០ប៊ីលានដុល្លាអាម៉េរិក ក្នុងមួយឆ្នាំ[៨៨]។ កម្រិតទឹកប្រាក់នេះមានន័យថា បណ្តាទីក្រុងជាច្រើនក្នុងតំបន់នឹងជួបការលំបាកក្នុងការដោះស្រាយបញ្ហានគរូបនីយកម្មយ៉ាងរហ័សរបស់ខ្លួន[១០៦]។

**“ ទីក្រុងធំៗដូចជា ចាការតា ម៉ានីល បាងកក និងកូឡាឡាំពួរបានផ្តល់ជាជម្រកដល់មនុស្សជាង ២០% នៃប្រជាជនសរុបក្នុងប្រទេសទាំងនោះ។ ”**

> “ បណ្តាទីក្រុងនានារបស់ប្រទេសក្នុងតំបន់អាស៊ានបានប្រឈមនឹងបញ្ហាពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងសង្គមដើម្បីរក្សាកន្លែងសម្រាប់ការរីកលូតលាស់ទីក្រុង។ ស្ថានភាពនេះចាំបាច់ត្រូវធ្វើផែនការផ្តួចផ្តើមទីក្រុងឆ្លាតវៃសម្រាប់ការអភិវឌ្ឍទីក្រុងប្រកបដោយចីរភាព។ ”

តាមនិយមន័យទីក្រុងឆ្លាតវៃសំដៅទៅលើការប្រើប្រាស់បច្ចេកវិទ្យានិងដំណោះស្រាយបច្ចេកទេសបែបឆ្លាតវៃដើម្បីដោះស្រាយបញ្ហាទីក្រុង ក្នុងគោលដៅជម្រុញប្រសិទ្ធិភាពចីរភាព និងភាពរស់នៅយូរអង្វែង[១០៤, ១០៥, ១០៨, ១០៩]។ អាស៊ានចាប់ផ្តើមអនុវត្តក្របខ័ណ្ឌអភិវឌ្ឍន៍ទីក្រុងឆ្លាតវៃ(ASCF)នៅឆ្នាំ២០១៨បន្ទាប់ពីការបង្កើតបណ្តាញទីក្រុងឆ្លាតវៃអាស៊ាន (ASCN) ។ គម្រោង ASCF ត្រូវបានដាក់អោយអនុវត្តនៅ ២៦ទីក្រុងទូទាំងតំបន់។ គម្រោងទាំងនោះគឺផ្តោតលើការដឹកជញ្ជូន ប្រព្រឹត្តិកម្មទឹកស្អាត ថាមពល សុខាភិបាល ការអប់រំ សេវាសាធារណៈ និងប្រព័ន្ធបណ្តាញទូរគមនាគមន៍[១០៤, ១០៧]។ រដ្ឋដែលជាសមាជិកនីមួយៗមានតួនាទីក្នុងការអភិវឌ្ឍផែនការមេ និងដាក់ចុះនូវវិស័យអាទិភាពសម្រាប់គម្រោងនីមួយៗ[១០៤, ១០៩]។ ASCF ផ្តោតជាសំខាន់ទៅលើវិស័យចំនួន៦គឺ៖ (១) ប្រជាពលរដ្ឋនិងសង្គម (២) សុខភាពនិងសុខមាលភាព (៣)សុវត្ថិភាពនិងសន្តិសុខ (៤)គុណភាពបរិស្ថាន (៥)ការកសាងហេដ្ឋារចនាសម្ព័ន្ធ និង(៦) ឧស្សាហកម្ម និងបច្ចេកវិទ្យា [១០៧, ១០៩]។

បណ្តាទីក្រុងជាច្រើនបាននឹងកំពុងខិតខំអភិវឌ្ឍក្នុងទិសដៅលើកកម្ពស់សុខដុមនីយកម្មរបស់ខ្លួន ។ សិង្ហបុរីជាប្រទេសនាំមុខគេក្នុងអាស៊ានក្នុងការអភិវឌ្ឍទីក្រុងឆ្លាតវៃដោយការប្រើប្រាស់បញ្ញាសិប្បនិមិត្ត (AI) ដើម្បីជួយដល់ការងារនានារបស់រដ្ឋាភិបាលដែលរួមបញ្ចូលទាំងការរៀបចំផែនការទីក្រុង[១១០, ១១១]។ សិង្ហបុរី និងទីក្រុងម៉ាកាសារបស់ឥណ្ឌូនេស៊ីបានកែប្រែសេវារដ្ឋមួយចំនួនឲ្យទៅជាស្វ័យប្រវត្តិ ក្នុងគោលបំណងលើកកម្ពស់សក្តិសិទ្ធភាពក្នុងការផ្តល់សេវា និងកាត់បន្ថយចំណាយ។ សិង្ហបុរីក៏បាន

> “ ទីក្រុងនៅតាមបណ្តាប្រទេសអាស៊ានមួយចំនួនបានបញ្ចូលការប្រើប្រាស់បច្ចេកវិទ្យាឆ្លាតវៃដើម្បីជំរុញការអភិវឌ្ឍសង្គមសេដ្ឋកិច្ច។ ”

ដាក់អោយប្រើប្រាស់ផងដែរនូវសេវា GRAB សម្រាប់ការធ្វើដំណើរក្នុងទីក្រុង។ បច្ចេកវិទ្យានេះត្រូវបានបន្តយកទៅប្រើប្រាស់នៅបណ្តាប្រទេសក្នុងតំបន់ដទៃទៀត[១១០]។

ទីក្រុងចាការតាបានដាក់អោយប្រើប្រាស់កម្មវិធីក្នុងទូរស័ព្ទមួយដែលមានឈ្មោះថា “Qlue” ដែលអាចឲ្យប្រជាពលរដ្ឋនៅក្នុងទីក្រុងរាយការណ៍បញ្ហានានាទាក់ទងទៅនឹងការគ្រប់គ្រងទីក្រុង និងអភិបាលកិច្ច ដើម្បីទទួលបានការឆ្លើយតបទាន់ពេល។ ទីក្រុងបាត់ដំបងរបស់កម្ពុជាបានធ្វើការពង្រីកឆ្លាសាធារណៈដើម្បីសំរួលការរស់នៅរបស់ប្រជាពលរដ្ឋ។ ទីក្រុងយ៉ាងហ្គូន និង ទីក្រុងបានដាសេរីបេហ្គាវ៉ាន់ផ្តោតជាសំខាន់ទៅលើការអភិរក្សតំបន់វប្បធម៌ប្រវត្តិសាស្ត្ររបស់ទីក្រុង[១០៧]។ តេលេមេឌីស៊ីនកំណត់ត្រាសុខភាពឌីជីថល និងសេវាសុខភាពបំលាស់ទីគឺជាបច្ចេកវិទ្យាសុខាភិបាលថ្មីៗដែលបានដាក់បញ្ចូលទៅក្នុងសេវាសុខាភិបាលនៅទីក្រុងម៉ានីល និងទីក្រុងម៉ាកាសា។ ប្រព័ន្ធសិក្សាតាមបែបអេឡិចត្រូនិច (E-education) ក៏ត្រូវបានដាក់អោយសាកល្បងនៅទីក្រុងមួយចំនួនដូចជា បានូវ៉ាន់ហ្គី ម៉ានីល និង ណៃពិដោរ។ ក្រៅពីគម្រោងលំនៅដ្ឋានតំលៃសមរម្យ ទីក្រុងយ៉ាងហ្គូន និងណៃពិដោរបានបំពាក់ឧបករណ៍បញ្ជាចរាចរណ៍ឆ្លាតវៃ រួមជាមួយនិងប្រព័ន្ធតាមដានដើម្បីជួយសំរួលចរាចរណ៍ទីក្រុង[១០៧]។ កាមេរ៉ាសុវត្ថិភាពកាន់តែច្រើនត្រូវបានបំពាក់នៅទីក្រុងហាណូយ ដាណាង ដាវ៉ៅ និងស៊ីប៊ូ ដើម្បីជួយសំរួលចរាចរណ៍ និងពង្រឹងសន្តិសុខ [១០៧]។

ការងារទាក់ទងទៅនឹងការពង្រឹងគុណភាពបរិស្ថានមានច្រើនលើការងារប្រព្រឹត្តិកម្មទឹកស្អាតនិងចែកចាយ និងការធ្វើអោយប្រសើរឡើងប្រព័ន្ធលូនៅតាមទីក្រុងតូចៗមួយចំនួនដូចជា បានដាសេរីបេហ្គាវ៉ាន់ វៀងច័ន្ទ ដាណាង សៀមរាប ហ្លួងព្រះបាង និងចូហូបារូ[១០៧]។ ទីក្រុងគូឡាឡាំពួរបានប្រើប្រាស់បច្ចេកវិទ្យាឆ្លាតវៃជាជំនួយក្នុងការរៀបចំគម្រោងប្រព័ន្ធដឹកជញ្ជូនសាធារណៈ ផ្លូវសម្រាប់អ្នកជិះកង់ និងអ្នកថ្មើរជើង។ បណ្តាទីក្រុងដូចជា សៀមរាប បាត់ដំបង គូជីង ម៉ានដាឡេ និង កូតាគីណាបាលូ រក្សាអនាម័យទីក្រុងតាមការអនុវត្តការគ្រប់គ្រងសំណល់ប្រកប

## ផែនទី ៣១៖ ទីក្រុងឆ្លាត




ប្រភព៖ កែសម្រួលពីមជ្ឈមណ្ឌលសម្រាប់ទីក្រុងដែលអាចរស់នៅបាន (២០១៨) បណ្ដាញទីក្រុងឆ្លាតក្នុងអាស៊ាន ក្រសួងការបរទេសសិង្ហបុរី

ដោយនិរន្តរភាព។ ទីក្រុងភ្នំពេញបានដាក់អោយប្រើប្រាស់ការទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិចសម្រាប់សេវាដឹកជញ្ជូនសាធារណៈ[១០៧]។ ទីក្រុងនៅតាមតំបន់ឆ្នេរដូចជាដាណាង ស៊ីប៊ូ និងសូរ៉ាបាយ៉ាកំពុងព្យាយាមកែលំអរបរិស្ថានទីក្រុង តាមចក្ខុវិស័យការអភិវឌ្ឍទីក្រុងបៃតង[១១២]។ ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ជាផ្នែកមួយក្នុងផែនការអភិវឌ្ឍទីក្រុងរបស់ទីក្រុងចាការតានិងដាណាង។ មធ្យោបាយ បច្ចេកទេសមួយចំនួនដូចជាការលើកកម្ពស់ប្រសិទ្ធភាពក្នុងការប្រើប្រាស់ថាមពលត្រូវបានយកមកប្រើ[១១២]។ ទីក្រុងបាងកកនិងហូជីមិញបាន និងកំពុងប្រើប្រាស់ប្រព័ន្ធដឹកជញ្ជូនសាធារណៈដែលមានលក្ខណៈទំនើបដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងការស្ទះចរាចរណ៍[១០៦]។

ទីក្រុងនៅតាមបណ្ដាប្រទេសអាស៊ានមួយចំនួនបានបញ្ចូលការប្រើប្រាស់បច្ចេកវិទ្យាឆ្លាតវៃដើម្បីជំរុញការអភិវឌ្ឍសង្គមសេដ្ឋកិច្ច។ សម្រាប់ទីក្រុងចាការតា គម្រោងទីក្រុងឆ្លាតវៃមានគោលបំណងបង្កើតការងារ ២០០.០០០កន្លែងដោយអោយស្ថាប័នស្រាវជ្រាវផ្ដល់នូវសេវាសម្រាប់ការអភិវឌ្ឍគំនិតអាជីវកម្មផ្សេងៗសម្រាប់ក្រុមហ៊ុនណាដែលត្រូវការ។ ទីក្រុងសៀមរាបបានរៀបចំប្រព័ន្ធគ្រប់គ្រងទេសចរណ៍ដើម្បីគ្រប់គ្រងកំណើនចំនួនទេសចរ ដែលវិធានការស្រដៀងគ្នានេះដែរត្រូវបានយកទៅប្រើនៅទីក្រុងភូកេត[១០៧]។

ការកសាងទីក្រុងឆ្លាតវៃជាការងារមួយដ៏លំបាក។ វាតម្រូវអោយមានការថ្លឹងថ្លែងរវាងកំណើនសេដ្ឋកិច្ចជាមួយនឹងការរៀបចំផែនការអភិវឌ្ឍទីក្រុងដែលប្រកបដោយបរិយាបន្ន ហើយក្នុងពេលជាមួយគ្នាត្រូវធានានូវគុណភាពបរិស្ថាន។ ដូច្នេះការអភិវឌ្ឍនេះទាមទារជាចាំបាច់នូវការវិភាគស៊ីជម្រៅពាក់ព័ន្ធនឹងកត្តាសេដ្ឋកិច្ចនយោបាយ សង្គមវប្បធម៌រួមជាមួយនិងលក្ខខណ្ឌប្រជាសាស្ត្រនិងភូមិសាស្ត្ររបស់ទីក្រុងនីមួយៗ[១០៣]។ សំខាន់ជាងនេះទៀត គ្រប់គម្រោងអភិវឌ្ឍទីក្រុងត្រូវតែឲ្យមានការចូលរួមពីប្រជាជនដែលនឹងរងផលប៉ះពាល់ពីគម្រោងក្នុងគ្រប់ដំណើរការអភិវឌ្ឍគម្រោងក្នុងគោលដៅដើម្បីធានាឲ្យបានថាផលប៉ះពាល់អវិជ្ជមានលើពួកគេត្រូវបានកាត់បន្ថយ និងផលប្រយោជន៍ពីការអនុវត្តគម្រោងត្រូវបានចែករំលែកដោយសមធម៌[១]។



**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដែលបកដោយវិទ្យាស្ថានសភាកម្ពុជា (PIC)។ អត្ថបទដើមជាភាសាអង់គ្លេសអាចទាញយកពីគេហទំព័រ៖ https://www.pic.org.kh ។

## MAP 24 SOURCES


International Court of Justice (ICJ). (2003). *Sovereignty over Pedra Branca/Pulau Batu Puteh, Middle Rocks and South Ledge (Malaysia/Singapore) [Online]. Netherlands ICJ. Available at: https://www.icj-cij.org/en/case/130* [Accessed 21 Sep. 2019].

Ministry of Foreign Affairs Singapore. (n.d). Pedra Branca [Online]. Singapore: Ministry of Foreign Affairs. Available at: https://www.mfa.gov.sg/SINGAPORES-FOREIGN-POLICY/Key-Issues/Pedra-Branca [Accessed 23 Sep. 2019].

PMC Editor. (2017). *Indonesia, Timor-Leste establish new forum process to settle border disputes* [Online]. Indonesia: Asia Pacific Report. Available at: https://asiapacificreport.nz/2017/02/15/indonesia-timor-leste-establish-new-forum-process-to-settle-border-disputes/ [Accessed 23 Sep. 2019].

Singh, R. (2019). *The Indonesia-Malaysia Dispute Concerning Sovereignty over Sipadan and Ligitan Islands: Historical Antecedents and the International Court of Justice Judgment* [Online]. Singapore: ISEAS – Yusof Ishak Institute.  [Accessed 21 Sep. 2019].

Radio Free Asia. (2015). *Cambodia protests against Vietnam's road construction projects in border area* [Online]. Washington: UNHCR. Available at: https://www.refworld.org/docid/55b1f82329.html [Accessed 29 May. 2020].

Pech, S. (2015). *Vietnam renews claim to Mondulkiri land* [Online]. Phnom Penh, Cambodia: The Phnom Penh Post. Available at: https://www.phnompenhpost.com/national/vietnam-renews-claim-mondulkiri-land [Accessed 22 Sep. 2019].

Niem, C. (2018). *VN border ''largely' marked* [Online]. Phnom Penh, Cambodia: The Phnom Penh Post. Available at: https://www.phnompenhpost.com/national/vn-border-largely-marked [Accessed 22 Sep. 2019].

Eckert, P. (2017). *Troops from Laos and Cambodia in Cross-Border Standoff Over Road Construction* [Online]. Washington: Radio Free Asia (RFA). Available at: https://www.rfa.org/english/news/laos/cambodia-border-05162017174520.html [Accessed 23 Sep. 2019].

## FOOTNOTES

A. Productive health measured by maternal mortality ratio and adolescent birth rates

B. Empowerment measured by proportion of parliamentary seats occupied by females and proportion of adult females and males aged 25 years and older with at least some secondary education.

C. Economic status expressed as labor market participation and measured by labor force participation rate of female and male populations aged 15 years and older.

D. State-based institutions that advocate for gender equality

E. Political life is organized according to male norms and values, and in some cases even male lifestyles.

F. End all forms of discrimination against all women and girls everywhere

## REFERENCES


១. International Republican Institute (IRI), (2016). Women's Political Empowerment, Representation and Influence in Africa: A Pilot Study of Women's Leadership in Political Decision-Making Washington, DC: IRI, 4. Available at: https://www.iri.org/sites/default/files/wysiwyg/womens_political_index_0.pdf [Accessed 10 Mar 2019 ].

២. Ben, H. (2017). Increasing Women's Parliamentary Representation in Asia andthe Pacific: The Indonesian Experience. Asia and the Pacific Policy Studies, 4. Available at: https://onlinelibrary.wiley.com/doi/epdf/10.1002/app5.160 [Accessed 10 Mar 2019 ].

៣. IPU. (2019). Women in National Parliaments [Online]. Online IPU. Available at: http://archive.ipu.org/wmn-e/world.htm [Accessed 06 Jan 2020].

៤. UNWOMEN. (2019 ). Facts and figures: Leadership and political participation [Online]. Online UNWOMEN Available at: https://www.unwomen.org/en/what-we-do/leadership-and-political-participation/facts-and-figures#notes [Accessed 10 Jan 2020 ].

៥. UNDP, (2019). Human Development Report 2019. Online: UNDP, Available at: http://hdr.undp.org/sites/default/files/hdr_2019_overview_-_english.pdf [Accessed 10 Mar 2019 ].

៦. Kumar, P. (2017). Participation of Women in Politics: Worldwide Experience. IOSR Journal Of Humanities And Social Science, 22(12), 77-88. [Accessed 13 Mar 2019].

៧. Asiedu, E., Branstette, C., Gaekwad-Babulal, N., et al. (2016). The Effect of Women's Representation in Parliament and the Passing of Gender Sensitive Policies. [Accessed 13 Mar 2019].

៨. Asiedu, E., Branstette, C., Gaekwad-Babulal, N., et al., (2018 ). The Effect of Women's Representation in Parliament and the Passing of Gender Sensitive Policies Online SDC, [Accessed 10 Jan 2020 ].

៩. Drage, J., (2001). Women in Local Government in Asia and the Pacific: A comparative analysis of thirteen countries. Thailand: UNESCAP, Available at: https://www.onlinewomeninpolitics.org/beijing12/wlgap.pdf [Accessed 10 Mar 2019].

១០. Ballington, J. (2009). Equality in Politics: A Survey of Men and Women in Parliaments, Geneva, Switzerland, IPU,

១១. Shames, S. (2015). Barriers and Solutions to Increasing Women's Political Power. Discussion Draft, 13. Available at: https://scholars.org/sites/scholars/files/shauna_shames_-_barriers_and_solutions.pdf [Accessed 10 Jan 2020 ].

១២. KEM, K. and CHEA, M., (2016). Progress of Women in Politics in Cambodia. Phnom Penh PIC, Available at: https://www.pic.org.kh/images/2016Research/20170523%20Progress%20of%20Women%20in%20Politics_Eng.pdf [Accessed 12 Mar 2019].

១៣. ASEAN. (N.D). Overview [Online]. Online: ASEAN. Available at: https://asean.org/asean-socio-cultural/asean-ministerial-meeting-on-women-ammw/overview/ [Accessed 10 Mar 2019].

១៤. ASEAN. (2015). ASEAN Socio-Cultural Community [Online]. Online: ASEAN. Available at: https://asean.org/asean-socio-cultural/ [Accessed 11 Mar 2019].

១៥. Raitzer, D. A., Bosello, F., Tavoni, M., Orecchia, C., Marangoni, G., et al., (2015). Southeast Asia and the Economics of global Climate Stabilization Manilla, Phillipines: ADB.

១៦. Indra Overland et al (2017). Impact of Climate Change on ASEAN International Affairs: Risk and Opportunity Multiplier. Norwegian Institute of International Affairs and Myanmar Institute of International and Strategic Studies. Available at: https://www.researchgate.net/publication/320622312_Impact_of_Climate_Change_on_ASEAN_International_Affairs_Risk_and_Opportunity_Multiplie [Accessed 13 September 2018].

១៧. Sam Fankhauser, C. G., Murray Collins, (2014). Domestic dynamics and international influence what explains the passage of climate change legislation. Center for Climate Change Economics and Policy Working Paper,No.175.

១៨. Michal Nachmany, S. F., Joana Setzer and Alina Averchenkova,, (2017). Global trends in climate change legislation and litigation.

១៩. UNDP. (2017). Parliament Plays Central Role in Sustainable Development [Online]. UNDP. Available at: http://www.pacific.undp.org/content/pacific/en/home/presscenter/pressreleases/2017/08/15/parliament-plays-central-role-in-sustainable-development.html [Accessed 12 September 2018].

២០. Chhan Paul and Nun Assachan. (2015). Parliamentary Contributions to the 2015 UN Climate Change Conference [Online]. Phnom Penh, Cambodia.: PIC. Available at: https://www.pic.org.kh/images/2015Research/20160329_%20Parliamentary%20contribution%20to%20the%202015%20UN%20Climate%20Change%20Conference-EN.pdf [Accessed 12 September 2018].

២១. Parliamentary Strengthening. (2017). The Role of Parliament and Climate Change [Online]. PS. Available at:http://www.parliamentarystrengthening.org/climatechangemodule/pdf/unit%2014.pdf [Accessed 12 September 2018].

២២. Dilip, R., Soonhwa, Y. and Seyed, R. Y. (2018). Magnitude and pattern of migration and remittances. Migration and remittances for development in Asia. Manila, Philippines: ADB and World Bank. Charpter 2. pp. 4-17. Available at: https://www.adb.org/sites/default/files/publication/419611/migration-remittances-development-asia.pdf[Accessed 16 Feb. 2019].

២៣. The World Bank. (2018). Accelerated remittances growth to low- and middle-income countries in 2018[Online]. Washington: The World Bank. Available at: https://www.worldbank.org/en/news/press-release/2018/12/08/accelerated-remittances-growth-to-low-and-middle-income-countries-in-2018 [Accessed 26 Feb. 2019].

២៤. Thailand Today Editorial Team. (2019). Thailand's role in driving ASEAN towards the fourth Industrial Revolution [Online]. France: Ambassade Royale de Thaïlande en France Available at: http://www.thaiembassy.fr/fr/2019/02/15/thailands-role-driving-asean-towards-fourth-industrial-revolution/ [Accessed 03 Mar. 2019].

២៥. Eijas, A. (2018). Financing ASEAN's infrastructure demand [Online]. The ASEAN Post,. Available at: https://theaseanpost.com/article/financing-aseans-infrastructure-demand [Accessed 13 Feb. 2019].

២៦. Mohamed, B. A. (2017). Achieving the SDGs: The key role of ICT, Innovation & Partnership. In: Fostering Innovation in the Public Sector of Arab Countries, [pdf] Cairo, Egypt: UNESCWA.Available at.: https://www.unescwa.org/sites/www.unescwa.org/files/events/files/mohamed-ben-amor-sdgs-innovation-partnership.pdf [Accessed 26 Nov. 2018].

២៧. UNESCO. (2018). Positioning ICT in education to achieve the Education 2030 Agenda in Asia and the Pacific: recommendations for a regional strategy. Bangkok, Thailand: UNESCO, Available at: https://unesdoc.unesco.org/ark:/48223/pf0000261661 [Accessed 20 Nov. 2018].

២៨. FactsMaps. (n.d). PISA Worldwide Ranking – average score of math, science and reading [Online]. FactsMaps. Available at: http://factsmaps.com/pisa-worldwide-ranking-average-score-of-math-science-reading/ [Accessed 26 Nov. 2018].

២៩. OECD (2011). Singapore: Rapid Improvement Followed by Strong Performance. In: Lessons from PISA for the United States. Paris: OECD. Available at: https://www.oecd-ilibrary.org/education/lessons-from-pisa-for-the-united-states/singapore-rapid-improvement-followed-by-strong-performance_9789264096660-8-en [Accessed 26 Nov. 2018].

៣០. Patchanee, W. and Pathomporn, R. (2017). Education reform in Thailand: The case of basic education quality improvement for raising the National competitiveness of Thailand among ASEAN member countries. Phnom Penh, Cambodia: Parliamentary Institute of Cambodia (PIC), Available at: https://pic.org.kh/images/2017Research/20170523%20Education_Reform_Thailand_%20Eng.pdf [Accessed 20 Nov. 2018].

៣១. OECD. (2016). Country Note-Results from PISA 2015. [pdf] OECD, Available at: http://www.oecd.org/pisa/PISA-2015-Indonesia.pdf [Accessed 20 Nov. 2018].

៣២. Ministry of Education of Malaysia (2013). Malaysia Education Blueprint 2013-2015, Malaysia: Kementerian Pendidikan

៣៣. Siritharan Kuttappan. (2017). Education reform in Malaysia: An overview and sustainability towards a developed nation. [pdf] Phnom Penh, Cambodia: Parliamentary Institute of Cambodia (PIC), Available at: https://pic.org.kh/images/2017Research/20170523%20Education_Reform_Malaysia_Eng.pdf [Accessed 20 Nov. 2018].

៣៤. Than Tha Aung. (2019). CLM must prepare for 'Industry 4.0' [Online]. Bangkok, Thailand: Bangkok Post. Available at: https://www.bangkokpost.com/opinion/opinion/1648420/clm-must-prepare-for-industry-4-0 [Accessed 28 Mar. 2019].

៣៥. International Monetary Fund. (2018). Regional economic outlook Asia and Pacific. Available at: https://www.imf.org/en/Publications/REO/APAC/Issues/2018/04/16/areo0509 [Accessed 19 Mar. 2019].

៣៦. Malaysian Global Innovation and Creativity Centre (MAGIC) (2017). ASEAN Start-up Landscape, Policy Roundtable, GECS 2017 December 13, 2017. Available at: https://s3-ap-southeast-1.amazonaws.com/mymagic-misc/ASEAN+Startup+Landscape.pdf

៣៧. Association of Southeast Asian Nations. (n.d). ASEAN Free Trade Area (AFTA Council). Available at: https://asean.org/asean-economic-community/asean-free-trade-area-afta-council/ [Accessed 21 Mar. 2019].

៣៨. Eijas, A. (2018). Financing ASEAN's infrastructure demand [Online]. The ASEAN Post. Available at: https://theaseanpost.com/article/financing-aseans-infrastructure-demand [Accessed 13 Feb. 2019].

៣៩. ADB. (2017). Meeting Asia's Infrastructure Needs. Philippines: ADB, Available at: https://www.adb.org/publications/asia-infrastructure-needs [Accessed 18 Feb. 2019].

៤០. Zhuang, B. (2017). Spotlight: China-Myanmar oil, gas project benfits both [Online]. China: Xinhua Net. Available at: http://www.xinhuanet.com/english/2017-05/10/c_136272395.htm [Accessed 17 Feb. 2019].

៤១. Jane, L. (2019). Feature: Thailand strives to connect Belt and Road Initiative with its Eastern Economic Corridor [Online]. China: Xinhua Net. Available at: http://www.xinhuanet.com/english/2019-01/22/c_137765246.htm [Accessed 17 Feb. 2019].

៤២. Hou, Q. (2017). Construction of Thailand-China railway project to start in 2017: official [Online]. China: Xinhua Net. Available at: http://www.xinhuanet.com//english/2017-05/17/c_136291277.htm [Accessed 17 Feb. 2019].

៤៣. Jiaxin. (2018). Malaysia calls tender for KL-Singapore high speed rail final survey consultants [Online]. China: Xinhua Net,. Available at: http://www.xinhuanet.com/english/2018-03/07/c_137022039.htm [Accessed 17 Feb. 2019].

៤៤. Yamei. (2017). Belt and Road connect platform launched at Singapore Regional Business Forum 2017[Online]. China: Xinhua Net. Available at: http://www.xinhuanet.com//english/2017-08/15/c_136527627.htm[Accessed 17 Feb. 2019].

៤៥. ASEAN Single Window. (2019). What is the ASEAN Single Window? [Online]. ASEAN Single Window. Available at: http://asw.asean.org/component/content/?view=featured [Accessed 17 Feb. 2019].

៤៦. IRASEC (2018). L'Asie du Sud-Est 2018: Bilan, enjeux et perspectives., Bangkok, Thailand, IRASEC, pp. 471-479.

៤៧. SÉNAT. (2014). Rapport D information Fait au nom de la commission des affaires étrangères, de la défense et des forces armées , Paris: Par le groupe de travail sur la France face à l'émergence de l'Asie du Sud-Est.

៤៨. Association of Southeast Asian Nations. (2018). ASEAN Economic Integration Brief. [online] Jakarta, Indonesia: ASEAN, Available at: https://asean.org/storage/2018/11/AEIB_4th-Issue_r1.pdf [Accessed 23 May. 2019].

៤៩. ASEAN Secretariat. (2018). ASEAN Key Figures 2018. [online] Jakarta, Indonesia: ASEAN, Available at: https://asean.org/?static_post=asean-key-figures-2018 [Accessed 23 May. 2019].

៥០. World Bank. (2019). Managing Headwinds [Online]. Washington, DC: World Bank. Available at: https://openknowledge.worldbank.org/handle/10986/31500 [Accessed 23 May. 2019].

៥១. Asian Development Bank Institute (ADBI). (2014). ASEAN 2030 towards a borderless economic community. Tokyo, Japan: ADBI, Available at: https://espas.secure.europarl.europa.eu/orbis/sites/ default/files/generated/document/en/adbi-asean-2030-borderless-economic-community.pdf [Accessed 25 May. 2019].

៥២. Wijeratne, D. (2018). The future of ASEAN time to act. [online] PWC, Available at: https://www.pwc. com/gx/en/growth-markets-centre/publications/assets/pwc-gmc-the-future-of-asean-time-to-act. pdf [Accessed 25 May. 2019].

៥៣. IRENA. (2019). Global energy transformation: A roadmap to 2050 (2019 edition). Abu Dhabi: International Renewable Energy Agency.

៥៤. UNSCAP. (2018). Asia-Pacific progress in sustainable energy: A global tracking framework 2017 regional assessment report. Bangkok: UNSCAP.

៥៥. UNDESA. (2012). A guidebook to the Green Economy. [online] UNDESA, Available at: https://sustainabledevelopment.un.org/content/documents/GE%20Guidebook.pdf#page=6&zoom=auto,-83,128 [Accessed 23 May. 2019].

៥៦. ASEAN Centre for Energy. (2015). ASEAN Plan of Action for Energy Cooperation (APAEC) 2016-2025: Phase I: 2016-2020. [online] ASEAN Centre for Energy, Available at: http://www.aseanenergy.org/ resources/publications/asean-plan-of-action-for-energy-cooperation-apaec-2016-2025/ [Accessed 24 May. 2019].

៥៧. PWC.(2018). The Future of ASEAN Time of Act. [online, PwC Growth Market Centers], Available at: https://www.pwc.com/sg/en/publications/assets/healthcare-future-asean-2018.pdf[Accessed 29 Dec. 2019]

៥៨. ASEAN. (2019). Investment in Southeast Asian Nations 2019/2020. [online], Available at: https://asean.org/storage/2019/10/Investing_in_ASEAN_2019_2020.pdf [Accessed 29 Dec. 2019]

៥៩. UN ESCAP. (2017). Southeast Asia Subregion Challenges and Priorities for SDG Implementation. [online, UNs], Aviable at: https://www.unescap.org/sites/default/files/Southeast%20Asia%20Subregion%20Challenges%20and%20Priorities%20for%20SDG%20Implementation%202017.pdf

៦០. ASEAN. (2019). ASEAN Declaration on Industrial Transformation to Industry 4.0 [online, ASEAN Thailand, Advance Partnership for Sustainability], Available at: https://www.asean2019.go.th/en/news/asean-declaration-on-industrial-transformation-to-industry-4-0/

៦១. World Bank. (2019). The Digital Economy in Southeast Asia: Strengthening the Foundations for Future Growth. World Bank, Washington, D.C. [online], Available at: http://documents.worldbank.org/curated/en/328941558708267736/pdf/The-Digital-Economy-in-Southeast-Asia-Strengthening-the-Foundations-for-Future-Growth.pdf

៦២. ASEAN Secretariat. (2019). ASEAN Integration Report. [online], Available at: https://asean.org/storage/2019/11/ASEAN-integration-report-2019.pdf [Accessed 15 Jan. 2020]

៦៣. Jason, T. (2019). Strengthening ASEAN's digital economy [Online]. The ASEAN Post. Available at: https://theaseanpost.com/article/strengthening-aseans-digital-economy [Accessed 2 Jan. 2020].

៦៤. Hootsuite & We Are Social. (2019). "Digital 2019 Global Digital Overview" [Online]. DataReportal.com, Available at: https://datareportal.com/reports/digital-2019-global-digital-overview [Accessed 01 Jan. 2020]

៦៥. World Bank. (2020). Doing Business 2020: Comparing Business Regulation in 190 Economies. Washington, DC: World Bank. Available at: https://openknowledge.worldbank.org/bitstream/handle/10986/32436/9781464814402.pdf [ Accessed 29 Dec. 2019]

៦៦. Inguirer.net. (2019). Building an Inclusive Digital ASEAN by 2040 [online]. Available at: https://opinion.inquirer.net/123839/building-an-inclusive-digital-asean-by-2040 [Accessed 15 Jan. 2020]

៦៧. OECD/ADB. (2019). Government at a Glance Southeast Asia 2019, OECD Publishing, Paris.

៦៨. International Energy Agency. (2017). Southeast Asia Energy Outlook 2017 [online]. Available at: https://iea.blob.core.windows.net/assets/88a6b01e-5e42-4105-b7de-7099cd18ec4b/WEO2017SpecialReportSoutheastAsiaEnergyOutlookExecutiveSummaryEnglish.pdf

៦៩. IEA. (2019). Southeast Asia Energy Outlook 2019 [Online] Available at: https://www.iea.org/reports/southeast-asia-energy-outlook-2019. [Accessed 15 Jan. 2019]

៧០. Andrews-Speed P., and Singh H. V. (2018). How to power a bright future for ASEAN [online]. World Economic Forum, Available at: https://www.weforum.org/agenda/2018/09/developing-a-shared-vision-for-aseans-energy-transition [Accessed 15 Jan. 2020]

៧១. ERIA and OECD, (2014). ASEAN SME Policy Index 2014, Towards Competitive and Innovative ASEAN SMEs. Jakarta, Available at: https://www.oecd.org/southeast-asia/ASEAN%20SME%20Policy%20Index%2014.pdf [Accessed 24 May 2019].

៧២. ASEAN Secretariat. (2018). ASEAN Commemorates Micro, Small and Medium-sized Enterprises Day [Online]. ASEAN Secretariat, Jakarta Available at: https://asean.org/asean-economic-community/sectoral-bodies-under-the-purview-of-aem/micro-small-and-medium-enterprises/international-msme-day/ [Accessed 24 May 2019 2019].

៧៣. OECD/ERIA, (2018). SME Policy Index: ASEAN 2018: Boosting Competitiveness and Inclusive Growth. OECD Publishing, Paris/Economic Research Institute for ASEAN and East Asia, Jakarta. Available at: https://doi.org/10.1787/9789264305328-en

៧៤. ACCA, (2016). SMEs development in ASEAN. The Association of Chartered Certified Accountants, United Kingdom. Available at: https://www.accaglobal.com/content/dam/ACCA_Global/Technical/smb/pi-sme-development-asean.pdf.

៧៥. OECD/ERIA, (2018). SME Policy Index ASEAN 2018: Boosting Competitiveness and Inclusive Growth, Brochure. OECD Publishing, Paris/Economic Research Institute for ASEAN and East Asia, Jakarta.: O. f. E. C.-o. a. Development, Available at: http://www.oecd.org/southeast-asia/ASEAN-SMEPI-2018-brochure.pdf [Accessed 18 April 2019].

៧៦. ASEAN Secretariat, (2015). ASEAN Strategic Action Plan for SME Development 2016-2025. ASEAN Secretariat, Jakarta, Available at: https://asean.org/wp-content/uploads/2012/05/3-SAP-SMED-Final.pdf [Accessed 18 April 2019].

៧៧. ADB, W. E. F., (2017). What does the Fourth Industrial Revolution mean for regional economic integration? Phillippines: ADB, Available at: https://www.adb.org/sites/default/files/publication/379401/asean-fourth-industrial-revolution-rci.pdf [Accessed 24/05/2019].

៧៨. Stiglitz, J. (2017). The coming great transformation. Journal of Policy Modeling 39:625–638, 625-638. Available at: https://www8.gsb.columbia.edu/faculty/jstiglitz/sites/jstiglitz/files/The%20Coming%20Great%20Transformation%20Final.pdf [Accessed 31/05/2019].

៧៩. Jae-Hee Chang andPhu Huynh, (2016). ASEAN in transformation. Geneva: I. R. O. f. Asia andPacific a. t., Available at: https://www.ilo.org/wcmsp5/groups/public/---ed_dialogue/---act_emp/documents/publication/wcms_579554.pdf [Accessed 31/05/2019].

៨០. Fratocchi, L. (2017). Is 3D Printing an Enabling Technology for Manufacturing Reshoring?

៨១. Chris Baraniuk. (2018). How talking machines are taking call centre jobs [Online]. BBC. Available at: https://www.bbc.com/news/business-45272835 [Accessed 31/05 2019]?

៨២. Kearney, A. (2015). The ASEAN Digital Revolution.

៨៣. World Economic Forum. (2018). Readiness for the Future of Production Report 2018. Geneva: World Economic Forum.

៨៤. The WORLD BANK Washingto, D. C., (2010). Innovation PolicyA Guide for DevelopingCountries. T. W. Bank, Available at: https://openknowledge.worldbank.org/bitstream/handle/10986/2460/548930PUB0EPI11C10Dislosed061312010.pdf?sequence=1&isAllowed=y [Accessed 31/05/2019].

៨៥. ADB, (2017). What does the Fourth Industrial Revolution mean for regional economic integration? Manila, Philippines: A. D. Bank, Available at: https://www.adb.org/sites/default/files/publication/379401/asean-fourth-industrial-revolution-rci.pdf [Accessed 31/05/2019].

៨៦. Gunawan, A. andStoffers, J. (2017). Technology-based Business Model for Facing ASEAN Economic Community. 5(1), 2321-2802. Available at: https://irp-cdn.multiscreensite.com/153c3631/files/uploaded/Gunawan%20en%20Stoffers%202017.pdf [Accessed 24/05/2019].

៨៧. World Economic Forum, (2018). World Economic Forum on ASEAN Overview. Han Noi, Vietnam Available at: http://www3.weforum.org/docs/ASEAN18_Meeting_Overview.pdf [Accessed 24/05/2019].

៨៨. ERIA and OECD (2018). ASEAN 2018 SME Policy Index: Boosting Competitiveness and Inclusive Growth. OECD Publishing, Paris/Economic Research Institute for ASEAN and East Asia, Jakarta.

៨៩. UNESCAP (2017). Fostering Women's Entrepreneurship in ASEAN: Transforming Prospects, Transforming Societies. UNESCAP. Available at: https://www.unescap.org/sites/default/files/ESCAP-FWE-ASEAN-full_0.pdf

៩០. Anandan, R., Sipahimalani, R., Saini, S., Aryasomayajula, S., and Smittinet, W. (2018). E-conomy SEA 2018: Southeast Asia's internet economy hits an inflection point. Google & Temase. Available at: https://www.thinkwithgoogle.com/intl/en-apac/tools-resources/research-studies/e-conomy-sea-2018-southeast-asias-internet-economy-hits-inflection-point/

៩១. Xavier, S.R., Sidin, S.M., Guelich, U., and Nawangpalupi, C. (2016). Global Entrepreneurship Monitor ASEAN Regional Entrepreneurship Report 2015/2016. ASEAN Entrepreneurship: The Context, Impact and Opportunities for Women Entrepreneurs and Startups; Key Pivots for Growth and Sustainability. Kuala Lumpur: Universiti Tun Addul Razak.

៩២. Bosma, N. and Kelley, D. (2019). Global Entrepreneurship Monitor: 2018/2019 Global Report. Global Entrepreneurship Research Association (GERA). Available at: https://www.gemconsortium.org/report

៩៣. Herrington, M. and Kew, P. (2017). Global Entrepreneurship Monitor: 2016/2017 Global Report. Global Entrepreneurship Research Association (GERA). Available at: https://www.gemconsortium.org/report



ក្រុមប្រទេសដែលចូលរួមកិច្ចប្រជុំ ASEP ទាំង១០
ខែកញ្ញា ឆ្នាំ២០១៨ នៅទីក្រុងព្រុចសែល ប្រទេសបែលហ្សិក
Arnaud DEVILLERS / រក្សាសិទ្ធិ©សហភាពអឺរ៉ុបឆ្នាំ២០១៨

# កិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុប លើកទី១១ (ASEP 11)

ព្រះរាជាណាចក្រកម្ពុជាត្រូវបានជ្រើសរើសសម្រាប់ជាម្ចាស់ផ្ទះនៃកិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុប លើកទី១១ ។ មូលបទត្រូវបានជ្រើសរើសដោយប្រទេសជាម្ចាស់ផ្ទះគឺ “ការពង្រឹងភាពដៃគូសភា ដើម្បីសន្តិភាព និងការអភិវឌ្ឍប្រកបដោយចីរភាព”។ កាលបរិច្ឆេទនៃកិច្ចប្រជុំ ASEP លើកទី១១ ដំបូងបានកំណត់យកខែតុលា ឆ្នាំ២០២០ តែដោយសារផលប៉ះពាល់ពីការរីករាលដាលនៃកូវីដ ១៩ កិច្ចប្រជុំនេះត្រូវពន្យារពេលរហូតដល់ឆ្នាំ២០២១ ។

កិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុប (ASEP) ជាទូទៅរៀបចំរៀងរាល់ពីរឆ្នាំម្តង មុនពេលកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប (ASEM) ដោយផ្លាស់វេណគ្នារវាងអាស៊ី និងអឺរ៉ុប។ កិច្ចប្រជុំ ASEP គឺជាធាតុផ្សំដ៏សំខាន់ក្នុងដំណើរការភាពជាដៃគូអាស៊ី-អឺរ៉ុប។ កិច្ចប្រជុំនេះជួយលើកកម្ពស់យន្តការនៃការពិគ្រោះយោបល់គ្នា ជួយលើកកម្ពស់ការទូតរវាងសភា ជួយលើកកម្ពស់ការយោគយល់គ្នាទៅវិញទៅមករវាងប្រជាជាតិនៃប្រទេសនៅអាស៊ី និងអឺរ៉ុប ក៏ដូចជាផ្តល់នូវគំនិត និងសំណើនានាសម្រាប់កិច្ចប្រជុំ ASEM បន្ទាប់ពីកិច្ចប្រជុំ ASEP ។



# កម្មវិធីបណ្តុះបណ្តាលថ្នាក់តំបន់ស្តីពី ការទូតសភា

ក្នុងឆ្នាំ២០១៩ វិទ្យាស្ថានសភាកម្ពុជា (Parliamentary Institute of Cambodia) បានពង្រីកកម្មវិធីបណ្តុះបណ្តាលថ្នាក់ជាតិរបស់ខ្លួនស្តីពី ការទូតសភា ទៅជាកម្មវិធីថ្នាក់តំបន់។ ក្នុងអំឡុងពេលនៃវគ្គបណ្តុះបណ្តាលលើកដំបូង សិក្ខាកាមដែលមកពីប្រទេសជាសមាជិកទាំងប្រាំនៃអន្តរសភាអាស៊ាន (AIPA) បានទទួលនូវចំណេះដឹង និងជំនាញ ដើម្បីជួយសភារបស់ពួកគេត្រៀមខ្លួនក្នុងការចូលរួមឲ្យបានកាន់តែសកម្មក្នុងការងារសំខាន់ៗដែលកាន់តែកើនឡើងទាក់ទងនឹងការទូតសភា។

"យើងទទួលបានការបណ្តុះបណ្តាលដើម្បីអភិវឌ្ឍសមត្ថភាពក្នុងការគិតបែបស៊ីជម្រៅ ដោយមិនត្រឹមតែគិតក្នុងបរិបទប្រទេសមួយទេ ប៉ុន្តែជាការគិតក្នុងបរិបទតំបន់ និងពិភពលោក។

យើងប្រហែលជាអាចមានភាពខុសគ្នាទៅលើភាសា សញ្ជាតិ និងសាសនា ប៉ុន្តែជាក់ស្តែងអ្វីដែលយើងចង់បានគឺដូចគ្នា ហើយក៏ចង់សម្រេចគោលដៅរួមមួយដូចគ្នាផងដែរ។

**Zulfa Amirah binti Jubri,**
**ប្រទេសម៉ាឡេស៊ី**"

"«ខ្ញុំទទួលបានទាំងចំណេះដឹង និងជំនាញ...ដើម្បីគាំទ្រយ៉ាងពេញទំហឹងដល់គោលការណ៍របស់ខ្ញុំក្នុងការសម្រេចបាន ... ការសម្រុះសម្រួលភាពខុសគ្នា និងការកសាងភាពជាដៃគូក្នុងតំបន់ និងពិភពលោក។

ពាក្យគន្លឹះបួនដែលគូសបញ្ជាក់អំពីបទពិសោធន៍ការងារការទូតរបស់ខ្ញុំគឺ៖ បរិបទ ទស្សនៈវិស័យ ការចរចា និងការមូលមតិគ្នាទាំងស្រុង។

**Aline Ruth Vidal-Villaluz,**
**ប្រទេសហ្វីលីពីន**"

ការបណ្តុះបណ្តាលរយៈពេល៦ខែ បានបញ្ចប់តាមរយៈការអនុវត្តត្រាប់តាមកិច្ចប្រជុំអន្តរជាតិមួយ ដោយយកគំរូតាមកិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុបលើកទី១១ (the 11th Asia-Europe Parliamentary Partnership Meeting)។ ក្នុងអំឡុងពេលការអនុវត្តត្រាប់តាម សិក្ខាកាមដែលសម្តែងជាតំណាងឲ្យបណ្តាប្រទេសមកពីអាស៊ី និងអឺរ៉ុបបានឈានដល់ការសម្រេចជាឯកច្ឆ័នមួយលើបញ្ហាជាច្រើន រួមបញ្ចូលទាំងបញ្ហាដែលបង្ហាញខាងក្រោម។





លំហាត់ត្រាប់តាម
ចេសហ្វ្រី កូល



ពិធីប្រគល់វិញ្ញាបនប័ត្រសម្រាប់កម្មវិធីអាហារូបករណ៍ក្នុងតំបន់របស់ PIC អំពីការទូតសភា
ឡឹង វណ្ណា

## គំរូនៃសេចក្តីសម្រេចចុងក្រោយពីលំហាត់ត្រាប់តាម

សមាជិក សមាជិកាសភាទទួលស្គាល់ពីសារៈសំខាន់ខ្លាំងរបស់អាហារ ទឹក និងថាមពលសម្រាប់ការអភិវឌ្ឍ ព្រមទាំងដាក់ជាឯកច្ឆ័នក្នុងការផ្តល់នូវឆន្ទៈនយោបាយ ដើម្បីលើកកម្ពស់ការអភិវឌ្ឍថាមពលកើតឡើងវិញ ដោយការកំណត់គោលនយោបាយដែលអាចអនុវត្តបាន។ គោលនយោបាយទាំងនេះរួមមានការលើកទឹកចិត្តសារពើពន្ធរយៈពេលវែង និងក្របខ័ណ្ឌបទបញ្ញត្តិប្រកបដោយតម្លាភាព ក៏ដូចជាការបែងចែកថវិកាឲ្យមានស្ថិរភាព និងបានគ្រប់គ្រាន់ ដើម្បីធានាដល់ការវិនិយោគដែលចាំបាច់។

ប្រទេសចូលរួមទាំងអស់គូសបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តរួមគ្នា ដូច្នេះហើយកិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុប អំពាវនាវឲ្យសហរដ្ឋអាម៉េរិកត្រឡប់ទៅអនុវត្តកិច្ចព្រមព្រៀងទីក្រុងប៉ារីសឡើងវិញ។ កិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុបគួរតែចែករំលែក និងផ្ទេរនូវបច្ចេកវិទ្យាក្នុងចំណោមប្រទេសសមាជិក ក៏ដូចជាផ្តល់ជំនាញ ការបណ្តុះបណ្តាលជំនួយព្រមទាំងការស្រាវជ្រាវ និងការអភិវឌ្ឍដល់បណ្តាប្រទេសដែលត្រូវការជំនួយ។ សមាជិកសមាជិកាសភាទាំងអស់ប្តេជ្ញាចិត្តទប់ស្កាត់ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដើម្បីឈានទៅសម្រេចគោលដៅនៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់«កម្រិតសូន្យ» ក្នុងឆ្នាំ២០៥០ ។

កិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុបនឹងរៀបចំគណៈកម្មាធិការស្រាវជ្រាវមួយស្តីពី ស្វ័យភាពយុទ្ធសាស្ត្រអាស៊ី-អឺរ៉ុប (Asia-Europe Strategic Autonomy) ដែលមានសមាជិកចំនួនដប់មកពីបណ្តាប្រទេសអាស៊ី និងអឺរ៉ុប ដែលនឹងធ្វើការអនុវត្តការស្រាវជ្រាវ ការសិក្សា ការប្រមូលទិន្នន័យ និងភ្ជាប់ទំនាក់ទំនងជាមួយអ្នកជំនាញសម្រាប់លទ្ធភាពនៃភាពជាដៃគូនេះ ជាពិសេសលើទំនាក់ទំនងសេដ្ឋកិច្ច និងពាណិជ្ជកម្ម ។ ក្រុមនេះនឹងផ្តល់របាយការណ៍ទៅកិច្ចប្រជុំពេញអង្គនៃភាពជាដៃគូសភាអាស៊ី-អឺរ៉ុបលើកទី១២ ។

តាមរយៈកម្មវិធីបណ្តុះបណ្តាលថ្នាក់តំបន់ស្តីពី ការទូតសភា វិទ្យាស្ថានសភាកម្ពុជា និងដៃគូទាំងអស់ជឿជាក់ថា កម្មវិធីបណ្តុះបណ្តាលនេះមិនត្រឹមតែជួយបង្កើនសមត្ថភាពសិក្ខាកាមដើម្បីជួយដល់សភារបស់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែក៏ផ្តល់ឲ្យសិក្ខាកាមទាំងអស់នូវឧបករណ៍ចាំបាច់ដើម្បីក្លាយជាអ្នកកសាងសន្តិភាព និងកិច្ចសហប្រតិបត្តិការក្នុងតំបន់អាស៊ាន និងតំបន់ដទៃទៀតនាថ្ងៃអនាគតផងដែរ។

# អក្សរកាត់

| | |
|---|---|
| **4IR** | Fourth Industrial Revolution |
| **ACAP** | ASEAN Competition Action Plan |
| **ADB** | Asia Development Bank |
| **ADMM** | ASEAN Defense Minister's Meeting |
| **ADSOM** | ASEAN Defense Senior Officials' Meetings |
| **AFPPD** | Asian Forum for Parliamentarians on Population and Development |
| **AFTA** | ASEAN Free Trade Area |
| **AI** | artificial intelligence |
| **AIIB** | Asian Infrastructure Investment Bank |
| **AIPA** | ASEAN Inter-Parliamentary Assembly |
| **AIPO** | ASEAN Inter-Parliamentary Organization |
| **ALDE** | Alliance of Liberals and Democrats for Europe |
| **AMECS** | Ayeyawady - Chao Pharaya Mekong Economic Cooperation Strategy |
| **AMS** | ASEAN Member States |
| **APA** | Asian Parliamentary Assembly |
| **APF** | Asia Pacific Forum |
| **APPF** | Asia Pacific Parliamentary Forum |
| **APSC** | ASEAN Political-Security Community |
| **APF** | Assemblée Parlementaire de la Francophonie |
| **APT** | ASEAN Plus Three |
| **ARF** | ASEAN Regional Forum |
| **ASCC** | ASEAN Socio-Cultural Community |
| **ASCF** | ASEAN Smart City Framework |
| **ASCN** | ASEAN Smart Cities Network |
| **ASEAN** | Association of Southeast Asian Nations |
| **ASEM** | Asia-Europe Meeting |
| **ASEP** | Asia-Europe Parliamentary Partnership Meeting |
| **AVI** | Asian Vision Institute |
| **AWGNCB** | ASEAN Working Group on Nature Conservation and Biodiversity |
| **AWGWRM** | ASEAN Working Group on Water Resources Management |
| **BRI** | Belt and Road Initiative |
| **BRIC** | Brazil, Russia, India and China |
| **CEMAC** | Economic and Monetary Community of Central Africa |
| **CLM** | Cambodia, Lao PDR and Myanmar |
| **CLMV** | Cambodia, Lao PDR, Myanmar and Vietnam |

| | |
|---|---|
| **COMESA** | Common Market for Eastern and Southern Africa |
| **COP** | code of practice |
| **COP** | Conference of the Parties (UN Climate Change Conference) |
| **CPA** | Commonwealth Parliamentary Association |
| **CPC** | Commonwealth Parliamentary Conference |
| **CPTPP** | Comprehensive and Progressive Agreement for Trans-Pacific Partnership |
| **CWPC** | Cambodian Women Parliamentarians Caucus |
| **DDA** | Doha Development Agenda |
| **DSS** | World Trade Organization Dispute Settlement System |
| **EAS** | East Asia Summit |
| **EBA** | Everything but Arms |
| **ECOWAS** | Economic Community of West African States |
| **EE&C** | energy efficiency and conservation |
| **EEC** | European Economic Community |
| **EEZ** | Exclusive Economic Zone |
| **EGD** | European Green Deal |
| **EU** | European Union |
| **EP** | European Parliament |
| **EPBD** | Energy Performance in Buildings Directive |
| **EWG** | Expert Working Group |
| **FACT** | PIC Fiscal Analysis Capacity Training |
| **FAO** | United Nations Food and Agriculture Organization |
| **FDI** | foreign direct investment |
| **FTA** | free trade agreement |
| **GATT** | General Agreement on Tariffs and Trade |
| **GDP** | gross domestic product |
| **GEI** | Global Entrepreneurship Index |
| **GEM** | Global Entrepreneurship Monitor |
| **GHG** | greenhouse gas |
| **GIEC** | Groupe d'experts intergouvernemental sur l'évolution du climat |
| **GII** | Gender Equality Index |
| **GMV** | gross merchandise value |
| **GSP** | General System of Preferences |
| **HLPF** | High Level Political Forum for Sustainable Development |
| **HDI** | Human Development Index |
| **ICAO** | International Civil Aviation Organization |
| **ICPD PoA** | Programme of Action of the International Conference on Population and Development |

| | |
|---|---|
| **ICT** | information and communications technology |
| **IoT** | Internet of Things |
| **IMD** | International Institute for Management Development |
| **IMF** | International Monetary Fund |
| **IORA** | Indian Ocean Rim Association |
| **IPCC** | International Panel on Climate Change |
| **IPU** | Inter-Parliamentary Union |
| **IRASEC** | Institute for Research on Contemporary Southeast Asia |
| **ITTO** | International Tropical Timber Organization |
| **KIT** | Kirirom Institute of Technology |
| **MBps** | megabytes per second |
| **MEP** | Member of the European Parliament |
| **MEP** | marine environmental protection |
| **MERCOSUR** | Southern Common Market, a South American trade bloc with Argentina, Brazil, Paraguay and Uruguay as full members |
| **MEWR** | Singapore Ministry of the Environment and Water Resources |
| **MFF** | Multiannual Financial Framework |
| **MIT** | Massachusetts Institute of Technology |
| **MoWA** | Cambodian Ministry of Women's Affairs |
| **MPAC** | Master Plan on ASEAN Connectivity |
| **MTJA** | Malaysia-Thailand Joint Authority |
| **NAFTA/USMCA** | North American Free Trade Agreement / United States–Mexico–Canada Agreement |
| **NCOP** | Thailand National Council for Peace and Order |
| **NECP** | National Energy and Climate Plan |
| **NEEAP** | National Energy Efficiency Action Plan |
| **NGO** | Non-Governmental Organization |
| **OECD** | Organization for Economic Cooperation and Development |
| **PAF** | Parliamentary Assembly of la Francophonie |
| **PAP** | Pan-African Parliament |
| **PCAsia** | Parliamentary Centre of Asia |
| **PIC** | Parliamentary Institute of Cambodia |
| **PISA** | Programme for International Student Assessment |
| **RCEP** | Regional Comprehensive Economic Partnership |
| **RE** | renewable energy |
| **PRC** | People's Republic of China |
| **SADC** | Southern African Development Community |
| **SBF** | Singapore Business Federation |

| | |
|---|---|
| **SCW** | Save Cambodia's Wildlife |
| **SDC** | Swiss Agency for Development and Cooperation |
| **SDGs** | United Nations Sustainable Development Goals |
| **SFA** | Singapore Food Agency |
| **SFM** | Sustainable Forest Management |
| **Sida** | Swedish International Development Cooperation Agency |
| **SKRL** | Singapore-Kunming Rail Link |
| **SME** | small and medium enterprise |
| **SOP** | standard operating procedures |
| **TPP** | Trans-Pacific Partnership |
| **TTIP** | Transatlantic Trade and Investment Partnership |
| **UN** | United Nations |
| **UNCLOS** | United Nations Convention of the Law of the Sea |
| **UNDRR** | United Nations Office for Disaster Risk Reduction |
| **UNESCO** | United Nations Educational, Scientific and Cultural Organization |
| **UNDP** | United Nations Development Programme |
| **UNEP** | United Nations Environment Programme |
| **UNSC** | United Nations Security Council |
| **UNSDGs** | United Nations Sustainable Development Goals |
| **VNR** | voluntary national review |
| **WAEMU** | West African Economic and Monetary Union |
| **WEF** | World Economic Forum |
| **WPFSD** | World Parliamentary Forum on Sustainable Development |
| **WB** | World Bank |
| **WHO** | World Health Organization |
| **WTO** | World Trade Organization |

# និពន្ធនាយក

**មីហៀល ហួសហៀ**

អ្នកភូមិសាស្ត្រ អ្នកការទូត អតីតឯកអគ្គរដ្ឋទូត និងថ្មីៗនេះជាទីប្រឹក្សាគណៈកម្មការអឺរ៉ុបទទួលបន្ទុកសមាហរណកម្មតំបន់អាស៊ីខាងត្បូងនិងអាស៊ីអាគ្នេយ៍ និងបច្ចុប្បន្នលោកកាន់តំណែងជាប្រធានផ្នែកភូមិសាស្ត្រនយោបាយអនុវត្ត នៅមហាវិទ្យាល័យការសិក្សាសកល (College of World Studies) (FMSH, ទីក្រុងប៉ារីស) និងជានាយកកម្មវិធីការទូតសភា នៅវិទ្យាស្ថានសភាកម្ពុជា។

# អ្នកចូលរួម

**អត្ថបទ**

**លោក ហ៊ីរ៉ូយូគី អាឌី រ៉ាំងតួរ**

អ្នកជំនាញផ្នែកកិច្ចសហប្រតិបត្តិការអន្តរសភា ច្បាប់ និងអភិបាលកិច្ច និងកំពុងបម្រើការងារជាមន្ត្រីកម្មវិធីជាន់ខ្ពស់របស់អង្គការពិភពលោកនៃសមាជិកសភាប្រឆាំងនឹងអំពើពុករលួយ និងជាមួយគណៈកម្មាធិការសភាឥណ្ឌូនេស៊ីសម្រាប់កិច្ចសហប្រតិបត្តិការអន្តរសភា។

**លោក ស្អុត ខេមរិន**

ទីប្រឹក្សា-អ្នកវិភាគសេដ្ឋកិច្ច នៅការិយាល័យថវិកាសភានៃសភាកាណាដា និងពីមុនលោកជាគ្រូបណ្តុះបណ្តាលជាន់ខ្ពស់ទទួលបន្ទុកកម្មវិធីបណ្តុះបណ្តាលសមត្ថភាពវិភាគសារពើពន្ធនៃវិទ្យាស្ថានសភាកម្ពុជា ដែលផ្តល់ការហ្វឹកហ្វឺនលើប្រធានបទជាច្រើនទាក់ទងនឹងថវិកានិងសារពើពន្ធ។

**លោកស្រី ជា ម៉ាលីកា**

អតីតអ្នកសម្របសម្រួលកម្មវិធីបណ្តុះបណ្តាលសមត្ថភាពវិភាគសារពើពន្ធនៃវិទ្យាស្ថានសភាកម្ពុជា និងបច្ចុប្បន្នលោកស្រីទទួលខុសត្រូវលើការរៀបចំកម្មវិធីបណ្តុះបណ្តាលជាមួយអ្នកជំនាញ និងសិក្ខាកាមនៅក្នុងសភា។

**កញ្ញា ជា សិរីរតន៍**

បម្រើការងារជាមន្ត្រីនៅនាយកដ្ឋានស្រាវជ្រាវថវិកានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាកម្ពុជា។

**បណ្ឌិត ឈាង វណ្ណារិទ្ធ**

អ្នកវិភាគសេដ្ឋកិច្ចនយោបាយ ភូមិសាស្ត្រនយោបាយ និងគោលនយោបាយសាធារណៈ ដែលបច្ចុប្បន្នកាន់តំណែងជាប្រធានវិទ្យាស្ថានចក្ខុវិស័យអាស៊ី (Asian Vision Institute) ប្រធានក្រុមប្រឹក្សាផ្តល់យោបល់នៃរដ្ឋសភាកម្ពុជា ទីប្រឹក្សាក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សមាជិកក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានបច្ចេកវិទ្យាគីរីរម្យ (Kirirom Institute of Technology) និងជាសាស្ត្រាចារ្យក្រៅម៉ោងនៅសាលាវិទ្យាសាស្ត្រសង្គមនៃសាកលវិទ្យាល័យបច្ចេកវិទ្យាណានយ៉ាង (Nanyang Technological University)។

**បណ្ឌិត ឈីវ យីស៊ាង**

អតីតអនុព័ន្ធសារព័ត៌មាននិងជាអ្នកបកប្រែផ្ទាល់របស់ឯកអគ្គរដ្ឋទូតបារាំងប្រចាំនៅកម្ពុជា និងក្រោយមកឯកឧត្តមជាអនុប្រធានខុទ្ទកាល័យនាយករដ្ឋមន្ត្រី ហើយបច្ចុប្បន្នជាប្រធានវិទ្យាស្ថានជាតិការទូតនិងទំនាក់ទំនងអន្តរជាតិ នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ។

**លោក ឈុន ហាំ**

បម្រើការងារជាមន្ត្រីនៅនាយកដ្ឋានស្រាវជ្រាវថវិកានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាកម្ពុជា។

**បណ្ឌិត ឈួ ស្រ៊ីនាថ**

គ្រូបណ្ដុះបណ្ដាលនិងអ្នកស្រាវជ្រាវនៅវិទ្យាស្ថានសភាកម្ពុជា ហើយលោកស្រីបណ្ឌិតបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យណាកូយ៉ា (Nagoya University) ផ្នែកអភិវឌ្ឍន៍អន្តរជាតិ ជំនាញគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច និងការគ្រប់គ្រង។

**ហ្វ្រេដេរីក ហ្គ្រារេ**

សហការីអនិវាសនជនជាន់ខ្ពស់ក្នុងកម្មវិធី Carnegie's South Asia ដែលការងាររបស់លោកផ្ដោតលើបញ្ហាសន្តិសុខតំបន់អាស៊ីខាងត្បូង។ លោកក៏កាន់តំណែងជាប្រធានការិយាល័យអាស៊ីនៅនាយកដ្ឋានសម្រាប់កិច្ចការយុទ្ធសាស្ត្រក្នុងក្រសួងការពារជាតិបារាំង ក្នុងស្ថានទូតបារាំងប្រចាំនៅប៉ាគីស្ថាន ហើយចាប់ពីឆ្នាំ១៩៩៩ ដល់ឆ្នាំ២០០៣ ជានាយកនៃមជ្ឈមណ្ឌលសម្រាប់វិទ្យាសាស្ត្រសង្គមនិងមនុស្សសាស្ត្រនៅក្នុងទីក្រុងញូដេលី។

**លោក ហេង សន្យា**

មុនបម្រើការងារនៅវិទ្យាស្ថានសភាកម្ពុជា លោកជាសាស្ត្រាចារ្យផ្នែកវិទ្យាសាស្ត្រនយោបាយនិងស្ថាប័នអន្តរជាតិនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ហើយលោកបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកទំនាក់ទំនងអន្តរជាតិ ជាមួយនឹងជំនាញសន្តិសុខតំបន់និងអន្តរកម្មរវាងមហាអំណាចធំៗនៅក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក។

**បណ្ឌិត គឹម សុធន**

អតីតគ្រូបណ្ដុះបណ្ដាលស្រាវជ្រាវជាន់ខ្ពស់នៅវិទ្យាស្ថានសភាកម្ពុជា និងអតីតអ្នកស្រាវជ្រាវនៅវិទ្យាស្ថាន បណ្ដុះបណ្ដាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (Cambodia Development Resources Institute)។ កិច្ចការស្រាវជ្រាវរបស់លោកផ្ដោតលើការផ្លាស់ប្ដូរកសិកម្ម ការគ្រប់គ្រងធនធានធម្មជាតិ និងភាពក្រីក្រ។

**លោកស្រី គឹម កែវធីតា**

គ្រូបណ្ដុះបណ្ដាលស្រាវជ្រាវជាន់ខ្ពស់នៅវិទ្យាស្ថានសភាកម្ពុជា និងជាអ្នកជំនាញផ្នែកវិភាគយេនឌ័រ ហើយពីមុនលោកស្រីបានធ្វើការនៅក្រសួងកិច្ចការនារីជាមួយនឹងបទពិសោធន៍ធ្វើការលើគម្រោងជាច្រើនទាក់ទងនឹងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ស្ត្រីនៅទូទាំងប្រទេសកម្ពុជា។

**លោកស្រី គង់ គន្ធា**

ជាមួយនឹងសញ្ញាប័ត្រថ្នាក់អនុបណ្ឌិតផ្នែកអភិវឌ្ឍន៍អន្តរជាតិពីសាកលវិទ្យាល័យហ្វ្លីនដឺ (Flinders University) និងបន្ទាប់ពីមានបទពិសោធន៍ធ្វើការជាមួយនឹងសភាកម្ពុជាអស់រយៈពេល ១២ឆ្នាំ លោកស្រីបានចូលបម្រើការងារនៅវិទ្យាស្ថានសភាកម្ពុជា ដែលលោកស្រីមានតួនាទីសម្របសម្រួលជាមួយនឹងសភាជាសមាជិករបស់អន្តរសភាអាស៊ាន (AIPA) និងទទួលខុសត្រូវលើកិច្ចការទំនាក់ទំនងសភា។

**បណ្ឌិត លន់ ពេជ្រតារា**

ប្រធានផ្នែកបរិស្ថាននៅវិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា លោកបានទទួលសញ្ញាប័ត្របណ្ឌិតពីសាកលវិទ្យាល័យយូស៊្វ (Kyushu University) ដែលនៅទីនោះ លោកបានសិក្សាផ្នែកព្រៃឈើ និងការគ្រប់គ្រងធនធានព្រៃឈើ។

**បណ្ឌិត លី យ៉ាសាក់**

ជាអ្នកវិភាគស្ថិតិដែលមានបទពិសោធន៍ប្រើប្រាស់ការវិភាគបែបស្ថិតិលើបញ្ហាសេដ្ឋកិច្ច និងថវិកាសម្រាប់វិទ្យាស្ថានសភាកម្ពុជា លោកក៏ជាសាស្ត្រាចារ្យមុខវិជ្ជាអភិបាលកិច្ចនិងអភិវឌ្ឍន៍នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

**បណ្ឌិត ស្រ៊ីនីវ៉ាសា ម៉ាឌូ**

បច្ចុប្បន្នជាសាស្ត្រាចារ្យជាន់ខ្ពស់ក្រៅម៉ោងនៅសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជានៅក្នុងទីក្រុងភ្នំពេញ ហើយលោកជាអតីតនាយកជាន់ខ្ពស់នៅធនាគារអភិវឌ្ឍន៍អាស៊ីនៅក្នុងទីក្រុងម៉ានីល និង ជាអតីតនាយកស្រាវជ្រាវនៅវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ។

**បណ្ឌិត ឡុតហ្ស ម៉េហ្ស**

ជំនួយការសាស្ត្រាចារ្យជាន់ខ្ពស់ក្នុងដេប៉ាតឺម៉ង់វិទ្យាសាស្ត្រសង្គមនិងនយោបាយនៅសាកលវិទ្យាល័យប៊ែកឡាំង (Freie Universität Berlin) បានទទួលពានរង្វាន់ German Federal Cross of Merit ក្នុងឆ្នាំ២០១៦ សម្រាប់ភាពជោគជ័យផ្នែកវិទ្យាសាស្ត្ររបស់លោកទាក់ទងនឹងការផ្លាស់ប្តូរថាមពល និងការអភិវឌ្ឍគោលនយោបាយថាមពលប្រកបដោយចីរភាពនៅថ្នាក់សហព័ន្ធ តំបន់ និងសហភាពអឺរ៉ុប។

**បណ្ឌិត ម៉ាគឺស មូហ៍លីន**

បច្ចុប្បន្នជាជំនួយការសាស្ត្រាចារ្យក្នុងការសិក្សាពីសង្គ្រាមនិងជាមេបញ្ជាការកងទ័ពជើងទឹកភូមិន្ទស៊ុយអ៊ែត (Royal Swedish Navy)។ អតីតមន្ត្រីនាវាមុជទឹករូបនេះបានចំណាយពេលមួយទសវត្សរ៍ចុងក្រោយនេះក្នុងការបំពេញការងារមួយទៀតនៅសាកលវិទ្យាល័យការពារជាតិស៊ុយអ៊ែត (Swedish Defense University) ជាសាស្ត្រាចារ្យនិងអ្នកស្រាវជ្រាវផ្នែកការសិក្សាយុទ្ធសាស្ត្រ។ បណ្ឌិត Mohlin ក៏បានធ្វើការងារជាមួយអង្គការសហប្រជាជាតិនៅក្នុងប្រទេសអង់ហ្គោឡា និងជាមួយអង្គការសន្ធិសញ្ញាអាត្លង់ទិចខាងជើងក្នុងរដ្ឋបាល់កង់។

**លោក មូសារ អ៊ីស្សាម**

បច្ចុប្បន្ន លោកជាប្រធានផ្នែកស្រាវជ្រាវសភានៃវិទ្យាស្ថានសភាកម្ពុជា និងជាសាស្ត្រាចារ្យផ្នែកច្បាប់ ជាមួយនឹងបទសោធន៍បណ្តុះបណ្តាលមន្ត្រីនិងអ្នកកាសែតលើប្រធានបទច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិនិងការយល់ដឹងពីឧក្រិដ្ឋកម្មអន្តរជាតិ។

**ហ៊្សាវីយេ នូទីន**

ការីជាន់ខ្ពស់ និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានអឺរ៉ុបសម្រាប់ការសិក្សាអាស៊ី ដែលលោកមានបទពិសោធន៍ជាមន្ត្រីនៃសភាអឺរ៉ុបដោយធ្វើការក្នុងអគ្គនាយកដ្ឋានកិច្ចការខាងក្រៅ (Directorate General for External Affairs) នៃសភាអឺរ៉ុប ដែលគ្របដណ្តប់លើទ្វីបអាស៊ីក្នុងនាយកដ្ឋានគោលនយោបាយ និងផ្តល់ប្រឹក្សាដល់អង្គសភាដូចជាគណៈកម្មាធិការកិច្ចការបរទេស។

**បណ្ឌិត រតនា ពៅ នូប៊ីត មុនហ្ស៍**

អ្នកស្រាវជ្រាវគោលនយោបាយនៅសាកលវិទ្យាល័យ Utrecht និងជាអ្នករៀបរៀងវគ្គសិក្សាដំបូងគេបង្អស់ស្តីពីផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុនិងគោលនយោបាយ នៅវិទ្យាស្ថានសភាកម្ពុជាជាមួយនឹងបទពិសោធន៍ថ្មីៗស្តីពីការទូតសភាទាក់ទងនឹងអាកាសធាតុនិងច្បាប់នៅក្នុងប្រទេសសមាជិកអាស៊ាន។

**លោក អូថារ៉ាំ ភីរីយ៉ូសាមី**

ត្រូវបានស្គាល់ថា P O Ram ដែលពីមុនលោកបានបម្រើការងារជាអគ្គលេខាធិការនៃសភាសិង្ហបុរីនិងជាលេខានៃក្រុមប្រឹក្សាប្រធានាធិបតីសម្រាប់សិទ្ធិជនជាតិភាគតិច (Presidential Council for Minority Rights) ហើយក្រោយមកត្រូវបានតែងតាំងជាអគ្គលេខានៃអន្តរសភាអាស៊ាន។

**អង់ទាន់ ភីរីឡាត ឆាលឡាហ្ស៍**

លោកបានសិក្សាផ្នែកនយោបាយ សេដ្ឋកិច្ច និងប្រវត្តិសាស្ត្រនៅវិទ្យាស្ថានការសិក្សានយោបាយ (Science Po) នៃទីក្រុង Aix-en-Provence និងច្បាប់នៅសាកលវិទ្យាល័យ La Sorbonne Paris 1 និងកំពុងសរសេរសារណាទាក់ទងនឹងអាស៊ានដែលជាផ្នែកមួយនៃការសិក្សារបស់លោកនិងការចុះកម្មសិក្សារយៈពេលបួនខែជាមួយនឹងវិទ្យាស្ថានសភាកម្ពុជា។

**ឯកអគ្គរាជទូត ពូ សុធីរៈ**

បច្ចុប្បន្នជានាយកប្រតិបត្តិនៃវិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការនិងសន្តិភាព និងជាទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា ហើយពីមុនលោកកាន់តំណែងជារដ្ឋលេខាធិការនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ហើយក៏ជាឯកអគ្គរាជទូតកម្ពុជាប្រចាំនៅប្រទេសជប៉ុន និងបានជាប់ឆ្នោតជាសមាជិកសភាកម្ពុជាចំនួនពីរអាណត្តិ ព្រមទាំងជាអតីតរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

**សូ សុវណ្ណារិទ្ធិ**

ប្រធានគ្រប់គ្រងផ្នែកអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវសភានៅវិទ្យាស្ថានសភាកម្ពុជា ជាមួយនឹងបទពិសោធន៍ជាច្រើនលើការរៀបចំវគ្គបណ្តុះបណ្តាលសម្រាប់ការស្រាវជ្រាវគោលនយោបាយ និងបានសរសេរប្រធានបទផ្សេងៗជាច្រើនដែលរួមមានការអភិវឌ្ឍជនបទ ការកាត់បន្ថយភាពក្រីក្រ និងការគ្រប់គ្រងធនធានធម្មជាតិ។

**ឯកអគ្គរដ្ឋទូត តាំង យុក ចូវ**

អតីតឯកអគ្គរដ្ឋទូតនៃសាធារណៈរដ្ឋសិង្ហបុរីប្រចាំនៅសាធារណៈរដ្ឋបារាំងនិងព័រទុយហ្គាល់ លោកកាន់តំណែងជាតំណាងអចិន្ត្រៃយ៍នៃប្រទេសរបស់លោកនៅអង្គការសហប្រជាជាតិក្នុងទីក្រុងហ្សឺណែវនិងជាតំណាងអចិន្ត្រៃយ៍របស់សិង្ហបុរីនៅទីភ្នាក់ងារថាមពលអាតូមិកអន្តរជាតិ ក្នុងទីក្រុងវីយែន។ មុននេះទៀតលោកបានធ្វើការនៅក្រសួងការពារជាតិ និងក្រសួងការបរទេសរបស់សិង្ហបុរី។

**លោក វត្តាវង្ស វឌ្ឍនៈ**

មន្ត្រីនៅនាយកដ្ឋានស្រាវជ្រាវវិចារណ៍នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាកម្ពុជា។

**ដេវី អាមីលៀ ត្រេស្នា វីចាយ៉ានទី**

ជាមួយនឹងសញ្ញាប័ត្រថ្នាក់អនុបណ្ឌិតផ្នែកសិក្សាការអភិវឌ្ឍពីសាកលវិទ្យាល័យមែលប៊ន លោកស្រីធ្វើការស្រាវជ្រាវពីទំនាក់ទំនងអន្តរសភា និងបញ្ហាប្រឈមទាក់ទងនឹងទំនាក់ទំនងអន្តរជាតិក្នុងតួនាទីរបស់លោកស្រីជាទីប្រឹក្សារបស់គណៈកម្មាធិការសម្រាប់កិច្ចសហប្រតិបត្តិការអន្តរសភា នៃសភាតំណាងឥណ្ឌូនេស៊ី។

**បណ្ឌិត ម៉ូរីហ្ស៍ វុន វីស្ស៍**

ប្រធានផ្នែកសេវាសភានៃក្រុមប្រឹក្សាទីក្រុងហ្ស៊ូរិចចាប់ពីឆ្នាំ២០១០ ហើយលោកបណ្ឌិតបានសិក្សាច្បាប់នៅសាកលវិទ្យាល័យហ្ស៊ូរិច ដែលនៅទីនោះលោកបានបម្រើការងារជាជំនួយការសាស្ត្រាចារ្យ មុនពេលចូលបម្រើការងារក្នុងសេវាសភារបស់សភាសហព័ន្ធនៅក្នុងលេខាធិការដ្ឋាននៃគណៈកម្មការរដ្ឋធម្មនុញ្ញ ដែលក្រោយមកនៅក្នុងគណៈកម្មការនយោបាយរដ្ឋ ហើយបន្ទាប់មកទៀតបានទទួលតួនាទីជាអនុប្រធានផ្នែកសេវាច្បាប់។ ចាប់ពីឆ្នាំ២០០៧ ដល់ឆ្នាំ២០១៤ លោកបណ្ឌិតក៏បានបម្រើការងារជាលេខារបស់អង្គការសង្គមស៊ុយអ៊ែតសម្រាប់បញ្ហាសភា (Swiss Society for Parliamentary Issues)។

**ហ្វ្រូរិន ហ្ស៊ីយើស្ស៍**

ទីប្រឹក្សាសម្រាប់ការអភិវឌ្ឍកម្មវិធីសិក្សានិងគរុកោសល្យសម្រាប់វិទ្យាស្ថានសភាកម្ពុជា ជាមួយនឹងសញ្ញាបត្រថ្នាក់អនុបណ្ឌិតជំនាញកិច្ចការអន្តរជាតិ លោកមានបទពិសោធន៍ធ្វើការនៅក្នុងផ្នែកវិទ្យាសាស្ត្រអប់រំនិងផ្តោតលើគោលនយោបាយអប់រំនិងគោលនយោបាយសង្គម។

## ផែនទី

### លោក ញៀប សិលា

អ្នកជំនាញភូគព្ភសាស្ត្រជាមួយនឹងឯកទេសក្នុងផ្នែកពិនិត្យមើលបម្លាស់ប្តូរការប្រើប្រាស់ដី និងគំរូកំណើនទីក្រុង។ លោកបានរៀបចំផែនទីសម្រាប់វិទ្យាស្ថានសភាកម្ពុជា អង្គការសង្គ្រោះសត្វព្រៃកម្ពុជា (Save Cambodia's Wildlife) និងផែនទីអន្តរកម្មសម្រាប់អង្គការទិន្នន័យអំពីការអភិវឌ្ឍ (Open Development Cambodia) សម្រាប់ការប្រើប្រាស់ជាសាធារណៈ។

## អ្នករៀបរៀងនិងសម្របសម្រួល

### អ្នកកែសម្រួលនិងសម្របសម្រួលគម្រោង

### ចេសហ្វ្រី គូល

អ្នកកែសម្រួលនិងសម្របសម្រួល Atlas របស់វិទ្យាស្ថានសភាកម្ពុជា លោកក៏ជួយដឹកនាំកម្មវិធីថ្នាក់តំបន់ស្តីពី ការទូតសភា ក៏ដូចជាការបង្រៀនការសរសេរ និងការផ្តល់ប្រឹក្សាដល់បុគ្គលិកមកពីសភាជាសមាជិកអន្តរសភាអាស៊ាន។

### អ្នកសម្របសម្រួលគម្រោង

### កញ្ញា សាប្រីណា វ៉េលឡែត

ប្រធានគ្រប់គ្រងកម្មវិធីនិវាសនជននៅវិទ្យាស្ថានប្រជាធិបតេយ្យជាតិ (National Democratic Institute) ហើយក៏ជាអតីតអ្នកសម្របសម្រួលផ្នែកទំនាក់ទំនងខាងក្រៅ និងកម្មវិធីតំបន់នៅវិទ្យាស្ថានសភាកម្ពុជា ជាមួយនឹងបទពិសោធន៍ក្នុងផ្នែកអភិបាលកិច្ចប្រជាធិបតេយ្យនិងការផ្តល់អំណាចដល់ស្ត្រី។

### អ្នកកែសម្រួល

### ផេន ចាយល័រ

អ្នកកែសម្រួលប្រកបដោយបទពិសោធន៍ ទីប្រឹក្សាផ្នែកទំនាក់ទំនងនិងការតែងនិពន្ធ និងជាគ្រូបណ្តុះបណ្តាលនៃវិទ្យាស្ថានសភាកម្ពុជា ហើយលោកស្រីមានសញ្ញាបត្រថ្នាក់បណ្ឌិតនិងអនុបណ្ឌិតជំនាញសារព័ត៌មាននិងទំនាក់ទំនងអន្តរជាតិ។

### អ្នករៀបរៀងនិងសម្របសម្រួលការផ្សព្វផ្សាយ

### លោក អែម សូ៉ានី

លោកមានសញ្ញាប័ត្រថ្នាក់អនុបណ្ឌិតផ្នែកទំនាក់ទំនងសម្រាប់ការអភិវឌ្ឍ ពីសាកលវិទ្យាល័យហ្វីលីពីនឡូសបាណូស និងមានបទពិសោធន៍២០ឆ្នាំក្នុងវិស័យទំនាក់ទំនង បោះពុម្ពផ្សាយ និងសម្ភារៈអប់រំឌីជីថល។ បច្ចុប្បន្ន លោកបម្រើការងារជាអ្នកជំនាញការទំនាក់ទំនងសម្រាប់វិទ្យាស្ថានសភាកម្ពុជា ដែលលោកមានឯកទេសផ្នែកទំនាក់ទំនងសភានិងទំនាក់ទំនងសាធារណៈ។

### ការរចនា និងប្លង់ឌីហ្សាញ

រចនាដោយ ក្រុមហ៊ុនក្រាហ្វិករូត (Graphic Roots)
ទូរស័ព្ទលេខ៖ +855 (0) 23 210 712 | (0) 92 979 295
គេហទំព័រ៖ www.graphicroots.net

សៀវភៅឌីជីថល (digital version) ខែធ្នូ ឆ្នាំ២០២០

រក្សាសិទ្ធិ © ២០២០ ដោយវិទ្យាស្ថានសភាកម្ពុជា

សៀវភៅផែនទីស្តីអំពីការទូតសភា

ផ្នែកទី ១៖ ការទូតសភាបែបបុរេសកម្ម

ផ្នែកទី ២៖ ការទូតសភាក្នុងបរិបទអាស៊ាន

ISBN-13: 978-9924-9144-3-3

**បោះពុម្ពផ្សាយដោយ**

វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក)

**អាសយដ្ឋាន**

ការិយាល័យកណ្តាល ផ្ទះលេខ ៣២ ផ្លូវលេខ ៩ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ និង

ការិយាល័យទីពីរ ស្ថិតនៅក្នុងបរិវេណព្រឹទ្ធសភា វិមានរដ្ឋចម្ការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូស័ព្ទលេខ៖ +៨៨៥ (០) ២៣ ២១០ ០៥៥/៦

អ៊ីម៉េល៖ digital.atlas@pic.org.kh | គេហទំព័រ៖ www.pic.org.kh

**គាំទ្រដោយ**

- ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអ៊ែត (Sida)
- ទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍនិងសហប្រតិបត្តិការ (SDC)
- សហភាពអឺរ៉ុប (EU)

**បដិសេធការទទួលខុសត្រូវ**

ទស្សនៈ ទិន្នន័យ និងមតិយោបល់នៅក្នុងសៀវភៅនេះ គឺជាការទទួលខុសត្រូវផ្ទាល់របស់អ្នកនិពន្ធម្នាក់ៗ។ ទស្សនៈនិងការបកស្រាយទាំងនោះមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់វិទ្យាស្ថានសភាកម្ពុជានោះទ។

រាល់ផែនទីទាំងអស់ដែលមាននៅក្នុងសៀវភៅផែនទីស្តីអំពី ការទូតសភានេះ ត្រូវបានប្រើប្រាស់ក្នុងគោលបំណងពិភាក្សាតែប៉ុណ្ណោះ។

ចំណងជើង និងខ្លឹមសារនៅលើផែនទីទាំងនេះ មិនបង្ហាញ អំពីការបញ្ចេញមតិណាមួយរបស់វិទ្យាស្ថានកម្ពុជា ឬរបស់ភាគីណាមួយដែលពាក់ព័ន្ធក្នុងការផលិតសៀវភៅផែនទីនេះ ដែលទាក់ទងនឹងស្ថានភាពច្បាប់នៃប្រទេស ទឹកដី ទីក្រុង ឬតំបន់ណាមួយ ឬសិទ្ធិអំណាច ឬដែលពាក់ព័ន្ធនឹងការកំណត់ព្រំដែនឬខណ្ឌសីមានៃប្រទេស ទឹកដី ទីក្រុង ឬតំបន់នោះឡើយ។

**ការដកស្រង់**

វិទ្យាស្ថានសភាកម្ពុជា (PIC). 2020. ឯកសារអេឡិចត្រូនិកនៃសៀវភៅផែនទីស្តីអំពីការទូតសភា៖
ភាគទី ១៖ ការទូតសភាសភាបែបបុរេសកម្ម ភាគទី ២៖ ការទូតសភាក្នុងបរិបទអាស៊ាន (ភ្នំពេញ PIC)

## សៀវភៅផែនទី ស្តីអំពី

# ការទូតសភា

## ភាគទី ១៖ ការទូតសភាសភាបែបបុរេសកម្ម
## ភាគទី ២៖ ការទូតសភាក្នុងបរិបទអាស៊ាន



ការទូតសភាគឺជា “ព្រំដែនថ្មី” មួយសម្រាប់សភា។ វាសំដៅលើសកម្មភាពការទូតរបស់សន្និបាតសភាទាំងមូល ឬសមាជិកខ្លះនៃសភាក្នុងវិស័យទំនាក់ទំនងអន្តរជាតិ។ វាបំពេញឲ្យការទូតអធិបតេយ្យភាព និងកំពុងក្លាយជាផ្នែកដែលកាន់តែសំខាន់មួយនៃគោលនយោបាយការបរទេស។ សកម្មភាពពហុភាគីគឺជាស្នូលនៃការទូតសភា។ ផ្អែកទៅលើភាពស្របច្បាប់របស់សភា ការទូតសភាខិតខំកាត់បន្ថយឱនភាពប្រជាធិបតេយ្យក្នុងទំនាក់ទំនងអន្តរជាតិ និងនាំមកនូវភាពជាក់ស្តែងដ៏គួរឲ្យស្វាគមន៍មួយសម្រាប់ពិភពលោកថ្មីនៃសកលភាវូបនីយកម្ម ។

សៀវភៅផែនទីនេះ គឺជាឧបករណ៍ពិសេសមួយសម្រាប់ការឈ្វេងយល់អំពីបញ្ហាជាក់ស្តែងក្នុងតំបន់បញ្ហាឆ្លងដែននិងបញ្ហាពិភពលោកដែលសភាជាតិទាំងឡាយត្រូវជំនះជាមួយគ្នា ដើម្បីបង្កើនការយល់ដឹងពីគ្នាទៅវិញទៅមករវាងប្រទេសនានា ដើម្បីឲ្យពួកគេអាចទប់ទល់នឹងបញ្ហាប្រឈមរួមគ្នាបាន។ ផ្នែកទីមួយបង្ហាញពីទស្សនៈផ្ទាល់ខ្លួនជាច្រើនរបស់អ្នកជំនាញនិងពលរដ្ឋមកពីតំបន់អាស៊ីនិងអឺរ៉ុបលើបញ្ហារួមដែលប៉ះពាល់ដល់ប្រជាពលរដ្ឋនិងសភានៃទ្វីបទាំងពីរ។ អ្នកអានអាចសញ្ជឹងគិតដល់ទស្សនៈទាំងនេះ នៅពេលពិភាក្សាអំពី ច្បាប់និងសកម្មភាពរបស់រដ្ឋាភិបាលដែលមានគោលបំណងដោះស្រាយបញ្ហាបន្ទាន់បំផុតនានាក្នុងពេលបច្ចុប្បន្ននេះ។ ផ្នែកទី២ ពិនិត្យមើលឲ្យបានកាន់តែច្បាស់អំពីតួនាទីដែលកំពុងអភិវឌ្ឍ យន្តការ និងបញ្ហានានា ដែលទាក់ទងនឹងសភានិងសមាគមអន្តរសភានានានៅអាស៊ីអាគ្នេយ៍ជាពិសេសក្នុងចំណោមសភាដែលជាសមាជិកអាយប៉ា។




វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

PCAsia
PARLIAMENTARY CENTRE OF ASIA
Strengthening Parliamentary Capacity

Sweden Sverige

Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

Swiss Agency for Development and Cooperation SDC

EUROPEAN UNION


**50**USD


9 789924 914433 >